


# អដ្ឋកថា បដិសម្ភិទាមគ្គ

## ឈ្មោះ សទ្ធម្មប្បកាសិនី

## នៃព្រះសុត្តន្តបិដក ខុទ្ទកនិកាយ

## បឋមភាគ

# ៦៩

“ ភាគ ១ ”

ពុទ្ធសករាជ ២៥៥១

# ពាក្យផ្ដើម

ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖

**សុត្ត** បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។

**គេយ្យ** បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។

**វេយ្យាករណ** គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។

**គាថា** គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។

**ឧទាន** គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។

**ឥតិវុត្តក** គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។

**ជាតក** គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មាន



អបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។

**អព្ភូតធម៌** គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។

**វេទល្ល** គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងរីក-រាយ ព្រមទាំងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្ដែងថា ៖

**ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម**
**ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត**
**មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល**
**បណ្ឌិតគប្បីដឹងបាន ។**

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្ដីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទីកន្លែងផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្ដែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគមាន ៣

ប្រការ គឺ ៖

***១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង*** *ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។*

***២ ទ្រង់សម្តែងធម៌មានហេតុផល*** *ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។*

***៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ*** *គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍ សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។*

*ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ច្វាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះដោយព្រះញាណ ទ្រង់ជ្រាបថាការបានស្តាប់នូវពុទ្ធោវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។*

*ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិ បញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យតាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិ ផ្សេង ៗ គ្នា រហូតមាននិកាយ ដល់ទៅ ១៨ ។*



*ព្រះអដ្ឋកថាចារ្យជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធវចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមកមាន ៖*

***១ ព្រះសូត្រ*** *គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។*

***២ សុត្តានុលោម*** *គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយសេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។*

***៣ អាចរិយវាទ*** *វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។*

***៤ អត្តនោមតិ*** *ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធសាសនា ។*

*ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាមអាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯងដោយច្រើនទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមាន*

គោលសំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថា មិនទាន់បានប្រែ អដ្ឋកថា ចំណែកច្រើននៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិច តួច សំនួនភាសាបាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នក ដែលមិនបានសិក្សាភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹងក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

**សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ**
**របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ**
**សេចក្តីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់**
**ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។**

**ក្រុមរៀបរៀងព្រះអដ្ឋកថា**



## និទានកថា

សេចក្តីសង្ខេបថា ក្នុងទីបំផុតនៃការសម្តែងយមកប្បាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ស្តេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្តែងបករណ៍ធម្មសង្គណីបាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្តែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្លាក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ខ បដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុស-ត្រូវយ៉ាងណា ប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ

គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ឈ្មោះថា កាកណ្ឌកៈបានស្ដាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្លាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គ ក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញាំញីវត្ថុ ១០ ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌-វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មីឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញ



មកពីនិកាយ គោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទកើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺមហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្ដាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តចរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយសង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះកើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើម ក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់និកាយដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។



## តារាងសម្តែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈដែលជាធម្មវាទីទាំងឡាយបានបណ្តេញចេញហើយ បានពួកដទៃទៀត ទើបផ្តើមតាំងជាគណាចារ្យថ្មី ។

( ស្រង់ចេញពីព្រះអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា ព្រះពុទ្ធឃោសាចារ្យ បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនី ថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះពុទ្ធឃោសៈតែងព្រះគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធ-សាសនា បានសិក្សាសិល្ប៍សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។



តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហា ដែលសមណព្រាហ្មណ៍ និងបណ្ឌិត សួរបាន ដូច្នោះ ព្រាហ្មណ៍ កំលោះទើបមានឈ្មោះបោះសំឡេងខ្ចរខ្ចារគ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទីពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេចបដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះបានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាងត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេងៗ ក្នុងគម្ពីរត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយអធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិ-ធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថាពុទ្ធមន្ត ទើបសុំរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុងព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនាបករណ៍ឈ្មោះ ញាណោទ័យទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា

ឈ្មោះអដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈបានឃើញអដ្ឋកថាដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះសារីបុត្ត ( ឈ្មោះដូចអគ្គសាវក ) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីបត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្តី ចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជួសផ្លូវគ្នានៅកណ្តាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា មហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុថៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃ



ក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈនៃសម្នាក់មហាបធាន បានស្តាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិអំពីសង្ឃ ដើម្បីបានឱកាសរចនាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កាដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្តាប់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយបាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញ វេលានោះទើបបានគម្ពីរវិសុទ្ធិមគ្គជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬ

ដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលីទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡៈមកជាភាសាមគធៈ ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្តាប់កិត្តិគុណរបស់លោក ស្តេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃ ហើយនមស្ការព្រះពុទ្ធឃោសៈ និមន្តឲ្យគង់នៅក្នុងប្រាសាទមួយឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡៈ ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធៈ ។

អដ្ឋកថាក្នុងភាសាសីហឡៈពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរីយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនាព្រះមហិន្ទត្ថេរៈនាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡៈ ឈ្មោះ **មហាអដ្ឋកថា** ។



អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡៈហៅថា បច្ចរីយៈ ឈ្មោះថា **បច្ចរីយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទីវេឡុ-វិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទៈដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរៈជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡៈ ដែលព្រះពុទ្ធឃោសៈបានប្រែមកជាអដ្ឋកថាព្រះត្រៃបិដកជាភាសាមគធៈ មានច្រើនជាងពាក់កណ្តាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តប្បាសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា

១៤ ញាណោទ័យ តែងមុនកាលនៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែងចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្ដីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបុរាណាចារ្យយ៉ាងសំខាន់ក្រៃលែងរបស់លោក ។

---



# ប្រវត្តិព្រះធម្មសេនាបតី

ព្រះសារីបុត្តត្ថេរ មុននឹងចូលមកបួសក្នុងព្រះពុទ្ធសាសនា មានឈ្មោះថា ឧបតិស្សៈ ជាបុត្តរបស់ព្រាហ្មណ៍ឈ្មោះ វង្គន្តៈ ដែលជាមេស្រុកក្នុងស្រុកមួយឈ្មោះ ឧបតិស្សគ្រាម ជួនកាលហៅថា “ នាលកៈ ” ឬ “ នាលន្ទា ” តាំងនៅមិនឆ្ងាយពីក្រុងរាជគ្រឹះ , មានមាតាឈ្មោះ សារី ហើយត្រកូលរបស់លោក មានទ្រព្យប្រមាណ ៥៦០ កោដិកហាបណៈ , ព្រះសារីបុត្ត ដែលមានឈ្មោះថា សារីបុត្ត ព្រោះហៅតាមឈ្មោះរបស់មាតា ឬន័យម្យ៉ាងទៀត ពាក្យថា សារីបុត្ត ប្រែថា បុត្ររបស់អ្នកលេងបាស្កា តែកាលលោកឧបសម្បទាហើយ មិត្តសព្រហ្មចារីនិយមហៅលោកថា “ សារីបុត្ត ” ឯឈ្មោះដើម ឧបតិស្សៈ ក៏បាត់ទៅ ។

ព្រះសារីបុត្តមានប្អូនប្រុស ៣ នាក់ គឺ ១. ចុន្ទៈ ២. ឧបសេន ៣ . រេវតៈ និងមានប្អូនស្រី ៣ នាក់ គឺ ១ . ចាលា ២ . ឧបចាលា ៣ . សីសុបចាលា រួមទាំងខ្លួនលោកជា ៧ នាក់ និងសុទ្ធតែជាព្រះអរហន្តបានបរិនិព្វានហើយ ក្នុងសម័យព្រះពុទ្ធបរមគ្រូនៃយើងនេះ ។

កាលលោកនៅជាបរិព្វាជក ជាអ្នកបួសក្រៅព្រះពុទ្ធសាសនា ដើរស្វែងរកមោក្ខធម៌ជាមួយសម្លាញ់ កោលិតៈ “ ព្រះមហាមោគ្គល្លាន ” ក៏

បានជួបនឹងព្រះអស្សជិត្ថេរ និមន្តបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ កាលបានចង្ហាន់ហើយ ក៏ត្រឡប់ដើម្បីរកកន្លែងឆាន់ លុះជ្រាបថា លោកប្រាថ្នានឹងគង់ឆាន់ ក៏ក្រាលអាសនៈរបស់ខ្លួនប្រគេន ក្រោយវេលាដែលព្រះថេរៈឆាន់ហើយ ក៏ប្រគេនទឹកកំសៀវរបស់ខ្លួនទៀត កាលធ្វើអាចរិយវត្តដូច្នេះហើយ ទើបប្រាស្រ័យដោយពាក្យពេចន៍យ៉ាងពីរោះនឹងព្រះអស្សជិត្ថេរ បានសួរថា លោកម្ចាស់ ឥន្ទ្រីយ៍របស់លោកផូរផង់ក្រៃលែង ពណ៌សម្បុរក៏បរិសុទ្ធ លោកតាំងចិត្តបួសចំពោះអ្នកណា អ្នកណាជាសាស្ដារបស់លោក លោកពេញចិត្តក្នុងធម៌របស់អ្នកណា ? ព្រះអស្សជិត្ថេរឆ្លើយថា មានព្រះសមណៈជាបុត្រសក្យរាជ ចេញបួសពីសក្យៈត្រកូល យើងតាំងចិត្តបួសចំពោះព្រះមានព្រះភាគនោះ ព្រះមានព្រះភាគអង្គនោះ ជាសាស្ដារបស់យើង យើងពេញចិត្តក្នុងធម៌របស់ព្រះមានព្រះភាគអង្គនោះ ។

ឧបតិស្សបរិព្វាជក សួរដោយមានការចាប់អារម្មណ៍យ៉ាងខ្លាំងថា សាស្ដារបស់លោកប្រៀនប្រដៅយ៉ាងណា ? , អស្សជិត្ថេរ ពិចារណាថា ជាប្រក្រតី ពួកបរិព្វាជករមែងជាបដិបក្ខចំពោះព្រះពុទ្ធសាសនា យើងនឹងសម្ដែងជម្រៅព្រះពុទ្ធសាសនាដល់បរិព្វាជកនេះ គិតដូច្នេះហើយ ក៏បានប្រកាសខ្លួនថា យើងជាអ្នកបួសថ្មី ទើបនឹងមកកាន់ធម្មវិន័យនេះ យើងមិនអាចសម្ដែងធម៌ឲ្យពិស្ដារបានទេ តែយើងនឹងសម្ដែងបានចំពោះតែខ្លឹមសារ



ប៉ុណ្ណោះ ។ ឧបតិស្សៈគិតថា យើងឈ្មោះថា ឧបតិស្សៈ ជាអ្នកអាចដឹងច្បាស់នូវធម៌តិច ឬច្រើនបានដោយន័យទាំងរយ ទាំងពាន់ គិតដូច្នេះហើយ ទើបពោលថា លោកម្ចាស់សម្ដែងច្រើន ឬតិចក៏ដោយចុះ សូមសម្ដែងតែវត្ថុដែលមានប្រយោជន៍ប៉ុណ្ណោះ ខ្ញុំត្រូវការខ្លឹមសារជាសំខាន់ ការសម្ដែងព្យញ្ជនៈច្រើន ឬពាក្យនិយាយច្រើន មានប្រយោជន៍អ្វីទៅ ។

កាលឧបតិស្សបរិព្វាជកពោលយ៉ាងនេះ ព្រះអស្សជិត្ថេរទើបបានពោលគាថាថា ៖

**យេ ធម្មា ហេតុប្បភវា  តេសំ ហេតុំ តថាគតោ**
**តេសញ្ច យោ និរោធោ ច  ឯវំ វាទីមហាសមណោតិ**

ធម៌ទាំងឡាយកើតអំពីហេតុ ព្រះតថាគតទ្រង់សម្ដែងនូវហេតុនៃធម៌នោះ និងការរលត់នៃធម៌នោះ ព្រះមហាសមណៈទ្រង់ទូន្មានយ៉ាងនេះ ។

ឧបតិស្សៈបានស្ដាប់ធម្មកថានេះ ត្រឹមតែ ២ បាទដំបូង ក៏តាំងនៅក្នុងសោតាបត្តិមគ្គប្រកបដោយពាន់ន័យ លុះបានស្ដាប់ពីរបាទចុងក្រោយក៏បានតាំងនៅក្នុងសោតាបត្តិផល ។ល។

ក្នុងតំណែងជាអគ្គសាវកទី ១ និងជាកំពូលលើសភិក្ខុទាំងឡាយផ្នែកខាងបញ្ញា ព្រះសារីបុត្តបានតាំងសេចក្ដីប្រាថ្នាអស់កាលដ៏យូរប្រមាណ ១ អសង្ខេយ្យនិង ១ សែនកប្ប ក្នុងសម័យព្រះអនោមទស្សីសម្មាសម្ពុទ្ធ

ជាម្ចាស់ បានប្រារព្ធនូវបុណ្យធំមួយកាលដែលលោកនៅជាតាបស ឈ្មោះថា សរទតាបស ដោយឈរបាំងស្វេតឆ័ត្រផ្កាឈើធំថ្វាយចំពោះ ព្រះអនោម-ទស្សីសម្មាសម្ពុទ្ធ ក្នុងពេលព្រះអង្គចូលនិរោធសមាបត្តិរហូត ៧ ថ្ងៃ មិនបរិភោគអាហារអ្វីឡើយ ។

ព្រះសារីបុត្តត្ថេរ ជាអ្នកមានបដិភាណ គឺ បញ្ញា ដោះស្រាយរាល់បញ្ហាចំពោះមុខបានយ៉ាងល្អ និងឆាប់រហ័ស ដែលមានចារឹកទុកក្នុងបាលីគម្ពីរសំយុត្តនិកាយ ខន្ធវគ្គ ក្នុងរឿងសូចិបរិព្វាជិកាសួរអំពីការបរិភោគ ឱនងើយ ងាកឆ្វេង.ស្តាំមើលទៅទិសតូច ទិសធំ ។ល។

ចំណែករឿងទាក់ទងនឹងកតញ្ញូកតវេទី គឺ អ្នកដឹងឧបការគុណដល់អ្នកដទៃធ្វើហើយ មានចារឹកទុកថា ព្រះសារីបុត្តប្រាកដកិត្តិគុណថា ជាអ្នកមានកតញ្ញូកតវេទី រកអ្នកស្មើគ្មាន ដូចមានដំណាលទុកក្នុងអដ្ឋកថាគម្ពីរធម្មបទ នៃព្រាហ្មណវគ្គ បញ្ជាក់ថា ចាប់តាំងពីលោកបានស្តាប់ធម៌អំពីព្រះអស្សជិត្ថេរ បាននូវធម្មចក្ខុ និងបានបួសជាភិក្ខុហើយ លុះបានជ្រាបដំណឹងថា ព្រះអស្សជិត្ថេរជាអាចារ្យនៅក្នុងទិសណា មុននឹងសឹង លោកថ្វាយបង្គំទៅទិសនោះ ហើយសឹងងាកសិរសាទៅទិសនោះ ។ល។

ការរំលត់ខន្ធបរិនិព្វានរបស់ព្រះសារីបុត្ត ការចាត់ចែងពិធីបុណ្យមានទេវតា និងមនុស្សទាំងឡាយរៀបចំឡើងដ៏ធំ មានរឿងដំណាលក្នុង



អដ្ឋកថាសារត្ថប្បកាសិនី ដែលជាគម្ពីរអធិប្បាយបាលីគម្ពីរសំយុត្តនិកាយ មហាវារវគ្គ បញ្ជាក់ថា លុះព្រះសារីបុត្តពោលសុំខមាទោសចំពោះសង្ឃ និងសង្ឃសូមខមាទោសចំពោះលោកហើយ លោកក៏យកចីវរផ្ទាំងធំមកដណ្តប់និងគ្របមុខ ហើយសឹងផ្អៀងទៅខាងស្តាំ និងចូលអនុបុព្វសមាបត្តិ ( ការចូលសមាបត្តិក្នុងធម៌ជាគ្រឿងនៅដោយលំដាប់ ៤ យ៉ាង គឺ រូប- ឈាន ៤ អរូបឈាន ៤ និងសញ្ញាវេទយិតនិរោធ ដូចព្រះមានព្រះភាគ ដោយលោកចូលជាអនុលោម និងបដិលោម ហើយក៏បរិនិព្វាន ដោយ អនុបាទិសេសនិព្វាន ។

ពន្លឺនៃអារុណោទ័យប្រាកដឡើងនៅលើផ្ទៃមេឃ នាថ្ងៃ ១៥ កើត ខែ កត្តិក , ព្រះសារីបុត្តដែលជាធម្មសេនាបតី ក៏បានរំលត់ខន្ធបរិនិព្វានដំណាលគ្នា ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ តថាគតបានប្រាប់អ្នកទាំងឡាយជាមុនហើយមិនមែនឬ ថាការព្រាត់ប្រាសចាកសត្វ និងសង្ខារជាទីស្រឡាញ់ ជាទីពេញចិត្តទាំងអស់ រមែងមានជាធម្មតា តើអ្នកណានឹងបានជាទីពឹងក្នុងរបស់ដែលជាទីស្រឡាញ់ពេញចិត្ត ព្រោះវត្ថុណាកើតឡើងហើយ មានបច្ច័យតាក់តែងហើយ មានការបែកធ្លាយជាធម្មតា ការប្រាថ្នាថា សូមវត្ថុទាំងនោះកុំបែកធ្លាយទៅឡើយ មិនជាឋានៈដែលអាចប្រព្រឹត្តទៅបានឡើយ យ៉ាងណាមិញ សារីបុត្តដែលដូចជាដើមឈើធំ ជា

ទីពឹងពំនាក់របស់ភិក្ខុសង្ឃជាច្រើន ក៏ត្រូវបរិនិព្វាន ។ ព្រោះដូច្នោះឯង អានន្ទ អ្នកទាំងឡាយចូរមានខ្លួនជាកោះ មានខ្លួនជាទីពឹង មិនគប្បីមានវត្ថុដទៃជាទីពឹងឡើយ គឺ ចូរមានធម៌ជាកោះ មានធម៌ជាទីពឹង មិនគប្បីមានវត្ថុដទៃជាទីពឹងឡើយ ម្នាលអានន្ទ យ៉ាងណាហៅថា ភិក្ខុមានខ្លួនជាកោះ មានខ្លួនជាទីពឹង ? យ៉ាងនេះគឺ ភិក្ខុក្នុងធម្មវិន័យនេះ រមែងជាអ្នកឃើញកាយក្នុងកាយ ឃើញវេទនាក្នុងវេទនា ឃើញចិត្តក្នុងចិត្ត ឃើញធម៌ក្នុងធម៌ទាំងឡាយ ជាអ្នកប្រារព្ធសេចក្ដីព្យាយាម មានសតិ មានសម្បជញ្ញៈ កម្ចាត់បង់នូវអភិជ្ឈា និងទោមនស្សក្នុងលោកចេញបាន ម្នាលអានន្ទ នេះឯងហៅថា ភិក្ខុមានខ្លួនជាកោះ មានខ្លួនជាទីពឹង មិនមែនមានវត្ថុដទៃជា កោះ មិនមែនមានវត្ថុដទៃជាទីពឹងឡើយ ។ល។

ម្នាលភិក្ខុទាំងឡាយ សារីបុត្តនោះ បានបំពេញបារមីអស់មួយអសង្ខេយ្យ និងមួយសែនកប្ប បានប្រកាសធម្មចក្រឲ្យប្រព្រឹត្តទៅដូចជាតថាគត សារីបុត្តនោះ បានជាអ្នកប្រៀនប្រដៅសាសនាចាត់ជាទី ២ បន្ទាប់ពីតថាគត សារីបុត្តនោះ ក្នុងបណ្ដាសាវកសន្និបាត វៀរតែតថាគតចេញហើយ គ្មាននរណាផ្ទឹមឡើយដោយបញ្ញាក្នុងម៉ឺនចក្រវាឡ សារីបុត្តជាអ្នកមានបញ្ញាច្រើន មានបញ្ញាក្រាស់ មានបញ្ញាទូលំទូលាយ មានបញ្ញារហ័ស មានបញ្ញាមុតស្រួច មានបញ្ញាជាគ្រឿងកម្ចាត់កិលេស ។



សារីបុត្តជាអ្នកមានសេចក្ដីប្រាថ្នាតិច មានសេចក្ដីសន្ដោស ពេញចិត្តនឹងទីស្ងប់ស្ងាត់ មិនច្រឡូកច្រឡំដោយពួកគណៈ ប្រារព្ធសេចក្ដីព្យាយាម ជាអ្នកចូលចិត្តដាស់តឿនអ្នកដទៃ ជាអ្នកតិះដៀលអំពើអាក្រក់ ភិក្ខុរូបនោះជាអ្នកមានខន្តីធម៌ជានិច្ច ដូចជាផែនដី សារីបុត្តប្រព្រឹត្តខ្លួនដូចជាគោឧសភរាជបាក់ស្នែង ប្រព្រឹត្តខ្លួនមានចិត្តទាបដូចកូនរបស់មនុស្សអ្នកស្រុកចណ្ឌាល អ្នកទាំងឡាយចូរមើលអដ្ឋិធាតុទាំងឡាយរបស់ភិក្ខុដែលមានបញ្ញាច្រើន ។ល។ មានបញ្ញាជាគ្រឿងកម្ចាត់កិលេសបាន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់សរសើរគុណរបស់ព្រះសារីបុត្ត ដោយព្រះគាថា ៥០០ គាថា ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ទទួលអដ្ឋិធាតុរបស់ព្រះសារីបុត្តត្ថេរទុកហើយ ទើបប្រោសឲ្យសាងស្តូបបញ្ចុះអដ្ឋិធាតុរបស់លោកទុកក្នុងទីជិតទ្វារវត្តជេតពនមហាវិហារ ក្រុងសាវត្ថី ដើម្បីបានជា “ **អគ្គសាវកានុស្សរណដ្ឋាន** ” ជាការលើកឡើងនូវកិត្តិគុណរបស់ព្រះធម្មសេនាបតីសារីបុត្ត និងដើម្បីជាទីសក្ការបូជារបស់ពុទ្ធបរិស័ទតទៅក្នុងអនាគតកាល ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក នាក់ ម៉ៅ |
| ឧបាសក ទុំ ទូន | ឧបាសក ហុក សឹងហួត |
| ឧបាសក ជឹម ជំនិត | ឧបាសក កើត ទិត្យ |
| ឧបាសក សន ម៉ារឌី | ឧបាសក ហាយ ចំរើន |
| ឧបាសក អ៊ឹម រ៉ៃយ៉ា | ឧបាសក សុក្រ ហ៊ត |
| ឧបាសក សំ ឆាយ | ឧបាសិកា ថាប់ លឿម |
| ឧបាសិកា ហាយ សារ៉ាត់ | ឧបាសិកា ប៊ុត សុម៉ាលី |
| ឧបាសិកា យស សម្បត្តិ | ឧបាសិកា ពូ ហ៊ាង |

**ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស**



# រាយនាមអ្នកប្រែសម្រួល

**ព្រះសង្ឃអាស្រមព្រះគន្ធកុដិ**

| | |
|---|---|
| ព្រះភិក្ខុអគ្គទិន្នោ នូវ ប៊ូរ៉ា | ចៅអាវាស |
| ព្រះភិក្ខុឌាហមុត្តោ ប៊ូច សុផល | ធម្មាចារ្យ |
| ព្រះភិក្ខុធម្មប្បញ្ញោ ឆុំ សារឿន | ធម្មាចារ្យ |
| ព្រះភិក្ខុចន្ទរក្ខិតោ ម៉ឺន សុច័ន្ទ | ធម្មាចារ្យ |
| ព្រះភិក្ខុវរធម្មោ ផុត តៅ | ធម្មាចារ្យ |
| ព្រះភិក្ខុសរញ្ញាណោ ស សត្ថា | ធម្មាចារ្យ |

ព្រះភិក្ខុកល្យាណធម្មោ យ៉ាត កល្យាណ ធម្មាចារ្យ

សាមណេរ អ៊ឹម សុជាន សាមណេរ ម៉ៅ អៀប

សាមណេរ រិន សុវ៉ាន

**ផ្នែកឧបាសក**

| | |
|---|---|
| ឧបាសក ក្អាត ហ៊ន | ឧបាសក ហាយ ចំរើន |
| ឧបាសក សន ម៉ារឌី | ឧបាសក អ៊ឹម រ៉ៃយ៉ា |
| ឧបាសក ទុំ ទូន | ឧបាសក ហុក សឹងហួត |

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.000 ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

**ឧទ្ទិសថ្វាយ និងគោរពជូន :**

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្ត្រីរាជការ និងប្រជានុរាស្ត្រនៃកម្ពុជារដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

**ក្រុមរៀបរៀង និងប្រែសម្រួល**



# មាតិកាធម៌

| ឈ្មោះធម៌ | ទំព័រ |
| --- | --- |
| មាតិកា ពោលដោយញាណ ៧៣ | ១ |
| គន្ថារម្ភកថា | ៨ |
| ពោលអំពី សុតមយញ្ញាណ | ៣៨ |
| ពោលអំពី សីលមយញ្ញាណ | ៤៥ |
| ពោលអំពី សមាធិភាវនាមយញ្ញាណ | ៥២ |
| ពោលអំពី ធម្មដ្ឋិតិញ្ញាណ | ៥៤ |
| ពោលអំពី សម្មសនញ្ញាណ | ៦០ |
| ពោលអំពី ឧទយព្វយញ្ញាណ | ៦២ |
| ពោលអំពី វិបស្សនាញាណ | ៦៤ |
| ពោលអំពី អាទីនវញ្ញាណ | ៦៦ |
| ពោលអំពី សង្ខារុបេក្ខាញាណ | ៧២ |
| ពោលអំពី អនុលោមញ្ញាណ | ៨០ |
| ពោលអំពី គោត្រភូញាណ | ៨២ |
| ពោលអំពី មគ្គញ្ញាណ | ៨៤ |
| ពោលអំពី ផលញ្ញាណ | ៨៩ |
| ពោលអំពី វិមុត្តិញ្ញាណ | ៩១ |
| ពោលអំពី បច្ចវេក្ខណញ្ញាណ | ៩៣ |
| ពោលអំពី វត្ថុនានត្តញ្ញាណ | ១០២ |
| ពោលអំពី គោចរនានត្តញ្ញាណ | ១០៥ |
| ពោលអំពី ចរិយានានត្តញ្ញាណ | ១០៥ |

ពោលអំពី ភូមិនានត្តញ្ញាណ ១០៦

ពោលអំពី ធម្មនានត្តញ្ញាណ ១០៧

ពោលអំពី ញាតដ្ឋញ្ញាណ ១០៨

ពោលអំពី តីរណដ្ឋញ្ញាណ ១១១

ពោលអំពី បរិច្ចាគដ្ឋញ្ញាណ ១១២

ពោលអំពី ឯករសដ្ឋញ្ញាណ ១១៣

ពោលអំពី ផស្សនដ្ឋញ្ញាណ ១១៣

ពោលអំពី បដិសម្ភិទាញាណ ១១៤

ពោលអំពី វិហារដ្ឋ.....សមាបត្តិញ្ញាណ ១១៥

ពោលអំពី អនន្តរិកសមាធិញ្ញាណ ១១៧

ពោលអំពី អរណវិហារញ្ញាណ ១២១

ពោលអំពី និរោធសមាបត្តិញ្ញាណ ១៣១

ពោលអំពី បរិនិព្វានញ្ញាណ ១៣៤

ពោលអំពី សមសីសដ្ឋញ្ញាណ ១៣៥

ពោលអំពី សល្លេខដ្ឋញ្ញាណ ១៤០

ពោលអំពី វីរិយារម្ភញ្ញាណ ១៤៣

ពោលអំពី អត្ថសទ្ទសនញ្ញាណ ១៤៩

ពោលអំពី ទស្សនវិសុទ្ធិញ្ញាណ ១៥០

ពោលអំពី ខន្តិញ្ញាណ ១៥៤

ពោលអំពី បរិយោគាហណញ្ញាណ ១៥៥

ពោលអំពី បទេសវិហារញ្ញាណ ១៥៦

ពោលអំពី សញ្ញាវិវដ្តញ្ញាណ ១៥៩

ពោលអំពី ចេតោវិវដ្តញ្ញាណ ១៦១





ពោលអំពី ចិត្តវិវដ្តញ្ញាណ ១៦៣

ពោលអំពី ញាណវិវដ្តញ្ញាណ ១៦៤

ពោលអំពី វិមោក្ខវិវដ្តញ្ញាណ ១៦៤

ពោលអំពី សច្ចវិវដ្តញ្ញាណ ១៦៥

ពោលអំពី ឥទ្ធិវិធិញ្ញាណុទ្ទេស ១៦៧

ពោលអំពី សោតធាតុវិសុទ្ធិញ្ញាណុទ្ទេស ១៧២

ពោលអំពី ចេតោបរិយញ្ញាណុទ្ទេស ១៧៤

ពោលអំពី បុព្វេនិវាសានុសតិញ្ញាណុទ្ទេស ១៧៧

ពោលអំពី ទិព្វចក្ខុញ្ញាណុទ្ទេស ១៧៩

ពោលអំពី អាសវក្ខយញ្ញាណុទ្ទេស ១៨១

ពោលអំពី ទុក្ខសមុទយនិរោធមគ្គញ្ញាណុទ្ទេស ១៨២

ពោលអំពី ទុក្ខទុក្ខសមុទយសច្ចទុក្ខនិរោធ-
ទុក្ខនិរោធគាមិនីបដិបទាញាណុទ្ទេស ១៨៥

ពោលអំពី បដិសម្ភិទាធម្មប្បដិសម្ភិទានិ-
រុត្តិប្បដិសម្ភិទាបដិភាណប្បដិសម្ភិទាញាណុទ្ទេស ១៨៨

ពោលអំពី ឥន្ទ្រិយបរោយត្តញ្ញាណុទ្ទេស ១៩០

ពោលអំពី អាសយានុសយញ្ញាណុទ្ទេស ១៩៤

ពោលអំពី យមកប្បាដិហីរញ្ញាណុទ្ទេស ១៩៦

ពោលអំពី មហាករុណាសមាបត្តិញ្ញាណុទ្ទេស ១៩៧

ពោលអំពី សព្វញ្ញុតញ្ញាណអនាវរណញ្ញាណុទ្ទេស ១៩៨


**អដ្ឋកថាវិសជ្ជនុទ្ទេស**


សុតមយញ្ញាណកថា ២០៣

អដ្ឋកថា អភិញ្ញេយ្យនិទ្ទេស ២១៧

អដ្ឋកថា ឯកនិទ្ទេស ( អំពីអាហារ ) ២១៧
អដ្ឋកថា ទុកនិទ្ទេស ( អំពីធាតុ ២ ) ២២៦
អដ្ឋកថា តិកនិទ្ទេស ( អំពីធាតុ ៣ ) ២២៧
អដ្ឋកថា ចតុកនិទ្ទេស ( អំពីអរិយសច្ច ៤ ) ២៣០
អដ្ឋកថា បញ្ចកនិទ្ទេស ( វិមុត្តាយតនៈ ៥ ) ២៣១
អដ្ឋកថា ឆកនិទ្ទេស ( អនុត្តរិយៈ ៦ ) ២៣៥
អដ្ឋកថា សត្តកនិទ្ទេស ( និទ្ទស ) ២៤៤
អដ្ឋកថា អដ្ឋកនិទ្ទេស ( អភិភាយតនៈ ៨ ) ២៤៧
អដ្ឋកថា នវកនិទ្ទេស ( អនុបព្វវិហារធម៌ ) ២៥១
អដ្ឋកថា ទសកនិទ្ទេស ២៥៣
អដ្ឋកថា ចក្ខុនិទ្ទេស ២៥៨
ខន្ធ ៥ ២៦៦
ធម៌ពួក ៦ ២៦៧
ធាតុ ៦ ២៦៨
កសិណ ១០ ២៦៩
អាការ ៣២ ២៧០
អាយតនៈ ១២ ២៧៨
ធាតុ ១៨ ២៨២
ឥន្ទ្រីយ៍ ២២ ២៨៥
ធាតុ ៣ ភព ៣ វេការ ៣ ២៩៦
ឈាន ២៩៤
បច្ចយាការ ១២ ៣០១
អដ្ឋកថា ទុក្ខសច្ចជាដើម ៣០៤





អដ្ឋកថា ទុតិយភាណវារៈ ៣១៧
អដ្ឋកថា បរិញ្ញេយ្យនិទ្ទេស ( តតិយភាណវារៈ ) ៣៧១
ពោលអំពី បហាតព្វនិទ្ទេស ៣៨៩
ពោលអំពី ទុក្ខសច្ចជាដើម ៤០៦
ពោលអំពី ភាវេតព្វនិទ្ទេស ៤១២
ពោលអំពី បឋមភាវនា ៤៣៤
ពោលអំពី ទុតិយភាវនា ៤៣៥
ពោលអំពី តតិយភាវនា ៤៣៨
ពោលអំពី សច្ឆិកតព្វនិទ្ទេស ៤៤៧
ពោលអំពី ហានភាគិយចតុកនិទ្ទេស ៤៦០
ពោលអំពី លក្ខណត្តិកនិទ្ទេស ៤៦៦
ពោលអំពី ទុក្ខសច្ចនិទ្ទេស ៤៦៨
ពោលអំពី សមុទយសច្ចនិទ្ទេស ៥១៤
ពោលអំពី និរោធសច្ចនិទ្ទេស ៥១៩
ពោលអំពី មគ្គសច្ចនិទ្ទេស ៥២៧
ពោលអំពី សម្មាទិដ្ឋិនិទ្ទេស ៥២៩
ពោលអំពី សម្មាសង្កប្បនិទ្ទេស ៥៣៨
ពោលអំពី សម្មាវាចានិទ្ទេស ៥៤១
ពោលអំពី សម្មាកម្មន្តនិទ្ទេស ៥៤២
ពោលអំពី សម្មាអាជីវនិទ្ទេស ៥៤២
ពោលអំពី សម្មាវាយាមនិទ្ទេស ៥៤៣
ពោលអំពី សម្មាសតិនិទ្ទេស ៥៦០
ពោលអំពី សម្មាសមាធិនិទ្ទេស ៥៧៦

| | |
|---|---|
| អធិប្បាយ វិតក្កវិចារៈ | ៥៨៤ |
| អធិប្បាយ បីតិសុខៈ | ៥៨៦ |
| អធិប្បាយ ឈាន ២ យ៉ាង | ៥៩០ |
| អធិប្បាយ ឧបេក្ខា | ៥៩៨ |
| អដ្ឋកថា សច្ចបកិណ្ណក | ៦២៨ |
| អដ្ឋកថា សីលមយញ្ញាណ | ៦៤២ |
| អធិប្បាយ បាណាតិបាត | ៦៩៨ |
| អធិប្បាយ អទិន្នាទាន | ៧០០ |
| អធិប្បាយ កាមេសុមិច្ឆាចារ | ៧០១ |
| អធិប្បាយ មុសា | ៧០២ |
| អធិប្បាយ បិសុណាវាទ | ៧០៥ |
| អធិប្បាយ ផរុសវាទ | ៧០៦ |
| អធិប្បាយ សម្ផប្បលាបៈ | ៧០៧ |
| អធិប្បាយ អភិជ្ឈា , ព្យាបាទៈ | ៧០៨ |
| អធិប្បាយ មិច្ឆាទិដ្ឋិ | ៧១០ |
| អធិប្បាយ កុសលកម្មបថ | ៧១៦ |
| អធិប្បាយ សីលមយញ្ញាណនិទ្ទេសបន្ថែម | ៧២០ |
| ប្រជុំកងធម៌ | ៧៣៣ |




**បោត្ថកេសុ ច យំ សិប្បំ បរហត្ថេសុ យំ ធនំ**
**យថា កិច្ចេ សមុប្បន្នេ ន តំ សិប្បំ ន តំ ធនំ**

វិជ្ជាផ្សេង ៗ ដែលនៅតែក្នុងគម្ពីរ ទ្រព្យដែលនៅក្នុងដៃអ្នកដទៃ កាលបើមានកិច្ចចាំបាច់កើតឡើង វិជ្ជានោះ ៗ ក៏មិនបានដឹងដល់យើង ទ្រព្យនោះ ៗ ក៏ប្រើប្រាស់ជារបស់យើងមិនបាន ។

# បដិសម្ភិទាមគ្គ

## នៃព្រះសុត្តន្តបិដក ខុទ្ទកនិកាយ

## បឋមភាគ ( ភាគ ១ )

## សូមនមស្ការ

## ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ អង្គនោះ

## មាតិកា

ពោលដោយញាណ ៧៣

១. បញ្ញា ( ការដឹងច្បាស ) ក្នុងការប្រុងត្រចៀក ឈ្មោះថា សុតមយញ្ញាណ ។

២. បញ្ញាក្នុងការស្តាប់ហើយសង្រួម ឈ្មោះថា សីលមយញ្ញាណ ។

៣ បញ្ញាក្នុងការសង្រួមហើយតំកល់ទុក ឈ្មោះថា សមាធិភាវនាមយញ្ញាណ ។

៤. បញ្ញាក្នុងការកំណត់នូវបច្ច័យ ឈ្មោះថា ធម្មដ្ឋិតិញ្ញាណ ។

៥. បញ្ញាក្នុងការសង្ខេបនូវពួកធម៌ជាអតីត អនាគត និងបច្ចុប្បន្នហើយកំណត់ទុក ឈ្មោះថា សម្មសនញ្ញាណ ។

៦. បញ្ញាក្នុងការឃើញ នូវការប្រែប្រួល នៃពួកធម៌ជាបច្ចុប្បន្ន ឈ្មោះថា



ឧទយព្វយានុបស្សនាញាណ ។

៧. បញ្ញាក្នុងការឃើញនូវអារម្មណ៍ថា បែកធ្លាយ ឈ្មោះថា វិបស្សនាញាណ ។

៨. បញ្ញាក្នុងការប្រាកដឡើងថា ជាភ័យ ឈ្មោះថា អាទីនវញ្ញាណ ។

៩. បញ្ញា គឺ សេចក្តីប្រាថ្នាដើម្បីរួច ឬការព្រងើយកន្តើយ ឈ្មោះថា សង្ខារុបេក្ខាញាណ ។

១០. បញ្ញាក្នុងការចេញ និង ការវិលត្រឡប់ចាកសង្ខារនិមិត្តខាងក្រៅ ឈ្មោះថា គោត្រភូញាណ ។

១១. បញ្ញាក្នុងការចេញ និងការវិលត្រឡប់ចាកសភាវៈទាំងពីរ ឈ្មោះថា មគ្គញ្ញាណ ។

១២. បញ្ញាដែលសម្រាប់រម្ងាប់នូវការព្យាយាម ឈ្មោះថា ផលញ្ញាណ ។

១៣. បញ្ញាក្នុងការឃើញនូវកិលេសដែលដាច់ ឈ្មោះថា វិមុត្តិញ្ញាណ ។

១៤. បញ្ញាក្នុងការឃើញនូវធម៌ ដែលតាំងឡើង ក្នុងខណៈមគ្គ ផលនោះ ឈ្មោះថា បច្ចវេក្ខណញ្ញាណ ។

១៥. បញ្ញាក្នុងការកំណត់ នូវអាយតនៈខាងក្នុង ឈ្មោះថា វត្ថុនានត្តញ្ញាណ ។

១៦. បញ្ញាក្នុងការកំណត់ នូវអារម្មណ៍ខាងក្រៅ ឈ្មោះថាគោចរនានត្ត-

ញ្ញាណ ។

១៧. បញ្ញាក្នុងការកំណត់នូវការត្រាច់ទៅ ( នៃវិញ្ញាណ ) ឈ្មោះថា ចរិ-យានានត្តញ្ញាណ ។

១៨. បញ្ញាក្នុងការកំណត់ធម៌ ៤ ឈ្មោះថា ភូមិនានត្តញ្ញាណ ។

១៩. បញ្ញាក្នុងការកំណត់ធម៌ ៩ ឈ្មោះថា ធម្មនានត្តញ្ញាណ ។

២០. បញ្ញាដែលជាគ្រឿងដឹងដ៏ប្រសើរ ឈ្មោះថា ញាតដ្ឋញ្ញាណ ។

២១. បញ្ញាជាគ្រឿងដឹងជ្រួតជ្រាប ឈ្មោះថា តីរណដ្ឋញ្ញាណ ។

២២. បញ្ញាជាគ្រឿងលះ ឈ្មោះថា បរិច្ចាគដ្ឋញ្ញាណ ។

២៣. បញ្ញាជាគ្រឿងអប់រំ ឈ្មោះថា ឯករសដ្ឋញ្ញាណ ។

២៤. បញ្ញាគ្រឿងធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា ផស្សនដ្ឋញ្ញាណ ។

២៥. បញ្ញាក្នុងអត្ថផ្សេង ៗ ឈ្មោះថា អត្ថប្បដិសម្ភិទាញាណ ។

២៦. បញ្ញាក្នុងធម៌ផ្សេង ៗ ឈ្មោះថា ធម្មប្បដិសម្ភិទាញាណ ។

២៧. បញ្ញាក្នុងនិរុត្តិផ្សេង ៗ ឈ្មោះថា និរុត្តិប្បដិសម្ភិទាញាណ ។

២៨.បញ្ញាក្នុងបដិភាណផ្សេង ៗ ឈ្មោះថា បដិភាណប្បដិសម្ភិទាញាណ ។

២៩. បញ្ញាក្នុងវិបស្សនាវិហារផ្សេង ៗ ឈ្មោះថា វិហារដ្ឋញ្ញាណ ។

៣០. បញ្ញាក្នុងផលសមាបត្តិផ្សេង ៗ ឈ្មោះថា សមាបត្តដ្ឋញ្ញាណ ។

៣១. បញ្ញាក្នុងវិហារសមាបត្តិផ្សេង ៗ ឈ្មោះថា វិហារសមាបត្តដ្ឋញ្ញាណ ។



៣២. បញ្ញាក្នុងការផ្តាច់បង់នូវអាសវៈ ព្រោះសេចក្តីបរិសុទ្ធិ ដោយសេចក្តីមិនរាយមាយ ឈ្មោះថា អានន្តរិកសមាធិញ្ញាណ ។

៣៣. បញ្ញា គឺ ទស្សនាធិបតេយ្យផង ការបាននូវវិហារដ៏ស្ងប់ផងសេចក្តីចុះចិត្តស៊ប់ក្នុងធម៌ដ៏ឧត្តមផង ឈ្មោះថា អរណវិហារញ្ញាណ ។

៣៤. បញ្ញា ដែលមានការស្ទាត់ជំនាញ ព្រោះហេតុប្រកបដោយសមថៈនិងវិបស្សនាទាំង ២ ផង ព្រោះការរម្ងាប់នូវសង្ខារទាំង ៣ ផង ព្រោះញាណចរិយា ១៦ ផង ព្រោះសមាធិចរិយា ៩ ផង ឈ្មោះថា និរោធសមាបត្តិញ្ញាណ ។

៣៥.បញ្ញាដឹងក្នុងការអស់ទៅ ( នៃកិលេសនិងខន្ធ ) របស់បុគ្គលអ្នកដឹងខ្លួនឈ្មោះថា បរិនិព្វានញ្ញាណ ។

៣៦. បញ្ញា ដែលមិនប្រាកដ ក្នុងការកាត់ផ្តាច់ផ្តិលដោយប្រពៃនូវធម៌ទាំងពួងផង ក្នុងការរំលត់ផង ឈ្មោះថា សមសីសដ្ឋញ្ញាណ ។

៣៧. បញ្ញាក្នុងការរំលត់នូវភ្លើងដ៏ក្រាស់មានភាពផ្សេង ៗ និងមានភាពតែមួយឈ្មោះ ថា សល្លេខដ្ឋញ្ញាណ ។

៣៨. បញ្ញា ក្នុងការផ្គងរបស់បុគ្គលមានចិត្តមិនរួញរា និងបុគ្គលមានខ្លួនបញ្ជូនទៅហើយ ឈ្មោះថា វិរិយារម្ភញ្ញាណ ។

៣៩.បញ្ញា គឺការប្រកាសនូវធម៌ផ្សេង ៗ ឈ្មោះថា អត្ថសន្ទស្សនញ្ញាណ ។

៤០. បញ្ញា ក្នុងការត្រាស់ដឹងនូវការសង្គ្រោះធម៌ទាំងពួង ឲ្យមានតែមួយ និងកិលេសមានភាពផ្សេង ៗ ទាំងគុណធម៌មានសភាពតែមួយឈ្មោះថា ទស្សនវិសុទ្ធិញ្ញាណ ។

៤១. បញ្ញាព្រោះការដឹង ឈ្មោះថា ខន្តិញ្ញាណ ។

៤២. បញ្ញាព្រោះការពាល់ត្រូវ ឈ្មោះថា បរិយោគាហនញ្ញាណ ។

៤៣. បញ្ញាក្នុងការប្រមូល ឈ្មោះថា បទេសវិហារញ្ញាណ ។

៤៤. បញ្ញាព្រោះភាពជាអធិបតី ឈ្មោះថា សញ្ញាវិវដ្តញ្ញាណ ។

៤៥. បញ្ញាក្នុងភាពផ្សេង ៗ ឈ្មោះថា ចេតោវិវដ្តញ្ញាណ ។

៤៦. បញ្ញាក្នុងការអធិដ្ឋាន ឈ្មោះថា ចិត្តវិវដ្តញ្ញាណ ។

៤៧. បញ្ញាក្នុងសភាវសូន្យ ឈ្មោះថា ញាណវិវដ្តញ្ញាណ ។

៤៨. បញ្ញាក្នុងការលះបង់ ឈ្មោះថា វិមោក្ខវិវដ្តញ្ញាណ ។

៤៩. បញ្ញាក្នុងសេចក្តីពិត ឈ្មោះថា សច្ចវិវដ្តញ្ញាណ ។

៥០. បញ្ញាក្នុងអត្ថថា សម្រេចដោយអំណាចនៃការអធិដ្ឋាន នូវសុខសញ្ញា និងលហុសញ្ញា ព្រោះកំណត់នូវកាយ និងចិត្តថា តែមួយ ឈ្មោះថា ឥទ្ធិវិធញ្ញាណ ។

៥១.បញ្ញាក្នុងការស្ទង់នូវសទ្ទនិមិត្តមានភាពផ្សេង ៗ ទាំងមានភាពតែមួយ ដោយអំណាចផ្សាយទៅនៃវិតក្កៈ ឈ្មោះថា សោតធាតុវិសុទ្ធិញ្ញាណ ។



៥២. បញ្ញាក្នុងការស្ទាបស្ទង់នៃការគ្រាច់ទៅនៃវិញ្ញាណ ដែលមានសភាពផ្សេង ៗ ទាំងមានសភាពតែមួយ ដោយអំណាចនៃបសាទរបស់ឥន្ទ្រីយ៍ទាំងឡាយ ព្រោះផ្សាយទៅនៃចិត្ត ទាំង ៣ ឈ្មោះថា ចេតោ-បរិយញ្ញាណ ។

៥៣. បញ្ញាក្នុងការស្ទង់នូវពួកធម៌ដែលប្រព្រឹត្តទៅបាន ព្រោះបច្ច័យដោយអំណាចនៃកិរិយាផ្សាយទៅនៃកម្ម ដែលមានសភាពផ្សេង ៗ គ្នា ទាំងមានសភាពតែមួយ ឈ្មោះថា បុព្វេនិវាសានុស្សតិញ្ញាណ ។

៥៤. បញ្ញាក្នុងអត្ថថា ឃើញនូវរូបនិមិត្ត មានសភាវៈផ្សេង ៗ ទាំងមានសភាពតែមួយដោយអំណាចនៃពន្លឺ ឈ្មោះថា ទិព្វចក្ខុញ្ញាណ ។

៥៥. បញ្ញាដែលស្ទាត់ជំនាញនៃឥន្ទ្រីយ៍ ៣ ដោយអាការ ៦៤ ឈ្មោះថា អាសវក្ខយញ្ញាណ ។

៥៦. បញ្ញាក្នុងអត្ថថា កំណត់ដឹង ឈ្មោះថា ទុក្ខញ្ញាណ ។

៥៧. បញ្ញាក្នុងអត្ថថា លះ ឈ្មោះថា សមុទយញ្ញាណ ។

៥៨. បញ្ញាក្នុងអត្ថថា ធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា និរោធញ្ញាណ ។

៥៩. បញ្ញាក្នុងអត្ថថា ចម្រើន ឈ្មោះថា មគ្គញ្ញាណ ។

៦០. ទុក្ខញ្ញាណ ។

៦១. ទុក្ខសមុទយញ្ញាណ ។

៦២. ទុក្ខនិរោធញ្ញាណ ។

៦៣. ទុក្ខនិរោធគាមិនីបដិបទាញ្ញាណ ។

៦៤. អត្ថប្បដិសម្ភិទាញ្ញាណ ។

៦៥. ធម្មប្បដិសម្ភិទាញ្ញាណ ។

៦៦. និរុត្តិប្បដិសម្ភិទាញ្ញាណ ។

៦៧. បដិភាណប្បដិសម្ភិទាញ្ញាណ ។

៦៨. ឥន្ទ្រិយបរោបរិយត្តញ្ញាណ ។

៦៩. សត្តសយានុសយញ្ញាណ ។

៧០. យមកប្បាដិហិរញ្ញាណ ។

៧១. មហាករុណាសមាបត្តិញ្ញាណ ។

៧២. សព្វញ្ញុតញ្ញាណ ។

៧៣. អនាវរណញ្ញាណ ។

នេះញាណ ៧៣ បណ្តាញាណ ៧៣ នេះ ញាណ ៦៧ ជាសាធារណៈដល់ពួកសាវ័ក , ញាណ ៦ មិនសាធារណៈដល់ពួក សាវ័ក ។

**( ចប់មាតិកា )**



# អ ដ្ឋ ក ថា

# បដិសម្ភិទាមគ្គ

# ឈ្មោះសទ្ធម្មប្បកាសិនី ក្នុងខុទ្ទកនិកាយ

# ភាគទី ១

## គន្ថារម្ភកថា

ព្រះមានព្រះភាគជាម្ចាស់ព្រះអង្គណា ទ្រទ្រង់ព្រះគុណគ្រប់សព្វហើយ ដោយសេចក្តីល្អគ្រប់យ៉ាង កន្ទុងនូវសេចក្តីល្អរបស់ លោកទាំងពួង ទ្រង់ផុតអំពីមន្ទិលកិលេសដែលជាគ្រឿងប្រទូសរ៉ាយ ព្រមទាំងវាសនា ទ្រង់ប្រទានវិមុត្តិធម៌ដ៏ឧត្តុង្គឧត្តម ។

ព្រះអង្គទ្រង់មានព្រះទ័យត្រជាក់ ដូចជាភាពត្រជាក់នៃខ្ទឹមច័ន្ទន៍ ពោលគឺ ព្រះករុណាជានិច្ច ទ្រង់មានព្រះបញ្ញាភ្លឺស្វាងដូចរស្មីព្រះអាទិត្យ មានធម៌ជាគ្រឿងដឹកនាំសត្វ ខ្ញុំម្ចាស់សូមក្រាបថ្វាយ បង្គំព្រះមានព្រះភាគជាម្ចាស់អង្គនោះ ដែលជាបុគ្គលដ៏ឧត្តមប្រសើរលើសក្នុងពពួកសត្វ ដែលជាទីពឹងក្នុងប្រយោជន៍

ដល់សត្វទាំងពួង ដោយសិរសា ។

បណ្ដាព្រះមហាថេរៈជាពុទ្ធជិនោរស មានចំនួនជាអនន្ត ព្រះមហាថេរៈអង្គណា ដែលប្រដូចនឹងព្រះមុនីអ្នកប្រសើរលើសពពួកសត្វទាំងពួង បានជាអ្នកលីលាធ្វើតាមនៃព្រះសាស្ដាក្នុងការបំពេញប្រយោជន៍ ឃិតយោងប្រជុំជនដោយគុណ ពោលគឺករុណា និងបញ្ញាញាណ ។

ខ្ញុំម្ចាស់សូមនមស្ការព្រះថេរៈអង្គនោះ ដែលមានឈ្មោះថាសារីបុត្រ ជាមុនីរាជបុត្រ អ្នកត្រេកអរលើសក្នុងស្ដេរគុណជាអនេក អ្នករុងរឿងដោយពន្លឺភ្លឺស្វាងនៃបញ្ញា មានកិត្តិយសល្អផ្សាយខ្ទ័រខ្ទារទៅ និងមានចរិយាវត្តស្ងប់ល្អ ។

វិសិសដ្ឋបាឋៈ គឺ ព្រះបាលីណាដែលព្រះសាវ័កជាសទ្ធម្មសេនាបតី អ្នកប្រកាសព្រះសទ្ធម្មចក្រ អ្នកចូលដល់សេចក្ដីយល់ច្បាស់ក្នុងអដ្ឋកថាតាមសេចក្ដីពិត ក្នុងព្រះសូត្រទាំងឡាយ ដែលព្រះតថាគតជាម្ចាស់បានត្រាស់ទុកហើយ អ្នកនាំក្នុងការញុំាងធម៌ជាប្រទីបឲ្យភ្លឺស្វាង ពោលវិសិសដ្ឋបាឋៈនោះទុក ដោយនាមដ៏វិសេសថា **បដិសម្ភិទានំ មគ្គោ** ប្រែថា ផ្លូវនៃបដិសម្ភិទា



ទាំងឡាយ ។

បដិសម្ភិទាមគ្គនោះ ជាបករណ៍ដែលមានសភាពរៀបរយដោយអត្ថ និងន័យផ្សេង ៗ យ៉ាងវិចិត្រ ដែលបណ្ឌិតអ្នកតាំងចិត្តបំពេញ **អត្តទត្ថ** ប្រយោជន៍ខ្លួន និង **លោកត្ថ** ប្រយោជន៍ដល់មនុស្សលោក មានបញ្ញាជ្រាលជ្រៅ និងគប្បីយល់ដឹងបានក្នុងគ្រប់កាល ដែលសាធុជនទាំងឡាយនឹងគប្បីចូលចិត្តសេពជានិច្ច ។

ខ្ញុំម្ចាស់នឹងពណ៌នាខ្លឹមសារដែលមិនស្ទួនគ្នា ទៅតាមលំដាប់មិនលើសពីសុតៈ និងត្រឹមត្រូវតាមបដិសម្ភិទាមគ្គបករណ៍នោះ ដែលនាំមកនូវប្រភេទនៃញាណ ដែលព្រះយោគាវចរទាំងឡាយជាអនេក ត្រូវចិត្តហើយ គ្រប់ប្រការ ។

ម្យ៉ាងទៀត ក៏នឹងមិនល្មើសលទ្ធិរបស់ខ្លួននិងមិនបៀតបៀនលទ្ធិរបស់អ្នកដទៃ ប៉ុន្តែនឹងរួបរួមយកឧបទេស និងន័យនៃអដ្ឋកថាពីគ្រាមុន មកសម្ដែងតាមសមគួរ ខ្ញុំម្ចាស់នឹងពោលអដ្ឋកថាឈ្មោះសទ្ធម្មបកាសិនីនោះ ដោយគោរព ដើម្បីប្រយោជន៍ដល់មហាជន ដើម្បីសេចក្ដីតាំងមាំ នៃព្រះសទ្ធម្មរហូតអស់កាលយូរ សូម

សាធុសប្បុរសចូរតាំងចិត្តស្តាប់ ចងចាំទុកចុះ ។

សម្ភិទាមគ្គ ជាមគ្គនៃបដិសម្ភិទា ខ្ញុំម្ចាស់ត្រូវពោលមុន ព្រោះ បានពោលទុកហើយក្នុងគន្ថារម្ភកថា ថា **បដិសម្ភិទានំ មគ្គោតិ តន្នាមវិសេសិតោ** ច ប្រែថា វិសិដ្ឋបាឋៈនោះ ដោយឈ្មោះ ដ៏វិសេសថា បដិសម្ភិទាមគ្គ ។

បដិសម្ភិទាមាន ៤ គឺ :

១. **អត្ថប្បដិសម្ភិទា** បញ្ញា ជំនាញក្នុងអត្ថ

២. **ធម្មប្បដិសម្ភិទា** បញ្ញា ជំនាញក្នុងធម៌

៣. **និរុត្តិប្បដិសម្ភិទា** បញ្ញា ជំនាញក្នុងនិរុត្តិ

៤. **បដិភាណប្បដិសម្ភិទា** បញ្ញា ជំនាញក្នុងបដិភាណ ផ្លូវ គឺ ឧបាយជាគ្រឿងសម្រេចបដិសម្ភិទាទាំងនោះ ដូច្នោះទើប ឈ្មោះថា **បដិសម្ភិទាមគ្គ** មានពាក្យលោកអធិប្បាយទុកថាជា ហេតុនៃការបានចំពោះនូវបដិសម្ភិទា ។

ប្រសិនបើមានបុច្ឆាថា ផ្លូវនេះ ជាផ្លូវនៃបដិសម្ភិទាបាន ព្រោះហេតុអ្វី ?

ក៏គប្បីមានវិសជ្ជនាថា ព្រោះជាទេសនាដែលព្រះមានព្រះ-



ភាគជាម្ចាស់ ទ្រង់សម្តែងដោយប្រភេទជាទេសនា ដែលនាំមក នូវបដិសម្ភិទាញាណ ។

ពិតហើយ ធម៌ទាំងឡាយមានប្រភេទផ្សេង ៗ ទេសនាក៏ មានប្រភេទផ្សេង ៗ រមែងឲ្យកើតប្រភេទនៃបដិសម្ភិទាញាណ ដល់ព្រះអរិយបុគ្គលទាំងឡាយដែលជាអ្នកស្តាប់ ហើយក៏ជាបច្ច័យ ដល់ការស្ទាត់ជំនាញក្នុងបដិសម្ភិទាញាណដល់បុថុជ្ជន តទៅ អនាគត លោកពោលពាក្យនេះទុកថា ទេសនាដោយប្រភេទ រមែងនាំមកនូវ បដិសម្ភិទាញាណ ដែលជាគ្រឿងកម្ចាត់ឃន-សញ្ញាចេញទៅបាន យ៉ាងនេះ ។ ក៏ទេសនាមានប្រភេទផ្សេង ៗ នេះ ក៏មាន , ព្រោះហេតុនោះ ទេសនានោះ ទើបជាទេសនាឲ្យ សម្រេចជាមគ្គនៃបដិសម្ភិទាទាំងឡាយ ។

បណ្តាបទទាំងនោះ បទថា **ចតស្សោ** ជាបទកំណត់ចំនួន បទថា **បដិសម្ភិទា** បានដល់ បញ្ញាជាគ្រឿងស្ទាត់ជំនាញ ។ បញ្ញា ជាគ្រឿងជំនាញរបស់ញាណប៉ុណ្ណោះ មិនមែនជាការជំនាញ របស់អ្នកណា ៗ ដទៃទេ ព្រោះលោកបានពោលទុកថា សេចក្តីដឹង ក្នុងអត្ថ ឈ្មោះថា **អត្ថប្បដិសម្ភិទា** , ការដឹងក្នុងធម៌ ឈ្មោះថា

**ធម្មប្បដិសម្ភិទា** , ការដឹងក្នុងវោហារនៃភាសាដែលពោលដល់អត្ថ និងធម៌ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** , សេចក្តីដឹងក្នុងញាណទាំងឡាយ ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។ ព្រោះដូច្នោះ ពាក្យថា **ចតស្សោ បដិសម្ភិទា** ទើបមានសេចក្តីថា ប្រភេទនៃញាណ ៤ ប្រការ ។

ញាណដែលដល់នូវការបែកធ្លាយក្នុងអត្ថ អាចធ្វើការកំណត់សល្លក្ខណៈ និងវិការៈរបស់ប្រភេទនៃផល ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។

ញាណដែលដល់នូវការបែកធ្លាយក្នុងធម៌ អាចធ្វើការកំណត់សល្លក្ខណៈ និងវិការៈរបស់ប្រភេទនៃហេតុ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។

ញាណដែលដល់នូវការបែកធ្លាយក្នុងនិរុត្តិ អាចធ្វើការកំណត់សល្លក្ខណៈ និងវិការៈរបស់ប្រភេទនៃនិរុត្តិ ឈ្មោះថា **និរុត្តិប្បសម្ភិទា** ។

ញាណដែលដល់នូវការបែកធ្លាយក្នុងបដិភាណ អាចធ្វើការកំណត់សល្លក្ខណៈ និងវិការៈ របស់ប្រភេទនៃបដិភាណ



ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។

បណ្តាបទទាំងនោះ បទថា **អត្ថោ** ពោលដោយសង្ខេប បានដល់ ផលដែលកើតអំពីហេតុ ។ ពិតហើយ ផលដែលកើតអំពីហេតុនោះ រមែងកើត គឺ សម្រេចតាមគន្លងនៃហេតុ ដូច្នោះ លោកទើបហៅថា **អត្ថ** ។ តែកាលណាពោលដោយប្រភេទហើយ ធម៌ ៥ ប្រការទាំងនោះ គឺ ៖

- ធម៌ដែលកើតពីបច្ច័យ ( **បច្ចយសមុប្បន្នំ** ) ណាមួយ ១
- និព្វាន ១
- អដ្ឋកថានៃព្រះបាលីដែលព្រះមានព្រះភាគត្រាស់ហើយ ១
- វិបាកចិត្ត ១
- កិរិយាចិត្ត ១

បណ្ឌិតគប្បីជ្រាបថា **អត្ថ** ។ ញាណដែលដល់នូវការបែកធ្លាយក្នុងអត្ថទាំង របស់ព្រះអរិយបុគ្គលអ្នកពិចារណា **អត្ថ** នោះឯង ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។

បទថា **ធម្មោ** ពោលដោយសង្ខេប បានដល់ បច្ច័យ ។ ពិតហើយ បច្ច័យនោះ រមែងឲ្យ គឺ រមែងឲ្យប្រព្រឹត្តទៅ និង

រមែងឲ្យដល់នូវផលនោះ ៗ ដូច្នោះ លោកទើបឲ្យហៅថា **ធម្ម** ។ តែបើពោលដោយប្រភេទហើយ ធម៌ ៥ ប្រការទាំងនេះ គឺ ៖

- ហេតុឲ្យកើតផលយ៉ាងណាមួយ ១
- អរិយមគ្គ ១
- ព្រះបាលីដែលព្រះមានព្រះភាគត្រាស់ហើយ ១
- កុសលចិត្ត ១
- អកុសលចិត្ត ១

បណ្ឌិតគប្បីជ្រាបថា **ធម្ម** ។ ញាណ ដែលបែកធ្លាយក្នុងធម៌ទាំះ របស់ព្រះអរិយបុគ្គលអ្នកពិចារណាធម៌នោះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។

ពិតហើយ ខ្លឹមសារដូចតទៅនេះ មកក្នុងព្រះអភិធម្មបិដក លោកសម្ដែងចែកទុកដោយន័យជាដើមថា ៖

បញ្ញា បែកធ្លាយក្នុងទុក្ខ ឈ្មោះថា **អត្ថប្បដិសម្ភិទា** , បញ្ញាបែកធ្លាយក្នុងទុក្ខសមុទយ ឈ្មោះថា **ធម្មប្បដិសម្ភិទា** , បញ្ញាបែកធ្លាយក្នុងទុក្ខនិរោធ ឈ្មោះថា **អត្ថប្បដិសម្ភិទា** , បញ្ញាបែកធ្លាយក្នុងទុក្ខនិរោធគាមិនីបដិបទា ឈ្មោះថា **ធម្មប្ប-**



**ដិសម្ភិទា** , បញ្ញាបែកធ្លាយក្នុងហេតុ ឈ្មោះថា **ធម្មប្បដិសម្ភិ-ទា** , បញ្ញាបែកធ្លាយក្នុងផលដែលកើតអំពីហេតុ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។

ធម៌ពួកណា កើតហើយ មានហើយ កើតព្រមហើយ បង្កើតហើយ បង្កើតចំពោះហើយ ប្រាកដហើយ , បញ្ញាបែកធ្លាយក្នុងធម៌ទាំងនេះ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។

ធម៌ទាំងនោះ កើតហើយ មានហើយ កើតព្រមហើយ បង្កើតហើយ បង្កើតចំពោះហើយ ប្រាកដហើយ ពីធម៌ពួកណា បញ្ញាបែកធ្លាយក្នុងធម៌ទាំងនោះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។

បញ្ញាបែកធ្លាយក្នុងជរាមរណៈ ឈ្មោះថា **អត្ថប្បដិសម្ភិ-ទា** , បញ្ញាបែកធ្លាយក្នុងហេតុកើតនៃជរាមរណៈ ឈ្មោះថា **ធម្មប្បដិសម្ភិទា** , បញ្ញាបែកធ្លាយក្នុងការរលត់នៃជរាមរណៈ ឈ្មោះថា **អត្ថប្បដិសម្ភិទា** , បញ្ញាបែកធ្លាយក្នុងបដិបទាដែលជាហេតុឲ្យ ដល់នូវសេចក្ដីរលត់នៃជរាមរណៈ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។

បញ្ញាបែកធ្លាយក្នុងជាតិ ។ល។ បញ្ញា បែកធ្លាយក្នុង

ភព ។ល។ បញ្ញាបែកធ្លាយក្នុងឧបាទាន ។ល។ បញ្ញាបែកធ្លាយក្នុងតណ្ហា ។ល។ បញ្ញាបែកធ្លាយក្នុងវេទនា ។ល។ បញ្ញាបែកធ្លាយក្នុងផស្សៈ ។ល។ បញ្ញាបែកធ្លាយក្នុងសឡាយតនៈ ។ល។ បញ្ញាបែកធ្លាយក្នុងនាមរូប ។ល។ បញ្ញាបែកធ្លាយក្នុងវិញ្ញាណ ។ល។ បញ្ញាបែកធ្លាយក្នុង សង្ខារទាំងឡាយឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ បញ្ញាបែកធ្លាយក្នុង ហេតុកើតនៃសង្ខារ ឈ្មោះថា **ធម្មប្បដិសម្ភិទា** , បញ្ញាបែកធ្លាយ ក្នុងការរលត់នៃសង្ខារ ឈ្មោះថា **អត្ថប្បដិសម្ភិទា** , បញ្ញាបែកធ្លាយ ក្នុងបដិបទាដែលជាហេតុឲ្យដល់ការរលត់នៃសង្ខារ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។

ភិក្ខុក្នុងធម្មវិន័យនេះ រមែងបញ្ញាបែកធ្លាយដល់ធម៌ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ ជាតកៈ អព្ភូតធម្មៈ វេទល្លៈ នេះហៅថា **ធម្មប្បដិសម្ភិទា** , ភិក្ខុនោះ រមែងមានបញ្ញា បែកធ្លាយអត្ថនៃភាសិតនោះ ៗ ថា នេះជាអត្ថនៃភាសិតនេះ នេះជាអត្ថនៃភាសិតនោះ នេះហៅថា **អត្ថប្បដិសម្ភិទា** ។



សភាវធម៌ទាំងឡាយ ដែលជាកុសលដូចម្តេច ?

កាមាវចរកុសលចិត្ត កើតព្រមដោយសោមនស្ស ប្រកបដោយបញ្ញា មានរូបជាអារម្មណ៍ ។ល។ មានធម៌ជាអារម្មណ៍ ឬប្រារព្ធអារម្មណ៍ណា ៗ កើតឡើងក្នុងសម័យណា ផស្សៈ ។ល។ អវិក្ខេបៈ មានក្នុងសម័យនោះ ធម៌ទាំងនេះ ឈ្មោះថា **សភាវធម៌ទាំងឡាយដែលជាកុសល** ។ បញ្ញាបែកធ្លាយក្នុងធម៌ទាំងនេះ ឈ្មោះថា **ធម្មប្បដិសម្ភិទា** បញ្ញាបែកធ្លាយក្នុងវិបាកនៃធម៌ទាំងនោះ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។

ពាក្យថា **តត្រ ធម្មនិរុត្តាភិលាបេ ញាណំ** សេចក្តីថា បញ្ញាបែកធ្លាយក្នុងពាក្យនិយាយ ពាក្យពោល ពាក្យដែលបន្លឺឡើងដល់សភាវនិរុត្តិដែលជាវោហារ ដែលមិនខុសប្លែកទាំងក្នុងអត្ថ និងក្នុងធម៌នោះ , ក្នុងពាក្យនិយាយដែលជាសភាវនិរុត្តិរបស់ព្រះអរិយបុគ្គលអ្នកធ្វើសភាវនិរុត្តិស័ព្ទ ដែលគេនិយាយហើយពោល ហើយថ្លែងចេញហើយ ឲ្យជាអារម្មណ៍ហើយ ពិចារណាហើយ , ក្នុងមាគធីមូលភាសារបស់សត្វទាំងឡាយដែលជាសភាវនិរុត្តិ ព្រោះសភាវនិរុត្តិនោះ បណ្ឌិតទទួលស្គាល់

ថាជាធម្មនិរុត្តិយ៉ាងនេះថា នេះជាសភាវនិរុត្តិ , នេះមិនមែនសភាវនិរុត្តិ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ។

ដោយប្រការយ៉ាងនេះ និរុត្តិប្បដិសម្ភិទានេះ ឈ្មោះថា មានសទ្ទៈ គឺ សំឡេងជាអារម្មណ៍ មិនមានបញ្ញត្តិជាអារម្មណ៍ , ព្រោះហេតុអ្វី ? ព្រោះព្រះអរិយបុគ្គលបានឮសំឡេងហើយ រមែងដឹងថា នេះជាសភាវនិរុត្តិ , នេះមិនមែនសភាវនិរុត្តិ ។ ពិតហើយ ព្រះអរិយបុគ្គលអ្នកសម្រេចនូវនិរុត្តិប្បដិសម្ភិទា កាលគេនិយាយថា **ផស្សោ** ក៏រមែងដឹថា នេះជាសភាវនិរុត្តិ , កាលបើគេនិយាយថា **ផស្សា** ឬ **ផស្សំ** ក៏រមែងដឹងថា នេះមិនមែនសភាវនិរុត្តិ សូម្បីក្នុងសភាវធម៌ទាំងឡាយ មានវេទនាជាដើម ក៏ន័យនេះដូចគ្នា ។

សួរថា ក៏ព្រះអរិយបុគ្គលអ្នកសម្រេចនូវនិរុត្តិប្បដិសម្ភិទានេះ នឹងដឹង ឬមិនដឹងពាក្យដទៃ គឺ សំឡេងនៃព្យញ្ជនៈដែលពោលដល់នាម , អាខ្យាត , ឧបសគ្គ និងនិបាត ។

ឆ្លើយថា ព្រះអរិយបុគ្គលអ្នកសម្រេចនូវនិរុត្តិប្បដិសម្ភិទានោះ កាលបើបានឮសំឡេងហើយ ក៏ដឹងថា នេះជាសភាវនិរុត្តិ , 



នេះមិនមែនសភាវនិរុត្តិ ដោយហេតុសម្គាល់យ៉ាងណា ក៏ដឹងពាក្យនោះ ដោយហេតុសម្គាល់យ៉ាងនោះ , តែប្រការនេះមានអ្នកពោលបដិសេធថា នេះមិនមែនជាកិច្ចរបស់បដិសម្ភិទា ហើយពោលថា បណ្តាភាសាសត្វទាំងឡាយ រមែងសិក្សាបាន ហើយលើកឧទាហរណ៍នេះឡើងមកបរិយាយថា ពិតហើយ មាតា និងបិតា យកកុមារតូចក្នុងគ្រានៅជាទារក ឲ្យដេកនៅលើគ្រែ ឬតាំង ហើយនិយាយភាសានោះ ៗ ធ្វើកិច្ចនោះ ៗ , ទារកកំណត់ភាសានោះ ៗ របស់មាតា និងបិតាទាំងនោះថា ពាក្យនេះលោកអ្នកនេះនិយាយ , ពាក្យនេះលោកអ្នកនេះនិយាយ កាលកន្លងមកយូរថ្ងៃទៅ ក៏រមែងដឹងភាសាទាំងអស់បាន ។ មាតាជាអ្នកស្រុកទមិឡ , បិតាជាអ្នកស្រុកអន្ធកៈ ទារករបស់មាតាបិតាទាំងនោះ បើបានឮពាក្យនិយាយរបស់មាតាមុន ក៏នឹងនិយាយភាសាទមិឡ បើបានឮពាក្យនិយាយរបស់បិតាមុន ក៏នឹងនិយាយភាសាអន្ធកៈ ។ តែបើមិនបានឮពាក្យ និយាយរបស់មាតា និងបិតាទាំង ២ នោះ ក៏នឹងនិយាយភាសាមាគធីតែម្យ៉ាង ។

សូម្បីទារកណា កើតក្នុងព្រៃធំមិនមានផ្ទះ អ្នកដទៃដែល

ឈ្មោះថា នឹងនិយាយជាមួយក៏មិនមានក្នុងទីនោះ , ទារកនោះកាលបើនឹងផ្ដើមនិយាយតាមធម្មតារបស់ខ្លួន ក៏នឹងនិយាយភាសាមាគធីនោះឯង ។ ភាសាមាគធីមានច្រើនក្នុងទីទាំងពួង ។ គឺក្នុងនរក , ក្នុងកំណើតតិរច្ឆាន , ក្នុងបេតិវិស័យ , ក្នុងមនុស្សលោក , ក្នុងទេវលោក ។ បណ្ដាភាសារបស់សត្វក្នុងភូមិនោះ ៗ ភាសាដ៏សេស ដូចជា ឱដ្ឋភាសា , កិរាតភាសា , អន្ធកភាសា , យោនកភាសា និងទមិឡភាសាជាដើម រមែងប្រែប្រួលបាន , មាគធីភាសាតែមួយប៉ុណ្ណោះ រាប់ថាជាព្រហ្ម-វោហារ និងអរិយវោហារតាមការពិត រមែងមិនប្រែប្រួល ។

សូម្បីព្រះសម្មាសម្ពុទ្ធជាម្ចាស់ កាលទ្រង់នឹងលើកព្រះ-ពុទ្ធវចនៈ គឺ ព្រះត្រៃបិដកឡើងជាបែបផែន ក៏ទ្រង់លើកឡើងទុកក្នុងភាសាមាគធីប៉ុណ្ណោះ ។ ព្រោះហេតុអ្វី ? ក៏ព្រោះដើម្បីនឹងនាំអត្ថមកឲ្យដឹងបានដោយងាយ ។ ពិតហើយ ព្រះ-ពុទ្ធវចនៈដែលលើកឡើង ជាបែបផែនដោយមាគធីភាសា នៅមិនសម្រេចដល់គន្លងសោតបសាទ របស់ព្រះអរិយបុគ្គលដែលសម្រេចបដិសម្ភិទានោះ ជាការយឺតយូរ ។ តែប្រសិនបើសោត-



បសាទល្មមព្រះពុទ្ធវចនៈប៉ះខ្ទប់ហើយប៉ុណ្ណោះ ខ្ញីមសារក៏ប្រាកដទាំងរយន័យ ពាន់ន័យ ។ ក៏ព្រះពុទ្ធវចនៈ ដែលលើកឡើងសម្ដែងទៅតាមបែបផែនភាសាដទៃ ក៏រមែងត្រូវរៀនយកបែបបកស្រាយហើយ បកស្រាយទៀត ។ តាមធម្មតាការរៀនព្រះពុទ្ធវចនៈសូម្បីតិចច្រើន ហើយសម្រេចបដិសម្ភិទា រមែងមិនមានដល់បុថុជ្ជន តែព្រះអរិយសាវកដែលនឹងឈ្មោះថា មិនសម្រេចបដិសម្ភិទានោះ រមែងមិនមានឡើយ ។

បទថា **ញាណេសុ ញាណំ** សេចក្ដីថា បញ្ញាបែកធ្លាយក្នុងញាណទាំង ៣ ទាំងនោះ របស់ព្រះអរិយបុគ្គលអ្នកធ្វើញាណដែលមានក្នុងទីទាំងពួងឲ្យមកជាអារម្មណ៍ ហើយពិចារណា , ឬថាញាណដែលដល់នូវការធំទូលាយក្នុងញាណទាំង ៣ នោះដោយអំណាចនៃអារម្មណ៍ និងកិច្ចជាដើម ឈ្មោះថា **បដិភា-ណប្បដិសម្ភិទា** ។

ក៏បណ្ឌិតគប្បីជ្រាបបដិសម្ភិទា ៤ ទាំងនេះថា រមែងដល់នូវប្រភេទក្នុងឋានៈ ២ , រមែងផូរផង់ដោយហេតុ ៥ ។ រមែងដល់នូវប្រភេទក្នុងឋានៈ ២ ដូចម្ដេច ? គឺ ក្នុងសេក្ខភូមិ ១

អសេក្ខភូមិ ១ ។

ក្នុង ២ ភូមិនោះ បដិសម្ភិទារបស់មហាថេរៈ ៨០ អង្គ មានព្រះថេរៈអ្នកមានឈ្មោះយ៉ាងនេះ គឺ ព្រះសារីបុត្រត្ថេរ , ព្រះមហាមោគ្គលានត្ថេរ , ព្រះមហាកស្សបត្ថេរ , ព្រះមហា-កច្ចាយនត្ថេរ , ព្រះមហាកោដ្ឋិតត្ថេរជាដើម ដល់នូវប្រភេទក្នុងអសេក្ខភូមិ , បដិសម្ភិទារបស់ព្រះអរិយបុគ្គលទាំងឡាយ មានព្រះអរិយបុគ្គលដែលមាននាមយ៉ាងនេះ គឺ ព្រះអានន្ទត្ថេរ , ចិត្តគហបតី , ធម្មិកឧបាសក , ឧបាលីគហបតី , ខុជ្ជុ-ត្តរាឧបាសិកាជាដើម ដល់នូវប្រភេទសេក្ខភូមិ , បដិសម្ភិទារមែងដល់នូវប្រភេទក្នុងភូមិ ២ នេះ ដោយប្រការដូច្នេះ ។

បដិសម្ភិទារមែងផូរផង់ដោយហេតុ ៥ ប្រការ ដូចម្ដេច ? រមែងផូរផង់ដោយហេតុ ៥ ប្រការ គឺ ដោយអធិគម , ដោយបរិយត្តិ , ដោយសវនៈ , ដោយបរិបុច្ឆា , ដោយបុព្វយោគៈ ។

ក្នុងហេតុ ៥ ប្រការទាំងនោះ ការសម្រេចព្រះអរហត្ត ឈ្មោះថា **អធិគម** ។ ក៏បដិសម្ភិទារបស់អ្នកសម្រេចព្រះអរហត្ត រមែងផូរផង់ ។



ព្រះពុទ្ធវចនៈ ឈ្មោះថា **បរិយត្តិ** ។ ក៏បដិសម្ភិទារបស់អ្នករៀនព្រះពុទ្ធវចនៈនោះ រមែងផូរផង់ ។

ការស្ដាប់ព្រះសទ្ធម្ម ឈ្មោះថា **សវន** ។ ក៏បដិសម្ភិទារបស់អ្នកយកចិត្តទុកដាក់រៀនធម៌ដោយគោរព រមែងផូរផង់ ។

កថាជាគ្រឿងវិនិច្ឆ័យ គណ្ឋិបទ និងអត្ថបទ ក្នុងព្រះបាលី និងអដ្ឋកថាជាដើម ឈ្មោះថា **បរិបុច្ឆា** ។ ក៏បដិបទារបស់អ្នកសាកសួរអត្ថក្នុងព្រះពុទ្ធវចនៈទាំងឡាយ មានព្រះបាលីជាដើម ដែលខ្លួនរៀនហើយ រមែងផូរផង់ ។

ការបំពេញនូវសេចក្ដីព្យាយាមក្នុងវិបស្សនាកម្មដ្ឋានរឿយៗ រហូតដល់សង្ខារុបេក្ខាញាណ ដែលជាទីជិតអនុលោមញ្ញាណ និងគោត្រភូញាណ អាស្រ័យការចម្រើនវិបស្សនានោះ ដែលព្រះយោគាវចរធ្លាប់បដិបត្តិ ហើយសិក្សាបដិបត្តិមកក្នុងសាសនារបស់ព្រះពុទ្ធជាម្ចាស់មុន ៗ ឈ្មោះថា **បុព្វយោគ** ។ ក៏បដិបទារបស់អ្នកបំពេញសេចក្ដីព្យាយាមមកហើយក្នុងគ្រាមុន រមែងផូរផង់... បដិបទារមែងផូរផង់ដោយហេតុ ៥ ប្រការទាំងនេះ ដោយប្រការដូច្នេះ ។

ក៏ក្នុងបណ្តាហេតុទាំង ៥ នេះ ហេតុ ៣ នេះ គឺ បរិយត្តិ , សវនៈ , បរិបុច្ឆា , ជាហេតុមានកម្លាំងដើម្បីសេចក្តីបែកធ្លាយ ។ បុព្វយោគៈ ជាបច្ច័យមានកម្លាំងដើម្បីសម្រេចព្រះអរហត្ត ។

សួរថា ពួក ៣ នៃហេតុ មានបរិយត្តិជាដើម រមែងមានដើម្បីការបែកធ្លាយ មិនអាចដើម្បីសេចក្តីសម្រេចឬ ?

ឆ្លើយថា មាន តែមិនមែនយ៉ាងនោះ ។ ព្រោះបរិយត្តិ , សវនៈ និងបរិបុច្ឆា នឹងមានក្នុងកាលមុន ឬមិនមានក្តី តែវៀរការពិចារណាសង្ខារធម៌ ដោយការបំពេញសេចក្តីព្យាយាមក្នុងគ្រាមុន និងការពិចារណាសង្ខារក្នុងបច្ចុប្បន្នចេញហើយ ឈ្មោះថា បដិសម្ភិទា ក៏មានមិនបាន ។ ហេតុ និងបច្ច័យទាំង ២ នេះ រួមគ្នាជួយឧត្តម្ភបដិសម្ភិទា ធ្វើឲ្យផូរផង់បាន ដោយប្រការដូច្នេះ ។

នៅមានពួកអាចារ្យដទៃទៀត បានពោលទុកថា ៖

**បុព្វយោគ ១ , ពាហុសច្ចៈ ១ , ទេសភាសា ១ , និគម ១ , បរិបុច្ឆា ១ , អធិគម ១ , គរុសន្និ-ស្សយ័ ១ និងមិត្តសម្បត្តិ ១ ។ រួម ៨ ប្រការនេះ**



**សុទ្ធតែជាបច្ច័យដល់បដិសម្ភិទា ដូច្នេះ ។**

បណ្តាធម៌ទាំង ៨ ប្រការនោះ ន័យដូចបានពោលមកហើយ ឈ្មោះថា **បុព្វបយោគ** ។

សេចក្តីឆ្លាតក្នុងសាស្ត្រនោះ ៗ និងសិល្បាយតនៈទាំង-ឡាយ ឈ្មោះថា **ពាហុសច្ច** ។

សេចក្តីឆ្លាតក្នុងភាសា ១០១ ភាសា សេចក្តីឆ្លាតក្នុងភាសាមាគធីដោយវិសេស ឈ្មោះថា **ទេសភាសា** ។

ការបង្រៀនព្រះពុទ្ធវចនៈ ដោយទីបំផុតសូម្បីត្រឹមតែឱបម្មវគ្គ ឈ្មោះថា **អគម** ។

ការវិនិច្ឆ័យសាកសួរអត្ថ សូម្បីក្នុងគាថា ១ ឈ្មោះថា **បរិបុច្ឆា** ។

ភាពជាព្រះសោតាបន្នក្តី ភាពជាព្រះសកទាគាមីក្តី ភាពជាព្រះអនាគាមីក្តី ភាពជាព្រះអរហន្តក្តី ឈ្មោះថា **អធិគម** ។

ការនៅក្នុងសំណាក់គ្រូអ្នកច្រើនដោយសុត្តៈ និងបដិភាណ ឈ្មោះថា **គរុសន្និស្សយ័** ។

ការបានមិត្រយល់ត្រូវនោះឯង ឈ្មោះថា **មិត្តសម្បត្តិ** ។

បណ្ដាធម៌ទាំង ៨ ប្រការនោះ ព្រះពុទ្ធជាម្ចាស់ទាំងឡាយ និងព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងឡាយ បានអាស្រ័យបុព្វយោគៈ និងអធិគមហើយ សម្រេចបដិសម្ភិទា , ចំណែកព្រះសាវកទាំងឡាយអាស្រ័យហេតុទាំងនេះ សូម្បីទាំងអស់ ទើបសម្រេចបដិសម្ភិទា ។

ក៏ក្នុងការសម្រេចបដិសម្ភិទា មិនមានការបំពេញនូវសេចក្ដីព្យាយាមក្នុងកម្មដ្ឋានភាវនាដោយចំពោះទៀត , ចំណែកព្រះសេក្ខបុគ្គល មានផល និងវិមោក្ខ របស់ព្រះសេក្ខៈជាទីបំផុត ការសម្រេចបដិសម្ភិទា ក៏រមែងមានបាន ។

អធិប្បាយថា បដិសម្ភិទាទាំងឡាយ ក៏រមែងសម្រេចដល់បណ្ដាព្រះអរិយបុគ្គល ដោយអរិយផលទាំងឡាយនោះឯង ដូចជាទសពលញ្ញាណ ញាណសម្រេចដល់ព្រះសម្ពុទ្ធទាំងឡាយដូច្នោះ ។ ផ្លូវនៃបដិសម្ភិទា ៤ ទាំងនេះ ដូច្នោះទើបឈ្មោះថា **បដិសម្ភិទាមគ្គ** , បករណ៍ គឺ បដិសម្ភិទាមគ្គ ឈ្មោះថា **បដិសម្ភិទាមគ្គបករណ៍** , ឈ្មោះថា **បករណ៍** ព្រោះអត្ថថា អត្ថដ៏ជ្រាលជ្រៅ ចែកដោយប្រភេទផ្សេង ៗ ក្នុងបដិសម្ភិទានេះ



លោកពោលធ្វើដោយប្រការផ្សេង ៗ ។

បដិសម្ភិទាមគ្គបករណ៍នេះ សម្បូរដោយអត្ថៈ , ព្យញ្ជនៈ , ជ្រាលជ្រៅ , មានអត្ថជ្រាលជ្រៅ , ប្រកាសលោកុត្តរៈ , ប្រកបដោយសុញ្ញតា , ឲ្យសម្រេចផលវិសេសក្នុងការបដិបត្តិ , ហាមអកុសលដែលជាបដិបក្ស , ជារតនាករឲ្យកើតញាណដ៏ប្រសើររបស់ព្រះយោគាវចរ , ជាហេតុដ៏វិសេសក្នុងការបរិយាយធម្មកថាឲ្យបានពីរោះរបស់ធម្មកថិកទាំងឡាយ , ជាគ្រឿងនាំចេញចាកទុក្ខរបស់អ្នកឃើញភ័យក្នុងសង្សារវដ្ដ ។ មានប្រយោជន៍ក្នុងការញ៉ាំងសេចក្ដីត្រជាក់ឲ្យកើត ព្រោះឃើញឧបាយក្នុងការចេញចាកទុក្ខនោះ , និងមានប្រយោជន៍ក្នុងការកម្ចាត់អកុសលធម៌ ដែលជាបដិបក្សដល់និស្សរណធម៌នោះ និងមានប្រយោជន៍ឲ្យកើតសេចក្ដីត្រេកអរក្នុងហឫទ័យរបស់កល្យាណជន ដោយការបញ្ចេញឲ្យដឹងអត្ថ នៃបទព្រះសូត្រមានខ្លឹមសារដ៏ជ្រាលជ្រៅក្រៃលែង ដែលព្រះសារីបុត្រជាធម្មសេនាបតីរបស់ព្រះសម្មាសម្ពុទ្ធ បានភាសិតហើយ កាលបើប្រទីបដួងធំពោលគឺ ព្រះសទ្ធម្មរុងរឿងហើយដោយពន្លឺប្រទីបដួងធំ គឺ

ព្រះសព្វញ្ញុតញ្ញាណ ដែលព្រះតថាគតអរហន្តសម្មាសម្ពុទ្ធត្រាស់ដឹងហើយដោយមិនទើសទាក់ បញ្ចេញពន្លឺភ្លឺស្វាងទូទៅគ្រប់ទិសទី មានព្រះទ័យស្និទ្ធស្នេហា ប្រកបទៅដោយព្រះមហាករុណាផ្សព្វផ្សាយទៅក្នុងពពួកជន ដើម្បីកម្ចាត់សេចក្តីងងឹតអន្ធការពោល គឺ កិលេស ដោយព្រះមហាករុណាក្នុងវេនេយ្យសត្វ ដោយការលើកព្រះសទ្ធម្មនោះឡើងអធិប្បាយ ឲ្យភ្លឺច្បាស់ដល់ពួកជន ដោយសេចក្តីស្នេហា ប្រាថ្នាសេចក្តីរុងរឿងនៃព្រះសទ្ធម្មរហូតដល់ ៥.០០០ ព្រះវស្សា អ្នកមានចេតនាចង់គាំទ្រលោកតាមបែបផែនព្រះសាស្តា ដែលព្រះអានន្ទត្ថេរស្តាប់ភាសិតនោះហើយ លើកឡើងប្រមូលទុក ក្នុងពេលធ្វើបឋមមហាសង្គីតិតាមដែលបានស្តាប់មកហើយនុ៎ះឯង ។

ក្នុងបិដកទាំង ៣ គឺ ព្រះវិន័យបិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក , បដិសម្ភិទាមគ្គបករណ៍នេះនោះ រាប់ចូលក្នុងព្រះសុត្តន្តបិដក ។

ក្នុងនិកាយធំទាំង ៥ គឺ ទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ និងខុទ្ទកនិកាយ , បដិសម្ភិទា-



មគ្គបករណ៍នេះ រាប់ចូលក្នុងខុទ្ទនិកាយ ។

ក្នុងអង្គនៃសត្ថុសាសន៍ទាំង ៩ គឺ សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទាន ឥតិវុត្តកៈ អព្ភូតធម្មៈ វេទល្លៈ , បដិសម្ភិទាមគ្គបករណ៍នេះ រាប់សង្គ្រោះចូលក្នុង ២ អង្គ គឺ គេយ្យៈ និង វេយ្យាករណ៍ តាមដែលអាចបាន ។

ក៏បណ្តាព្រះធម្មក្ខន្ធ ៨៤.០០០ ព្រះធម្មក្ខន្ធ ដែលព្រះ-អានន្ទត្ថេរជាភណ្ឌាគារិក ដែលព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់លើកឡើងកាន់ឯតទគ្គៈក្នុង ៥ តំណែង ប្តេជ្ញាទុកយ៉ាងនេះថា ៖

ធម៌ពួកណាដែលប្រព្រឹត្តទៅដល់ខ្ញុំម្ចាស់ ធម៌ទាំងនោះខ្ញុំបានរៀនពីព្រះពុទ្ធជាម្ចាស់ ៨២.០០០ ព្រះធម្មក្ខន្ធ , ពីភិក្ខុដទៃ ២.០០០ ព្រះធម្មក្ខន្ធ ទើបរួមជា ៨៤.០០០ ព្រះធម្មក្ខន្ធដូច្នេះ ។

បដិសម្ភិទាមគ្គបករណ៍នេះ រាប់បញ្ចូលក្នុងព្រះធម្មក្ខន្ធច្រើនជាងរយ ក្នុងធម្មក្ខន្ធ ២.០០០ ព្រះធម្មក្ខន្ធដែលរៀនពីភិក្ខុ ។

បដិសម្ភិទាមគ្គបករណ៍ មាន ៣ វគ្គ គឺ មហាវគ្គ , មជ្ឈិមវគ្គ និងចូឡវគ្គ ។

ក្នុងវគ្គមួយ ៗ មានមួយវគ្គ ៗ ១០ កថា រួមជា ៣០ កថា មានញាណកថាជាខាងដើម មានមាតិកាកថា ជាបរិ-យោសាន ។

ខ្ញុំម្ចាស់នឹងពណ៌នាខ្លឹមសារនៃបទ មិនឲ្យដដែល ៗ ទៅតាមលំដាប់នៃបដិសម្ភិទាមគ្គបករណ៍នេះ ដែលកំណត់ដោយចំណែកតែមួយ ដោយប្រការដូច្នេះ ។

ក៏បករណ៍នេះ ដែលកុលបុត្រ ទាំងអ្នកសូត្រ ទាំងអ្នកសម្តែងដោយបាលី ដោយអត្ថ ក៏គប្បីសូត្រ គប្បីសម្តែងដោយគោរពចុះ , សូម្បីនឹងរៀន ក៏គប្បីរៀន គប្បីចាំទុកដោយគោរពចុះ ។ សេចក្តីនោះព្រោះហេតុអ្វី ? ព្រោះបករណ៍នេះ ជាបករណ៍មានអត្ថដ៏ជ្រាលជ្រៅ ដើម្បីប្រយោជន៍គាំទ្រដល់លោក ដើម្បីសេចក្តីតាំងមាំនៅក្នុងលោក ។

ប្រសិនបើនឹងមានពាក្យសួរថា ក្នុងកថា ៣០ កថា នោះ ព្រោះហេតុអ្វី លោកទើបពោលញាណកថាទុកអំពីខាងដើម ? ឆ្លើយថា ព្រោះញាណជាខាងដើមនៃការបដិបត្តិ ព្រោះជាធម៌ជាគ្រឿងជម្រះមន្ទិលនៃការបដិបត្តិ ។ សមពិតដូចព្រះតម្រាស់



ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

> **ម្នាលភិក្ខុ ព្រោះហេតុនោះឯង អ្នកចូរញ៉ាំងខាងដើមនៃកុសលធម៌ទាំងឡាយ ឲ្យបរិសុទ្ធសិន ខាងដើមនៃកុសលធម៌ទាំងឡាយគឺអ្វី ? គឺ សីលដ៏បរិសុទ្ធល្អ និងសេចក្តីយល់ត្រង់ ដូច្នេះ ។**

ក៏ញាណពោល គឺ សម្មាទិដ្ឋិ លោកពោលហើយដោយបទថា **ឧជុកា ទិដ្ឋិ** សូម្បីព្រោះហេតុនោះ លោកទើបពោលញាណកថា ទុកជាខាងដើម ។ សូម្បីពាក្យដទៃ ព្រះមានព្រះ-ភាគជាម្ចាស់ ក៏បានត្រាស់ទុកទៀតថា ៖

ម្នាលភិក្ខុទាំងឡាយ **បណ្តាអង្គទាំង ៨** នោះ សម្មាទិដ្ឋិរមែងជាប្រធាន , ម្នាលភិក្ខុទាំងឡាយ ក៏សម្មាទិដ្ឋិ រមែងជាប្រធានយ៉ាងណា ? គឺ ភិក្ខុស្គាល់សម្មាទិដ្ឋិថា ជាសម្មាទិដ្ឋិ ស្គាល់មិច្ឆាទិដ្ឋិ ថាជាមិច្ឆាទិដ្ឋិ សេចក្តីដឹងរបស់អ្នកនោះ ជាសម្មាទិដ្ឋិ ។

ភិក្ខុស្គាល់សម្មាសង្កប្បៈ ថាជាសម្មាសង្កប្បៈ , ស្គាល់មិច្ឆាសង្កប្បៈ ថាជាមិច្ឆាសង្កប្បៈ ។

ភិក្ខុស្គាល់សម្មាវាចា ថាជាសម្មាវាចា , ស្គាល់មិច្ឆាវាចា ថាជាមិច្ឆាវាចា ។

ភិក្ខុស្គាល់សម្មាកម្មន្តៈ ថាជាសម្មាកម្មន្តៈ , ស្គាល់មិច្ឆា-កម្មន្តៈ ថាជាមិច្ឆាកម្មន្តៈ ។

ភិក្ខុស្គាល់សម្មាអាជីវៈ ថាជាសម្មាអាជីវៈ , ភិក្ខុស្គាល់មិច្ឆាអាជីវៈ ថាជាមិច្ឆាអាជីវៈ ។

ភិក្ខុស្គាល់សម្មាវាយាមៈ ថាជាសម្មវាយាមៈ , ភិក្ខុស្គាល់មិច្ឆាវាយាមៈ ថាជាមិច្ឆាវាយាមៈ ។

ភិក្ខុស្គាល់សម្មាសតិ ថាជាសម្មាសតិ , ភិក្ខុស្គាល់មិច្ឆាសតិ ថាជាមិច្ឆាសតិ ។

ភិក្ខុស្គាល់សម្មាសមាធិ ថាជាសម្មាសមាធិ , ភិក្ខុស្គាល់មិច្ឆាសមាធិ ថាជាមិច្ឆាសមាធិ ។ ការដឹងរបស់អ្នកនោះ ជាសម្មាទិដ្ឋិ ។

លោកពោលញាណកថាទុកពីខាងដើម ក៏ដើម្បីនឹងឲ្យញាណ ពោលគឺ ការឃើញត្រូវថា កាលបើសម្មាទិដ្ឋិជាប្រធានសម្រេចហើយ ក៏នឹងស្គាល់មិច្ឆាទិដ្ឋិទាំងឡាយថា ជាមិច្ឆាទិដ្ឋិ



ដូច្នេះ ឲ្យបានសម្រេចជាមុន ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ៖

ម្នាលឧទាយី អ្នកចូរលះបង់ខន្ធចំណែកអតីត និងអនាគតទុកសិន តថាគតនឹងសម្តែងធម៌ដល់អ្នកថា កាលបើហេតុនេះមាន ផលនេះទើបមាន , ព្រោះហេតុនេះកើត ផលនេះទើបកើត , កាលបើហេតុនេះមិនមាន ផលនេះក៏រមែងមិនមាន , ព្រោះហេតុនេះរលត់ ផលនេះរមែងរលត់ ដូច្នេះ ។

និងព្រោះវៀរបុព្វន្តទិដ្ឋិ និងអបរន្តទិដ្ឋិ ហើយពោលញាណប៉ុណ្ណោះ លោកទើបពោលញាណកថាទុកពីខាងដើម ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ៖

កុំឡើយ សុភទ្ទៈ ប្រការដែលសួរថា សមណព្រាហ្មណ៍ទាំងនោះទាំងអស់ បានត្រាស់ដឹងតាមបដិញ្ញារបស់ខ្លួន ៗ ឬ ឬថាទាំងអស់មិនបានត្រាស់ដឹង ឬថាពួកខ្លះមិនបានត្រាស់ដឹង ដូច្នេះនោះ ចូរវៀរទុកសិន ។ ម្នាលសុភទ្ទៈ តថាគតនឹងសម្តែងធម៌ដល់អ្នក អ្នកចូរតាំងចិត្តស្តាប់ធម៌នោះ ចូរមនសិការឲ្យល្អ , តថាគតនឹងសម្តែងក្នុងកាលឥឡូវនេះ ដូច្នេះ ។

ព្រោះវៀរវាទៈរបស់ពួកសមណព្រាហ្មណ៍បុថុជ្ជន ផ្នែកបរប្បវាទទាំងឡាយចេញ ហើយសម្ដែងអដ្ឋង្គិកមគ្គដ៏ប្រសើរ និងព្រោះញាណ ពោលគឺ សម្មាទិដ្ឋិក្នុងអដ្ឋង្គិកមគ្គជាប្រធាន លោកទើបពោលញាណកថាទុកពីខាងដើម ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ អង្គនៃការសម្រេចសោតាបន្ន ៤ យ៉ាង ទាំងនេះ គឺ ៖

១. **សប្បុរិសំសេវោ** ការសេពគប់នឹងសប្បុរស

២. **សទ្ធម្មស្សវនំ** ការស្ដាប់ព្រះសទ្ធម្ម

៣. **យោនិសោមនសិការោ** ការធ្វើទុកក្នុងចិត្តដោយប្រពៃ

៤. **ធម្មានុធម្មប្បដិបត្តិ** ការបដិបត្តិធម៌សមគួរដល់ធម៌

ហើយត្រាស់ថា ៖

កុលបុត្រកើតសទ្ធាហើយ រមែងចូលទៅជិត កាលបើចូលទៅជិត រមែងអង្គុយជិត កាលបើអង្គុយជិត រមែងផ្ទៀងត្រចៀកស្ដាប់ កាលបើផ្ទៀងត្រចៀកស្ដាប់ហើយ រមែងស្ដាប់ កាលបើស្ដាប់ធម៌ហើយ រមែងចាំធម៌ទុក រមែងពិចាណាខ្លឹមសារ



នៃធម៌ដែលចាំទុកហើយ កាលពិចារណាខ្លឹមសារហើយ ធម៌ទាំងឡាយរមែងអត់ធន់ដល់ការពិនិត្យ កាលធម៌អត់ធន់ដល់ការពិនិត្យបានហើយ ឆន្ទៈរមែងកើត កាលណាកើតឆន្ទៈហើយ រមែងឧស្សាហ៍ កាលបើឧស្សាហ៍ហើយ រមែងពិចារណា កាលបើពិចារណាហើយ រមែងតាំងសេចក្ដីព្យាយាម កាលបើមានខ្លួនបញ្ជូនទៅហើយ រមែងធ្វើឲ្យជាក់ច្បាស់នូវបរមត្ថសច្ចៈនោះដោយកាយ និងឃើញច្បាស់ ចាក់ធ្លុះនូវបរមត្ថសច្ចៈនោះដោយបញ្ញា ដូច្នេះ ។

និងត្រាស់ថា ៖

ព្រះតថាគតឧប្បត្តិឡើងក្នុងលោកនេះ ។ល។ ព្រះតថាគតនោះ ទ្រង់សម្ដែងធម៌ពីរោះក្នុងខាងដើម ដូច្នេះ ។

លោកពោលញាណកថាទុកពីខាងដើម ធ្វើសុតមយញ្ញាណទុកជាញាណដើម ដោយអនុលោមសុត្តន្តបទយ៉ាងច្រើន តាមដែលបានពោលមកហើយនេះជាអាទិ៍ ។

ក៏ញាណកថានេះនោះ បែងចែក ជា ២ គឺ ឧទ្ទេស ១ និទ្ទេស ១ ។ ក្នុងឧទ្ទេស លោកសម្ដែងញាណ ៧៣ ដោយ

អំណាចនៃមាតិកា ដោយន័យជាដើមថា **សោតាវធានេ បញ្ញា សុតមយេ ញាណំ** ដែលប្រែថា បញ្ញា ( ការដឹងច្បាស់ ) ក្នុងការប្រុងត្រចៀក ឈ្មោះថា សុតមយញ្ញាណ ដូច្នេះ ។

ក្នុងនិទ្ទេស លោកសម្តែងញាណ ៧៣ ទាំងនោះនុ៎ះឯង យ៉ាងពិស្តារ ដោយន័យជាដើមថា **កថំ សោតាវធានេ បញ្ញា សុតមយេ ញាណំ ។ ឥមេ ធម្មា អភិញ្ញេយ្យាតិ សោតាវធានំ , តំបជាននា បញ្ញា សុតមយេ ញាណំ** ដែលប្រែថា បញ្ញាក្នុងការប្រុងត្រចៀក ឈ្មោះថា សុតមយញ្ញាណ តើដូចម្តេច ? បញ្ញាក្នុងការចងចាំធម៌ដែលបានស្តាប់មកហើយ គឺ ជាគ្រឿងដឹងច្បាស់នូវធម៌ដែលបានស្តាប់មកហើយនោះថា ធម៌ទាំងនេះគួរដឹងច្បាស់ដូច្នេះ ជា **សុតមយញ្ញាណ** ។

***( ចប់គន្ថារម្ភកថា )***



# មហាវគ្គ

## អដ្ឋកថាញ្ញាណកថាមាតិកា

## ១.អដ្ឋកថា សុតមយញ្ញាណុទ្ទេស

### ពោលអំពី សុតមយញ្ញាណ

ក្នុងឧទ្ទេសនោះ ជាដំបូងគប្បីជ្រាប **សោត** សព្ទ ក្នុងពាក្យនេះ **សោតាវធានេ បញ្ញា សុតមយេ ញាណំ** មានប្រភេទនៃអត្ថជាអនេក ។ ពិតយ៉ាងនោះ **សោត** សព្ទនោះ រមែងប្រាកដ ៖

**ក្នុងអត្ថថា មំសសោត , សោតវិញ្ញាណ ,**
**ញាណសោត , ក្រសែនៃតណ្ហាជាដើម ,**
**ធារនៃក្រសែទឹក , អរិយមគ្គ និងសូម្បីក្នុង**
**ការបន្តនៃចិត្ត ។**

ក៏ **សោត** សព្ទនេះ រមែងប្រាកដក្នុងអត្ថថា **មំសសោត** បានក្នុងពាក្យជាដើមថាសោតាយតនៈ , សោតធាតុ , សោតិន្ទ្រិយ៍ ។

ប្រាកដក្នុងអត្ថថា **សោតវិញ្ញាណ** បានក្នុងពាក្យជាដើមថា បានឮសំឡេងដោយសោតៈ ។

ប្រាកដក្នុងអត្ថ **ញាណសោត** បានក្នុងពាក្យជាដើមថា បានព្រួសំឡេងដោយសោតធាតុដែលជាទិព្វ ។

ប្រាកដក្នុងធម៌ទាំង ៥ **មានតណ្ហាជាដើម** បានក្នុងពាក្យជាដើមថា ពាក្យថា ក្រសែពួកណាក្នុងលោក សេចក្ដីថា ក្រសែពួកនេះណា តថាគតប្រាប់ហើយ ពោលហើយ សម្ដែងហើយ បញ្ញត្តិហើយ តែងតាំងហើយ បើកបង្ហាញហើយ ចែកហើយ ធ្វើឲ្យរាក់ឡើងហើយ ប្រកាសហើយ , នេះយ៉ាងណា គឺ ក្រសែតណ្ហា , ក្រសែទិដ្ឋិ , ក្រសែកិលេស , ក្រសែទុច្ចរិត , ក្រសែអវិជ្ជា ។

ប្រាកដក្នុងអត្ថថា **ធារនៃខ្សែទឹក** បានក្នុងពាក្យជាដើមថា ព្រះមានព្រះភាគ បានទតព្រះនេត្រឃើញហើយ នូវកំណាត់ឈើមួយកំណាត់ធំ ត្រូវក្រសែទឹកហូរផាត់នាំទៅកាន់ទន្លេគង្គា ។

ប្រាកដក្នុងអត្ថថា **អរិយមគ្គ** បានក្នុងពាក្យជាដើមថា ម្នាលអាវុសោ ពាក្យនេះជាឈ្មោះរបស់អដ្ឋង្គិកមគ្គដ៏ប្រសើរ គឺ សោតៈ ។

ប្រាកដក្នុងអត្ថថា **ការបន្តនៃចិត្ត** បានក្នុងពាក្យជាដើមថា រមែងដឹងខ្សែវិញ្ញាណរបស់បុរស ដែលដាច់ហើយទាំង ២ ចំណែក គឺ ទាំងដែលមិនតាំងនៅក្នុងលោកនេះ ទាំងដែលមិនតាំងនៅក្នុង បរលោក ។



ក៏ **សោត** សព្ទ ក្នុងទីនេះ គប្បីសំដៅយក **មំសសោត** ។

ឈ្មោះថា **សោតាវធាន** ព្រោះអត្ថថា ចាំទុក កំណត់ទុក តាំងទុកដោយសោតៈនោះ ជាហេតុ ឬជាហេតុឲ្យសម្រេច ។ ឈ្មោះ ថា **សោតាវធាន** នោះដូចម្ដេច ? គឺ **សុត** ។ ក៏ធម្មជាតិដែល ដឹងច្បាស់កំណត់បានតាមគន្លងនៃសោតទ្វារ ឈ្មោះថា **សុត** ដូចក្នុងពាក្យជាដើមថា ជាអ្នកស្ដាប់ច្រើន ជាអ្នកចាំសុតៈ ជាអ្នក សន្សំសុតៈ , សុតៈនុ៎ះ ក្នុងទីនេះលោកពោលថា **សោតាវធាន** ។ បញ្ញាដែលប្រព្រឹត្តទៅក្នុងសុតៈ ពោលគឺ **សោតាវធាន** នោះ ឈ្មោះថា **សោតាវធានេ បញ្ញា** ។

ក៏បទថា **បញ្ញា** បានដល់ បញ្ញាដោយអត្ថថា ជាគ្រឿងធ្វើឲ្យដឹងច្បាស់ ពោលគឺ ជាគ្រឿងធ្វើអត្ថនោះ ៗ ឲ្យប្រាកដ ។ ម្យ៉ាងទៀត ធម្មជាតិណា រមែងដឹងធម៌ទាំងឡាយដោយប្រការនោះ ៗ គឺ ដោយអនិច្ចលក្ខណៈជាដើម ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា បញ្ញា ។

គប្បីជ្រាប **សុត** សព្ទ ទាំងដែលមានឧបសគ្គ និងមិនមាន ឧបសគ្គ ក្នុងពាក្យនេះថា **សុតមយេ ញាណំ** ដូច្នេះ ជាមុន ។

**សុត** ស័ព្ទ រមែងប្រាកដក្នុងអត្ថថា **ទៅ** , **ប្រាកដ** , **ត្រេកអរ** , **ប្រកបរឿយ ៗ** , **សន្សំ** , **សទ្ទារម្មណ៍** , **ដឹងបានតាមគន្លងនៃសោតទ្វារ** ។

ពិតយ៉ាងនោះ **សុត** ស័ព្ទ មានអត្ថថា **ទៅ** បានក្នុងពាក្យជាដើមថា **សេនាយ បសុតោ** សេនាចេញដំណើរទៅ ។

**សុត** ស័ព្ទ មានអត្ថថា **មានធម៌ដែលប្រាកដហើយ** បានក្នុងពាក្យជាដើមថា **សុតធម្មស្ស បស្សតោ** មានធម៌ដែលស្តាប់ហើយ ឃើញហើយ ។

**សុត** ស័ព្ទ មានអត្ថថា **ត្រេកអរ** និង **មិនត្រេកអរ** បានក្នុងពាក្យជាដើមថា **អវស្សុតា អវស្សុតស្ស បុរិសបុគ្គលស្ស** កិក្ខុនី ត្រេកអរហើយ ចំពោះបុរសជាអ្នកដែលមិនត្រេកអរ ។

**សុត** ស័ព្ទ មានអត្ថថា **ប្រកបរឿយ ៗ** បានក្នុងពាក្យជាដើមថា **យេ ឈានបសុតា ធីរា** កុលបុត្រពួកណាប្រកបរឿយ ៗ ក្នុងឈានកុលបុត្រពួកនោះ ឈ្មោះថា អ្នកប្រាជ្ញ ។

**សុត** ស័ព្ទ មានអត្ថថា **សន្សំ** បានក្នុងពាក្យជាដើមថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** បុណ្យមិនមែនតិច ដែលលោកទាំងឡាយសន្សំ



ទុកហើយ ។

**សុត** ស័ព្ទ មានអត្ថថា **សទ្ទារម្មណ៍** បានក្នុងពាក្យជាដើម ថា **ទិដ្ឋំ សុតំ មុតំ វិញ្ញាតំ** រូបដែលយើងឃើញហើយ សំឡេងដែលយើងបានឮហើយ ពួក ៣ នៃអារម្មណ៍ដែលយើងជ្រាបហើយ អារម្មណ៍ដែលដឹងច្បាស់ហើយ ។

**សុត** ស័ព្ទ មានអត្ថថា ចាំទុកនូវសទ្ទារម្មណ៍ដែលដឹងហើយ ដោយគន្លងនៃសោតទ្វារ បានក្នុងពាក្យជាដើមថា **ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ** ជាអ្នកស្តាប់ច្រើន ជាអ្នក ចាំសុតៈ ជាអ្នកសន្សំសុតៈ ។ តែក្នុងទីនេះ **សុត** ស័ព្ទ មានអត្ថថា ដែលខ្លួនដឹងហើយ , ចូលទៅចាំទុកហើយដោយគន្លងនៃសោតទ្វារ ។

បទថា **សុតមយេ ញាណំ** សេចក្តីថា បញ្ញានេះបានប្រារព្ធព្រះសទ្ធម្ម គឺ សុតៈនេះ ដែលដឹងហើយ ចាំទុកល្អហើយ ធ្វើឲ្យជាអារម្មណ៍ ប្រព្រឹត្តទៅហើយក្នុងគ្រាដំបូង និង គ្រាត ៗ មក , បញ្ញាញាណនោះ ក៏លោកពោលហើយថា **សុតមយេ ញាណំ** ញាណដែលសម្រេចហើយដោយការស្តាប់ , អធិប្បាយថា **សុតមយំ ញាណំ** នុ៎ះឯង ។ ក៏ពាក្យថា **សុតមយេ** នេះ ជាបច្ចត្តវចនៈ ,

បច្ចត្តវចនៈ ក្នុងពាក្យជាដើមថា **ន ហេវំ វត្តព្វេ** មិនគប្បីពោលយ៉ាងនោះ , **វនប្បគុម្ពេ យថា ផុស្សិតគ្គេ** គុម្ពឈើក្នុងព្រៃមានចុង គឺផ្ការីកស្គុសស្គាយ , **នត្ថិ អត្តការេ** ការធ្វើរបស់ខ្លួនមិនមាន , **នត្ថិ បុរការេ** ការធ្វើរបស់អ្នកដទៃមិនមាន , **នត្ថិ បុរិសការេ** ការធ្វើរបស់បុរសមិនមាន ដូច្នេះ យ៉ាងណា សូម្បីក្នុងទីនេះ បទថា **សុតមយេ** ក៏គប្បីយល់ដូច្នោះ ។ ព្រោះហេតុនោះ លោកទើបពោលពាក្យថា **សុតមយំ ញាណន្តិ អត្ថោ** អធិប្បាយថា ញាណដែលសម្រេចហើយដោយការស្តាប់ ដូច្នេះ ។

ម្យ៉ាងទៀត ពួកធម៌ដែលមានផស្សៈជាដើម ដែលសម្រេចហើយដោយការស្តាប់ ទើបឈ្មោះថា **សុតមយ** , ញាណប្រព្រឹត្តទៅក្នុងពួកនៃធម៌ដែលឈ្មោះថា សុតមយៈនោះ គឺ សម្បយុត្តជាមួយសុតមយៈនោះ ឈ្មោះថា **សុតមយេ ញាណំ** ។ ញាណនោះឯងលោកពោលថា **បញ្ញា** ព្រោះមិនកំណត់ ក៏ដើម្បីនឹងអធិប្បាយដោយបរិយាយ ក្រោយមកទើបពោលកំណត់ថា **ញាណ** សាធុជនគប្បីជ្រាបតាមដែលពោលមកនេះ ។

ក៏ឈ្មោះថា **ញាណ** មានការចាក់ធ្លុះសភាវៈជាលក្ខណៈ ឬ



មានការចាក់ធ្លុះដោយមិនខុសក្លាត់ ជាលក្ខណៈ ដូចការបាញ់ព្រួញរបស់នាយខ្មាន់ធ្នូដែលធ្លាត បាញ់ទៅហើយ ដូច្នោះ ។

មានការបំភ្លឺនូវអារម្មណ៍ជារសដូចប្រទីបចាំងបំភ្លឺ ដូច្នោះ ។

មានការមិនវង្វេងជាបច្ចុប្បដ្ឋាន ដូចព្រានព្រៃប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ដូច្នោះ ។

មានសមាធិជាបទដ្ឋាន តាមព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តតាំងមាំហើយ រមែងដឹងតាមសេចក្តីពិត ។ ក៏ក្នុងលក្ខណៈជាដើម គប្បីជ្រាបថា សភាវៈក្តី សាមញ្ញៈក្តី ឈ្មោះថា **លក្ខណ** កិច្ចក្តី សម្បត្តិក្តី ឈ្មោះថា **រស** , អាការដែលប្រាកដក្តី ផលក្តី ឈ្មោះថា **បច្ចុប្បដ្ឋាន** , ហេតុជិត ឈ្មោះថា **បទដ្ឋាន** ដូច្នេះ ។

## ២.អដ្ឋកថា សីលមយញ្ញាណុទ្ទេស

### ពោលអំពី សីលមយញ្ញាណ

ពាក្យថា **សុត្វាន សំវរេ បញ្ញា** សេចក្ដីថា ៖

ធម៌ ៥ ប្រការទាំងនេះ គឺ បាតិមោក្ខ ១ សតិ ១ ញាណ១ ខន្តី ១ និង វិរិយៈ ១ លោកសម្ដែងថា **សំវរ** ។

សំវរៈមកហើយដោយន័យជាដើមថា ៖

ជាអ្នកចូលដល់ , ចូលដល់ព្រម , ចូលមក , ចូលមកព្រម , ដល់ហើយ , ដល់ព្រមហើយ , ប្រកបព្រមហើយ ដោយបាតិមោក្ខ-សំវរៈនេះ ឈ្មោះថា **បាតិមោក្ខសំវរ** ។

សំវរៈដែលមកហើយដោយន័យជាដើមថា ៖

ភិក្ខុឃើញរូបដោយចក្ខុហើយ មិនកាន់យកនិមិត្ត មិនកាន់យកអនុព្យញ្ជនៈ , លោករមែងបដិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយ៍ កាលមិនសង្រួមហើយ នឹងជាហេតុឲ្យអកុសលធម៌ដ៏លាមក គឺ អភិជ្ឈា និងទោមនស្សគ្របសង្កត់ ឈ្មោះថា រក្សាចក្ខុន្ទ្រិយ៍ , ឈ្មោះថា ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ៍ ឈ្មោះថា **សតិសំវរ** ។



សំវរៈដែលមកហើយដោយន័យជាដើមថា ៖

ក្រសែទាំងឡាយឯណាក្នុងលោក មានហើយ , សតិជាគ្រឿងបិទក្រសែទាំងនោះ តថាគតពោលសតិថា ជាគ្រឿងបិទក្រសែទាំងឡាយ , ក្រសែទាំងនោះ បណ្ឌិតរមែងបិទបានដោយបញ្ញា ដូច្នេះ ឈ្មោះថា **ញាណសំវរ** ។

សំវរៈដែលមកហើយដោយន័យជាដើមថា ៖

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ពិចារណាដោយល្អហើយ សេពចីវរ ដូច្នេះ ឈ្មោះថា **បច្ចយបដិសេវនាសំវរ** , បច្ចយបដិសេវនាសំវរៈនោះលោកសង្គ្រោះដោយ **ញាណសំវរ**នុ៎ះឯង ។

សំវរៈដែលមកហើយដោយន័យជាដើមថា ៖

ជាអ្នកខំអត់ទ្រាំចំពោះត្រជាក់ ក្ដៅ ឃ្លាន ស្រេក សម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ និងពស់តូច.ពស់ធំ មានជាតិនៃអ្នកអត់ទ្រាំចំពោះពាក្យសំដី ដែលអ្នកដទៃពោលអាក្រក់គ្រោតគ្រាតចំពោះវេទនាមាននៅក្នុងខ្លួន ដែលបង្កើតឡើងជាទុក្ខខ្លាំងក្លា គ្រោត-គ្រាត ក្ដៅរោលរាល មិនជាទីត្រេកអរ មិនជាទីពេញចិត្ត សូម្បីនឹងផ្ដាច់ជីវិតទៅបាន ដូច្នេះ ឈ្មោះថា **ខន្តិសំវរ** ។

សំវរៈដែលមកហើយដោយន័យជាដើមថា ៖

ភិក្ខុ រមែងអត់ទ្រាំ រមែងលះបង់ រមែងបន្ទោបង់កាមវិតក្ក ដែលកើតឡើងហើយ រមែងធ្វើឲ្យអស់ទៅ ឲ្យដល់ការមិនមាន ដូច្នេះ ឈ្មោះថា **វិរិយសំវរ** ។

សំវរៈដែលមកហើយដោយន័យជាដើមថា ៖

ព្រះអរិយសាវកក្នុងព្រះសាសនានេះ លះបង់មិច្ឆាអាជីវៈអស់ហើយ សម្រេចជីវិតនៅដោយសម្មាអាជីវៈ ដូច្នេះ ឈ្មោះថា **អាជីវ-បារិសុទ្ធិសំវរ** , អាជីវបារិសុទ្ធិសំវរៈនោះ លោកសង្គ្រោះដោយវិរិយសំវរៈ នុ៎ះឯង ។

ក្នុងសំវរៈ ៧ ទាំងនោះ សំវរៈ ៤ គឺ បាតិមោក្ខសំវរៈ , ឥន្ទ្រិយសំវរៈ , អាជីវបារិសុទ្ធិសំវរៈ និងបច្ចយបដិសេវនាសំវរៈ , លោកសំដៅយកក្នុងទីនេះ និងក្នុងសំវរៈ ៤ ទាំងនោះ បាតិមោក្ខសំវរៈ លោកសំដៅយកជាពិសេស ។ ក៏សំវរៈនេះ សូម្បីទាំងអស់ លោកហៅថា **សំវរ** ព្រោះទុច្ចរិតទាំងឡាយ មានកាយទុច្ចរិតជាដើម ដែលចាំបាច់ត្រូវសង្រួមតាមធម្មតារបស់ខ្លួន ។

បញ្ញារបស់កុលបុត្រ អ្នកស្តាប់ធម៌តាមដែលពោលហើយ ក្នុង



**សុតមយញ្ញាណ** ហើយសង្រួម ធ្វើការសង្រួម ប្រព្រឹត្តទៅហើយក្នុងការសង្រួមនោះ សម្បយុត្តនឹងសំវរៈនោះ លោកពោលហើយថា **សុត្វាន សំវរេ បញ្ញា** ។ មយ៉ាងទៀត មានសេចក្តីថា បញ្ញាក្នុងការសង្រួម ព្រោះមានការស្តាប់ជាហេតុខ្លះ ព្រោះមានពាក្យថា **ហេតុអត្ថេ សុត្វា** ស្តាប់ហេតុ និងផលប្រាកដ ។

បទថា **សីលំ** ក្នុងពាក្យនេះថា **សីលមយេ ញាណំ** សេចក្តីថា ឈ្មោះថា សីល ព្រោះអត្ថថា សង្រួម , ឈ្មោះថា ការសង្រួម នេះដូចម្តេច ? គឺ ការតាំងមាំ , អធិប្បាយថា ភាពមានកាយកម្មជាដើមមិនប្រេងប្រេងដោយអំណាចនៃភាពជាអ្នកសង្រួមដោយល្អ ។ ឬការចូលទៅតាំងមាំ , អធិប្បាយថា ភាវៈនៃកុសលធម៌ទាំងឡាយជាទីគាំទ្រ ដោយអំណាចជាទីតាំង ។

ក៏ក្នុងសីលនេះ អ្នកប្រាជ្ញដែលយល់ដឹងលក្ខណៈសព្ទ បានដឹងតាម ៗ គ្នាមកនូវអត្ថតែ ២ ប៉ុណ្ណោះ ។ តែអាចារ្យពួកដទៃពណ៌នាថា ឈ្មោះថា សីល ព្រោះអត្ថថា សេព ព្រោះអត្ថថា ជាទីរ៉ាប់រង ព្រោះអត្ថថា ជាប្រក្រតី ព្រោះអត្ថថា ជាសីរសៈ ព្រោះអត្ថថា ត្រជាក់ ព្រោះអត្ថថា ក្សេម ។

សីលនោះ សូម្បីនឹងមានប្រភេទផ្សេង ៗ ច្រើនយ៉ាង ក៏មានការសង្រួមជាលក្ខណៈ ដូចរូបមានប្រភេទផ្សេង ៗ ដ៏ច្រើនក៏មានការឃើញបានដោយភ្នែកជាលក្ខណៈ ដូច្នោះ ។ ដូចជារូបាយតនៈ សូម្បីមានប្រភេទផ្សេង ៗ ដ៏ច្រើនដោយប្រភេទនៃពណ៌ មានខៀវ និងពណ៌លឿងជាដើម ក៏មានការឃើញដោយភ្នែកជាលក្ខណៈ ព្រោះមិនឈានកន្លងភាវៈនៃរូបាយតនៈមានប្រភេទផ្សេង ៗ ដោយប្រភេទនៃពណ៌ មានពណ៌ខៀវជាដើម ក៏ជារូបាយតនៈដែលឃើញបានដោយភ្នែកយ៉ាងណា , ការសង្រួមនៃសីល សូម្បីមានប្រភេទផ្សេង ៗ ច្រើនយ៉ាង ដោយប្រភេទនៃវិរតិ មានចេតនាវិរតិជាដើម លោកពោលហើយថា ជាទីទទួលទុកនូវកាយកម្មជាដើម និងជាទីតាំងនៃកុសលធម៌នេះបាន , ការសង្រួមនោះនុ៎ះឯង ជាលក្ខណៈរបស់សីល សូម្បីមានប្រភេទផ្សេង ៗ ច្រើនយ៉ាង ដោយប្រភេទនៃវិរតិ មានចេតនាវិរតិជាដើម ព្រោះមិនឈានកន្លងភាពជាទីទទួលទុក និងជាទីតាំង ។

ក៏ការកម្ចាត់ភាពជាអ្នកទ្រុស្តសីល និងគុណ គឺ ការមិនមានទោស លោកហៅថា ជារស ព្រោះអត្ថថា ជាកិច្ច និងសម្បត្តិរបស់



សីលនោះ មានលក្ខណៈដូចដែលពោលមកហើយយ៉ាងនេះ ។

ព្រោះដូច្នោះ ធម្មតាថា សីលនេះ បណ្ឌិតគប្បីជ្រាបថា មានការកម្ចាត់ភាពជាអ្នកទ្រុស្តសីលជារស ព្រោះរសមានអត្ថថា កិច្ច , មានការមិនមានទោស ជារស ព្រោះរសមានអត្ថថា សម្បត្តិ ។

សីលនេះនោះ វិញ្ញូជនទាំងឡាយពណ៌នាទុកថា មានសេចក្តីស្អាតជាបច្ចុប្បដ្ឋាន មានឱត្តប្បៈ និងហិរិ ជាបទដ្ឋាននៃសីលនោះ ។

សីលនេះនោះ មានភាពល្អស្អាតជាបច្ចុប្បដ្ឋាន តាមដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកយ៉ាងនេះថា សេចក្តីស្អាតកាយ , ស្អាតវាចា , ស្អាតចិត្ត រមែងដល់នូវការរាប់ថា ប្រាកដដោយភាពជារបស់ស្អាត ។ ចំណែកហិរិ និងឱត្តប្បៈ វិញ្ញូជនទាំងឡាយពណ៌នាទុកថា ជាបទដ្ឋានរបស់សីលនោះ , អធិប្បាយថា ជាហេតុជិត ។ ព្រោះកាលបើហិរិ និងឱត្តប្បៈមាន សីលក៏រមែងកើតឡើង និងតាំងនៅ , កាលបើហិរិ និងឱត្តប្បៈមិនមាន សីលក៏រមែងមិនកើតឡើង និងមិនតាំងនៅ ដូច្នោះ ញាណដែលសហគតៈដោយសីល សម្បយុត្តដោយសីលនោះ ដោយវិធីដែលពោលមកហើយយ៉ាងនេះ ឈ្មោះថា **សីលមយេ ញាណំ** ម្យ៉ាងទៀត សីលនោះឯង

សម្រេចហើយ ឈ្មោះថា សីលមយៈ , ញាណក្នុងសីលមយៈនោះ គឺ សម្បយុត្តដោយសីលមយៈនោះ ។

ការពិចារណាទោសក្នុងការមិនសង្រួម ១ , ការពិចារណាអានិសង្សក្នុងការសង្រួម ១ , ការពិចារណាសេចក្តីបរិសុទ្ធិក្នុងការសង្រួម ១ , ការពិចារណាសេចក្តីស្អាតចាកសង្កិលេស ព្រោះការសង្រួម ១ លោកសង្គ្រោះដោយ **សីលមយញ្ញាណ** នុ៎ះឯង ។



## ៣. អដ្ឋកថា សមាធិភាវនាមយញ្ញាណុទ្ទេស

### ពោលអំពី សមាធិភាវនាមយញ្ញាណ

ពាក្យថា **សំវរិត្វា សមាទហនេ បញ្ញា** សេចក្តីថា បញ្ញារបស់កុលបុត្រដែលសង្រួមដោយសីលសំវរៈ តាមដែលពោលទុកក្នុងសីលមយញ្ញាណ ហើយធ្វើការសង្រួមតាំងនៅក្នុងសីលមានចិត្តតាំងទុកដោយល្អ ធ្វើចិត្តឲ្យមានអារម្មណ៍តែមួយ ដោយអំណាចនៃឧបចារសមាធិ និងអប្បនាសមាធិ ប្រព្រឹត្តទៅហើយក្នុងសមាធិចិត្តនោះ គឺ សម្បយុត្តជាមួយសមាធិចិត្តនោះ ។ ការតំកល់ទុក តាំងទុកដោយល្អប្រពៃ ដូច្នោះ ទើបឈ្មោះថា **សមាទហនំ** ការតាំងទុកដោយល្អ , ពាក្យនេះ ជាពាក្យហៅសមាធិ ដោយបរិយាយ ។

កុសលចិត្តឯកគ្គតា ឈ្មោះថា **សមាធិ** ក្នុងពាក្យនេះថា **សមាធិភាវនាមយេ ញាណំ** ឈ្មោះថា សមាធិ ព្រោះអត្ថថាអ្វី ? ឈ្មោះថា សមាធិ ព្រោះអត្ថថា តាំងមាំ ( **សមាធានំ** ) ។ ឈ្មោះថា សមាធាននេះ ដូចម្តេច ? មានពាក្យអធិប្បាយថា ការតំកល់ ការតាំងនូវចិត្ត និងចេតសិក ទុកក្នុងអារម្មណ៍តែមួយដោយប្រពៃ ដោយល្អ

ព្រោះដូច្នេះ ចិត្ត និងចេតសិក មិនរាយមាយ មិនខ្វាត់ខ្វាយ តាំងនៅដោយប្រពៃ ដោយល្អក្នុងអារម្មណ៍តែមួយ ដោយអានុភាពនៃធម៌ណា , ពាក្យដែលពោលមកហើយនេះ គប្បីជ្រាបថាជា **សមាធាន** ។

ក៏សេចក្ដីមិនរាយមាយជាលក្ខណៈ ការកម្ចាត់សេចក្ដីរាយមាយជារស ការមិនញាប់ញ័រជាបច្ចុប្បដ្ឋាន និងមានសេចក្ដីសុខជាបទដ្ឋានរបស់សមាធិនោះឯង ។

ធម្មជាតិណាដែលព្រះយោគីបុគ្គលអប់រំចម្រើនហើយ ដូច្នេះ ធម្មជាតិនោះ ឈ្មោះថា **ភាវនា** , ភាវនា គឺ **សមាធិ** ឈ្មោះថា សមាធិភាវនា ។ ម្យ៉ាងទៀត ការអប់រំចម្រើនសមាធិ ឈ្មោះថា **សមាធិភាវនា** , ហាមសមាធិដទៃ ដោយពាក្យថា សមាធិភាវនា ។ ញាណដែលសម្រេចដោយសមាធិភាវនា ដោយអំណាចនៃឧបចារសមាធិ និងអប្បនាសមាធិ ដូចពោលមកអំពីមុន ។



# ៤. អដ្ឋកថា ធម្មដ្ឋិតិញ្ញាណុទ្ទេស

## ពោលអំពី ធម្មដ្ឋិតិញ្ញាណ

ឈ្មោះថា បច្ច័យ ក្នុងពាក្យថា **បច្ចយបរិគ្គហេ បញ្ញា** មានវចនត្ថៈថា ផលរមែងអាស្រ័យធម៌នោះកើត ដូច្នោះ ធម៌នោះ ឈ្មោះថា បច្ច័យ ។

ពាក្យថា **បដិច្ច** បានដល់ មិនវៀរពីធម៌ដែលជាបច្ច័យនោះ អធិប្បាយថា អាស្រ័យបច្ច័យ ។ បទថា **ឯតិ** សេចក្ដីថា រមែងកើតឡើងផង រមែងប្រព្រឹត្តឲ្យទៅផង ។ ម្យ៉ាងទៀត មានសេចក្ដីថា ឧបការៈ មានអត្ថថា ជាដែនកើត , បញ្ញាក្នុងការកំណត់ គឺ កំណត់បាននូវបច្ច័យទាំងឡាយ ព្រោះបច្ច័យនោះមានច្រើនយ៉ាង ឈ្មោះថា **បច្ចយបរិគ្គហេ បញ្ញា** ប្រែថា បញ្ញាជាគ្រឿងកំណត់បច្ច័យ ។

**ធម្ម** ស័ព្ទ ក្នុងបទថា **ធម្មដ្ឋិតិញ្ញាណំ** នេះ រមែងប្រាកដក្នុងអត្ថថា សភាវៈ , បញ្ញា , បុញ្ញ , បញ្ញត្តិ , អាបត្តិ , បរិយត្តិ , និស្សត្តតា , វិការៈ , គុណ , បច្ច័យ , បច្ចយុប្បន្ន ជាដើម ។

ក៏ **ធម្ម** ស័ព្ទនេះ រមែងប្រាកដក្នុងអត្ថថា **សភាវ** បានក្នុងតិកៈថា **កុសលា ធម្មា** សភាវធម៌ទាំងឡាយដែលជាកុសល ,

**អកុសលា ធម្មា** សភាវធម៌ទាំងឡាយដែលជាអកុសល , **អព្យាកតា ធម្មា** សភាវធម៌ទាំងឡាយដែលជាអព្យាកតៈ ។

**ធម្ម** ស័ព្ទ រមែងប្រាកដក្នុងអត្ថថា **បញ្ញា** បានក្នុងពាក្យជាដើមថា បុគ្គលណាដែលនៅគ្រប់គ្រងផ្ទះប្រកបដោយសទ្ធា **មានធម៌ ៤ ប្រការទាំងនេះ** គឺ សច្ចៈ , ធម្មៈ , ធិតិ និងចាគៈ បុគ្គលនោះឯង លះលោកនេះទៅហើយ រមែងមិនសោយសោក ដូច្នេះ ។

**ធម្ម** ស័ព្ទ រមែងប្រាកដក្នុងអត្ថថា **បុញ្ញ** បានក្នុងពាក្យជាដើមថា ធម៌ និងអធម៌ទាំង ២ នេះ មានផលស្មើគ្នាមិនបានឡើយ អធម៌រមែងនាំទៅនរក ធម៌រមែងឲ្យដល់សុគតិ ដូច្នេះ ។

**ធម្ម** ស័ព្ទ រមែងប្រាកដក្នុងអត្ថថា **បញ្ញត្តិ** បានក្នុងពាក្យជាដើមថា បញ្ញត្តិធម៌ , និរុត្តិធម៌ , អធិវចនធម៌ ដូច្នេះ ។

**ធម្ម** ស័ព្ទ រមែងប្រាកដក្នុងអត្ថថា **អាបត្តិ** បានក្នុងពាក្យជាដើមថា ធម៌ គឺ បារាជិក ធម៌ គឺ សង្ឃាទិសេស ដូច្នេះ ។

**ធម្ម** ស័ព្ទ រមែងប្រាកដក្នុងអត្ថថា **បរិយត្តិ** បានក្នុងពាក្យជាដើមថា ភិក្ខុក្នុងធម្មវិន័យ រមែងរៀនធម៌ គឺ សុត្តៈ , គេយ្យៈ , វេយ្យាករណៈ ដូច្នេះ ។



**ធម្ម** ស័ព្ទ ប្រាកដក្នុងអត្ថថា **និស្សត្តតា** ភាពមិនមែនសត្វ បានក្នុងពាក្យជាដើមថា ក៏សម័យនោះឯង ធម៌ទាំងឡាយរមែងមាន , និងក្នុងពាក្យជាដើមថា ព្រះយោគីបុគ្គល តាមពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ដូច្នេះ ។

**ធម្ម** ស័ព្ទ រមែងប្រាកដក្នុងអត្ថថា **វិការ** ធម្មជាតិដែលប្រែប្រួល បានក្នុងពាក្យជាដើមថា ជាតិធម៌ ជរាធម៌ មរណៈធម៌ ដូច្នេះ ។

**ធម្ម** ស័ព្ទ ប្រាកដក្នុងអត្ថថា **គុណ** បានក្នុងពាក្យជាដើមថា ពុទ្ធធម៌ ៦ .... ដូច្នេះ ។

**ធម្ម** ស័ព្ទ ប្រាកដក្នុងអត្ថថា **បច្ច័យ** បានក្នុងពាក្យជាដើមថា បញ្ញាបែកធ្លាយក្នុងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា ដូច្នេះ ។

**ធម្ម** ស័ព្ទ ប្រាកដក្នុងអត្ថថា **បច្ចយុប្បន្ន** បានក្នុងពាក្យជាដើមថា ធាតុនោះ តាំងនៅហើយ ឈ្មោះថា ធម្មដ្ឋិតិ ធម្មនិយាម ដូច្នេះ ។

**ធម្ម** ស័ព្ទនេះនោះ គប្បីឃើញថា ចុះក្នុងអត្ថថា **បច្ចយុប្បន្ន** ប្រែថា ធម៌ដែលកើតពីបច្ច័យ ។ ដោយអត្ថ លោកហៅថា ធម្មៈ ព្រោះទ្រទ្រង់ទុកនូវសភាវៈរបស់ខ្លួន ឬដែលបច្ច័យទ្រទ្រង់ទុក , ឬ

រមែងទ្រទ្រង់ទុកនូវផលរបស់ខ្លួន , ឬអ្នកណាបំពេញធម៌ឲ្យបរិបូរ ធម៌ក៏ទ្រទ្រង់អ្នកនោះទុក មិនឲ្យធ្លាក់ទៅក្នុងអបាយទាំងឡាយ , ឬទ្រទ្រង់ទុកក្នុងលក្ខណៈរបស់ខ្លួន ៗ , ឬថា រមែងតាំងទុកបានដោយចិត្ត , តាមសមគួរ ។ តែក្នុងទីនេះ ឈ្មោះថា **ធម៌** ព្រោះអត្ថថា ដែលបច្ច័យទាំងឡាយរបស់ខ្លួន ទ្រទ្រង់ទុក , ធម៌ទាំងឡាយអាស្រ័យបច្ច័យកើតឡើង រមែងតាំងឡើង គឺ រមែងកើតឡើងផង រមែងប្រព្រឹត្តទៅផងដោយធម្មជាតិណា ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា ធម្មដ្ឋិតិ , ពាក្យនេះជាឈ្មោះរបស់បច្ច័យធម៌ទាំងឡាយ , ញាណក្នុងធម្មដ្ឋិតិនោះ ឈ្មោះថា **ធម្មដ្ឋិតិញ្ញាណ** ។

ក៏ធម្មដ្ឋិតិញ្ញាណនេះ មានបរិយាយនៃការកំណត់បច្ច័យនៃនាមរូបទាំងឡាយទាំងនោះ រមែងកើតឡើងដល់ព្រះយោគីបុគ្គល អ្នកប្រារព្ធសេចក្ដីព្យាយាមដើម្បីយថាភូតញ្ញាណទស្សនៈ ដោយចិត្តដែលតាំងមាំដោយសមាធិ តាមដែលពោលមកហើយក្នុងសមាធិភាវនា-មយញ្ញាណ ហើយកំណត់នាមរូប ។

ប្រសិនបើនឹងមានបុច្ឆាថា ញាណនេះ ដូចម្ដេចលោកមិនពោលថា **នាមរូបវវត្ថានញ្ញាណ** តែម្យ៉ាង តែត្រឡប់ជាពោលថា



ធម្មដ្ឋិតិញ្ញាណវិញ ? ក៏មានវិសជ្ជនាថា ព្រោះការកំណត់ធម៌ដែលអាស្រ័យបច្ច័យកើតឡើង សុទ្ធតែសម្រេចដោយការកំណត់បច្ច័យ តែម្យ៉ាង ។ ព្រោះថា ធម៌ដែលអាស្រ័យបច្ច័យកើតឡើង ដែលព្រះយោគីបុគ្គលមិនបានកំណត់ហើយ ក៏មិនអាចនឹងធ្វើការកំណត់បច្ច័យបាន ។ ព្រោះដូច្នោះ គប្បីជ្រាប នាមរូបវវត្ថានញ្ញាណ ដែលជាហេតុនៃបច្ចយបរិគ្គហញ្ញាណនោះ សម្រេចហើយក្នុងកាលមុន ក៏រមែងជាញាណដែលលោកពោលហើយដោយស័ព្ទថា **ធម្មដ្ឋិតិញ្ញាណ** នុ៎ះឯង ។

ប្រសិនបើមានពាក្យសួរថា ព្រោះហេតុអ្វី លោកនឹងមិនពោល **សមាទហិត្វា បច្ចយបរិគ្គហេ បញ្ញា** ប្រែថា បញ្ញាក្នុងការកំណត់បច្ច័យ ព្រោះមានចិត្តតាំងមាំ ដូចញាណទី ១ និងញាណទី ២ ហ្ន៎ ? ឆ្លើយថា ព្រោះសមថៈ និងវិបស្សនា ជាធម៌គូគ្នា ។

សមពិតដូចគាថាប្រព័ន្ធ ដែលបុរាណាចារ្យបានពោលទុកថា

**ប្រសិនបើ ព្រះយោគីបុគ្គលមានចិត្តតាំងមាំ**
**រមែងឃើញច្បាស់បាន ដោយប្រការណា**
**សោត និងប្រសិនបើព្រះយោគីបុគ្គលកាល**

យើញច្បាស់ រមែងមានចិត្តតាំងមាំដោយ
ប្រការនោះ , ក្នុងកាលនោះ វិបស្សនា
និង សមថៈជាធម៌មានចំណែកស្មើគ្នា ជា
ធម៌គូគ្នា ប្រព្រឹត្តទៅ ។

ព្រោះដូច្នោះ គប្បីជ្រាបថា លោកពោលថា **បច្ចយបរិគ្គហេ បញ្ញា ធម្មដ្ឋិតិញ្ញាណំ** ប្រែថា បញ្ញាក្នុងការកំណត់បច្ច័យ ជាធម្មដ្ឋិតិញ្ញាណ ដូច្នេះទុក ក៏ដើម្បីនឹងឲ្យយល់ថា ដរាបណាដែលអរិយមគ្គនៅមិនទាន់បានលះ សមាធិ ធ្វើសមាធិ និងបញ្ញា ឲ្យជាធម៌គូគ្នា , ព្រះយោគីបុគ្គលក៏ចាំបាច់ខ្វល់ខ្វាយដរាបនោះ ។



## ៥. អដ្ឋកថា សម្មសនញ្ញាណុទ្ទេស

### ពោលអំពី សម្មសនញ្ញាណ

ឈ្មោះថា **អតីត** ព្រោះអត្ថថា ដល់ហើយដល់ស៊ប់ហើយ ឈានកន្លងហើយនូវសភាវៈរបស់ខ្លួន ឬខណៈ មានឧប្បាទ-ខណៈជាដើម , ឈ្មោះថា **អនាគត** ព្រោះអត្ថថា មិនទាន់មកដល់ មិនដល់ព្រមហើយ សូម្បីនូវសភាវៈរបស់ខ្លួន និងខណៈ មានឧប្បាទ-ខណៈជាដើម ទាំង ២ នោះ ។ ឈ្មោះថា **បច្ចុប្បន្ន** ព្រោះអត្ថថា សម្រេចហើយ ដល់ហើយ ប្រព្រឹត្តទៅហើយ ព្រោះអាស្រ័យហេតុនោះ ៗ រហូតកន្លងខណៈ មានឧប្បាទខណៈជាដើម ក្នុងពាក្យនេះថា **អតីតានាគតបច្ចុប្បន្នានំ ធម្មានំ សង្ខិបិត្វា វវត្ថានេ បញ្ញា** ។ ក្នុងកាល ក្នុងខណៈបន្ត និងក្នុងបច្ចុប្បន្ន ក្នុងទីនេះបំណងយកបច្ចុប្បន្នសន្តតិ គឺ បច្ចុប្បន្នដែលកំពុងបន្ត ។ បញ្ញា ក្នុងការរួបរួមយកធម៌ គឺ ខន្ធ ៥ ដែលជាអតីត អនាគត បច្ចុប្បន្នទាំងនោះចូលទុកក្នុងខន្ធមួយ ៗ ហើយធ្វើឲ្យជាក្រុម ដោយអំណាចកលាបៈ គឺពួកក្រុម ហើយកំណត់វិនិច្ឆ័យកាត់ក្តីបាន ។

ញាណ គឺ បញ្ញាក្នុងការពាល់ត្រូវ សំរិតសំរាំង សម្ទឹង ពិនិត្យដោយល្អ អធិប្បាយថា ញាណក្នុងការពិចារណាក្នុងបញ្ចក្ខន្ធ ដោយភាពជាពួកក្រុម ឈ្មោះថា **សម្មសនេ ញាណំ** ប្រែថា ញាណក្នុងការពិចារណាបញ្ចក្ខន្ធ ។

ពិតហើយ **កលាបសម្មសនញ្ញាណ** នេះ រមែងកើតដល់ព្រះយោគីបុគ្គល អ្នកបានធម្មដ្ឋិតិញ្ញាណជាគ្រឿងកំណត់បច្ច័យរបស់នាមរូប ក្នុងលំដាប់នៃនាមរូបវវត្ថានញ្ញាណ លើកយកខន្ធមួយ ៗ ដែលកំណត់ទុកហើយក្នុងកាលមុន ឡើងកាន់ត្រៃលក្ខណ៍ ហើយឃើញច្បាស់ដោយភាពជា អនិច្ចំ ទុក្ខំ អនត្តា ដោយអំណាចនៃការពិចារណាតាមដែលពោលហើយ ដោយន័យនៃព្រះបាលីជាដើមថា ៖

ព្រះយោគីបុគ្គលដែលកំណត់រូបណាមួយ ទាំងដែលជាអតីតៈ អនាគត និងបច្ចុប្បន្ន ជាខាងក្នុងក្តី ខាងក្រៅក្តី គ្រោតគ្រាតក្តី ថោកទាបក្តី ប្រណីតក្តី មានក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី ដោយភាពជារបស់មិនទៀង ការកំណត់នេះ ជាសម្មសនញ្ញាណប្រការមួយ , កំណត់ដោយភាពជាទុក្ខ ការកំណត់នេះជាសម្មសនញ្ញាណប្រការមួយ , កំណត់ដោយភាពជាអនត្តា ការកំណត់នេះ ក៏ជាសម្មសនញ្ញាណប្រការមួយ ។



# ៦. អដ្ឋកថា ឧទយព្វយានុបស្សនាញាណុទ្ទេស

## ពោលអំពី ឧទយព្វយានុបស្សនាញាណ

ពាក្យថា **បច្ចុប្បន្នានំ ធម្មានំ វិបរិណាមានុបស្សនេ បញ្ញា** សេចក្តីថា បញ្ញាក្នុងការឃើញភាពប្រែប្រួល គឺ ការរលត់ទៅនៃធម៌ គឺ បញ្ចក្ខន្ធក្នុងខាងក្នុង ដែលជាបច្ចុប្បន្នដោយអំណាចសន្តតិ ។ ចិត្តសូម្បីកំណត់ការកើតឡើងថា ធម៌ទាំងឡាយនេះលុះកើតឡើងហើយ ក៏រមែងរលត់ទៅ ដូច្នេះ ក៏ឈ្មោះថា ត្រូវតាំងនៅក្នុងការបែកធ្លាយទៅដូចគ្នា , ព្រោះដូច្នោះគប្បីជ្រាបថា ការកើតឡើង សូម្បីមិនបានពោលទុកហើយ ក៏ដូចជាពោលទុកដូចគ្នា ។ ម្យ៉ាងទៀត ការកើតឡើងនៃបច្ចុប្បន្នធម៌ទាំងឡាយ រមែងជាការពោលហើយ ដោយទស្សនៈ ព្រោះសម្រេចការឃើញនូវភាពកើតឡើង ។

ពិតហើយ វៀរឧទយៈ គឺ ការកើតឡើងចេញ ការកើតឡើងនៃធម៌ទាំងឡាយ ក៏រមែងមិនសម្រេច , ព្រោះដូច្នោះ សូម្បីកាលមិនពោលថា បញ្ញាក្នុងការតាមឃើញការកើតឡើង និងការប្រែប្រួលទៅនៃបច្ចុប្បន្នធម៌ទាំងឡាយ ក៏គប្បីជ្រាបថា ដូចដែលពោល

ហើយដូចគ្នា ។

**ឧទយព្វយានុបស្សនាញាណ** កើតដល់ព្រះយោគីបុគ្គលអ្នកសម្រេចសម្មសនញ្ញាណ តាមដែលបានពោលហើយក្នុងលំដាប់ថាក៏ការឃើញការកើតឡើង រមែងសម្រេច ព្រោះពាក្យនោះកំណត់តាមព្រះបាលីថា **ឧទយព្វយានុបស្សនេ ញាណំ** ប្រែថា បញ្ញាក្នុងការតាមឃើញការកើតឡើង និងការរលត់ទៅ ដូច្នេះហើយក៏កំណត់ការកើតឡើង និងការរលត់ទៅក្នុងសង្ខារធម៌ ដែលកំពុងប្រាកដក្នុងសម្មសនញ្ញាណនុ៎ះឯង ហើយប្រារព្ធឧទយព្វយានុបស្សនាដើម្បីធ្វើការកំណត់សង្ខារធម៌ទាំងឡាយ ។ ព្រោះញាណនោះលោកហៅថា **ឧទយព្វយានុបស្សនា** ព្រោះតាមឃើញការកើត និងការរលត់ ។



## ៧. អដ្ឋកថា វិបស្សនាញាណុទ្ទេស

### ពោលអំពី វិបស្សនាញាណ

ពាក្យថា **អារម្មណំ បដិសង្ខា** សេចក្ដីថា ដឹង ឃើញអារម្មណ៍ មានរូបក្ខន្ធជាដើម , ព្រោះពិចារណាដោយភាពជាភង្គៈ គឺ បែកធ្លាយទៅ ។

ពាក្យថា **ភង្គានុបស្សនេ បញ្ញា វិបស្សនេ ញាណំ** សេចក្ដីថា បញ្ញាណាដឹងក្នុងការតាមឃើញការរលត់នៃញាណដែលកើតឡើងហើយ ព្រោះពិចារណាអារម្មណ៍របស់ញាណនោះដោយភាពជាភង្គៈ គឺ បែកធ្លាយទៅ , ញាណនោះ លោកពោលថា **វិប-ស្សនេ ញាណំ** ប្រែថា ញាណក្នុងវិបស្សនា ។

បទថា **វិបស្សនា** បានដល់ ឃើញ ឃើញច្បាស់ ដោយប្រការផ្សេងៗ ។ បាឋៈថា **អារម្មណបដិសង្ខា** ដូច្នេះ ក៏មាន ។

ខ្លឹមសារនៃវិបស្សនាញាណនោះ មានដូចតទៅនេះ ៖

ពាក្យថា បញ្ញាក្នុងការពិចារណាអារម្មណ៍ហើយពិចារណាឃើញការបែកធ្លាយទៅ ជាវិបស្សនាញាណ លោកពោលទុកហើយ

ព្រោះពិចារណាអារម្មណ៍ ដោយន័យតាមដែលពោលទុកហើយថាការពិចារណា ការដឹង ការឃើញនូវអារម្មណ៍ ។ ក៏វិបស្សនារមែងដល់កំពូលនៃភង្គានុបស្សនាទុំះឯង ព្រោះដូច្នោះ លោកទើបពោលពាក្យនេះទុកជាពិសេសថា **វិបស្សនេ ញាណំ** ប្រែថា ញាណក្នុងវិបស្សនា ។

មគ្គាមគ្គញាណទស្សនៈ រមែងកើតដល់ព្រះយោគីបុគ្គលអ្នកបានឧទយព្វយានុបស្សនាញាណ , ព្រោះដូច្នោះ កាលឧទយព្វយានុបស្សនាសម្រេចហើយ មគ្គាមគ្គញាណទស្សនៈនោះ ក៏រមែងសម្រេចដែរ ពាក្យនោះលោកមិនបានទុកឡើយ គប្បីជ្រាបថា ញាណមានវិបស្សនាជាកំពូល លោកពោលទុកហើយ ដោយភង្គានុបស្សនាញាណ ។

កាលសង្ខារទាំងឡាយ ដែលព្រះយោគីបុគ្គលទាំងឡាយអ្នកកំណត់នូវឧទយព្វយៈដែលខ្លួនឃើញច្បាស់ហើយ ដោយឧទយព្វយានុបស្សនាហើយ ក៏ប្រាកដឡើងដោយមួយរំពេចតែម្តង កាលញាណចាស់ក្លាហើយ សតិក៏លះឧទយៈ គឺ ការកើត ហើយតាំងនៅក្នុងភង្គៈ ការរលត់តែម្យ៉ាង , ភង្គានុបស្សនាញាណ ក៏រមែងកើតឡើងបានក្នុងឋានៈនេះដល់ព្រះយោគីបុគ្គលនោះ អ្នកដែលបានឃើញថា ធម្មតាសង្ខារទាំងឡាយកើតឡើងហើយយ៉ាងនេះ ក៏រមែងរលត់ទៅយ៉ាងនេះ ។



# ៨. អដ្ឋកថា អាទីនវញ្ញាណុទ្ទេស

## ពោលអំពី អាទីនវញ្ញាណ

ពាក្យថា **ភយតូបដ្ឋានេ បញ្ញា** មានសេចក្តីថា បញ្ញាក្នុងការប្រាកដឡើងនៃឧប្បាទៈ ( ការកើត ) បវត្តៈ ( ការប្រព្រឹត្តទៅ ) និមិត្ត ( គ្រឿងសម្គាល់ ) អាយូហនា ( ការប្រមូលមក ) និងបដិសន្ធិ ( ការកើត ) ក្នុងភពថ្មី ដោយសេចក្តីជាភ័យ គឺ ក្នុងការចូលទៅកំណត់ថា មានភ័យប្រាកដនៅចំពោះមុខ ដោយការប្រកបសេចក្តីបៀតបៀនជារឿយ ៗ ។ រមែងប្រាកដដោយភាពជាភ័យ ដូច្នោះទើបឈ្មោះថា **ភយតូបដ្ឋាន** គឺ អារម្មណ៍ ។ បញ្ញាក្នុងភយតូបដ្ឋាននោះ ។ ម្យ៉ាងទៀត ឈ្មោះថា ភយតូបដ្ឋាន គឺ បញ្ញា ព្រោះអត្ថថា ប្រាកដដោយភាពជាភ័យ ពាក្យនោះរមែងជាពាក្យអធិប្បាយ ដែលលោកពោលហើយថា **ភយតូបដ្ឋាន** ។

ពាក្យថា **អាទីនវេ ញាណំ** ជាកុម្មវចនៈ គឺ សត្តមីវិភត្តិ ។ ព្រោះព្រះធម្មសេនាបតីសារីបុត្របានពោលទុកថា ធម៌ទាំងនោះ គឺ បញ្ញាក្នុងការប្រាកដដោយភាពជាភ័យ ១ , អាទីនវញ្ញាណ ១ ,

និព្វិទាញាណ ១ , មានអត្ថដូចគ្នា ខុសគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។

សូម្បី ពោលត្រឹមតែពាក្យមួយ ( ញាណមួយ ) ក៏រមែងជាការពោលទាំង ៣ ដោយប្រភេទនៃការកំណត់ ដូចមុញ្ចិតុកម្យតាញាណជាដើម ដូច្នោះ សូម្បីមិនពោលថា កាលភយតូបដ្ឋាន និងអាទីនវានុបស្សនាសម្រេចហើយ និព្វិទានុបស្សនា ក៏រមែងសម្រេច ដូច្នេះ ក៏គប្បីជ្រាបថា គឺ ជាការពោលហើយតែម្តង ។

សង្ខារទាំងឡាយ ដែលចែកទុកក្នុងភព ៣ , កំណើត ៤ , គតិ ៥ , វិញ្ញាណឋិតិ ៧ និងសត្តាវាស ៩ រមែងប្រាកដជាមហាភ័យដល់ព្រះយោគីបុគ្គលអ្នកចម្រើន ធ្វើឲ្យច្រើននូវភង្គានុបស្សនាមានការរលត់ទៅនៃសង្ខារទាំងពួងជាអារម្មណ៍ ដូចជាសីហៈ , ខ្លាដំបង , ខ្លាធំ , ខ្លាឃ្មុំ , ខ្លារខិន , យក្ស , អារក្សទឹក , គោកាច , ឆ្កែកាច , ដំរីចុះប្រេង , ពស់កាច , ព្រៃស្មសាន , សមរភូមិ , រណ្តៅរងើកភ្លើងដែលឆេះសន្ធោសន្ធៅជាដើម រមែងប្រាកដជាភ័យធំដល់បុរសអ្នកខ្លាចភ័យចង់រស់នៅជាសុខ , ភយតូបដ្ឋានញាណរមែងកើតឡើងបានក្នុងឋានៈនេះដល់ព្រះយោគីបុគ្គលអ្នកបាន ឃើញថា សង្ខារទាំងឡាយក្នុងអតីតៈក៏រលត់ទៅហើយ , បច្ចុប្បន្ន ក៏កំពុង



រលត់ សូម្បីអនាគតក៏នឹងរលត់ទៅយ៉ាងនេះ ដូចគ្នា ។

ក្នុងភព , កំណើត , គតិ , ឋិតិ និងសត្តាវាស ទូទៅគ្រប់ទីកន្លែង ទីទប់ទល់ ទីលាក់ ទីពួន ទីទៅ ទីពឹង រមែងមិនប្រាកដឡើយដល់ព្រះយោគីបុគ្គលអ្នកសេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ នូវភយតូបដ្ឋានញាណនោះ , សេចក្តីប្រាថ្នាក្តី សេចក្តីប្រកាន់មាំក្តី រមែងមិនមានក្នុងសង្ខារទាំងឡាយ ដែលមានក្នុងភព , កំណើត , គតិ , ឋិតិ , និវាសៈ , សូម្បីតែសង្ខារមួយ , ភពទាំង ៣ ប្រាកដដូចជារណ្តៅរងើកភ្លើងដែលពេញដោយរងើកភ្លើង មិនមានអណ្តាត , មហាភូតរូប ៤ ប្រាកដដូចអសិរពិសដែលមានពិសដ៏សាហាវពន្លឹក , ខន្ធ ៥ ប្រាកដដូចពេជ្ឈឃាតដែលកំពុងយាដាវ , អជ្ឈត្តិកាយតនៈ ៦ ប្រាកដដូចផ្ទះទំនេរ , ពាហិរាយតនៈ ៦ ប្រាកដដូចចោរប្លន់អ្នកស្រុក , វិញ្ញាណឋិតិ ៧ និងសត្តាវាស ៩ ប្រាកដដូចភ្លើង ១១ កង ឆេះសន្ធោសន្ធៅ , សង្ខារទាំងឡាយទាំងពួងប្រាកដដល់អ្នកនោះ ដូចជាបូស , ជារោគ , ជាសរ , ជាជម្ងឺ , ជាអាពាធ , ប្រាសចាកការស្រស់បស់ , មិនមានរសជាតិ ជាកងនៃទុក្ខធំ ប្រៀបដូចព្រៃក្រាស់ដែលមានសត្វកាច សូម្បីនឹងតាំងឡើង

ដោយអាការដែលគួររីករាយដល់បុរសអ្នកខ្លាចភ័យ ចង់រស់នៅជាសុខ ដូចជាល្អាងដែលមានភ្នំភ្លើងឆេះហុយ , ដូចជាស្រះទឹកដែលមានអារក្សទឹកស្ថិតនៅ ដូចជាសត្រូវដែលកំពុងយាដាវឡើង , ដូចជាភាជនៈដែលលាយដោយថ្នាំពុល ដូចជាដើរតាមផ្លូវដែលពេញទៅដោយចោរ , ដូចជាផ្ទះដែលភ្លើងឆេះពេញហើយ , ដូចជាសមរភូមិដែលពួកទាហានកំពុងប្រយុទ្ធគ្នា ។ ដូចជាថា បុរសនោះ អាស្រ័យភ័យ មានព្រៃក្រាស់ដែលពេញទៅដោយសត្វកាច ៗ ទាំងនេះ ខ្លាចហើយ រន្ធត់ហើយ ព្រឺរោម រមែងឃើញទោសដោយជុំវិញ យ៉ាងណា , ព្រះយោគាវចរនោះ ក៏ដូច្នោះដូចគ្នា លុះកាលសង្ខារទាំងពួង ប្រាកដហើយ ដោយមានភាពជាភ័យ ដោយអំណាចភយត្ថានុបស្សនា ក៏រមែងឃើញទោសតែម្យ៉ាង ប្រាសចាកអស់សេចក្ដីរីករាយ ។ អាទីនវានុបស្សនាញាណ ក៏រមែងកើតឡើងដល់ព្រះយោគីបុគ្គលនោះ ដែលជាអ្នកឃើញយ៉ាងនេះ ។

ព្រះយោគីបុគ្គលនោះ កាលឃើញសង្ខារទាំងពួងដោយភាពជាទោសយ៉ាងនេះ រមែងនឿយណាយ ក្រវល់ក្រវាយ មិនត្រេកអរក្នុងសង្ខារទាំងឡាយ ដែលមានប្រភេទក្នុងភព , កំណើត , គតិ ,



វិញ្ញាណឋិតិ និងសត្តាវាសទាំងពួង ។ ដូចជាហង្សមាស ដែលត្រេកអរចំពោះជើងភ្នំចិត្រកូដ រមែងមិនត្រេកអរនឹងអណ្ដូងទឹក ជិតទ្វារស្រុកមនុស្សចណ្ឌាលដែលមិនស្អាត , រមែងត្រេកអរចំពោះស្រះធំទាំង ៧ ប៉ុណ្ណោះ យ៉ាងណា , ស្ដេចហង្ស គឺ ព្រះយោគីនេះ រមែងមិនត្រេកអរក្នុងសង្ខារទាំងឡាយ សុទ្ធតែសម្រេចហើយតាមដែលខ្លួនឃើញហើយ , តែរមែងត្រេកអរក្រៃលែងក្នុងអនុបស្សនា ៧ ប៉ុណ្ណោះ ព្រោះត្រេកអរក្នុងភាវនា គឺ ព្រោះប្រកបដោយសេចក្ដីរីករាយក្នុងភាវនា ក៏ដូច្នោះដូចគ្នា ។ និងដូចសីហៈ ជាស្ដេចម្រឹគត្រូវចាប់យាំងទុក សូម្បីក្នុងទ្រុងមាសក៏មិនត្រេកអរ , តែរមែងត្រេកអរក្នុងហិមវន្តប្រទេសដ៏ធំធេងទំហំ ៣.០០០ យោជន៍ យ៉ាងណា , សីហៈ គឺ ព្រះយោគីបុគ្គលសូម្បីនេះ រមែងមិនត្រេកអរក្នុងសុគតិទាំង ៣ តែរមែងត្រេកអរក្នុងអនុបស្សនា ៣ ប៉ុណ្ណោះ ។

ម្យ៉ាងទៀត ដូចស្ដេចដំរីឆទ្ទន្តសទាំងខ្លួន មានទីតាំង ៧ ស្ថាន មានឫទ្ធិហោះទៅក្នុងវេហាស៍ រមែងមិនត្រេកអរនៅក្នុងកណ្ដាលនគរ , តែរមែងត្រេកអរក្នុងស្រះធំឈ្មោះឆទ្ទន្តប៉ុណ្ណោះ យ៉ាងណា , ព្រះ-យោគីបុគ្គល ដូចដំរីប្រសើរនេះ រមែងមិនត្រេកអរសូម្បីក្នុងសង្ខារ

ទាំងពួង , តែរមែងត្រេកអរក្នុងសន្តិបទ គឺ ព្រះនិព្វានប៉ុណ្ណោះ ដែលលោកសម្តែងហើយ ដោយន័យជាដើមថា ការមិនកើតឡើង ជាការផុតពីភ័យ , មានចិត្តបង្អោនទៅ ទោរទន់ទៅក្នុងសន្តិបទ គឺ ព្រះនិព្វាននោះ ។ និព្វិទានុបស្សនាញាណ រមែងកើតឡើងហើយដល់ព្រះយោគីនោះ ដោយហេតុត្រឹមប៉ុណ្ណោះ ដោយប្រការដូច្នេះ ។



## ៩. អដ្ឋកថា សង្ខារុបេក្ខាញាណុទ្ទេស

### ពោលអំពី សង្ខារុបេក្ខាញាណ

ពាក្យថា **មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា បញ្ញា សង្ខារុ-បេក្ខាសុ ញាណំ** សេចក្តីថា ព្រះយោគីបុគ្គលណាមានបំណង គឺ ប្រាថ្នាដើម្បីនឹងរួចផុត ដើម្បីនឹងលះបង់ ដូច្នោះ ព្រះយោគីបុគ្គលនោះ ទើបឈ្មោះថា **មុញ្ចិតុកម្យោ** ប្រែថា អ្នកប្រាថ្នានឹងរួចផុត , ភាពជាអ្នកប្រាថ្នានឹងរួចផុត ឈ្មោះថា **មុញ្ចិតុកម្យតា** ។

បញ្ញាណា រមែងពិចារណា រមែងត្រិះរិះ ដូច្នោះ បញ្ញានោះ ទើបឈ្មោះថា **បដិសង្ខា** , ម្យ៉ាងទៀត ការពិចារណាដោយចំពោះ ឈ្មោះថា **បដិសង្ខា** ។

បញ្ញាណា រមែងយល់ព្រម រមែងព្រងើយកន្តើយ ដូច្នោះ បញ្ញានោះ ឈ្មោះថា **សន្តិដ្ឋនា** ប្រែថា ព្រងើយ ។ ម្យ៉ាងទៀត ការព្រងើយ ឈ្មោះថា **សន្តិដ្ឋនា** ។

បញ្ញា ឈ្មោះថា មុញ្ចិតុកម្យតានោះផង បដិសង្ខាផង សន្តិដ្ឋនាផង ដូច្នោះ ទើបឈ្មោះថា **មុញ្ចិតុកម្យតាបដិសង្ខាសន្តិដ្ឋនា**

ប្រែថា ការប្រាថ្នានឹងរួចផុត , ការពិចារណា និងការព្រងើយកន្តើយ ។

ភាពជាអ្នកប្រាថ្នានឹងរលាស់ចេញ នូវការកើតជាដើម របស់ព្រះយោគីបុគ្គលអ្នកនឿយណាយដោយនិព្វិទាញាណ ក្នុងខាងដើម ឈ្មោះថា **មុញ្ចិតុកម្យតា** ។ ការពិចារណាសង្ខារទាំងឡាយ ដែលពិចារណាហើយ ដើម្បីរកឧបាយលះបង់ ឈ្មោះថា **បដិសង្ខា** , ការព្រមតាម ហើយព្រងើយកន្តើយក្នុងទីបំផុត ឈ្មោះថា **សន្តិដ្ឋនា** , បញ្ញា ៣ ប្រការ ដោយប្រភេទនៃការកំណត់យ៉ាងនេះ ឈ្មោះថា បញ្ញា ក្នុងការពិចារណាសង្ខារទាំងឡាយ ។ ក៏ព្រះយោគីបុគ្គលអ្នកប្រាថ្នាការចូលទៅព្រងើយកន្តើយក្នុងសង្ខារ ដោយបញ្ញា សូម្បីទាំង ៣ ផ្សេងគ្នាដោយប្រភេទ ការកំណត់ពោលគឺ ៖

**១.មុញ្ចិតុកម្យតា** ប្រាថ្នានឹងរួចផុតពីការកើតជាដើម

**២.បដិសង្ខា** ពិចារណាសង្ខារទាំងឡាយ

**៣.សន្តិដ្ឋនា** ព្រងើយកន្តើយក្នុងសង្ខារទាំងឡាយ

ពាក្យថា **បញ្ញា** និងពាក្យថា **សង្ខារុបេក្ខាសុ** លោកធ្វើជាពហុវចនៈទុក , ពាក្យថា **ញាណំ** គប្បីជ្រាបថា លោកធ្វើទុកជាឯកវចនៈ ព្រោះសូម្បីនឹងផ្សេងគ្នាដោយប្រភេទនៃការកំណត់ ក៏ដូចតែគ្នា ។



សមពិតដូចដែលព្រះធម្មសេនាបតីសារីបុត្រពោលទុកថា ៖ ធម៌ទាំងនេះ គឺ មុញ្ចិតុកម្យតា , បដិសង្ខានុបស្សនា និងបដិសង្ខារុបេក្ខា មានខ្លឹមសារដូចគ្នា ផ្សេងគ្នាតែព្យញ្ជនៈប៉ុណ្ណោះ ។ តែអាចារ្យពួកខ្លះពោលថា ពាក្យថា **សង្ខារុបេក្ខាសុ** នេះ ជាពហុវចនៈ ព្រោះបដិសង្ខារុបេក្ខា ជារបស់ច្រើន ដោយអំណាចនៃសមថៈ និងវិបស្សនា ដូច្នេះក៏មាន ។ ក៏ពាក្យថា **សង្ខារុបេក្ខាសុ** ក្នុងការសម្លឹងសង្ខារទាំងឡាយ គប្បីជ្រាបថា សម្លឹងដល់ការធ្វើ ។

តែចិត្តរបស់ព្រះយោគីបុគ្គលអ្នកនឿយណាយ មានការភ័យខ្លាចដោយនិព្វិទាញាណនោះ ដោយប្រភេទនៃការកំណត់ រមែងមិនជាប់ រមែងមិនទើទាក់ រមែងមិនជាប់ជំពាក់នៅក្នុងសង្ខារទាំងឡាយគ្រប់ប្រភេទ ដែលនៅក្នុងភព , កំណើត , គតិ , វិញ្ញាណឋិតិ និងសត្តាវាសទាំងពួង , ចិត្តនោះក៏ប្រាថ្នារួចផុត ប្រាថ្នានឹងរលាស់បោលសព្វសង្ខារ ។

ម្យ៉ាងទៀត ដូចជាត្រីដែលជាប់នៅក្នុងសំណាញ់ កង្កែបដែលនៅក្នុងមាត់ពស់ , មាន់ព្រៃដែលត្រូវក្រុងនៅក្នុងទ្រុង , ម្រឹគ

ដែលជាប់អន្ទាក់ , ពស់ដែលនៅក្នុងកណ្ដាប់ដៃអ្នកចាប់ពស់ , ដំរីដែលដើរទៅធ្លាក់ក្នុងរណ្ដៅភក់ធំ , នាគរាជនៅក្នុងមាត់របស់គ្រុឌ , ព្រះច័ន្ទដែលចូលទៅនៅក្នុងមាត់របស់រាហូ , បុរសជាប់ឡោមសត្រូវទាំងនេះជាដើម សុទ្ធជាអ្នកចង់ដើម្បីនឹងរួចផុត ដើម្បីនឹងរួចរបូតទៅពីពន្ធនាគារនោះ ៗ ដូចគ្នាទាំងអស់ យ៉ាងណា , ចិត្តរបស់ព្រះយោគីបុគ្គលនោះ រមែងចង់នឹងរួចផុត ប្រាថ្នារួចរបូតពីសង្ខារទាំងពួង ក៏ដូច្នោះ ។ ក៏កាលពោលយ៉ាងនេះ បាឋៈថា **មុញ្ចិតុកាមស្ស មុញ្ចិតុកម្យតា** ប្រែថា ការប្រាថ្នារួចផុតរបស់ព្រះយោគីបុគ្គលអ្នកចង់នឹងរួចផុត ក៏រមែងត្រឹមត្រូវ ។ កាលបើដូច្នេះ ក៏គប្បីពោល បានថា ក្នុងបទថា **ឧប្បាទំ មុញ្ចិតុកម្យតា** ជាដើម , ក៏គួរជា **ឧប្បាទា មុញ្ចិតុកម្យតា** ជាដើម , ព្រោះដូច្នោះ ខ្លឹមសារមុននុ៎ះឯង ល្អជាង ។

ម្យ៉ាងទៀត **មុញ្ចិតុកម្យតាញាណ** រមែងកើតដល់ព្រះយោគីបុគ្គលនោះអ្នកអស់អាល័យក្នុងសង្ខារទាំងពួង , អ្នកប្រាថ្នារួចផុតពីសង្ខារទាំងពួង ។ ព្រះយោគីបុគ្គលជាអ្នកប្រាថ្នារួចផុតពីសង្ខារគ្រប់ប្រភេទ មានក្នុងភព កំណើត គតិ វិញ្ញាណឋិតិ និងសត្តាវាសទាំងពួង ទើបលើកសង្ខារទាំងនោះ ឡើងកាន់ព្រះត្រៃលក្ខណ៍ទៀត



ដើម្បីនឹងធ្វើឧបាយនៃការរួចផុតឲ្យសម្រេច ទើបឃើញជាក់ច្បាស់ដោយបដិសង្ខានុបស្សនាញាណ ។

ក៏កាលព្រះយោគីបុគ្គលនោះឃើញច្បាស់យ៉ាងនេះឯង បដិសង្ខាញាណមាននិមិត្តដោយអនិច្ចលក្ខណៈ រមែងកើតឡើង , បដិសង្ខាញាណដែលប្រព្រឹត្តទៅដោយទុក្ខលក្ខណៈ រមែងកើតឡើង, និងបដិសង្ខាញាណមាននិមិត្ត និងប្រព្រឹត្តទៅហើយដោយអនត្តលក្ខណៈ ក៏រមែងកើត ។

ព្រះយោគីបុគ្គលនោះឃើញថា **សព្វេ សង្ខារា សុញ្ញា** ប្រែថា សង្ខារទាំងឡាយទាំងពួង ជារបស់ទទេ ដូច្នេះហើយទើបលើកឡើងកាន់ព្រះត្រៃលក្ខណ៍ ពិចារណាសង្ខារទាំងឡាយ ។ ទើបលះសេចក្តីខ្លាច និងសេចក្តីត្រេកអរចេញបាន រមែងព្រងើយ មានខ្លួនជាកណ្តាលក្នុងសង្ខារទាំងឡាយ ដូចបុរសឃើញទោសរបស់ភរិយា ហើយលះបង់ភរិយាទៅ ហើយព្រងើយ មានខ្លួនជាកណ្តាល ក្នុងរាងកាយរបស់ភរិយានោះ , ព្រះយោគីបុគ្គលនោះ រមែងមិនប្រកាន់ **អហង្ការ** ថាយើង ឬ **មមង្ការ** ថារបស់យើង ។ ចិត្តរបស់ព្រះយោគីបុគ្គលនោះ កាលដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ក៏រមែងគេចចេញ ថយ

ត្រឡប់ វិលត្រឡប់ មិនត្រេកអរក្នុងភពទាំង ៣ ។ ដូចស្លឹកឈូកឱនទៅបន្តិច ដំណក់ទឹកទាំងឡាយរមែងហូរទៅ ថយត្រឡប់ វិលត្រឡប់ មិនជន់លិច , ឬដូចរោមមាន់ ឬសរសៃ ឬស្បែក ដែលគេដាក់ក្នុងភ្លើង រមែងខ្ទាតចេញ រួញង មូត្រឡប់ មិនរលាចេញយ៉ាងណា , ចិត្តរបស់ព្រះយោគីបុគ្គលនោះ រមែងគេចចេញ ថយត្រឡប់ វិលត្រឡប់ មិនត្រេកអរក្នុងភពទាំង ៣ ដូច្នោះ , ឧបេក្ខាការព្រងើយ ក៏តាំងឡើង ។ សង្ខារុបេក្ខាញាណ រមែងកើតឡើងហើយ ដល់ព្រះយោគីបុគ្គលនោះ ដោយប្រការដូច្នេះ ។

អនុលោមញ្ញាណ និងសង្ខារុបេក្ខាញាណនេះ ជាហេតុឲ្យសម្រេចគោត្រភូញាណក្នុងខាងលើ សូម្បីមិនបានពោលទុកដោយញាណដើម និងញាណក្រោយ ក៏គប្បីជ្រាបថា រមែងបានពោលទុកហើយតែម្យ៉ាង ។ សមពិតដូចព្រះតម្រាស់ដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់សម្តែងទុកថា ៖

**ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកពិចារណាឃើញសង្ខារណា ៗ ដោយភាពជារបស់ទៀងនឹងជាអ្នកប្រកបដោយខន្តិដ៏សមគួរ ប្រការ**



**នោះ រមែងមិនជាឋានៈដែលនឹងមានបាន , មិនប្រកបដោយខន្តិដ៏សមគួរ នឹងឈានចុះកាន់ភាពនៃការឃើញប្រពៃ និងត្រឹមត្រូវ ប្រការនោះ រមែងមិនជាឋានៈ ដែលនឹងមានបាន , កាលមិនឈានចុះកាន់ភាពនៃកាឃើញប្រពៃ និងប្រាកដនឹងធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល , សកទាគាមិផល , អនាគាមិផល ឬ អរហត្តផលប្រការនោះ រមែងមិនជាឋានៈ ដែលនឹងមានបាន ដូច្នេះជាដើម ។**

ព្រះធម្មសេនាបតីសារីបុត្របានពោលពាក្យជាដើមថា ៖

ភិក្ខុ រមែងបានអនុលោមខន្តិដោយប្រការដូចម្តេច , រមែងឈានចុះកាន់សម្មត្តនិយាមដោយប្រការដូចម្តេច ។

ភិក្ខុ រមែងបានអនុលោមខន្តិដោយអាការ ៤០ , រមែងឈានចុះកាន់សម្មត្តនិយាមដោយអាការ ៤០ ដូច្នេះ ។

ក្នុងបដ្ឋានបករណ៍ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ពាក្យជា

ដើមថា ៖

អនុលោម ជាបច្ច័យដល់គោត្រភូ ដោយអំណាចនៃអនន្តរប្បច្ច័យ អនុលោម ជាបច្ច័យដល់វោទាន ដោយអំណាចនៃអនន្តរប្បច្ច័យ ។

ពិតហើយ កាលព្រះយោគីបុគ្គលនោះ សេពហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ នូវសង្ខារុបេក្ខាញាណនោះ អធិមោក្ខសទ្ធាក៏រមែងមានកម្លាំងក្រៃលែង , វិរិយៈក៏ផ្គងទុកបានដោយល្អ , សតិក៏មាំមួន , ចិត្តក៏ជាសមាធិ , សង្ខារុបេក្ខាញាណ ក៏រមែងប្រព្រឹត្តទៅយ៉ាងចាស់ក្លា ។

ចិត្តនោះ ពិចារណាសង្ខារទាំងឡាយថា **អនិច្ចា** មិនទៀង , **ទុក្ខា** ជាទុក្ខ , ឬ **អនត្តា** មិនមែនតួខ្លួន ដោយសង្ខារុបេក្ខា ដោយសង្ឃឹមថា មគ្គនឹងកើតឡើងក្នុងឥឡូវនេះ ដូច្នេះ ហើយក៏ចុះកាន់ភវង្គ ។



## អនុលោមញ្ញាណ

បន្ទាប់ពីភវង្គ មនោទ្វារាវជ្ជនៈក៏កើតឡើង ធ្វើសង្ខារទាំងឡាយ ដោយន័យដែលសង្ខារុបេក្ខាធ្វើហើយនោះឯង ឲ្យជាអារម្មណ៍ថា **អនិច្ចា** មិនទៀង , **ទុក្ខា** ជាទុក្ខ ឬ **អនត្តា** មិនមែនតួខ្លួន ។

បន្ទាប់ពីមនោទ្វារាវជ្ជនៈនោះ ជវនចិត្តក៏កើតឡើង ២ ខណៈ ៣ ខណៈ ឬ ៤ ខណៈ ទទួលយកសង្ខារទាំងឡាយធ្វើជាអារម្មណ៍ដូច្នោះ នុ៎ះឯង ។

ញាណដែលសម្បយុត្តដោយជវនចិត្តនោះ ឈ្មោះថា អនុលោមញ្ញាណ ។

ពិតហើយ អនុលោមញ្ញាណនោះ រមែងអនុលោមតាមវិបស្សនាញាណ ៨ ក្នុងខាងដើម ព្រោះជាកិច្ចនៃសច្ចញាណ និងអនុលោមតាមពោធិបក្ខិយធម៌ ៣៧ ជាធម៌ដែលនឹងគប្បីសម្រេចក្នុងខាងមុខ ។

ដូចឧទាហរណ៍ថា ធម្មិករាជាគង់ប្រថាប់លើបល្ល័ង្កជាកន្លែងវិនិច្ឆ័យ ទ្រង់ស្តាប់ការវិនិច្ឆ័យរបស់អាមាត្យដែលឆ្លាតឈ្លាសក្នុងវោហារ

៨ នាក់ ហើយទ្រង់លះអគតិ ដាក់ព្រះទ័យនៅជាកណ្តាល អនុមោទនាថា យ៉ាងនុ៎ះចុះ រមែងអនុលោមតាមការវិនិច្ឆ័យរបស់អាមាត្យទាំង ៨ នាក់ទាំងនោះ និងអនុលោមតាមបុរាណរាជធម៌ ។

ក្នុងការឧបមានោះ អនុលោមញ្ញាណ ប្រៀបដូចព្រះរាជា , វិបស្សនា ៨ ប្រៀបដូចអាមាត្យដែលឈ្លាសក្នុងវោហារ , ពោធិបក្ខិយធម៌ ៣៧ ប្រៀបដូចបុរាណរាជធម៌ , ព្រះរាជាអនុមោទនាថា ពិតយ៉ាងនោះចុះ ឈ្មោះថា រមែងអនុលោមតាមការវិនិច្ឆ័យរបស់ពួកអាមាត្យដែលឈ្លាសក្នុងវោហារផង តាមរាជធម៌ផងយ៉ាងណា , អនុលោមញ្ញាណ ក៏ដូច្នោះ រមែងអនុលោមតាមវិបស្សនា ៨ ដែលកើតឡើង ប្រារព្ធសង្ខារទាំងឡាយ ដោយអំណាចនៃត្រៃលក្ខណ៍មានអនិច្ចលក្ខណៈជាដើម ព្រោះជាកិច្ចនៃសច្ចៈ , អនុលោមតាមពោធិបក្ខិយធម៌ ៣៧ ប្រការ ជាធម៌ដែលនឹងគប្បីសម្រេចក្នុងខាងមុខ ។ ព្រោះដូច្នោះ ញាណនេះ លោកទើបហៅថា **អនុលោមញ្ញាណ** ដូច្នេះឯង ។



# ១០. អដ្ឋកថា គោត្រភូញាណុទ្ទេស

## ពោលអំពី គោត្រភូញាណ

ក្នុងពាក្យថា **ពហិទ្ធា វុដ្ឋានវិវដ្ដនេ បញ្ញា គោត្រភូញាណំ** ប្រែថា បញ្ញាក្នុងការចេញ និងគេចទៅពីសង្ខារនិមិត្តខាងក្រៅ ជា **គោត្រភូញាណ** នេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **ពហិទ្ធា** បានដល់ សង្ខារនិមិត្ត ។ ព្រោះថា សង្ខារនិមិត្តនោះ លោកពោលថា ពហិទ្ធា ខាងក្រៅ ព្រោះអាស្រ័យអកុសលក្ខន្ធក្នុងចិត្តសន្តានក្នុងខាងក្នុង ។ ព្រោះដូច្នោះ គោត្រភូញាណនោះ រមែងចេញ គឺ តាំងនៅក្នុងខាងលើ ប្រាសចាកសង្ខារនិមិត្តខាងក្រៅ ដូច្នោះគោត្រភូញាណនោះ ទើបឈ្មោះថា **វុដ្ឋាន** , គោត្រភូញាណនោះ រមែងចេញចាក រមែងងាកចេញ គឺ បែរខ្នងឲ្យ ដូច្នោះគោត្រភូញាណនោះ ទើបឈ្មោះថា **វិវដ្ដន** , វុដ្ឋាននោះផង វិវដ្ដនៈនោះផង ដូច្នោះ ទើបឈ្មោះថា **វុដ្ឋានវិវដ្ដន** ។ ព្រោះហេតុនោះ ព្រះពុទ្ធឃោសាចារ្យទើបពោលថា ៖

**គោត្រភូញាណ មិនទាន់ចេញពីបវត្តខន្ធ ព្រោះ**

**លះសមុទយមិនដាច់ , តែចេញពីនិមិត្តបាន ព្រោះមានព្រះនិព្វានជាអារម្មណ៍ ដូច្នេះ ទើបឈ្មោះថា ឯកតោវុដ្ឋាន គឺ ចេញពីសង្ខារនិមិត្តតែម្យ៉ាង ដូច្នេះ ។**

ឈ្មោះថា **គោត្រភូ** ព្រោះគ្របសង្កត់ចេញបានទូវគោត្រ-បុថុជ្ជន និងព្រោះឈានឡើងកាន់គោត្រអរិយៈ ។ ព្រោះគោត្រភូ-ញាណនេះ ធ្វើព្រះនិព្វាន ឈ្មោះថា អនិមិត្ត មិនមាននិមិត្ត ឲ្យជាអារម្មណ៍នៅទីបំផុតនៃអាសេវនៈ នៃអនុលោមញ្ញាណរបស់ចិត្ត ដែលនឿយណាយចាកសង្ខារទាំងពួង ដូចទឹកធ្លាក់ពីស្លឹកឈូក , ឈានកន្លងអស់នូវគោត្របុថុជ្ជន ដែលរាប់បានថាបុថុជ្ជន , ភូមិនៃ បុថុជ្ជន , ឈានចុះកាន់គោត្រនៃអរិយៈ ដែលរាប់ថា អរិយៈ ជាភូមិ នៃអរិយៈ , ញុំាងភាពជាបច្ច័យឲ្យសម្រេចដល់មគ្គ ដោយអំណាច បច្ច័យ ៦ គឺ អនន្តរៈ , សមនន្តរៈ , អាសេវនៈ , ឧបនិស្សយៈ , នត្ថិ , វិគតៈ , ដែលប្រព្រឹត្តទៅក្នុងគ្រាដំបូង ការសេពគ្រាដំបូង , ដែលប្រជុំព្រមគ្នាក្នុងគ្រាដំបូងក្នុងអារម្មណ៍ គឺ និព្វាន , ដល់កំពូល ជាសីរសៈវិបស្សនា រមែងកើតឡើង ធ្វើឲ្យជាសភាពដែលឲ្យវិលត្រឡប់មកវិញទៀតមិនបាន ។



# ១១. អដ្ឋកថា មគ្គញ្ញាណុទ្ទេស

## ពោលអំពី មគ្គញ្ញាណ

ក្នុងពាក្យថា **ទុភតោ វុដ្ឋានវិវដ្ដនេ បញ្ញា មគ្គេ ញាណំ** ប្រែថា បញ្ញាក្នុងការចេញ និងគេចពីខន្ធ និងនិមិត្តទាំង ២ ជាមគ្គញ្ញាណនេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

ពាក្យ **ទុភតោ** ប្រែថា ទាំង ២ , ម្យ៉ាងទៀត លោកពោលអធិប្បាយថា ទាំងគូ ។ មគ្គញ្ញាណ រមែងចេញ គឺ រមែងប្រព្រឹត្តទៅបញ្ចៀសពីកិលេសទាំងឡាយ និងខន្ធដែលប្រព្រឹត្តទៅតាមកិលេសទាំងនោះ និងចេញចាកសង្ខារនិមិត្តទាំងពួង ក្នុងការធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ ព្រោះលះកិលេសទាំងឡាយបានដាច់ខាតហើយ ដូច្នោះ ទើបឈ្មោះថា បញ្ញាក្នុងការចេញ និងរលាស់ចេញពីខន្ធ និងនិមិត្តទាំង ២ ។

ព្រោះហេតុនោះ ព្រះពុទ្ធឃោសាចារ្យទើបពោលថា ៖

**មគ្គញ្ញាណសូម្បីទាំង ៤ ចេញពីនិមិត្ត ព្រោះមានព្រះនិព្វាន ដែលមិនមាននិមិត្តជាអារម្មណ៍ , និងរមែងចេញពីបវត្តខន្ធ ព្រោះលះសមុទយបានដោយ**

ដាច់ខាត ដូច្នេះទើបឈ្មោះថា ទុកតោវុដ្ឋានៈ គឺ ចេញដោយចំណែកទាំង ២ ដូច្នេះ ។

ធម្មជាតិណា រមែងខ្វល់ខ្វាយ រមែងសម្លឹងមើលព្រះនិព្វាន , ឬព្រះយោគីបុគ្គលអ្នកត្រូវការព្រះនិព្វាន រមែងខ្វល់ខ្វាយ គឺ រមែងស្វែងរកឬថាធម្មជាតិញាំងកិលេសទាំងឡាយឲ្យស្លាប់ទៅប្រព្រឹត្ត ទៅ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា មគ្គ , ញាណក្នុងមគ្គនោះ ឈ្មោះថា **មគ្គេ ញាណំ** មគ្គញ្ញាណ ។

មគ្គញ្ញាណ លោកធ្វើឯកវចនៈដោយជាតិស័ព្ទ ។ ក៏មគ្គញ្ញាណនោះ កើតឡើង ធ្វើព្រះនិព្វានឲ្យជាអារម្មណ៍ តពីគោត្រភូញាណ , លះបង់កិលេស ដែលនឹងគប្បីសម្លាប់បាន ដោយមិនមានចំណែកសល់ ដុតបំផ្លាញអន្លង់សមុទ្រ គឺ ទុក្ខក្នុងសង្សារវដ្ដ ដែលមានខាងដើម និងទីបំផុត ដែលបុគ្គលដឹងមិនបាន ឲ្យរីងស្ងួតទៅ , បិទទ្វារអបាយទាំងពួង , ធ្វើអរិយទ្រព្យ ៧ ឲ្យប្រាកដនៅចំពោះមុខ , លះមិច្ឆាមគ្គប្រកបដោយអង្គ ៨ , ធ្វើភ័យវេរាទាំងពួងឲ្យស្ងប់ , នាំខ្លួនចូលកាន់ភាពជាបុត្តដែលកើតពីព្រះឱរៈនៃព្រះសម្មាសម្ពុទ្ធជាម្ចាស់ និងបានអានិសង្សដទៃ ៗ ទៀតច្រើនរយជង



ដូចពាក្យដែលពោលថា ៖

បុរសប្រាថ្នានឹងលោតឆ្លងស្ទឹងតូច ឡើងទៅឈរនៅលើមាត់ប្រាំងខាងអាយ ទើបចាប់ខ្សែ ឬកំណាត់ឈើដែលជាប់នៅនឹងដើមឈើលើប្រាំងនេះ ហើយលោតឆ្លងទៅយ៉ាងលឿន រហូតខ្លួនទៅធ្លាក់នៅប្រាំងខាងនាយ កាលបើខ្លួនទៅធ្លាក់នៅប្រាំងខាងនាយហើយ ក៏លះបង់ការភ័យខ្លាចនោះ ឈរនៅលើប្រាំង បានយ៉ាងណា , ព្រះយោគីបុគ្គលប្រាថ្នានឹងឆ្លងផុតកិលេសទាំងឡាយ ឃើញភ័យនៅត្រើយអាយពេញដោយសក្កាយទិដ្ឋិ ហើយឈរនៅមាត់ត្រើយនាយ គឺ ព្រះនិព្វាន ដែលមិនមានភ័យ ទើបចាប់ខ្សែ គឺ រូបក្ខន្ធដែលជាទីទាញឡើងមក យ៉ាងលឿនដោយឧទយព្វយានុបស្សនាជាខាងដើម ឬចាប់ឈើ គឺ នាមខន្ធនោះទុកដោយល្អ លោតមកដោយអាវជ្ជនចិត្ត ដោយន័យតាមដែលពោលហើយពីមុន លោតឡើងដោយអនុលោមញ្ញាណ ហើយបង្អោនទៅក្នុងព្រះនិព្វាន ចូលទៅកន្លែងជិតនៃព្រះនិព្វាននោះ ក៏លែងនូវអារម្មណ៍ គឺ សង្ខារធម៌នោះចេញបាន ដោយគោត្រភូញាណ ហើយឈរលើប្រាំងដទៃ គឺ ព្រះនិព្វានដែលជាអសង្ខតធម៌ អំពីនោះក៏តាំងនៅដោយមគ្គញ្ញាណ ដូច្នោះ ។

នរជនអ្នកចង់មើលវង់ព្រះចន្ទ ក្នុងវេលាដែលព្រះចន្ទត្រូវពពកបិទបាំង កាលបើពពកត្រូវខ្យល់ផាត់ទៅតាមលំដាប់ ពីក្រាស់ខ្ទឹកទៅស្តើង និងអស់ទៅ ក៏ឃើញព្រះចន្ទបាន យ៉ាងណា , គោត្រភូញាណដែលកំពុងសម្លឹងអមតនិព្វាន កាលបើមោហៈបិទបាំងសច្ចៈទុក ត្រូវបំផ្លាញឲ្យវិនាសទៅដោយអនុលោមញ្ញាណតាមលំដាប់ក៏ដូចគ្នា អនុលោមញ្ញាណ ក៏មិនបានឃើញអមតនិព្វាន ដូចខ្យល់ទាំងនោះ ក៏មិនបានឃើញព្រះចន្ទ , គោត្រភូញាណ ក៏បន្ទោបង់ភាពងងឹតមិនបានដូចបុរស ក៏បន្ទោបង់ពពកអំពូមិនបាន ដូច្នោះ ។ តែមគ្គញ្ញាណនេះប្រព្រឹត្តទៅក្នុងព្រះនិព្វាន មិនបានលះសញ្ញាដែលគោត្រភូឲ្យឡើយ ទើបបំផ្លាញកងកិលេស មានកងលោភៈជាដើមបាន ដូចចក្រយន្តដែលវិលដោយកម្លាំងបង្វិល ហើយនាយខ្មាន់ធ្នូឈរតម្រង់បាញ់ ល្មមមានសញ្ញាអ្នកដទៃដែលឲ្យហើយ ក៏បាញ់ព្រួញទៅ ទម្លុះគោលដៅទាំង ១០០ ដូច្នោះ ។ មគ្គញ្ញាណនោះឯង ធ្វើសមុទ្រធំ គឺ សង្សារទុក្ខឲ្យរីងស្ងួតទៅ បិទទ្វារទុគ្គតិបាន ធ្វើមនុស្សដែលមានបំណុល គឺកិលេស ឲ្យជាសេក្ខបុគ្គលអ្នកសម្បូរណ៍ដោយអរិយទ្រព្យ លះមិច្ឆាមគ្គបាន ។ ធ្វើវេរា និងភ័យ ទាំងឡាយឲ្យស្ងប់,ធ្វើខ្លួនឲ្យជាកូន



អ្នកកើតពីទ្រូងនៃព្រះពុទ្ធជាម្ចាស់ ជានាថៈរបស់លោក , ញាណនេះរមែងបាននូវអានិសង្សដទៃ ៗ ទៀតច្រើនរយយ៉ាង ។

## ១២. អដ្ឋកថា ផលញ្ញាណុទ្ទេស

### ពោលអំពី ផលញ្ញាណ

ក្នុងពាក្យថា **បយោគប្បដិប្បស្សទ្ធិបញ្ញា ផលេ ញាណំ** ប្រែថា បញ្ញាក្នុងការម្ងាប់យោគៈ ជាផលញ្ញាណនេះ មានវិនិច្ឆ័យដូចតទៅនេះ ៖

បទថា **បយោគោ** ការប្រកបយ៉ាងខ្ជាំងក្លា , គឺ សេចក្តីព្យាយាមចេញចាកពីកិលេស និងខន្ធ ទាំង ២ បានដោយមគ្គភាវនាដោយធ្វើឲ្យច្បាស់នូវផល , សេចក្តីស្ងប់យោគៈ គឺ សេចក្តីព្យាយាមនោះ គឺ ការដល់ទីបំផុតនៃយោគៈ ឈ្មោះថា **បយោគប្បដិប្បស្សទ្ធិ** ។ បយោគប្បដិប្បស្សទ្ធិ នោះ យ៉ាងណា ? គឺ ការចប់នៃកិច្ចក្នុងមគ្គទាំង ៤ ។

បញ្ញាក្នុងផលប្រព្រឹត្តទៅហើយ ព្រោះបយោគប្បដិប្បស្សទ្ធិនោះជាហេតុ ឈ្មោះថា បយោគប្បដិប្បស្សទ្ធិបញ្ញា ។ បញ្ញានេះជាផល ព្រោះអត្ថថា រមែងផលិតផល គឺ រមែងឲ្យកើតវិបាកក្នុងផលនោះញាណដែលសម្បយុត្តជាមួយផលចិត្តនោះ(ឈ្មោះថា**ផលេ**



**ញាណំ** ) ក៏តពីមគ្គញ្ញាណមួយ ៗ ផលចិត្តដែលជាវិបាកនៃមគ្គចិត្តនោះ ៗ ឯង មានព្រះនិព្វានជាអារម្មណ៍ កើតឡើង ៣ ខណៈក៏មាន ២ ខណៈក៏មាន ១ ខណៈក៏មាន ។ ព្រោះផលចិត្តនោះជាវិបាកកើតឡើងក្នុងលំដាប់នៃលោកុត្តរកុសលទាំងឡាយ ព្រះដ៏-មានព្រះភាគត្រាស់ថា **សមាធិមានន្តរិកញ្ញមាហុ** បណ្ឌិតទាំងឡាយពោលសមាធិដែលប្រកបដោយផលញ្ញាណ ដែលកើតតពីមគ្គញ្ញាណថា ជាធម៌ដែលបណ្ឌិតគប្បីដឹងទូទៅ , និងត្រាស់ពាក្យជា ដើមថា **ទន្ធំ អានន្តរិកំ បាបុណាតិ អាសវានំ ខយាយ** ព្រះយោគីបុគ្គលសម្រេចធម៌វិសេសដើម្បីការអស់អាសវៈយឺតយូរ ។

អនុលោមចិត្តរបស់ព្រះយោគីបុគ្គលណា មាន ២ ខណៈ , ទី ៣ ជាគោត្រភូ ទី ៤ ជាមគ្គចិត្ត ផលចិត្ត ៣ ខណៈទៀត រមែងមានដល់ព្រះយោគីបុគ្គលនោះ ។ ( រួមជា ៧ តាមជវននិយាម ) ។

អនុលោមចិត្តរបស់ព្រះយោគីបុគ្គលណា មាន ៣ ខណៈ , ទី ៤ ជាគោត្រភូ ទី ៥ ជាមគ្គចិត្ត ផលចិត្ត ២ ខណៈ រមែងមានដល់ព្រះអរិយបុគ្គលនោះ ។ ( រួមជា ៧ តាមជវននិយាម ) ។

អនុលោមចិត្តរបស់ព្រះយោគីបុគ្គលណា មាន ៤ ខណៈ ,

ទី ៥ ជាគោត្រភូ ទី ៦ ជាមគ្គចិត្ត ផលចិត្ត ១ ខណៈទៀត រមែងមានដល់ព្រះអរិយបុគ្គលនោះ ។ ( រួមជា ៧ តាមជវននិយាម ) ។

នេះជាផលក្នុងមគ្គវិថី ។ ចំណែកផល ក្នុងវាងកាលកើតឡើងដោយអំណាចសមាបត្តិ និងកើតឡើងដល់អ្នកចេញពីនិរោធ-សមាបត្តិ ក៏សង្គ្រោះដោយផលញ្ញាណនេះ ដូចគ្នា ។

## ១៣. អដ្ឋកថា វិមុត្តិញ្ញាណុទ្ទេស

### ពោលអំពី វិមុត្តិញ្ញាណ

ពាក្យថា **ឆិន្នវដុមានុបស្សនេ បញ្ញា** ប្រែថា បញ្ញាក្នុងការពិចារណាឃើញឧបក្កិលេសដែលអរិយមគ្គកាត់ផ្តាច់ហើយ សេចក្តីថា បញ្ញាក្នុងការឃើញជាខាងក្រោយនូវឧបក្កិលេសនោះ ៗ ដែលអរិយ-មគ្គនោះ ៗ កាត់ផ្តាច់ហើយ ។

ពាក្យថា **វិមុត្តិញ្ញាណំ** ជាវិមុត្តិញ្ញាណ សេចក្តីថា ញាណក្នុងវិមុត្តិ ។

ពាក្យថា **វិមុត្តិ** បានដល់ចិត្តបរិសុទ្ធិដែលរួចផុតពីឧបក្កិលេស



ទាំងឡាយ ឬភាពដែលចិត្តនោះរួចផុតហើយ , ញាណ គឺ សេចក្តីដឹងក្នុងវិមុត្តិនោះ ឈ្មោះថា **វិមុត្តិញ្ញាណ** ។

លោកពោលអធិប្បាយ ការពិចារណាកិលេសដែលលះបង់ហើយដោយញាណនេះថា ព្រះអរិយបុគ្គល កាលបើពិចារណាការបន្តនៃចិត្តដែលរួចផុតពីកិលេសហើយក្តី នូវការរួចផុតពីកិលេសហើយក្តី វៀរកិលេសចេញ ក៏ពិចារណាមិនបាន យ៉ាងនេះ ។ ក៏ពាក្យថា **វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ** ប្រែថា កាលបើចិត្តរួចផុតហើយ ក៏ដឹងថារួចផុតហើយដូច្នេះ លោកពោលសំដៅយកវិមុត្តិញ្ញាណនេះ នោះឯង ។ ចំណែកការពិចារណាកិលេសដែលនៅសល់ សូម្បីមិនបានពោលទុកហើយ ក៏គប្បីកាន់យកថា ជាការពោលហើយដោយវិមុត្តិញ្ញាណនេះឯង និងលោកពោលទុកថា ៖

**សូម្បីពោលទុកក្នុងឯកធម៌ ក៏ដូចជាការពោល**
**ទាំងអស់ ព្រោះសភាវៈធម៌នោះ មានលក្ខណៈ**
**តែមួយដូចគ្នា នេះជាលក្ខណៈ ជាហារៈ ដូច្នេះ ។**

ម្យ៉ាងទៀត គប្បីជ្រាបថា ជាការពោលដល់ការពិចារណាកិលេសដែលលះហើយដល់ព្រះអរិយបុគ្គល ៤ នឹងគប្បីបាន ព្រោះ

ព្រះអរហន្តមិនមានការពិចារណាកិលេសដែលនៅសល់ឡើយ ។

## ១៤_អដ្ឋកថា បច្ចវេក្ខណញ្ញាណនុទ្ទេស

### ពោលអំពី បច្ចវេក្ខណញ្ញាណ

ពាក្យថា **តទា សមុទាគតេ ធម្មេ បស្សនេ បញ្ញា** ប្រែថា បញ្ញា ក្នុងការពិចារណាឃើញធម៌ដែលចូលមកប្រជុំក្នុងខណៈនោះ សេចក្តីថា បញ្ញាជាគ្រឿងដឹងច្បាស់ក្នុងធម៌ គឺ មគ្គ និងផល ទាំងក្នុងធម៌ គឺ សច្ចៈ ៤ ដែលកើតឡើងក្នុងមគ្គខណៈ និងផលខណៈ គឺមកព្រមហើយ ដល់ព្រមហើយ ប្រជុំគ្នាក្នុងកាលនោះ ដោយអំណាចការបានចំពោះ និងដោយអំណាចនៃការចាក់ធ្លុះ ។

ពាក្យថា **បច្ចវេក្ខណេ ញាណំ** បច្ចវេក្ខណញ្ញាណ , សេចក្តីថា ញាណជាគ្រឿងវិលត្រឡប់មកឃើញច្បាស់ ។ ក៏បច្ចវេក្ខណញ្ញាណ លោកពោលទុកដោយញាណទាំង ២ នេះ ។

ក៏ក្នុងទីបំផុតនៃសោតាបត្តិផលក្នុងមគ្គវិថី ចិត្តរបស់ព្រះសោ-តាបន្ន ក៏ចុះកាន់ភវង្គ , តពីនោះក៏ផ្តាច់ភវង្គ មនោទ្វារាវជ្ជនៈ ក៏កើត



ឡើងដើម្បីពិចារណាមគ្គ , កាលមនោទ្វារាវជ្ជនៈនោះរលត់ ហើយ ជវនចិត្តពិចារណាមគ្គក៏កើតឡើង ៧ ខណៈ ដោយលំដាប់ ដូច្នេះឯង ។ បន្ទាប់មកក៏ចុះកាន់ភវង្គទៀត អាវជ្ជនៈចិត្តជាដើម ក៏កើតឡើង ដើម្បីការពិចារណាធម៌ទាំងឡាយ មានផលជាដើម ដោយន័យនោះឯង ។ ព្រោះការកើតឡើងនៃធម៌ពួកណា មានផលជាដើម ព្រះសោតាបន្ននោះ ក៏ពិចារណាមគ្គ , ផល , កិលេសដែលលះហើយ , កិលេសដែលនៅសល់ និងព្រះនិព្វាន ។

ក៏ព្រះសោតាបន្ននោះ ពិចារណាមគ្គថា យើងមកហើយដោយមគ្គនេះហ្ន៎ , តពីនោះក៏ពិចារណាផលថា អានិសង្សនេះ យើងបានហើយ , តពីនោះក៏ពិចារណាកិលេសលះហើយថា ដែលឈ្មោះថា កិលេសទាំងនេះយើងលះបានហើយ , តពីនោះ ក៏ពិចារណាកិលេសដែលមគ្គខាងលើដែលនឹងប្រហារថា កិលេសទាំងនេះយើងនៅមានសល់ , ក្នុងទីបំផុតក៏ពិចារណាអមតនិព្វានថា ធម៌នេះយើងបានហើយដោយភាពជាអារម្មណ៍ ។

ព្រះអរិយសាវកជាសោតាបន្ន មានបច្ចវេក្ខណៈ ៥ យ៉ាងដោយប្រការយ៉ាងនេះ ។ បច្ចវេក្ខណៈរបស់ព្រះសកទាគាមី និង

ព្រះអនាគាមី ក៏មានដូចព្រះសោតាបន្ន ។ តែចំពោះព្រះអរហន្ត មានបច្ចវេក្ខណៈ ៤ យ៉ាង គឺ មិនមានការពិចារណាកិលេសដែលនៅសល់ ។ រួមបច្ចវេក្ខណញ្ញាណមាន ១៩ ដោយប្រការដូច្នេះ ។ នេះជាការកំណត់យ៉ាងឧក្រិដ្ឋ ។

សួរថា ការពិចារណាកិលេសដែលលះបានហើយ និងដែលនៅសល់ នៅមានដល់ព្រះសេក្ខៈទាំងឡាយឬទេ ?

ឆ្លើយថា ព្រោះសេចក្តីដែលពិចារណាការលះកិលេសនោះមិនមាន ស្តេចមហានាមសក្យរាជ ទើបក្រាបទូលសួរព្រះមានព្រះភាគជាម្ចាស់ថា ធម៌ឈ្មោះអ្វីទៅ ដែលខ្ញុំព្រះអង្គនៅលះមិនទាន់បាន ដាច់ខាតក្នុងខាងក្នុង ដែលជាហេតុឲ្យលោភធម៌ នៅគ្របសង្កត់ចិត្តខ្ញុំព្រះអង្គមួយដងមួយគ្រា ដូច្នេះជាដើម ។

ក្នុងទីនេះ ដើម្បីឲ្យញាណ ១១ មានធម្មដ្ឋិតិញ្ញាណក្លីច្បាស់ គប្បីជ្រាបឧបមាដូចតទៅនេះ ៖

ប្រៀបដូចបុរសគិតថា យើងនឹងចាប់ត្រី ទើបកាន់យកអង្រុតទៅរុតក្នុងទឹកដែលគិតថា គួរមានត្រី ហើយទើបលូកដៃតាមមាត់អង្រុត ហើយក៏ស្រវាចាប់កពស់វែកនៅក្នុងទឹកដោយស្មានថា ត្រី



សប្បាយចិត្តគិតថា យើងបានត្រីធំហើយ ក៏លើកឡើង ក៏ដឹងថា ពស់ ព្រោះឃើញត្រា.ក ៣ ជាន់ គួរខ្លាច ឃើញទោស ជិនណាយក្នុងការចាប់ ប្រាថ្នានឹងរួចផុត ទើបធ្វើឧបាយដើម្បីនឹងឲ្យរបូតផុត ទើបចាប់ពស់ពីចុងកន្ទុយ លើកឡើងគ្រវី ២-៣ ជុំ ជុំវិញខ្លួន ធ្វើឲ្យពស់ទុព្វល ហើយគ្រវែងទៅ ព្រមទាំងនិយាយថា ហក ! ទៅអាពស់កំណាច ហើយក៏លោតឡើងឈរលើគោកយ៉ាងរហ័សតែម្តង កើតសេចក្តីសប្បាយរីករាយចិត្តថា លោកដ៏ចម្រើន យើងផុតហើយពីមាត់ពស់ ហើយក្រឡេកមើលផ្លូវដែលខ្លួនមក ។

ក្នុងការឧបមាប្រៀបធៀបនោះ មានដូចតទៅនេះ ៖

ការប្រកាន់ទុកនូវខន្ធ ៥ ដែលគួរខ្លាច ដោយអំណាចនៃលក្ខណៈ មានការមិនទៀងជាដើម ហើយត្រេកអរដោយសម្គាល់ថាទៀងដោយតណ្ហាដែលសម្បយុត្តដោយទិដ្ឋិ ( គឺ លោភទិដ្ឋិសម្បយុត្ត ) ថាយើង របស់យើង របស់ពាលបុថុជ្ជន ចាប់ផ្តើមតាំងពីព្រះយោគីបុគ្គលនេះ ដូចចាប់ពស់វែកទុកពេញទំហឹងដោយសម្គាល់ថា ត្រីរបស់បុរសនោះ ដូច្នោះ ។ កាលបំបែកឃនៈសញ្ញាដោយការកំណត់នាមរូបព្រមទាំងបច្ច័យ ហើយឃើញត្រៃលក្ខណ៍ធម៌ មាន

អនិច្ចតាជាដើមរបស់ខន្ធ ៥ ដោយញាណ មានការពិចារណាដោយកាពជាកលាបៈ ហើយកំណត់ខន្ធ ៥ នោះថា មិនទៀង ជាទុក្ខ ជាអនត្តា ដូចជាការយកពស់ចេញពីមាត់អន្ទ្រុត ដោយឃើញក្អាត់នៅនិងក ទើបដឹងថាពស់ របស់បុរសនោះដូច្នោះ ។

កយតូបដ្ឋានញ្ញាណរបស់ព្រះយោគីបុគ្គលនេះ ដូចជាការខ្លាចរបស់បុរសនោះ ដូច្នោះ , អាទីវានុបស្សនាញាណ ដូចជាការឃើញទោសក្នុងពស់ដូច្នោះ , និព្វិទានុបស្សនាញាណ ដូចជាការក្រែងរអាក្នុងការចាប់ពស់ដូច្នោះ មុញ្ចិតុកម្យតាញាណ ដូចជាការចង់គ្រវែងពស់ទៅឲ្យផុតដូច្នោះ , បដិសង្ខានុបស្សនាញាណ ដូចជាការធ្វើឧបាយដើម្បីនឹងគ្រវែងពស់ឲ្យផុតដូច្នោះ ។ ការពិចារណាអនុលោមនូវសង្ខារទាំងឡាយដោយសង្ខារុបេក្ខាញាណ ដោយការលើកឡើងឆ្កោះត្រៃលក្ខណ៍ ហើយធ្វើឲ្យទុព្វល មិនអាចនឹងប្រាកដដោយអាការថា ទៀង , ជាសុខ និងជាអត្តាបានទៀត ដូចជាការចាប់ពស់ឡើងគ្រវីទៅជុំវិញ នៅខាងលើសិរសា ធ្វើឲ្យទុព្វលមិនអាចនឹងបែរមកចឹកបានទៀត , គោត្រភូញាណ ដូចជាការគ្រវែងពស់ចោលដូច្នោះ , មគ្គញ្ញាណផលញ្ញាណ ឈានឡើងឈរនៅលើ



គោក គឺ ព្រះនិព្វាន ដូចជាបុរសនោះគ្រវែងចោលពស់ចេញទៅ ហើយឡើងឈរនៅលើគោកដូច្នោះ , បច្ចវេក្ខណញ្ញាណក្នុងធម៌មានមគ្គជាដើម ដូចជាការក្រឡេកមើលផ្លូវដែលមកហើយ របស់បុគ្គលអ្នកសប្បាយរីករាយដូច្នោះ ។

ក្នុងបណ្តាបច្ចវេក្ខណញ្ញាណទាំងឡាយនោះ គប្បីជ្រាបថា កិលេសបច្ចវេក្ខណៈ ការពិចារណាកិលេសជាលើកដំបូង តពីនោះទើបជាការពិចារណាមគ្គផល និងនិព្វាន ព្រោះលំដាប់នៃទេសនាដែលព្រះយោគីបុគ្គលធ្វើហើយតាមលំដាប់ នៃការកើតឡើងរបស់ញាណ ១៤ ទាំងនេះ មានសុតមយញ្ញាណជាដើម និងតាមលំដាប់នៃការបដិបត្តិ ។

កិលេសបច្ចវេក្ខណៈ ការពិចារណាកិលេសតាមសមគួរដល់ការបដិបត្តិនោះឯងជាខាងដើម រមែងគួរ ព្រោះលោកពោលការបដិបត្តិមគ្គទុក ព្រោះការប្រហារកិលេសនោះឯង ឲ្យជាការសម្គាល់ថា ព្រះយោគីបុគ្គលអ្នកចម្រើនលោកុត្តរឈាន ដែលជានិយ្យានិក-ធម៌នាំចេញចាកទុក្ខ ជាអបចយគាមី ជាហេតុឲ្យដល់ព្រះនិព្វានក៏ដើម្បីលះបង់ចោលមិច្ឆាទិដ្ឋិ , ដើម្បីបន្ទោបង់កាមរាគៈ និងព្យាបាទៈ

ឲ្យស្រោលស្តើងចុះ , ដើម្បីលះកាមរាគៈ និងព្យាបាទៈ មិនមានចំណែកសល់ ដើម្បីលះរូបរាគៈ អរូបរាគៈ មានះ ឧទ្ធច្ចៈ និងអវិជ្ជាមិនមានចំណែកសល់ពីលំដាប់នៃការពោល លោកបានសម្តែងទុកហើយក្នុងអដ្ឋកថា ។

ក៏លំដាប់នោះមាន ៥ យ៉ាង គឺ លំដាប់នៃការកើតឡើង , លំដាប់នៃការប្រហារ , លំដាប់នៃការបដិបត្តិ , លំដាប់នៃភូមិ , លំដាប់នៃទេសនា ។

**ពាក្យមានជាអាទិ៍យ៉ាងនេះថា ៖**

**បឋមំ កលលំ ហោតិ កលលា ហោតិ**

**អព្ពុទំ អព្ពុទា ជាយតេ បេសិ បេសិ**

**និព្វត្តតី ឃនោតិ ។**

- សប្តាហ៍ទី ១ កើតកលលៈ
- សប្តាហ៍ទី ២ ពីកលលៈ ក៏ជាអម្ពុទៈ
- សប្តាហ៍ទី ៣ ពីអព្ពុទៈកើតជាបេសិ
- សប្តាហ៍ទី ៤ ពីបេសិកើតជាឃនៈ ដូច្នេះ ឈ្មោះថា លំដាប់នៃការកើត ។



**បហាតព្វតិកមាតិកាមានជាអាទិ៍យ៉ាងនេះថា ៖**

**ទស្សនេន បហាតព្វា ធម្មា** សភាវធម៌ទាំងឡាយដែលសោតាបត្តិមគ្គគប្បីប្រហារ ។

**ភាវនាយ បហាតព្វា ធម្មា** សភាវធម៌ទាំងឡាយដែលមគ្គ ៣ ក្នុងខាងលើ គប្បីប្រហារ ដូច្នេះ ឈ្មោះថា លំដាប់នៃការលះ ។

**ពាក្យមានជាអាទិ៍យ៉ាងនេះថា ៖**

- សីលវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃសីល
- ចិត្តវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃចិត្ត ( សមាធិ )
- ទិដ្ឋិវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃទិដ្ឋិ ( បញ្ញា )
- កង្ខាវិតរណវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃកង្ខាវិតរណៈ ( ឆ្លងផុតការសង្ស័យ ) ។
- មគ្គាមគ្គញាណទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃមគ្គាមគ្គ-ញាណទស្សនៈ ( ការឃើលដោយបញ្ញាថាជាផ្លូវនិងមិនមែនផ្លូវ ) ។
- បដិបទាញាណទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃញាណ-ទស្សន ក្នុងបដិបទា ( ការឃើញដោយបញ្ញាក្នុងការបដិបត្តិ ) ។
- ញាណទស្សនវិសុទ្ធិ សេចក្តីបរិសុទ្ធិនៃញាណទស្សនៈ ( ឃើញ

ច្បាស់ដោយបញ្ញា ) ដូច្នេះ ឈ្មោះថា លំដាប់នៃការ បដិបត្តិ ។

**ពាក្យមានជាអាទិ៍ថា ៖**

- សភាវធម៌ទាំងឡាយដែលជាកាមាវចរៈ

- សភាវធម៌ទាំងឡាយដែលជារូបាវចរៈ

- សភាវធម៌ទាំងឡាយដែលជាអរូបាវចរៈ , យ៉ាងនេះ ឈ្មោះថា លំដាប់នៃភូមិ ។

**ពាក្យមានជាអាទិ៍យ៉ាងនេះថា ៖**

សតិប្បដ្ឋាន ៤ , សម្មប្បធាន ៤ , ឥទ្ធិបាទ ៤ , ឥន្ទ្រីយ៍ ៥ , ពលៈ ៥ , ពោជ្ឈង្គ ៧ , អរិយមគ្គអង្គ ៨ ។

**ឬពាក្យមានជាអាទិថា ៖**

សម្តែងអនុបុព្វិកថា គឺ ទានកថា , សីលកថា , សគ្គកថា ប្រកាសទោសសេចក្តីថោកទាប សេចក្តីសៅហ្មងនៃកាមទាំងឡាយ និងអានិសង្សក្នុងការចេញចាកកាម ដូច្នេះ ឈ្មោះថា លំដាប់នៃការទេសនា ។

តែក្នុងទីនេះ គប្បីជ្រាបថា សំដៅយកលំដាប់ ៣ ប្រការ គឺ លំដាប់នៃការកើតឡើងនៃញាណ ១៤ , លំដាប់នៃការបដិបត្តិ , និង



លំដាប់នៃទេសនា ព្រោះសម្តែងតាមលំដាប់ ដោយអំណាចលំដាប់ទាំង ២ នោះ ។

## ១៥. អដ្ឋកថា វត្ថុនានត្តញ្ញាណុទ្ទេស

### ពោលអំពី វត្ថុនានត្តញ្ញាណ ៣

នាមរូបវវត្ថានញ្ញាណ លោកនៅមិនបានពោលទុក ដូច្នោះ ដើម្បីនឹងសម្តែងប្រភេទនៃនាមរូប ៥ យ៉ាង ក្នុងឥឡូវនេះ លោកទើបលើកយកញាណ ៥ មានពាក្យថា

**អជ្ឈត្តវវត្ថានេ បញ្ញា វត្ថុនានត្តេ ញាណំ** បញ្ញាក្នុងការកំណត់ធម៌ខាងក្នុង ជាវត្ថុនានត្តញាណ មកសម្តែងក្នុងឥឡូវនេះ ។

ពិតហើយ ក្នុងនាមរូបទាំងអស់ដែលលោកពោលហើយ , នាមរូបអាចកំណត់បាន , និងនាមរូបណាគួរកំណត់ ក៏នឹងកំណត់នាមរូបនោះ ។ ចំណែកនាមដែលជាលោកុត្តរៈ មិនអាចនឹងកំណត់បាន ព្រោះនៅមិនទាន់សម្រេច និងមិនគួរកំណត់ ព្រោះនាមដែលជាលោកុត្តរៈមិនមែនជាអារម្មណ៍របស់វិបស្សនា ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **អជ្ឈត្តវវត្ថានេ** ក្នុងការកំណត់ធម៌ខាងក្នុង ដោយសេចក្ដីថា ឈ្មោះថា **អជ្ឈត្ត** ព្រោះអត្ថថា ធ្វើខ្លួនឲ្យជាអធិការប្រព្រឹត្តទៅដោយបំណងយ៉ាងនេះថា យើងកាលប្រព្រឹត្តទៅយ៉ាងនេះ ក៏នឹងដល់ការប្រកាន់មាំថា ជាអត្តាតួខ្លួន ។

ក៏ស័ព្ទថា **អជ្ឈត្ត** នេះ ប្រាកដអត្ថ ៤ យ៉ាង គឺ គោចរជ្ឈត្ត , និយកជ្ឈត្ត , អជ្ឈត្តជ្ឈត្ត , វិសយជ្ឈត្ត ។

ដែលអត្ថក្នុង **គោចរជ្ឈត្ត** នេះ រមែងប្រាកដក្នុងបាលីអាគតស្ថានថា ម្នាលអានន្ទ ភិក្ខុនោះតំកល់ចិត្តខាងក្នុងឲ្យតាំងមាំ ក្នុងសមាធិនិមិត្តខាងដើមនោះ ហើយជាអ្នកត្រេកអរក្នុងធម៌ខាងក្នុង ជាអ្នកមានចិត្តតាំងមាំហើយ ដូច្នេះ ជាដើម ។

អត្ថក្នុង **និយកជ្ឈត្ត** រមែងប្រាកដក្នុងបាលីអាគតស្ថានថា មានសេចក្ដីផូរផង់នៃចិត្តក្នុងខាងក្នុង ឬភិក្ខុពិចារណាក្នុងធម៌ខាងក្នុង ដូច្នេះ ជាដើម ។

អត្ថក្នុង **អជ្ឈត្តជ្ឈត្ត** រមែងប្រាកដក្នុងបាលីអាគតស្ថានថា អាយតនៈខាងក្នុង ៦ និងសភាវធម៌ទាំងឡាយដែលជាខាងក្នុង ជាដើម ។



អត្ថក្នុង **វិសយជ្ឈត្ត** រមែងប្រាកដក្នុងបាលីអាគតស្ថានថា ម្នាលអានន្ទ ក៏វិហារធម៌ដែលតថាគតត្រាស់ដឹងហើយនេះ គឺ តថាគតចូលសុញ្ញតខាងក្នុង ព្រោះមិនយកចិត្តទុកដាក់នឹងនិមិត្តទាំងពួង ដូច្នេះជាដើម ។ អធិប្បាយថា វិសយជ្ឈត្តនេះ រមែងប្រាកដក្នុងអត្ថថា **ឥស្សរិយឋាន** ។ ពិតហើយ ផលសមាបត្តិ ឈ្មោះថាជាឥស្សរិយឋានរបស់ព្រះពុទ្ធជាម្ចាស់ទាំងឡាយ ។ តែក្នុងទីនេះ គប្បីឃើញថា សំដៅយកក្នុងអត្ថថា **អជ្ឈត្តជ្ឈត្ត** ។ ក្នុងការកំណត់អជ្ឈត្តទាំងនោះ ឈ្មោះថា អជ្ឈត្តវវត្ថានេ ក្នុងការកំណត់អជ្ឈត្ត ។

ពាក្យថា **វត្ថុនានត្តេ** បានដល់ ក្នុងការខុស ៗ គ្នា នៃវត្ថុទាំងឡាយ , អធិប្បាយថា ក្នុងវត្ថុផ្សេង ៗ ។ ក្នុងទីនេះ សូម្បីកវង្គចិត្តដែលជាបច្ច័យដល់មនោវិញ្ញាណ គឺ ជវនៈ លោកក៏ហៅថាវត្ថុ ព្រោះជាឋានៈដែលកើតឡើងដូចពួកបសាទទាំង ៥ មានចក្ខុបសាទជាដើម ដូច្នោះ ។ សូម្បីអាវជ្ជនចិត្ត ក៏គប្បីធ្វើឲ្យជាទីអាស្រ័យរបស់វត្ថុនោះបានដូចគ្នា ។

~ * ~

## ១៦. អដ្ឋកថា គោចរនានត្តញ្ញាណុទ្ទេស

### ពោលអំពី គោចរនានត្តញ្ញាណ

ពាក្យថា **ពហិទ្ធា** ខាងក្រៅ សេចក្តីថា ក្នុងអារម្មណ៍នៃញាណទាំងនោះដែលមានក្រៅពីធម៌ដែលជាអជ្ឈត្តជ្ឈត្ត ៦ ។

ពាក្យថា **គោចរនានត្តេ** ក្នុងសេចក្តីផ្សេង ៗ នៃគោចរ បានដល់ ក្នុងសេចក្តីផ្សេង ៗ នៃវិស័យ គឺ អារម្មណ៍ ។

## ១៧. អដ្ឋកថា ចរិយានានត្តញ្ញាណុទ្ទេស

### ពោលអំពី ចរិយានានត្តញ្ញាណ

ពាក្យថា **ចរិយវវត្ថានេ** ក្នុងការកំណត់ចរិយា សេចក្តីថា ក្នុងការកំណត់ចរិយា គឺ វិញ្ញាណចរិយា អញ្ញាណចរិយា និងញាណចរិយា ។ អាចារ្យពួកខ្លះធ្វើរស្សៈខ្លះ ហើយសូត្រថា **ចរិយា-វវត្ថានេ** ។

~ * ~



## ១៨. អដ្ឋកថា ភូមិនានត្តញ្ញាណុទ្ទេស

### ពោលអំពី ភូមិនានត្តញ្ញាណ

ពាក្យថា **ចតុធម្មវវត្ថានេ** ក្នុងការកំណត់ធម៌ ៤ យ៉ាង សេចក្តីថា ក្នុងការកំណត់ធម៌ម្យ៉ាង ៤ ដោយអំណាចនៃធម៌ទាំង-ឡាយ ១៤ មានធម៌ក្នុងកាមាវចរភូមិជាដើម មួយពួក ៤ ៗ ។

ក៏ពាក្យថា ភូមិ ភាគ តំបន់ រមែងប្រព្រឹត្តទៅក្នុងអត្ថថា បឋវីផែនដី ដូចក្នុងប្រយោគថា មាសប្រាក់ដែលមាននៅក្នុងផែនដីទាំងដែលមាននៅក្នុងអាកាសជាដើម ។ ប្រព្រឹត្តទៅក្នុងអត្ថថា វិសយស្ថានទី ដូចក្នុងប្រយោគថា កូនអើយ ឯងកុំរស់នៅក្នុងភូមិស្ថានដែលមិនសមគួរ ជាដើម ។ ប្រព្រឹត្តទៅក្នុងអត្ថថា **ឧប្បជ្ជនដ្ឋាន** ដែលជាទីកើត ដូចក្នុងប្រយោគថា កាមាវចរចិត្តដែលជាទីកើតនៃសុខវេទនាជាដើម ។ តែក្នុងទីនេះ រមែងប្រព្រឹត្តទៅក្នុង **កោដ្ឋាស** គឺ **ចំណែក** ។ អាចារ្យពួកខ្លះពោលថា រមែងប្រព្រឹត្តទៅ ក្នុងអត្ថថា **បរិច្ឆេទ** ប្រែថា **កំណត់** ក៏មាន ។

~ * ~

# ១៩. អដ្ឋកថា ធម្មនានត្តញ្ញាណុទ្ទេស

## ពោលអំពី ធម្មនានត្តញ្ញាណ

ពាក្យថា **នវធម្មវវត្ថានេ** ក្នុងការកំណត់ធម៌ ៩ សេចក្តីថា ក្នុងការកំណត់ធម៌ទាំងឡាយម៉្យាង ៗ ៩ ដោយអំណាចកាមាវចរ-កុសលចិត្ត , ដោយអំណាចនៃចិត្តមានបាមោជ្ជជាមូល , និងដោយអំណាចចិត្តមានមនសិការជាមូល ។

ក៏បណ្តាញាណទាំង ៥ ទាំងនេះ អជ្ឈត្តធម៌ ជាធម៌ដែលព្រះយោគីបុគ្គលគប្បីកំណត់មុន ។ ដូច្នោះ លោកទើបពោល **វត្ថុ-នានត្តញ្ញាណ** , ញាណក្នុងសេចក្តីផ្សេង ៗ នៃវត្ថុ ទុកជាទី ១ តពីនោះ ក៏គប្បីកំណត់អារម្មណ៍នៃនានត្តធម៌ទាំងនោះ ដូច្នោះក្នុងលំដាប់តពីនោះវត្ថុនានត្តញ្ញាណនោះលោកទើបពោលគោចរនានត្តញ្ញាណ គឺញាណនៃការខុសគ្នានៃអារម្មណ៍ , ញាណ ៣ ដទៃទៀតពីនោះលោកពោលដោយអនុលោមការរាប់ដោយអំណាចនៃធម៌ ៣ , ៤ , និង ៩ ។

~ * ~



# ២០. អដ្ឋកថា ញាតដ្ឋញ្ញាណុទ្ទេស

## ពោលអំពី ញាតដ្ឋញ្ញាណ

ឥឡូវនេះ បរិញ្ញា ៣ គឺ ការកំណត់ដឹងដោយប្រភេទនោះជាញាតប្បរិញ្ញា , តពីនោះក៏ជាតីរណប្បរិញ្ញា ក្នុងលំដាប់តទៅក៏ជាបហានប្បរិញ្ញា , និងភាវនាការចម្រើនសច្ចិកិរិយា ការធ្វើឲ្យដឹងក៏រមែងមានដោយបរិញ្ញា ៣ នោះ , ព្រោះដូច្នោះ លោកទើបលើកយកញាណទាំង ៥ មានញាតដ្ឋញ្ញាណ ជាដើម ឡើងសម្តែងតពីធម្មនានត្តញ្ញាណ ។

ក៏បរិញ្ញាណ ៣ គឺ ញាតប្បរិញ្ញា , តីរណប្បរិញ្ញា និងបហានប្បរិញ្ញា ។ ក្នុងបរិញ្ញាទាំង ៣ នោះដូច្នេះ ៖

បញ្ញា ដែលប្រព្រឹត្តទៅក្នុងការកំណត់លក្ខណៈដោយចំពោះនៃសភាវធម៌ទាំងនោះ ៗ យ៉ាងនេះថា រូបមានការបែកធ្លាយទៅជាលក្ខណៈ , វេទនាមានការសោយអារម្មណ៍ជាលក្ខណៈ ឈ្មោះថាញាតប្បរិញ្ញា ។

វិបស្សនាបញ្ញា មានលក្ខណៈជាអារម្មណ៍ លើកសាមញ្ញលក្ខណៈ

នៃសភាវធម៌ទាំងនោះ ៗ ឡើង ប្រព្រឹត្តទៅដោយន័យជាដើមថា **រូបំ អនិច្ចំ ទុក្ខំ អនត្តា** រូបមិនទៀង ជាទុក្ខ ជាអនត្តា , **វេទនា អនិច្ចា ទុក្ខា អនត្តា** វេទនាមិនទៀង ជាទុក្ខ ជាអនត្តា យ៉ាងនេះ ឈ្មោះថា **តីរណបរិញ្ញា** ។

ក៏វិបស្សនា ដែលមានលក្ខណៈជាអារម្មណ៍ ប្រព្រឹត្តទៅដោយអំណាចនៃការលះវិបល្លាសទាំងឡាយ មាននិច្ចសញ្ញាវិបល្លាស ជាដើមក្នុងធម៌ទាំងឡាយនោះបាន ឈ្មោះថា **បហានបរិញ្ញា** ។

បណ្តាបរិញ្ញាទាំង ៣ នោះ ចាប់ផ្តើមពីសង្ខារបរិច្ឆេទញ្ញាណ ញាណក្នុងការកំណត់សង្ខារធម៌ រហូតដល់បច្ច័យបរិគ្គហញ្ញាណ ញាណក្នុងការកំណត់បច្ច័យក្នុងសង្ខារធម៌ ជាភូមិរបស់ញាតបរិញ្ញា ។ ព្រោះក្នុងរវាងនេះ ភាពជាអធិបតី រមែងមានដល់ព្រះយោគីបុគ្គលអ្នកចាក់ធ្លុះលក្ខណៈដោយចំពោះៗរបស់សភាវធម៌ទាំងឡាយបាន ។

តាំងពីកលាបសម្មសនញ្ញាណ ញាណក្នុងការពិចារណាសង្ខារធម៌ដោយកលាបៈ រហូតដល់ឧទយព្វយានុបស្សនាញាណ ញាណក្នុងការឃើញរឿយ ៗ នូវការកើតឡើង និងរលត់ទៅរបស់សង្ខារធម៌ ព្រោះក្នុងរវាងនេះ ភាពជាអធិបតី រមែងមានដល់ព្រះ-



យោគីបុគ្គលអ្នកចាក់ធ្លុះសាមញ្ញលក្ខណៈបាន ។

ផ្តើមពីភង្គានុបស្សនាញាណ ញាណក្នុងការឃើញរឿយ ៗ នូវការរលត់សង្ខារធម៌ឡើងទៅ ជាភូមិនៃបហានបរិញ្ញា ។ ព្រោះចាប់ផ្តើមអំពីនោះទៅ ភាពជាអធិបតី រមែងមានដល់អនុបស្សនា ៧ ដែលនឹងឲ្យសម្រេចការចូលលះវិបល្លាស មាននិច្ចសញ្ញាវិបល្លាសជាដើមបាន យ៉ាងនេះគឺ កាលបើពិចារណាឃើញជារបស់មិនទៀងក៏រមែងលះនិច្ចសញ្ញាវិបល្លាសបាន , កាលបើពិចារណាឃើញដោយសេចក្តីជាទុក្ខ ក៏លះសុខវិបល្លាសសញ្ញាបាន , កាលបើពិចារណាឃើញដោយសេចក្តីជាអនត្តា ក៏លះអត្តសញ្ញាវិបល្លាសបាន , កាលបើនឿយណាយ ក៏លះសេចក្តីត្រេកអរបាន , កាលបើប្រាសចាកតម្រេក ក៏លះរាគៈបាន , កាលបើឲ្យរលត់ ក៏លះសមុទយៈបាន , កាលបើលះមិនឲ្យត្រឡប់មកវិញបាន ក៏លះសេចក្តីប្រកាន់មាំបានដូច្នេះ ។

បណ្តាពាក្យទាំងនោះ ពាក្យថា **អភិញ្ញាបញ្ញា** បានដល់បញ្ញាជាគ្រឿងដឹងតាមភាវៈមានរូប្បនលក្ខណៈ គឺ រូបមានការបែកធ្លាយទៅជាលក្ខណៈជាដើម នៃសភាវៈធម៌ទាំងឡាយ ។ ពិតហើយ

បញ្ញានោះ លោកហៅថា **អភិញ្ញា** ព្រោះអធិប្បាយដោយ **អភិ** ស័ព្ទ មានអត្ថថា ក្រៃលែង យ៉ាងនេះ គឺ ការដឹងដ៏ក្រៃលែង ដោយអំណាចនៃការដឹងសភាវៈរបស់ធម៌ទាំងនោះ ។

ពាក្យថា **ញាតដ្ឋេ ញាណំ** ញាណក្នុងអត្ថថា ដឹង បានដល់ ញាណ ដែលមានការដឹងជាសភាវៈ ។

## ២១_ អដ្ឋកថា តីរណដ្ឋញ្ញាណុទ្ទេស

### ពោលអំពី តីរណដ្ឋញ្ញាណ

ពាក្យថា **បរិញ្ញាបញ្ញា** បានដល់ បញ្ញាជាគ្រឿងដឹង ។ ពិតហើយ បញ្ញានោះ លោកហៅថា **បរិញ្ញា** ព្រោះអធិប្បាយថា ដោយ **បរិ** ស័ព្ទ មានអត្ថថា ផ្សាយទៅជុំវិញ ដូច្នេះ សេចក្តីដឹងដែលផ្សាយទៅដោយអំណាចនៃសាមញ្ញលក្ខណៈ មានអនិច្ចលក្ខណៈជាដើម ឬដោយអំណាចនៃការចូលដល់កិច្ចរបស់ខ្លួន ។

ពាក្យថា **តីរណដ្ឋេ ញាណំ** ញាណក្នុងអត្ថថា សញ្ជឹងគិត បានដល់ ញាណមានការចូលទៅសញ្ជឹងគិតជាសភាវៈ ឬមានការ



ពិចារណាជាសភាវៈ ។

## ២២. អដ្ឋកថា បរិច្ចាគដ្ឋញ្ញាណុទ្ទេស

### ពោលអំពី បរិច្ចាគដ្ឋញ្ញាណ

ពាក្យថា **បហានេ បញ្ញា** បញ្ញាក្នុងការលះ សេចក្តីថា បញ្ញាជាគ្រឿងលះវិបល្លាសទាំងឡាយ មាននិច្ចសញ្ញាវិបល្លាសជាដើម , ឬធម្មជាតិណា រមែងលះនិច្ចសញ្ញាវិបល្លាសជាដើមបាន ដូច្នេះ ធម្មជាតិនោះឈ្មោះថា **បជ្ជនាបញ្ញា** , មយ៉ាងទៀត ព្រះ-យោគីបុគ្គល រមែងលះនិច្ចសញ្ញាវិបល្លាសបាន ដោយញាណនោះ ដូច្នោះ ញាណ នោះទើបឈ្មោះថា **បហានំ ញាណំ** ញាណជាគ្រឿងលះបង់និច្ចសញ្ញាវិបល្លាស ។

ពាក្យថា **បរិច្ចាគដ្ឋេ ញាណំ** ញាណក្នុងអត្ថថា លះបង់ បានដល់ ញាណមានការលះបង់និច្ចសញ្ញាវិបល្លាសជាដើម ជាសភាវៈ ។

~ * ~

## ២៣. អដ្ឋកថា ឯករសដ្ឋញ្ញាណុទ្ទេស

### ពោលអំពី ឯករសដ្ឋញ្ញាណ

ពាក្យថា **ភាវនាបញ្ញា** បញ្ញាជាគ្រឿងអប់រំ បានដល់ បញ្ញាជាគ្រឿងចម្រើន ។

ពាក្យថា **ឯករសដ្ឋេ ញាណំ** ញាណក្នុងអត្ថថា មានរសតែមួយ បានដល់ ញាណមានកិច្ចតែមួយជាសភាវៈ , ឬញាណមានរសដែលជាសភាវៈ គឺ **វិមុត្តិ** ។

## ២៤. អដ្ឋកថា ផស្សនដ្ឋញ្ញាណុទ្ទេស

### ពោលអំពី ផស្សនដ្ឋញ្ញាណ

ពាក្យថា **សច្ឆិកិរិយាបញ្ញា** បញ្ញាជាគ្រឿងធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ បានដល់ បញ្ញា ជាគ្រឿងធ្វើឲ្យនិព្វានប្រច័ក្សច្បាស់ដោយអំណាចនៃការចាក់ធ្លុះ ឬដោយអំណាចពីការបានចំពោះ ។

ពាក្យថា **ផស្សនដ្ឋេ ញាណំ** បានដល់ ញាណមានការបាននូវព្រះនិព្វានជាសភាវៈ ដោយអំណាចនៃការចាក់ធ្លុះ និងការបាន



ចំពោះទាំង ២ នោះឯង ។

## ២៥_២៨ អដ្ឋកថា

## អត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បសម្ភិទា

## បដិភាណប្បដិសម្ភិទាញាណុទ្ទេស

### ពោលអំពី បដិសម្ភិទាញាណ ៤

ឥឡូវនេះ ញាណក្នុងការលះ ក្នុងការចម្រើន និងក្នុងការធ្វើព្រះនិព្វានឲ្យជាក់ច្បាស់ រមែងប្រកបដោយអរិយមគ្គ អរិយផល ដូច្នោះ លោកទើបលើកយកបដិសម្ភិទាញាណ ៤ របស់ព្រះអរិយ-បុគ្គលនោះឯង និងត្រូវលើកសម្តែងតពីផស្សនញ្ញាណនោះ ។

សូម្បីក្នុងបដិសម្ភិទា ៤ នោះ **អត្ថ** គឺ ផលធម៌ដែលកើតអំពីបច្ច័យ រមែងប្រាកដដូចទុក្ខសច្ចៈ និងធម៌ដែលអ្នកណា ៗ នឹងគប្បីដឹងបានដោយងាយ ព្រោះដូច្នោះទើបលោកលើកយក **អត្ថ-ប្បដិសម្ភិទាញាណ** ឡើងសម្តែងមុន តពីនោះក៏យក **ធម្មប្បដិសម្ភិទា** ឡើងសម្តែង ព្រោះអត្ថនោះ ជាវិស័យនៃធម៌ដែលជាហេតុ , តពីនោះ

ទើបលើកយក **និរុត្តិប្បដិសម្ភិទាញាណ** ព្រោះអត្ថ និងធម៌ ទាំង ២ នោះជាវិស័យនៃនិរុត្តិ , និងតពីនិរុត្តិប្បដិសម្ភិទាញាណនោះ លោកក៏លើកយក **បដិភាណប្បដិសម្ភិទាញាណ** ឡើងសម្តែង ព្រោះប្រព្រឹត្តទៅសូម្បីទាំង ៣ នោះ ។ តែអាចារ្យពួកខ្លះធ្វើទីឃៈ **ប** អក្សរ ហើយសូត្រក៏មាន ។

## ២៩_៣១ អដ្ឋកថា វិហារដ្ឋសមាបត្តិដ្ឋញ្ញាណុទ្ទេស

## ពោលអំពី វិហារដ្ឋញ្ញាណ និងសមាបត្តិដ្ឋញ្ញាណ

ញាណទាំងឡាយដទៃពីនេះ ៣ មានវិហារដ្ឋញ្ញាណជាដើម លោកលើកឡើងសម្តែងតពីបដិសម្ភិទាញាណ ព្រោះកើតដល់ព្រះអរិយបុគ្គលប៉ុណ្ណោះ និងព្រោះជាប្រភេទនៃបដិសម្ភិទា ។

ពិតហើយ វិហារដ្ឋញ្ញាណ ជាធម្មប្បដិសម្ភិទា សមាបត្តិដ្ឋញ្ញាណ ជាអត្ថប្បដិសម្ភទា ។ ពិតណាស់ ញាណក្នុងសភាវធម៌ លោកពោលទុក ក្នុងបដិសម្ភិទាកថា ថា ធម្មប្បដិសម្ភិទា ។ ចំណែកញាណក្នុងនិព្វាន ជាអត្ថប្បដិសម្ភិទា នោះឯង ។



បណ្តាពាក្យទាំងនោះ **វិហារនានត្តេ** ក្នុងសេចក្តីផ្សេងនៃធម៌ជាគ្រឿងនៅ សេចក្តីថា ក្នុងធម៌ជាគ្រឿងនៅ គឺ វិបស្សនាផ្សេង ៗ ដោយអំណាចអនិច្ចានុបស្សនាជាដើម ។

ពាក្យថា **វិហារដ្ឋេ** ក្នុងអត្ថថា ធម៌ជាគ្រឿងនៅ បានដល់ក្នុងធម៌ជាគ្រឿងនៅ គឺ មានវិបស្សនាជាសភាវៈ ។

ពាក្យថា **វិហារោ** បានដល់ វិបស្សនាព្រមដោយសម្បយុត្តធម៌ [1] នោះឯង ។

ពាក្យថា **សមាបត្តិនានត្តេ** ក្នុងសេចក្តីផ្សេងគ្នានៃសមាបត្តិ សេចក្តីថា ក្នុងផលសមាបត្តិដោយអំណាចនៃអនិមិត្តនិព្វានជាដើម។

ពាក្យថា **សមាបត្តិ** សមាបត្តិ បានដល់ ចិត្ត និងចេតសិកធម៌ទាំងឡាយដែលជាលោកុត្តរផល ។

ពាក្យថា **វិហារសមាបត្តិនានត្តេ** ក្នុងវិហារធម៌ និងភាពផ្សេងគ្នានៃសមាបត្តិ លោកពោលហើយដោយអំណាចនៃញាណទាំង ២។

---

[1] **សម្បយុត្តធម៌** បានដល់ មហាកុសលញាណសម្បយុត្តចិត្ត ៤ ចេតសិក ៣៥ ( វៀរអប្បមញ្ញា ២ ព្រោះក្នុងខណៈវិបស្សនាកើត មិនមានសត្តប្បញ្ញត្តិជាអារម្មណ៍ , និងបញ្ញាចេតសិក ១ ព្រោះបញ្ញា ជាតួវិបស្សនា ) ។

## ៣២. អដ្ឋកថា អានន្តរិកសមាធិញ្ញាណុទ្ទេស

### ពោលអំពី អានន្តរិកសមាធិញ្ញាណ

ញាណទាំង ២ នោះឯង ដែលព្រះធម្មសេនាបតីសារីបុត្រ លោកមានបំណងនឹងពោលដោយប្រការដទៃទៀត ឲ្យពិសេសដោយហេតុដែលសម្ដែងដល់មគ្គញាណ សូម្បីបានពោលហើយក្នុងកាលមុនថា **ទុភតោ វុដ្ឋានវិវដ្ដនេ បញ្ញា** បញ្ញាក្នុងការចេញ និងចៀសចេញពីកិលេសខន្ធ និងសង្ខារនិមិត្តខាងក្រៅទាំង ២ ដែលឲ្យសម្រេចវិហារញ្ញាណ និងសមាបត្តិញ្ញាណទាំង ២ នោះ ជាញាណដែលលះបង់អាសវៈបានជាសមុច្ឆេទ និងជាញាណដែលឲ្យផលតាមលំដាប់ ដោយលើកឡើងសម្ដែងថា **អានន្តរិកសមាធិម្ហិ ញាណំ** ញាណក្នុងសមាធិដែលមានក្នុងលំដាប់ តពីញាណទាំង ២ នោះ ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **អវិក្ខេបបរិសុទ្ធត្តា** សេចក្ដីបរិសុទ្ធិនៃសមាធិដែលមិនរាយមាយ សេចក្ដីថា ចិត្ត រមែងរាយ-មាយទៅដោយធម្មជាតិនោះ ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា វិក្ខេបៈ សេចក្ដីរាយមាយពាក្យនេះជាឈ្មោះរបស់ឧទ្ធច្ចៈ , ធម្មជាតិ



នេះមិនមែនវិក្ខេបៈ សេចក្ដីរាយមាយឈ្មោះថា អវិក្ខេបៈ មិនរាយ-មាយ , ពាក្យនេះជាឈ្មោះរបស់សមាធិ ជាបដិបក្ខដល់ឧទ្ធច្ចៈ ។

សភាពនៃសេចក្ដីបរិសុទ្ធិ ឈ្មោះថា **បរិសុទ្ធត្ត** សេចក្ដីបរិសុទ្ធិ , សេចក្ដីបរិសុទ្ធិនៃសមាធិ ឈ្មោះថា អវិក្ខេបបរិសុទ្ធត្ត សេចក្ដីបរិសុទ្ធិនៃសមាធិដែលមិនរាយមាយ , ដូច្នោះ **អវិក្ខេបប-រិសុទ្ធត្តា** ទើបមានអធិប្បាយថា ព្រោះជាសភាពនៃសេចក្ដីបរិសុទ្ធិរបស់សមាធិ ។ ពិតហើយ ពាក្យនេះ ជាតតិយាវិភត្តិប្រាប់ហេតុនៃការលះបង់អាសវៈបានដោយដាច់ខាត និងការឲ្យផលក្នុងលំដាប់នៃខ្លួន ។ ក្នុងពាក្យថា **អាសវសមុច្ឆេទេ** ក្នុងការលះបង់អាសវៈបានដោយមិនមានសល់ មានវិនិច្ឆ័យដូចតទៅនេះ ៖

ធម្មជាតិណា រមែងហូរទៅ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **អាសវ** លោកពោលពាក្យអធិប្បាយទុកថា អាសវៈទាំងឡាយ រមែងហូរទៅ គឺ រមែងប្រព្រឹត្តទៅតាមផ្លូវភ្នែកខ្លះ ។ល។ ផ្លូវចិត្តខ្លះ ។ អាសវៈទាំងឡាយ កាលបើនិយាយដោយធម៌ រមែងហូរទៅដល់គោត្រភូ ឬកាលបើនិយាយដោយឱកាស គឺ ជាស្ថានភូមិ ដែលជាទីនៅរបស់សត្វ រមែងហូរទៅដល់ភវគ្គកព ដូច្នោះទើបឈ្មោះថា

**អាសវ** អធិប្បាយថា អាសវៈទាំងឡាយរមែងគ្របសង្កត់ទាំងធម៌នោះផង ទាំងឱកាសនោះផង ប្រព្រឹត្តទៅ ។ ពិតហើយ **អា** អក្សរនេះ មានអត្ថថា ធ្វើក្នុងខាងក្នុង ។

មេរ័យ ដែលឈ្មោះថា មទិរៈជាដើម ឈ្មោះថា **អាសវ** ព្រោះដូចជារបស់ត្រាំ ព្រោះអត្ថថា ត្រាំមកយូរ ។ ពិតហើយ មេរ័យដែលឈ្មោះថា មទិរៈជាដើម ព្រោះត្រាំមកយូរក្នុងផ្លូវលោក លោករមែងហៅថា **អាសវ** ។ ក៏បើឈ្មោះថា **អាសវ** ព្រោះអត្ថថា ត្រាំមកយូរហើយ អាសវៈទាំងនោះ ក៏រមែងនឹងមានបាន សមពិត ដូចពាក្យដែលលោកពោលទុកថា ៖

**ម្នាលភិក្ខុទាំងឡាយ ខាងដើមនៃអវិជ្ជារមែង**
**មិនប្រាកដ , ក្នុងកាលមុនពីនេះ អវិជ្ជាមិនបានមាន**
**ហើយ តែក្រោយមក ទើបមានយ៉ាងនេះជាដើម ។**

មួយ៉ាងទៀត ធម្មជាតិណារមែងទៅ គឺ រមែងហូរទៅកាន់សង្សារទុក្ខតទៅ សូម្បីព្រោះហេតុនោះ ធម្មជាតិនោះទើបឈ្មោះថា **អាសវ** , អាសវៈទាំងឡាយ រមែងអស់ទៅដោយមគ្គនោះ ដូច្នោះ មគ្គនោះ ទើបឈ្មោះថា **សមុច្ឆេទ** ជាគ្រឿងលះបង់អាសវៈមិនមាន



សល់ ។

ពាក្យថា **បញ្ញា** បានដល់ បញ្ញាក្នុងការកម្ចាត់អាសវៈ ៤ មានកាមាសវៈជាដើមបាន ដោយមិនមានសេសសល់ ។

ពាក្យថា **អានន្តរិកសមាធិម្ហិ ញាណំ** ញាណក្នុងសមាធិដែលឲ្យផលក្នុងលំដាប់ សេចក្តីថា សមាធិក្នុងមគ្គ បានឈ្មោះថា **អនន្តរិក** ព្រោះទៀងតែឲ្យផលក្នុងលំដាប់នៃការប្រព្រឹត្តទៅរបស់ខ្លួន ។ ព្រោះកាលបើមគ្គសមាធិកើតឡើងហើយ អន្តរាយអ្វីៗ ដែលនឹងរារាំងចំពោះការកើតឡើងនៃផលសមាធិនោះ រមែងមិនមាន ។ ដូចដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ៖

**បុគ្គលនេះ គប្បីជាអ្នកបដិបត្តិធ្វើឲ្យជាក់ច្បាស់**
**នូវសោតាបត្តិផល និងវេលាដែលភ្លើងឆេះកប្បនឹង**
**គប្បីមាន កប្បក៏មិនគប្បីឆេះដរាបណាដែលបុគ្គល**
**នេះ នៅមិនទាន់ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល**
**បុគ្គលនោះហៅថា ឋិតកប្បី ។ បុគ្គលជាអ្នកព្រម-**
**ព្រៀងដោយមគ្គសូម្បីទាំងអស់ ឈ្មោះថា ជាអ្នក**
**មានកប្បតាំងនៅហើយ ដូច្នេះ ។**

នេះជាញាណដែលសម្បយុត្តដោយអានន្តរិកសមាធិនោះ ។

## ៣៣. អដ្ឋកថា អរណវិហារញ្ញាណុទ្ទេស

### ពោលអំពី អរណវិហារញ្ញាណ

ញាណទាំង ៤ មានអរណវិហារញ្ញាណជាដើម លោកលើកឡើងសម្តែងក្នុងលំដាប់នៃញាណនេះ ព្រោះកើតឡើងដល់ព្រះអរិយទាំងឡាយជាអ្នកសម្រេចអរិយផលដោយមគ្គញ្ញាណនេះប៉ុណ្ណោះ ។

ក៏ក្នុងញាណទាំង ៤ នោះ លោកលើកអរណវិហារញ្ញាណឡើងសម្តែងមុន ព្រោះកើតជាប់គ្នាក្នុងព្រះអរហន្តនោះឯង និងកើតតពីនោះ លោកក៏លើកនិរោធសមាបត្តិញ្ញាណឡើងសម្តែង ព្រោះនិរោធសមាបត្តិនោះ ជាធម៌មានសំភារៈច្រើន សូម្បីក្នុងកាលកើតដល់ព្រះអនាគាមី និងព្រះអរហន្ត និងព្រោះនិរោធសមាបត្តិជាធម៌ដែលលោកសន្មតថា ជានិព្វានដោយពិសេស តពីនោះ លោកក៏លើកបរិនិព្វានញ្ញាណឡើងសម្តែងថា **ទីឃកាលលិក** មានកាលយូរ ព្រោះតាំងនៅអស់កាលជាទីបរិនិព្វានក្នុងរវាងកាលបរិនិព្វាន , ក្នុង



លំដាប់តពីនោះ ក៏លោកលើកឡើងសមសីសដ្ឋញ្ញាណឡើងសម្តែងថា **រស្សកាលិក** មានកាលខ្លី ព្រោះតាំងនៅអស់កាលជាទីបរិនិព្វានក្នុងលំដាប់នៃការអស់កិលេសទាំងពួង របស់ព្រះអរហន្តដែលជា **សមសីស** ។

បណ្តាពាក្យទាំងនោះ **ច** អក្សរ ក្នុងពាក្យថា **សន្តោ ច** គប្បីប្រែគួបចូលជាមួយបទសូម្បីទាំង ៣ យ៉ាងនេះ គឺ **ទស្សនាធិបតេយ្យំ ច សន្តោវិហារាគមោ ច បណីតាធិមុត្តតា ច** ។

( គប្បីជ្រាបការអធិប្បាយដូចតទៅនេះ )

ពាក្យថា **ទស្សនំ** ការឃើញ បានដល់ វិបស្សនាញាណ , ភាពជាធំនោះឯង ឈ្មោះថា **អាធិបតេយ្យ** សភាពជាធំ , ម្យ៉ាងទៀតព្រោះសម្រេចដល់ដោយអធិបតី ទើបឈ្មោះថា **អាធិបតេយ្យំ** ភាពជាធំ , **ទស្សន** គឺ វិបស្សនាញាណនោះផង ជាអាធិបតេយ្យផង ដូច្នោះទើបឈ្មោះថា **ទស្សនាធិបតេយ្យ** វិបស្សនាញាណជាអធិបតិ[1] ។

ធម៌ណារមែងនៅ ដូច្នោះធម៌នោះ ឈ្មោះថា **វិហារ** ឬថា

---

**១ វិមំសាធិបតិ ។**

ព្រះយោគីបុគ្គលរមែងនៅដោយធម៌នោះ ដូច្នោះ ធម៌នោះឈ្មោះថា **វិហារ** ជាគ្រឿងនៅរបស់ព្រះយោគីបុគ្គល , ធម៌ណាដែលព្រះ-យោគីបុគ្គលរមែងដល់ការគ្របសង្កត់ គឺ រមែងសម្រេច ដូច្នោះ ធម៌នោះឈ្មោះថា **អធិគម** ធម៌ដែលព្រះយោគីបុគ្គលសម្រេចវិ-ហារធម៌នោះឯង ជាអង្គគុណដែលសម្រេច ដូច្នោះទើបឈ្មោះថា **វិហារាធិគម** វិហារធម៌ដែលបានសម្រេច ។

ក៏វិហារាធិគមនុ៎ះ ជានិព្វុតៈ រលត់មិនមានសល់ ព្រោះវៀរពីការបៀតបៀនរបស់កិលេស ដូច្នោះទើបឈ្មោះថា **សន្ត** ស្ងប់ ។ ក៏សន្តៈនោះ គឺ អរហត្តផលសមាបត្តិប្បញ្ញា ។

ព្រោះអត្ថថា ខ្ពស់បំផុត និងព្រោះអត្ថថា មិនធ្វើឲ្យក្តៅក្រហាយ ទើបឈ្មោះថា **បណីត** , ម្យ៉ាងទៀតឈ្មោះថា **បណីត** ព្រោះទៅកាន់ភាពជាប្រធាន , ការមានចិត្តបង្អោនទៅ គឺ មានចិត្តបញ្ជូនទៅហើយក្នុងបណីតៈ មានផលសមាបត្តិនោះដ៏ក្រៃលែង ឈ្មោះថា **បណីតាធិមុត្ត** បង្អោនចិត្តទៅក្នុងផលសមាបត្តិ , សេចក្តីថា ជាកន្លែងបង្អោនចិត្តទៅក្នុងផលសមាបត្តិនោះ ឈ្មោះថា **បណីតា-ធិមុត្តតា** ការបង្អោនចិត្តទៅក្នុងផលសមាបត្តិដ៏ប្រណីត ក៏ក្នុងបណី-



តាធិមុត្តតានោះ ជាបុព្វភាគបញ្ញា មានការបង្អោនចិត្តទៅក្នុងផល-សមាបត្តិ ។

ពាក្យថា **អរណវិហារេ** ក្នុងវិហារធម៌ដែលមិនមានកិលេសជាសត្រូវ បានដល់ វិហារធម៌មានកិលេសទៅប្រាសហើយ ។ ពិតហើយ កិលេសទាំងឡាយមានរាគៈជាដើម រមែងរុករាន ញាំញីបៀតបៀន សត្វទាំងឡាយ ដូច្នោះ រាគាទិក្កិលេសនោះ ទើបឈ្មោះថា **រណា** អ្នកបៀតបៀន , ប្រការមួយទៀត សត្វទាំងឡាយរមែងយំរៀបរាប់ដោយរាគទិក្កិលេសទាំងនោះ ដូច្នោះ រាគាទិក្កិ-លេសទាំងនោះ ទើបឈ្មោះថា **រណា** កិលេសជាហេតុឲ្យសត្វយំត្អូញត្អែរ វិហារធម៌សូម្បីទាំង ៣ យ៉ាង លោកបានពោលទុកហើយ , **រណ** គឺ កិលេសជាហេតុឲ្យសត្វទួញយំ ត្អូញត្អែរ មិនមានដល់ធម៌នោះ ដូច្នេះ ធម៌នេះទើបឈ្មោះថា **អរណ** ព្រះអរិយៈរមែងនាំធម៌ដែលជាសត្រូវចេញបានដោយធម៌នោះ ដូច្នោះ ធម៌នោះឈ្មោះថា **វិហារ** នាំធម៌ដែលជាសត្រូវចេញ ។ អរណធម៌នោះ ក៏ឈ្មោះថាវិហារធម៌ ។

ក្នុងនិទ្ទេសវារៈ បឋមជ្ឈានជាដើម លោកសង្គ្រោះទុកក្នុង

បណីតាធិមុត្តតាដូចគ្នា ។ ក៏ព្រោះបំណងនឹងចូលផលសមាបត្តិ ទើបចូលឈាន មានបឋមជ្ឈានជាដើម ចេញហើយ ឃើញច្បាស់ធម៌ដែលសម្បយុត្តជាមួយឈាន , ក៏អរណបដិបទាណា ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែងហើយ ក្នុងអរណវិភង្គ-សូត្រ សូម្បីអរណបដិបទានោះ ក៏គប្បីជ្រាបថា លោកសង្គ្រោះដោយប្រការនេះឯង ។

ពិតណាស់ ក្នុងអរណវិភង្គសូត្រនោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ យើងនឹងសម្តែងធម៌ឈ្មោះអរណវិភង្គ ដល់អ្នកទាំងឡាយថា មិនគប្បីប្រកបរឿយ ៗ នូវសុខអាស្រ័យកាម ដែលអាក្រក់ ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយៈ មិនប្រកបដោយប្រ-យោជន៍ និងមិនគប្បីប្រកបរឿយៗ នូវសេចក្តីព្យាយាមគ្រឿងប្រកបខ្លួនឲ្យលំបាក ដែលជាទុក្ខ មិនមែនរបស់ព្រះអរិយៈ មិនប្រកបដោយ



ប្រយោជន៍ ការបដិបត្តិជាកណ្តាល មិនចូលជិតទីបំផុត ២ យ៉ាងនេះនោះ ដែលតថាគតដឹងព្រមដោយបញ្ញាដ៏ក្រៃលែងហើយ ជាប្រ-ការបដិបត្តិធ្វើឲ្យមានចក្ខុ ធ្វើឲ្យមានញាណប្រព្រឹត្តិទៅ ដើម្បីចូលទៅស្ងប់ ដើម្បីសេចក្តីដឹងដ៏ក្រៃលែង ដើម្បីសេចក្តីត្រាស់ដឹង , ដើម្បីនិព្វាន គប្បីស្គាល់ការលើកតម្កើង និងការតិះដៀល កាលបើដឹងហើយ មិនគប្បីលើកតម្កើងមិនគប្បីតិដៀល គប្បីសម្តែងធម៌ប៉ុណ្ណោះ , គប្បីដឹងការលះបង់សេចក្តីសុខ កាលបើដឹងហើយគប្បីប្រកបរឿយ ៗ នូវសេចក្តីសុខខាងក្នុង , មិនពោលវាទៈកំបាំងពីក្រោយ មិនគប្បីពោលពាក្យជ្រុលហួសចំពោះមុខ មិនមែនជាអ្នកប្រញាប់និយាយ កុំនិយាយប្រញាប់ប្រញាល់ មិនគប្បីបន្ទោសភាសាជនបទ មិននិយាយហួសពាក្យសាមញ្ញ នេះជាឧទ្ទេសនៃអរណ-

វិភង្គ ម្នាលភិក្ខុទាំងឡាយ ក្នុងអរណាវិភង្គនោះការមិនតាមប្រកបសេចក្តីព្យាយាមរឿយ ៗ ដែលសោមនស្ស អ្នកមានសេចក្តីសុខដោយការបន្តនៃកាម ដែលជារបស់ថោកទាប របស់អ្នកស្រុកជារបស់បុថុជ្ជន មិនមែនជារបស់ព្រះអរិយៈ មិនប្រកបដោយប្រយោជន៍ នេះជាធម៌មិនមានទុក្ខ មិនមានសេចក្តីតឹងចិត្ត មិនមានសេចក្តីតូចចិត្ត មិនមានសេចក្តីក្តៅក្រហាយ ជាសម្មាបដិបទា ។ ព្រោះដូច្នោះ ធម៌នេះឈ្មោះថា អរណាធម៌ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងអរណាវិភង្គនោះ ការមិនតាមប្រកបសេចក្តីព្យាយាម គ្រឿងប្រកបខ្លួនឲ្យលំបាក ដែលជាទុក្ខ មិនមែនរបស់ព្រះអរិយៈ មិនប្រកបដោយប្រយោជន៍ នេះជាធម៌មិនមានទុក្ខ ។ល។ ព្រោះដូច្នោះធម៌នេះឈ្មោះថា អរណាធម៌ ។



ម្នាលភិក្ខុទាំងឡាយ ក្នុងអរណាវិភង្គនោះ មជ្ឈិមាបដិបទានេះ ដែលព្រះតថាគតដឹងព្រមហើយ ។ល។ ព្រោះដូច្នោះ ធម៌នោះឈ្មោះថា អរណាធម៌ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងអរណាវិភង្គនេះការមិនលើកតម្កើង ការមិនតិះដៀល ការសម្តែងធម៌បុណ្ណោះ , នេះជាធម៌មិនមានទុក្ខ ។ល។ ព្រោះដូច្នោះ ធម៌នេះឈ្មោះថា អរណាធម៌ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងអរណាវិភង្គនោះ សុខអាស្រ័យនេក្ខម្ម សុខកើតពីសេចក្តីស្ងាត់ សុខកើតពីសេចក្តីស្ងប់ សុខកើតអំពីសេចក្តីត្រាស់ដឹង នោះជាធម៌មិនមានទុក្ខ ។ល។ ព្រោះដូច្នោះ ធម៌នេះឈ្មោថា អរណាធម៌ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងអរណាវិភង្គនោះ វាទៈកំបាំងពីក្រោយ ដែលពិត ដែលមែនប្រកបដោយប្រយោជន៍ , នេះជាធម៌មិនមាន

ទុក្ខ ។ល។ ព្រោះដូច្នោះ ធម៌នេះឈ្មោះថា អរណធម៌ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងអរណវិភង្គនោះ ពាក្យពោលលើសលោះចំពោះមុខ ដែលពិត ដែលមែន ប្រកបដោយប្រយោជន៍ នេះជាធម៌មិនមានទុក្ខ ។ល។ ដូច្នោះ ធម៌នេះឈ្មោះថា អរណធម៌ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងអរណវិភង្គនោះ ពាក្យដែលមិនប្រញាប់និយាយ នេះជាធម៌ដែលមិនមានទុក្ខ ។ល។ ព្រោះដូច្នោះ ធម៌នេះឈ្មោះថា អរណធម៌ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងអរណវិភង្គនោះ ការមិនបន្ទោសភាសាជនបទ និងការមិនហួសសាមញ្ញភាសា នេះជាធម៌មិនមានទុក្ខ ។ល។ ព្រោះដូច្នោះ ធម៌នេះ ឈ្មោះថា អរណធម៌ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះដូច្នោះ ពួកអ្នកគប្បីសិក្សាយ៉ាងនេះឯងថា យើងទាំង



ឡាយនឹងដឹងធម៌ ឈ្មោះថា សរណៈ និងដឹងធម៌ឈ្មោះថា អរណៈ កាលបើដឹងហើយនឹងបដិបត្តិ អរណបដិបទា ដូច្នេះ ។

ម្នាលភិក្ខុទាំងឡាយ ឯកុលបុត្តឈ្មោះសុភូតិ ជាអ្នកបដិបត្តិហើយ នូវអរណបដិបទា ដូច្នេះ ។

ក្នុងអរណវិភង្គសូត្រនោះ មជ្ឈិមាបដិបទា លោកសង្គ្រោះដោយទស្សនាធិបតេយ្យ ព្រះនិព្វាន និងវិហារាធិគមៈ ។

ការមិនប្រកបកាមសុខល្លិកានុយោគ និងអត្តកិលមថានុយោគ ជាមជ្ឈិមាបដិបទាពិតតែម្តង ។ ពិតហើយ សំរាប់ព្រះអរហន្តបុព្វភាគនៃវិបស្សនា ជាមជ្ឈិមាបដិបទា និងអរហត្តផលសមាបត្តិក៏ជាមជ្ឈិមាបដិបទា ដោយអំណាចនៃមគ្គមានអង្គ ៨ ។ ចំណែកបដិបទាដែលនៅសល់ គប្បីជ្រាបថា សង្គ្រោះដោយបណីតាធិមុត្តតានោះឯង ។ ព្រះអរហន្តទាំងឡាយ ជាអ្នកនៅដោយអរណធម៌ដ៏ពិតកាលយ៉ាងនោះ ព្រះអរហន្តពួកដទៃ កាលណានឹងសម្តែងធម៌ ក៏រមែងសម្តែងធម៌លើកសរសើរ និងគ្របសង្កត់ ដោយអំណាចបុគ្គលថា កុលបុត្រទាំងនោះ បដិបត្តិពេញចិត្តក្នុងសម្មាបដិបត្តិ ព្រោះ

កុលបុត្រទាំងនេះ បដិបត្តិខុសក្នុងមិច្ឆាបដិបត្តិ , តែព្រះសុភូតិថេរៈ សម្តែងធម៌ដោយអំណាចនៃធម៌ប៉ុណ្ណោះថា នេះជាមិច្ឆាបដិបត្តិ , នេះជាសម្មាបដិបត្តិ ។ ព្រោះហេតុនោះឯង ព្រះដ៏មានព្រះភាគជាម្ចាស់ទើបទ្រង់សរសើរថា ព្រះសុភូតិជាអ្នកបដិបត្តិ អរណបដិបទានោះឯង , ទ្រង់តាំងទុកក្នុងតំណែងដ៏កំពូលលើសភិក្ខុទាំងឡាយ អ្នកអរណវិហារីថា ម្នាលភិក្ខុទាំងឡាយ ព្រះសុភូតិ ប្រសើរលើសភិក្ខុសាវករបស់តថាគត ជាអ្នកមានប្រក្រតីនៅដោយ **អរណធម៌** ដូច្នេះឯង ។

## ៣៤_ អដ្ឋកថា និរោធសមាបត្តិញ្ញាណុទ្ទេស

## ពោលអំពី និរោធសមាបត្តិញ្ញាណ

ពាក្យថា **ទ្វីហិ ពលេហិ** ដោយពលៈ ២ សេចក្តីថា ដោយសមថពលៈ និងវិបស្សនាពលៈ ។

ពាក្យថា **សមន្នាគតត្តា** ព្រោះប្រកបហើយ សេចក្តីថា ព្រោះប្រកបហើយ ឬព្រោះបរិបូរណ៍ហើយ ។



ពាក្យថា **តយោ ច** សង្ខារ ៣ ជាវិភត្តិវិបល្លាស លោកពោលកែទុកថា **តិណ្ណញ្ច** ប្រែថា ៣ ។

ពាក្យថា **សង្ខារានំ** សង្ខារទាំងឡាយ បានដល់ វចីសង្ខារ កាយសង្ខារ និងចិត្តសង្ខារ ។

ពាក្យថា **បដិប្បស្សទ្ធិយា** ដើម្បីរម្ងាប់ សេចក្តីថា ដើម្បីសេចក្តីថា ស្ងប់ គឺ ដើម្បីរំលត់ , អធិប្បាយថា ដើម្បីមិនប្រព្រឹត្តទៅ ។

ពាក្យថា **សោឡសហិ** ញាណចរិយា ១៦ បានដល់ អនុបស្សនា ៨ មានអនិច្ចានុបស្សនាជាដើម , លោកុត្តរៈ ៨ គឺ មគ្គ ៤ ផល ៤ ទើបរួមជា ១៦ ។

ពាក្យថា **ញាណចរិយាហិ** ញាណចរិយាទាំងឡាយ បាន ដល់ការប្រព្រឹត្តិទៅនៃញាណ ។

ពាក្យថា **នវហិ** ដោយសមាធិចរិយា ៩ បានដល់ រូបាវចរសមាធិ ៤ អរូបាវចរសមាធិ ៤ និងឧបចារៈសមាធិ ១ ទើប រួមជា ៩ ។

ពាក្យថា **វសិភាវតា បញ្ញា** បញ្ញានៃអ្នកមានភាពជំនាញ

សេចក្តីថា **ឥស្សរិយ** ភាពជាធំដែលប្រព្រឹត្តទៅដោយសប្បាយ ក្លាម ៗ ឈ្មោះថា **វស** អំណាច , **វស** គឺ អំណាចនុ៎ះ មានដល់បុគ្គលនោះ ដូច្នោះ អ្នកនោះឈ្មោះថា **វសី** អ្នកមានអំណាច , ការរស់នៅរបស់បុគ្គលដែលមានវសី ឈ្មោះថា **វសីភាវ** , វសី-ភាវៈហ្នឹងឯង ឈ្មោះថា **វសីភាវតា** ដូច **បាតិកុល្យមេវ** ជារបស់បដិកូលនោះឯង ឈ្មោះថា **បាដិកុល្យតា** ដូច្នោះ ។ បញ្ញាមានតួយ៉ាងដូច្នេះ មានអធិប្បាយថា បញ្ញាក្នុងវសីភាវតា គឺ បញ្ញានៃអ្នកមានភាពជំនាញ ។ តែអាចារ្យពួកខ្លះ ធ្វើទីឃៈ **សិ** អក្សរហើយសូត្រ ។

**ច** ស័ព្ទ ត្រូវសម្ព័ន្ធគួបនឹង **សមន្នាគតត្តា ច** ព្រោះប្រកបជាមួយ , **បដិប្បស្សទ្ធិយា ច** ដើម្បីរម្ងាប់សង្ខារទាំងបីផង , **ញាណចរិយាហិ ច** ដោយចរិយាទាំងឡាយផង , **សមាធិចរិយាហិ** ដោយសមាធិចរិយាផង។

ពាក្យថា **និរោធសមាបត្តិយា ញាណំ** ញាណក្នុងនិរោធ-សមាបត្តិ សេចក្តីថា ញាណដែលជានិមិត្តនៃនិរោធសមាបត្តិ ឧបមាដូចខ្លាជំបង នឹងត្រូវស្លាប់ក៏ព្រោះស្បែក ។



ពាក្យថា **និរោធសមាបត្តិ** និរោធសមាបត្តិ សេចក្តីថា គ្រាន់តែថា មិនមាននេវសញ្ញានាសញ្ញាយតនៈ , និងថា ជាធម៌ណាមួយក៏មិនមែន គ្រាន់តែបញ្ញត្តិ ។ ឈ្មោះថា **និរោធ** ព្រោះហេតុត្រឹមតែថា មិនមាន , មួយទៀត ដែលព្រះអរិយបុគ្គលអ្នកចូលទៅនៅ ឈ្មោះថា រមែងចូល ដូច្នោះ លោកទើបហៅថា សមាបត្តិ ។

## ៣៥_អដ្ឋកថា បរិនិព្វានញ្ញាណុទ្ទេស

## ពោលអំពី បរិនិព្វានញ្ញាណ

ពាក្យថា **សម្បជានស្ស** អ្នកមានសម្បជញ្ញៈ សេចក្តីថា ព្រះយោគីបុគ្គលណា រមែងដឹងដោយប្រការទាំងឡាយដោយល្អ ដូច្នោះ ព្រះយោគីបុគ្គលនោះ ឈ្មោះថា **សម្បជានោ** អ្នកដឹង ដោយល្អ , នៃព្រះយោគីបុគ្គលនោះ អ្នកដឹងដោយល្អ ។

ពាក្យថា **បវត្តបរិយាទានេ** ក្នុងការគ្របសង្កត់បវត្តខន្ធ សេចក្តីថា ការប្រព្រឹត្តទៅនៃខន្ធ ឈ្មោះថា **បវត្ត** អធិប្បាយថា ការកើតឡើង ។ ការប្រព្រឹតិទៅនៃកិលេសផង ។ ការគ្របសង្កត់

ការអស់ទៅ ការមិនប្រព្រឹត្តិទៅនៃបវត្តខន្ធនោះ ឈ្មោះថា **បវត្ត-បរិយាទានំ** ការគ្របសង្កត់បវត្តខន្ធ ។ ក្នុងការគ្របសង្កត់បវត្តខន្ធនោះ ។

ពាក្យថា **បរិនិព្វានេ ញាណំ** ញាណក្នុងបរិនិព្វាន សេចក្តីថា ញាណដែលប្រព្រឹត្តទៅហើយក្នុងកិលេសបរិនិព្វាន និងខន្ធបរិនិព្វាននោះ របស់ព្រះអរហន្តអ្នកពិចារណានូវការរលត់ទៅ គឺ ការមិនប្រព្រឹត្តិទៅនៃកិលេសទាំងឡាយ មានកាមច្ឆន្ទៈជាដើម និងអនុបាទិ-សេសបរិនិព្វានរំលត់កិលេស និងខន្ធដោយមិនមានសេសសល់ ។

## ៣៦_អដ្ឋកថា សមសីសដ្ឋញ្ញាណុទ្ទេស

## ពោលអំពី សមសីសដ្ឋញាណ

ពាក្យថា **សព្វធម្មានំ** នៃធម៌ទាំងពួង សេចក្តីថា នៃធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ទាំងពួង ។

ពាក្យថា **សម្មាសមុច្ឆេទេ** ការកាត់ផ្តាច់ដោយល្អ សេចក្តីថា ក្នុងការរំលត់ដោយល្អ ដោយការកាត់ផ្តាច់សន្តតិផង ។



ពាក្យថា **និរោធេ ច អនុបដ្ឋានុតា** ក្នុងការរំលត់ផង ក្នុងការមិនប្រាកដផង សេចក្តីថា ដំណើរទៅក្នុងនិរោធ ក្នុងការមិនប្រាកដទៀត , អធិប្បាយថា មិនកើតឡើងទៀត ។

**ច** អក្សរ ត្រូវសម្ព័ន្ធជាមួយនឹង **សម្មាសមុច្ឆេទេ ច** ក្នុងការកាត់ផ្តាច់ដោយល្អផង , **និរោធ ច** ក្នុងការរំលត់ផង , **អនុបដ្ឋានតា ច** ក្នុងការមិនប្រាកដផង ។

ពាក្យថា **សមសីសដ្ឋេ ញាណំ** ញាណក្នុងអត្ថនៃធម៌ដែលស្ងប់ និងជាប្រធាន សេចក្តីថា ធម៌ ៣៧ ប្រការ មាននេក្ខម្មៈជាដើម ឈ្មោះ **សម** ធម៌ដែលស្ងប់ , ធម៌ ១៣ ប្រការ មានតណ្ហាជាដើម ឈ្មោះ **សីស** ធម៌ដែលជាប្រធាន ។ ឈ្មោះថា **សម** ព្រោះបច្ចនិកធម៌ទាំងឡាយស្ងប់ ឈ្មោះថា **សីស** ព្រោះជាប្រធានតាមសមគួរដល់ការប្រកប និងព្រោះជាកំពូល ។

ធម៌ដែលស្ងប់មាននេក្ខម្មៈជាដើម និងធម៌ដែលជាប្រធាន មានសទ្ធាជាដើម ក្នុងឥរិយាបថមួយក្តី ក្នុងរោគមួយ ក្នុងជីវិតមួយ ដោយការបន្តគ្នា ដោយស្មើភាគគ្នាក្តី មាននៅដល់អ្នកនោះ ដូច្នោះអ្នកនោះទើបឈ្មោះថា **សមសីសី** អ្នកមានធម៌ដ៏ស្ងប់ និងជាប្រធាន ,

អត្ថ គឺ ខ្លឹមសារនៃសមសីសី ឈ្មោះថា **សមសីសដ្ឋ** ក្នុងអត្ថនៃសមសីសដ្ឋនោះ , អធិប្បាយថា ក្នុងភាពជាសមសីសី ។

កាពនៃសមសីសី រមែងមានដល់ព្រះអរហន្តប៉ុណ្ណោះជាអ្នកប្រារព្ធវិបស្សនាក្នុងឥរិយាបថមួយ ឬក្នុងរោគមួយ ឬក្នុងជីវិតមួយ ដោយការបន្តគ្នា ដោយស្មើភាគ ហើយសម្រេចមគ្គ ៤ ផល ៤ ក្នុងឥរិយាបថនោះនោះឯង ឬក្នុងរោគ ក្នុងជីវិតដោយការបន្តគ្នា ដោយស្មើភាគគ្នា បរិនិព្វានហើយក្នុងខណៈនោះនោះឯង ដូច្នោះ ទើបលោកពោលទុកថា ញាណក្នុងភាពនៃសមសីសី ដូច្នេះ ។ សមពិតដូចដែលលោកពោលទុកក្នុងបុគ្គលប្បញ្ញត្តិបករណ៍ និងអដ្ឋកថានៃបករណ៍ថា ៖

*ក៏បុគ្គលឈ្មោះថា សមសីសី ដូចម្ដេច ?*

*ការអស់ទៅនៃអាសវៈ និង ការអស់ទៅនៃជីវិត របស់បុគ្គលណាមានមិនមុនមិនក្រោយគ្នា បុគ្គលនេះហៅថា សមសីសី ។*

*គប្បីជ្រាបវិនិច្ឆ័យក្នុងសមសីសីនិទ្ទេស ដូចតទៅនេះពាក្យថា អបុព្វំ អចរិមំ មិនមុនមិនក្រោយ*



*សេចក្ដីថា មិនមែនក្នុងខាងមុខ មិនមែនក្នុងខាងក្រោយ គឺក្នុងគ្រាជាមួយគ្នាដោយអំណាចនៃបច្ចុ-ប្បន្នសន្តតិ , អធិប្បាយថា ក្នុងពេលតែមួយនោះឯង ។*

*ពាក្យថា បរិយាទានំ ការប្រហារ បានដល់ការអស់ទៅជុំវិញ ។*

*ពាក្យថា អយំ បុគ្គលនេះ សេចក្ដីថា បុគ្គលនេះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ហៅឈ្មោះថា សមសីសី ។ ក៏សមសីសីបុគ្គលនេះនោះ មាន ៣ ជំពូក គឺ ឥរិយាបថសមសីសី ១ , រោគសមសីសី ១ ជីវិតសមសីសី ១ ។*

បណ្ដាសមសីសីបុគ្គលទាំង ៣ ជំពូកនោះ បុគ្គលណាកំពុងចង្ក្រមផ្ដើមតាំងវិបស្សនាហើយសម្រេចព្រះអរហត្ត នៅដោយចង្ក្រមនោះឯងក៏បរិនិព្វាន , បុគ្គលណាកំពុងឈរ ផ្ដើមតាំងវិបស្សនាសម្រេចព្រះអរហត្តដោយនៅឈរនោះឯង ក៏បរិនិព្វាន , បុគ្គលណាកំពុងអង្គុយផ្ដើមតាំងវិបស្សនា ហើយសម្រេចព្រះអរហត្ត , នៅអង្គុយ

នោះឯង ក៏បរិនិព្វាន បុគ្គលនេះឈ្មោះថា **ឥរិយាបថសមសីសី** ។

ចំណែកបុគ្គលណា កើតរោគណាមួយហើយ ផ្តើមតាំងវិបស្សនាហើយសម្រេចព្រះអរហត្ត , ហើយក៏បរិនិព្វានទៅ ដោយរោគនោះឯង បុគ្គលនោះឈ្មោះថា **រោគសមសីសី** ។

បុគ្គលឈ្មោះថា **ជីវិតសមសីសី** យ៉ាងណា ? សីសៈ មាន ១៣ [1] ។ បណ្តាសិរសាទាំងនោះ អរហត្តមគ្គ រមែងគ្របសង្កត់អវិជ្ជាដែលជាកិលេសសីសៈ , ចុតិចិត្ត រមែងគ្របសង្កត់ជីវិតិន្ទ្រីយ៍ដែលជាបវត្តសីសៈ , ចិត្តដែលគ្របសង្កត់អវិជ្ជា គ្របសង្កត់ជីវិតិន្ទ្រីយ៍មិនបាន , ចិត្តដែលគ្របសង្កត់ជីវិតិន្ទ្រីយ៍ គ្របសង្កត់អវិជ្ជាមិនបាន ។ ចិត្តដែលគ្របសង្កត់អវិជ្ជាមួយ , និងចិត្តគ្របសង្កត់ជីវិតិន្ទ្រីយ៍មួយទៀត ។ ក៏ទាំង ២ សីសៈនេះ របស់បុគ្គលណា រមែងដល់នូវការគ្របសង្កត់ព្រមគ្នា , បុគ្គលនោះឈ្មោះថា **ជីវិតសមសីសី** ។

សីសៈទាំង ២ នេះ នឹងមានព្រមគ្នាបានយ៉ាងណា ? មានបាន

---

១ តណ្ហា មានៈ ទិដ្ឋិ ឧទ្ធច្ចៈ អវិជ្ជា សទ្ធា វិរិយៈ សតិ សមាធិ បញ្ញា ជីវិតិន្ទ្រីយ៍ វិមោក្ខ និរោធៈ ។



ព្រមគ្នាដោយវារៈ ។ អធិប្បាយថា ការចេញចាកមគ្គមានក្នុងវារៈណា ព្រះអរិយបុគ្គលតាំងនៅក្នុងបច្ចវេក្ខណញាណ ១៩ គឺ ៖

ក្នុងសោតាបត្តិមគ្គ មានបច្ចវេក្ខណញ្ញាណ ៥
ក្នុងសកទាមិមគ្គ មានបច្ចវេក្ខណញ្ញាណ ៥
ក្នុងអនាគាមិមគ្គ មានបច្ចវេក្ខណញ្ញាណ ៥
ក្នុងអរហត្តមគ្គ មានបច្ចវេក្ខណញ្ញាណ ៤

ហើយធ្លាក់ចុះកាន់ភវង្គ ទើបបរិនិព្វាន ។

ការគ្របសង្កត់សីសៈទាំង ២ ឈ្មោះថា រមែងមានព្រមគ្នាបាន ព្រោះព្រមគ្នាដោយវារៈយ៉ាងនេះឯង ព្រោះហេតុនោះ លោកទើបហៅថា **ជីវិតសមសីសី** ។ ក៏ជីវិតសមសីសីបុគ្គលនេះឯង ព្រះមានព្រះភាគជាម្ចាស់ទ្រង់បំណាងយកហើយក្នុងទីនេះ ។

## ៣៧_ អដ្ឋកថា សល្លេខដ្ឋញ្ញាណុទ្ទេស

### ពោលអំពី សល្លេខដ្ឋញ្ញាណ

សុតមយញ្ញាណ សីលមយញ្ញាណ និងភាវនាមយញ្ញាណ

ដែលជាបាទនៃវដ្តសង្សារ រមែងមិនឈ្មោះថា **សល្លេខ** ធម៌ជាគ្រឿងជុសខាត់ , ញាណទាំងនេះក្តី ញាណដទៃក្តី ចំពោះដែលជាបាទនៃលោកុត្តរៈ លោកហៅថា **សល្លេខ** ធម៌ជាគ្រឿងជុសខាត់ ដូច្នោះ ដើម្បីនឹងសម្តែងញាណទាំងឡាយដែលប្រព្រឹត្តទៅ ដោយអាការជុសខាត់បច្ចនិកធម៌ ព្រះធម្មសេនាបតីសារីបុត្រ ទើបលើកយកសល្លេខដ្ឋញ្ញាណឡើងសម្តែងតពីសមសីសដ្ឋញ្ញាណ ក្នុងពេលឥឡូវនេះ ។

ក្នុងសល្លេខដ្ឋញ្ញាណនោះ ពាក្យថា **បុថុនានត្តតេជបរិយាទានេ បញ្ញា** បញ្ញាក្នុងការអស់ទៅនៃកិលេសដ៏ក្រាស់ **មានសភាពផ្សេង ៗ** និង **តេជ** សេចក្តីថា បញ្ញាក្នុងការអស់ទៅនៃកិលេសដ៏ក្រាស់ទាំងឡាយ មានរាគៈជាដើម និងនានត្តកិលេស ដែលជាសភាវៈផ្សេង ៗ មានកាមច្ឆន្ទៈជាដើម និងទាំងកិលេស មានភាពជាអ្នកទ្រុស្តសីលជាដើម ដែលមានឈ្មោះថា **តេជ** ព្រោះអត្ថថា ក្តៅក្រហាយ ព្រោះអត្ថថា មិនលាយដោយលោកុត្តរៈ មានពាក្យពោលអធិប្បាយទុកថា បញ្ញាក្នុងធម៌ ៣៧ ប្រភេទ មាននេក្ខម្មៈជាដើម ។



ឬអធិប្បាយថា បញ្ញាដែលក្រាស់ , បញ្ញាដែលមានសភាព ( ប្រភេទ ) ផ្សេង ៗ , និងបញ្ញាដែលជាតេជៈ ជាបញ្ញាអស់ទៅនៃកិលេសដ៏ក្រាស់ ដែលមានសភាពផ្សេង ៗ និងតេជៈ ៥ មានភាពជាអ្នកទ្រុស្តសីលជាដើម ទាំងនោះដូច្នេះ ។ នឹងសម្តែងការសង្គ្រោះបុថុធម៌ [1] និងនានត្តធម៌ [2] ដោយតេជៈទាំងឡាយ ក្នុងនិទ្ទេសវារៈ ។

ពាក្យថា **សល្លេខដ្ឋេ ញាណំ** ញាណក្នុងអត្ថថា ជុសខាត់ មានវិគ្រោះថា ធម៌ណា រមែងជុសខាត់ រមែងកាត់ផ្តាច់បច្ចនិកធម៌ទាំងឡាយ ដូច្នេះ ធម៌នោះទើបឈ្មោះថា **សល្លេខ** ជុសខាត់ , ញាណក្នុងធម៌ ៣៧ ប្រភេទ មាននេក្ខម្មៈនោះ មានការជុសខាត់ជាសភាវៈ ។

សូម្បីសល្លេខធម៌ ៤៤ ប្រភេទ ដែលព្រះមានព្រះភាគ ជាម្ចាស់ត្រាស់ទុកក្នុងសល្លេខសុត្តន្តៈ ដោយន័យជាដើមថា ជនទាំងឡាយពួកអ្នកដទៃនឹងជាអ្នកបៀតបៀន , ក្នុងប្រការនេះ យើងមិនមែន

---

**១ . ២** បុថុធម៌ និងនានត្តធម៌ មានទាំងចំណែកកុសល និងអកុសល ។

ជាអ្នកបៀតបៀន ដូច្នេះ ក៏គប្បីជ្រាបថា លោកសង្គ្រោះដោយសល្លេខញ្ញាណនេះ ដូចគ្នា ។

## ៣៨_អដ្ឋកថា វិរិយារម្ភញ្ញាណុទ្ទេស

## ពោលអំពី វិរិយារម្ភញ្ញាណ

ឥឡូវនេះ ដើម្បីនឹងសម្ដែងវិរិយៈ គឺ សម្មប្បធានដែលព្រះ-យោគីបុគ្គលអ្នកតាំងនៅក្នុងសល្លេខញ្ញាណគប្បីធ្វើ ព្រះធម្មសេនាបតីសារីបុត្រ ទើបលើកយកវិរិយារម្ភញ្ញាណឡើងសម្ដែងតពីសល្លេខ-ញ្ញាណនោះ ។

ក្នុងវិរិយារម្ភញ្ញាណនោះ ពាក្យថា **អសល្លីនត្តបហិតត្តបគ្គ-ហដ្ឋេ** ក្នុងអដ្ឋកថាផ្គងទុកនូវចិត្តដែលមិនស្ទុតនិងខ្លួនដែលបញ្ជូនទៅហើយ សេចក្ដីថា ឈ្មោះថា **អសល្លីនត្ត** មានចិត្តមិនតក់ស្លុតព្រោះអត្ថវិគ្រោះថា ចិត្តមិនតក់ស្លុត មិនរួញរាដោយអំណាចនៃសេចក្ដីខ្ជិលច្រអូស របស់បុគ្គលនោះ ដូច្នេះ ។

ពាក្យថា **អត្តា** បានដល់ ចិត្ត ។ ដូចព្រះតម្រាស់ព្រះមាន-



ព្រះភាគជាម្ចាស់មានអាទិ៍ថា ក៏ពួកអ្នកបង្ហូរទឹក រមែងបង្ហូរទឹកទៅពួកជាងធ្វើព្រួញរមែងពត់ព្រួញឲ្យត្រង់ ជាងចាំងឈើ ក៏ចាំងឈើបណ្ឌិតទាំងឡាយ ក៏រមែងហ្វឹកហាត់ខ្លួនយ៉ាងនេះ ។

ឈ្មោះថា **បហិតត្ត** មានខ្លួនបញ្ជូនទៅហើយ ព្រោះអត្ថវិគ្រោះថា អត្តភាពដែលតាំងឡើងទៀងអស់ទៅ ៗ សាបសូន្យទៅដោយមិនគិតដល់រាងកាយ និងជីវិត ដោយធម៌នោះ ដូច្នេះ ។

ពាក្យថា **អត្តា** បានដល់ **អត្តភាព** ។ ដូចពាក្យដែលព្រះ-មានព្រះភាគជាម្ចាស់ត្រាស់ជាអាទិ៍ទុកថា ៖

ម្យ៉ាងទៀត ភិក្ខុនីណារអ៊ូរទាំ វាយខ្លួនហើយយំ ( ជាបា-ចិត្តិយៈ ) ។

**អសល្លីនត្ត** នោះផង **បហិតត្ត** នោះផង ឈ្មោះថា **អសល្លីនត្តបហិតត្ត** មានចិត្តមិនតក់ស្លុត និងមានខ្លួនបញ្ជូនទៅហើយធម៌ណារមែងផ្គង គឺ រមែងឧបត្ថម្ភសហជាតធម៌ ដូច្នេះទើបឈ្មោះថា **បគ្គហ** ធម៌ដែលផ្គងសហជាតធម៌ , **បគ្គហ** ធម៌ដែលផ្គង សហជាត-ធម៌នោះឯង ដោយអត្ថឈ្មោះថា **បគ្គហដ្ឋ** , អធិប្បាយថា មានការផ្គងជាសភាវៈ ។

ការផ្គងនូវចិត្តមិនតក់ស្លុត និងមានខ្លួនដែលបញ្ជូនទៅហើយ ឈ្មោះថា **អសល្លីនត្តបហិតត្តបគ្គហត្ថ** ។ ក្នុងអត្ថថា ផ្គងទុកនូវចិត្ត ដែលមិនតក់ស្លុត និងមានខ្លួនដែលបញ្ជូនទៅហើយនោះ ។

ការមិនរួញរា ការមិនវិលត្រឡប់ក្នុងសេចក្ដីព្យាយាមដែល ព្រះសារីបុត្រពោលហើយដោយពាក្យថា **អសល្លីនតត្ត បហិតត្ត** ព្រោះជាពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ៖

**ព្រោះហេតុនោះហើយ អ្នកទាំងឡាយគប្បីសិក្សា យ៉ាងនេះថា នឹងផ្ដើមតាំងសេចក្ដីព្យាយាមដែល មិនបន្ធូរតាំងអធិដ្ឋានថា ស្បែកសរសៃ និងឆ្អឹង នៅសល់ រីឯសាច់ និងឈាមក្នុងសរីរៈចូរហួត ហែងចុះ បើនៅមិនទាន់សម្រេចផលដែលបុគ្គល គប្បីសម្រេចបានដោយកម្លាំងរបស់បុរស ដោយ សេចក្ដីព្យាយាមរបស់បុរស ដោយសេចក្ដីតស៊ូ របស់បុរសហើយតែម្ដង ក៏មិនឈប់ការព្យា- យាមឡើយយ៉ាងនេះ ជាដើម ។**

ក៏វិរិយៈ ការព្យាយាមដែលប្រព្រឹត្តទៅដោយល្អ ផុតហើយ ពី



**កោសជ្ជៈ** សេចក្ដីខ្ជិលច្រអូស និងឧទ្ធច្ចៈ សេចក្ដីរាយមាយ ព្រះធម្ម- សេនាបតីពោលហើយដោយពាក្យថា **បគ្គហត្ថ** ។

ពាក្យថា **វិរិយារម្ភេ ញាណំ** ញាណក្នុងការប្រារព្ធសេចក្ដី ព្យាយាម សេចក្ដីថា ជាភាពក្លាហាន ឈ្មោះថា វិរិយៈ , ឬ វីរកម្មរបស់អ្នកក្លាហានទាំងឡាយ ឈ្មោះថា វិរិយៈ ឬឈ្មោះថា វិរិយៈ ព្រោះជាកិច្ចដែលបុគ្គលគប្បីឲ្យដំណើរទៅ គប្បីឲ្យប្រព្រឹត្ត ទៅដោយវិធី , ដោយន័យ , ដោយឧបាយ ។

វិរិយៈនេះនោះ មានសេចក្ដីឧស្សាហ៍ជាលក្ខណៈ , មានការ ឧបត្ថម្ភសហជាតធម៌ជាកិច្ច , មានការមិនរួញរាជាអាការប្រាកដ ចំពោះមុខ , មានការសង្វេគជាហេតុជិត ដោយព្រះបាលីថា ជាអ្នក ស្លុតហើយ ផ្ដើមតាំងសេចក្ដីព្យាយាមទុក ដូច្នេះជាដើម , ឬមាន ហេតុជាគ្រឿងផ្ដើមសេចក្ដីព្យាយាមជាហេតុជិត ។

ការប្រារព្ធសេចក្ដីព្យាយាមដោយល្អ គប្បីជ្រាបថា ជាមូល នៃសម្បត្តិទាំងពួង ។ ការផ្ដួចផ្ដើម ពោលគឺ វិរិយៈ ឈ្មោះថា **វិរិយារម្ភ** ផ្ដើមសេចក្ដីព្យាយាម ។ លោកហាមការផ្ដួចផ្ដើមដ៏- សេសដោយវិរិយារម្ភៈសព្ទនេះ ។ ពិតហើយ **អារម្ភ** សព្ទនេះ មាន

ហើយក្នុងអត្ថជាអនេក ដោយសេចក្តីថា កម្ម , កិរិយា , វិរិយៈ , ហឹង្សា , វិកោបនៈ ។

ក៏ពាក្យថា **អារម្ភោ** ប្រែថា **កម្ម** មកក្នុងគាថានេះថា ៖

**ទុក្ខយ៉ាងណាមួយមាន ទុក្ខទាំងអស់រមែងកើត ព្រោះ**

**កម្ម ជាបច្ច័យ , ការកើតឡើងនៃទុក្ខ រមែងមិនមាន**

**ព្រោះការលត់នៃកម្មទាំងឡាយ ។**

ពាក្យថា **អារម្ភោ** ប្រែថា **អាបត្តិ** មកក្នុងពាក្យនេះថា ប្រារព្ធនឹងកន្លងអាបត្តិដែរ រមែងក្តៅក្រហាយ ។

**អារម្ភោ** ប្រែថា **កិរិយា** ជាគ្រឿងលើកសសរសំរាប់ចងសត្វបូជាយ័ញ្ញ មកក្នុងពាក្យនេះថា មហាយ័ញ្ញទាំងឡាយត្រូវមានការផ្តួចផ្តើមច្រើន , មហាយ័ញ្ញទាំងនោះ មិនមានផលច្រើនទេ ។

**អារម្ភោ** ប្រែថា **វិរិយ** មកក្នុងពាក្យនេះថា អ្នកទាំងឡាយចូរផ្តួចផ្តើម , ចូរឈានទៅ , ចូរប្រកបការព្យាយាមក្នុងព្រះពុទ្ធ-សាសនា ។

**អារម្ភោ** ប្រែថា ហឹង្សា , សម្លាប់ , បៀតបៀន មកក្នុងពាក្យនេះថា ជនទាំងឡាយរមែងសម្លាប់សត្វ ឧទ្ទិសចំពោះព្រះ-



សមណគោតម ។

**អារម្ភោ** ប្រែថា **វិកោបន** ការពន្រាត់ មានការកាច់ជាដើម មកក្នុងពាក្យនេះថាជាអ្នកវៀរចាកធ្វើឲ្យដាច់ពីជគាម និងភូតគាម ។

តែនៅក្នុងទីនេះ លោកបំណងយក **វិរិយ** ប៉ុណ្ណោះ ។ ព្រោះដូច្នោះ លោកទើបពោលទុកថា ការផ្តួចផ្តើម ពោលគឺ វិរិយៈ សេចក្តីព្យាយាម ឈ្មោះថា **វិរិយារម្ភោ** ប្រារព្ធសេចក្តីព្យាយាម , វិរិយៈនេះ លោកហៅថា **អារម្ភ** ដោយអំណាចនៃការព្យាយាម ។ ញាណក្នុងវិរិយារម្ភៈនោះ អាចារ្យពួកខ្លះពោលថា **អសល្លីនត្តា បហិតត្តា** យ៉ាងនេះខ្លះ , សេចក្តីថា ព្រោះមិនតក់ស្លុត , ព្រោះមិនគិតដល់រាងកាយ និងជីវិត ។ បាឋៈមុនត្រូវ ។ តែអាចារ្យពួកខ្លះពណ៌នាទុកថា សេចក្តី ព្រមព្រៀងនៃសម្ពោជ្ឈង្គៈ គឺ សតិ , ធម្មវិចយៈ វីរិយៈ បីតិ ឈ្មោះថា **អសល្លីនត្តា** , ការព្រមព្រៀងនៃពោជ្ឈង្គៈ គឺ សតិ សមាធិ បស្សទ្ធិ , ឧបេក្ខា ឈ្មោះថា **បហិតត្តា** ការព្រមព្រៀង នៃសម្ពោជ្ឈង្គៈទាំង ៧ ឈ្មោះថា **បគ្គហត្ថ** ដូច្នេះ ។

~ * ~

## ៣៩_អដ្ឋកថា អត្ថសន្ទស្សនញ្ញាណុទ្ទេស

### ពោលអំពី អត្ថសន្ទស្សនញ្ញាណ

ឥឡូវនេះដើម្បីសំដែងថា ធម្មទេសនាដែលលោកអ្នកសម្រេចមគ្គ.ផលហើយ សម្រេចដោយសម្មាវាយាមៈ គប្បីធ្វើដើម្បីប្រយោជន៍ដល់មនុស្សលោកយ៉ាងនេះ ព្រះធម្មសេនាបតីសារីបុត្រ ទើបលើកអត្ថសន្ទស្សនញ្ញាណឡើងសំដែងតពីវិរិយារម្ភញ្ញាណនោះ ។

ក្នុងអត្ថសន្ទស្សនញ្ញាណនោះ ពាក្យថា **នានាធម្មប្បកាសនតា** ការប្រកាសធម៌ផ្សេង ៗ សេចក្ដីថា ការសំដែងធម៌ទេសនា ដោយការប្រកាសធម៌ផ្សេង ៗ គឺ សង្ខតធម៌ និងអសង្ខតធម៌ទាំងពួង ។ ក៏ការប្រកាសនោះឯង ឈ្មោះថា **បកាសនតា** ។

ពាក្យថា **អត្ថសន្ទស្សនេ** ក្នុងការសំដែងឲ្យឃើញច្បាស់នូវអត្ថធម៌ សេចក្ដីថា ក្នុងការសំដែងឲ្យឃើញច្បាស់នូវអត្ថធម៌ផ្សេង ៗ ដល់ជនទាំងឡាយពួកដទៃ ។ ធម៌ទាំងឡាយ និងអត្ថទាំងឡាយ ឈ្មោះថា អត្ថធម៌ ទាំងឡាយនោះ នោះឯង ។

❀ ❀



## ៤០ _ អដ្ឋកថា ទស្សនវិសុទ្ធិញ្ញាណុទ្ទេស

### ពោលអំពី ទស្សនវិសុទ្ធិញ្ញាណ

ឥឡូវនេះ នឹងសំដែងទស្សនវិសុទ្ធិ ដែលជាហេតុនៃការសំដែងតាមសភាវធម៌ របស់ព្រះអរិយបុគ្គលនោះ អ្នកកំពុងសំដែងឲ្យឃើញច្បាស់ដល់ជនទាំងឡាយពួកដទៃ ដោយធម្មកថា ព្រះធម្មសេនាបតីសារីបុត្រ ទើបលើកយកទស្សនវិសុទ្ធិញ្ញាណឡើងសំដែងតពីអត្ថសន្ទស្សនញ្ញាណនោះ ។

ក្នុងទស្សនវិសុទ្ធិញ្ញាណនោះ ពាក្យថា **សព្វធម្មានំ ឯកសង្គហតានានត្តេកត្តបដិវេធេ** ការសង្គ្រោះធម៌ទាំងពួងជាកងជាមួយគ្នាក្នុងការចាក់ធ្លុះធម៌ផ្សេងគ្នា និងធម៌ជាមួយគ្នា និងសេចក្ដីផ្សេងគ្នានៃនីវរណធម៌ មានកាមច្ឆន្ទៈជាដើម និងទាំងសេចក្ដីតែមួយជាមួយគ្នានៃធម៌ទាំងឡាយ មាននេក្ខម្មៈជាដើម អធិប្បាយ **អភិសមយ** គឺ ត្រាស់ដឹង ។

ក៏បដិវេធនោះ បានដល់ មគ្គបញ្ញា ១ ផលបញ្ញា ១ ។ មគ្គបញ្ញា ១ ជាបដិវេធ ព្រោះកំពុងចាក់ធ្លុះ ដោយការត្រាស់ដឹង

សច្ចៈធម៌ក្នុងខណៈត្រាស់ដឹងសច្ចៈ , ផលបញ្ញា ជាបដិវេធ ព្រោះចាក់ធ្លុះហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **ឯកសង្គហតា** ដូចតទៅនេះ ៖

**សង្គហ** ការសង្គ្រោះមាន ៤ យ៉ាង គឺ **ជាតិសង្គហ** សង្គ្រោះដោយជាតិ **សញ្ជាតិសង្គហ** សង្គ្រោះដោយសញ្ជាតិ , **កិរិយាសង្គហ** សង្គ្រោះដោយការធ្វើ , **គណនសង្គហ** សង្គ្រោះដោយការរាប់ ។

បណ្ដាសង្គហៈ ៤ យ៉ាងនេះ សង្គហៈនេះថា ក្សត្រទាំងពួងត្រូវមក ព្រាហ្មណ៍ទាំងពួងត្រូវមក , អ្នកជំនួញទាំងពួងត្រូវមក , សូទ្រទាំងពួងត្រូវមក , ឬម្នាលវិសាខៈអ្នកមានអាយុ សម្មាវាចា , សម្មាកម្មន្តៈ និងសម្មាអាជីវៈ ធម៌ទាំងនេះ លោកសង្គ្រោះចុះក្នុងសីលក្ខន្ធ យ៉ាងនេះឈ្មោះថា **ជាតសង្គហ** ។ ព្រោះថា ក្នុងទីនេះ ក្សត្រយ៍ជាដើម ដូចដែលបានពោលហើយទាំងអស់ លោកសង្គ្រោះកំណត់ជាមួយគ្នាដោយជាតិ ដូចជាក្នុងឋានៈនៃពាក្យដែលពោលថា មនុស្សជាតិជាមួយគ្នា ត្រូវមកយ៉ាងនេះ ។

សង្គហៈនេះថា ជនជាតិកោសលទាំងពួងត្រូវមក , ជនជាតិមគធៈទាំងពួងត្រូវមក , ជនជាតិការុកច្ឆកៈត្រូវមក ម្នាលវិសាខៈ



ដ៏មានអាយុ សម្មាវាយាមៈ , សម្មាសតិ និងសម្មាសមាធិ ធម៌ទាំងនេះ លោកសង្គ្រោះចូលសមាធិខន្ធ យ៉ាងនេះ ឈ្មោះថា សញ្ជាតិសង្គហៈ ។ ព្រោះថា ក្នុងទីនេះមកទាំងអស់ ព្រោះក្នុងទីនេះ ជនជាតិកោសលជាដើម ដូចដែលបានពោលហើយទាំងអស់ លោកសង្គ្រោះកំណត់ជាមួយគ្នា ជាទីកើតដោយជាទីនៅអាស្រ័យដូចក្នុងឋានៈនៃពាក្យដែលពោលថា មនុស្សសម្ព័ន្ធគ្នាដោយជាតិក្នុងកន្លែងជាមួយគ្នា ត្រូវមកយ៉ាងនេះ ។

សង្គហៈនេះថា នាយទ្រមាក់ដំរីទាំងពួងត្រូវមក , នាយសារថីហ្វឹកហាត់សេះទាំងពួងត្រូវមក , ឬម្នាលវិសាខៈដ៏មានអាយុ សម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ធម៌ទាំងនេះ លោកសង្គ្រោះចុះក្នុងបញ្ញា យ៉ាងនេះ ឈ្មោះថា **កិរិយាសង្គហ** ។ ព្រោះថា នាយទ្រមាក់ដំរីជាដើមនោះទាំងអស់ លោកសង្គ្រោះកំណត់ជាមួយគ្នាដោយការធ្វើ គឺ កិរិយារបស់ខ្លួន ។

សង្គហៈនេះថា ចក្ខាយតនៈ រមែងដល់ការរាប់ដោយខន្ធដូចម្ដេច ? ចក្ខាយតនៈ ដល់នូវការរាប់បានដោយរូបក្ខន្ធ ។ បើសិនចក្ខាយតនៈ ដល់នូវការរាប់បានដោយរូបក្ខន្ធ , ដោយហេតុនោះ

ទើបលោកត្រូវពោលថា ចក្ខាយតនះ លោករាប់សង្គ្រោះដោយរូបក្ខន្ធ ដូច្នេះ ឈ្មោះថា **គណនសង្គហ** ។ ក្នុងទីនេះលោកបំណងយក គណនសង្គហៈ នេះ ។

ការកំណត់រាប់សង្គ្រោះធម៌ជាផ្នែក ៗ ដោយសេចក្តីកំណត់ជាមួយគ្នា ក្នុងអាការ ១២ **មានត្តត្ត** សភាពតាមការពិតជាដើម បានដល់ សង្គហៈទាំងនោះ ដូច្នោះ សង្គហៈទាំងនោះ ទើបឈ្មោះថា **ឯកសង្គហតា** ការសង្គ្រោះធម៌ផ្សេង ៗ ដោយសេចក្តីកំណត់ជាមួយគ្នា ។

ពាក្យថា **ទស្សនវិសុទ្ធិញ្ញាណំ** ញាណក្នុងសេចក្តីបរិសុទ្ធិនៃមគ្គញ្ញាណ និងផលញ្ញាណ សេចក្តីថា មគ្គញ្ញាណ និងផលញ្ញាណ ឈ្មោះថា ទស្សនះ , ទស្សនះនោះឯងបរិសុទ្ធិ ឈ្មោះថា ទស្សនវិសុទ្ធិ , ញាណ គឺ ទស្សនវិសុទ្ធិ ឈ្មោះថា ទស្សនវិសុទ្ធិញ្ញាណ ។

មគ្គញ្ញាណ រមែងបរិសុទ្ធិ ដូច្នោះទើបឈ្មោះថា ទស្សនវិសុទ្ធិ , ផលញ្ញាណក៏ឈ្មោះថា ទស្សនវិសុទ្ធិ ព្រោះបរិសុទ្ធហើយ ។



# ៤១ _ អដ្ឋកថា ខន្តិញ្ញាណុទ្ទេស

## ពោលអំពី ខន្តិញ្ញាណ

ឥឡូវនេះ ដើម្បីនឹងសម្តែងវិបស្សនាញាណ ២ ប្រការដោយឲ្យសម្រេចទស្សនវិសុទ្ធិ ព្រះធម្មសេនាបតីសារីបុត្រ ទើបលើកខន្តិញ្ញាណ និង បរិយោគាហញ្ញាណឡើងសម្តែងតពីទស្សនវិសុទ្ធិញ្ញាណនោះ ។

ក្នុងខន្តិញ្ញាណនោះ ពាក្យថា **វិទិតត្តា បញ្ញា** បញ្ញាក្នុងការដែលធម៌ប្រាកដ សេចក្តីថា បញ្ញាដែលប្រព្រឹត្តទៅហើយ ព្រោះដឹងច្បាស់នូវធម៌ មានរូបក្ខន្ធជាដើម ដោយសេចក្តីជារបស់មិនទៀងជាដើម ។

ពាក្យថា **ខន្តិ ញាណំ** ខន្តិញ្ញាណ សេចក្តីថា ធម្មជាតិណារមែងដឹងធម៌ដោយភាពជារបស់មិនទៀងនោះឯងជាដើម ដូច្នោះទើបឈ្មោះថា ខន្តិ , ញាណ គឺ ខន្តិ ឈ្មោះថា ខន្តិញ្ញាណ ។ ដោយខន្តិញ្ញាណនេះ រមែងហាមអធិវាសនខន្តិ ។ ខន្តិញ្ញាណនេះ ជាតរុណវិបស្សនាញាណ ដែលប្រព្រឹត្តទៅហើយ ដោយសម្មសនញ្ញាណ

មានការពិចារណាសង្ខារធម៌ដោយភាពជាកលាបៈជាដើម ។

## ៤២ _ អដ្ឋកថា បរិយោគាហណញ្ញាណុទ្ទេស

### ពោលអំពី បរិយោគាហណញ្ញាណ

ពាក្យថា **ផុដ្ឋត្តា បញ្ញា** បញ្ញាដែលពាល់ត្រូវនូវធម៌ សេចក្ដីថា បញ្ញាដែលប្រព្រឹត្តទៅហើយ ព្រោះសភាពនៃធម៌ទាំងឡាយ មានរូបក្ខន្ធជាដើម ជាធម៌ដែលញាណផស្សៈពាល់ត្រូវហើយ ដោយអំណាចនៃការពិចារណា ដោយសភាពជារបស់មិនទៀងជាដើម ។

ពាក្យថា **បរិយោគាហណេ ញាណំ** ញាណក្នុងការស្ទាបស្ទង់ រមែងចូលទៅដល់ធម៌ ដែលញាណផស្សៈពាល់ត្រូវហើយនោះឯង ដូច្នោះ ញាណនោះទើបឈ្មោះថា បរិយោគាហណញ្ញាណ ។ ពួកអាចារ្យខ្លះធ្វើស្រៈ **គា** អក្សរចេញខ្លះ ហើយសូត្រ ។ បរិយោគាហណញ្ញាណនេះ ជាតិក្ខវិបស្សនាញាណ ប្រព្រឹត្តទៅហើយដោយអំណាចនៃកង្ខានុបស្សនាញាណ ។ តែអាចារ្យពួកខ្លះ ពោលថា វិបស្សនាញាណនោះឯង ជាខន្តិញ្ញាណ សម្រាប់អ្នកមានសទ្ធា ជាអ្នក



នាំ , ជាបរិយោគាហណញ្ញាណសំរាប់ អ្នកមានបញ្ញា ជាអ្នកនាំ ។ កាលបើដូច្នោះ ញាណទាំង ២ នេះ រមែងមិនកើតព្រមដល់មនុស្សតែម្នាក់ ៗ នោះទេ ញាណដែលជាសាធារណៈដល់សាវក ៦៧ រមែងមិនកើតឡើងព្រមគ្នាដល់ព្រះសាវកតែមួយអង្គ ក្នុងការកើតឡើងព្រមគ្នានៃញាណនោះ , ព្រោះដូច្នោះ ពាក្យអាចារ្យពួកខ្លះនោះទើបមិនត្រូវ ។

## ៤៣ _ អដ្ឋកថា បទេសវិហារញ្ញាណុទ្ទេស

### ពោលអំពី បទេសវិហារញ្ញាណ

ប្រទេសវិហារញ្ញាណ ដែលឲ្យសម្រេចទស្សនវិសុទ្ធិញ្ញាណរបស់ព្រះអរហន្ត ដែលព្រះធម្មសេនាបតីសារីបុត្រ ពោលញាណដែលជាហេតុឲ្យសម្រេចទស្សនវិសុទ្ធិញ្ញាណថា បុថុជ្ជន និងព្រះសេក្ខបុគ្គលទាំងឡាយ ពិចារណានូវធម៌ទាំងអស់ មានខន្ធជាដើមដែលចូលដល់វិបស្សនា , មិនពិចារណាឯកទេសនៃធម៌ទាំងនោះ , ព្រោះដូច្នោះ បទេសវិហារញ្ញាណ រមែងមិនមានដល់បុថុជ្ជន និង

ព្រះសេក្ខបុគ្គលទាំងនោះ , តែរមែងបានតាមការពេញចិត្តដល់ព្រះ-អរហន្តប៉ុណ្ណោះ ដូច្នេះទើបលើកសម្តែងតពីបរិយោគាហណញ្ញាណ ។

ក្នុងបទេសវិហារញ្ញាណ ពាក្យថា **សមោទហនេ បញ្ញា** បញ្ញាក្នុងការប្រមូលមក សេចក្តីថា បញ្ញាក្នុងការប្រមូលមក គឺ បញ្ញាក្នុងរួបរួមមក បានដល់ បញ្ញាក្នុងការធ្វើនូវធម៌ គឺ វេទនាដែលជាធម៌ពួកជាមួយគ្នា ឲ្យជាកងក្នុងបណ្តាធម៌ មានខន្ធជាដើម ។ បាឋៈថា **សមោធានេ បញ្ញា** បញ្ញាក្នុងការប្រជុំយ៉ាងនេះក៏មាន , អត្ថន័យក៏យ៉ាងនោះឯង ។

ពាក្យថា **បទេសវិហារ ញាណំ** ញាណក្នុងវិហារធម៌មួយចំណែក សេចក្តីថា ធម៌ជាគ្រឿងនៅតែម្នាក់ឯង ដោយចំណែក មានខន្ធជាដើម ឈ្មោះថា បទេសវិហារ ធម៌ជាគ្រឿងនៅតែម្នាក់ឯង , ញាណក្នុងបទេសវិហារធម៌នោះ ។

ក្នុងពាក្យថា បទេសវិហារនោះ **បទេស** មានផ្សេង ៗ គឺ ខន្ធប្បទេសៈ , អាយតនប្បទេសៈ , ធាតុប្បទេសៈ , សច្ចប្បទេសៈ , ឥន្ទ្រីយប្បទេសៈ , បច្ចយាការប្បទេសៈ , សតិប្បដ្ឋានប្បទេសៈ , ញាណប្បទេសៈ , នាមរូបប្បទេសៈ , ធម្មប្បទេសៈឈ្មោះថា **បទេស** ។



ក៏បទេសៈមានផ្សេងៗយ៉ាងនេះ ក៏គឺ វេទនា នោះឯង ។ យ៉ាងណា ? វេទនានោះឯង ជាបទេសៈនៃធម៌មាន ខន្ធជាដើម យ៉ាងនេះគឺ ៖

**ខន្ធ ៥ ឯកទេសនៃខន្ធ គឺវេទនាខន្ធ , អាយតនៈ ១២ ឯកទេសនៃធម្មាយតនៈ គឺ វេទនា , ធាតុ ១៨ ឯកទេសនៃធម្មធាតុ គឺ វេទនា , សច្ចៈ ៤ ឯកទេសនៃទុក្ខសច្ចៈ គឺ វេទនា , ឥន្ទ្រីយ៍ ២២ ឯកទេសនៃឥន្ទ្រីយ៍ គឺ វេទនិន្ទ្រីយ៍ ៥ , បដិច្ចសមុប្បាទង្គ ១២ ឯកទេស នៃបច្ចយាការ គឺវេទនាមានផស្សៈជាបច្ច័យ , សតិប្បដ្ឋាន ៤ ឯកទេសនៃសតិប្បដ្ឋាន គឺវេទនានុបស្សនា , ឈាន ៤ ឯកទេសនៃឈាន គឺសុខវេទនានិងឧបេក្ខា-វេទនា , នាមរូប ឯកទេសនៃនាមរូប គឺ វេទនាចេតសិក ។**

ធម៌ទាំងពួង មានកុសលជាដើម ឯកទេសនៃធម៌ គឺ វេទនា , ឈ្មោះថា **បទេសវិហារ** ដោយអំណាចនៃការពិចារណាវេទនានោះ

នោះឯង ។

## ៤៤. អដ្ឋកថា សញ្ញាវិវដ្តញ្ញាណុទ្ទេស

### ពោលអំពី សញ្ញាវិវដ្តញ្ញាណ

ព្រោះហេតុដែលបុថុជ្ជន និងព្រះសេក្ខបុគ្គលទាំងឡាយ កាលបើចម្រើនញ្ញាណ ដែលសម្រេចហើយដោយសមាធិភាវនា ធ្វើភាវនាធម៌ដែលគួរចម្រើននោះ ៗ ឲ្យជាអធិបតី ឲ្យជាធំ ពិចារណាធម៌ទាំងឡាយដែលផ្ទុយគ្នា និងភាវនាធម៌នោះ មានសភាវៈផ្សេង ៗ មានទោសជាអនេក ដោយភាពជាធម៌មានទោស ហើយតាំងចិត្តទុកដោយអំណាចនៃភាវនាធម៌នោះ ៗ ក៏រមែងលះបច្ចនិកធម៌ទាំងនោះ ៗ ចេញបាន , និងកាលបើលះ ក៏ឃើញសង្ខារធម៌ទាំងពួងដោយសេចក្តីជារបស់ទទេក្នុងកាលនៃវិបស្សនា ។

បន្ទាប់ពីនោះមក , រមែងលះបានដោយសមុច្ឆេទប្បហាន , កាលបើលះបង់ដូច្នោះ រមែងចាក់ធ្លុះសច្ចៈទាំងឡាយ លះបានដោយការត្រាស់ដឹងក្នុងមួយខណៈ , ព្រះអរិយៈទាំងឡាយ សូម្បីទាំងពួងរមែងបដិបត្តិតាមគួរដោយអាការទាំងឡាយ តាមដែលពោលហើយ



នោះឯង , ដូច្នោះ ព្រះធម្មសេនាតីសារីបុត្រ ទើបលើកញ្ញាណទាំង ៦ មានសញ្ញាវិវដ្តញ្ញាណជាដើម ឡើងសម្តែងតពីបទេសវិហារញ្ញាណ តាមលំដាប់ក្នុងឥឡូវនេះ ។

ក្នុងសញ្ញាវិវដ្តញ្ញាណនោះ ពាក្យថា **អធិបតត្តា បញ្ញា** បញ្ញាមានកុសលជាអធិបតី សេចក្តីថា បញ្ញាដែលធ្វើកុសលធម៌ មាននេក្ខម្មៈជាដើម ឲ្យជាធម៌ដ៏ក្រៃលែងដោយភាពជាអធិបតីនៃកុសលធម៌ទាំងឡាយ មាននេក្ខម្មៈជាដើម ហើយប្រព្រឹត្តទៅដោយសេចក្តីជាធម៌ក្រៃលែងក្នុងកុសលធម៌ មាននេក្ខម្មៈជាដើមនោះ ។

ពាក្យថា **សញ្ញាវិវដ្តេ ញាណំ** ញាណក្នុងការចៀសចេញពីនីវរណៈ ដោយបញ្ញា លោកពោលអធិប្បាយទុកថា ការចៀសចេញ ការងាកចេញ ភាពជាអ្នកងាកចេញអំពីនីវរណៈ មានកាមច្ឆន្ទៈជាដើមនោះ ៗ បានដោយសញ្ញា ដូច្នោះទើបឈ្មោះថា សញ្ញាវិវដ្តៈ , ញាណក្នុងការចេញចាកពីនីវរណៈធម៌ មានកាមច្ឆន្ទៈជាដើមនោះ ៗ ដោយសញ្ញាដែលធ្វើភាវនាធម៌នោះ ៗ ឲ្យជាអធិបតី ជាហេតុ ជាការណៈ ។

សញ្ញាសូម្បីមិនបានពោលទុកថា **ឯត្តោ វិវដ្តោ** ងាកត្រឡប់

ពីការនៅធម៌នេះ តែក៏ជាហេតុឲ្យសញ្ញាវិលត្រឡប់ ដូចវិវដ្តនានុបស្សនា ។

ក៏សញ្ញានោះ មានការចាំអារម្មណ៍ ជាលក្ខណៈ មានការចាំអារម្មណ៍បាន និងធ្វើនិមិត្តទុក ជាកិច្ច ដូចជាងឈើធ្វើគ្រឿងសម្គាល់ទុកនឹងឈើជាដើម ។ មានការចាំបាន ក្នុងរបស់ដែលសម្គាល់ទុក ជាបច្ចុប្បដ្ឋាន ដូចមនុស្សក្អែកខ្វាក់ស្ទាបដំរី , ម្យ៉ាងទៀត មានការតាំងនៅមិនយូរ ព្រោះស្ទួនចុះក្នុងអារម្មណ៍ជាបច្ចុប្បដ្ឋាន ដូចផ្លេកបន្ទោរ , មានអារម្មណ៍ដែលកំណត់ទុក ជាបទដ្ឋាន ដូចសញ្ញាក្នុងទីងមោង ធ្វើដោយចំបើងកើតដល់សត្វ ស្មានថាជាបុរស ។

## ៤៥. អដ្ឋកថា ចេតោវិវដ្តញ្ញាណុទ្ទេស

## ពោលអំពី ចេតោវិវដ្តញ្ញាណ

ពាក្យថា **នានត្តេ បញ្ញា** បញ្ញាក្នុងនានត្តធម៌ សេចក្ដីថា បញ្ញាដែលប្រព្រឹត្តទៅហើយក្នុងការនៅធម៌ផ្សេង ៗ ដោយសេចក្ដីជាកាវេតព្វធម៌ធម៌ ដែលគួរចំរើន និងក្នុងសភាវធម៌ដទៃ មានកាមច្ឆន្ទៈជាដើម ដោយឃើញថា ជាធម៌មានទោស ។



និងពាក្យថា **នានត្តេ** ជាសត្តមីវិភត្តិចុះក្នុងអត្ថនៃនិមិត្តសត្តមី , ម្យ៉ាងទៀត លះសេចក្ដីផ្សេង ៗ ឈ្មោះថា **នានត្ត** , អធិប្បាយថា ហេតុនៃការលះបង់នានត្តធម៌ ជានិមិត្តនៃការលះបង់នានត្តធម៌ ជាបញ្ញាក្នុងកុសលធម៌ មាននេក្ខម្មៈជាដើម ។

ក្នុងពាក្យថា **ចេតោវិវដ្តេ ញាណំ** ញាណក្នុងការគេចចេញពីនីវរណៈដោយចិត្ត ដោយសេចក្ដីថា ការចេញពីនីវរណៈ មានកាមច្ឆន្ទៈជាដើមបានដោយចិត្ត ជាញាណក្នុងកុសលធម៌មាននេក្ខម្មៈជាដើម ។

ក៏ក្នុងពាក្យថា **ចេតោ** នេះ លោកបំណងយកចេតនា ។ ចេតនានោះ ៖

**មានការតាំងចិត្តជាលក្ខណៈ , ម្យ៉ាងទៀត**
**មានការហូរចេញនៃផល ជាលក្ខណៈ ,**
**មានការរួបរួម ជាកិច្ច , មានការចាត់**
**ចែង ជាបច្ចុប្បដ្ឋាន ។**

ដូចមេជាងធំ ឬជាប្រធានសិស្ស ធ្វើកិច្ចរបស់ខ្លួន និងកិច្ច

របស់អ្នកដទៃឲ្យសម្រេច ដូច្នោះ ។ ក៏ចេតនានេះ រមែងប្រាកដ ដោយការលើកសម្បយុត្តធម៌ទាំងឡាយក្នុងកិច្ច មានការលើកដល់ការងារដ៏រហ័ស ។

## ៤៦ . អដ្ឋកថា ចិត្តវិវដ្ដញ្ញាណុទ្ទេស

## ពោលអំពី ចិត្តវិវដ្ដញ្ញាណ

ពាក្យថា **អធិដ្ឋានេ បញ្ញា** បញ្ញាក្នុងការអធិដ្ឋាន សេចក្ដីថា បញ្ញា ក្នុងការតាំងមាំនៃចិត្តដោយអំណាចនៃគុណ មាននេក្ខម្មៈជាដើម ។

ពាក្យថា **ចិត្តវិវដ្ដេ ញាណំ** ញាណក្នុងការចេញទៅនៃចិត្ត សេចក្ដីថា ញាណក្នុងការគេចចេញនៃចិត្តដោយអំណាចនៃការលះនីវរណៈ មានកាមច្ឆន្ទៈជាដើម ក៏ក្នុងទីនេះ ចិត្តមានការដឹងនីវរណៈជាលក្ខណៈ មានការកើតមុន និងជាប្រធាននៃធម៌ទាំងពួងជាកិច្ច មានការកើតឡើងបន្តគ្នាមិនដាច់ខ្សែជាបច្ចុប្បដ្ឋាន មាននាមរូប ជាបទដ្ឋាន ។



## ៤៧ . អដ្ឋកថា ញាណវិវដ្ដញ្ញាណុទ្ទេស

## ពោលអំពី ញាណវិវដ្ដញ្ញាណ

ពាក្យថា **សុញ្ញតេ បញ្ញា** បញ្ញាក្នុងភាពសូន្យទទេ សេចក្ដីថា បញ្ញា ជាគ្រឿងតាមការឃើញដោយសេចក្ដីជាអនត្តា ដែលប្រព្រឹត្តទៅហើយក្នុងអនត្តធម៌ និងធម៌ដែលជាប់ដោយអនត្តៈ ព្រោះអត្តៈ និងធម្មៈ ដែលជាប់ដោយអត្តៈជារបស់សូន្យទទេ ។

ពាក្យថា **ញាណវិវដ្ដេ ញាណំ** ញាណក្នុងការគេចចេញដោយញាណ សេចក្ដីថា ញាណនោះឯង រមែងគេចចេញពីការប្រកាន់ខ្ជាប់ ប្រកាន់មាំ , ដូច្នោះទើបឈ្មោះថា **វិវដ្ដ** ញាណដែលជាហេតុនៃការគេចចេញដោយញាណនោះ ។

## ៤៨ . អដ្ឋកថា វិមោក្ខវិវដ្ដញ្ញាណុទ្ទេស

## ពោលអំពី វិមោក្ខវិវដ្ដញ្ញាណ

ក្នុងពាក្យនេះថា **វោស្សគ្គេ បញ្ញា** បញ្ញាក្នុងការលះបង់ គប្បីជ្រាបវិនិច្ឆ័យដូចទៅនេះ ធម៌ណា រមែងរលាស់ចេញ ដូច្នោះ

ធម៌នោះ ឈ្មោះថា **វោស្សគ្គ** ការលោសចេញ , ការលះបង់បាន នូវកាមច្ឆន្ទៈជាដើម ជាបញ្ញា ក្នុងគុណមាននេក្ខម្មៈជាដើម ។

ពាក្យថា **វិមោក្ខវិវដ្ដ ញាណំ** ញាណក្នុងការគេចចេញនៃចិត្តដោយវិមោក្ខ សេចក្ដីថា ធម៌ណា រមែងផុតពីនីវរណៈទាំងឡាយ មានកាមច្ឆន្ទៈជាដើម ដូច្នោះ ធម៌នោះឈ្មោះថា **វិមោក្ខ** ការចេញចាក គឺ **វិមោក្ខ** ឈ្មោះថា វិមោក្ខវិវដ្ដៈ **វិមោក្ខវិវដ្ដ** នោះឯង ជាញាណ ។

## ៤៩. អដ្ឋកថា សច្ចវិវដ្ដញ្ញាណុទ្ទេស

## ពោលអំពី សច្ចវិវដ្ដញ្ញាណ

ពាក្យថា **តថដ្ឋេ បញ្ញា** បញ្ញាក្នុងសភាវៈដែលមានពិត សេចក្ដីថា បញ្ញាដែលប្រព្រឹត្តទៅដោយមិនវង្វេង ដោយអំណាចនៃកិច្ចក្នុងសភាវៈធម៌ ដែលមិនវិបរិតក្នុងសច្ចៈមួយ ៗ , សច្ចៈមួយ ៗ មាន ៤ ។

ពាក្យថា **សច្ចវិវដ្ដេ ញាណំ** ញាណក្នុងការចេញចាក ដោយ



សច្ចៈ សេចក្ដីថា ធម៌ណា រមែងគេចចេញដោយអំណាចនៃការចេញពីចំណែកបំផុតទាំង ២ ក្នុងសច្ចៈទាំង ៤ ដូច្នោះ ធម៌នោះ ឈ្មោះថា **សច្ចវិវដ្ដ** , **សច្ចវិវដ្ដ** នោះឯង ជាញាណ ។

ញាណមួយប៉ុណ្ណោះ លោកពោលទុកដល់ ៤ ប្រការ យ៉ាងនេះ គឺ ៖

**១- សញ្ញាវិវដ្ដ** ដោយអំណាចនៃកុសលធម៌ជាអធិបតី

**២- ចេតោវិវដ្ដ** ដោយអំណាចនៃធម៌ដែលគួរលះបង់

**៣- ចិត្តវិវដ្ដ** ដោយអំណាចនៃការតាំងមាំនៃចិត្ត

**៤- វិមោក្ខវិវដ្ដ** ដោយអំណាចនៃការលះបច្ចនិកធម៌

អនត្តានុបស្សនា លោកពោលថា **ញាណវិវដ្ដេ ញាណំ** ញាណ ក្នុងការចេញចាកដោយញាណ ដោយអំណាចនៃអាការដែលសូន្យចាកអត្តា ក្រោយមកលោកក៏ពោលមគ្គញ្ញាណទុក ២ យ៉ាង គឺ **មគ្គេ ញាណំ** ញាណក្នុងមគ្គ និង **អានន្តរិកសមាធិម្ហិ ញាណំ** ញាណក្នុងអានន្តរិកសមាធិ , លោកពោលពាក្យថា **សច្ចវិវដ្ដេ ញាណំ** ញាណ ក្នុងការចេញចាកដោយសច្ចៈ ។

~ * ~

## ៥០ . អដ្ឋកថា ឥទ្ធិវិធញ្ញាណុទ្ទេស

### ពោលអំពី ឥទ្ធិវិធញ្ញាណ

ឥឡូវនេះ ព្រះធម្មសេនាបតីសារីបុត្រ លើកអភិញ្ញា ៦ ដែលប្រព្រឹត្តទៅដោយអំណាចនៃញាណ ក្នុងការអស់ទៅនៃអាសវៈទាំងឡាយប្រព្រឹត្តទៅដោយអំណាចសច្ចវិវដ្តញាណនោះឡើង សម្តែងដោយលំដាប់ ។ ក្នុងអភិញ្ញា ៦ នោះ លោកលើកឥទ្ធិវិធញ្ញាណសម្តែងមុន គឺ សេចក្តីប្លែក ចម្លែក ព្រោះជាអានុភាព ដែលប្រាកដដល់លោក , លើកទិព្វសោតញ្ញាណ ឡើងសម្តែងជាលំដាប់ទី ២ គឺ ទិព្វសោតញ្ញាណដែលជាឧឡារិកវិស័យ ព្រោះជាអារម្មណ៍របស់ចេ-តោបរិយញ្ញាណ , លើកយកចេតោបរិយញ្ញាណ សម្តែងលំដាប់ទី ៣ ព្រោះជាសុខុមវិស័យ ។ បណ្តាវិជ្ជា ៣ លោកលើកបុព្វេនិវាសា-នុស្សតិញ្ញាណឡើងសម្តែងជាលំដាប់ទី ១ ព្រោះបន្ទោបង់ភាពងងឹតក្នុងអតីត ដែលបិទបាំងបុព្វេនិវាស គឺ ការកើត ក្នុងជាតិមុន , លើកទិព្វចក្ខុញ្ញាណសម្តែងលំដាប់ទី ២ ព្រោះបន្ទោបង់ភាពងងឹតទាំងក្នុងបច្ចុប្បន្ន និងអនាគត , លើកអាសវក្ខយញ្ញាណឡើងសម្តែង



ជាលំដាប់ទី ៣ ព្រោះកម្ចាត់សេចក្តីងងឹត ទាំងអស់បានជាសមុច្ឆេទ ។

បណ្តាពាក្យទាំងនោះ ពាក្យថា **កាយម្បិ** សូម្បីកាយ បានដល់រូបកាយ ។ ពាក្យថា **ចិត្តម្បិ** សូម្បីចិត្ត បានដល់ ចិត្តសូម្បីមានឈានជាបាទ ។

ពាក្យ **ឯកវវត្ថានតា** ព្រោះការកំណត់ចូលគ្នាតែមួយ មានពាក្យអធិប្បាយថា ដោយទិសមានកាយ និងអទិសមានកាយ ព្រោះតាំងទុកដោយរបស់តែមួយ និងបរិកម្មចិត្ត ព្រោះធ្វើកាយ និងចិត្តឲ្យលាយឡំគ្នា តាមដែលនឹងប្រកបបានក្នុងគ្រាដែលបំណងនឹងទៅ ។

ក៏ពាក្យថា **កាយោ** កាយក្នុងទីនេះ បានដល់សរីរៈ ។ ពិតហើយសរីរៈ លោកហៅថា កាយ ព្រោះជាអណ្តូងកើតនៃអវយវៈទាំងឡាយ មានកេសា “ សក់ ” ជាដើមដែលគួរខ្ពើម ព្រោះប្រមូលទុកនូវទឹកកាម និងជាអណ្តូងកើតនៃរោគច្រើនរយ មានចក្ខុ-រោគជាដើម ។

**ច** ស័ព្ទ លោកប្រកបទុកក្នុងពាក្យនេះថា **សុខសញ្ញញ្ច លហុសញ្ញញ្ច** សុខសញ្ញាផង លហុសញ្ញាផង ជាសមុច្ចយត្ថ រួមជាសញ្ញាស័ព្ទតែមួយប៉ុណ្ណោះ ដែលសម្បយុត្តជាមួយចតុត្ថជ្ឈាន ឲ្យ

ជា ២ បទ ព្រោះខុសគ្នាដោយអាការ ។ ពិតហើយ ឧបេក្ខាក្នុងចតុត្ថជ្ឈាន លោកពោលថា **សន្តំ** ស្ងប់ , **សុខំ** ជាសុខ , សញ្ញាដែលសម្បយុត្តជាមួយឧបេក្ខានោះ ឈ្មោះថា សុខសញ្ញា ។ សុខសញ្ញានោះឯង ឈ្មោះថា **លហុសញ្ញា** ព្រោះផុតនីវរណធម៌ទាំងឡាយ និងបច្ចនិកធម៌ មានវិតក្កជាដើម ។

ពាក្យថា **អធិដ្ឋានវសេន** ដោយអំណាចនៃការតាំងទុក សេចក្តីថា ដោយអំណាចនៃការតាំងទុកដ៏ក្រៃលែង , អធិប្បាយថា ដោយអំណាចនៃការចូលទៅ ។ **ច** ស័ព្ទ ក្នុងពាក្យថា **អធិដ្ឋានវសេន ច** លោកនាំមកភ្ជាប់ចូលទុក ។ ហេតុដែលប្រកបបាននៃឥទ្ធិវិធីមានប្រការទាំងពួង លោកពោលទុកហើយត្រឹមប៉ុណ្ណេះ ។

ពាក្យថា **ឥជ្ឈនដ្ឋេ បញ្ញា** បញ្ញាក្នុងការសម្រេច សេចក្តីថា បញ្ញាក្នុងសភាវៈ គឺ ការសម្រេច ។

ពាក្យថា **ឥទ្ធិវិធេ ញាណំ** ញាណក្នុងការសម្តែងឫទ្ធិបានផ្សេង ៗ មានពាក្យអធិប្បាយលោកពោលទុកថា ឈ្មោះថា ឥទ្ធិឫទ្ធិ ក្នុងអត្ថថា សម្រេច , និងក្នុងអត្ថថា បានចំពោះ ព្រោះអត្ថថា សម្រេច ។ ពិតហើយ របស់ណានឹងកើតឡើង និងបានចំពោះរបស់



នោះ លោកហៅថា **ឥជ្ឈតិ** រមែងសម្រេច ។ សមពិតដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

បើថា កាលបុគ្គលនៅប្រាថ្នាកាម នឹងកាម ក៏រមែងសម្រេចដល់អ្នកនោះ ដូច្នេះ ។ មួយទៀត ដែលលោកប្រដូចទុកថា នេក្ខម្មៈ រមែងសម្រេច ដូច្នោះទើបឈ្មោះថា ឥទ្ធិឫទ្ធិ នេក្ខម្មៈរមែងកំចាត់កាមច្ឆន្ទៈ ដូច្នេះទើបឈ្មោះថា បាដិហារិយ៍ អរហត្តមគ្គរមែងសម្រេច ដូច្នោះទើបឈ្មោះថា ឥទ្ធិឫទ្ធិ , អរហត្តមគ្គនោះ រមែងទម្លាយកិលេសទាំងអស់បាន ដូច្នោះទើបឈ្មោះថាបាដិហារិយ៍យ៉ាងនេះ ។

ន័យមួយទៀត

ឈ្មោះថា ឥទ្ធិឫទ្ធិ ព្រោះអត្ថថា សម្រេច , ពាក្យនេះជាឈ្មោះនៃឧបាយសម្បទា , ពិតហើយ ឧបាយសម្បទារមែងសម្រេច ព្រោះប្រសព្វផលដែលខ្លួនប្រាថ្នា ។ សមពិតដូចដែលលោកពោលថា ៖

ចិត្តគហបតីនេះ មានសីលជាកល្យាណធម៌ ,

បើអ្នកនឹងប្រាថ្នាថា សុំឲ្យយើងបានជាស្ដេចចក្រពត្រាធិរាជក្នុងអនាគតកាល សេចក្ដីប្រាថ្នាដោយចិត្តរបស់អ្នកមានសីល នឹងសម្រេច ព្រោះសេចក្ដីប្រាថ្នានោះបរិសុទ្ធិ យ៉ាងនេះ ។

ន័យដទៃទៀត

សត្វទាំងឡាយ រមែងសម្រេចបានដោយធម្មជាតិនោះ ហេតុនោះ ធម្មជាតិនោះ ទើបឈ្មោះថា ឥទ្ធិឫទ្ធិ គឺ ធម្មជាតិជាហេតុឲ្យសម្រេច ។

ពាក្យថា **ឥជ្ឈន្តិ** រមែងសម្រេច មានពាក្យអធិប្បាយថា **សម្រេច** គឺ ចម្រើន គឺ រមែងដល់នូវសេចក្ដីល្បីល្បាញ ។ **វិធ** គឺ ឥទ្ធិឫទ្ធិនោះឯង ឈ្មោះថា ឥទ្ធិវិធី សម្ដែងឫទ្ធិផ្សេង ៗ , អធិប្បាយថា **ឥទ្ធិកោដ្ឋាស** ចំណែកនៃឫទ្ធិ **ឥទ្ធិវិកប្ប** ឫទ្ធិសម្រេចបាន ផ្សេង ៗ ។ មានពាក្យអធិប្បាយលោកពោលទុកថា ឥទ្ធិវិធិញ្ញាណ ញាណក្នុងការសម្ដែងឫទ្ធិបានផ្សេង ៗ ។



## ៥១ . អដ្ឋកថា សោតធាតុវិសុទ្ធិញ្ញាណុទ្ទេស

## ពោលអំពី សោតធាតុវិសុទ្ធិញ្ញាណ

ពាក្យថា **វិតក្កវិប្ផារវសេន** ដោយអំណាចនៃការផ្សាយវិតក្កៈទៅ សេចក្ដីថា ដោយអំណាចនៃការផ្សាយទៅ គឺ ដោយអំណាចកម្លាំង នៃវិតក្កៈរបស់ខ្លួន ក្នុងសទ្ទនិមិត្តក្នុងពេលធ្វើបរិកម្ម ដើម្បីឲ្យកើតទិព្វសោតធាតុ ។

ក៏ក្នុងពាក្យថា **វិតក្កោ** នេះ មានវិគ្រោះថា ធម្មជាតិណារមែងគិត ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **វិតក្ក** ម្យ៉ាងទៀត ការត្រិះរិះ ឈ្មោះថា **វិតក្ក** , មានពាក្យអធិប្បាយលោកពោលទុកថា ការពិចារណា ។ វិតក្កនេះនោះ មានការលើកចិត្តឡើងកាន់អារម្មណ៍ជាលក្ខណៈ មានការផ្គងចិត្តទុកក្នុងអារម្មណ៍ជាកិច្ច ។

ពិតយ៉ាងនោះ លោកពោលថា ព្រះយោគីបុគ្គល រមែងធ្វើអារម្មណ៍ឲ្យប៉ះខ្ទប់ដោយវិតក្កៈ ។

មានចិត្តដែលស្ថិតនៅក្នុងអារម្មណ៍ជាបច្ចុប្បដ្ឋាន , និងលោកពោលថា មានអារម្មណ៍ដែលមកកាន់គន្លង ជាបទដ្ឋាន ព្រោះកើតឡើងដោយឥន្ទ្រីយ៍ ដែលមកប្រជុំព្រមជាមួយអារម្មណ៍នោះ និង

ដោយមិនមានអន្តរាយក្នុងអារម្មណ៍ដោយជុំវិញ ។

ពាក្យថា **នានត្តេកត្តសទ្ទនិមិត្តានំ** សំឡេងជានិមិត្តច្រើនយ៉ាង ឬតែមយ៉ាង សេចក្តីថា សំឡេងជានិមិត្តមានសភាវៈផ្សេង ៗ និងមានសភាវៈមួយ ។ ក៏ក្នុងពាក្យថា សទ្ទនិមិត្តនេះ សទ្ទៈ គឺ សំឡេង និមិត្តនោះឯង ជានិមិត្ត ព្រោះជាហេតុនៃការកើតឡើងនៃវិតក្កៈ និងជានិមិត្តនៃសង្ខារ ។ សំឡេងដែលមូលតែមួយដូចសំឡេងស្គរ ឬសំឡេងច្រើនសន្ធឹកសន្ធាប់ , សំឡេងក្នុងទិសផ្សេង ៗ សំឡេងក្នុងទិសតែមួយ , ឬសំឡេងតែមួយ សំឡេងដូចសំឡេងស្គរជាដើម ឈ្មោះថា **ឯកត្តសទ្ទា** សំឡេងតែមួយ ។

ក៏ពាក្យថា **សទ្ទោ** នេះ មានវិគ្រោះថា ធម្មជាតិណាមែងផ្សាយទៅ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **សទ្ទ** សំឡេង , អធិប្បាយថាសំឡេងដែលបន្លឺចេញមក ។

ពាក្យថា **បរិយោគាហណេ បញ្ញា** បញ្ញាក្នុងការកំណត់ សេចក្តីថា បញ្ញាជាគ្រឿងចូលដល់ អធិប្បាយថា បញ្ញាជាគ្រឿងដឹង ។

ពាក្យថា **សោតធាតុវិសុទ្ធិញ្ញាណំ** ញាណក្នុងសោតធាតុដែលបរិសុទ្ធ សេចក្តីថា ឈ្មោះថា **សោតធាតុ** ព្រោះអត្ថថា បានឮ



និងព្រោះអត្ថថា មិនមែនជីវៈ , និងឈ្មោះថា សោតធាតុ ព្រោះបញ្ញាធ្វើសោតធាតុ ដោយអំណាចធ្វើកិច្ចរបស់សោតធាតុ , ឈ្មោះថា **វិសុទ្ធិ** ព្រោះសោតធាតុនោះ បរិសុទ្ធិហើយ ព្រោះប្រាសចាកឧបក្កិលេស , សោតធាតុនោះឯង បរិសុទ្ធិ ឈ្មោះថា សោតធាតុវិសុទ្ធិ , ញាណ គឺ ការដឹងក្នុងសោតធាតុវិសុទ្ធិនោះឯង ឈ្មោះថា **សោតធាតុវិសុទ្ធិញ្ញាណ** ។

## ៥២ . អដ្ឋកថា ចេតោបរិយញ្ញាណុទ្ទេស

### ពោលអំពី ចេតោបរិយញ្ញាណ

ពាក្យថា **តិណ្ណំ ចិត្តានំ** នៃចិត្ត ៣ ដួង សេចក្តីថា នៃចិត្ត ៣ ដួង គឺ សោមនស្សសហគតចិត្ត ១ , ទោមនស្សសហគតចិត្ត ១ , ឧបេក្ខាសហគតចិត្ត ១ ។

ពាក្យថា **វិប្ផារត្តា** ដោយការផ្សាយទៅ សេចក្តីថា ដោយសភាពជាកន្ទេងផ្សាយទៅ អធិប្បាយថា ដោយសភាពរហ័ស ។ ពាក្យថា **វិប្ផារត្តា** នេះ ជាបញ្ចមីវិភត្តិចុះក្នុងអត្ថនៃហេតុ , សេចក្តីថា ព្រោះហេតុនៃការផ្សាយទៅនៃចិត្ត ៣ ដួង របស់បុគ្គលពួកដទៃ ក្នុង

កាលដែលធ្វើបរិកម្ម ដើម្បីឲ្យចេតោបរិយញ្ញាណកើតឡើង ។

ពាក្យថា **ឥន្ទ្រិយានំ បសាទវសេន** ដោយអំណាចនៃការផូរផង់នៃឥន្ទ្រីយ៍ទាំងឡាយ សេចក្តីថា ដោយអំណាចភាពផូរផង់របស់ឥន្ទ្រីយ៍ ៦ មានចក្ខុន្ទ្រីយ៍ជាដើម , ក៏នៅក្នុងទីនេះ ឱកាសជាទីតាំងនៃឥន្ទ្រីយ៍ទាំងឡាយ លោកពោលថា **ឥន្ទ្រិយានំ** ដោយ **ផលូបចារន័យ** ដូចពាក្យថា ៖

ម្នាលលោកដ៏មានអាយុ ឥន្ទ្រីយ៍របស់លោកផូរផង់ពេកណាស់ ពណ៌សម្បុររបស់លោកបរិសុទ្ធផូរផង់ដូច្នេះ ។ ហទយវត្ថុ នោះឯង លោកប្រាថ្នាហើយក្នុងទីនេះ សូម្បីក្នុងឱកាសនៃឥន្ទ្រីយ៍ ប្រតិស្ថានហើយ ។

ពាក្យថា **បសាទវសេន** ដោយអំណាចនៃសេចក្តីផូរផង់ សេចក្តីថា ដោយអំណាចនៃការមិនល្អក់កករ ។ កាលបើពោលថា **បសាទប្បសាទវសេន** ដោយអំណាចនៃសេចក្តីជ្រះថ្លា និងសេចក្តីជ្រះថ្លាដ៏ក្រៃលែង ពាក្យនេះគប្បីជ្រាបថា លោកធ្វើការលុប **សប្បសាទ** ស័ព្ទ ចេញ ។ម្យ៉ាងទៀត ពាក្យនេះគប្បីជ្រាបថា សូម្បីមិនជ្រះថ្លាក៏លោកពោលហើយ ដោយពាក្យថា **បសាទវសេន** ដោយអំណាច



នៃសេចក្តីជ្រះថ្លានោះឯង ព្រោះស័ព្ទថា **អប្បសន្នំ** មិនផូរផង់ ហើយជាស័ព្ទ ដែលមិនសម្ដីងដល់សេចក្តីជ្រះថ្លា ។

ពាក្យថា **នានត្តេកត្តវិញ្ញាណចរិយាបរិយោគាហណេ បញ្ញា** បញ្ញាក្នុងការកំណត់ចរិយា គឺ វិញ្ញាណច្រើនយ៉ាង ឬតែម្យ៉ាង សេចក្តីថា បញ្ញាក្នុងការដឹង ការប្រព្រឹត្តទៅរបស់ចិត្ត ៨៩ ដែលមានសភាពផ្សេង ៗ គ្នា និងមានសភាពតែមួយ តាមសមគួរដល់ការកើតឡើង ។ ក្នុងវិញ្ញាណចរិយាទាំង ២ នេះ វិញ្ញាណចរិយារបស់អ្នកមិនមានសមាធិជា **នានត្តវិញ្ញាណចរិយា** , វិញ្ញាណចរិយារបស់អ្នកបានសមាធិជា **ឯកត្តវិញ្ញាណចរិយា** , ចិត្តប្រាសចាករាគៈជាដើម ជា **ឯកត្តវិញ្ញាណចរិយា** ។

ឈ្មោះថា **បរិយ** ក្នុងពាក្យនេះថា **ចេតោបរិយញ្ញាណំ** នេះ ព្រោះអត្ថថា កំណត់ អធិប្បាយថា កំណត់ជុំវិញ ។ ការកំណត់ដោយចិត្ត ឈ្មោះថា **ចេតោបរិយ** កំណត់ដោយចិត្ត , **ចេតោបរិយ** នោះផង **ញាណ** ផង ដូច្នោះឈ្មោះថា **ចេតោបរិយញ្ញាណ** ញាណក្នុងការកំណត់ដោយចិត្ត ។ បាឋៈថា **វិប្ផារតោ** ដូច្នេះក៏មាន បានសេចក្តីថា ដោយការផ្សាយទៅ ។

## ៥៣ . អដ្ឋកថា បុព្វេនិវាសានុស្សតិញ្ញាណុទ្ទេស

### ពោលអំពី បុព្វេនិវាសានុស្សតិញ្ញាណ

ពាក្យថា **បច្ចយប្បវត្តានំ ធម្មានំ** ធម៌ទាំងឡាយដែលប្រព្រឹត្តទៅតាមបច្ច័យ សេចក្តីថា បច្ចយុប្បន្នធម៌ ដែលប្រព្រឹត្តទៅហើយព្រោះបច្ច័យ ដោយអំណាចការអាស្រ័យគ្នាកើតឡើង ។

អកុសលកម្ម ឈ្មោះថា **នានត្ត** ច្រើនយ៉ាង , កុសលកម្ម ឈ្មោះថា **ឯកត្ត** តែម្យ៉ាង ក្នុងពាក្យថា **នានត្តេកត្តកម្មវិប្ផារវសេន** នេះ ។ ម្យ៉ាងទៀត កាមាវចរកម្ម ឈ្មោះថា **នានត្ត** ច្រើនយ៉ាង ។ រូបាវចរ និងអរូបាវចរ ឈ្មោះថា **ឯកត្ត** តែម្យ៉ាង ។ សម្ព័ន្ធសេចក្តីបញ្ញាក្នុងការកំណត់ធម៌ដែលកើតឡើងពីបច្ច័យ ដោយអំណាចនៃការផ្សាយទៅនៃកម្មច្រើនយ៉ាង ឬតែម្យ៉ាង ។

ពាក្យថា **បុព្វេនិវាសានុស្សតិញ្ញាណំ** ញាណជាគ្រឿងរលឹកដល់ជាតិមុន ៗ បាន ។ សេចក្តីថា ខន្ធដែលធ្លាប់អាស្រ័យពីកាលមុន គឺ ក្នុងអតីតជាតិ ឈ្មោះថា **បុព្វេនិវាស** ខន្ធដែលធ្លាប់អាស្រ័យក្នុងជាតិមុន ។



ពាក្យថា **និវុត្ថា** ខន្ធដែលធ្លាប់អាស្រ័យនៅ សេចក្តីថា ខន្ធដែលធ្លាប់នៅ គឺ ដែលមានហើយ កើតឡើងហើយ ក៏រលត់ទៅក្នុងសន្តានរបស់ខ្លួន ។ ឬធម៌ដែលធ្លាប់នៅហើយក្នុងកាលមុន គឺក្នុងអតីតជាតិ ឈ្មោះថា **បុព្វេនិវាស** ធម៌ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន ។

បទថា **និវុត្ថា** ខន្ធដែលធ្លាប់អាស្រ័យនៅ សេចក្តីថា នៅហើយដោយការនៅ ព្រោះអាស្រ័យធម៌ដូចបានពោលមកហើយជាអារម្មណ៍ គឺ ដឹងច្បាស់ដោយចិត្តរបស់ខ្លួន ឈ្មោះថា ការកំណត់សូម្បីថា ដឹងច្បាស់នូវចិត្តរបស់អ្នកដទៃ ក៏ឈ្មោះថា ការកំណត់តែអ្នកទ្រទ្រង់គុណដូចបានពោលមកនេះ រមែងមានចំពោះព្រះពុទ្ធជាម្ចាស់ប៉ុណ្ណោះ ក្នុងបណ្តាការរលឹកដល់ការរៀលស្ងាប់ វិលកើតដែលដាច់ជាវគ្គ ៗ ជាដើម ។

ពាក្យថា **បុព្វេនិវាសានុស្សតិ** តាមរលឹកដឹងជាតិមុន ៗ បាន សេចក្តីថា តាមរលឹកដឹងខន្ធដែលធ្លាប់អាស្រ័យនៅក្នុងគ្រាមុនបាន ដោយសតិណា សតិនោះ ឈ្មោះថា **បុព្វេនិវាសានុស្សតិ** ។

ពាក្យថា **ញាណំ** ញាណ បានដល់ ញាណដែលសម្បយុត្ត

ដោយសតិនោះ ។

## ៥៤. អដ្ឋកថា ទិព្វចក្ខុញ្ញាណុទ្ទេស

### ពោលអំពី ទិព្វចក្ខុញ្ញាណ

ពាក្យថា **ឧភាសវសេន** ដោយអំណាចពន្លឺភ្លឺ សេចក្ដីថា ដោយអំណាចពន្លឺភ្លឺនៃកសិណណាមួយ គឺ តេជោកសិណ ឱទាតកសិណ អាលោកកសិណ ដែលជាអារម្មណ៍នៃចតុត្ថជ្ឈានដែលផ្សាយទៅ ដើម្បីឲ្យឃើញរូបដោយទិព្វចក្ខុ ។

ពាក្យថា **នានត្តេកត្តរូបនិមិត្តានំ** និមិត្ត គឺ រូបខុសគ្នា និងដូចគ្នា សេចក្ដីថា រូបនៃសត្វផ្សេង ៗ , ឬរូបសត្វទាំងឡាយដែលកើតឡើងក្នុងជំពូកដែលមានកាយខុសគ្នា , ឬរូបទាំងឡាយក្នុងទិសផ្សេង ៗ , ឬរូបទាំងឡាយដែលមិនប្រឡំគ្នា ឈ្មោះថា **នានត្តរូប** រូបដូចគ្នា , រូបនៃសត្វមួយ , ឬរូបនៃសត្វដែលកើតនៅក្នុងជំពូកដែលមានកាយដូចគ្នា , ឬរូបទាំងឡាយក្នុងទិសតែមួយ ឬរូបទាំងឡាយដែលដូចគ្នា និងទិសផ្សេង ៗ ជាដើម ឈ្មោះថា **ឯកត្តរូប** រូប



ដូចគ្នា ។

ក៏ក្នុងពាក្យថា **រូបំ** នេះ បានដល់ រូបាយតនៈ ( ពណ៌ ) ប៉ុណ្ណោះ ។ ព្រោះរូបាយតនៈនោះ រមែងបែកធ្លាយទៅ ដូច្នោះ ទើបឈ្មោះថា រូប , អធិប្បាយថា វណ្ណាយតនៈនោះ កាលបើដល់នូវវណ្ណវិការ ការប្រែប្រួលនៃវណ្ណៈ ក៏រមែងប្រកាសការដល់នូវហទយៈ ។ រូបនោះឯង ឈ្មោះថា និមិត្ត គឺ រូបនៃនិមិត្ត គឺ រូបផ្សេងគ្នា និងដូចគ្នាទាំងនោះ ។

ពាក្យថា **ទស្សនដ្ឋេ បញ្ញា** បញ្ញាក្នុងអត្ថថាឃើញ បានដល់ បញ្ញាក្នុងការឃើញជាសភាវៈ ។

ពាក្យថា **ទិព្វចក្ខុញាណំ** ញាណក្នុងទិព្វចក្ខុ ឈ្មោះថា **ទិព្វ** ព្រោះដូចជារបស់ទិព្វ ។ បសាទចក្ខុដែលជាទិព្វរបស់ពួកទេព ដែលកើតឡើងដោយសុចរិតកម្ម ដែលមិនប្រឡាក់ដោយមន្ទិលទាំងឡាយ មានទឹកប្រមាត់ , ស្លេស និងឈាមជាដើម អាចទទួលអារម្មណ៍សូម្បីនៅក្នុងទីឆ្ងាយបាន ព្រោះផុតពីមន្ទិលជាគ្រឿងសៅហ្មង ។ សូម្បីញាណចក្ខុនេះ ដែលកើតព្រោះកម្លាំងនៃវិរិយៈភាវនា ក៏យ៉ាងដូច្នោះនោះឯង ទើបឈ្មោះថា **ទិព្វ** ព្រោះដូចជារបស់ទិព្វ ឈ្មោះថា

**ទិព្វ** ព្រោះជាធម៌ដែលអាស្រ័យទិព្វវិហារធម៌ ព្រោះបានចំពោះដោយអំណាចទិព្វវិហារធម៌ , ឈ្មោះថា **ទិព្វ** ព្រោះជារបស់រុងរឿង ច្រើនដោយការកំណត់អាលោកៈ ( ពន្លឺ ) ឈ្មោះថា **ទិព្វ** សូម្បីព្រោះមានផ្លូវទៅច្រើន ដោយការឃើញរូបខាងក្រៅជញ្ជាំងផ្ទះជាដើមបាន ។

ពាក្យទាំងអស់នោះ គប្បីជ្រាបបានតាមគន្លងនៃគម្ពីរស័ព្ទ-សាស្ត្រ ។ ព្រោះអត្ថថា ឃើញ ទើបឈ្មោះថា ចក្ខុ ញាណចក្ខុដូចគ្នានឹងចក្ខុ សូម្បីហេតុនោះ ទើបឈ្មោះថា ចក្ខុ , ចក្ខុនោះដែលគ្រាន់តែដូចជាទិព្វផង ដូច្នោះទើបឈ្មោះថា ទិព្វចក្ខុនោះផងញាណផង រួមគ្នាថា **ទិព្វចក្ខុញ្ញាណ** ញាណក្នុងទិព្វចក្ខុ ។

## ៥៥ . អដ្ឋកថា អាសវក្ខយញ្ញាណុទ្ទេស

## ពោលអំពី អាសវក្ខយញ្ញាណ

ពាក្យថា **ចតុសដ្ឋិយា អាការេហិ** ដោយអាការ ៦៤ សេចក្តីថា ដោយអាការនៃឥន្ទ្រីយ៍មួយម្យ៉ាង ៨ ក្នុងមគ្គផលមួយ ៗ ក្នុងមគ្គផលមួយ ៗ ៨ ទើបរួមជា ៦៤ ។



ពាក្យថា **តិណ្ណន្នំ ឥន្ទ្រិយានំ** ឥន្ទ្រីយ៍ ៣ សេចក្តីថា ក្នុងឥន្ទ្រីយ៍ទាំង ៣ នេះ គឺ អនញ្ញាតញ្ញស្សាមីតិន្ទ្រីយ៍ , អញ្ញិន្ទ្រីយ៍ , អញ្ញាតាវិន្ទ្រីយ៍ ។

ពាក្យថា **វសិភាវតា បញ្ញា** បញ្ញា គឺ ភាពជាអ្នកមានសេចក្តីជំនាញ សេចក្តីថា បញ្ញាដែលប្រព្រឹត្តទៅហើយដោយភាពជាអ្នកមានសេចក្តីជំនាញ បញ្ញាដែលប្រព្រឹត្តទៅហើយដោយភាពជាអ្នកមានសេចក្តីជំនាញនៃអញ្ញាតាវិន្ទ្រីយ៍នោះឯង ដោយអាការ ៨ ដោយអំណាចនៃឥន្ទ្រីយ៍ ៨ ក្នុងអរហត្តផល ពាក្យនេះគប្បីជ្រាបថាលោកពោលហើយ ព្រោះការសម្រេចផលនោះ ដោយអំណាចនៃការសម្រេចហេតុ សូម្បីព្រោះការមិនមានក្នុងខណៈអរហត្តមគ្គ ។

បទថា **អាសវានំ ខយេ ញាណំ** ញាណក្នុងការអស់ទៅនៃអាសវៈទាំងឡាយ សេចក្តីថា អរហត្តមគ្គញ្ញាណដែលធ្វើការកម្ចាត់អាសវៈទាំងឡាយឲ្យអស់ទៅ ដែលខ្ជួនសម្ចាប់អស់ហើយ ។

## ៥៦ . ៥៩ អដ្ឋកថា ទុក្ខសមុទយនិរោធមគ្គញ្ញាណុទ្ទេស

## ពោលអំពី ញាណក្នុងអរិយសច្ច

ឥឡូវនេះ ដើម្បីសម្តែងការត្រាស់ដឹងដោយញាណ ដូចគ្នានៃ

មគ្គញ្ញាណមួយ ៗ បណ្ដាមគ្គញ្ញាណទាំង ៤ ដោយការទាក់ទងដោយអរហត្តមគ្គញ្ញាណ ពោលគឺ អាសវក្ខយញ្ញាណ ព្រះធម្មសេនាបតីសារីបុត្រ ទើបបានលើកញាណទាំង ៤ មានពាក្យថា **បរិញ្ញដ្ឋេ បញ្ញា** បញ្ញាក្នុងអត្ថថា ដឹងជុំវិញជាដើម លើកឡើងសម្ដែង ។

បណ្ដាសច្ចៈទាំង ៤ នោះ ទុក្ខសច្ចលោកពោលមុន ព្រោះទុក្ខសច្ច ជារបស់គ្រោតគ្រាត ។ ព្រោះមាននៅទូទៅដល់សត្វទាំងពួង , និងជារបស់ដែលដឹងបានដោយងាយ , ហើយសម្ដែងសមុទយសច្ច តពីទុក្ខសច្ចនោះ ដើម្បីសម្ដែងហេតុនៃទុក្ខសច្ចនោះ តពីនោះក៏សម្ដែងនិរោធសច្ច ដើម្បីឲ្យដឹងថា ផលរលត់ ក៏ព្រោះហេតុរលត់ ហើយសម្ដែងមគ្គសច្ចក្នុងទីបំផុត ដើម្បីសម្ដែងឧបាយជាគ្រឿងសម្រេចដល់និរោធសច្ចនោះ ។ ម្យ៉ាងទៀត លោកពោលទុក្ខមុន ក៏ដើម្បីឲ្យកើតសេចក្ដីសង្វេគដល់សត្វទាំងឡាយជាអ្នកជាប់ដោយសេចក្ដីត្រេកអរនឹងសុខក្នុងភព , ទុក្ខនុ៎ះ មិនមែនមានដោយមិនមានហេតុ មិនមែនមានមកព្រោះព្រះឥស្វរៈនិម្មិតជាដើម តែមានមកពីសមុទយសច្ចនេះ ដូច្នោះ លោកទើបពោលសមុទយសច្ចទុកក្នុងលំដាប់ទុក្ខនោះ ដើម្បីឲ្យដឹងខ្លឹមសារនេះ ហើយពោលទុក្ខនិរោធ



ដើម្បីស្វែងរកធម៌ជាគ្រឿងផុតទុក្ខ ពោះត្រូវទុក្ខ ដែលប្រព្រឹត្តទៅជាមួយដោយហេតុ គឺ សមុទយគ្របសង្កត់ ហើយពោលមគ្គដែលឲ្យដល់និរោធ ដើម្បីឲ្យសម្រេចនិរោធ ។ លោកបានលើកញាណទាំងឡាយដែលជាវិស័យនៃសច្ចៈទាំង ៤ នោះ ឡើងសម្ដែងតាមលំដាប់ឥឡូវនេះ ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **បរិញ្ញដ្ឋេ** ដឹងជុំវិញក្នុងអត្ថ សេចក្ដីថា ក្នុងសភាវៈដែលគួរដឹងជុំវិញ ៤ យ៉ាង មានការបៀតបៀនជាដើមនៃទុក្ខ ។

ពាក្យថា **បហានដ្ឋេ** ក្នុងអត្ថថា លះ សេចក្ដីថា ក្នុងសភាវៈដែលគួរលះ ៤ យ៉ាង មានការប្រមូលមកនៃសមុទយសច្ចជាដើម ។ ពាក្យថា **សច្ឆិកិរិយដ្ឋេ** ក្នុងអត្ថថា ធ្វើឲ្យដឹងសេចក្ដីថា ក្នុងសភាវៈដែលគួរធ្វើឲ្យដឹង ៤ យ៉ាង មានការចេញពីទុក្ខជាដើមនៃនិរោធ ។

ពាក្យថា **ភាវនដ្ឋេ** ក្នុងអត្ថថា ចម្រើន សេចក្ដីថា ក្នុងសភាវៈដែលគួរចម្រើន ៤ យ៉ាង មានការនាំចេញជាដើមនៃមគ្គ ។

~ * ~

## ៦០.៦៣ អដ្ឋកថា ទុក្ខទុក្ខសមុទយសច្ចទុក្ខនិរោធ ទុក្ខនិរោធគាមិនីបដិបទាញាណុទ្ទេស

## ពោលអំពី ទុក្ខ ទុក្ខសមុទយ ទុក្ខនិរោធ ទុក្ខនិរោធគាមិនីបដិបទាញាណ

ឥឡូវនេះ ដើម្បីនឹងសម្ដែងសច្ចញាណជាផ្នែក ៗ ទៅដោយអំណាចនៃការពិចារណាដល់មគ្គ ដែលបានចំរើនហើយក្ដី ដោយអំណាចការបានឮ បានស្ដាប់របស់អ្នកមិនបានអប់រំមគ្គក្ដី ព្រះធម្មសេនាបតីសារីបុត្រទើបលើកយកញាណ ៤ មានទុក្ខសច្ចញាណជាដើម ឡើងសម្ដែង ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **ទុក្ខេ** ក្នុង ទុក្ខ **ទុ** ស័ព្ទក្នុងពាក្យនេះ រមែងប្រាកដក្នុងអត្ថថា គួរខ្ពើម ។ ជនទាំងឡាយរមែងហៅបុត្រគួរស្អប់ថា **ទុបុត្ត** បុត្រខូច ។ **ខ** ស័ព្ទនោះ រមែងប្រាកដក្នុងអត្ថថា សោះសូន្យ ។ ពិតហើយលោកហៅអាកាសដែលទទេថា **ខំ** ។ ក៏សច្ចទី ១ នេះ ឈ្មោះថា គួរខ្ពើម ព្រោះជាទីតាំងនៃឧបទ្រវៈជាអនេក , ឈ្មោះថា សោះសូន្យ ព្រោះវៀរចាក



ពីសេចក្ដីយឺនយូរ , សេចក្ដីសុខ សេចក្ដីល្អ និងអត្តា ជារបស់ដែលគួរប្រាថ្នានៃជនពាល ។ ព្រោះដូចោះ លោកទើបពោលថា **ទុក្ខ** ព្រោះជារបស់គួរស្អប់ និងព្រោះជារបស់សោះសូន្យ ។

ក្នុងពាក្យថា **ទុក្ខសមុទយ** ក្នុងទុក្ខសមុទយនេះ **សំ** ស័ព្ទនេះសម្ដែងដល់ **សំយោគ** ការប្រកបព្រមគ្នា ដូចក្នុងពាក្យ ជាដើមថា **សមាគមោ** មកប្រជុំព្រមគ្នា **សមេតំ** មកដល់ព្រមគ្នា , **ឧ** ស័ព្ទនេះសម្ដែងដល់ការឧប្បត្តិ ដូចក្នុងពាក្យជាដើមថា **ឧប្បន្នំ** កើតឡើងហើយ **ឧទិតំ** តាំងឡើងហើយ ។ **អយ** ស័ព្ទ ក៏រមែងសម្ដែងដល់ **ការណ** ហេតុ ។ ព្រោះជាហេតុកើតឡើងនៃទុក្ខ ព្រោះដូច្នោះលោកទើបពោលថា **ទុក្ខសមុទយ** ព្រោះហេតុដែល សច្ចៈទី ២ ជាហេតុកើតនៃទុក្ខក្នុងកាលមានការប្រកប ។

ក្នុងពាក្យថា **ទុក្ខនិរោធ** ក្នុងការរំលត់នៃទុក្ខនេះ **និ** ស័ព្ទសម្ដែងដល់ សភាវៈ ការមិនមាន , និង **រោធ** ស័ព្ទ សម្ដែងដល់ការធ្វើដំណើរទៅក្នុងវដ្ដសង្សារ ។ ព្រោះដូច្នោះ ការមិនមាននៃការធ្វើដំណើរទៅនៃទុក្ខ ពោលគឺ ការធ្វើដំណើរទៅក្នុងសង្សារទុក្ខ ព្រោះទំនេរពីគតិទាំងពួង , មយ៉ាងទៀត កាលបើសម្រេចនិរោធនោះហើយ

ទុក្ខនិរោធដែលធ្វើដំណើរទៅក្នុងសង្សារ រមែងមិនមាន ព្រោះទុក្ខ-និរោធ ជាបដិបក្ខចំពោះការធ្វើដំណើរទៅក្នុងសង្សារ សូម្បីព្រោះហេតុនោះ ក៏ហៅទុក្ខនិរោធ ម្យ៉ាងទៀត ហៅថា ទុក្ខនិរោធ ព្រោះជាបច្ច័យដល់ការរំលត់មិនកើតនៃទុក្ខ ។

ក្នុងពាក្យថា **ទុក្ខនិរោធគាមិនីយា បដិទាយ** ក្នុងបដិបទាជាហេតុដល់នូវទុក្ខនិរោធនេះ មគ្គមានអង្គ ៨ នេះ រមែងដល់នូវទុក្ខ ព្រោះមានមុខឆ្ពោះទៅទុក្ខនិរោធនោះ ដោយការធ្វើឲ្យជាអារម្មណ៍ និងជាបដិបទានៃការសម្រេចទុក្ខនិរោធ ដូច្នោះលោកទើបហៅថា ទុក្ខនិរោធគាមិនីបដិបទា ។

មគ្គញាណ ៤ ប៉ុណ្ណោះ ក្នុងខាងដើមលោកពោលថា មគ្គ-ញាណ ដោយអំណាចនៃការសម្តែងអាការ គឺ ការចេញ , លោកពោលថា **អានន្តរិកសមាធិញ្ញាណ** ដោយអំណាចនៃការសម្តែងហេតុនៃការឲ្យផលក្នុងលំដាប់ , លោកពោល **សច្ចវិវដ្តញ្ញាណ** ដោយអំណាចនៃការគេចចេញពីវដ្តៈដោយសច្ចៈ , លោកពោល **អាសវក្ខយញ្ញាណ** ដើម្បីសម្តែងការកើតឡើងនៃអរហត្តមគ្គញ្ញាណតាមលំដាប់នៃមគ្គ និងសម្តែងការដឹងដ៏ក្រៃលែងនៃញាណនោះ ,



លោកសម្តែងញាណ ៤ ជាដើម បញ្ញាក្នុងបរិញ្ញេយ្យធម៌ ឈ្មោះថា ទុក្ខញាណ ដើម្បីសម្តែងមគ្គញ្ញាណទាំង ៤ ជាញាណដែលត្រាស់ដឹងជាមួយគ្នាបន្ថែមទៀត លោកលើកញាណទាំង ៤ មានទុក្ខញាណជាដើម ដោយអំណាចនៃការសម្តែងការកើតឡើងបែកគ្នាក្នុងសច្ចៈមួយ ៗ ទៀត ដូច្នោះ គប្បីជ្រាបការខុសគ្នាទាំងក្នុងខាងដើម និងខាងចុង ដូចសម្តែងមកដោយប្រការដូច្នេះឯង ។

## ៦៥.៦៧ អដ្ឋកថា បដិសម្ភិទាធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទាបដិភាណប្បដិសម្ភិទាញាណុទ្ទេស

### ពោលអំពី បដិសម្ភិទាញាណ ៤

ឥឡូវនេះ ដើម្បីនឹងសម្តែងថា បដិសម្ភិទាញាណសម្រេចដល់ព្រះអរិយបុគ្គលទាំងពួង ដោយអានុភាពនៃអរិយមគ្គប៉ុណ្ណោះ លោកទើបលើកយកបដិសម្ភិទាញាណ ៤ មានអដ្ឋកថាបដិសម្ភិ-ទាញាណជាដើម ឡើងសម្តែងទៀត ។ ក៏បដិសម្ភិទាញាណទាំងនេះ ជាបដិសម្ភិទាញាណទូទៅ ដល់ព្រះអរិយបុគ្គលទាំងពួង សូម្បីក្នុង

ខណៈមិនមានការជំនាញក្នុងបដិសម្ភិទាជាមួយគ្នា , តែលោកលើកសម្ដែងក្នុងខាងក្រោយ , គប្បីជ្រាបថា ជាបដិសម្ភិទាញាណដែលដល់ភាពជំនាញរបស់អ្នកមានបដិសម្ភិទាជំនាញហើយ នេះជាការខុសគ្នារបស់អត្ថវចនៈទាំង ២ នៃពាក្យទាំងនោះ ។ ឬញាណដែលលោកសម្ដែងក្នុងលំដាប់មានទុក្ខជាអារម្មណ៍ និងមាននិរោធជាអារម្មណ៍ ជាអត្ថប្បដិសម្ភិទា , ញាណមានសមុទយជាអារម្មណ៍ និងមានមគ្គជាអារម្មណ៍ ជាធម្មប្បដិសម្ភិទា , ញាណក្នុងវោហារដែលសម្ដែងអត្ថ និងធម៌នោះ ជានិរុត្តិប្បដិសម្ភិទា , ញាណក្នុងញាណទាំង ៣ ទាំងនោះ ជាបដិភាណប្បដិម្ភិទា , ព្រោះដូច្នោះ គប្បីជ្រាបថា លោកលើកយក សុទ្ធិកបដិសម្ភិទាញាណឡើងសម្ដែង ដើម្បីនឹងបង្ហាញសេចក្ដីប្លែកគ្នានៃវិមសារនោះ ។ ក៏ព្រោះហេតុនោះឯងលោកទើបពោលឲ្យប្លែកគ្នាដោយនានត្តស័ព្ទក្នុងខាងក្រោយ , ក្នុងទីនេះ ទើបមិនពោលឲ្យប្លែកគ្នាដូច្នោះ ដូច្នេះ ។

~ * ~



## ៦៨ . អដ្ឋកថា ឥន្ទ្រិយបរោយត្តញ្ញាណុទ្ទេស

## ពោលអំពី ឥន្ទ្រិយបរោបរិយត្តញ្ញាណ

ព្រះធម្មសេនាបតីសារីបុត្រ កាលលើកយកញាណដ៏ទូទៅដល់ព្រះសាវក ៦៧ ញាណឡើងសម្ដែងតាមលំដាប់យ៉ាង នេះហើយ ដើម្បីនឹងសម្ដែងញាណ ដែលមានដោយចំពោះព្រះតថាគតជាម្ចាស់ប៉ុណ្ណោះ មិនទូទៅដល់ព្រះសាវកទាំងឡាយ ទើបលើកយកអសាធារណញ្ញាណ ៦ មានឥន្ទ្រិយបរោបរិយត្តញ្ញាណ ឡើងសម្ដែងក្នុងឥឡូវនេះ ។

សូម្បីងសាធារណញ្ញាណទាំង ៦ នោះ ព្រះតថាគតជាម្ចាស់ទាំងឡាយ កាលបើទ្រង់ពិចារណាមើលនូវសត្វទាំងឡាយ ជាអ្នកមានភាជនៈជាគ្រឿងទទួលព្រះធម៌ទេសនា ក៏រមែងពិចារណាមើលដោយពុទ្ធចក្ខុ ។ ឥន្ទ្រិយបរោបរិយត្តញ្ញាណ និងអាសយានុសយញ្ញាណទាំង ២ នេះ ប៉ុណ្ណោះ ឈ្មោះថា **ពុទ្ធចក្ខុ** ។ សមពិតដូចលោកពោលទុកថា ៖

**ព្រះមានព្រះភាគជាម្ចាស់ ពិចារណាមើលសត្វ**

**លោកដោយពុទ្ធចក្ខុ ទ្រង់បានឃើញហើយ នូវសត្វទាំងឡាយពួកខ្លះ មានធូលី គឺកិលេសតិចក្នុងចក្ខុ ពួកខ្លះមានធូលីគឺកិលេសច្រើនក្នុងចក្ខុ ពួកខ្លះមានឥន្ទ្រីយ៍ចាស់ក្លា ពួកខ្លះមានឥន្ទ្រីយ៍ទន់ខ្វី យ៉ាងនេះជាដើម ។**

កាលបើពិចារណាមើលសត្វទាំងឡាយ ទ្រង់ក៏ពិចារណាមើលសេចក្ដីចាស់ក្លានៃឥន្ទ្រីយ៍ក្នុងសន្តានរបស់សត្វមុន , កាលបើទ្រង់ជ្រាបសេចក្ដីចាស់ក្លានៃឥន្ទ្រីយ៍ហើយ តពីនោះក៏ទ្រង់ពិចារណាមើលអាសយានុសយ និងចរិត ដើម្បីសម្ដែងធម៌តាមសមគួរដល់អាសយៈជាដើម , ព្រោះហេតុនោះ លោកទើបលើកយកឥន្ទ្រិយ-បរោបរិយត្តញាណឡើងសម្ដែង ។

ក៏កាលបើទ្រង់សម្ដែងធម៌ ទ្រង់រមែងធ្វើបាដិហារិយ៍ដល់អ្នកគួរណែនាំដោយបាដិហារិយ៍ , ព្រោះហេតុនោះ ព្រះធម្មសេនាបតីសារីបុត្រ ទើបលើកយកញាណក្នុងយមកប្បាដិហារិយ៍ ឡើងសម្ដែងក្នុងលំដាប់តពីអាសយានុសយញាណ ដើម្បនឹងសម្ដែងហេតុនៃញាណទាំង ៣ នោះ ទើបលើកមហាករុណាញាណឡើងសម្ដែង



ហើយលើកសព្វញ្ញុតញ្ញាណឡើងសម្ដែងជាលំដាប់តទៅ ដើម្បីសម្ដែងសេចក្ដីបរិសុទ្ធិនៃមហាករុណាញាណ ។

គប្បីជ្រាបថា ព្រះធម្មសេនាបតីសារីបុត្រ បានលើកយកអនាវរណញ្ញាណឡើង សម្ដែងក្នុងលំដាប់នៃសព្វញ្ញុតញ្ញាណនោះ ដើម្បីសម្ដែងសភាពនៃព្រះសព្វញ្ញុតញ្ញាណ ជាញាណដែលទាក់ទងដោយការរំលឹកដល់ធម៌ទាំងពួង និងដើម្បីសម្ដែងព្រះសព្វញ្ញុត-ញ្ញាណ ជាអនាវរិយភាព គឺ មិនមានអ្វីទើសទាក់ ។

ក្នុងពាក្យថា **ឥន្ទ្រិយបរោបរិយត្តញ្ញាណំ** ញាណក្នុងភាពដ៏ក្រៃលែង និងទន់ខ្វីនៃឥន្ទ្រិយរបស់សត្វទាំងឡាយនេះ បទថា **សត្តានំ** នៃសត្វទាំងឡាយ ខាងមុខគប្បីនាំមកប្រកបក្នុងទីនេះដោយ ជា **សត្តានំ ឥន្ទ្រិយបរោបរិយញ្ញាណំ** ។ កាលណាគួរនឹងពោលថា **បរានិ ច អបរានិ ច បរាបរានិ** លោកក៏ហៅទៅថា **បរោបរានិ** ព្រោះធ្វើឲ្យជា **រោ** អក្សរ ដោយសន្ធិវិធី ។ **ភាវនៃបរោបរ** ឈ្មោះថា **បរោបរិយ** បរោបរិយៈនោះឯង , ឈ្មោះថា បរោបរិយត្ត ភាពខ្វីនិងចាស់នៃឥន្ទ្រិយ ៥ មានសទ្ធាជាដើម របស់វេនេយ្យសត្វទាំងឡាយ ឈ្មោះថា **ឥន្ទ្រិយបរោបរិយត្ត** , ញាណក្នុងឥន្ទ្រិយ-

បរោបរិយត្តៈ ឈ្មោះថា ឥន្ទ្រិយបរោបរិយត្តញ្ញាណ , អធិប្បាយថា ញាណក្នុងឥន្ទ្រិយទាំងឡាយជាគុណខ្ពស់ និងទាប បាឋៈថា **ឥន្ទ្រិយ-វរោវរិយត្តញាណំ** ញាណក្នុងឥន្ទ្រិយដែលជាគុណប្រសើរ និងមិនប្រសើរ យ៉ាងនេះក៏មាន ។ គប្បីប្រកបពាក្យថា **វរានិ ច អវរានិ ច វរោវរិយានិ** ប្រសើរផង មិនប្រសើរផង ឈ្មោះថា ប្រសើរ និងមិនប្រសើរ , ភាវៈនៃវរោវរិយៈ ឈ្មោះថា **វរោវរិយត្ត** ។

ពាក្យថា **អវរិយានិ** មិនប្រសើរ សេចក្តីថា មិនខ្ពស់ផុតម្យ៉ាងទៀត **បរ** ឥន្ទ្រិយដែលប្រើបានផង , **ឱបរ** ឥន្ទ្រិយដែលប្រើមិនបានផង ឈ្មោះថា **បរោបរ** , គប្បីប្រកបសេចក្តីថា ភាវៈនៃបរោបរៈ ឈ្មោះថា **បរោបរិយត្ត** ភាពនៃឥន្ទ្រិយដែលប្រើបាន និងប្រើមិនបាន ដូច្នេះ ។

ពាក្យថា **ឱបរានិ** ឥន្ទ្រិយដែលប្រើមិនបាន មានពាក្យអធិប្បាយថា ទាបថោក សេចក្តីថា លាមក ដូចក្នុងពាក្យជាដើមថា ពិចារណាធម៌ដែលលាមករបស់អ្នកណា ដូច្នេះ ។ លោកតាំងបាឋៈទុកជាសត្តមីវិភត្តិថា **ឥន្ទ្រិយបរោបរិយត្តេញាណំ** យ៉ាងនេះ ក៏មាន ។



## ៦៩. អដ្ឋកថា អាសយានុសយញ្ញាណុទ្ទេស

## ពោលអំពី អាសយានុសយញ្ញាណ

សត្វទាំងឡាយ ជាប់ជំពាក់ដោយឆន្ទរាគៈក្នុងខន្ធទាំងឡាយមានរូបក្ខន្ធជាដើម ហៅថា **សត្តា** សត្វទាំងឡាយ ក្នុងពាក្យនេះថា **សត្តានំ អាសយានុសយេ ញាណំ** ញាណក្នុងអាសយានុស័យរបស់សត្វទាំងឡាយ ។

សមពិតដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលរាធៈ ព្រោះហេតុនៃសេចក្តីពេញចិត្ត សេចក្តីស្រឡាញ់ សេចក្តីក្ដីតក្ដីន សេចក្តីប្រាថ្នាក្នុងរូប ជាអ្នកជាប់ក្នុងរូប ជាអ្នកជាប់ទាក់ទងក្នុងរូបនោះ ដូច្នោះទើបហៅថា សត្វ ព្រោះហេតុនៃសេចក្តីពេញចិត្ត សេចក្តីស្រឡាញ់ សេចក្តីក្ដីតក្ដីន សេចក្តីប្រាថ្នាក្នុងវេទនា ... ក្នុងសញ្ញា ...ក្នុងសង្ខារ ... ក្នុងវិញ្ញាណជាអ្នកជាប់ក្នុងវិញ្ញាណ ជាអ្នកទាក់ទងក្នុងវិញ្ញាណនោះ ដូច្នោះទើបហៅថា សត្វដូច្នេះជាដើម

ចំណែកអាចារ្យពួកខ្លះ អ្នកមើលចំពោះតួអក្សរ មិនពិចារណាដល់អត្ថ ក៏សម្រេចសេចក្ដីយល់ឃើញថា ពាក្យនេះ គ្រាន់តែជាពាក្យនាមប៉ុណ្ណោះ ។ ចំណែកអាចារ្យអ្នកពិចារណាដល់អត្ថ , អាចារ្យទាំងនោះ ក៏រមែងបំណងសេចក្ដីថា ឈ្មោះថា សត្វ ព្រោះប្រកបជាមួយវត្ថុទាំងពួង ។ វត្ថុណាអាស្រ័យនៅ ជាទីអាស្រ័យនៅនៃសត្វទាំងនោះ ដូច្នោះទើបឈ្មោះថា អាសយៈ , ពាក្យនេះជាឈ្មោះរបស់សន្តាននៃមិច្ឆាទិដ្ឋិ ឬសម្មាទិដ្ឋិអប់រំហើយ , ឬថាដែលទោសទាំងឡាយ មានកាមជាដើម ឬគុណទាំងឡាយ មាននេក្ខម្មៈជាដើម អប់រំហើយ ។ កិលេសណា ៗ ដែលដេកសម្ងំប្រព្រឹត្តទៅតាម នៅក្នុងសន្តានរបស់សត្វ ដូច្នោះ កិលេសនោះ ៗ ទើបឈ្មោះថា **អនុសយា** ។ ពាក្យនេះ ជាឈ្មោះរបស់កិលេសទាំងឡាយ មានកាមរាគៈជាដើម ដែលមានកម្លាំង ។

**អាសយ** ផង **អនុសយ** ផង ឈ្មោះថា **អាសយនុសយ** ។ គប្បីជ្រាបថា ជាឯកវចនៈ ដោយជាតិស័ព្ទ និងដោយអំណាចនៃទ្វន្ទវសមាស ។ អធិមុត្តិ ពោលគឺ ចរិត សង្គ្រោះចូលក្នុងអាសយានុសយ , ព្រោះហេតុនោះក្នុងឧទ្ទេស លោកទើបសង្គ្រោះញាណ



ក្នុងចរិតាធិមុត្តិចូលជាមួយ **អាសយានុសយេ ញាណំ** ញាណក្នុងអាសយានុសយ ។ លោកធ្វើនិទ្ទេសទុកដោយបំណងណា , និទ្ទេសលោកក៏ធ្វើទុកដោយបំណងនោះ នោះឯង ។

## ៧០ . អដ្ឋកថា យមកប្បាដិហីរញ្ញាណុទ្ទេស

### ពោលអំពី យមកប្បាដិហីរញ្ញាណ

គប្បីជ្រាបពាក្យវិនិច្ឆ័យក្នុងពាក្យថា **យមកបាតិហីរញាណំ** ញាណក្នុងយមកប្បាដិហីរ នេះ ដូចតទៅនេះ ៖

ឈ្មោះថា **យមក** ព្រោះធ្វើទភ្លើង និងទទឹកជាដើម ឲ្យប្រព្រឹត្តទៅក្នុងគ្រាជាមួយគ្នា មិនមុនមិនក្រោយតែម្ដង , ឈ្មោះថា បាដិហីរៈ ព្រោះកម្ចាត់ចេញនូវបដិបក្ខនៃធម៌ទាំងឡាយ មានការមិន ជឿជាដើម , យមកៈនោះផង បាតិហីរៈផង ដូច្នោះ ទើបឈ្មោះថា **យមកប្បាដិហីរ** ។

## ៧១ . អដ្ឋកថា មហាករុណាសមាបត្តិញ្ញាណុទ្ទេស

### ពោលអំពី មហាករុណាសមាបត្តិញ្ញាណ

គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា **មហាករុណាសមាបត្តិយា ញាណំ** ញាណក្នុងករុណាសមាបត្តិនេះ ដូចតទៅនេះ ៖

ធម្មជាតិណា កាលបើទុក្ខរបស់អ្នកដទៃមាន រមែងធ្វើឲ្យញាប់ញ័រដល់សាធុជនទាំងឡាយ ឬថា រមែងស្មោះត្រង់ គឺ រមែងបៀតបៀន បំផ្លាញទុក្ខរបស់អ្នកដទៃ ដូច្នោះធម្មជាតិនោះ ឈ្មោះថា ករុណា , ម្យ៉ាងទៀត ធម្មជាតិណា រមែងអាណិតអាសូ គឺ រមែងផ្សាយទៅដោយអំណាចនៃការផ្សាយទៅក្នុងពួកទុក្ខិតសត្វ សត្វដែលមានទុក្ខ ដូច្នោះ ធម្មជាតិនោះឈ្មោះថា **ករុណា** ករុណាធំ ឈ្មោះថា មហាករុណា ដោយអំណាចកម្ម គឺ ការផ្សាយទៅ និងដោយអំណាចកម្មដែលជាគុណ , ព្រះមានព្រះភាគ ទ្រង់ព្រះមហាករុណា រមែងចូលកាន់សមាបត្តិនេះបាន ដូច្នោះទើបឈ្មោះថា **សមាបត្តិ** សមាបត្តិ , ព្រះមហាករុណានោះផង ជាសមាបត្តិផង ដូច្នោះទើបឈ្មោះថា **មហាករុណាសមាបត្តិ** ។ ក្នុងមហាករុណាសមាបត្តិនោះ ,



ញាណដែលសម្បយុត្តជាមួយមហាករុណាសមាបត្តិនោះ ។

## ៧២ . ៧៣ អដ្ឋកថា សព្វញ្ញុតញ្ញាណអនាវរណញ្ញាណុទ្ទេស

### ពោលអំពី សព្វញ្ញុតញ្ញាណអនាវរណញ្ញាណ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សព្វញ្ញុតញ្ញាណំ អនាវរណ-ញ្ញាណំ** ញាណជាគ្រឿងដឹងធម៌ទាំងពួង ញាណដែលមិនមានអ្វីបិទបាំងនេះ ដូចតទៅនេះ ៖

ឈ្មោះថា ព្រះពុទ្ធព្រះអង្គណា ទ្រង់ត្រាស់ដឹងធម៌ទាំងពួង មានប្រភេទនៃគន្លងដែលនឹងគប្បីណែនាំ ៥ ប្រការ ដូច្នោះ ព្រះពុទ្ធព្រះអង្គនោះ ឈ្មោះថា **សព្វញ្ញូ** ត្រាស់ដឹងធម៌ទាំងពួង , សេចក្តីនៃព្រះសព្វញ្ញូ ឈ្មោះថា **សព្វញ្ញុតា** , ញាណ គឺ **ព្រះសព្វ-ញ្ញុតាញ្ញាណ** នោះ គួរពោលថា **សព្វញ្ញុតាញ្ញាណ** លោកក៏ពោលទៅថា **សព្វញ្ញុតញ្ញាណ** ។ ពិតហើយ ធម៌ទាំងពួងខុសគ្នាដោយជាសង្ខតធម៌ជាដើម ជាគន្លងធម៌ដែលគប្បីណែនាំ មាន ៥ យ៉ាងប៉ុណ្ណោះ គឺ សង្ខារ ១ វិការ ១ លក្ខណៈ ១ និព្វាន ១ និង

បញ្ញត្តិ ១ ។

ពាក្យថា **សព្វញ្ញូ** ត្រាស់ដឹងធម៌ទាំងពួង សេចក្តីថា សព្វញ្ញូ មាន ៥ យ៉ាង គឺ ៖

**១- កមសព្វញ្ញូ** ដឹងធម៌ទាំងពួងតាមលំដាប់

**២- សកឹសព្វញ្ញូ** ដឹងធម៌ទាំងពួងក្នុងគ្រាជាមួយគ្នា

**៣- សត្តសព្វញ្ញូ** ដឹងធម៌ទាំងពួងជាប់តគ្នា

**៤- សត្តិសព្វញ្ញូ** ដឹងធម៌ទាំងពួងដោយសេចក្តីអង់អាច

**៥- ញាតសព្វញ្ញូ** ដឹងធម៌ទាំងពួងដែលដឹងហើយ

**កមសព្វញ្ញុតា** រមែងមានមិនបាន ព្រោះកាលជាទីដឹងធម៌ទាំងពួងមិនកើតឡើង តាមលំដាប់ ។

**សកឹសព្វញ្ញុតា** ក៏មានមិនបាន ព្រោះមិនមានការទទួលអារម្មណ៍ទាំងពួងបានក្នុងគ្រាជាមួយគ្នា ។

**សត្តសព្វញ្ញុតា** ក៏មានមិនបាន ព្រោះសេចក្តីកើតឡើងនៃចិត្តក្នុងអារម្មណ៍ តាមសមគួរដល់ចិត្ត មានចក្ខុវិញ្ញាណចិត្តជាដើម និងព្រោះមិនមានការប្រកបក្នុងភវង្គចិត្ត ។



**សត្តិសព្វញ្ញុតា** គប្បីមានបាន ព្រោះអាចដឹងធម៌ទាំងពួង ដោយការស្វែងរក ។

**ញាតសព្វញ្ញុតា** ក៏គប្បីមានបាន ព្រោះធម៌ទាំងពួងក្លីច្បាស់ហើយ ។

សេចក្តីថា ការដឹងធម៌ទាំងពួង មិនមានក្នុងសត្តិសព្វញ្ញុតាសូម្បីយ៉ាងនោះ រមែងមិនត្រឹមត្រូវ ។ ព្រោះលោកពោលទុកថា ៖

**អ្វី ៗ ដែលព្រះតថាគតជាម្ចាស់នោះមិនឃើញ**
**ហើយមិនមានក្នុងលោកនេះ មប្យ៉ាងទៀត អ្វី ៗ**
**ដែលមិនត្រាស់ដឹង និងមិនគួរដឹងក៏មាន , វត្ថុ**
**ណាដែលគួរណែនាំមាន ព្រះតថាគតជាម្ចាស់**
**បានដឹងធម៌នោះហើយ ព្រោះហេតុនោះ ព្រះ-**
**តថាគតជាម្ចាស់ ទើបឈ្មោះថា សមន្តចក្ខុ ។**

ដូច្នោះ **ញាតសព្វញ្ញុតា** ប៉ុណ្ណោះ រមែងត្រឹមត្រូវ ។ ក៏កាលបើដូច្នេះ សព្វញ្ញុតញ្ញាណនោះឯង រមែងមានបានដោយកិច្ច ដោយអសម្មោហៈ ដោយការសម្រេចនៃហេតុ ដោយសារៈ និងអាវជ្ជនៈ

ដោយប្រការដូច្នេះ ។ អារម្មណ៍ជាគ្រឿងរាំងញាណនោះ មិនមានជាញាណដែលទាក់ទងដោយអាវជ្ជនៈនោះឯង ដូច្នោះ ញាណទើបឈ្មោះថា **អនាវរណ** មិនមានការបិទបាំង , អនាវរណៈនោះឯងលោកហៅថា **អនាវរណញ្ញាណ** ដោយប្រការដូច្នេះ ។

ពាក្យថា **ឥមានិ តេសត្តតិ ញាណានិ** ញាណ ៧៣ ទាំងនេះ សេចក្ដីថា ញាណ ៧៣ ទាំងនេះ លោកលើកឡើងសម្ដែងដោយអំណាចនៃញាណដែលទូទៅ និងមិនទូទៅដល់ព្រះសាវកទាំងឡាយ ។

ពាក្យថា **ឥមេសំ តេសត្តតិយា ញាណំ** នៃញាណទាំង ៧៣ នេះ សេចក្ដីថា នៃញាណទាំងឡាយ ៧៣ ញាណទាំងនេះដែលលោកពោលហើយតាំងពីដើម ។ ក៏ពាក្យនេះ ជាឆដ្ឋីវិភត្តិចុះក្នុងអត្ថថា ជាក្រុម ។ បាឋៈថា **តេសត្តតីនំ** ដូច្នេះក៏មាន ។ កាលបើពោលថា **តេសត្តតិយា** គប្បីជ្រាបថាជាពហុវចនៈក្នុងរូបឯកវចនៈ ។

ពាក្យថា **សត្តសដ្ឋិ ញាណានិ** ញាណ ៦៧ បានដល់ ញាណ ៦៧ រាប់តាំងពីដើមមក ។

ពាក្យថា **សាវកសាធារណានិ** ទូទៅដល់ព្រះសាវក សេចក្ដីថា ឈ្មោះថា **សាវក** ព្រោះកើតដោយជាតិនៃអរិយៈក្នុងទីបំផុតនៃ



ការស្ដាប់ , ឈ្មោះថា **សាធារណ** ព្រោះការទ្រទ្រង់ទុក មានដល់ញាណទាំងនោះ , ញាណ ៦៧ នោះ ជាញាណដែលទូទៅដល់ព្រះសាវករបស់ព្រះតថាគតជាម្ចាស់ទាំងឡាយ ឈ្មោះថា **សាវក-សាធារណ** ទូទៅដល់ព្រះសាវកទាំងឡាយ ។

ពាក្យថា **ឆ ញាណានិ** ញាណ ៦ បានដល់ ៦ ញាណដែលលោកលើកឡើងសម្ដែងក្នុងទីបំផុត ។

ពាក្យថា **អសាធារណានិ សាវកេហិ** មិនទូទៅដល់ព្រះសាវក សេចក្ដីថា ញាណទាំងឡាយ ៦ ញាណ ចំពោះតែព្រះតថាគតទាំងឡាយ មិនទូទៅដល់ព្រះសាវកទាំងឡាយ ដូច្នេះឯង ។

## អដ្ឋកថា ញាណកថាមាតិកុទ្ទេស

## ក្នុងអដ្ឋកថាបដិសម្ភិទាមគ្គ ឈ្មោះសទ្ធម្មបកាសនី

**( ចប់ )**

# សទ្ធម្មប្បកាសិនី អដ្ឋកថាខុទ្ទកនិកាយ

# បដិសម្ភិទាមគ្គ

## ១-សុតមយញ្ញាណកថា

### អដ្ឋកថាវិសជ្ជនុទ្ទេស

១- ឥឡូវនេះ លោកប្រារព្ធនិទ្ទេសវារមានអាទិថា **កថំ សោតាវធានេ បញ្ញា សុតមយេ ញាណំ** បញ្ញាក្នុងការមានស្មារតីចាំធម៌ដែលបានស្តាប់មកហើយ ឈ្មោះថា **សុតមយញ្ញាណ** គឺ យ៉ាងណា ? យ៉ាងនេះ ដើម្បីសម្តែងធម៌ទាំងឡាយដែលរួបរួមទុកដោយឧទ្ទេស តាមដែលបានលើកឡើងហើយជាប្រភេទ ៗ ទៅ ។

ក្នុងនិទ្ទេសវារៈនោះពាក្យណាដែលលោកបានពោលទុក ថា **សោតាវធានេ បញ្ញា សុតមយេ ញាណំ** បញ្ញាក្នុងការមានស្មារតីចាំធម៌ដែលបានស្តាប់មកហើយ ឈ្មោះថា **សុតមយញ្ញាណ** ដូច្នេះ ពាក្យនេះ ជាពាក្យសួរដើម្បីនឹងពោលឆ្លើយ



ដោយខ្លួនឯងថា សុតមយញ្ញាណនោះ យ៉ាងណា ?

ពិតហើយ បុច្ឆា ពាក្យសួរមាន ៥ យ៉ាង គឺ ៖

**១-អទិដ្ឋជោតនាបុច្ឆ** សួរដើម្បីប្រៀបធៀបសេចក្តី ដែលនៅមិនទាន់ឃើញ ។

**២- ទិដ្ឋទិដសំសន្ទនាបុច្ឆ** សួរដើម្បីនឹងប្រៀបធៀបវត្ថុ ដែលឃើញហើយ ។

**៣- វិមតិច្ឆេទនាបុច្ឆា** សួរដើម្បីកាត់សេចក្តីសង្ស័យ ។

**៤- អនុមតិបុច្ឆា** សួរដើម្បីការជាក់ច្បាស់ ។

**៥- កថេតុកម្យតាបុច្ឆា** សួរដើម្បីនឹងឆ្លើយខ្លួនឯង ។

ការខុសគ្នានៃបុច្ឆា ៥ យ៉ាងនោះ មានដូចតទៅនេះ ៖

អទិដ្ឋជោតនាបុច្ឆា ដើម្បីនឹងដឹង ដើម្បីនឹងឃើញ ដើម្បីនឹងប្រៀបធៀប ដើម្បីនឹងគិតសញ្ជឹង ដើម្បីនឹងយល់ច្បាស់ ដើម្បីនឹងបង្ហើបឲ្យដឹងនូវលក្ខណៈប្រក្រតីដែលខ្លួននៅមិនធ្លាប់ដឹង មិនធ្លាប់ឃើញ នៅមិនធ្លាប់ប្រៀបធៀប នៅមិនធ្លាប់សញ្ជឹងគិត នៅមិនធ្លាប់យល់ច្បាស់ នៅមិនធ្លាប់បង្ហើបឲ្យដឹង បុច្ឆានេះ ឈ្មោះថា **អទិដ្ឋជោតនាបុច្ឆា** ។

**ទិដ្ឋសំសន្ទនាបុច្ឆា** ដូចម្ដេច ? គឺ បុគ្គលនោះ រមែងសួរបញ្ហា ដល់លក្ខណៈតាមប្រក្រតី ដែលខ្លួនធ្លាប់បានដឹងហើយ ធ្លាប់ឃើញហើយ ធ្លាប់ប្រៀបធៀបហើយ ធ្លាប់សញ្ជឹងគិតហើយ ធ្លាប់យល់ច្បាស់ហើយ ធ្លាប់បង្ហើបឲ្យដឹងហើយ ដើម្បីប្រៀបធៀបជាមួយបណ្ឌិតដទៃ បុច្ឆានេះឈ្មោះថា **ទិដ្ឋសំសន្ទនាបុច្ឆា** ។

**វិមតិច្ឆេទនាបុច្ឆា** ដូចម្ដេច ? បុគ្គលនោះ តាមធម្មតាជាអ្នកបង្អោនទៅកាន់សេចក្ដីសង្ស័យ ជាអ្នកបង្អោនទៅកាន់សេចក្ដីងឿង-ឆ្ងល់ ជាអ្នកបង្អោនទៅកាន់ការឃើញដែលដូចជាផ្លូវបំបែកជា ២ រមែងសួរបញ្ហាដើម្បីកាត់ការសង្ស័យថា យ៉ាងនោះឬហ្ន៎ ? ឬមិនមែនយ៉ាងនោះ ? អ្វីហ្ន៎ ? យ៉ាងណាហ្ន៎ ? ដូច្នេះ នេះឈ្មោះថា វិមតិច្ឆេទនាបុច្ឆា ។

**អនុមតិបុច្ឆា** គឺ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់សួរការចេះដឹងរបស់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់រូបនោះ ទៀង ឬមិនទៀង ? កាលបើភិក្ខុទាំងឡាយ ក្រាបទូលថា មិនទៀងទេព្រះអង្គ , កាលត្រាស់សួរតទៅទៀតថា របស់ណាមិនទៀង របស់នោះជាទុក្ខឬជាសុខ ? កាលបើភិក្ខុទាំងឡាយ ក្រាបទូល



ថាជាទុក្ខព្រះអង្គ , ក៏ត្រាស់សួរបន្តទៅទៀតថា របស់ណាមិនទៀងជាទុក្ខ មានការប្រែប្រួលជាធម្មតា គួរលះ ឬគួរ នឹងប្រកាន់ គឺយល់ឃើញថា នោះជារបស់យើង នោះជាយើង នោះជាអត្តាតួខ្លួនរបស់យើង ? ភិក្ខុទាំងឡាយក្រាបទូលថា សេចក្ដីនេះមិនសមគួរឡើយព្រះអង្គ យ៉ាងនេះ ឈ្មោះថា **អនុមតិបុច្ឆា** ។

**កថេតុកម្យតាបុច្ឆា** ដូចម្ដេច ? គឺ ព្រះមានព្រះភាគជាម្ចាស់ត្រាស់សួរដល់ភិក្ខុទាំងឡាយ ព្រោះមានបំណងនឹងឆ្លើយដោយព្រះអង្គឯងថា ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានទាំងនេះមាន ៤ ។ សតិប្ប-ដ្ឋាន ៤ ដូចម្ដេច ? យ៉ាងនេះ ឈ្មោះថា **កថេតុកម្យតាបុច្ឆា** ។

ក្នុងបណ្ដាបុច្ឆាទាំង ៥ នោះ បុច្ឆានេះ បណ្ឌិតគប្បីជ្រាបថា ជាកថេតុកម្យតាបុច្ឆា របស់ព្រះសារីបុត្តត្ថេរ ។

ឥឡូវនេះ លោកបានពោលវិសជ្ជនុទ្ទេស ឧទ្ទេសតាំងឡើងដើម្បីនឹងឆ្លើយ ១៦ ប្រការ មានអាទិ៍ថា បញ្ញាជាគ្រឿងចាំធម៌ដែលបានស្ដាប់មកហើយ គឺ គ្រឿងដឹងច្បាស់នូវធម៌ ដែលស្ដាប់មកហើយនោះថា ធម៌ទាំងឡាយនេះគួរដឹងច្បាស់ ដូច្នេះ ឈ្មោះថា **សុតមយ-ញាណ** តាមកថេតុម្យតាបុច្ឆា ដែលលើកឡើងតាំងទុកក្នុងខាងដើម ។

បណ្ដាពាក្យទាំងនោះ **បាឋសេស** គឺ ព្រះបាលីថា **ទេសយន្តស្ស** របស់អ្នកសម្ដែងរបស់ពាក្យថា **ឥមេ ធម្មា អភិញ្ញេយ្យា** ធម៌ទាំង-ឡាយទាំងនេះ គួរដឹងដ៏ក្រៃលែង ។ អធិប្បាយថា **សុត** ការដឹងតាមដែលចាំធម៌បានស្ដាប់មកហើយ ឈ្មោះថា **សោតាវធាន** តាមន័យដែលបានពោលទុកហើយក្នុងពេលមុនរបស់ព្រះសាស្ដា ឬរបស់មិត្រព្រហ្មចារ្យអ្នកគួរគោរព សម្ដែងនូវធម៌ថា ធម៌ទាំងឡាយនេះ ដែលព្រះយោគាវចរគួរដឹងដ៏ក្រៃលែងយ៉ាងនេះ បញ្ញាជាគ្រឿងដឹង **សោតា-វធានសោតាវធា** នោះ គឺ បញ្ញាជាគ្រឿងដឹងសុតៈនោះ បានដល់បញ្ញាធ្វើការកំណត់ ដឹងនូវបរិយាយ ឈ្មោះថា **សុតមយញ្ញាណ** ។

ពាក្យថា **តំបជានទា** ជាគ្រឿងដឹងនូវសុតៈនោះ ជាឆដ្ឋីតប្បុ-រិសសមាស វិគ្រោះថា **តស្ស បជានទា** ជាគ្រឿងដឹងនូវសុតៈនោះ ។ម្យ៉ាងទៀត ជាទុតិយាវិភត្តិដោយអំណាចនៃវិភត្តិវិបល្លាសថា **តំ បជានទា** យ៉ាងនេះ ។

ក៏ពាក្យថា **អភិញ្ញេយ្យា** គួរដឹងក្រៃលែង សេចក្ដីថា គួរដឹងដោយអំណាចនៃការដឹងនូវសភាវៈលក្ខណៈ គឺ ដោយអាការនៃមហាកុសលញាណសម្បយុត្តចិត្ត ។



ពាក្យថា **បរិញ្ញេយ្យាបរិញ្ញេយ្យ** គួរកំណត់ដឹង សេចក្ដីថា គួរយល់ដឹងដោយអំណាចនៃការដឹងសាមញ្ញលក្ខណៈ និងដោយអំណាចនៃការញ៉ាំងកិច្ចឲ្យសម្រេច ។

ពាក្យថា **ភាវេតព្វា** គួរអប់រំ សេចក្ដីថា គួរចម្រើន ។

ពាក្យថា **សច្ឆិកាតព្វ** គួរធ្វើឲ្យជាក់ច្បាស់ សេចក្ដីថា គួរធ្វើឲ្យប្រចក្ស ។ ក៏ការធ្វើឲ្យដឹងមាន ២ យ៉ាង គឺ ការធ្វើឲ្យជាក់ច្បាស់ដោយការបានចំពោះ ១ , ការធ្វើឲ្យជាក់ច្បាស់ដោយការធ្វើឲ្យជាអារម្មណ៍ ១ ។

ធម៌ទាំងឡាយពួកណា ចាត់ចូលជាផ្នែកវិនាស ពោល គឺ ការប្រព្រឹត្តទៅក្នុងផ្នែកនៃភាពវិនាស ដោយអំណាចការកម្រើកឡើងនូវធម៌ដែលជាសត្រូវ ដូច្នោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **ហានភាគិយា** ជាចំណែកនៃសេចក្ដីវិនាស ។ ធម៌ទាំងឡាយពួកណា ចាត់ចូលក្នុងផ្នែកតាំងនៅ ពោលគឺ តាំងនៅដោយអំណាចនៃការតាំងមាំរបស់សតិ តាមសមគួរ ដល់ធម៌នោះ ដូច្នោះ ធម៌ទាំងឡាយទាំងនោះ ទើបឈ្មោះថា **ឋិតិភាគិយា** ដែលជាចំណែកនៃការតាំងនៅ ។

ធម៌ទាំងឡាយពួកណា ចាត់ចូលក្នុងផ្នែកគុណវិសេស ដោយអំណាចនៃការសម្រេចគុណវិសេសខាងលើ ដូច្នោះ ធម៌ទាំងឡាយទាំងនោះ ទើបឈ្មោះថា **វិសេសភាគិយា** ដែលជាចំណែកនៃគុណវិសេស ។

ធម៌ណា រមែងជ្រៀតចូល រមែងកម្ចាត់ កងលោភៈ ទោសៈ មោហៈ ដែលមិនធ្លាប់ជ្រៀតចូល មិនធ្លាប់កម្ចាត់ ដូច្នោះ ធម៌នោះទើបឈ្មោះថា **និព្វេធ** អ្នកកម្ចាត់ គឺ អរិយមគ្គ ធម៌ទាំងឡាយណា រមែងចាត់ចូលក្នុងផ្នែកទម្លាយនោះ ដោយអំណាចនៃការតាំងឡើងនៃសញ្ញាមនសិការៈ ដែលសហគតដោយនិព្វិទា សេចក្ដីនឿយណាយ ដូច្នោះ ធម៌ទាំងឡាយនោះ ទើបឈ្មោះថា **និព្វេធ-ភាគិយា** ដែលលជាចំណែកនៃសេចក្ដីនឿយណាយ ។

ពាក្យថា **សព្វេ សង្ខារា** សង្ខារទាំងពួង បានដល់ ធម៌ដែលប្រព្រឹត្តទៅដោយបច្ច័យទាំងពួង ។ ក៏ធម៌ទាំងនោះ ឈ្មោះថា **សង្ខតធម៌** ធម៌មានបច្ច័យតាក់តែងហើយ ។ ធម៌ពួកណាដែលបច្ច័យទាំងឡាយតាក់តែងឡើង ដូច្នោះ ធម៌ទាំងឡាយនោះ ទើប



ឈ្មោះថា **សង្ខារ** , សង្ខារទាំងនោះឯង លោកពោលឲ្យប្លែកចេញទៅថា **សង្ខតា** ព្រោះត្រូវបច្ច័យទាំងឡាយសាងឡើង ។ រូបធម៌និងអរូបធម៌ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ក្នុងអដ្ឋកថាលោកពោលថា **អភិសង្ខតសង្ខារ** ព្រោះកើតពីកម្ម ។ សូម្បីអភិសង្ខតសង្ខារទាំងនោះ ក៏រមែងសង្គ្រោះចូលក្នុង **សង្ខតសង្ខារ** ដូចក្នុងពាក្យជាដើមថា **អនិច្ចា វត សង្ខារា** សង្ខារទាំងឡាយមិនទៀងហ្ន៎យ៉ាងនេះ ។

សង្ខារទាំងឡាយ អង្គធម៌ បានដល់ កុសលាកុសល-ចេតនាក្នុងភូមិ ៣ មានអវិជ្ជាជាបច្ច័យ មកហើយក្នុងពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ បុរសនេះធ្លាក់ក្នុងអំណាចអវិជ្ជារមែងតាក់តែងសង្ខារដែលជាបុណ្យ និងបាប ដូច្នេះ ឈ្មោះថា **អភិសង្ខរណកសង្ខារ** ។

សេចក្ដីព្យាយាម ដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងផ្លូវចិត្តមកក្នុងពាក្យថា **គតិអភិសង្ខារ** មានទៅប៉ុនណា ក៏ទៅប៉ុណ្ណោះដូចជាសត្រូវទ្រឹង តាំងនៅដូច្នេះ ឈ្មោះថា **បយោគាភិសង្ខារ** ។

វិតក្កវិចារៈ តាក់តែងវាចា មកហើយក្នុងពាក្យជាដើមថា

ម្នាលវិសាខៈឧបាសកមានអាយុ កាលបើភិក្ខុចូលសញ្ញាវេទយិតនិរោធ វចីសង្ខាររលត់មុន តពីនោះកាយសង្ខាររលត់ តទៅចិត្តសង្ខារទើបរលត់ ដូច្នេះ ឈ្មោះថា **វចីសង្ខារ** ។

អស្សាសបស្សាសៈ ខ្យល់ដកដង្ហើមចូលចេញ រមែងតាក់តែងកាយ ដូច្នោះទើបឈ្មោះថា **កាយសង្ខារ** ។

សញ្ញាផង វេទនាផង រមែងតាក់តែងចិត្ត ដូច្នោះទើបឈ្មោះថា **ចិត្តសង្ខារ** ។

តែក្នុងទីនេះ លោកបំណងយក **សង្ខតសង្ខារ** ។

ឈ្មោះថា **អនិច្ចា** មិនទៀង ព្រោះអត្ថថា មានហើយត្រឡប់មិនមាន ។ ឈ្មោះថា **ទុក្ខា** ជាទុក្ខ ព្រោះអត្ថថា បៀតបៀន ។

ពាក្យថា **សព្វេ ធម្មា** ធម៌ទាំងពួង លោកពោលរួមយកព្រះនិព្វានចូលទុកដែរ ។ ឈ្មោះថា **អនត្តា** ព្រោះអត្ថថា មិនប្រព្រឹត្តទៅក្នុងអំណាច ។

កាលបើនឹងពោលថា **ទុក្ខសមុទយោ ទុក្ខនិរោធោ** ដូច្នេះ លោកធ្វើឲ្យជាលិង្គវិបល្លាសទៅថា **ទុក្ខសមុទយំ ទុក្ខនិរោធំ**



ដូច្នេះ ដូចក្នុងពាក្យជាដើមថា **ឥទំ ទុក្ខំ អរិយសច្ចំ** ដូច្នេះ តែព្រះអរិយៈជាម្ចាស់ទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម រមែងចាក់ធ្លុះ ដូច្នោះ លោកទើបពោលថា **អរិយសច្ចានិ** អរិយសច្ចៈទាំងឡាយ យ៉ាងនេះ ។

ឈ្មោះថា អរិយសច្ចៈ ព្រោះជាសច្ចៈរបស់ព្រះអរិយៈជាម្ចាស់ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ ទាំងនេះ ។បេ។
ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ ទាំងនេះ ព្រះអរិយៈទាំងឡាយរមែងចាក់ធ្លុះ ព្រោះដូច្នោះទើបហៅថា អរិយសច្ច ។

ឈ្មោះថា **អរិយសច្ច** ព្រោះសម្រេចភាពជាអរិយៈ ព្រោះបានត្រាស់ដឹងព្រមនូវអរិយសច្ចៈទាំងឡាយនោះ ដូចដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ៖

ព្រះតថាគតជាព្រះអរិយៈក្នុងលោក ព្រមទាំង
ទេវលោក ។បេ។ ព្រមទាំងទេវតា និងមនុស្ស
ព្រោះដូច្នោះ ទើបហៅថា អរិយសច្ចៈ ។

ដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ៖

និងឈ្មោះថា អរិយសច្ចៈ ព្រោះជាសច្ចៈដ៏ប្រសើរ ដូចដែលព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា ៖

**តថាគត អរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ព្រោះត្រាស់**
**ដឹងព្រមចំពោះនូវអរិយសច្ច ៤ ទាំងនេះ តាមការ**
**ពិត ព្រោះដូច្នោះបណ្ឌិតទើបហៅថា អរិយៈ ។**

ពាក្យថា **អរិយានិ** ដ៏ប្រសើរ គឺ មិនខុសឃ្លៀងឃ្លាត , អធិប្បាយថា មិនបោកបញ្ឆោត ។ ដូចព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

**ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ ទាំងនេះ**
**ជារបស់ពិត មិនប្រែប្រួល មិនជាយ៉ាងដទៃ**
**ព្រោះដូច្នោះ ទើបហៅថា អរិយសច្ច ។**

ពាក្យថា **សច្ចានិ** សច្ចៈទាំងឡាយ សេចក្តីថា បើសិននឹងសួរថា អ្វីជាអត្ថរបស់សច្ចៈ ? ក៏មានពាក្យឆ្លើយថា ធម៌ណាមិនវិបរិតដូចមាយា ជាធម៌ដែលធ្វើឲ្យយល់ខុស ដូចថ្ងៃបណ្តើរកូន ឬដូច .....? រកសភាវៈមិនបាន រមែងប្រាកដដល់អ្នកពិចារណា



ដោយបញ្ញាចក្ខុ ធម៌នោះជាគោចររបស់អរិយញ្ញាណ ដោយប្រការនៃ **សន្តិ** សេចក្តីស្ងប់ និង **និយ្យាន** ការនាំចេញពីដែនកើតនៃសេចក្តីលំបាក និងដោយសេចក្តីពិត ដែលមិនវិបរិត សេចក្តីពិត គឺសេចក្តីប្រាកដ ភាពមិនវិបរិត គប្បីជ្រាបថា ជាអត្ថរបស់សច្ចៈ ដូចលក្ខណៈនៃភ្លើង និងដូចប្រក្រតីរបស់លោក ។ សេចក្តីពិស្តារដូចព្រះដ៏មានព្រះភាគ ត្រាស់ទុកថា ៖

**ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះហើយ**
**អ្នកទាំងឡាយ គប្បីធ្វើនូវសេចក្តីព្យាយាម**
**ដើម្បីដឹងតាមពិតថា នេះទុក្ខ ជារបស់ពិត**
**ប្រាកដ មិនប្រែប្រួល មិនជាយ៉ាងដទៃ ។**

មយ៉ាងទៀត ទុក្ខជារបស់ធ្វើឲ្យលំបាក ក្រៅអំពីទុក្ខ គ្មានអ្វីធ្វើឲ្យលំបាកទេ របស់នេះទើបហៅថា សច្ចៈ ព្រោះនិយាមថាធ្វើឲ្យលំបាក វៀរពីរបស់នោះហើយ ទុក្ខមិនមានពីរបស់ដទៃដោយហេតុនៃរបស់នោះ ជាហេតុនៃទុក្ខ ដោយជាក់លាក់ ទើបហៅរបស់នោះ **វិសត្តិការ** គឺ តណ្ហា ថាជាសច្ចៈ , សេចក្តីស្ងប់ដទៃពីព្រះនិព្វានមិនមាន ។ ព្រោះហេតុដូច្នោះ សេចក្តីទុក្ខ

ទើបជារបស់ពិត ដោយហេតុនៃព្រះនិព្វាននោះ ជាការរំលត់ទុក្ខយ៉ាងជាក់លាក់ ។ ផ្លូវនាំចេញ ក្រៅពីអរិយមគ្គមិនមាន ព្រោះដូច្នោះ អរិយមគ្គ ទើបជាការពិត ព្រោះជាការនាំចេញពិតប្រាកដ , ព្រោះហេតុនោះ បណ្ឌិតទាំងឡាយ ទើបពោលថា តាមសេចក្តីពិតដែលមិនវិបល្លាសពីការពិតក្នុងធម៌សូម្បីទាំង ៤ មានទុក្ខជាដើមជាអត្ថនៃសច្ចៈដ៏ពិសេស យ៉ាងនេះ ។ ក៏សច្ចៈស័ព្ទនេះ រមែងប្រាកដក្នុងអត្ថជាអនេក គឺ៖

រមែងប្រាកដក្នុងអត្ថថា **វាចាសច្ច** ដូចមានក្នុងពាក្យជាដើមថា បុគ្គលគប្បីពោលការពិត មិនគប្បីក្រោធយ៉ាងនេះ ។

រមែងប្រាកដក្នុងអត្ថថា **វិរតិសច្ច** បានក្នុងពាក្យជាដើមថា សមណព្រាហ្មណ៍ទាំងឡាយតាំងនៅហើយក្នុងសច្ចៈ យ៉ាងនេះ ។

រមែងប្រាកដក្នុងអត្ថថា **ទិដ្ឋិសច្ច** បានក្នុងពាក្យជាដើមថា ពួកមានទិដ្ឋិខុសគ្នា រមែងពោលសច្ចៈថា របស់នេះជារបស់ពិត ពួកនោះនឹងហៅថា ជាអ្នកឆ្លាតដូចគ្នាទាំងអស់ ឬយ៉ាងណា ? យ៉ាងនេះ ។

រមែងប្រាកដក្នុងអត្ថថា **បរមត្ថសច្ច** គឺ និព្វាន និងមគ្គ



ក្នុងពាក្យជាដើមថា សច្ចៈមានត្រឹមតែមយ៉ាង សច្ចៈទី ២ មិនមាន ដែលជាហេតុធ្វើឲ្យដឹង សន្ទនាគ្នាបាន ។

រមែងប្រាកដក្នុង **អរិយសច្ច** ក្នុងពាក្យជាដើមថា សច្ចៈ ៤ ជាកុសលប៉ុន្មាន ? ជាអកុសលប៉ុន្មាន ? យ៉ាងនេះ ។ សូម្បីក្នុងទីនេះ **សច្ច** សព្ទនេះ រមែងប្រព្រឹត្តទៅក្នុងអត្ថថា **អរិយសច្ច** ដូច្នេះឯង ។

## អដ្ឋកថា វណ្ណនាវិសជ្ជនុទ្ទេស

## ដែលលោកសង្គ្រោះហើយក្នុងនិទ្ទេសវារៈ

( ចប់ )

## ២_ អដ្ឋកថា អភិញ្ញេយ្យនិទ្ទេស

### ស្ដីពីអភិញ្ញេយ្យធម៌

ឥឡូវនេះ ព្រះធម្មសេនាបតីសារីបុត្របានសម្ដែង និទ្ទេសវារៈ មានជាអាទិ៍ថា **កថំ ឥមេ ធម្មា អភិញ្ញេយ្យា** ធម៌ទាំងឡាយនេះ គួរដឹងដ៏ក្រៃលែង យ៉ាងណា ? ដូច្នេះ ក៏ដើម្បីនឹងសម្ដែងធម៌ដែលលោករួបរួមទុកក្នុងវិសជ្ជនុទ្ទេសជាប្រភេទ ៗ ទៅ ។

ក្នុងពាក្យទាំងនោះ ព្រះធម្មសេនាបតីសារីបុត្របានលើកយកមកវិសជ្ជនាមួយប្រការ ១០ ៗ តាំងពីដើមដោយអំណាច នៃឯកនិទ្ទេសជាដើមទៅ ក្នុងពាក្យទាំង ៥ មានពាក្យសម្ដែងធម៌ដែលគួរដឹងដ៏ក្រៃលែងជាដើម ឡើងសម្ដែងប្រៀបធៀបដោយបរិយាយនៃទសុត្តរសូត្រ ។

## អដ្ឋកថា ឯកនិទ្ទេស

### ស្ដីពីអាហារ

បណ្ដាពាក្យទាំង ៥ នោះ ក្នុងដើមដំបូង ពាក្យថា



**សព្វេ សត្តា** សត្វទាំងពួង ក្នុងអភិញ្ញេយ្យនិទ្ទេស បានដល់សត្វទាំងឡាយទាំងពួង គឺ ក្នុងកាមភពជាដើម និងក្នុងឯកវោ-ការភពជាដើម ។

ពាក្យថា **អាហារដ្ឋិតិកា** មានអាហារជាទីតាំង ពាក្យថា ការស្ថិតនៅរបស់សត្វទាំងឡាយទាំងនោះ ព្រោះអាហារ ដូច្នោះ ទើបឈ្មោះថា **អាហារដ្ឋិតិកា** មានអាហារជាទីតាំង ។

ក៏ក្នុងពាក្យថា **ឋិតិ** ការស្ថិតនៅនេះ លោកប្រាថ្នាយកការមាននៅក្នុងខណៈរបស់ខ្លួន ។

ឈ្មោះថា **អាហារ** ព្រោះជាហេតុនៃការស្ថិតនៅ នៃសត្វទាំងឡាយ ជាធម៌មួយ ជាធម៌គួរដឹងដោយបញ្ញាដ៏ក្រៃលែង ។ កាលបើដឹងបច្ច័យហើយ ក៏ជាការដឹងបច្ចយុប្បន្ន ធម៌ដែលកើតពីបច្ច័យ ព្រោះបច្ច័យ និងបច្ចយុប្បន្ន ទាំង ២ នោះ មានការអាស្រ័យគ្នានឹងគ្នា **ញាតប្បរិញ្ញា** ដែលលោកពោលហើយ ដោយពាក្យនោះ ។

សួរថា ក៏កាលបើយ៉ាងនោះ ពាក្យណាដែលលោកពោលទុកថា **អសញ្ញសត្តាទេវា អសញ្ញសត្តាព្រហ្ម** មិនមានហេតុ មិន

មានអាហារ មិនមានផស្សៈ យ៉ាងនេះជាដើម ពាក្យនោះនឹងមិនខុសទៅទេឬ ?

ឆ្លើយថា ពាក្យដែលលោកពោលនោះមិនខុស ព្រោះថា **ឈាន** ជាអាហាររបស់អសញ្ញសត្តាទេវតាទាំងនោះ ។

សួរថា សូម្បីយ៉ាងនោះ ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ អាហារទាំងឡាយ ៤ ទាំងនេះ ដើម្បីការតាំងនៅនៃសត្វ អ្នកកើតហើយ ដើម្បីអនុគ្រោះដល់ពួកសម្ភវេសី ។

អាហារ ៤ ដូចម្តេច ? គឺ កវឡីង្ការាហារ អាហារ គឺ បាយជាអាហារគ្រោតគ្រាត ឬល្អិត , ផស្សាហារ គឺ ផស្សៈ ជាទី ២ , មនោសញ្ចេតនាហារ អាហារ គឺ ចេតនាជាទី ៣ , វិញ្ញាណាហារ គឺ វិញ្ញាណជាទី ៤ យ៉ាងនេះ ក៏រមែងខុស ។ ព្រោះក្នុងព្រះសូត្រត្រាស់ទុកដោយនិប្បរិយាយថា ធម៌ទាំងឡាយ មានអាហារជាលក្ខណៈ ឈ្មោះថា អាហារ តែក្នុងទីនេះត្រាស់ដោយបរិយាយថា បច្ច័យ ឈ្មោះថា អាហារ ។

ព្រោះសង្ខតធម៌ទាំងពួងបានបច្ច័យ រមែងគួរ បច្ច័យនោះរមែងឲ្យផលញាណកើតឡើង ឈ្មោះថា រមែងនាំមកនូវផលនោះ ៗ



ព្រោះដូច្នោះ ទើបលោកហៅថា **អាហារ** ។ ដោយហេតុនោះឯង ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា៖

> **ម្នាលភិក្ខុទាំងឡាយ សូម្បីអវិជ្ជាក៏តថាគតពោលថាមានអាហារ មិនបានពោលថា មិនមានអាហារ ម្នាលភិក្ខុទាំងឡាយ ក៏អ្វីទៅជាអាហាររបស់អវិជ្ជា គួរពោលថា និវរណៈ ៥ ជាអាហាររបស់អវិជ្ជា ។ ម្នាលភិក្ខុទាំងឡាយ សូម្បីនិវរណៈ ៥ តថាគតក៏ពោលថា មានអាហារ មិនបានពោលថា មិនមានអាហារ , ម្នាលភិក្ខុទាំងឡាយ ក៏អ្វីទៅជាអាហាររបស់និវរណធម៌ ៥ ។ល។ គួរពោលថា អយោនិសោមនសិការៈ ជាអាហាររបស់និវរណៈ ដូច្នេះជាដើម ។**

អាហារដូចពោលហើយនេះ ប្រាថ្នាហើយក្នុងទីនេះ កាលបើកាន់យកអាហារ គឺ បច្ច័យ អាហារទាំងដោយបរិយាយ និងអាហារទាំងដោយនិប្បបរិយាយ ក៏ជាការកាន់យកទាំងអស់ ។

ក្នុងពាក្យនោះ **បច្ចយាហារ** រមែងបានក្នុងអសញ្ញីភព ។

ពិតហើយកាលបើព្រះពុទ្ធជាម្ចាស់ ស្តេចនៅមិនបានឧប្បត្តិឡើង ពួកដែលបួសជា តិរត្ថីយ៍ ធ្វើបរិកម្មក្នុងវាយោកសិណ ញុំាង ចតុត្ថជ្ឈានឲ្យកើតឡើង ចេញពីឈាននោះហើយ ក៏ឃើញថា ចិត្តនេះ ជារបស់គួរតិះដៀលច្រើន , ការមិនមានចិត្តសោះឡើយ ជាការល្អ ។ ព្រោះទុក្ខ មានការសម្លាប់ និងចងចាំជាដើម រមែង កើតឡើងព្រោះអាស្រ័យចិត្ត , កាលបើមិនមានចិត្ត ទុក្ខនោះ ក៏រមែងមិនមាន ព្រោះដូច្នោះ ទើបកើតសេចក្តីត្រេកអរ ពេញចិត្ត ឈានមិនដាច់ ធ្វើកាលកិរិយាហើយ ក៏បានកើតក្នុងអសញ្ញីភព ។ អ្នកណាតាំងនៅក្នុងឥរិយាបថណាក្នុងមនុស្ស អ្នកនោះ ក៏រមែង ស្ថិតនៅក្នុងឥរិយាបថនោះរហូត ៥០០កប្ប ។ ដូចជាដេក អង្គុយ ឬឈរ រហូតអស់កាលយូរមានប្រមាណត្រឹមនោះ ។ ក៏បច្ចយាហារ រមែងបានដល់សត្វទាំងឡាយទាំងនោះ ។

ព្រោះសត្វទាំងនោះចម្រើនឈានណាហើយកើត ឈាននោះ ក៏ជាបច្ច័យដល់សត្វទាំងឡាយនោះ ដូចកូនព្រួញដែលបាញ់ដោយ កម្លាំងនៃខ្សែធ្នូ កម្លាំងខ្សែធ្នូមានកម្លាំងត្រឹមណា ក៏ទៅបានត្រឹមនោះ យ៉ាងណា កម្លាំងឈានបច្ច័យមានប្រមាណត្រឹមណា ក៏ស្ថិតនៅ



ត្រឹមនោះ ដូច្នោះ ។ កាលបើកម្លាំងឈានបច្ច័យអស់ហើយ សត្វ ទាំងនោះក៏ចុតិ ដូចកូនព្រួញដែលមានកម្លាំងអស់ហើយ ដូច្នោះ ។

ចំណែកសត្វពួកណា ជាអ្នកកើតក្នុងនរក សត្វទាំងនោះ លោកពោលថា មិនជាអ្នកមានជីវិតនៅដោយសេចក្តីព្យាយាម មិនជាអ្នកមានជីវិតនៅដោយផលបុណ្យឡើយ , អ្វីជាអាហារ របស់សត្វទាំងនោះ ? កម្មនោះឯងហើយ ជាអាហាររបស់សត្វ ទាំងនោះ ដូច្នេះ ។

សួរថា អាហារមាន ៥ យ៉ាងឬ ? ឆ្លើយថា ពាក្យនេះ មិនគប្បីថាមាន ៥ ឬមិនមែន ៥ យ៉ាងនេះ ។ វាទះថា បច្ច័យ ជាអាហារ លោកពោលទុកហើយមិនមែនឬ ? ព្រោះហេតុនោះ សត្វទាំងនោះ នៅក្នុងនរកដោយកម្មណា , កម្មនោះឯងជាអាហារ របស់សត្វទាំងនោះ ព្រោះជាបច្ច័យនៃការរស់នៅ ។ ពាក្យនេះ លោកពោលសំដៅយកពាក្យណា ពាក្យនោះ ព្រះមានព្រះភាគជា ម្ចាស់ត្រាស់ទុកហើយថាៈ

**កាលបាបកម្មមិនទាន់អស់ ដរាបណា**

**សត្វនរកក៏មិនទាន់ស្លាប់ដរាបនោះ ។**

ព្រោះដូច្នោះ ពាក្យថា **អាហារដ្ឋិតិកា** មានអាហារជាទីតាំង ទើបមានសេចក្តីថា មានបច្ច័យជាទីតាំង ។ ក៏នៅក្នុងពាក្យនេះថា ព្រោះប្រារព្ធកវឡីង្ការាហារ មិនគប្បីពោលឲ្យខុសគ្នា ព្រោះថា សូម្បីទឹកមាត់ដែលកើតក្នុងមាត់ ក៏ឲ្យសម្រេចកិច្ចជាអាហារដល់សត្វទាំងនោះបាន ។ ពិតហើយ ទឹកមាត់ក៏ជាបច្ច័យដល់ពួកសត្វកើតក្នុងនរកដែលសោយទុក្ខវេទនា និងដល់ពួកអ្នកកើតក្នុងស្ថានសួគ៌ដែលសោយសុខវេទនា ។

ក្នុងកាមភពមានអាហារ ៤ ដោយត្រង់ , ក្នុងរូបភព និងអរូបភព វៀរអសញ្ញីភពចេញ ក្រៅពីនោះមានអាហារ ៣ , អសញ្ញីភព និងភពក្រៅពីនោះ មានបច្ចយាហារ ដោយប្រការដូច្នេះ ព្រោះហេតុនោះ សត្វទាំងឡាយទាំងពួងជាអ្នកមានអាហារជាទីតាំង ដោយអាហារដូចពោលមកហើយនេះ ។

ពាក្យថា **សព្វេ សត្តា** សត្វទាំងឡាយទាំងពួង ជាបុគ្គលាធិដ្ឋាននៃធម៌ទេសនា , អធិប្បាយថា សង្ខារទាំងឡាយទាំងពួង ។ ពិតហើយ ទេសនារបស់ព្រះមានព្រះភាគជាម្ចាស់មាន ៤ យ៉ាង ដោយអំណាចនៃធម្មៈ និងបុគ្គល គឺ ៖



**-ធម្មាធិដ្ឋានធម្មទេសនា ១**

**-ធម្មាធិដ្ឋានបុគ្គលទេសនា ១**

**-បុគ្គលាធិដ្ឋានបុគ្គលទេសនា ១**

**-បុគ្គលាធិដ្ឋានធម្មទេសនា ១**

**ធម្មាធិដ្ឋានធម្មទេសនា** ដូចសម្តែងថា ម្នាលភិក្ខុទាំងឡាយ តថាគត រមែងពិចារណាមិនឃើញធម៌ដទៃសូម្បីតែមួយ ដែលអប់រំហើយ រមែងគួរដល់ការងារ ដូចចិត្ត ម្នាលភិក្ខុទាំងឡាយ ចិត្តដែលអប់រំហើយ រមែងគួរដល់ការងារ ។

**ធម្មាធិដ្ឋានបុគ្គលទេសនា** ដូចសម្តែងថា ម្នាលភិក្ខុទាំង-ឡាយ ប្រការដែលបុគ្គលដល់ព្រមដោយទិដ្ឋិ ដែលគប្បីប្រកាន់សង្ខារអ្វី ៗ ដោយសេចក្តីជារបស់ទៀងនោះ មិនមែនជាឋានៈ មិនមែនជាឱកាស ដែលមានបាន ។

**បុគ្គលាធិដ្ឋានបុគ្គលទេសនា** ដូចសម្តែងថា ម្នាលភិក្ខុទាំងឡាយ បុគ្គលម្នាក់ឯង កាលបើកើតក្នុងលោក រមែងកើតឡើងដើម្បីជាប្រយោជន៍ គាំទ្រដល់ជនចំនួនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់មនុស្សលោក ដើម្បីប្រ-

យោជន៍ ដើម្បីគាំទ្រ ដើម្បីសេចក្ដីសុខដល់មនុស្ស និងទេវតាទាំងឡាយ ។

**បុគ្គលាធិដ្ឋានធម្មទេសនា** ដូចសម្ដែងថា ម្នាលភិក្ខុទាំង-ឡាយ សេចក្ដីប្រាកដនៃចក្ខុរមែងមាន ព្រោះការប្រាកដឡើងនៃបុគ្គលម្នាក់ ។

ក្នុងទេសនា ៤ ទាំងនោះ ក្នុងទីនេះ លោកប្រាថ្នាយកបុគ្គលាធិដ្ឋានធម្មទេសនា ។ គួរជ្រាបថា លោកសម្ដែងស័ត្វ គឺធម្មៈ ដោយសត្តស័ត្វ ព្រោះសំដៅយកធម៌ប៉ុណ្ណោះ តាំងពីដើមរហូតដល់ពួក ១០ , ម្យ៉ាងទៀត គប្បីជ្រាបថា លោកសម្ដែងស័ត្វ គឺ **សត្ត** ដោយវិសេស ព្រោះគប្បីចូលទៅសញ្ជឹងពិចារណាធម៌ ដែលទាក់ទងក្នុងសន្ដានរបស់សត្វបានតាមសភាវៈ ដោយញាណដ៏ក្រៃលែង ឬគួរជ្រាបថា សង្ខារទាំងឡាយ លោកពោលថា សត្វដោយផលោបចារន័យ ព្រោះគ្រាន់តែបញ្ញត្តថា សត្វ យ៉ាងនេះក៏ព្រោះអាស្រ័យសង្ខារទាំងឡាយ ។ សត្វអ្វី ៗ ឈ្មោះថា តាំងនៅដោយបច្ច័យនោះ មិនមានឡើយ ក្នុងទីណា ៗ ក៏មានតែសង្ខារទាំងអស់ , តែលោកហៅយ៉ាងនេះ ដោយអំណាចនៃវោហារ ។



**ញាតបរិញ្ញា** គឺ លោកពោលទុកដោយ ពាក្យនេះដោយប្រការដូច្នេះ ។

## អដ្ឋកថា ទុកនិទ្ទេស

### ស្ដីពីធាតុ ២

ពាក្យថា **ទ្វេ ធាតុយោ** ធាតុ ២ បានដល់ សង្ខតធាតុ ១ អសង្ខតធាតុ ១ ។

បណ្ដាធាតុទាំង ២ នោះ ខន្ធ ៥ ដែលបច្ច័យដ៏អនេកតាក់តែងហើយ ឈ្មោះថា **សង្ខតធាតុ** , ព្រះនិព្វានដែលបច្ច័យអ្វី ៗ តាក់តែងមិនបាន ឈ្មោះថា **អសង្ខតធាតុ** ។

# អដ្ឋកថា តិកនិទ្ទេស

## ស្តីពីធាតុ ៣

ពាក្យថា **តិស្សោ ធាតុយោ** ធាតុ ៣ បានដល់ កាមធាតុ ១ រូបធាតុ ១ អរូបធាតុ ១ ។

បណ្តាធាតុទាំង ៣ នោះ កាមធាតុដូម្តេច ?

ក្នុងខាងក្រោម មានអវេចីនរកជាទីបំផុត , ក្នុងខាងលើ មានបរនិម្មិតវសវត្តីជាទីបំផុត ខន្ធ ធាតុ អាយតនៈ រូប វេទនា សញ្ញា សង្ខារ និងវិញ្ញាណ ដែលប្រព្រឹត្តទៅក្នុងរវាងនេះ ដែលទាក់ទងក្នុងរវាងនេះ , នេះហៅថា **កាមធាតុ** ។

បណ្តាធាតុទាំង ៣ នោះ រូបធាតុដូម្តេច ? ក្នុងខាងក្រោម មានព្រហ្មលោកជាទីបំផុត ក្នុងខាងលើមានអកនិដ្ឋកព្រហ្មលោកជាទីបំផុត សភាវៈធម៌ទាំងឡាយ គឺ ចិត្ត និងចេតសិក របស់បុគ្គលអ្នកចូលសមាបត្តិក្តី របស់អ្នកកើតហើយក្តី របស់អ្នកនៅដោយសុខវិហារធម៌ក្នុងបច្ចុប្បន្នក្តី ដែលប្រព្រឹត្ត ទៅក្នុងរវាងនេះ ទាក់ទងក្នុងរវាងនេះ , នេះហៅថា **រូបធាតុ** ។



បណ្តាធាតុទាំង ៣ នោះ អរូបធាតុដូចម្តេច ? ក្នុងខាងក្រោមមានអាកាសានញ្ចាយតនៈព្រហ្មលោកជាទីបំផុត ក្នុងខាងលើមាននេវសញ្ញានាសញ្ញាយតនៈព្រហ្មលោកជាទីបំផុត សភាវៈទាំងឡាយ គឺ ចិត្ត និងចេតសិករបស់អ្នកចូលសមាបត្តិក្តី របស់អ្នកកើតហើយក្តី របស់អ្នកនៅដោយសុខវិហារធម៌ក្នុងបច្ចុប្បន្ន ក្តី ដែលដើរប្រព្រឹត្តទៅក្នុងចន្លោះនេះ ទាក់ទងក្នុងចន្លោះនេះ , នេះលោកហៅថា **អរូបធាតុ** ។

តែក្នុងអដ្ឋកថាលោកពោលថា កាមកត ឈ្មោះថា កាម-ធាតុ បានខន្ធ ៥ , រូបកត ឈ្មោះថា រូបធាតុ បានខន្ធ ៥ , អរូបកត ឈ្មោះថា អរូបធាតុ បានខន្ធ ៤ ។ នេះប្រកបដោយបរិយាយនៃទសុត្តរសូត្រ ។

ចំណែកក្នុងបរិយាយនៃសង្គីតិសូត្រថា សូម្បីធាតុទាំងឡាយ ដែលលោកពោលទុកថា **កុសលធាតុមាន ៣** គឺ នេក្ខម្មធាតុ ១ , អព្យាបាទធាតុ ១ , អវិហឹង្សាធាតុ ១ ។ ធាតុ ៣ ដទៃទៀត គឺ រូបធាតុ ១ អរូបធាតុ ១ និរោធធាតុ ១ ។ ធាតុ ៣ ដទៃទៀត គឺ ហីនាធាតុ ១ មជ្ឈិមាធាតុ ១ បណីតាធាតុ ១ ។ ក៏រមែងប្រកប

ក្នុងទីនេះ ។

ការនឹកគិត ការសញ្ចឹងគិត ដែលប្រកបដោយនេក្ខម្មៈ ។ល។ សម្មាសង្កប្បៈ នេះហៅថា **នេក្ខម្មធាតុ** , កុសលធម៌ សូម្បីទាំងអស់ ក៏ហៅថា នេក្ខម្មធាតុ ។

ការនឹកគិត ការសញ្ចឹងគិត ដែលក្របដោយអព្យាបាទ ។ល។ សម្មាសង្កប្បៈ ហៅថា **អព្យាបាទធាតុ** ការមានមេត្រី អាការដែលមានមេត្រី សភាពដែលមានមេត្រីក្នុងសត្វទាំងឡាយ មេត្តាចេតោវិមុត្តិ នេះហៅថា អព្យាបាទធាតុ ។

ការនឹកគិត ការសញ្ចឹងគិត ដែលប្រកបដោយអវិហឹង្សា ។ល។ សម្មាសង្កប្បៈ ហៅថា **អវិហឹង្សាធាតុ** , សេចក្តីករុណា អាការដែលករុណា សភាវដែលករុណាក្នុងសត្វទាំងឡាយ ករុណាចេតោវិមុត្តិ នេះហៅថា អវិហឹង្សាធាតុ ។

ហៅថា **និរោធធាតុ** ។ អកុសលចិត្តុប្បាទ ១២ ហៅថា **ហីនាធាតុ** , ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស ហៅថា **មជ្ឈិមាធាតុ** , លោកុត្តរធម៌ ៩ ហៅថា **បណីតាធាតុ** ។ ក៏ធម៌សូម្បីទាំងអស់ ហៅថា **ធាតុ** ព្រោះអត្ថថា មិនមែនជីវៈ ។



# អដ្ឋកថា ចតុកនិទ្ទេស

## ស្តីពី អរិយសច្ច ៤

ពាក្យថា **ចត្តារិ អរិយសច្ចានិ** អរិយសច្ច ៤ បានដល់ ទុក្ខអរិយសច្ច ១ , ទុក្ខសមុទយអរិយសច្ច ១ , ទុក្ខនិរោធអរិយសច្ច ១ , ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច ១ , វណ្ណនានៃអរិយសច្ច ៤ ទាំងនេះ មានច្បាស់ក្នុងវិសជ្ជនា នៃសច្ចៈនោះឯង ។

## អដ្ឋកថា បញ្ចកនិទ្ទេស

## ស្តីពីវិមុត្តាយតនៈ ៥

ពាក្យថា **បញ្ច វិមុត្តាយតនានិ** វិមុត្តាយតនៈ ៥ សេចក្តីថា ហេតុនៃការផុត ៥ ប្រការ ទាំងនេះគឺ ៖

- ការស្តាប់ធម្មទេសនាដែលអ្នកដទៃសម្តែង ដើម្បីប្រយោជន៍ឧបត្ថម្ភដល់ខ្លួន ១ ។
- ការសម្តែងធម៌តាមដែលខ្លួនស្តាប់មកហើយ ដើម្បីប្រយោជន៍ឧបត្ថម្ភដល់អ្នកដទៃ ១ ។
- ការស្វាធ្យាយធម៌ដែលខ្លួនបានស្តាប់មកហើយ ១ ។
- ការនឹកគិតដល់ធម៌តាមដែលបានស្តាប់មកហើយ ដោយចិត្ត ១ ។
- អារម្មណ៍ដែលសមគួរដល់សមថកម្មដ្ឋាន ៤០ មានកសិណ ១០ អសុភ ១០ ជាដើម ណាមួយ ។

ដូចដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា ៖



ម្នាលភិក្ខុទាំងឡាយ ព្រះសាស្តា ឬមិត្រសព្រហ្មចារី អ្នកតាំងនៅក្នុងឋានៈគួរដល់ការគោរព បានសម្តែងធម៌ដល់ភិក្ខុក្នុងធម្មវិន័យនេះ ភិក្ខុនោះរមែងយល់អត្ថ យល់ធម៌នោះ តាមដែលព្រះសាស្តា ឬមិត្រសព្រហ្មចារី អ្នកតាំងនៅក្នុងឋានៈគួរដល់ការគោរព សម្តែងធម៌ដល់ភិក្ខុ កាលបើភិក្ខុនោះយល់អត្ថ យល់ធម៌ ក៏រមែងកើតបាមោជ្ជៈ កាលបើកើតបាមោជ្ជៈហើយ បីតិក៏មែងកើត កាលបើចិត្តសហគតដោយបីតិ កាយរមែងស្ងប់ អ្នកមានកាយស្ងប់ ក៏រមែងសោយសុខ , កាលបើមានសុខ ចិត្តរមែងតាំងមាំ , នេះជា **វិមុត្តាយតន** ប្រការទី ១ ។

ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ព្រះសាស្តា ឬមិត្រសព្រហ្មចារី អ្នកតាំងនៅក្នុងឋានៈគួរដល់ការគោរពរូបណាមួយ រមែងមិនសម្តែងធម៌ដល់ភិក្ខុឡើយ តែថា ភិក្ខុរមែងសម្តែងធម៌តាមដែលបានស្តាប់មក តាមដែលបានសិក្សាមកពីមនុស្សពួកដទៃដោយពិស្តារ ភិក្ខុរមែងយល់អត្ថ យល់ធម៌ ក្នុងធម៌នោះ ដែលភិក្ខុសម្តែងធម៌តាមដែលបានស្តាប់មក តាមដែលបានសិក្សាមកពីមនុស្សពួកដទៃដោយពិស្តារ កាលបើ ភិក្ខុយល់អត្ថ យល់ធម៌

រមែងកើតបាមោជ្ជៈ ។ល។ នេះជា **វិមុត្តាយតន** ប្រការទី ២ ។

ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ព្រះសាស្តា ឬមិត្រសព្រហ្មចារីអ្នកតាំងនៅក្នុងឋានៈគួរគោរពរូបណាមួយ ក៏មិនបានសម្តែងធម៌ដល់ភិក្ខុ សូម្បីភិក្ខុក៏មិនបានសម្តែងធម៌ តាមដែលបានស្តាប់មក តាមដែលបានសិក្សាមកពីមនុស្សពួកដទៃ ដោយពិស្តារ តែថា ភិក្ខុរមែងធ្វើការស្វាធ្យាយតាមដែលបានស្តាប់មក តាមដែលសិក្សាមកដោយពិស្តារ ភិក្ខុរមែងយល់ក្នុងអត្ថ យល់ក្នុងធម៌ តាមដែលភិក្ខុស្វាធ្យាយធម៌ តាមដែលបានស្តាប់មក តាមដែលបានសិក្សារៀនសូត្រមកដោយពិស្តារ កាលបើភិក្ខុយល់អត្ថ យល់ធម៌ រមែងកើតបាមោជ្ជៈ ។ល។ កាលបើមានសុខ ចិត្តរមែងតាំងមាំ នេះជា **វិមុត្តាយតន** ប្រការទី ៣ ។

ម្នាលភិក្ខុទាំងឡាយ ប្រការមួយទៀត ព្រះសាស្តា ឬមិត្រសព្រហ្មចារី អ្នកតាំងនៅក្នុងឋានៈគួរដល់ការគោរពរូបណាមួយ មិនបានសម្តែងធម៌ដល់ភិក្ខុ ភិក្ខុក៏មិនបានសម្តែងធម៌តាមដែលបានស្តាប់មក តាមដែលបានសិក្សាមក ដល់មនុស្សពួកដទៃដោយពិស្តារ សូម្បីភិក្ខុ ក៏មិនបានធ្វើការស្វាធ្យាយធម៌ តាមដែលបាន



ស្តាប់មក តាមដែលបានសិក្សាមកដោយពិស្តារ តែថាភិក្ខុរមែងសញ្ជឹងគិត ពិចារណាធម៌ដែលបានស្តាប់មក តាមដែលបានសិក្សាមកដោយចិត្ត ភិក្ខុមែងយល់អត្ថ យល់ធម៌ រមែងកើតបាមោជ្ជៈ ។ល។

កាលបើមានសុខ ចិត្តរមែងតាំងមាំ នេះជា **វិមុត្តាយតន** ទី ៤ ។

ម្នាលភិក្ខុទាំងឡាយ ប្រការមួយរទៀត ព្រះសាស្តា ឬមិត្រសព្រហ្មចារី អ្នកតាំងនៅក្នុងឋានៈដែលគួរគោរពរូបណាមួយ មិនបានសម្តែងធម៌ដល់ភិក្ខុ ភិក្ខុក៏មិនបានសម្តែងធម៌តាមដែលស្តាប់មក តាមដែលបានសិក្សាមក ដល់មនុស្សពួកដទៃដោយពិស្តារ ភិក្ខុក៏មិនបានស្វាធ្យាយធម៌តាមដែលបានស្តាប់មក តាមដែលបានសិក្សាមកដោយពិស្តារ សូម្បីភិក្ខុក៏មិនបានសញ្ជឹងគិត ពិចារណាធម៌តាមដែលបានស្តាប់ តាមដែលបានសិក្សាមកដោយចិត្ត តែថាសមាធិនិមិត្តឯណាមួយ លោកសិក្សាមកដោយល្អ ធ្វើទុកក្នុងចិត្តដោយល្អ ចាំទុកដោយល្អ ចាក់ធ្លុះដោយល្អដោយបញ្ញា ភិក្ខុរមែងយល់ធម៌នោះ តាមដែលបានសិក្សាសមាធិនិមិត្ត ឯណាមួយដោយល្អ ចាំទុកដោយល្អ ចាក់ធ្លុះដោយល្អ ដោយបញ្ញា កាល

បើភិក្ខុយល់អត្ថ យល់ធម៌ រមែងកើតការបាមោជ្ជៈ កាលបើកើតបាមោជ្ជៈហើយ រមែងកើតបីតិ កាលបើមានចិត្តសហគតដោយបីតិ កាយរមែងស្ងប់ អ្នកមានកាយស្ងប់ហើយ រមែងបានសុខ កាលណាមានសុខ ចិត្តរមែងតាំងមាំ ។ នេះជា **វិមុត្តាយតន** ប្រការទី ៥ ដោយប្រការដូច្នេះ ។

## អដ្ឋកថា ឆក្កនិទ្ទេស

## ស្តីពី អនុត្តរិយ ៦

ក្នុងពាក្យថា **ឆ អនុត្តរិយានិ** អនុត្តរិយៈ ៦ មាន សេចក្តីថា គុណដ៏ប្រសើរជាងធម្មជាតិទាំងនោះមិនមាន ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **អនុត្តរ** អនុត្តរៈនោះឯង ឈ្មោះថា **អនុត្តរិយ** , អធិប្បាយថា ជាធម្មជាតិដ៏ប្រសើរ ។ សមពិត ដូចព្រះតម្រាស់ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ អនុត្តរិយៈ ៦ ប្រការនេះ ។ ៦ ប្រការ ដូម្តេច ? គឺ ៖



១- **ទស្សនានុត្តរិយ** ការឃើញដ៏ប្រសើរ

២- **សវនានុត្តរិយ** ការស្តាប់ដ៏ប្រសើរ

៣- **លាភានុត្តិយ** ការបានដ៏ប្រសើរ

៤- **សិក្ខានុត្តរិយ** ការសិក្សាដ៏ប្រសើរ

៥- **បារិចរិយានុត្តរិយ** ការបំរុងដ៏ប្រសើរ

៦- **អនុស្សតានុត្តរិយ** អនុស្សតិដ៏ប្រសើរ

ម្នាលភិក្ខុទាំងឡាយ ក៏ **ទស្សនានុត្តរិយ** ដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រមែងទៅដើម្បីនឹងមើលដំរីកែវខ្លះ សេះកែវខ្លះ កែវមណីខ្លះ របស់ធំរបស់តូចខ្លះ ឬសមណព្រាហ្មណ៍អ្នកយល់ខុស បដិបត្តិខុសខ្លះ ម្នាលភិក្ខុទាំងឡាយ ទស្សនៈនេះមាន តថាគតមិនពោលថា មិនមានទេ ម្នាលភិក្ខុទាំងឡាយ ដោយសេចក្តីថា ទស្សនៈនេះនោះជាទស្សនៈដ៏អាក្រក់ ជារបស់អ្នកស្រុក ជារបស់បុថុជ្ជន មិនមែនរបស់ព្រះអរិយៈ មិនប្រកបដោយប្រយោជន៍ មិនប្រព្រឹត្តទៅដើម្បីនឿយណាយ ដើម្បីការរំលត់ ដើម្បីការស្ងប់ ដើម្បីសេចក្តីដឹងដ៏ក្រៃលែង ដើម្បីត្រាស់ដឹង ដើម្បីព្រះនិព្វាន ម្នាលភិក្ខុ

ទាំងឡាយ ចំណែកបុគ្គលណាមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនកម្រើក មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង រមែងទៅដើម្បីឃើញព្រះតថាគត ឬសាវករបស់តថាគត ម្នាលភិក្ខុទាំងឡាយ ការឃើញនេះ ប្រសើរជាងការឃើញទាំង-ឡាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ដើម្បីឈានកន្លងនូវសេចក្តីសោកខ្សឹកខ្សួល ដើម្បីសេចក្តីរំលត់បង់នូវទុក្ខ និងទោមនស្ស ដើម្បីសម្រេចញាយធម៌ ដើម្បីធ្វើជាក់ច្បាស់នូវព្រះនិព្វាន ម្នាលភិក្ខុទាំងឡាយ ប្រការដែលបុគ្គលអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង បានឃើញព្រះតថាគត ឬសាវករបស់ព្រះតថាគតនេះ តថាគតហៅថា ទស្សនានុត្តរិយៈ ។ **ទស្សនានុត្តរិយ** យ៉ាងដូច្នេះ ។

ក៏ **សវនានុត្តរិយ** យ៉ាងណា ? ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រមែងទៅដើម្បីស្តាប់សំឡេងស្គរខ្លះ សំឡេងពិណខ្លះ សំឡេងភ្លេងខ្លះ ឬសំឡេងខ្លាំង ៗ តិច ៗ រមែងទៅដើម្បីស្តាប់ធម៌របស់សមណព្រាហ្មណ៍អ្នកយល់ខុស អ្នកបដិបត្តិខុស



ម្នាលភិក្ខុទាំងឡាយ ការស្តាប់នេះមាន តថាគតមិនបានពោលថាមិនមានទេ តែថាការស្តាប់នេះ ជាការស្តាប់ដ៏អាក្រក់ ។ល។ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលណាអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនកម្រើក មានសេចក្តីជ្រះថ្លាដ៏ប្រសើរ រមែងទៅដើម្បីស្តាប់ធម៌តថាគត ឬសាវករបស់តថាគត ។ ម្នាលភិក្ខុទាំងឡាយ ការស្តាប់នេះ ប្រសើរជាងការស្តាប់ទាំងឡាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។ល។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន , ម្នាលភិក្ខុទាំងឡាយ ប្រការដែលបុគ្គលមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនកម្រើក មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង រមែងទៅស្តាប់ធម៌របស់តថាគត ឬរបស់សាវករបស់តថាគត នេះតថាគតហៅថា **សវ-នានុត្តរិយ** ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ ដូច្នេះឯង ។

ក៏ **លាភានុត្តរិយ** ដូចម្តេច ?

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រមែងបានបុត្រខ្លះ ភរិយាខ្លះ ទ្រព្យខ្លះ ឬលាភច្រើនខ្លះ តិចខ្លះ ឬបានសទ្ធា

ក្នុងសមណព្រាហ្មណ៍អ្នកយល់ខុស អ្នកបដិបត្តិខុស ។ ម្នាលភិក្ខុទាំងឡាយ **លាភ** គឺ ការបាននេះមាន តថាគតមិនបានពោលថាមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ សេចក្តីថា លាភ គឺការបាននេះជាលាភអាក្រក់ ។បេ។ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលណាជាអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង រមែងបានសទ្ធាក្នុងព្រះតថាគត ឬសាវករបស់ព្រះតថាគត ។ ម្នាលភិក្ខុទាំងឡាយ លាភ គឺការបាននេះ ជាលាភដ៏ប្រសើរជាងលាភទាំងឡាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។បេ។ ដើម្បីធ្វើឲ្យជាក់-ច្បាស់នូវព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ការដែលបុគ្គលអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង រមែងបានសទ្ធាក្នុងព្រះតថាគត ឬសាវករបស់ព្រះតថាគតនេះ តថាគតហៅថា



**លាភានុត្តរិយ** ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុ-ត្តរិយៈ យ៉ាងដូច្នេះ ។

ក៏ **សិក្ខានុត្តរិយ** ដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ រមែងសិក្សាសិល្បៈទាក់ទិននឹងដំរីខ្លះ សេះខ្លះ រថខ្លះ ធ្នូខ្លះ ដាវខ្លះ ឬសិក្សាសិល្បៈថ្នាក់ខ្ពស់ ថ្នាក់ទាប រមែងសិក្សាជាមួយសមណព្រាហ្មណ៍អ្នកមានការយល់ខុស អ្នកបដិបត្តិខុស ។ ម្នាលភិក្ខុទាំងឡាយ ការសិក្សានេះមាន តថាគតមិនបានពោលថា ការសិក្សានេះមិនមានទេ ។ តែថា ការសិក្សានេះ ជារបស់អាក្រក់ ។បេ។ រមែងប្រព្រឹត្តទៅមិនដើម្បីព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ ចំណែកបុគ្គលណាមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាមុតមាំ រមែងសិក្សាអធិសីលខ្លះ អធិចិត្តខ្លះ អធិប្បញ្ញាខ្លះក្នុងធម្មវិន័យដែលតថាគតប្រកាសហើយ ។ ម្នាលភិក្ខុទាំងឡាយ ការសិក្សានេះ ប្រសើរជាងការសិក្សាទាំងឡាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធិនៃសត្វទាំងឡាយ ។បេ។ ដើម្បីធ្វើឲ្យជាក់-ច្បាស់នូវព្រះនិព្វាន , ម្នាលភិក្ខុទាំងឡាយ ប្រការដែលបុគ្គល

អ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាដ៏ក្រៃលែង រមែងសិក្សាអធិសីលខ្លះ អធិចិត្តខ្លះ អធិប្បញ្ញាខ្លះ ក្នុងធម្មវិន័យដែលតថាគតប្រកាសហើយ នេះតថាគតហៅថា **សិក្ខានុត្តរិយ** ។ ទស្សនានុត្តរិយៈ , សវនានុត្តរិយៈ , លាភានុត្តរិយៈ , សិក្ខានុត្តរិយៈ ដូច្នេះឯង ។

បុគ្គលខ្លះក្នុងលោកនេះ រមែងទំនុកបម្រុងក្សត្រខ្លះ ព្រាហ្មណ៍ខ្លះ គហបតីខ្លះ ឬថា រមែងទំនុកបម្រុងបុគ្គលថ្នាក់ខ្ពស់ ថ្នាក់ទាប ឬរមែងទំនុកបម្រុងសមណព្រាហ្មណ៍ដែលមានការយល់ខុស អ្នកបដិបត្តិខុស ។ ម្នាលភិក្ខុទាំងឡាយការទំនុកបម្រុងនេះមាន តថាគតមិនបានពោលថា ការទំនុកបម្រុងនេះមិនមានទេ ។ ម្នាលភិក្ខុទាំងឡាយ តែការទំនុកបម្រុងនេះ ជាការទំនុកបម្រុងដ៏អាក្រក់ ។លៗ មិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ តែថា បុគ្គលណាអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាក្រៃលែង រមែងទំនុកបម្រុងតថាគត ឬសាវករបស់តថាគត ។ ម្នាលភិក្ខុទាំងឡាយ ការទំនុកបំរុងនេះប្រសើរជាងការទំនុកបម្រុង



ទាំងឡាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីបរិសុទ្ធ ដល់សត្វទាំងឡាយ ។លៗ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ ប្រការដែលបុគ្គលអ្នកមានសទ្ធាតាំងមាំ មានសេចក្តីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្តីជ្រះថ្លាមុតមាំ រមែងទំនុកបម្រុងព្រះតថាគត ឬសាវករបស់តថាគត ។ នេះហៅថា **បារិចរិយានុត្តរិយ** ។ ទស្សនានុត្តរិយៈ សវនានុត្តរិយៈ លាភានុត្តរិយៈ សិក្ខានុត្តរិយៈ បារិចរិយានុត្តរិយៈ ដូច្នេះឯង ។

ក៏ **អនុស្សតានុត្តរិយ** ដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ រមែងរលឹកដល់ការបានបុត្រខ្លះ ការបានភរិយាខ្លះ ការបានទ្រព្យខ្លះ ឬថារមែងរលឹកដល់ការបានច្រើនខ្លះ តិចខ្លះ ឬរលឹកដល់សមណព្រាហ្មណ៍អ្នកមានការ យល់ខុស អ្នកបដិបត្តិខុស ។

ម្នាលភិក្ខុទាំងឡាយ ការរលឹកដល់នេះមាន តថាគតមិនបានពោលថា ការរលឹកដល់នេះមិនមានទេ ។ តែថាការរលឹកនេះ ជាការរលឹកដល់ដ៏អាក្រក់ ។លៗ រមែងមិនប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ។ ម្នាលភិក្ខុទាំងឡាយ តែថាបុគ្គលណា អ្នកមានសទ្ធា

តាំងមាំ មានសេចក្ដីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្ដីជ្រះដ៏មុតមាំ រមែងរលឹកដល់តថាគត ឬសាវករបស់តថា-គត ។

ម្នាលភិក្ខុទាំងឡាយ ការរលឹកនេះ ប្រសើរជាងការរលឹកទាំងឡាយ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីបរិសុទ្ធិនៃសត្វទាំងឡាយ ។ល។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន , ម្នាលភិក្ខុទាំងឡាយ ប្រការដែលបុគ្គលអ្នកមានសទ្ធាតាំងមាំ មានសេចក្ដីស្រឡាញ់តាំងមាំ មានសទ្ធាមិនញាប់ញ័រ មានសេចក្ដីជ្រះថ្លាយ៉ាងក្រៃលែង រមែងរលឹកដល់ព្រះតថាគត ឬសាវករបស់ព្រះតថាគត ។ នេះតថាគតហៅថា **អនុស្សតានុត្តរិយ** ម្នាលភិក្ខុទាំងឡាយ ទាំងនេះ គឺ អនុត្តរិយៈ ៦ ដូច្នេះឯង ។



# អដ្ឋកថា សត្តកនិទ្ទេស

## ស្ដីពី និទ្ទស

ក្នុងពាក្យថា **សត្ត និទ្ទសវត្ថូនិ** នេះ មានសេចក្ដីថា **ទស** ប្រែថា ១០ មិនមានដល់អ្នកនោះ ដូច្នោះ អ្នកនោះទើបឈ្មោះថា **និទ្ទស** វត្ថុ គឺ ហេតុនៃនិទ្ទស គឺ សេចក្ដីនៃនិទ្ទស ឈ្មោះថា **និទ្ទសវត្ថុ** ។

ពិតហើយ ព្រះខីណាស្រព បរិនិព្វានក្នុងកាលដែលមានវស្សា ១០ ក៏មិនឈ្មោះថា មានវស្សា ១០ ទៀត ព្រោះមិនមានបដិសន្ធិទៀតតទៅ ដូច្នោះ លោកទើបហៅថា **និទ្ទស** មិនមានវស្សា ១០ ។ និងមិនមានវស្សា ១០ ម្យ៉ាងប៉ុណ្ណោះ ក៏មិនមែនសូម្បីវស្សា ៩ ក៏មិនមាន ។ល។ សូម្បីកាលប្រហែលមួយស្របក់ក៏នៅមិនមាន ។ ព្រះខីណាស្រពបរិនិព្វាន ក្នុងកាលដែលមានវស្សា ១០ ប៉ុណ្ណោះក៏មិនមាន សូម្បីបរិនិព្វានក្នុងកាលដែលមានវស្សា ៧ ក៏មិនឈ្មោះថា មានវស្សា ៧ , មិនមានវស្សា ១០ មិនមាន សូម្បីកាលប្រហែលមួយស្របក់ ។ ក៏ព្រះមានព្រះភាគ

ជាម្ចាស់ កាលបើលើកយកវោហារ ដែលកើតក្នុងលទ្ធិតិរ្ថិយ៍មក ទុកក្នុងព្រះសាសនាហើយ ទ្រង់សម្តែងការមិនមាននៃព្រះខីណា-ស្រពក្នុងលទ្ធិតិរ្ថិយ៍នោះ និងការមាននៅនៃព្រះខីណាស្រពក្នុងព្រះសាសនា ទើបត្រាស់ហេតុនៃការមាននៅនៃព្រះខីណាស្រព ដូច្នេះថា **សត្ត និទ្ទសវត្ថូនិ** វត្ថុនៃនិទ្ទសៈ ៧ ។ ដូចដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ **និទ្ទសវត្ថុ ៧** ប្រការនេះ ។ ៧ ប្រការដូចម្តេច ? គឺ ៖

១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកមានសេចក្តីពេញចិត្តយ៉ាងខ្លាំងក្នុងការសមាទានសិក្ខា និងជាអ្នកមានសេចក្តីស្រឡាញ់ដែលមិនប្រាសចាកក្នុងការសមាទានសិក្ខា ។

២ ជាអ្នកមានសេចក្តីត្រេកអរយ៉ាងខ្លាំងក្លា ក្នុងការពិចារណាធម៌ និងជាអ្នកមានសេចក្តីស្រឡាញ់ ដែលមិនប្រាសចាក ក្នុងការពិចារណាធម៌តទៅ ។

៣ ជាអ្នកត្រេកអរយ៉ាងខ្លាំងក្លា ក្នុងការកម្ចាត់ការលំបាក និងជាអ្នកមានសេចក្តីស្រឡាញ់ ដែលមិនប្រាសចាកក្នុងការកម្ចាត់



ការលំបាកតទៅ ។

៤ ជាអ្នកត្រេកអរយ៉ាងខ្លាំងក្លាក្នុងការពួនសម្ងំ និងជាអ្នកមានការស្រឡាញ់មិនប្រាសចាកក្នុងការពួនសម្ងំតទៅ ។

៥ ជាអ្នកមានការពេញចិត្តយ៉ាងខ្លាំង ក្នុងការផ្តើមសេចក្តីព្យាយាម និងជាអ្នកមានការស្រឡាញ់ ដែលមិនប្រាសចាកក្នុងការផ្តើមសេចក្តីព្យាយាមតទៅ ។

៦ ជាអ្នកមានការពេញចិត្តយ៉ាងខ្លាំង ក្នុងភាពជាអ្នកមានសតិបញ្ញាជាគ្រឿងរក្សាខ្លួន និងជាអ្នកមានការស្រឡាញ់ ដែលមិនប្រាសចាកក្នុងភាពជាអ្នកមានសតិបញ្ញាជាគ្រឿងរក្សាខ្លួនតទៅ ។

៧ ជាអ្នកមានការពេញចិត្តយ៉ាងខ្លាំងក្លា ក្នុងការចាក់ធ្លុះដោយទិដ្ឋិ និងជាអ្នកមានការស្រឡាញ់ ដែលមិនប្រាសចាកក្នុងការចាក់ធ្លុះដោយទិដ្ឋិតទៅ ។

ម្នាលភិក្ខុទាំងឡាយ **និទ្ទសវត្ថុ ៧** ប្រការ ដូច្នេះ ។

សូម្បីព្រះថេរៈ កាលលើកទេសនាយ៉ាងនោះឡើងពោលថា **សត្ត និទ្ទសវត្ថូនិ** និទ្ទសវត្ថុ ៧ ប្រការនេះ ។

# អដ្ឋកថា អដ្ឋកនិទ្ទេស

## ស្តីពី អភិភាយតន ៨

ក្នុងពាក្យថា **អដ្ឋ អភិភាយតនានិ** អភិភាយតន ៨ នេះ សេចក្តីថា អាយតនៈទាំងឡាយគ្របសង្កត់ឈានទាំងនោះ ដូច្នោះ ឈានទាំងនោះ ទើបឈ្មោះថា **អភិភាយតន** ។ ពាក្យថា **អាយតនានិ** សេចក្តីថា ឈានមានកសិណជាអារម្មណ៍ពោល គឺ អាយតនៈ ព្រោះអត្ថថា ជាទីតាំងដ៏ប្រសើរ ។ អធិប្បាយថា ក៏បុគ្គលមានញាណដ៏ស្រើរ អ្នកមានញាណក្លៀវក្លាគិតថា ដែលយើងគប្បីចូលទៅក្នុងអារម្មណ៍នេះ ព្រោះហេតុអ្វី ? ការៈក្នុងការធ្វើចិត្តឲ្យជាឯកគ្គតា មិនមានដល់យើងយ៉ាងនេះ ហើយគ្របសង្កត់អារម្មណ៍ទាំងនោះចេញ ចូលសមាបត្តិ , ញុំាងអប្បនាឲ្យកើតឡើងក្នុងអារម្មណ៍នេះ ព្រមជាមួយការកើតនៃនិមិត្ត ។ ឈានដែលឲ្យកើតឡើងដោយប្រការយ៉ាងនេះ លោកហៅថា អភិភាយតនៈ ។ **អភិភាយតន ៨** ដូចម្តេច ?

១ បុគ្គលម្នាក់ មានការសម្គាល់រូបខាងក្នុង យើញរូប



ខាងក្រៅតិចតួច មានវណ្ណៈល្អ និងអាក្រក់ គ្របសង្កត់រូបទាំង-នោះហើយ មានការយល់យ៉ាងនេះថា យើងដឹង យើងឃើញ នេះជា **អភិភាយតន ទី ១** ។

២ បុគ្គលម្នាក់ មានការសម្គាល់រូបខាងក្នុង ឃើញរូបខាងក្រៅមិនមានប្រមាណ មានវណ្ណៈល្អ និងអាក្រក់ គ្របសង្កត់រូបទាំងនោះហើយ មានការយល់យ៉ាងនេះថា យើងដឹង យើងឃើញ នេះជា **អភិភាយតន ទី ២** ។

៣ បុគ្គលម្នាក់ មានការសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាងក្រៅតិចតួច មានវណ្ណៈល្អ និងអាក្រក់ គ្របសង្កត់រូបទាំងនោះហើយ មានការយល់យ៉ាងនេះថា យើងដឹង យើងឃើញ នេះជា **អភិភាយតន ទី ៣** ។

៤ បុគ្គលម្នាក់ មានការសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាងក្រៅមិនមានប្រមាណ មានវណ្ណៈល្អ និងអាក្រក់ គ្របសង្កត់រូបទាំងនោះហើយ មានការយល់យ៉ាងនេះថា យើងដឹង យើងឃើញ នេះជា **អភិភាយតន ទី ៤** ។

៥ បុគ្គលម្នាក់ មានការសម្គាល់ក្នុងអរូបខាងក្នុង ឃើញ

រូបខាងក្រៅខៀវ មានវណ្ណៈខៀវ ខៀវសុទ្ធ មានរស្មីខៀវ , ដូចផ្កាត្រគៀតខៀវ មានវណ្ណៈខៀវ ខៀវសុទ្ធ មានរស្មីខៀវ , ឬថា សំពត់ដែលផលិតនៅក្រុងពារាណសី មានចំណែកទាំងពីរខៀវរលោង មានពណ៌ខៀវ ខៀវសុទ្ធ មានរស្មីខៀវ ដូច្នោះយ៉ាងណា បុគ្គលម្នាក់ទៀត មានការសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាងក្រៅពណ៌ខៀវ មានពណ៌ខៀវ ខៀវសុទ្ធ រស្មីពណ៌ខៀវ ដូច្នោះដូចគ្នា គ្របសង្កត់រូបទាំងនោះហើយ មានការសម្គាល់យ៉ាងនេះថា យើងដឹង យើងឃើញ , នេះជា **អភិភាយតន ទី ៥** ។

៦ បុគ្គលម្នាក់ មានការសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាងក្រៅលឿង មានពណ៌លឿង លឿងសុទ្ធ មានរស្មីលឿង ដូចផ្កាកិណ្ណិកាលឿង មានពណ៌លឿង លឿងសុទ្ធ មានរស្មីលឿង, ឬថា ដូចសំពត់ដែលបានផលិតនៅក្រុងពារាណសី មានចំណែកទាំងពីរលឿងរលោង មានពណ៌លឿង លឿងសុទ្ធ មានរស្មីពណ៌លឿង សូម្បីយ៉ាងណា អ្នកណាមានការសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាងក្រៅលឿង មានពណ៌លឿងសុទ្ធ មានរស្មីលឿងសុទ្ធ ដូច្នោះដូចគ្នា គ្របសង្កត់នូវរូបទាំងនោះ ហើយមានការសម្គាល់



យ៉ាងនេះថា យើងដឹង យើងឃើញ នេះជា **អភិភាយតន ទី ៦** ។

៧ បុគ្គលម្នាក់ មានការសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាងក្រៅដែលក្រហម មានពណ៌ក្រហម ក្រហមសុទ្ធ មានរស្មីក្រហមដូចផ្កាសិរីមាន់ក្រហម ឬថា ដូចសំពត់ដែលផលិតនៅក្នុងក្រុងពារាណសី មានចំណែកទាំងពីរក្រហមរលោង មានពណ៌ក្រហម ក្រហមសុទ្ធ មានរស្មីក្រហម សូម្បីយ៉ាងណា , បុគ្គលនោះ មានការសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាង ក្រៅក្រហម មានពណ៌ក្រហម ក្រហមសុទ្ធ មានរស្មីក្រហម ដូច្នោះដូចគ្នា ក៏គ្របសង្កត់រូបទាំងនោះហើយ មានការយល់យ៉ាងនេះថា យើងដឹង យើងឃើញ នេះជា **អភិភាយតនទី ៧** ។

៨ បុគ្គលម្នាក់ទៀត មានការសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាងក្រៅដែលសដូចផ្កាយព្រឹក មានពណ៌ស សសុទ្ធ មានរស្មីស ឬថា ដូចជាសំពត់ដែលផលិតនៅក្រុងពារាណសី មានចំណែកទាំងពីរសរលោង មានពណ៌ស សសុទ្ធ មានរស្មីស យ៉ាងណា បុគ្គលនោះមានការសម្គាល់ក្នុងអរូបខាងក្នុង ឃើញរូបខាងក្រៅពណ៌ស សសុទ្ធ មានរស្មីពណ៌ស ដូច្នោះដូចគ្នា គ្របសង្កត់រូប

ទាំងនោះ ហើយមានការយល់យ៉ាងនេះថា យើងដឹង យើងឃើញ , នេះជា **អភិភាយតនទី ៨** ។

## អដ្ឋកថា នវកនិទ្ទេស
## ស្តីពី អនុបុព្វវិហារធម៌

ពាក្យថា **នវ អនុបុព្វវិហារា** អនុបុព្វវិហារ ៩ មានសេចក្តីថា ខាងក្រោយនៃធម៌មានពីមុន ៗ ឈ្មោះថា **អនុបុព្វ** តាមលំដាប់ **វិហារធម៌** ជាគ្រឿងនៅតាមលំដាប់ ឈ្មោះថា **អនុបុព្វវិហារ** ព្រោះជាធម៌ដែលយោគីបុគ្គលគប្បីនៅ គឺ គប្បីចូលទៅតាមលំដាប់ ។ អធិប្បាយថា ធម៌ជាគ្រឿងនៅ ដែលព្រះយោគីបុគ្គលគប្បីចូលតាមលំដាប់ ។ អនុបុព្វវិហារធម៌ ៩ ដូចម្តេច ? ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា ៖

១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ចូលបឋមជ្ឈាន ស្ងាត់ចាកអកុសលធម៌ទាំងឡាយ មានវិតក្កវិចារៈ មានបីតិសុខ ដែលកើតពីវិវេក ។



២ ភិក្ខុ ព្រោះរម្ងាប់វិតក្កវិចារៈទៅបាន ក៏ចូលទុតិយជ្ឈាន ដែលជាសេចក្តីថ្លាផង់នៃចិត្តក្នុងខាងក្នុង មានអារម្មណ៍ជាឯកោទិភាព ភាពនៃចិត្តមានអារម្មណ៍តែមួយ មិនមានវិតក្កវិចារៈ មានតែបីតិសុខកើតពីសមាធិ ។

៣ ភិក្ខុចូលតតិយជ្ឈាន ដែលប្រាសចាកបីតិ ប្រកបដោយឧបេក្ខា , សតិ សម្បជញ្ញៈ សោយសុខផ្លូវកាយ ដែលព្រះអរិយៈទាំងឡាយហៅថា ជាអ្នកមានឧបេក្ខា មានសតិ មានធម៌ជាគ្រឿងនៅជាសុខយ៉ាងនេះ ។

៤ ភិក្ខុ ព្រោះលះបង់សុខ និងទុក្ខ រំលត់សោមនស្ស ទោមនស្សពីមុនទៅបាន ទើបចូលចតុត្ថជ្ឈាន ដែលមិនមានសុខ និងទុក្ខ , បរិសុទ្ធដោយឧបេក្ខា និងសតិ ។

៥ ភិក្ខុ ព្រោះកន្លងរូបសញ្ញា រំលត់បដិឃសញ្ញា មិនយកចិត្តទុកដាក់ចំពោះនានត្តសញ្ញាបានដោយប្រការទាំងពួង ទើបចូលអាកាសានញ្ចាយតនៈដោយបរិកម្មថា **អនន្តោ អាកាសោ** អាកាសមិនមានទីបំផុត ។

៦ ភិក្ខុ ឈានកន្លងអាកាសានញ្ចាយតនៈទៅបាន ដោយ

ប្រការទាំងពួង ទើបចូលវិញ្ញាណញ្ចាយតនៈ ដោយបរិកម្មថា **អនន្តំ វិញ្ញាណំ** វិញ្ញាណមិនមានទីបំផុត ។

៧ ភិក្ខុ ឈានកន្លងវិញ្ញាណញ្ចាយតនៈទៅ ដោយប្រការទាំងពួង ទើបចូលអាកិញ្ចញ្ញាយតនៈ ដោយបរិកម្មថា **នត្ថិ កិញ្ចិ** អ្វីបន្តិចបន្តួចមិនមាន ។

៨ ភិក្ខុ ឈានកន្លងអាកិញ្ចញ្ញាយតនៈទៅបាន ដោយប្រការទាំងពួង ទើបចូលនេវសញ្ញានាសញ្ញាយតនៈ ។

៩ ភិក្ខុ ឈានកន្លងនេវសញ្ញានាសញ្ញាយតនៈទៅ ដោយប្រការទាំងពួង ទើបចូលសញ្ញាវេទយិតនិរោធ យ៉ាងនេះ ។

## អដ្ឋកថា ទសកនិទ្ទេស

## ស្តីពី និជ្ជរវត្ថុ ១០

ពាក្យថា **ទស និជ្ជរវត្ថូនិ** និជ្ជរវត្ថុ ១០ សេចក្តីថា មិច្ឆាទិដ្ឋិជាដើម រមែងវិនាស រមែងសាបសូន្យទៅ ដូច្នោះទើបឈ្មោះថា **និជ្ជរ** ។



ពាក្យថា **វត្ថូនិ** វត្ថុទាំងឡាយ បានដល់ ហេតុ ។ វត្ថុ គឺហេតុនោះវិនាសទៅដែរ ដូច្នោះទើបឈ្មោះថា **និជ្ជរវត្ថុ** ។ និជ្ជរវត្ថុនេះ ជាឈ្មោះរបស់កុសលធម៌ មានសម្មាទិដ្ឋិជាដើម ។

និជ្ជរវត្ថុ ១០ ដូចម្តេច ? និជ្ជរវត្ថុ ១០ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖

១ ម្នាលភិក្ខុទាំងឡាយ មិច្ឆាទិដ្ឋិរបស់អ្នកមានសម្មាទិដ្ឋិ រមែងវិនាស អកុសលធម៌ដ៏លាមកជាអនេកពួកណា មានមិច្ឆាទិដ្ឋិជាបច្ច័យ រមែងកើតឡើង អកុសលធម៌ទាំងឡាយនោះ របស់អ្នកមានសម្មាទិដ្ឋិនោះ ក៏រមែងវិនាសដែរ ហើយកុសលជាអនេកមានសម្មាទិដ្ឋិជាបច្ច័យ រមែងដល់នូវសេចក្តីចម្រើនពេញលេញ ។

២ ម្នាលភិក្ខុទាំងឡាយ មិច្ឆាសង្កប្បៈរបស់អ្នកមានសម្មាសង្កប្បៈរមែងវិនាស , អកុសលធម៌ដ៏លាមក ជាអនេកពួកណា មានមិច្ឆាសង្កប្បៈជាបច្ច័យ រមែងកើតឡើង អកុសលធម៌ទាំងឡាយនោះ របស់អ្នកមានសម្មាសង្កប្បៈនោះ ក៏រមែងសាបសូន្យដែរ និងកុសលធម៌ជាអនេកមានសម្មាសង្កប្បៈជាបច្ច័យ ក៏រមែងដល់នូវការចម្រើនលូតលាស់ឡើង ។

៣ ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាចារបស់អ្នកមានសម្មាវាចា រមែងវិនាស , អកុសលធម៌ដ៏លាមក ជាអនេកពួកណា មានមិច្ឆាវាចាជាបច្ច័យ រមែងកើតឡើង អកុសលធម៌ទាំងឡាយនោះ របស់អ្នកមានសម្មាវាចានោះ ក៏រមែងសាបសូន្យដែរ និងកុសលធម៌ជាអនេកមានសម្មាវាចាជាបច្ច័យ ក៏រមែងដល់នូវការចម្រើនលូតលាស់ឡើង ។

៤ ម្នាលភិក្ខុទាំងឡាយ មិច្ឆាកម្មន្តៈរបស់អ្នកមានសម្មាកម្មន្តៈរមែងសាបសូន្យ អកុសលធម៌ដ៏លាមកជាអនេកពួកណា មានមិច្ឆាកម្មន្តៈជាបច្ច័យ រមែងកើតឡើង អកុសលធម៌ទាំងឡាយនោះ របស់សម្មាកម្មន្តៈនោះ ក៏រមែងសាបសូន្យដែរ និងកុសលធម៌ជាអនេកមានសម្មាកម្មន្តៈជាបច្ច័យ ក៏រមែងដល់នូវការចម្រើនលូតលាស់ ។

៥ ម្នាលភិក្ខុទាំងឡាយ មិច្ឆាអាជីវៈរបស់អ្នកមានសម្មាអាជីវៈ រមែងសាបសូន្យ អកុសលធម៌ដ៏លាមកជាអនេកពួកណាមានមិច្ឆាអាជីវៈជាបច្ច័យ រមែងកើតឡើង អកុសលធម៌ទាំងឡាយនោះរបស់អ្នកមានសម្មាអាជីវៈនោះ ក៏រមែងសាបសូន្យដែរ និងកុសលធម៌ជាអនេក មានសម្មាអាជីវៈជាបច្ច័យ ក៏រមែងដល់



នូវការចម្រើនលូតលាស់ ។

៦ ម្នាលភិក្ខុទាំងឡាយ មិច្ឆាវាយាមៈរបស់អ្នកមានសម្មាវាយាមៈរមែងវិនាស អកុសលធម៌ដ៏លាមកជាអនេករបស់ពួកណា មានមិច្ឆាវាយាមៈជាបច្ច័យ រមែងកើតឡើង អកុសលធម៌ទាំងឡាយនោះ របស់អ្នកមានសម្មាវាយាមៈនោះ ក៏រមែងវិនាសចុះដែរ ហើយកុសលធម៌ជាអនេកមានសម្មាវាយាមៈជាបច្ច័យ ក៏រមែងដល់នូវការចម្រើនពេញលេញ ។

៧ ម្នាលភិក្ខុទាំងឡាយ មិច្ឆាសតិរបស់អ្នកមានសម្មាសតិ រមែងវិនាស អកុសលធម៌ដ៏លាមកជាអនេករបស់ពួកណា មាន មិច្ឆាសតិជាបច្ច័យ រមែងកើតឡើង អកុសលធម៌ទាំងឡាយនោះ របស់អ្នកមានសម្មាសតិនោះ ក៏រមែងវិនាសដែរ ហើយកុសលធម៌ជាអនេកមានសម្មាសតិជាបច្ច័យ ក៏រមែងដល់នូវការចម្រើនពេញលេញ ។

៨ ម្នាលភិក្ខុទាំងឡាយ មិច្ឆាសមាធិរបស់អ្នកមានសម្មាសមាធិរមែងវិនាស អកុសលធម៌ដ៏លាមកជាអនេករបស់ពួកណា មាន មិច្ឆាសមាធិជាបច្ច័យ រមែងកើតឡើង អកុសលធម៌ទាំងឡាយនោះ

របស់អ្នកមានសម្មាសមាធិនោះ ក៏រមែងវិនាសដែរ រីឯកុសលធម៌ជាអនេក មានសម្មាសមាធិជាបច្ច័យ ក៏រមែងដល់នូវការចម្រើនពេញលេញ ។

៩ ម្នាលភិក្ខុទាំងឡាយ មិច្ឆាញាណរបស់អ្នកមានសម្មាញាណ រមែងវិនាស អកុសលធម៌ដ៏លាមកជាអនេករបស់ពួកណា មានមិច្ឆាញាណជាបច្ច័យ រមែងកើតឡើង អកុសលធម៌ទាំងឡាយនោះ របស់អ្នកមានសម្មាញាណនោះ ក៏រមែងវិនាសទៅដែរ ហើយកុសលធម៌ជាអនេក មានសម្មាញាណជាបច្ច័យ ក៏រមែងដល់នូវការចម្រើនពេញលេញ ។

១០ ម្នាលភិក្ខុទាំងឡាយ មិច្ឆាវិមុត្តិរបស់អ្នកមានសម្មាវិមុត្តិ រមែងវិនាស អកុសលធម៌ដ៏លាមកជាអនេករបស់ពួកណា មានមិច្ឆាវិមុត្តិជាបច្ច័យ រមែងកើតឡើង អកុសលធម៌ទាំងឡាយនោះ របស់អ្នកមានសម្មាវិមុត្តិនោះ ក៏រមែងសាបសូន្យដែរ ហើយកុសលធម៌ជាអនេក មានសម្មាវិមុត្តិជាបច្ច័យ ក៏រមែងដល់នូវការចម្រើនពេញលេញ ។



## អដ្ឋកថា ចក្ខ្វាទិនិទ្ទេស
## ស្តីពី ចក្ខុជាដើម

ពាក្យមានជាអាទិ៍ថា **សព្វំ ភិក្ខវេ អភិញ្ញេយ្យំ** ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងគួរដឹងយ៉ាងនេះ ព្រះមានព្រះភាគត្រាស់ហើយ គប្បីជ្រាបថា ព្រះធម្មសេនាបតីសារីបុត្របាននាំមកសម្តែងហើយក្នុងទីនេះ ។ **ច** អក្សរ ក្នុងពាក្យថា **កិញ្ចិ** ជានិបាតត្រឹមតែធ្វើបទឲ្យពេញ ។ វិសជ្ជនា ៣០ មានចក្ខុជាដើម ព្រះធម្មសេនាបតីសារីបុត្រ សម្តែងចែកម្យ៉ាង ៥ ៗ ក្នុងទ្វារមួយ ៗ ក្នុងទាំង ៦ តាមលំដាប់នៃការប្រព្រឹត្តទៅនៃទ្វារ និងអារម្មណ៍ ។

ក្នុងពាក្យថា ចក្ខុមាន ២ យ៉ាង គឺ **មំសចក្ខុ ១** , **បញ្ញាចក្ខុ ១** ។ ក្នុងចក្ខុទាំង ២ នោះ **បញ្ញាចក្ខុ ៥** យ៉ាងគឺ ពុទ្ធចក្ខុ ១ , សមន្តចក្ខុ ១ , ញាណចក្ខុ ១ , ទិព្វចក្ខុ ១ , ធម្មចក្ខុ ១ ។

ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតកាលសំឡឹងមើលដល់សត្វលោក បានឃើញហើយ មើលដោយពុទ្ធចក្ខុ យ៉ាងនេះឈ្មោះថា **ពុទ្ធចក្ខុ** ។

ពាក្យនេះថា សព្វញ្ញុតញ្ញាណ ហៅថា សមន្តចក្ខុ យ៉ាងនេះឈ្មោះថា **សមន្តចក្ខុ** ។

ពាក្យនេះថា ភ្នែកឃើញធម៌កើតឡើងហើយ ញាណកើតឡើងហើយ យ៉ាងនេះឈ្មោះថា **ញាណចក្ខុ** ។

ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ តថាគតបានឃើញហើយដោយទិព្វចក្ខុដ៏បរិសុទ្ធ យ៉ាងនេះឈោះថា **ទិព្វចក្ខុ** ។

មគ្គញ្ញាណខាងក្រោម ៣ នេះ មកក្នុងពាក្យថា ធម្មចក្ខុ ដែលប្រាសចាកធូលី មិនមានមន្ទិល កើតឡើងហើយ យ៉ាងនេះឈ្មោះថា **ធម្មចក្ខុ** ។

ឯមំសចក្ខុមាន ២ យ៉ាង គឺ **សសម្ភារចក្ខុ ១** , **បសាទចក្ខុ ១** ។

ដុំសាច់ណា ដែលតាំងនៅក្នុងរន្ធភ្នែក ព្រមដោយស្បែកស្រោបគ្រាប់ភ្នែកផ្នែកខាងក្រៅទាំង ២ ខាងក្រោមកំណត់ដោយឆ្អឹងគ្រាប់ភ្នែក ខាងលើកំណត់ដោយឆ្អឹងចញ្ចើម ចងដោយសរសៃចេញពីកណ្ដាលគ្រាប់ភ្នែក តោងជាប់ទៅដល់ខួរក្បាល វិចិត្រដោយមណ្ឌលប្រស្រីខ្មៅ ព័ទ្ធជុំវិញដោយប្រស្រីស ដុំសាច់នេះ



ឈ្មោះថា **សសម្ភារចក្ខុ** ។

ចំណែកភាពថ្លាណា ដែលមានក្នុងសសម្ភារចក្ខុ អាស្រ័យមានមហាភូតរូប ៤ កន្លែងពោលនេះ ឈ្មោះថា **បសាទចក្ខុ** ។ ក្នុងទីនេះ លោកសំដៅយកបសាទចក្ខុនេះ ។ បសាទចក្ខុនេះដោយប្រមាណប៉ុនក្បាលចៃ អាស្រ័យធាតុទាំង ៤ បន្សើមដោយទឹករំអិលលើស្រទាប់ទាំង ៧ ជាន់ ដូចប្រេងដែលចាក់លើប៉ុយគ ៧ ជាន់ បន្សើមប៉ុយគគ្រប់ស្រទាប់ដូច្នោះ ឲ្យសម្រេចទៅជាវត្ថុនិងទ្វារតាមសមគួរ ដល់ចិត្ត និងវិថី មានចក្ខុវិញ្ញាណចិត្តជាដើម តាំងនៅក្នុងតំណែងជាកន្លែងសរីរៈសណ្ឋាន ដែលនៅត្រង់មុខ ក្នុងកណ្ដាលប្រស្រីខ្មៅ ដែលព័ទ្ធជុំវិញដោយមណ្ឌលប្រស្រីស នៃសសម្ភារៈចក្ខុនោះ ។

ធម្មជាតិណារមែងឃើញ ដូច្នោះធម្មជាតិនោះ ឈ្មោះថា **ចក្ខុ** , អធិប្បាយថា ចក្ខុនោះ រមែងត្រេកអរនឹងរូប ហើយធ្វើឲ្យរូបប្រាកដច្បាស់បាន ។

ធម្មជាតិណា រមែងបែកធ្លាយទៅ ដូច្នោះធម្មជាតិនោះឈ្មោះថា **រូប** , អធិប្បាយថា រូបនោះ កាលបើដល់នូវការប្រែ

ប្រួលទៅនៃវណ្ណៈ រមែងប្រកាសសេចក្តីដល់ហឫទ័យ ។

វិញ្ញាណប្រព្រឹត្តទៅតាមភ្នែក ឬការដឹងរូបារម្មណ៍ដោយចក្ខុ ឈ្មោះថា **ចក្ខុវិញ្ញាណ** ។

ឈ្មោះថា **ផស្ស** ព្រោះអត្ថថា ប៉ះពាល់ត្រូវ ។ លោកពោលថា **សម្ផស្ស** ព្រោះប្រកបបទដោយឧបសគ្គ ។ សម្ផស្សៈដែលប្រព្រឹត្តទៅតាមផ្លូវចក្ខុ ឈ្មោះថា **ចក្ខុសម្ផស្ស** ។

ពាក្យថា **ចក្ខុសម្ផស្សបច្ចយា** បានដល់ ផស្សចេតសិកដែលប្រកបជាមួយចក្ខុវិញ្ញាណជាដើម ។

ពាក្យថា **វេទយិតំ** បានដល់ ទទួលដឹងអារម្មណ៍ អធិប្បាយថា ការសោយអារម្មណ៍ ។

ធម្មជាតិដែលទទួលដឹងអារម្មណ៍នោះហ្នឹងឯង រមែងជាសុខ ដូច្នោះទើបឈ្មោះថា **សុខ** អធិប្បាយថា សុខនោះកើតដល់អ្នកណា ក៏រមែងធ្វើឲ្យអ្នកនោះដល់នូវសេចក្តីសុខ ។ ម្យ៉ាងទៀត ធម្មជាតិណា រមែងទំពាស៊ី និងគាស់រំលើងបានដោយល្អ នូវអាពាធផ្លូវកាយ និងចិត្ត ដូច្នោះធម្មជាតិនោះ ឈ្មោះថា **សុខ** ។

ធម្មជាតិណា រមែងសោយអារម្មណ៍ជាទុក្ខ ដូច្នោះធម្មជាតិ



នោះ ទើបឈ្មោះថា **ទុក្ខ** អធិប្បាយថា ទុក្ខកើតដល់អ្នកណា ក៏រមែងធ្វើអ្នកនោះឲ្យដល់នូវសេចក្តីទុក្ខ ។

ទុក្ខក៏មិនមែន សុខក៏មិនមែន ដូច្នោះទើបឈ្មោះថា អទុក្ខមសុខវេទនា ។ **ម** អក្សរ លោកពោលដោយអំណាចនៃបទសន្ធិ ។ ក៏ចក្ខុសម្ផស្សនោះ ជាសម្បយុត្តប្បច្ច័យជាមួយនឹងខ្លួន ដោយអំណាចនៃចក្ខុ គឺ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយៈ វិបាក អាហារ សម្បយុត្ត អត្ថិ អវិគតប្បច្ច័យ រួម ៨ បច្ច័យ , ជាបច្ច័យដែលដល់វេទនា ដែលសម្បយុត្តជាមួយសម្បដិច្ឆន្នចិត្ត ដោយអំណាច អនន្តរប្បច្ច័យ សមនន្តរ អនន្តរូបនិស្សយ នត្ថិ វិគត រួម ៥ បច្ច័យ ជាបច្ច័យដល់ធម៌ទាំងឡាយ ដែលសម្បយុត្តជាមួយសន្តីរណចិត្តជាដើម ដោយអំណាចឧបនិស្សយប្បច្ច័យ ត្រឹមតែបច្ច័យមួយ ។

ធម្មជាតិណារមែងបានឮ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **សោត** ។ សោតៈនោះ ញាំងភាពជាវត្ថុ និងទ្វារ តាមសមគួរ ដល់ចិត្តក្នុងវិថី មានសោតវិញ្ញាណចិត្តជាដើម ឲ្យសម្រេចតាំងនៅ ក្នុងតំណែងដែលមានសណ្ឋានដូចវង់ចិញ្ចៀន មានរោមទន់ ពណ៌

ស្ករត្នោត ដុះនៅខាងក្នុងរន្ធនៃសសម្ភារសោត ។

ធម្មជាតិណារមែងបន្លឺចេញ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **សទ្ទ** ( សំឡេង ) អធិប្បាយថា រមែងបន្លឺសំឡេង ។

ធម្មជាតិណា រមែងស្រូបហិត ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **ឃាន** ( ច្រមុះ ) ។ ឃានៈនោះ ញុាំងខ្លួនឯងជាវត្ថុ និងទ្វារតាមសមគួរដល់ចិត្តក្នុងវិថី មានឃានវិញ្ញាណជាដើមឲ្យសម្រេច តាំងនៅក្នុងតំណែងដែលមានសណ្ឋានដូចក្រចកជើងពពែ ក្នុងខាងក្នុងនៃរន្ធសសម្ភារឃាន ។

ធម្មជាតិណា រមែងផ្សាយទៅ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **គន្ធ** ( ក្លិន ) , អធិប្បាយថា រមែងប្រកាសកន្លែងនៅរបស់ខ្លួន ។

ធម្មជាតិណា រមែងនាំមកនូវជីវិត ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **ជិវ្ហា** ( អណ្តាត ) ឬឈ្មោះថា ជិវ្ហា ព្រោះអត្ថថា លិទ្ធរស ។ ជិវ្ហានោះ ញុាំងខ្លួនឲ្យជាវត្ថុ និងទ្វារ តាមសមគួរដល់ចិត្តក្នុងវិថី មានជិវ្ហាវិញ្ញាណជាដើមឲ្យសម្រេច តាំងនៅក្នុងតំណែងមានសណ្ឋានដូចចុងត្របកផ្កាឈូករីក ក្នុងកណ្តាលផ្ទៃ



អណ្តាត ខាងលើ វៀរចុងបំផុត គល់ និងខាង ៗ នៃសសម្ភារជិវ្ហា ។

សត្វទាំងឡាយរមែងត្រេកអរជាមួយធម្មជាតិនោះ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **រស** ( រស ) អធិប្បាយថា រមែងពេញចិត្ត ។

ធម្មជាតិណាជាអណ្តូងកើតនៃសាសវៈធម៌ទាំងឡាយដែលបណ្ឌិតស្អប់ខ្ពើម ដូច្នោះ ធម្មជាតិនោះឈ្មោះថា **កាយ** ( កាយ ) ពាក្យថា **អាយោ** ប្រែថា ប្រទេសជាកន្លែងកើតឡើង ។ ការប្រព្រឹត្តទៅនៃឧបាទិន្នករូបក្នុងកាយនេះ មាននៅដរាបណា ដរាបនោះ កាយបសាទនោះញុាំងខ្លួនឲ្យជាវត្ថុ និងទ្វារ តាមសមគួរដល់ចិត្តក្នុងវិថី មានកាយវិញ្ញាណជាដើមឲ្យសម្រេច តាំងនៅនឹងកាយនោះដោយច្រើន ។

ធម្មជាតិណា រមែងប៉ះត្រូវ ដូច្នោះ ធម្មជាតិនោះឈ្មោះថា **ផោដ្ឋព្វ** ប៉ះពាល់ ។

ធម្មជាតិណា រមែងដឹង ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **មនោ** ( ចិត្ត ) អធិប្បាយថា រមែងដឹងអារម្មណ៍ផ្សេង ៗ ។

ធម្មជាតិណា រមែងទ្រទ្រង់ទុកនូវលក្ខណៈរបស់ខ្លួន ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **ធម្ម** ( ធម្មារម្មណ៍ ) ។

ពាក្យថា **មនោ** ( ចិត្ត ) បានដល់ ភវង្គចិត្តដែលប្រព្រឹត្តទៅជាមួយការទទួលអារម្មណ៍ ។ ពាក្យថា **ធម្មា** បានដល់ ធម៌ គឺ ធម្មារម្មណ៍ មាន ១២ ប្រការ * ។

ពាក្យថា **មនោវិញ្ញាណំ** មនោវិញ្ញាណចិត្ត បានដល់ មនោវិញ្ញាណដែលធ្វើជវនកិច្ច ។ ពាក្យថា **មនោសម្ផស្សា** មនោសម្ផស្ស បានដល់ ផស្សៈចេតសិក ដែលប្រកបជាមួយមនោវិញ្ញាណនោះ ។ មនោសម្ផស្សនោះ ជាបច្ច័យដល់វេទនា ។

---

* ចិត្ត និងចេតសិកទទួលអារម្មណ៍ដោយពិតប្រាកដ មានអារម្មណ៍ ១២ ប្រភេទ គឺ ៖ ១ កាមារម្មណ៍ = កាមចិត្ត ៥៤ ចេតសិក ៥២ រូប ២៨ , ២- មហគ្គតារម្មណ៍ = មហគ្គតចិត្ត ២៧ ចេតសិក ៣៥ , ៣- និព្វានារម្មណ៍ = និព្វាន , ៤- នាមអារម្មណ៍ = ចិត្ត ចេតសិក និព្វាន , ៥- រូបអារម្មណ៍ រូប ២៨ , ៦- បច្ចុប្បន្នារម្មណ៍ = ចិត្ត ចេតសិក រូប , ៧- អតីតារម្មណ៍ = ចិត្ត ចេតសិក រូប , ៨- កាលវិមុត្តិអារម្មណ៍ = និព្វាន បញ្ញត្តិ , ៩-បញ្ញត្តិអារម្មណ៍ = អត្ថបញ្ញត្តិ សទ្ទបញ្ញត្តិ , ១០-បរមត្ថារម្មណ៍ = ចិត្ត ចេតសិក រូប និព្វាន , ១១- អជ្ឈត្តារម្មណ៍ = ចិត្ត ចេតសិក រូប , ១២- ពហិទ្ធារម្មណ៍ = ចិត្ត ចេតសិក រូប និព្វាន បញ្ញត្តិ ។



ដែលប្រកបដោយអំណាចបច្ច័យ ៧ បច្ច័យ , ដ៏សេស់ វៀរវិបាកប្បច្ច័យ ជាបច្ច័យដល់វេទនាដែលប្រកបជាមួយជវន ជាលំដាប់តទៅ គឺ ជវនដួងទី ២ ដោយអំណាចបច្ច័យ ៥ បច្ច័យទាំងនោះដូចគ្នា , ជាបច្ច័យដល់ជវនដែលដ៏សេស គឺ ជវនដួងទី ៣-៧ ដោយអំណាចឧបនិស្សយប្បច្ច័យប៉ុណ្ណោះ ។

## ខន្ធ ៥

វិសជ្ជនាខន្ធ ៥ មានវិសជ្ជនាក្នុងរូបជាដើម ព្រះធម្មសេនាបតីសារីបុត្រ សម្ដែងដោយអំណាចនៃខន្ធ ។

ធម្មជាតិណា រមែងបែកធ្លាយទៅ រមែងត្រូវបៀតបៀនដោយវិរោធិប្បច្ច័យ មានត្រជាក់ជាដើម ដូច្នោះ ធម្មជាតិនោះ ឈោះថា **រូប** ។

ធម្មជាតិណា រមែងសោយអារម្មណ៍ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **វេទនា** ។

ធម្មជាតិណា រមែងចាំអារម្មណ៍ ដូច្នោះ ធម្មជាតិនោះ

ឈ្មោះថា **សញ្ញា** ។

ធម្មជាតិណា រមែងតាក់តែង ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **សង្ខារ** ។

ធម្មជាតិណា រមែងដឹងអារម្មណ៍ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **វិញ្ញាណ** ។

## ធម៌ពួក ៦

វិសជ្ជនា ៦០ មានវិសជ្ជនាក្នុងចក្ខុជាដើម មានធម៌វិចារជាទីបំផុត ដោយអំណាចនៃពួក ៦ ក្នុងមួយពួក ១០ ព្រះធម្មសេនាបតីសារីបុត្រសម្តែងដោយជា **បិយរូបសាតរូប** ។

**វេទនា** មានវេទនាដែលកើតពីចក្ខុសម្ផស្សជាដើម និងទាំងធម៌ដែលសម្បយុត្តជាមួយ ។

ការសម្គាល់ក្នុងរូប ឈ្មោះថា **រូបសញ្ញា** ។

ធម្មជាតិណារមែងតាំងចិត្តក្នុងអារម្មណ៍ ដូច្នោះ ធម្មជាតិនោះឈ្មោះថា **សញ្ចេតនា** ។ អធិប្បាយថា រមែងបង្អោនទៅកាន់



អារម្មណ៍ ។

ធម្មជាតិណា រមែងស្រេកឃ្លាន ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **តណ្ហា** ។ អធិប្បាយថា រមែងចង់បាន ។

ធម្មជាតិណា រមែងត្រិះរិះនូវអារម្មណ៍ ដូច្នោះ ធម្មជាតិនោះឈ្មោះថា **វិតក្ក** ម្យ៉ាងទៀត ការត្រិះរិះ ឈ្មោះថា វិតក្កៈ អធិប្បាយថា ការលើកចិត្តឡើងកាន់អារម្មណ៍ ។

ធម្មជាតិណា រមែងផ្គងចិត្តទុកក្នុងអារម្មណ៍ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **វិចារ** , ម្យ៉ាងទៀត ការពិចារណា ឈ្មោះថា វិចារៈ លោកអធិប្បាយទុកថា ការពិចារណារឿយៗ ។

## ធាតុ ៦

វិសជ្ជនា មានវិសជ្ជនាក្នុងបឋវីធាតុជាដើម ព្រះធម្មសេនាបតីសារីបុត្រ បានសម្តែងដោយការកំណត់នាមរូបដោយសង្ខេប ។

ឈ្មោះថា **បឋវី** ( ដី ) ព្រោះជាធម្មជាតិផ្សាយទៅ ។

ធម្មជាតិណា រមែងជ្រួតជ្រាប ឬរមែងហូរទៅ និងប្រមូលផ្តុំ

ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **អាបោ** ( ទឹក ) ។

ធម្មជាតិណា រមែងធ្វើឲ្យក្តៅ ដូច្នោះធម្មជាតិនោះ ឈ្មោះថា **តេជោ** ( ភ្លើង ) ។

ធម្មជាតិណា រមែងបក់ទៅ ដូច្នោះធម្មជាតិនោះ ឈ្មោះថា **វាយោ** ( ខ្យល់ ) ។

ធម្មជាតិណា ដែលនរណា ៗ រមែងគូសមិនបាន សរសេរមិនបាន គឺ ដែលអ្នកណាមិនអាចនឹងក្ឈូរ កាត់ ឬបំផ្លាញបាន ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **អាកាសោ** ( អាកាស ) ។

ឈ្មោះថា **ធាតុ** ព្រោះអត្ថថា មិនមែនសត្វ ។

## កសិណ ១០

វិសជ្ជនា ១០ មានវិសជ្ជនាក្នុងបឋវីកសិណជាដើម ព្រះធម្មសេនាបតីសារីបុត្រសម្តែងដោយអំណាចនៃកសិណកាវនា ។

ដួងកសិណ ដោយអំណាចការផ្សាយទៅក្នុងអារម្មណ៍ទាំងអស់ក្តី និមិត្តដែលប្រាកដនៅនឹងដួងកសិណនោះក្តី , ឈានមាន



ដួងកសិណនោះជាអារម្មណ៍ក្តី លោកហៅថា **កសិណ** ។ តែនៅក្នុងទីនេះលោកប្រាថ្នាយក **ឈាន** ។ គឺ ឈាន ៤ មានមហាភូតជាកសិណជាអារម្មណ៍ជាខាងដើម ពីនោះឈាន ៤ មានវណ្ណកសិណជាអារម្មណ៍ជាខាងចុង ។ បរិច្ឆេទាកាស ១ ឈានមានបរិច្ឆេទាកាសនោះជាអារម្មណ៍ ១ កសិណុគ្ឃាដិមាកាស ១ និងអាកាសានញ្ចាយតនឈាន មានកសិណុគ្ឃាដិមាកាសនោះ ជាអារម្មណ៍ ១ លោកហៅថា **អាកាសកសិណ** ។

ចិត្តដែលដឹងអាកាសានញ្ចាយតនឈាន ១ , វិញ្ញាណញ្ចាយតនឈាន មានអាកាសានញ្ចាយតនឈាននោះជាអារម្មណ៍ ១ លោកហៅថា **វិញ្ញាណកសិណ** ។

## អាការ ៣២

វិសជ្ជនា ៣២ មានវិសជ្ជនាកេសាជាដើម ព្រះធម្មសេនាបតីសារីបុត្រ បានសម្តែងដោយអំណាចកម្មដ្ឋានមានអាការ ៣២ ជាអារម្មណ៍ ។ ក៏កាលបើអាការ ៣២ មានកេសាជាដើមទាំងនោះ

ប្រាកដដោយភាពជារបស់បដិកូល ក៏ជាអសុភកម្មដ្ឋានដោយអំណាចកាយគតាសតិ កាលបើប្រាកដដោយជាពណ៌ ក៏ជាវណ្ណកម្មដ្ឋាន , កាលបើប្រាកដដោយជាធាតុ ក៏ជាចតុធាតុវវត្ថានកម្មដ្ឋាន , មយ៉ាងទៀត អាការ ៣២ មានកេសាជាដើម ប្រាកដដោយជារបស់បដិ-កូល ឬដោយពណ៌ ឈានក៏មានរបស់ប្រាកដនោះជាអារម្មណ៍ ។ កាលធាតុប្រាកដហើយ ក៏គប្បីជ្រាបថា ជាកោដ្ឋាសៈទាំងនោះ និងជាការចម្រើនធាតុដែលមានកោដ្ឋាសៈនោះ ជាអារម្មណ៍ ។

**១-កេសា** សក់ទាំងឡាយកើតនៅលើស្បែកហុំលលាដ៍ក្បាលក្នុងផ្នែកខាងទាំង ២ នៃក្បាល កំណត់យកដោយគុម្ពត្រចៀកទាំង ២ ខាងមុខ កំណត់ដោយថ្ងាស់ជាទីបំផុត , និងខាងក្រោយកំណត់ដោយកញ្ចឹងក រាប់បានទាំងសែនជាអនេក ។

**២-លោមា** រោមទាំងឡាយតាំងនៅលើស្បែក ហុំព័ទ្ធសរីរៈដោយច្រើន លើកលែងកន្លែងជាទីតាំងនៃអវយវៈ មានសក់ជាដើម និងបាតដៃ បាតជើង ទាំង ២ ចេញ លោកកំណត់រន្ធរោមទុកដល់ ៩ ម៉ឺន ៩ ពាន់រន្ធ តាំងនៅទីងស្បែកហុំសរីរៈ មានប្រមាណប៉ុនពងចៃជាប្រមាណ ។



**៣-នខា** ក្រចកទាំងឡាយ តាំងនៅលើខ្នងនៃចុងម្រាមទាំងឡាយ រាប់បាន ២០ ។

**៤-ទន្តា** ធ្មេញទាំងឡាយ តាំងនៅទីងឆ្អឹងចង្កាទាំង ២ ដោយច្រើន រាប់បាន ៣២ ធ្មេញ ។

**៥-តចោ** ស្បែកហុំព័ទ្ធសរីរៈទាំងអស់ តាំងនៅខាងលើសាច់យាវស្រទាប់ក្រៅ ។

**៦-មំសំ** សាច់រាប់បាន ៩០០ ដុំ តាំងនៅព័ទ្ធជុំវិញឆ្អឹងជាង ៣០០ កំណាត់ ។

**៧-នហារូ** សរសៃ ៩០០ ចងព័ទ្ធឆ្អឹងទាំងឡាយ តាំងនៅទូទៅក្នុងសរីរៈ ។

**៨-អដ្ឋី** ឆ្អឹងជាង ៣០០ កំណាត់ តាំងនៅទាំងខាងក្រោមទាំងខាងលើ ពេញសរីរៈ ។

**៩-អដ្ឋិមិញ្ជំ** ខួរក្នុងឆ្អឹង តាំងនៅក្នុងឆ្អឹងទាំងនោះ ៗ ។

**១០-វក្កំ** ទាច ( តម្រងនោម ) បានដល់ ដុំសាច់ ២ ដុំនៅព័ទ្ធសាច់បេះដូង មានទងជាមួយគ្នាបែកចេញពីបំពង់កទៅបន្តិចហើយចែកចេញជា ២ រឹតជាប់ដោយសរសៃធំ ៗ ។

**១១-ហទយំ** បេះដូង បានដល់ សាច់ហទយៈ តាំងនៅចំកណ្ដាលដោះទាំងពីរក្នុងខាងក្នុងសរីរៈ ពេញទៅដោយលោហិតប្រមាណកន្ទះទូកដៃ ជាទីអាស្រ័យនៃចិត្ត មានប្រហោងក្នុងប្រមាណស្មើរនឹងគ្រាប់បុសនាគ ។

**១២-យកនំ** ថ្លើម បានដល់ បន្ទះសាច់មួយគូ អាស្រ័យតាំងនៅខាងស្ដាំ ខាងក្នុងរាងកាយរវាងដោះទាំង ២ ខាង ។

**១៣-កិលោមកំ** សាច់យាវ បានដល់ សាច់ស្រោប ២ យ៉ាង គឺ សាច់យាវដែលបិតស្រោបបេះដូង ១ និងសាច់យាវដែលស្រោបសាច់ក្រោមស្បែកនៅទូទៅពេញសរីរៈ ១ ។

**១៤-បិហកំ** ក្រពះនោម បានដល់ សាច់មានសណ្ឋានដូចអណ្ដាតកូនគោខ្មៅ តាំងនៅខាងឆ្វេងបេះដូង អាស្រ័យខាងលើក្រពេញស្រោបពោះ ។

**១៥-បប្ផាសំ** សួត បានដល់ ដុំសាច់ដែលហៅថា សួតដោយប្រភេទរាប់បាន ៣២ ដុំ សំយុងបិទសាច់ខាងលើបេះដូងនិងថ្លើម តាំងនៅចន្លោះដោះទាំងពីរខាង ក្នុងខាងក្នុងសរីរៈ ។

**១៦-អន្តំ** ពោះវៀនធំ បានដល់ ចង្វាយពោះវៀន ជាផ្នត់



បត់នៅក្នុងទីទាំងឡាយ គឺ ខាងលើក្រោមបំពង់កចុះមក ខាងកណ្ដាលដល់ករិសមគ្គ ( ទ្វារធំ ) តាំងនៅក្នុងខាងក្នុងសរីរៈ មានបំពង់កជាដើម និងមានករិសមគ្គជាទីបំផុត ព័ទ្ធព័ន្ធដល់គ្នា ។ របស់បុរសប្រវែង ៣២ ហត្ថ , ចំណែកស្ត្រីប្រវែង ២៨ ហត្ថ បត់ចុះបត់ឡើងជា ២១ ផ្នត់ ដូចគ្នា ។

**១៧-អន្តគុណំ** ពោះវៀនតូច បានដល់ ពោះវៀនតូចដែលតអំពីពោះវៀនធំ ព័ទ្ធជាចង្វាយរួមគ្នាជាមួយចង្វាយពោះ-វៀនធំ តាំងនៅចន្លោះចង្វាយពោះវៀនធំ មាន ២១ ចង្វាយ ។

**១៨-ឧទរិយំ** អាហារថ្មី បានដល់ អាហារ ដែលត្រូវកិនកំទេច ដោយអង្រែ គឺ ធ្មេញ បង្វិលដោយដៃ គឺ អណ្ដាតផ្សើមដោយទឹកមាត់ ក្នុងខណៈនោះ ប្រាសចាកសម្បត្តិនៃពណ៌ក្លិន រស ជាដើម ដូចជាទឹកបាយលាបអំបោះរបស់ជាងតម្បាញនិងដូចជាអាចម៍អណ្ដើក ធ្លាក់ទៅលាយឡំនឹងទឹកប្រមាត់ ស្លេសនិងខ្យល់ ក្ដៅដោយកំលាំងរបស់ភ្លើងធាតុ ក្នុងពោះពោរពេញទៅដោយដង្កូវធំ-តូច បញ្ចេញពពុះទៅខាងលើ ចំណែកកាកសំណល់មានក្លិនស្អុយគួរខ្ពើមពន់ពេក តាំងនៅលើផ្ទៃពោះវៀនធំ

លើនាភី ពោលគឺ នៅនឹងពោះដែលជាទីអាស្រ័យនៃអាហារថ្មីផ្សេង ៗ ដែលលេប ផឹក ទំពារស៊ី និងលិទ្ធចូលទៅ ។

**១៩-ករីសំ** អាហារចាស់ បានដល់ ឧច្ចារៈតាំងនៅក្នុងទីបំផុតក្នុងពោះវៀនធំ កំពស់ប្រមាណ ៨ អង្គុលី នៅក្នុងរវាងនាភី និងទីបំផុតនៃឆ្អឹងខ្នងក្នុងខាងក្រោម ពោលគឺ ទីនៅរបស់អាហារដែលរលាយហើយ ។

**២០-បិត្តំ** ទឹកប្រមាត់ បានដល់ ប្រមាត់ ២ យ៉ាង គឺទីអាស្រ័យនឹងថ្លើម ក្នុងចន្លោះសាច់ហឫទ័យ និងសួត តាំងនៅពោលគឺ ទឹកប្រមាត់ដែលនៅប្រចាំក្នុងថង់ទឹកប្រមាត់ មានសណ្ឋានដូចសាញនៃនោងធំមួយ ហើយមិនបាននៅប្រចាំ វៀរចេញពីសក់រោម ក្រចក និងធ្មេញ ដែលមិនមានសាច់ និងស្បែកដែលក្រិនស្ងួត ក៏ផ្សាយទៅពេញសរីរៈចំណែកដែលសល់ ។

**២១-សេមហំ** ស្លេស បានដល់ ស្លេស ប្រមាណពេញមួយទូកដៃ តាំងនៅនឹងផ្ទៃពោះ ។

**២២-បុព្វោ** ខ្ទុះ បានដល់ ការប្រែប្រួលទៅនៃលោហិតចាស់ កើតនៅនឹងអវយវៈ ដែលត្រូវនឹងបន្ទាស្រូច និងអណ្តាត



ភ្លើងជាដើម ប៉ះហើយ ឬដែលអវយវៈដែលមានរបួស ឬផ្លូសពោរពងជាដើម កើតឡើងហើយដោយការកម្រើកឡើងវិញនៃធាតុក្នុងខាងក្នុងសរីរប្រទេស ។

**២៣-លោហិតំ** លោហិត បានដល់ ឈាម ២ យ៉ាង គឺឈាមដែលសន្សំ មានប្រមាណត្រឹមតែមួយទូកដៃហូរចេញបន្តិច ៗផ្សើមនៅកន្ទែង សាច់បេះដូង ថ្លើម និងសួត ១ , និងឈាមដែលរត់ផ្សាយទៅពេញសរីរៈទាំងពួង ទំនងដូចជាអណ្តាតភ្លើងដែលបាញ់ចេញទៅ វៀរសក់ រោម ក្រចក និងធ្មេញ ដែលមិនមានសាច់ និងស្បែកក្រិន ។

**២៤-សេទោ** ញើស បានដល់ អាបោធាតុ ដែលហូរចេញមកពីប្រហោងរន្ធសក់ និងរោមទាំងពួងក្នុងសរីរៈ ដែលក្តៅ ព្រោះកំដៅអំពីភ្លើង និងកំដៅព្រះអាទិត្យ និងភាពប្រែប្រួលនៃរដូវជាដើម ។

**២៥-មេទោ** ខ្លាញ់ខាប់ បានដល់ ជរស្អិតខាប់ តាំងនៅរវាងស្បែក និងសាច់ , មនុស្សស្គម អាស្រ័យនៅនឹងអវយវៈទាំងឡាយមានសាច់ស្មងជាដើម ។

**២៦-អស្សុ** ទឹកភ្នែក បានដល់ អាបោធាតុ ដែលតាំងនៅពេញរន្ធភ្នែក ដែលហូរចេញមក ព្រោះកើតពីការសប្បាយ ចិត្តព្រួយចិត្ត អាហារដែលជាវិសភាគ គឺ ក្តៅខ្លាំង និងឧតុ ។

**២៧-វសា** ខ្លាញ់រាវ បានដល់ ខ្លាញ់រាវថ្លា តាំងនៅនឹងកដៃ នៅខ្នងដៃ បាតជើង ខ្នងជើង នៅច្រមុះ ថ្ងាស់ និងចង្កូយស្មា , ដោយច្រើនកើតពីឧស្មាតេជោ គឺ ចំហាយក្តៅឧណ្ហ ៗ ពីកំដៅរបស់ភ្លើង កំដៅរបស់ព្រះអាទិត្យ និងការប្រែប្រួលនៃរដូវ ។

**២៨- ខេឡោ** ទឹកមាត់ បានដល់ អាបោធាតុដែលច្របូកច្របល់គ្នាជាពពុះ តាំងនៅជាមួយអណ្តាត ខាងត្រយុលថ្ពាល់ទាំងពីរខាង ព្រោះដោយច្រើន កើតដល់អ្នកឃើញ ឬនឹកដល់ឬចាប់ដាក់អាហារទុកក្នុងមាត់ក្តី កើតដល់អ្នកហត់នឿយក្តី ឬកើតការស្អប់ខ្ពើមក្នុងរបស់ណាមួយក្តី ។

**២៩-សិង្ឃានិកា** សំបោរ បានដល់ របស់ស្អុយរលួយមិនស្អាត រអិលជាខ្លាញ់ កើតដល់អ្នកមានធាតុកម្រើក កើតដោយអាហារវិសភាគ និងការប្រែប្រួលនៃរដូវ ឬដល់អ្នកយំស្រែកហូរចេញពីក្រពេញខួរក្នុងក្បាល ហូរចេញមកពីពិតាន ទៅពេញ



នៅក្នុងរន្ធច្រមុះហូរហៀរ ស្ថិតនៅក៏មាន ហូរចេញក៏មាន ។

**៣០-លសិកា** ខួរឆ្អឹង បានដល់ ប្រេងដែលឲ្យសម្រេចកិច្ចក្នុងការបញ្ចេញប្រេងនៅតាមសន្ទាក់តនៃឆ្អឹង តាំងនៅចន្លោះសន្ទាក់តនៃឆ្អឹង ១៨០ សន្ទាក់ ។

**៣១-មុត្តំ** ទឹកម៉ូត្រ បានដល់ អាបោធាតុតាំងនៅខាងក្នុងក្រពះបស្សាវៈ ដោយអំណាចអាហារ និងឧតុ ។

**៣២-មត្ថលុង្គំ** ខួរក្នុងក្បាល បានដល់ ដុំនៃក្រពេញរួមគ្នាមានចំនួន ៤ ដុំ តាំងនៅ មានស្នាមថ្នេរ ៤ កន្លែង ខាងក្នុងលលាដ៏ក្បាល ។

## អាយតនៈ ១២

វិបស្សនា ១២ មានវិសជ្ជនាក្នុងចក្ខាយតនៈជាដើម ព្រះធម្មសេនាបតីសារីបុត្រសម្តែងដោយអំណាចនៃអាយតនៈ ១២ ។ ឈ្មោះថា **អាយតន** ព្រោះបន្ត , ឈ្មោះថា **អាយតន** ព្រោះបន្តនៃការមក , និងឈ្មោះថា **អាយតន** ព្រោះនាំទៅនៃការបន្ត មានពាក្យអធិប្បាយ លោកពោលទុកថា ពិតហើយ ធម៌ គឺ ចិត្ត

និងចេតសិក ក្នុងបណ្ដាចក្ខុ និងរូបជាដើម ជាទ្វារ និងអារម្មណ៍នោះ ៗ រមែងមក រមែងតាំងឡើង រមែងបន្ត គឺ រមែងព្យាយាមដោយកិច្ចរបស់ខ្លួន ៗ មានការសោយអារម្មណ៍ជាដើម និងមានពាក្យអធិប្បាយ លោកពោលទុកទៀតថា ក៏ធម៌ គឺ ចិត្ត និងចេតសិកទាំងនោះ រមែងផ្សាយទៅកាន់ធម៌ទាំងនោះ ក្នុងធម៌ដែលជាផ្លូវមក ។ និងនៅមានពាក្យអធិប្បាយ លោកពោលទុកទៀតថា សង្សារទុក្ខបន្តទៅច្រើនណាស់ ប្រព្រឹត្តទៅក្នុងសង្សារ ដែលយឺតយាវយូរកទីបំផុត គ្មាននេះនៅមិនវិលត្រឡប់ដរាបណាធម៌ គឺ ចិត្ត និងចេតសិកទាំងនោះ ក៏រមែងនាំទៅ គឺ រមែងឲ្យប្រព្រឹត្តទៅដរាបនោះ ។

ម្យ៉ាងទៀត ឈ្មោះថា **អាយតន** ព្រោះអត្ថថា ជាទីនៅ ព្រោះអត្ថថា ជាអណ្ដូងកើត ព្រោះអត្ថថា ជាទីប្រជុំចុះ ព្រោះអត្ថថា ជាកន្លែងកើត និងព្រោះអត្ថថា ជាការណៈ ។

ពិតយ៉ាងនោះ ក្នុងផ្លូវលោក ដែលជាទីនៅ លោកហៅថា អាយតនៈ បានក្នុងពាក្យជាដើមថា **ឥស្សរាយតនំ** ទីនៅរបស់ព្រះឥសូរ , **វាសុទេវាយតនំ** ទីនៅរបស់វាសុទេព ។



អណ្ដូងកើត លោកហៅថា អាយតនៈ បានក្នុងពាក្យជាដើមថា **សុវណ្ណាយតនំ** អណ្ដូងមាស , **រជតាយតនំ** អណ្ដូងប្រាក់ ។

តែផ្លូវសាសនា ដែលជាទីប្រជុំចុះ លោកហៅថា អាយតនៈ បានក្នុងពាក្យជាដើមថា **មនោរមេ អាយតនេ សេវន្តិ នំ វិហង្គមា** ពួកវិហគ រមែងអាស្រ័យដើមឈើនោះ ប្រជុំគ្នាក្នុងទីរីករាយនៃចិត្ត ។

កន្លែងកំណើត លោកហៅថា អាយតនៈ បានក្នុងពាក្យជាដើមថា **ទក្ខិណាបថោ គុន្នំ អាយតនំ** ទក្ខិណាបថ កន្លែងជាទីកើតនៃគោទាំងឡាយ ។

ការណៈ លោកហៅថា អាយតនៈ បានក្នុងពាក្យជាដើមថា **តត្រ តត្រេវ សក្ខិតព្វតំ បាបុណាតិ សតិ អាយតនេ** កាលបើអាយតនៈ គឺ ហេតុជាគ្រឿងរំពូកមាន អ្នកក៏សម្រេចផលក្នុងធម៌ គឺ អភិញ្ញានោះ ៗ ពិតប្រាកដ ។

ធម៌ គឺ ចិត្ត និងចេតសិកទាំងឡាយទាំងនោះ អាស្រ័យនៅនឹងចក្ខុវត្ថុជាដើម ព្រោះអាស្រ័យចក្ខុវត្ថុជាដើមនោះ ដូច្នោះចក្ខុជាដើមនោះ ទើបឈ្មោះថា ជាទីអាស្រ័យនៅនៃចិត្ត និងចេត-

សិកទាំងនោះ ។

ធម៌ គឺ ចិត្ត និងចេតសិកទាំងឡាយទាំងនោះ កើតអាស្រ័យនឹងចក្ខុវត្ថុជាដើម ព្រោះមានចក្ខុវត្ថុជាដើមនោះ ជាទីអាស្រ័យ និងព្រោះមានចក្ខុវត្ថុជាដើមនោះជាអារម្មណ៍ ដូច្នោះ ចក្ខុវត្ថុជាដើម ទើបឈ្មោះថា ជាទីកើតនៃចិត្ត និងចេតសិកទាំងនោះ ។

ចក្ខុជាដើម ជាទីប្រជុំនៃធម៌ គឺ ចិត្ត និងចេតសិកទាំងនោះ ព្រោះប្រជុំចុះដោយអំណាចនៃវត្ថុទ្វារ និងអារម្មណ៍ក្នុងទ្វារនោះ ៗ ។

ចក្ខុជាដើម ជាប្រទេស ជាទីកើតនៃធម៌ គឺ ចិត្ត និងចេតសិកទាំងនោះ ព្រោះកើតឡើងក្នុងចក្ខុវត្ថុជាដើមនោះ ដោយការអាស្រ័យចក្ខុវត្ថុជាដើមនោះ ជាអារម្មណ៍ ។

ចក្ខុជាដើម ជាហេតុនៃធម៌ គឺ ចិត្ត និងចេតសិកទាំងនោះ ក៏ព្រោះចក្ខុជាដើម នៅមិនវិនាសទៅ ។

ចក្ខុនោះ ជាអាយតនៈផង ដូច្នោះទើបឈ្មោះថា ចក្ខាយតនៈ តាមន័យដែលបានពោលមកហើយនេះឯង ។

សូម្បីអាយតនៈដ៏សេស ក៏យ៉ាងនោះដូចគ្នា ។



# ធាតុ ១៨

វិសជ្ជនាធាតុ ១៨ មានវិសជ្ជនាក្នុងចក្ខុធាតុជាដើមថា ព្រះធម្មសេនាបតីសារីបុត្រសម្ដែងដោយអំណាចនៃធាតុ ១៨ ។ ធម៌មួយ ៗ រមែងចាត់ចែងតាមសមគួរដល់អារម្មណ៍ទាំងឡាយ ក្នុងទ្វារទាំងឡាយមានចក្ខុធាតុជាដើម ដូច្នោះធម៌នោះឈ្មោះថា **ធាតុ** ។ ធម៌ រមែងទ្រទ្រង់ទុក ដូច្នោះ ធម៌នោះ ឈ្មោះថា **ធាតុ** ។ ការទ្រទ្រង់ទុក ឈ្មោះថា **ធាតុ** ។ សភាវៈដែលជាហេតុតាំងទុក ឈ្មោះថា **ធាតុ** ។ ឬសភាវៈរមែងទ្រទ្រង់ ទុកក្នុងទ្វារនោះ ដូច្នោះ ទ្វារនោះ ឈ្មោះថា **ធាតុ** ។

មានអធិប្បាយថា លោកិយធាតុទាំងឡាយ កំណត់តាំងទុកដោយសភាពជាហេតុ រមែងចាត់ចែងសង្សារទុក្ខជាអនេកប្បការ ដូចធាតុ មានធាតុមាស និងធាតុប្រាក់ជាដើម ។

ធម្មជាតិណា ដែលសត្វទ្រទ្រង់ទុក សេចក្ដីថា រមែងថែរក្សាទុក ដូចភារៈដែលបុគ្គលទទួលភារៈលីពុនទៅដូច្នោះ ។

ម្យ៉ាងទៀត ធាតុនេះ ក៏ត្រឹមតែទ្រទ្រង់ទុកនូវទុក្ខប៉ុណ្ណោះ ព្រោះមិន

ប្រព្រឹត្តទៅក្នុងអំណាច ។

អធិប្បាយថា សង្សារទុក្ខ ដែលសត្វទាំងឡាយទ្រទ្រង់ ទុកស្មើរដោយធាតុទាំងឡាយ ដែលជាហេតុប្រការមួយ , សង្សារទុក្ខនោះ ដែលសត្វទ្រទ្រង់ទុកហើយយ៉ាងនោះ រមែងតាំងនៅ ស្ថិតនៅក្នុងធាតុទាំងឡាយទាំងនោះ ប្រការមួយ ។

មួយទៀត សំរាប់អត្តារបស់តិរ្ថិយទាំងឡាយ មិនមាននៅដោយសភាវៈយ៉ាងណា ក៏ធាតុទាំងឡាយនោះ នឹងមានសភាវៈដូច្នោះក៏មិនមែន ។ តែដែលហៅថា **ធាតុ** ព្រោះអត្ថថា ជាធម្មជាតិដែលរក្សាទុកនូវសភាវៈរបស់ខ្លួន ។

ដូចជាថា ចំណែកផ្សេង ៗ របស់ថ្ម មានហរតាល និងមនោសិលាជាដើម ដែលវិចិត្រល្អក្នុងលោក ក៏ហៅថា ធាតុយ៉ាងណា ធាតុទាំងឡាយដែលវិចិត្រសូម្បីទាំងនេះ ក៏ហៅថា ជាចំណែកដែលគប្បីដឹងបានដោយញាណ ដូច្នោះ ។

ម្យ៉ាងទៀត ក្នុងចំណែកទាំងឡាយ មានរស និងលោហិតជាដើម កំណត់តាមលក្ខណៈ ដែលជាវិសភាគដល់គ្នានឹងគ្នាដែលជាចំណែកផ្សេង ៗ នៃអត្តភាព ពោលគឺ បញ្ចក្ខន្ធទាំងនេះ



ក៏គប្បីជ្រាបថា ឈ្មោះថា **ធាតុ** ដូច្នេះ ។ ព្រោះធាតុទាំងនោះមានចក្ខុធាតុជាដើម ក៏កំណត់ដោយលក្ខណៈ ដែលជាវិសភាគៈដល់គ្នានឹងគ្នា ។

ម្យ៉ាងទៀត ពាក្យថា **ធាតុ** នេះ គ្រាន់តែជាឈ្មោះនៃនិជ្ជិវធម៌ ។

ពិតជាយ៉ាងនោះ ក្នុងព្រះបាលីមានអាទិ៍ថា ម្នាលភិក្ខុទាំងឡាយ មនុស្សយើងនេះមានធាតុ ៦ ព្រះមានព្រះភាគជាម្ចាស់បានធ្វើទេសនាក្នុងរឿងធាតុទុក ក៏ដើម្បីនឹងដកការប្រកាន់នោះថាជាជីវៈ គឺ បុគ្គល ។

ចក្ខុនោះផង ជាធាតុផង ដូច្នោះ ឈ្មោះថា **ចក្ខុធាតុ** តាមន័យដែលបានពោលហើយ ។

សូម្បីធាតុដ៏សេស ក៏យ៉ាងនោះដូចគ្នា ។

ពាក្យថា **មនោធាតុ** បានដល់ មនោធាតុ ៣ ។

ពាក្យថា **ធម្មធាតុ** បានដល់ វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ សុខុមរូប ១៦ និងនិព្វាន ។

ពាក្យថា **មនោវិញ្ញាណធាតុ** បានដល់ មនោវិញ្ញាណ ៧៦ ។

## ឥន្ទ្រិយ ២២

វិសជ្ជនា ២២ មានវិសជ្ជនាក្នុងចក្ខុន្ទ្រិយជាដើម ព្រះធម្មសេនាបតីសារីបុត្រ សម្តែងដោយអំណាចនៃឥន្ទ្រិយ ២២ ។

ឈ្មោះថា **ចក្ខុន្ទ្រិយ** ព្រោះធ្វើចក្ខុវត្ថុនោះឲ្យជាធំ ក្នុងលក្ខណៈនៃការឃើញ ។

ឈ្មោះថា **សោតិន្ទ្រិយ** ព្រោះធ្វើសោតវត្ថុនោះឯងឲ្យជាធំក្នុងលក្ខណៈនៃការបានឮ ។

ឈ្មោះថា **ឃានិន្ទ្រិយ** ព្រោះធ្វើឃានវត្ថុនោះឯងឲ្យជាធំក្នុងលក្ខណៈនៃការហិតក្លិន ។

ឈ្មោះថា **ជិវ្ហិន្ទ្រិយ** ព្រោះធ្វើជីវ្ហាវត្ថុនោះឯង ឲ្យជាធំក្នុងលក្ខណៈនៃការភ្លក្សរស ។

ឈ្មោះថា **កាយិន្ទ្រិយ** ព្រោះធ្វើកាយវត្ថុនោះឯង ឲ្យជាធំក្នុងលក្ខណៈនៃការប៉ះពាល់ត្រូវ ។

ឈ្មោះថា **មនោ** ព្រោះដឹងអារម្មណ៍ , អធិប្បាយថា រមែងដឹងអារម្មណ៍ផ្សេង ៗ បាន ។ តែព្រះអដ្ឋកថាចារ្យទាំងឡាយ ពោល



ថា ឈ្មោះថា **មនោ** ព្រោះនឹក ព្រោះដឹងអារម្មណ៍ ដូចមនុស្សកំណត់រាប់ដោយរង្វាល់ម្យ៉ាង និងដូចរក្សាទុកដោយក្អែកជញ្ជីងធំ ដូច្នោះ , ឈ្មោះថា **មនិន្ទ្រិយ** ព្រោះធ្វើមនោនោះឯង ឲ្យជាធំក្នុងលក្ខណៈនៃការដឹងអារម្មណ៍ ។

សហជាតធម៌តាំងនៅបានដោយធម្មជាតិនោះ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **ជិវិត** , ឈ្មោះថា **ជិវិតិន្ទ្រិយ** ព្រោះធ្វើជីវិតិន្ទ្រិយនោះឲ្យជាធំក្នុងលក្ខណៈ នៃការអនុបាលសហជាតធម៌ ។

ជិវិតិន្ទ្រិយនោះមាន ២ យ៉ាង គឺ រូបជីវិតិន្ទ្រិយ ១ , អរូបជីវិតិន្ទ្រិយ ១ ។

ធម្មជាតិដែលកើតរួមនឹងកម្មជរូបទាំងអស់ អនុបាលសហជាតរូបទុក ឈ្មោះថា រូបជីវិតិន្ទ្រិយ , ចេតសិកដែលកើតរួមនឹងចិត្តទាំងអស់ អនុបាលសហជាតធម៌ទុក ឈ្មោះថា អរូបជីវិតិន្ទ្រិយ ។

អ្នកណារមែងប្រាថ្នា គឺ រមែងដល់នូវការរួមសង្វាសអ្នកនោះឈ្មោះថា **ឥត្ថី** ( ស្រី ) ព្រោះតាំងគភ៌បាន , ឈ្មោះថា ឥន្ទ្រិយ ព្រោះធ្វើភាពជាធំក្នុងអវយវៈទាំងឡាយ មានភេទស្រី

ជាដើម ភាពជាធំនៃស្រីនោះហើយ ឈ្មោះថា **ឥត្ថិន្ទ្រិយ** ដោយការកំណត់ ។

**និរយ** ( នរក ) លោកហៅថា **បុំ** អ្នកណាត្រូវបៀតបៀនក្នុងនរក ពោលគឺ **បុំ** ដូច្នោះអ្នកនោះឈ្មោះថា **បុរិស** ( ប្រុស ) ឈ្មោះថា ឥន្ទ្រិយ ព្រោះធ្វើភាពជាធំក្នុងអវយវៈទាំងឡាយ មានភេទនៃបុរសជាដើម , ភាពជាធំនៃបុរសនោះ ឈ្មោះថា **បុរិ-សិន្ទ្រិយ** ដោយការកំណត់ ។

ក្នុងឥន្ទ្រិយសូម្បីទាំង ២ នោះ ឥន្ទ្រិយនីមួយ ៗ ដែលកើតរួមនឹងកម្មជរូប រមែងមានឥន្ទ្រិយនីមួយ ៗ តាមសភាវៈ ។

**សុខវេទនា** ដែលប្រកបជាមួយកុសលវិបាកកាយវិញ្ញាណ-ចិត្ត ឈ្មោះថា ឥន្ទ្រិយ ព្រោះធ្វើភាពជាធំក្នុងលក្ខណៈនៃការដឹងខ្លួនសប្បាយផ្លូវកាយ , សុខវេទនានោះឯងជាធំ ឈ្មោះថា **សុខិន្ទ្រិយ** ។

**ទុក្ខវេទនា** ដែលប្រកបជាមួយអកុសលវិបាកកាយវិញ្ញាណ-ចិត្ត ឈ្មោះថា ឥន្ទ្រិយ ព្រោះធ្វើភាពជាធំក្នុងលក្ខណៈ នៃការដឹងខ្លួនមិនសប្បាយផ្លូវកាយ , ទុក្ខវេទនានោះឯង ជាធំ ឈ្មោះថា



**ទុក្ខិន្ទ្រិយ** ។

**មន** ( ចិត្ត ) ល្អ គឺ ស្អាត ព្រោះប្រកបដោយបីតិ និងសោមនស្សរបស់បុគ្គលនោះមាន ដូច្នោះ បុគ្គលនោះឈ្មោះថា **សុមនោ** មានចិត្តល្អ ភាពជាសុមនៈ ឈ្មោះថា **សោមនស្ស** , ជាឥន្ទ្រិយ ព្រោះធ្វើភាពជាធំ ក្នុងលក្ខណៈនៃការត្រេកអររបស់ចេតសិក , សោមនស្សនោះឯង ជាឥន្ទ្រិយ ឈ្មោះថា **សោម-នស្សិន្ទ្រិយ** ។

**មន** ( ចិត្ត ) អាក្រក់ ព្រោះប្រកបដោយទោមនស្សវេទនារបស់បុគ្គលនោះមាន ដូច្នោះ បុគ្គលនោះឈ្មោះថា **ទុម្មនោ** មានចិត្តអាក្រក់ , ភាពជាទុម្មនៈ ឈ្មោះថា **ទោមនស្ស** ជាឥន្ទ្រិយ ព្រោះធ្វើភាពជាធំ ក្នុងលក្ខណៈនៃការមិនត្រេកអររបស់ចេតសិក ទោម-នស្សនោះឯងជាឥន្ទ្រិយ ឈ្មោះថា **ទោមនស្សិន្ទ្រិយ** ។

ធម្មជាតិណា រមែងសម្លឹងមើលការប្រព្រឹត្តទៅ នៃអាការរបស់សុខវេទនា និងទុក្ខវេទនា រមែងប្រព្រឹត្តទៅដោយអាការនោះ ព្រោះតាំងនៅដោយភាពជាកណ្តាល ដូច្នោះ ធម្មជាតិនោះឈ្មោះថា **ឧបេក្ខា** ជាឥន្ទ្រិយ ព្រោះធ្វើភាពជាធំក្នុងលក្ខណៈ នៃ

ភាពជាកណ្តាល , ឧបេក្ខានោះឯង ជាឥន្ទ្រិយ ឈ្មោះថា **ឧបេក្ខិន្ទ្រិយ** ។

បុគ្គលរមែងជឿដោយធម្មជាតិនោះ ឬជឿខ្លួនឯង ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **សទ្ធា** , មយ៉ាងទៀត ធម្មជាតិគ្រាន់តែជឿនោះឯង ឈ្មោះថា **សទ្ធា** , ជាឥន្ទ្រិយ ព្រោះអត្ថថា ជាអធិបតី គ្របសង្កត់ការមិនជឿ , មយ៉ាងទៀត ឈ្មោះថា ឥន្ទ្រិយ ព្រោះធ្វើភាពជាធំក្នុងលក្ខណៈនៃការបង្អោនចិត្ត , សទ្ធានោះឯង ជាឥន្ទ្រិយ ឈ្មោះថា **សទ្ធិន្ទ្រិយ** ។

ភាពនៃសេចក្តីក្លាហាន ឈ្មោះថា **វិរិយ** ឬការងាររបស់អ្នកក្លាហានទាំងឡាយគប្បីខ្វល់ខ្វាយ គឺ គប្បីប្រព្រឹត្តទៅដោយវិធីដែលជាឧបាយគ្រឿងនាំទៅ , ជាឥន្ទ្រិយ ព្រោះអត្ថថា ជាអធិបតី គ្របសង្កត់ការខ្ជិលច្រអូស , មយ៉ាងទៀត ឈ្មោះថា ឥន្ទ្រិយ ព្រោះធ្វើភាពជាធំក្នុងលក្ខណៈនៃសេចក្តីព្យាយាម វិរិយៈនោះឯងជាឥន្ទ្រិយ ឈ្មោះថា **វិរិយន្ទ្រិយ** ។

បុគ្គលរមែងរលឹកបានដោយធម្មជាតិនោះ ឬរលឹកខ្លួនឯង ធម្មជាតិនោះឈ្មោះថា **សតិ** , មយ៉ាងទៀត ធម្មជាតិត្រឹមតែរលឹក



បាននោះឯង ឈ្មោះថា សតិ ជាឥន្ទ្រិយ ព្រោះអត្ថថា ជាអធិបតីគ្របសង្កត់ការភ្លាំងភ្លាត់សតិ មយ៉ាងទៀត ឈ្មោះថា ឥន្ទ្រិយ ព្រោះបានធ្វើភាពជាធំក្នុងលក្ខណៈនៃការតាំងមាំ សតិនោះឯងជាឥន្ទ្រិយ ឈ្មោះថា សតិន្ទ្រិយ ។ ធម្មជាតិណារមែងរក្សាទុក រមែងតាំងទុកដោយល្អនូវចិត្ត ក្នុងអារម្មណ៍ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **សមាធិ** , ជាឥន្ទ្រិយ ព្រោះអត្ថថា ជាអធិបតីគ្របសង្កត់ភាពរាយមាយទៅក្នុងអារម្មណ៍ផ្សេង ៗ , មយ៉ាងទៀត ឈ្មោះថា ឥន្ទ្រិយ ព្រោះធ្វើភាពជាធំ ក្នុងលក្ខណៈនៃភាពមិនរាយមាយទៅកាន់អារម្មណ៍ផ្សេង ៗ សមាធិ នោះឯងជាឥន្ទ្រិយ ឈ្មោះថា **សមាធិន្ទ្រិយ** ។

ធម្មជាតិណា រមែងដឹងអរិយសច្ច ដោយន័យជាដើមថា នេះទុក្ខ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **បញ្ញា** ។ តែក្នុងអដ្ឋកថាលោកពោលថា ឈ្មោះថា បញ្ញា ព្រោះប្រកាសព្រះត្រៃលក្ខណ៍ គឺ **អនិច្ចំ** ( មិនទៀង ) **ទុក្ខំ** ( ជាទុក្ខ ) **អនត្តា** មិនមែនអត្តា ។ ជាឥន្ទ្រិយ ព្រោះអត្ថថា ជាអធិបតីគ្របសង្កត់អវិជ្ជា ។ មយ៉ាងទៀត ឈ្មោះថា ឥន្ទ្រិយ ព្រោះធ្វើភាពជាធំក្នុង

លក្ខណៈនៃទស្សនញាណ , បញ្ញានោះឯងជាឥន្ទ្រិយ ឈ្មោះថា **បញ្ញិន្ទ្រិយ** ។

ឈ្មោះថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ** ព្រោះកើតដល់ព្រះយោគីបុគ្គលអ្នកបដិបត្តិដោយគិតថា យើងនឹងដឹងព្រះនិព្វានដែលជាអមតបទ ដែលមិនធ្លាប់ដឹងក្នុងសង្សារវដ្តដ៏យូរយារ ឬនឹងដឹងសច្ចធម៌ ៤ ប៉ុណ្ណោះ ដូច្នេះ និងព្រោះមានអត្ថថា ឥន្ទ្រិយ ។ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយនេះ ជាឈ្មោះរបស់ **សោតាបត្តិមគ្គញ្ញាណ** ។

ឈ្មោះថា **អញ្ញិន្ទ្រិយ** ព្រោះជាឥន្ទ្រិយដែលដឹងទូទៅ ព្រោះដឹងសច្ចធម៌ ៤ ដែលមគ្គនោះដឹងហើយ មិនកន្លងបង់ដែនខេត្តដែលបឋមមគ្គដឹងហើយ និងព្រោះអត្ថថា ឥន្ទ្រិយ ។ អញ្ញិន្ទ្រិយនេះជាឈ្មោះនៃញាណក្នុងឋានៈទាំង ៦ មានសោតាបត្តិផលញ្ញាណជាដើម ។

ឈ្មោះថា **អញ្ញាតាវិន្ទ្រិយ** ព្រោះកើតដល់ព្រះខីណាស្រពអ្នកដឹងទូទៅ ហើយមានកិច្ចក្នុងចតុសច្ចញាណស្រេចអស់ហើយ និងព្រោះអត្ថថា ឥន្ទ្រិយ ។ មយ៉ាងទៀត ឈ្មោះថា អញ្ញាតាវិន្ទ្រិយ



ព្រោះសម្រេចភាពជាធំក្នុងរវាងនៃធម៌ទាំងឡាយ ដែលព្រះខីណាស្រពអ្នកដឹងទូទៅហើយ គឺ អ្នកមានកិច្ចក្នុងសច្ចៈ ៤ ចប់ស្រេចហើយ ចាក់ធ្លុះសច្ចៈ ៤ អញ្ញាតាវិន្ទ្រិយនេះ ជាឈ្មោះ នៃអរហត្តផលញ្ញាណ ។

ឥន្ទ្រិយសូម្បីទាំងអស់ទាំងនេះ ឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថថា ប្រកាសកម្មដែលជាកំពូល ព្រោះអត្ថថា លោកអ្នកជាកំពូលសម្តែងហើយ , ព្រោះលោកអ្នកជាកំពូលឃើញហើយ , ព្រោះអត្ថថា លោកអ្នកជាកំពូលបានចាត់ចែងហើយ និងព្រោះអត្ថថា លោកអ្នកជាកំពូលសេពហើយ បណ្ឌិតគប្បីនាំទៅប្រកបតាមសមគួរ ។

ពិតហើយ ព្រះមានព្រះភាគជាម្ចាស់ ឈ្មោះថា ជាកំពូលព្រោះភាពជាអគ្គបុគ្គល និងកម្មទាំងដែលជាកុសល និងអកុសលក៏ឈ្មោះថា ជាកំពូល ព្រោះមិនមានអ្នកណាមានភាពជាធំលើសលើកម្ម ។ ព្រោះហេតុនោះហើយ ក្នុងឥន្ទ្រិយទាំងនេះ ឥន្ទ្រិយដែលកម្មឲ្យកើត រមែងប្រកាសឲ្យដឹងកុសលកម្ម និងអកុសលកម្ម , និងឥន្ទ្រិយទាំងនោះ ដែលព្រះមានព្រះភាគជាកំពូលនោះ

ទ្រង់ចាត់ចែងហើយ ដូច្នេះទើបឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា ប្រកាសកម្មដែលជាកំពូល និងព្រោះអត្ថថា លោកអ្នកជាកំពូលចាត់ចែងហើយ , មួយវិញទៀត ឥន្ទ្រិយសូម្បីទាំងអស់នោះឯង ដែលព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះអង្គជាកំពូល ទ្រង់ប្រកាសហើយ និងត្រាស់ដឹងដ៏ក្រៃលែងហើយតាមការពិត ដូច្នោះទើបឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា ព្រះអង្គជាកំពូលទ្រង់ត្រាស់សម្តែងហើយ និងព្រោះអត្ថថា ព្រះអង្គជាកំពូលទ្រង់ឃើញហើយ ។ ព្រះមានព្រះភាគជាម្ចាស់នោះឯង ជាកំពូលមុនី សេពឥន្ទ្រិយប្រភេទខ្លះ ដោយការសេពនៃភាពជាអារម្មណ៍ សេពឥន្ទ្រិយប្រភេទខ្លះ ដោយការសេពនៃភាវនា ដូច្នោះ ឈ្មោះថា **ឥន្ទ្រិយ** ព្រោះអត្ថថា ជាអគ្គបុគ្គលសេពហើយក៏មាន ។

ម្យ៉ាងទៀត ឥន្ទ្រិយទាំងនេះ ឈ្មោះថា ឥន្ទ្រិយ ព្រោះអត្ថថា ជាធំ ពោលគឺ ជាអធិបតីក៏មាន ។ ដោយភាពជាអធិបតីនៃចក្ខុជាដើម សម្រេចបានក្នុងបវត្តិកាលនៃចក្ខុវិញ្ញាណជាដើម ព្រោះកាលបើឥន្ទ្រិយចាស់ក្លា ចក្ខុវិញ្ញាណជាដើម ក៏ចាស់ក្លា កាលបើឥន្ទ្រិយនៅទន់ខ្សោយ ចក្ខុវិញ្ញាណជាដើម ក៏ទន់ខ្សោយ ដូច្នេះឯង ។



## ធាតុ ៣ ភព ៣ វោការ ៣

វិសជ្ជនា ១២ មានវិសជ្ជនាក្នុងកាមធាតុជាដើម ព្រះធម្មសេនាបតីសារីបុត្រ សម្តែងហើយដោយប្រភេទនៃភព ។

ធាតុដែលប្រកបដោយកាម ពោលគឺ កាមរាគៈ ឈ្មោះថា **កាមធាតុ** ឬធាតុ ពោលគឺ កាម ឈ្មោះថា **កាមធាតុ** ។

ធាតុ ដែលប្រកបហើយដោយរូបឈាន ឈ្មោះថា **រូបធាតុ** ព្រោះលះកាមចោលបាន ឬធាតុ ពោលគឺ រូបឈាន ឈ្មោះថា **រូបធាតុ** ។

ធាតុដែលប្រកបហើយដោយអរូបឈាន ឈ្មោះថា **អរូបធាតុ** ព្រោះលះកាមធាតុ និងរូបធាតុចេញបាន ឬធាតុ ពោលគឺ អរូបឈាន ឈ្មោះថា **អរូបធាតុ** ។

ធាតុទាំងនោះ នុ៎ះឯង លោកពោលដោយបរិយាយនៃភពតទៅទៀត ។ ពិតហើយ លោកពោលថា **ភព** ព្រោះរមែងកើត ។ ភពដែលប្រកបហើយដោយសញ្ញា ឈ្មោះថា **សញ្ញាភព** ឬភពដែលសហគតៈដោយសញ្ញា ឈ្មោះថា សញ្ញាភព សញ្ញាមាននៅក្នុងភពនេះ ដូច្នោះ ភពនេះ ទើបឈ្មោះថា **សញ្ញាភព** ។

កាមភពនោះ ១ រូបភព ដែលផុតពីអសញ្ញីភពនោះ ១ រូបភព ដែលផុតពីនេវសញ្ញានាសញ្ញាភព ១ មិនមែនសញ្ញាភព ឈ្មោះថា **អសញ្ញាភព** អសញ្ញាភពនោះ ជាឯកទេសនៃរូបភព ។

ព្រោះភាពមិនមានសញ្ញាគ្រោតគ្រាត ឈ្មោះថា **នេវសញ្ញា** ( មានសញ្ញាក៏មិនមែន ) , ព្រោះមានសញ្ញាល្អិត ឈ្មោះថា **នាសញ្ញា** ( មិនមានសញ្ញាក៏មិនមែន ) ដូច្នោះ ទើបឈ្មោះថា **នេវសញ្ញានាសញ្ញាភព** នេវសញ្ញានាសញ្ញា ភពដែលប្រកបនេវសញ្ញានាសញ្ញានោះ ឈ្មោះថា នេវសញ្ញានាសញ្ញាភព , ម្យ៉ាងទៀត ព្រោះមិនមានសញ្ញាគ្រោតគ្រាត និងព្រោះមានសញ្ញាល្អិត ឈ្មោះថា នេវសញ្ញានាសញ្ញាមាននៅក្នុងភពនេះ ដូច្នោះ ភពនេះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញាភព , នេវសញ្ញានាសញ្ញាភពនោះ ជាឯកទេសនៃអរូបភព ។

ភពដែលច្របូកច្របល់ដោយរូបក្ខន្ធ ៗ មួយ គឺ សុទ្ធទៅដោយរូបក្ខន្ធ ៗ មួយ នៃភពនោះមាន ដូច្នោះ ភពនោះ ទើបឈ្មោះថា ឯកវោការភព , ឯកវោការភពនោះជា **អសញ្ញាភព** ។

ភពដែលច្របូកច្របល់ដោយនាមក្ខន្ធ ៤ គឺ សុទ្ធទៅដោយ



នាមក្ខន្ធ ៤ នៃភពនោះមាន ដូច្នោះ ភពនោះទើបឈ្មោះថា ចតុវោការភព , ចតុវោការភពនោះ ជាអរូបភព ។

ភពដែលច្របូកច្របល់ដោយខន្ធ ៥ គឺ សុទ្ធទៅដោយខន្ធ ៥ នៃភពនោះមាន ដូច្នោះ ភពនោះទើបឈ្មោះថា បញ្ចវោការភព , បញ្ចវោការភពនោះ ជាកាមភពផង ជាឯកទេសនៃរូបភពផង ។

## ឈាន

វិសជ្ជនា ១២ មានវិសជ្ជនាក្នុងបឋមជ្ឈានជាដើម ព្រះធម្មសេនាបតីសារីបុត្រ សម្តែងដោយអំណាចនៃឈានសមាបត្តិ ។

ពាក្យថា **ឈាន** ក្នុងទីនេះប្រាថ្នាយកត្រឹមតែព្រហ្មវិហារធម៌ប៉ុណ្ណោះ ។

បឋមជ្ឈាន ប្រកបដោយវិតក្ក វិចារ បីតិ សុខ និងឯកគ្គតា ។

ទុតិយជ្ឈាន ប្រកបដោយបីតិ សុខ និងឯកគ្គតា ។

តតិយជ្ឈាន ប្រកបដោយសុខ និងឯកគ្គតា ។

ចតុត្ថជ្ឈាន ប្រកបដោយឧបេក្ខា និងឯកគ្គតា ។

ធម្មជាតិណារមែងស្និទ្ធស្នាល ស្រឡាញ់រាក់ទាក់ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **មេត្តា** អធិប្បាយថា រមែងស្នេហា ។ ម្យ៉ាងទៀត ភាពចម្រើនក្នុងមិត្រ ឬការប្រព្រឹត្តទៅនោះ នៃមិត្រមាន ដូច្នោះ ទើបឈ្មោះថា **មេត្តា** , ឈ្មោះថា **វិមុត្តិ** ព្រោះផុតពីបច្ចនិកធម៌ទាំងឡាយ និងព្រោះបង្អោនទៅក្នុងអារម្មណ៍ ភាពផុតនៃចិត្ត ឈ្មោះថា **ចេតោវិមុត្តិ** ឈ្មោះថា ចេតោវិមុត្តិ , មេត្តា គឺ ចេតោវិមុត្តិ ឈ្មោះថា **មេត្តាចេតោវិមុត្តិ** ។

**ករុណា** ក៏មានអត្ថតាមដែលពោលហើយនោះ ។

បុគ្គលប្រកបដោយធម្មជាតិនោះហើយ រមែងត្រេកអរ ឬធម្មជាតិណារមែងត្រេកអរខ្លួនឯង ឬថា ត្រឹមតែការត្រេកអរនោះ ដូច្នោះ ឈ្មោះថា **មុទិតា** ។

ធម្មជាតិណា រមែងសំឡឹងដោយការលះបង់ភាពវិបត្តិ ដោយន័យជាដើមថា សត្វទាំងឡាយទាំងពួងសូមជាអ្នកមិនមានពៀរវេរា និងដោយភាពជាកណ្ដាលដូច្នោះធម្មជាតិនោះ ឈ្មោះថា **ឧបេក្ខា** ។

ព្រហ្មវិហារ ៣ មានមេត្តាជាដើម ប្រកបដោយឈាន ៣



មានបឋមជ្ឈានជាដើម ចំណែកឧបេក្ខាព្រហ្មវិហារប្រកបដោយចតុត្ថជ្ឈាន ។

ទីបំផុតនៃអាកាសនោះ មិនមានដោយអំណាចនៃការផ្សាយទៅ ដូច្នោះ អាកាសនោះ ឈ្មោះថា **អនន្តោ** មិនមានទីបំផុត , អាកាសមិនមានទីបំផុត ឈ្មោះថា **អាកាសានន្ត** បានដល់ **កសិ-ណុគ្ឃាដិមាកាស** អាកាសដែលដកកសិណចេញ ។ អាកា-សានន្តៈនោះឯង ឈ្មោះថា **អាកាសានញ្ចំ** អាកាសានញ្ចៈនោះ ឈ្មោះថា ជាអាយតនៈ ព្រោះអត្ថថា ជាទីតាំងនៃឈាន ព្រមដោយសម្បយុត្តធម៌នោះ ដូចគ្នានឹងកន្លែងនៅរបស់ទេពទាំងឡាយ ឈ្មោះថា **ទេវាយតន** ព្រោះដូច្នោះ ទើបឈ្មោះថា អាកាសាន-ញ្ចាយតនសមាបត្តិ គឺ អាកាសានញ្ចាយតនៈនោះឯង ឈ្មោះថា **អាកាសានញ្ចាយតនសមាបត្តិ** ។

ទីបំផុតនៃវិញ្ញាណនោះមិនមាន ដោយអំណាចនៃការផ្សាយទៅ ដូច្នោះឈ្មោះថា **អនន្តំ** មិនមានទីបំផុត វិញ្ញាណមិនមានទីបំផុត មានអាកាសជាអារម្មណ៍នោះ ។ អនន្តៈនោះឯងឈ្មោះថា **អានញ្ចំ** , វិញ្ញាណមិនមានទីបំផុត លោកមិនពោលថា **វិញ្ញា-**

**ណានញ្ច** តែពោលថា **វិញ្ញាណញ្ច** ។ ក៏ស័ព្ទនេះ ក្នុងទីនេះ ជារុឡ្ហីស័ព្ទ គឺ ជាស័ព្ទដែលនិយមប្រើ ។

វិញ្ញាណញ្ចៈនោះ ជាអាយតនៈ ព្រោះអត្ថថា ជាទីតាំងនៃឈានព្រមដោយសម្បយុត្តធម៌នោះ ដូចគ្នានឹងកន្លែងទេពទាំងឡាយ ហៅថា ទេវាយតនៈ ព្រោះដូច្នោះ ទើបឈ្មោះថា **វិញ្ញាណញ្ចាយតន** ។

**ឈាន** ឈ្មោះថា **អាកិញ្ចន** ព្រោះមិនមានអ្វីសូម្បីបន្តិចបន្តួច មានអធិប្បាយថា សូម្បីនៅទីបំផុត គ្រាន់តែកវង្គខណៈក៏មិនមានសល់ ។ ភាវៈនៃអាកិញ្ចនៈ ឈ្មោះថា **អាកិញ្ចញ្ញ** ។ ពាក្យនេះ ជាឈ្មោះរបស់ឈានដែលមិនមានអាកាសានញ្ចាយតនៈជាអារម្មណ៍ ។ អាកិញ្ចញ្ញៈនោះ ជាអាយតនៈ ព្រោះជាទីតាំងនៃឈាន និងសម្បយុត្តធម៌ទាំងនោះ ។ ដូចគ្នានឹងកន្លែងនៅរបស់ទេពទាំងឡាយ ហៅថា ទេវាយតនៈ ព្រោះដូច្នោះ ទើបហៅថា **អាកិញ្ចញ្ញាយតន** ។

សញ្ញានៃឈាន ព្រមដោយសម្បយុត្តធម៌នោះមិនមាន មិនមានសញ្ញាក៏មិនមែន ព្រោះមិនមានសញ្ញាគ្រោតគ្រាត មាន



តែសញ្ញាល្អិត ដូច្នោះឈ្មោះថា **នេវសញ្ញានាសញ្ញា** , នេវសញ្ញានាសញ្ញានោះផង ជាអាយតនៈផង ព្រោះរាប់បន្តដោយមនាយតនៈ និងធម្មាយតនៈ ដូច្នោះទើបឈ្មោះថា **នេវសញ្ញានាសញ្ញាយតន** ។

ន័យមួយទៀត សញ្ញាក្នុងឈាននេះ ឈ្មោះថា ជាសញ្ញាមិនមែន ព្រោះមិនអាចធ្វើកិច្ចសញ្ញាឲ្យច្បាស់លាស់បាន , និងឈ្មោះថា មិនមានសញ្ញាក៏មិនមែន ព្រោះនៅមានសង្ខារធម៌ដែលនៅសល់ ជាសុខុមភាព ដូច្នោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញា , នេវសញ្ញានាសញ្ញានោះផង ជាអាយតនៈផង ព្រោះអត្ថថា ជាទីតាំងនៃធម៌ដ៏សេស ដូច្នោះ ទើបឈ្មោះថា នេវសញ្ញានាសញ្ញាយតនៈ ។ ពាក្យនេះ ជាឈ្មោះនៃសមាបត្តិ ដែលមានអាកិញ្ចញ្ញាយតនៈជាអារម្មណ៍ ។

មួយទៀត ក្នុងឈាននេះ មិនមែនសញ្ញាយ៉ាងនេះតែម្យ៉ាង សូម្បីវេទនា ក៏ឈ្មោះថា **នេវវេទនានាវេទនា** មានវេទនាក៏មិនមែន មិនមានវេទនាក៏មិនមែន ។ សូម្បីចិត្តក៏ឈ្មោះថា **នេវចិត្តនាចិត្ត** មានចិត្តក៏មិនមែន មិនមានចិត្តក៏មិនមែន ។ ឯផស្សៈ

ក៏ឈ្មោះថា **នេវផស្សនាផស្ស** មានផស្សៈក៏មិនមែន មិនមានផស្សៈក៏មិនមែន ក្នុងសម្បយុត្តធម៌ដ៏សេស ក៏មានន័យយ៉ាងនេះ តែទេសនានេះ លោកពោលដោយចំណងជើងថា **សញ្ញា** ។

## បច្ចយាការ ១២

វិសជ្ជនា ១២ មានវិសជ្ជនាក្នុងអវិជ្ជាជាដើម ព្រះធម្មសេនាបតីសារីបុត្រ សម្ដែងដោយអង្គនៃបដិច្ចសមុប្បាទ ។

កាយទុច្ចរិតជាដើម ឈ្មោះថា **អវិន្ទិយ** សេចក្ដីថា មិនគួរបាន ព្រោះអត្ថថា មិនគួរបំពេញ ។ ធម្មជាតិណា រមែងបាននូវអវិន្ទិយៈនោះ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **អវិជ្ជា** ។

កាយសុចរិតជាដើម ឈ្មោះថា **វិន្ទិយ** គួរបាន ព្រោះផ្ទុយគ្នានឹងអវិន្ទិយៈនោះ ធម្មជាតិណា រមែងបាននូវវិន្ទិយៈនោះ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **អវិជ្ជា** ។

ធម្មជាតិណាធ្វើអត្ថ គឺ កងនៃខន្ធទាំងឡាយមិនឲ្យប្រាកដ , ធ្វើអត្ថ គឺ ការតនៃអាយតនៈទាំងឡាយមិនឲ្យប្រាកដ , ធ្វើអត្ថ គឺ



ភាពទំនេរនៃធាតុទាំងឡាយមិនឲ្យប្រាកដ , ធ្វើអត្ថ គឺ ភាពជាធំនៃឥន្ទ្រិយទាំងឡាយមិនឲ្យប្រាកដ ធ្វើអត្ថ គឺ ការបម្រើននៃសច្ចៈទាំងឡាយមិនឲ្យប្រាកដ ដូច្នោះធម្មជាតិនោះ ឈ្មោះថា **អវិជ្ជា** , ធ្វើអត្ថ ៤ យ៉ាង ដែលពោលហើយដោយអំណាចនៃការបៀតបៀនជាដើម នៃសច្ចៈទាំងឡាយ មានទុក្ខសច្ចជាដើម ដូច្នោះទើបឈ្មោះថា **អវិជ្ជា** ។

ធម្មជាតិណា រមែងញុំាងសត្វទាំងឡាយឲ្យស្ទុះទៅក្នុង កំណើត គតិ ភព វិញ្ញាណឋិតិ និងសត្តាវាសទាំងពួង ក្នុងសង្សារវដ្ដដែលមិនមានទីបំផុត ដូច្នោះធម្មជាតិនោះ ទើបឈ្មោះថា **អវិជ្ជា** ។

ធម្មជាតិណា រមែងស្ទុះទៅក្នុងបញ្ញត្តិទាំងឡាយ មានស្រីនិងប្រុសជាដើម ដែលមិនមានដោយបរមត្ថ , មិនស្ទុះទៅ សូម្បីក្នុងវិជ្ជមានបញ្ញត្តិ មានខន្ធជាដើម ដូច្នោះ ធម្មជាតិនោះទើបឈ្មោះថា **អវិជ្ជា** ។

ម្យ៉ាងទៀត ឈ្មោះថា **អវិជ្ជា** ព្រោះបិទបាំងនូវវត្ថុ និងអារម្មណ៍នៃវិញ្ញាណ មានចក្ខុវិញ្ញាណជាដើម និងធម៌ទាំងឡាយដែលជាបដិច្ចសមុប្បាទ និងដែលជាបដិច្ចសមុប្បន្នៈ ។

ធម្មជាតិណា រមែងតាក់តែងនូវសង្ខតធម៌ ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **សង្ខារ** ។

ធម្មជាតិណា រមែងដឹងនូវអារម្មណ៍ផ្សេង ៗ បាន ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **វិញ្ញាណ** ។

ធម្មជាតិណា រមែងដឹងអារម្មណ៍ ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **នាម** , ម្យ៉ាងទៀត ធម្មជាតិណា រមែងបង្អោនទៅកាន់អារម្មណ៍ ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **នាម** , ធម្មជាតិណា រមែងបែកធ្លាយទៅ ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **រូប** ។

ធម្មជាតិណា រមែងផ្សាយទៅក្នុងចិត្ត និងចេតសិកដែលជាទីកើត និងនាំទៅកាន់សង្សារទុក្ខដែលអូសបន្លាយតទៅ ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **អាយតន** ។

ធម្មជាតិណា រមែងប៉ះត្រូវ ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **ផស្ស** ។

ធម្មជាតិណា រមែងសោយអារម្មណ៍ ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **វេទនា** ។



ធម្មជាតិណា រមែងចង់បានក្នុងអារម្មណ៍ ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **តណ្ហា** ។

ធម្មជាតិណា រមែងចូលទៅប្រកាន់ក្នុងអារម្មណ៍ គឺ រមែងប្រកាន់ទុកយ៉ាងមាំ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **ឧបាទាន** ។

ធម្មជាតិណា រមែងមាន គឺ រមែងកើត ដូច្នោះ ធម្មជាតិនោះ ទើបឈ្មោះថា **ភព** ។

ការកើត ឈ្មោះថា **ជាតិ** ។

ការចាស់ ឈ្មោះថា **ជរា** ។

សត្វទាំងឡាយ រមែងស្លាប់ដោយធម្មជាតិនោះ ដូច្នោះ ធម្មជាតិនោះ ឈ្មោះថា **មរណ** ។

## អដ្ឋកថា ទុក្ខសច្ចជាដើម

ព្រះសារីបុត្ត បានលើកឡើងសំដែងដល់ការវិសជ្ជនា ៨០៨ ប្រការ មានទុក្ខជាដើម ដោយប្រកបចូលគ្នាជាមួយនឹងអរិយសច្ច ៤ ។ ព្រះសារីបុត្តពោលប្រមូលការវិសជ្ជនា ២៤ យ៉ាង ដោយចតុក្កៈ ៦ ទុកក្នុងបទនេះ មានជាអាទិ៍ថា **ទុក្ខំ អភិញ្ញេយ្យំ** ទុក្ខគួរ

ដឹងដ៏ក្រៃលែង ដោយការវិសជ្ជនា ១៩៥ មានជាអាទិ៍ថា **ទុក្ខំ អភិញ្ញេយ្យំ សោតំ អភិញ្ញេយ្យំ** ... ចក្ខុ , សោតៈ គួរដឹងដ៏ក្រៃលែងក្នុងបេយ្យាល ( មួយពាក្យ ៗ ) ថា **ចក្ខុំ ។បេ។ ជរាមរណំ** -ចក្ខុ ។ល។ ជរាមរណៈ ទើបបាន ១៩៥ ចតុក្កៈ ។ ដោយអំណាចរបស់ចតុក្កៈទាំងនោះ ទើបជាការវិសជ្ជនា ៧៨០ ។ ក្នុងចតុក្កៈមានជាអាទិ៍ថា **ជរាមរណំ អភិញ្ញេយ្យំ** ជរាមរណៈគួរដឹងដ៏ក្រៃលែង ទាំងអស់ទើបជាការវិសជ្ជនា ៨០៨ ប្រការ ដោយប្រការដូច្នេះថា **ចត្តារិ វិសជ្ជនានិ** ការវិសជ្ជនា ៤ ប្រការ ។

ក្នុងការវិសជ្ជនានេះ គប្បីជ្រាបថា បច្ច័យដែលជាប្រធានរបស់ធម៌នោះ ៗ ជាសមុទ័យ , និព្វានសូន្យចាកសង្ខារទាំងពួងជានិរោធ ។ ក្នុងអធិការនេះ បទមានជាអាទិ៍ថា **អនញ្ញាតញ្ញស្សាមីតិន្ទ្រិយនិរោធោ** ការរលត់ឥន្ទ្រិយ៍ គឺ អធ្យាស្រ័យ ដែលមានបំណងសម្រេចមគ្គផលរបស់អ្នកបដិបត្តិ សំដៅដល់ ការមិនមានឥន្ទ្រិយ៍ដែលជាលោកុត្តរៈ ៣ ប្រការ មានអនញ្ញាតញ្ញស្សាមីតិន្ទ្រិយ៍ជាដើម ត្រឹមត្រូវ ។ បទថា **និរោធគាមិនីបដិបទា** ក្នុងគ្រប់កន្លែងជាអរិយមគ្គនោះឯង ។ សូម្បីកាល លោកពោលដល់



ផលយ៉ាងនេះទុកថា **អញ្ញិន្ទ្រិយ៍** ( ឥន្ទ្រិយ៍ គឺ ការត្រាស់ដឹងសច្ចធម៌ដោយមគ្គ ) **អញ្ញាតាវិន្ទ្រិយ៍** ( ឥន្ទ្រិយ៍របស់ព្រះអរហន្តដែលត្រាស់ដឹងសច្ចធម៌ហើយ ) រមែងត្រឹមត្រូវ ព្រោះមានឈ្មោះហៅថា មគ្គ , ព្រះសារីបុត្តបានចង្អុលបង្ហាញដល់ការវិសជ្ជនា ៨០៨ ប្រការ ដោយសភាពដែលគួរកំណត់ដឹងទុក្ខជាដើមតទៅ ។ លោកបានចង្អុលបង្ហាញការវិសជ្ជនា ៨០៨ ប្រការ ដោយសភាពដែលចាក់ធ្លុះ អាស្រ័យការកំណត់ដឹងទុក្ខ ជាដើមទៀត ។ ការកំណត់ដឹង និងការចាក់ធ្លុះដោយសភាពដែលគួរចាក់ធ្លុះ ឈ្មោះថា **បរិញ្ញាបដិវេធ** ។ អត្ថ គឺ បរិញ្ញាបដិវេធនោះឯង ឈ្មោះថា **បរិញ្ញាបដិវេធដ្ឋោ** សភាពដែលចាក់ធ្លុះដោយការកំណត់ដឹង ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ១.៦១៦ ប្រការ មានទុក្ខជាដើម មានជរាមរណៈជាទីបំផុត តទៅដោយ ២០២ អដ្ឋកៈ ប្រកបជាមួយបទ មួយ ៗ ៧ បទ មានសមុទ័យជាដើម ។

ក្នុងអធិការនោះ បច្ច័យដែលជាប្រធាន គឺ សមុទ័យ , ការរលត់សមុទ័យនោះ គឺ **សមុទយនិរោធ** ។ សេចក្ដីប្រាថ្នា គឺ

ការពេញចិត្ត គឺ **ឆន្ទរាគ** , សេចក្តីប្រាថ្នា គឺ ការពេញចិត្តក្នុងទុក្ខ ដោយសំគាល់ក្នុងទុក្ខ ថាជាសុខ , សេចក្តីរលត់ឆន្ទរាគៈនោះ គឺ **ឆន្ទរាគនិរោធ** ។ សុខសោមនស្សកើតឡើង ព្រោះអាស្រ័យទុក្ខ គឺ សេចក្តីត្រេកអរក្នុងទុក្ខ ។ ភាពមិនទៀងនៃទុក្ខ ភាពប្រែប្រួលជាធម្មតានៃទុក្ខ គឺ ទោសនៃទុក្ខ ។ ការនាំចេញនូវឆន្ទរាគៈ ការលះបង់ឆន្ទរាគៈក្នុងទុក្ខ គឺ ឧបាយជាគ្រឿងរលាស់ចេញចាកទុក្ខ ។ និព្វាននោះឯង គឺ ឧបាយជាគ្រឿងរលាស់ចេញចាកទុក្ខ ព្រោះបាលីថា **យំ ខោ បន កិញ្ចិ ភូតំ សង្ខតំ បដិច្ចសមុប្បន្នំ និរោធោ តស្ស និស្សរណំ** និរោធជាគ្រឿងរលាស់ចេញចាកសង្ខតធម៌ ដែលកើតឡើងហើយណាមួយ ដែលអាស្រ័យគ្នានឹងគ្នាកើតឡើង ។ គប្បីជ្រាបថា លោកពោលដល់និព្វាន ក្នុងឋានៈ ៤ យ៉ាង ដោយពាក្យដែលមានបរិយាយផ្សេង ៗ ដោយផ្ទុយគ្នាជាមួយនឹងសង្ខតធម៌ផ្សេង ៗ ថា ការរលត់ទុក្ខ , ការរលត់សមុទ័យ , ការរលត់ឆន្ទរាគៈ , ឧបាយគ្រឿងរលាស់ចេញចាកទុក្ខ ១ , ចំណែកអាចារ្យពួកខ្លះពោលថា ព្រោះអាហារជាដើមហេតុ ទុក្ខទើបកើត ព្រោះរលត់



អាហារ ទុក្ខទើបរលត់ ការរលត់សមុទ័យ ដោយអំណាចការប្រព្រឹត្តទៅជាមួយដោយកិច្ច **កិច្ចរស** , មយ៉ាងទៀត ការរលត់សមុទ័យ ដោយការឃើញការកើត និងការរលត់ មគ្គព្រមដោយវិបស្សនា ជាការរំលត់ឆន្ទរាគៈ , បើលោកពោលយ៉ាងនេះ គប្បីប្រកាន់យកន័យដែលពោលទុកជាដើមដំបូងថា មិនមែនជាសព្វ-សាធារណៈ ព្រោះឥន្ទ្រិយ៍ដែលជាលោកុត្តរៈមិនទាន់ចូលដល់វិប-ស្សនា ។ ន័យដែលលោកពោលថា ការរលត់ឆន្ទរាគៈ ព្រោះមិនមានឆន្ទរាគៈក្នុងឥន្ទ្រិយ៍ដែលជាលោកុត្តរៈនោះឯង ទើបត្រឹមត្រូវ ។ ជាការធ្វើឆន្ទរាគៈ សូម្បីក្នុងសក់ជាដើម ដែលជាចំណែកមួយរបស់សរីរៈដោយតម្រេក គឺ សេចក្តីពេញចិត្តក្នុងសរីរៈនោះឯង ។ ជាការធ្វើឆន្ទរាគៈ សូម្បីក្នុងជរា និងមរណៈដោយតម្រេក គឺ សេចក្តីពេញចិត្តក្នុងការមានជរា និងមរណៈដោយពិត គប្បីប្រកបសូម្បីសេចក្តីពេញចិត្ត និងទោសទុកយ៉ាងនេះផង ។ ព្រះសារីបុត្តបានចង្អុលដល់ការវិសជ្ជនា ១.៤១៤ ន័យ មាន ២០២ បទ មានទុក្ខជាដើម មានជរាមរណៈជាទីបំផុតតទៅ ដោយ ២០២ សត្តកៈប្រកបដោយបទមួយ ៗ ៦ មានសមុទ័យជាដើម ។

ឥឡូវនេះ ដើម្បីសំដែងប្រកបបទ ២០១ បទ មានរូបជាដើម មានជរាមរណៈជាទីបំផុត ដោយអនុបស្សនា ៧ ទើបព្រះសារីបុត្តបង្ហាញអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើមមុន ។ ទាំងអស់នោះ ជាវិសជ្ជនា ១.៤១៤ ន័យ ព្រមទាំងការវិសជ្ជនាអនុបស្សនាសុទ្ធ ៧ ប្រការ ។ ការពិចារណាឃើញថា មិនទៀង គឺ **អនិច្ចានុបស្សនា** ។ អនិច្ចានុបស្សនានោះ ជាបដិបក្ខដល់ **និច្ចសញ្ញា** ការសំគាល់ថាទៀង ។ ការពិចារណាឃើញថា ជាទុក្ខ គឺ **ទុក្ខានុបស្សនា** ។ ទុក្ខានុបស្សនានោះ ជាបដិបក្ខដល់ **សុខសញ្ញា** ការសំគាល់ថាជាសុខ ។ ការពិចារណាឃើញថា ជាអនត្តា គឺ **អនត្តានុបស្សនា** ។ អនត្តានុបស្សនានោះ ជាបដិបក្ខដល់ **អត្តសញ្ញា** ការសំគាល់ថាជាអត្តា ។ ព្រះយោគាវចរ រមែងនឿយណាយ ព្រោះអនុបស្សនា ៣ បរិបូរណ៍ ដូច្នោះទើប ឈ្មោះថា **និព្វិទា** , និព្វិទានោះផង អនុបស្សនាផង ឈ្មោះថា **និព្វិទានុបស្សនា** , និព្វិទានុបស្សនានោះ ជាបដិបក្ខដល់សេចក្តីភ្លើតភ្លើន ។ ព្រះយោគាវចរ រមែងប្រាសចាកតម្រេក ព្រោះអនុបស្សនា ៤ បរិបូរណ៍ ទើបឈ្មោះថា



**វិរាគោ** , វិរាគៈនោះផង អនុបស្សនានោះផង ឈ្មោះថា **វិរាគានុបស្សនា** ។ វិរាគានុបស្សានានោះ ជាបដិបក្ខដល់រាគៈ ។ ព្រះយោវចរ រមែងរំលត់រាគៈចេញបាន ព្រោះអនុបស្សនា ៥ បរិបូរណ៍ ទើបឈ្មោះថា **និរោធោ** ។ និរោធនោះផង អនុបស្សនាផង ឈ្មោះថា **និរោធានុបស្សនា** និរោធានុបស្សនានោះ ជាបដិបក្ខដល់សមុទ័យ ។ ព្រះយោគាវចរ រមែងកម្ចាត់ភាពងងឹតចេញបាន ព្រោះអនុបស្សនា ៦ បរិបូរណ៍ ទើបឈ្មោះថា **បដិនិស្សគ្គោ** ។ បដិនិស្សគ្គៈនោះផង អនុបស្សនាផង ឈ្មោះថា **បដិនិស្សគ្គានុបស្សនា** ។ បដិនិស្សគ្គានុបស្សនានោះ ជាបដិបក្ខដល់ការប្រកាន់មាំ ។ កាលបើឥន្ទ្រិយ៍ជាលោកុត្តរៈ ចូលដល់វិបស្សនា គប្បីជ្រាបថា លោកប្រកបអនុបស្សនា ៧ ទុកដោយធម៌សូម្បីទាំងនោះ ដោយពិចារណាឃើញថា ឈ្មោះថា មាននិរោធ ព្រោះ មិនមានសេចក្តីភ្លើតភ្លើន និងសេចក្តីប្រាថ្នាក្នុងវត្ថុដែលសំគាល់ថាទៀង ជាសុខ ជាតួខ្លួន ព្រោះវត្ថុទាំងនោះជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ដូចបាលីថា **សព្វេ សង្ខារា អនិច្ចា** , **សព្វេ សង្ខារា ទុក្ខា** , **សព្វេ ធម្មា អនត្តា** សង្ខារទាំងឡាយ

ទាំងពួងមិនទៀង សង្ខារទាំងពួងជាទុក្ខ , ធម៌ទាំងឡាយជាអនត្តា និងព្រោះមានការលះបង់ដោយការបរិច្ចាគ ការលះបង់ ដោយការស្ទុះទៅ ។ កាលបើអ្នកមានជរាមរណៈ ដែលខ្លួនឃើញហើយថា ជារបស់មិនទៀងជាដើម ក៏បានឈ្មោះថា ឃើញសូម្បីជរាមរណៈ ថាជារបស់មិនទៀងជាដើម , កាលនឿយណាយ ក៏ប្រាសចាកតម្រេកក្នុងជរាមរណៈ ដែលមានហើយ ជាការនឿយណាយ និងប្រាសចាកតម្រេកក្នុងជរាមរណៈ កាលបើមានជរាមរណៈ ដែលឃើញហើយដោយនិរោធ មានឈ្មោះថា ឃើញសូម្បីជរាមរណៈ ដោយនិរោធ កាលលះបង់ក្នុងជរាមរណៈដែលមានហើយ រមែងជាការលះបង់ជរាមរណៈ ដោយពិត គប្បីជ្រាបថា លោកប្រមូលអនុបស្សនា ៧ ដោយជរាមរណៈ ដោយប្រការដូច្នេះ ។

ឥឡូវនេះ ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ១៥ ប្រការ ដែលជាវេវចនៈរបស់ធម៌ទាំងនោះ មាន **ឧប្បាទោ** ការកើតឡើងជាដើម និងដោយអារម្មណ៍ ៥ មាន **ឧប្បាទោ** ជាដើម ដែលជាវត្ថុនៃ **អាទីនវញ្ញាណ** សេចក្ដីដឹងថាជាទោស , បង្ហាញការវិសជ្ជនា ១៥ ប្រការ មាន **អនុប្បាទោ** ជាដើម ដោយ



អារម្មណ៍ដែលជាបដិបក្ខនៃធម៌នោះ នៃ **សន្តិបទញ្ញាណ** ការដឹងផ្លូវនៃសន្តិ , បង្ហាញការវិសជ្ជនា ៣០ ប្រកបបទ មានឧប្បាទៈ និងអនុប្បាទៈជាដើមទាំងនោះតទៅ ជាគូគ្នា ដោយប្រការដូច្នេះ ទើបវិសជ្ជនាបាន ៦០ ក្នុងន័យនេះឯង ។

ក្នុងបទទាំងនោះ បទថា **ឧប្បាទោ** ការកើតឡើង បានដល់ការកើតក្នុងភពនេះ ព្រោះកម្មមុនជាបច្ច័យ ។

បទថា **បវត្តំ** ការប្រព្រឹត្តទៅ បានដល់ ការប្រព្រឹត្តទៅនៃការកើតយ៉ាងនោះ ។

បទថា **និមិត្តំ** គ្រឿងសម្គាល់ បានដល់ គ្រឿងសម្គាល់សង្ខារទាំងអស់ ។ ព្រោះសង្ខាររបស់ព្រះយោគាវចរ រមែងប្រាកដដូចមានទ្រង់ទ្រាយ ដូច្នោះ លោកទើបពោលថា **និមិត្តំ** ។

បទថា **អាយូហនា** ការប្រមូលមក បានដល់ កម្ម ដែលជាហេតុនៃបដិសន្ធិតទៅ ព្រោះថា កម្មនោះលោកហៅថា **អាយូហនា** ព្រោះអត្ថថា តាក់តែងបដិសន្ធិ ។

បទថា **បដិសន្ធិ** បានដល់ កើតតទៅ ។ ការកើតនោះលោកហៅថា បដិសន្ធិ ព្រោះបន្តគ្នាក្នុងរវាងភព ។

បទថា **គតិ** ការទៅ បានដល់ បដិសន្ធិ ដែលលោកហៅថា គតិ ព្រោះសត្វត្រូវទៅ ។

បទថា **និព្វត្តិ** ការបង្កើត បានដល់ ការកើតនៃខន្ធទាំងឡាយ ។

បទថា **ឧប្បត្តិ** ឧប្បត្តិ បានដល់ ការប្រព្រឹត្តទៅនៃវិបាក ដែលលោកពោលទុកយ៉ាងនេះថា **សមាបន្នស្ស វា ឧបបន្នស្ស វា** ធម៌ គឺ ចិត្ត និងចេតសិករបស់អ្នកចូលដល់ហើយ ឬអ្នកឧប្បត្តិហើយ ។

បទថា **ជាតិ** ការកើត បានដល់ ការប្រាកដគ្រាដំបូងនៃខន្ធរបស់សត្វទាំងឡាយអ្នកកើតក្នុងភពនោះ ៗ ។

បទថា **ជរា** ការទ្រុឌទ្រោម អធិប្បាយថា ជរានោះមាន ២ យ៉ាង គឺ **សន្តតលក្ខណ** ដែលបានដល់លក្ខណៈនៃទីតាំងនៅនិងភាពយ៉ាងដទៃ ១ , ភពចាស់នៃខន្ធដែលទាក់ទងក្នុងភពមួយក្នុងសន្តតិដែលធ្វើឲ្យដឹងថា ធ្មេញបាក់ជាដើម ១ ។ ក្នុងទីនេះ លោកបំណងយកជរានោះ ។

បទថា **ព្យាធិ** ការឈឺចាប់ បានដល់ អាពាធ ៨ យ៉ាង



ដែលតាំងឡើងព្រោះធាតុកំរើកជាបច្ច័យ គឺ ប្រម៉ាត់ ១ ស្លេស ១ ខ្យល់ ១ ប្រជុំជំងឺ ១ ការប្រែប្រួលរដូវ ១ ការប្រព្រឹត្តទៅនៃរាងកាយមិនស្មើ ១ ព្យាយាមខ្លាំងពេក ១ វិបាករបស់កម្ម ១ ។

ឈ្មោះថា **ព្យាធិ** ព្រោះទុក្ខច្រើនយ៉ាង ដុតរោល រួបរិត ឬព្រោះទុក្ខបៀតបៀនឲ្យក្តៅក្រហាយ ញាប់ញ័រ ។

បទថា **មរណំ** គឺ ព្យាធិជាហេតុឲ្យស្លាប់ មរណៈនោះ មាន ២ យ៉ាង គឺ **សន្តតលក្ខណ** ដែលមានសេចក្តីវិនាស ជាលក្ខណៈ ១ , ការកាត់ផ្តាច់ទំនាក់ទំនងគ្នានៃជីវិតិន្ទ្រីយ៍ ដែលរាប់ចូលក្នុងភពមួយ ១ ។ ក្នុងទីនេះ លោកបំណងយកមរណៈនោះ ។

បទថា **សោកោ** គឺ ការស្ងិតស្រពោននៃចិត្ត បានដល់ ភាពក្តៅក្រហាយចិត្ត របស់អ្នកដែលត្រូវសេចក្តីវិនាសចាកញាតិ សម្បត្តិ រោគ សីល និងទិដ្ឋិ ប៉ះខ្ទប់ ។

បទថា **បរិទេវោ** គឺ សភាពទួញយំត្អូញត្អែរ បានដល់ ការពោលរៀបរាប់ របស់អ្នកត្រូវសេចក្តីវិនាសចាកញាតិជាដើម ប៉ះខ្ទប់ ។

បទថា **ឧបាយាសោ** គឺ សេចក្តីចង្អៀតចង្អល់ចិត្ត បានដល់

ទោសៈ ដែលកើតពីទុក្ខដ៏ធ្ងន់របស់អ្នកដែលត្រូវសេចក្តីវិនាសចាកញាតិជាដើម ប៉ះខ្ទប់ ។

ក្នុងនិទ្ទេសនេះ លោកពោលអភិញ្ញេយ្យធម៌ ៥ មាន **ឧប្បាទោ** ជាដើម ដោយអំណាចជាវត្ថុនៃអាទីនវញ្ញាណ , ដ៏សេសលោកពោលដោយអំណាចជាវេវចនៈ របស់អភិញ្ញេយ្យធម៌ទាំង-នោះ , បទថា **និព្វត្តិ** ជាវេវចនៈរបស់ **ឧប្បាទោ** ។ បទថា **ជាតិ** ជាវេវចនៈរបស់ **បដិសន្ធិ** ។ ពីរបទថា **គតិ ឧប្បត្តិ** ជាវេវចនៈរបស់ **បវត្តំ** , **ជរា** ជាដើម ជាវេវចនៈរបស់ **និមិត្តំ** ។ លោកពោលនិព្វានប៉ុណ្ណោះ ដោយពាក្យមាន **អនុប្បាទោ** ការមិនកើតឡើងជាដើម ។ ព្រះសារីបុត្តចង្អុលបង្ហាញបទ ៦០ មាន **ឧប្បាទ** និង **អនុប្បាទ** ជាដើម ការវិសជ្ជនា ៦០ ប្រកបដោយបទថា ដោយទុក្ខ និងសុខ , ការវិសជ្ជនា ៦០ ប្រកបដោយបទថា ដោយភ័យ និងការផុតចាកភ័យ , ការវិសជ្ជនា ៦០ ប្រកបដោយបទថា ដោយសាមិស ( គ្រឿងបញ្ឆោត ) និង និរាមិស ( មិនមានគ្រឿងបញ្ឆោត ) , ការវិសជ្ជនា ៦០ ប្រកបដោយបទនៃសង្ខារ និងនិព្វាន ។ ក្នុងបទទាំងនោះ បទថា



**ទុក្ខំ** ជាទុក្ខ អធិប្បាយថា ឈ្មោះថា **ទុក្ខ** ព្រោះជារបស់មិនទៀង ។ ឈ្មោះថា **សុខ** ព្រោះផ្ទុយគ្នាជាមួយនឹងទុក្ខ ។ វត្ថុណាជាទុក្ខ វត្ថុនោះជាភ័យ ។ ឈ្មោះថា **ខេម** ការផុតចាកភ័យ ព្រោះផ្ទុយគ្នាជាមួយនឹងភ័យ ។ វត្ថុណាជាភ័យ វត្ថុនោះឈ្មោះថាជា **សាមិស** ( មានគ្រឿងបញ្ឆោត ) ព្រោះមិនផុតចាកវដ្តាមិស និងលោកាមិស , ឈ្មោះថា និរាមិស ( មិនមានគ្រឿងបញ្ឆោត ) ព្រោះផ្ទុយគ្នាជាមួយនឹងសាមិស ។ វត្ថុណាជាសាមិស វត្ថុនោះក៏ត្រឹមតែជាសង្ខារប៉ុណ្ណោះ ។ ឈ្មោះថានិព្វាន ព្រោះស្ងប់ចាកវត្ថុផ្ទុយគ្នាជាមួយនឹងសង្ខារ ។ ព្រោះសង្ខារជារបស់ក្តៅ និព្វានជារបស់ស្ងប់ ។ គប្បីជ្រាបថា លោកពោលទុកយ៉ាងនោះ ព្រោះសំដៅដល់ការប្រព្រឹត្តទៅដោយអាការនោះ ៗ យ៉ាងនេះថា ដោយអាការជាដែលទុក្ខ ដោយអាការដែលជាភ័យ ដោយអាការដែលជាសាមិៈស ដោយអាការដែលជាសង្ខារ ដោយប្រការដូច្នេះ ។

( ចប់អដ្ឋកថា បឋមភាណវារ )

## អដ្ឋកថា ទុតិយភាណវារ

ព្រះសារីបុត្តបានចង្អុលបង្ហាញដល់ការវិសជ្ជនា ៣១ ប្រការ មាន **បរិគ្គហដ្ឋោ** សភាពនៃធម៌ដែលគួរកំណត់កាន់យកជាដើម ដោយខណៈនៃអរិយមគ្គ ។ ពិតហើយ ធម៌ទាំងឡាយដែលសម្បយុត្តដោយអរិយមគ្គ រមែងកំណត់កាន់យកដើម្បីកើតឡើងតាំងតែពីដើម ព្រោះហេតុនោះទើបឈ្មោះថា **បរិគ្គហា** កំណត់កាន់យក ។ សភាពនៃធម៌ទាំងនោះ ឈ្មោះថា **បរិគ្គហដ្ឋោ** សភាពនៃធម៌ដែលគួរកំណត់កាន់យក ។ សភាពនៃធម៌ ឈ្មោះថា **បរិវារដ្ឋោ** សភាពនៃធម៌ដែលជាបរិវារ ព្រោះធម៌ទាំងនោះ ជាបរិវារដល់គ្នានឹងគ្នា ។ សភាពនៃធម៌ ឈ្មោះថា **បរិបូរដ្ឋោ** សភាពនៃធម៌ដែលពេញល្អ ដែលបរិបូរណ៍ដោយភាវនា ។ សភាពនៃធម៌ឈ្មោះថា **ឯកគ្គដ្ឋោ** សភាពនៃសមាធិ ដែលមានអារម្មណ៍តែមួយ ព្រោះសម្លឹងកំណត់កាន់យកអារម្មណ៍តែមួយ ។ សភាពនៃធម៌ ឈ្មោះថា **អវិក្ខេបដ្ឋោ** សភាពនៃសមាធិមិនមានការរាយមាយ ព្រោះសម្លឹងដល់ការមិនរាយមាយក្នុងអារម្មណ៍ផ្សេង ៗ ។ សភាពនៃធម៌ ឈ្មោះថា **បគ្គហដ្ឋោ** សភាពនៃធម៌ដែលផ្គងទុក គឺ ផ្គងទុក



ដោយសេចក្ដីព្យាយាម ។ សភាពនៃ ធម៌ឈ្មោះថា **អវិសារដ្ឋោ** សភាពនៃធម៌ដែលមិនរាយមាយទៅ ព្រោះមិនរាយមាយទៅ ដោយអំណាចនៃសមាធិ ដូចលាបម្សៅក្រោយពេលងូតទឹក មិនខ្ចាត់ខ្ចាយទៅដោយទឹកដូច្នោះ ។ សភាពនៃធម៌ ឈ្មោះថា **អនាវិលដ្ឋោ** សភាពនៃចិត្តមិនល្អក់កករ ព្រោះមិនល្អក់កករ ដោយការប្រកបសេចក្ដីព្យាយាម ។ សភាពនៃធម៌ ឈ្មោះថា **អនិញ្ជនដ្ឋោ** សភាពនៃចិត្តមិនញាប់ញ័រ ព្រោះមិនកម្រើក ។

បទថា **ឯកត្តុបដ្ឋានវសេន** ដោយអំណាចនៃសេចក្ដីប្រាកដនៃចិត្តមានអារម្មណ៍តែមួយ បានដល់ ដោយការប្រកបសមាធិ និងដោយអំណាចនៃការតាំងនៅក្នុងអារម្មណ៍តែមួយយ៉ាងមុតមាំ ។

បទថា **ឋិតដ្ឋោ** សភាពនៃចិត្តតាំងនៅ បានដល់ តាំងនៅដោយមិនញាប់ញ័រក្នុងអារម្មណ៍ ។ សភាពនៃធម៌ ឈ្មោះថា **អារម្មណដ្ឋោ** សភាពនៃធម៌ជាអារម្មណ៍ ព្រោះកាន់យកនិព្វានជាអារម្មណ៍ ។ សភាពនៃធម៌ ឈ្មោះថា **គោចរដ្ឋោ** សភាពនៃធម៌ជាគោចរ ព្រោះត្រាច់ទៅក្នុងសេចក្ដីប្រាថ្នា ។ សភាពនៃធម៌ ឈ្មោះថា **បហានដ្ឋោ** សភាពនៃធម៌ដែលលះបង់ ព្រោះភាវៈនិព្វាន

ជាសរណប្បហាន ។ សភាពនៃធម៌ ឈ្មោះថា **បរិច្ចាគដ្ឋោ** សភាពនៃធម៌ដែលលះបង់ ដោយអំណាចលះបង់កិលេសដោយអរិយមគ្គ ។ សភាពនៃធម៌ ឈ្មោះថា **វុដ្ឋានដ្ឋោ** សភាពនៃធម៌ដែលចេញចាកដោយអំណាចការចេញចាកគ្រោះអាក្រក់ ។ ភាពនៃធម៌ឈ្មោះថា **វិវដ្ដនដ្ឋោ** សភាពនៃធម៌ដែលចៀសចេញ ដោយអំណាចចៀសចេញចាកនិមិត្ត និងការប្រព្រឹត្តិទៅ ។ សភាពនៃធម៌ ឈ្មោះថា **សន្តដ្ឋោ** សភាពនៃធម៌ដ៏ល្អិត ព្រោះរំលត់ស្និទ្ធ ។ សភាពនៃធម៌ ឈ្មោះថា **បណីតដ្ឋោ** សភាពនៃធម៌ដ៏ប្រណីត ព្រោះជាធម៌មិនក្ដៅក្រហាយ និងព្រោះជាធម៌ដ៏ខ្ពង់ខ្ពស់ ។ សភាពនៃធម៌ ឈ្មោះថា **វិមុត្តដ្ឋោ** សភាពនៃធម៌ដែលរលាស់ផុត ព្រោះរលាស់ផុតចាកកិលេស និងបង្អោនទៅក្នុងអារម្មណ៍ ។ សភាពនៃធម៌ ឈ្មោះថា **អនាសវដ្ឋោ** សភាពនៃធម៌ដែលមិនមានអាសវៈ ព្រោះបរិសុទ្ធិដោយមិនមែនជាវិស័យនៃអាសវៈទាំងឡាយ ។

សភាពនៃធម៌ ឈ្មោះថា **តរណដ្ឋោ** សភាពនៃធម៌ ដែលជាគ្រឿងឆ្លង ព្រោះឈានកន្លងចាកកិលេសកន្ទារៈ និងសង្សារ-កន្តារៈ ។ សភាពនៃធម៌ ឈ្មោះថា **អនិមិត្តដ្ឋោ** សភាពនៃធម៌



ដែលមិនមានគ្រឿងសម្គាល់ ព្រោះមិនមានសង្ខារនិមិត្ត ។ សភាពនៃធម៌ ឈ្មោះថា **អប្បណិហិតដ្ឋោ** សភាពនៃធម៌ដែលមិនមានទីតាំង ព្រោះមិនមានទីតាំង គឺ តណ្ហា ។ សភាពនៃធម៌ ឈ្មោះថា **សុញ្ញតដ្ឋោ** សភាពនៃធម៌ដែលសូន្យទទេ ព្រោះមិនមានសារៈក្នុងខ្លួន ។ សភាពនៃធម៌ ឈ្មោះថា **ឯករសដ្ឋោ** សភាពនៃធម៌ដែលមានកិច្ចតែម្យ៉ាងដូចគ្នា ព្រោះមានរសតែម្យ៉ាងដូចគ្នាដោយវិមុត្តិ-រស ឬព្រោះសមថៈ និងវិបស្សនា មានរសតែម្យ៉ាងដូចគ្នា ។ សភាពនៃធម៌ ឈ្មោះថា **អនតិវត្តនដ្ឋោ** សភាពនៃធម៌ដែលមិនកន្លងហួសគ្នា ព្រោះសមថៈ និងវិបស្សនា អាស្រ័យដល់គ្នានឹងគ្នា ។ សភាពនៃធម៌ ឈ្មោះថា **យុគនទ្ធដ្ឋោ** សភាពនៃធម៌ដែលជាគូ ព្រោះសមថៈ និងវិបស្សនា នោះឯងជាគូ ។ សភាពនៃធម៌ ឈ្មោះថា **និយ្យានដ្ឋោ** សភាពនៃធម៌ដែលនាំចេញ ព្រោះចេញចាកពីសង្ខារ ដោយអរិយមគ្គ ។ សភាពនៃធម៌ ឈ្មោះថា **ហេតដ្ឋោ** សភាពនៃធម៌ដែលជាហេតុ ព្រោះជាហេតុឲ្យដល់និព្វាន ។ សភាពនៃធម៌ ឈ្មោះថា **ទស្សនដ្ឋោ** សភាពនៃធម៌ដែលឃើញ ព្រោះនាំនិព្វានឲ្យប្រចក្ស ។ សភាពនៃធម៌ ឈ្មោះថា **អាធិបតេយ្យដ្ឋោ**

សភាពនៃធម៌ដែលជាអធិបតី ព្រោះភាពជាធំដ៏ក្រៃលែង ។

ព្រះសារីបុត្តបានចង្អុលបង្ហាញដល់ការវិសជ្ជនា ៤ ប្រការ មានសមថៈជាដើម ដោយអំណាចនៃសមថៈ និងវិបស្សនា ។

សភាពនៃធម៌ ឈ្មោះថា **អនុបស្សនដ្ឋោ** សភាពដែលពិចារណាឃើញ ព្រោះពិចារណាឃើញដោយអនិច្ចលក្ខណៈជាដើម ។ សភាពនៃធម៌ ឈ្មោះថា **អនតិវត្តនដ្ឋោ** សភាពដែលមិនបានកន្លងគ្នា ព្រោះសមថៈ និងវិបស្សនា ទាំងពីរជាធម៌គូគ្នា ដោយមានកិច្ចតែម្យ៉ាងដូចគ្នា ។

ព្រះសារីបុត្តបានចង្អុលបង្ហាញដល់ការវិសជ្ជនា ៩ ប្រការ មានសិក្ខាជាដើម ដោយអំណាចអរិយមគ្គជាខាងដើម កណ្តាល និងខាងចុង ។ ឈ្មោះថា **សិក្ខា** ព្រោះត្រូវសិក្សា ។ សភាពនៃធម៌ឈ្មោះថា **សមាទានដ្ឋោ** សភាពដែលសមាទាន ព្រោះត្រូវសមាទានសិក្ខានោះ ។ សភាពនៃធម៌ ឈ្មោះថា **គោចរដ្ឋោ** សភាពដែលគោចរ ព្រោះជាទីតាំងនៃភាវនា និងការប្រព្រឹត្តទៅរបស់អារម្មណ៍ដែលតាំងនៅក្នុងសីលហើយ កាន់យកដោយកម្មដ្ឋាន និងព្រោះជាទីតាំងនៃគោចរ ។ សភាពនៃធម៌ឈ្មោះថា **បគ្គហដ្ឋោ**



សភាពដែលផ្គងចិត្ត គឺ សភាពនៃការព្យាយាមធ្វើចិត្តដែលរួញរាខ្ជិលច្រអូស ដោយចម្រើនធម្មវិចយសម្ពោជ្ឈង្គៈ វីរយសម្ពោជ្ឈង្គៈ និងបីតិសម្ពោជ្ឈង្គៈ ។

សភាពនៃធម៌ឈ្មោះថា **វិនិគ្គហដ្ឋោ** សភាពដែលបង្ក្រាបចិត្ត គឺ សភាពធ្វើចិត្តដែលរាយមាយដោយឧទ្ធច្ចៈឲ្យស្ងប់ ចម្រើនបស្សទ្ធិសម្ពោជ្ឈង្គៈ សមាធិសម្ពោជ្ឈង្គៈ និងឧបេក្ខាសម្ពោជ្ឈង្គៈ ។ បទថា **ឧភោ វិសុទ្ធានំ** ចិត្តបរិសុទ្ធចាកទាំងពីរ អធិប្បាយថា រក្សាចិត្តដែលបរិសុទ្ធចាកការខ្ជិលច្រអូស និងរាយមាយ ។ គប្បីជ្រាបថា លោកធ្វើជាពហុវចនៈ ដោយអំណាចនៃចិត្តតាំងនៅក្នុងភាពជាកណ្តាល ប្រព្រឹត្តទៅដោយអំណាចរបស់សន្តតិ ។ សភាពនៃធម៌ ឈ្មោះថា **អជ្ឈុបេក្ខណដ្ឋោ** សភាពនៃការឃុំគ្រងចិត្ត គឺ មិនមានសេចក្តីខ្វល់ខ្វាយក្នុងការព្យាយាម និងក្នុងការធ្វើឲ្យស្ងប់ ។ សភាពនៃធម៌ ឈ្មោះថា **វិសេសាធិគមនដ្ឋោ** សភាពដែលចិត្តសម្រេចគុណវិសេស គឺ ការអប់រំចិត្តឲ្យប្រព្រឹត្តទៅស្មើ ។ សភាពនៃធម៌ ឈ្មោះថា **ឧត្តរិបដិវេធដ្ឋោ** សភាពដែលសម្រេចអរិយមគ្គដ៏ប្រសើរ គឺ ដោយអំណាចធ្វើអរិយមគ្គឲ្យប្រាកដ ។

សភាពនៃធម៌ ឈ្មោះថា **សច្ចាភិសមយដ្ឋោ** សភាពដែលត្រាស់ដឹងសច្ចៈ គឺ ដោយអំណាចជាក់ច្បាស់អរិយសច្ច ៤ សម្រេចដោយអរិយមគ្គ ។ សភាពនៃធម៌ ឈ្មោះថា **បតិដ្ឋាបកដ្ឋោ** សភាពដែលធ្វើចិត្តឲ្យតាំងនៅ គឺ ឲ្យតាំងនៅក្នុងនិរោធ ដោយអំណាចផលសមាបត្តិ ។ ព្រោះផលសមាបត្តិនោះ ញុំាងបុគ្គលអ្នកមានសេចក្តីព្រមព្រៀងឲ្យតាំងនៅក្នុងនិព្វាន បានដល់ **និរោធ** ។

ព្រះសារីបុត្តពោលដល់ការវិសជ្ជនា ៥ ប្រការ មាន **សទ្ធិន្ទ្រិយ** ជាដើម ដោយអំណាចនៃសភាវធម៌ គឺ ឥន្ទ្រីយ៍ ។ បទថា **អធិមោក្ខដ្ឋោ** សភាពដែលបង្អោនទៅ ។ បទថា **ឧបដ្ឋានដ្ឋោ** សភាពដែលតាំងមាំ គឺ សភាពដែលចូលទៅតាំងមាំនូវអារម្មណ៍ ។ បទថា **ទស្សនដ្ឋោ** សភាពដែលឃើញ គឺ សភាពដែលសម្លឹងដល់សេចក្តីពិត ។

ព្រះសារីបុត្តបានចង្អុលបង្ហាញដល់ការវិសជ្ជនា ៥ ប្រការ មាន **សទ្ធាពល** ជាដើម ដោយអំណាចនៃសភាវធម៌ គឺ ពលៈ ។ ឈ្មោះថា **សទ្ធាពលំ** ព្រោះសទ្ធានោះឯងជាកម្លាំង ដោយអត្ថថាមិនញាប់ញ័រ ។ បទថា **អស្សទ្ធិយេ** ព្រោះមិនមានសទ្ធា ។



ម្យ៉ាងទៀតបទថា **អស្សទ្ធិយំ** បានដល់ ចិត្តុប្បាទ ដែលជាបដិបក្ខដល់សទ្ធា ។ បទថា **អកម្បិយដ្ឋោ** បានដល់ សភាពដែលមិនគួរញាប់ញ័រ អធិប្បាយថា មិនអាចឲ្យញាប់ញ័របាន ។ បទថា **កោសជ្ជេ** ព្រោះសេចក្តីខ្ជិលច្រអូស បានដល់ ព្រោះថីនមិទ្ធៈដែលជាសេចក្តីខ្ជិលច្រអូស ។ បទថា **បមាទេ** ព្រោះសេចក្តីប្រមាទ បានដល់ ព្រោះចិត្តុប្បាទដែលជាបដិបក្ខដល់សតិ ។ បទថា **ឧទ្ធច្ចេ** គឺ ព្រោះសេចក្តីរាយមាយ ពោលគឺ ការមិនស្ងប់ ។ បទថា **អវិជ្ជាយ** ព្រោះអវិជ្ជា បានដល់ ព្រោះមោហៈ ។

ព្រះសារីបុត្តបានចង្អុលបង្ហាញដល់ការវិសជ្ជនា ៧ ប្រការ មាន **សតិសម្ពោជ្ឈង្គ** ជាដើម ដោយអំណាចនៃសភាវធម៌ គឺ ពោជ្ឈង្គៈ ។ អង្គធម៌ជាគ្រឿងត្រាស់ដឹង ឈ្មោះថា **ពោជ្ឈង្គ** ។ ពោជ្ឈង្គជាធម៌ដ៏ប្រសើរ និងជាធម៌ល្អ ឈ្មោះថា សម្ពោជ្ឈង្គៈ ។ សតិនោះឯងជា សម្ពោជ្ឈង្គៈ ទើបឈ្មោះថា **សតិសម្ពោជ្ឈង្គ** ។ ឈ្មោះថា **ធម្មវិចយ** ព្រោះពិចារណាធម៌ ។ បទនេះជាឈ្មោះរបស់បញ្ញា ។ បទថា **បវិចយដ្ឋោ** សភាពដែលជ្រើសរើស បានដល់ សភាពដែលពិចារណា ។ ឈ្មោះថា **បីតិ** ព្រោះចិត្ត

រីករាយ ។ បទថា **ផរណដ្ឋោ** សភាពដែលផ្សាយទៅ បានដល់ សភាពដែលសាយទៅ ។ សេចក្ដីស្ងប់ ឈ្មោះថា **បស្សទ្ធិ** ។ បទថា **ឧបសមដ្ឋោ** សភាពដែលស្ងប់ បានដល់ សភាពដែលមិនមានសេចក្ដីក្រវល់ក្រវាយ ។ ឈ្មោះថា **ឧបេក្ខា** ព្រោះឃើញដោយឧបបត្តិ ។ អធិប្បាយថា សម្លឹងដោយស្មើ គឺ សម្លឹងមិនធ្លាក់ទៅក្នុងចំណែកណា ។ ឧបេក្ខានោះ ក្នុងទីនេះ បានដល់ **តត្រមជ្ឈត្តុបេក្ខា** គឺ ការព្រងើយ ដោយភាពជាកណ្ដាលក្នុងអារម្មណ៍នោះ ៗ ។ ខ្លះហៅថា **ពោជ្ឈង្គុបេក្ខា** ។ បទនោះ ជាឈ្មោះរបស់ឧបេក្ខានោះ ។ ឈ្មោះថា **បដិសង្ខានដ្ឋោ** សភាពដែលពិចារណារកផ្លូវ ព្រោះមានលក្ខណៈនាំទៅស្មើ ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ៨ ប្រការ មាន **សម្មាទិដ្ឋិ** ជាដើម ដោយមគ្គ ។ ឈ្មោះថា **សម្មាទិដ្ឋិ** ព្រោះឃើញត្រូវ ឬឃើញត្រូវដោយទិដ្ឋិនោះ ឬការឃើញដ៏ប្រសើរ ។ នៃសម្មាទិដ្ឋិនោះ ។

ឈ្មោះថា **សម្មាសង្កប្បោ** ព្រោះត្រិះរិះត្រូវ ឬត្រិះរិះត្រូវដោយការត្រិះរិះនោះ ឬការត្រិះរិះដ៏ប្រសើរ ។



បទថា **អភិរោបនដ្ឋោ** សភាពដែលពិចារណា បានដល់ សភាពដែលពិចារណាអារម្មណ៍របស់ចិត្ត ។ បាឋៈថា **អារម្មណាភិនិរោបនដ្ឋោ** សភាពដែលពិចារណាអារម្មណ៍ខ្លះ ។

ឈ្មោះថា **សម្មាវាចា** ព្រោះនិយាយត្រូវ ឬនិយាយដោយវាចានោះត្រូវ ឬវាចាដ៏ប្រសើរ បទនេះ ជាឈ្មោះរបស់ការវៀរចាកមិច្ឆាវាចា ។

បទថា **បរិគ្គហដ្ឋោ** សភាពដែលកំណត់ បានដល់ កំណត់ការសង្រួមវាចា ៤ យ៉ាង ។

ឈ្មោះថា **សម្មាកម្មំ** ព្រោះធ្វើត្រូវ ឬធ្វើត្រូវដោយការងារនោះ ឬការងារដ៏ប្រសើរ , ការងារត្រូវនោះឯង ឈ្មោះថា **សម្មាកម្មន្តោ** ។ បទនេះ ជាឈ្មោះការវៀរចាកមិច្ឆាកម្មន្តៈ ។

បទថា **សមុដ្ឋានដ្ឋោ** សភាពដែលតាំងឡើង បានដល់ សភាពដែលតាំងឡើងដោយការសង្រួមកាយ ៣ យ៉ាង ។

ឈ្មោះថា **សម្មាអាជីវោ** ព្រោះចិញ្ចឹមជីវិតត្រូវ ឬចិញ្ចឹមជីវិតដោយអាជីពនោះត្រូវ ឬអាជីពដ៏ប្រសើរ ។ បទនេះជាឈ្មោះការវៀរចាកមិច្ឆាជីព ។

បទថា **វោទានដ្ឋោ** សភាពដែលផូរផង់ បានដល់ សភាពដែលបរិសុទ្ធ ។

ឈ្មោះថា **សម្មាវាយាមោ** ព្រោះព្យាយាមត្រូវ ឬព្យាយាមត្រូវដោយការព្យាយាមនោះ ឬព្យាយាមដ៏ប្រសើរ ។

ឈ្មោះថា **សម្មាសតិ** ព្រោះរលឹកត្រូវ ឬរលឹកដោយសតិនោះត្រូវ ឬរលឹកដ៏ប្រសើរ ។

ឈ្មោះថា **សម្មាសមាធិ** ព្រោះតាំងចិត្តត្រូវ ឬតាំងចិត្តត្រូវដោយសមាធិនោះ ឬតាំងចិត្តដ៏ប្រសើរ ។

ព្រះសារីបុត្តបានចង្អុលបង្ហាញដល់ការវិសជ្ជនា ១០ ប្រការ មាន **ឥន្ទ្រិយ៍** ជាដើម ធ្វើឲ្យជាពួកក្រុមតាមលំដាប់ ។

បទថា **អាធិបតេយ្យដ្ឋោ** សភាពដែលជាធំ បានដល់ សភាពដែលជាអធិបតី ដោយអំណាចធ្វើភាពជាធំក្នុងមុខនាទីរបស់ខ្លួន ។

បទថា **អកម្បិយដ្ឋោ** សភាពដែលមិនញាប់ញ័រ បានដល់ បដិបក្ខ មិនអាចធ្វើឲ្យញាប់ញ័របាន ។

បទថា **និយ្យានដ្ឋោ** សភាពដែលនាំចេញ បានដល់ ការចេញទៅចាកបដិបក្ខ ដោយលោកិយៈ និងលោកុត្តរៈ ។



បទថា **ហេតដ្ឋោ** សភាពដែលជាហេតុ ។ ឈ្មោះថា **ហេតដ្ឋោ** ព្រោះសម្មាទិដ្ឋិជាដើម ជាហេតុដើម្បីលះមិច្ឆាទិដ្ឋិជាដើម ឬព្រោះសម្មាទិដ្ឋិទាំងអស់ជាហេតុឲ្យចូលដល់និព្វាន ។

ឈ្មោះថា **ឧបដ្ឋាន** ព្រោះស្ទុះទៅក្នុងអារម្មណ៍ដែលជាសតិប្បដ្ឋាន ហើយតាំងមាំ , សតិនោះឯងតាំងមាំ ទើបឈ្មោះថា **សតិប្បដ្ឋាន** ។

សតិនោះក្នុង កាយ វេទនា ចិត្ត ធម៌ រមែងមានប្រភេទ ៤ យ៉ាង ដែលប្រព្រឹត្តទៅដោយការកាន់យកអាការ គឺ សភាពមិនស្អាត សភាពជាទុក្ខ សភាពមិនទៀង និងសភាពមិនមែនជាតួខ្លួនជាដើម និងដោយសម្រេចកិច្ច គឺ លះបង់ការសម្គាល់ថា ជារបស់ស្អាត ជាសុខ ជារបស់ទៀង ជាតួខ្លួន ។ ចិត្តទាំងនេះ រមែងបានក្នុងចិត្តផ្សេង ៗ ក្នុងចំណែកខាងដើម , ចំណែកសតិតែម្យ៉ាងប៉ុណ្ណោះ រមែងបានឈ្មោះ ៤ យ៉ាង ក្នុងខណៈរបស់មគ្គ ។

ឈ្មោះថា **បធាន** ព្រោះជាហេតុផ្ដើមឡើងក្នុងសម្មប្បធាន , ការផ្ដើមឡើងត្រូវ ឈ្មោះថា **សម្មប្បធាន** , ឬជាហេតុផ្ដើមឡើងត្រូវ , ម្យ៉ាងទៀត ការផ្ដើមឡើងនោះត្រូវ ឈ្មោះថា **បធាន** ព្រោះ

វៀរចាកការខុសប្រក្រតីរបស់កិលេស , ឈ្មោះថា **សម្មប្បធាន** ព្រោះនាំមកនូវវត្ថុដ៏ប្រសើរបំផុតដោយឲ្យសម្រេចប្រយោជន៍ និង សេចក្ដីសុខ ឬធ្វើភាពផ្ដើមឡើង ។ បទនេះ ជាឈ្មោះរបស់វីរិយៈ ។ វីរិយៈនោះមាន ៤ ប្រភេទ ដោយឲ្យសម្រេច គឺ លះអកុសលធម៌ ដែលកើតឡើងហើយ ១ , អកុសលធម៌ដែលនៅមិនទាន់កើត មិនឲ្យកើតឡើង ១ , កុសលធម៌ ដែលនៅមិនទាន់កើតឲ្យកើតឡើង ១ , កុសលធម៌ ដែលកើតឡើងហើយ ឲ្យតាំងនៅ ១ ។ **បធាន** ទាំងនេះ រមែងបានក្នុងចិត្តផ្សេង ៗ ក្នុងចំណែកខាងដើម , ចំណែក វីរិយៈតែម្យ៉ាងប៉ុណ្ណោះ រមែងបានឈ្មោះ ៤ យ៉ាង ក្នុងខណៈនៃមគ្គ ។

បទថា **បទហនដ្ឋោ** សភាពដែលផ្ដើមឡើង បានដល់ សភាពដែល ឧស្សាហៈ ។ បាឋៈថា **បធានដ្ឋោ** ដូច្នេះក៏មាន , ន័យតែម្យ៉ាងដូចគ្នា ។ ក្នុងបទថា **ឥទ្ធិបាទានំ** នេះ មានវិនិច្ឆ័យដូចតទៅនេះ ឈ្មោះថា **ឥទ្ធិ** ព្រោះបណ្ដា ឆន្ទៈ វីរិយៈ ចិត្តៈ វិមំសា នីមួយ ៗ រមែងសម្រេច , អធិប្បាយថា រមែងសម្រេចស្មើ គឺ រមែងប្រាកដច្បាស់ ។ ម្យ៉ាងទៀត ឈ្មោះថា **ឥទ្ធិ** ព្រោះ



សត្វទាំងឡាយ រមែងសម្រេចដោយឥទ្ធិនោះ គឺថា សត្វទាំងឡាយ ជាអ្នកសម្រេចនូវសេចក្ដីសម្រេចក្រៃលែង ។ ដោយអត្ថទី ១ ឥទ្ធិបាទធម៌ ជាគ្រឿងឲ្យដល់ គឺ ឥទ្ធិ ការសម្រេច ឈ្មោះថា **ឥទ្ធិបាទ** , សេចក្ដីថា ចំណែកនៃសេចក្ដីសម្រេច ។ ដោយអត្ថទី ២ ឈ្មោះថា **ឥទ្ធិបាទ** ព្រោះធម៌ជាគ្រឿងឲ្យដល់នូវសេចក្ដីសម្រេច ។

បទថា **បាទោ** គឺជាទីតាំង អធិប្បាយថា ជាឧបាយឲ្យសម្រេច ។ ព្រោះសត្វទាំងឡាយរមែងដល់ គឺ រមែងសម្រេចសេចក្ដីសម្រេចដ៏ក្រៃលែង ៗ ឡើងទៅ ដោយឥទ្ធិបាទនោះ , ដូច្នោះទើបលោកហៅថា **បាទោ** ។ ឥទ្ធិបាទ មានឆន្ទៈជាដើម ទាំងនោះ រមែងបានក្នុងចិត្តផ្សេង ៗ ដោយភាពជាធំក្នុងចំណែកខាងដើម , ប៉ុន្តែក្នុងខណៈនៃមគ្គ រមែងបានរួមគ្នាដោយពិត ។

បទថា **ឥជ្ឈនដ្ឋោ** សភាពដែលសម្រេច គឺ សភាពដែលប្រាកដ ឬសភាពជាទីតាំង ។

បទថា **សច្ចានំ** បានដល់ អរិយសច្ច ៤ ។

បទថា **តថដ្ឋោ** សភាពដែលទៀងពិត បានដល់ សភាពតាមពិត ។ ការវិសជ្ជនា ៨ ទាំងនេះ លាយដោយលោកិយៈ

និងលោកុត្តរៈ ។

បទថា **បយោគានំ** បយោគទាំងឡាយ បានដល់ បយោគរបស់អរិយមគ្គ ៤ ។

បទថា **បដិបស្សទ្ធដ្ឋោ** សភាពដែលរំងាប់ បានដល់ រំងាប់ដោយអរិយផល ៤ ។ ពិតហើយ មគ្គប្បយោគជាការរំងាប់ក្នុងខណៈនៃផល ព្រោះអស់កិច្ចហើយ ។ ឬភាវៈនៃមគ្គប្បយោគរំងាប់ដោយផលកើតឡើង ។

បទថា **ផលានំ សច្ឆិកិរិយដ្ឋោ** សភាពដែលធ្វើឲ្យជាក់ច្បាស់នៃផល បានដល់ សភាពដែលធ្វើឲ្យប្រចក្សដោយពិចារណាអរិយផល ។ ជាការដែលលោកពោលដល់ការធ្វើឲ្យជាក់ច្បាស់នូវអារម្មណ៍ ។ ឬការធ្វើឲ្យជាក់ច្បាស់ នូវការបានក្នុងខណៈនៃផល ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ៥ ប្រការ មាន **វិតក្ក** ជាដើម ដោយអង្គឈាន ។ ការត្រិះរិះ ឈ្មោះថា វិតក្កៈ លោកពោលថា បានដល់ ការលើកឡើង , ការពិចារណា ឈ្មោះថា **វិចារ** លោកពោលថា បានដល់ ការតាមពិចារណា ។



បទថា **ឧបវិចារដ្ឋោ** សភាពដែលត្រួតពិនិត្យ បានដល់ សភាពដែលតាមដុសខាត់លាងជម្រះពណ៌ ។ បទថា **អភិសន្ទនដ្ឋោ** សភាពដែលហូរមក បានដល់ សភាពដែលផ្សាយឡើង គឺ សភាពដែលចិត្តមានអារម្មណ៍តែមួយ ដោយអំណាចសមាធិ ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ៥ ប្រការ មាន **អាវជ្ជន** ការគិតដល់ជាដើម ដោយជាចំណែកបន្តិចបន្តួច ។ សភាពដែលគិតដល់របស់ចិត្ត ២ ដួង បង្អោនទៅកាន់ចិត្តសន្តានក្នុងអារម្មណ៍ដទៃពីអារម្មណ៍នៃភវង្គក្នុងបញ្ចទ្វារ និង មនោទ្វារ , សភាពដែលដឹងច្បាស់ដោយវិញ្ញាណ សភាពដែលដឹងជាក់ដោយបញ្ញា សភាពដែលចាំបាននៃសញ្ញា ។ សភាពនៃសមាធិជាធម៌ឯកកើតឡើង ព្រោះសមាធិក្នុងទុតិយជ្ឈានជាឯក កើតឡើង លោកទើបពោលថា **ឯកោទិ** អធិប្បាយថា ជាសមាធិដ៏ប្រសើរឯកកើតឡើង ព្រោះវិតក្កវិចារស្ងប់រំងាប់ ។ ព្រោះសមាធិប្រសើរលោកទើបពោលថា ជាធម៌ឯកក្នុងលោក ។ ម្យ៉ាងទៀត លោកពោលថា ជាធម៌ឯកមិនមានគូ វៀរវិតក្កវិចារ ផុតស្រឡះដូច្នេះខ្វះរមែងគួរ ។ ម្យ៉ាងទៀត កុសលសមាធិ សូម្បីទាំងអស់ ជាធម៌

ស្ងប់ស្ងាត់ចាកវិតក្កវិចារទាំងនោះ ព្រោះជាបដិបក្ខដល់និវរណៈជាដើម ឬដល់ឧទ្ធច្ចៈប៉ុណ្ណោះ ដូច្នោះទើប ជាធម៌ដ៏ប្រសើរកើតឡើង ឬវៀរចាកវិតក្កវិចារទាំងនោះ ទើបជាធម៌មិនមានគូកើតឡើង ទើបឈ្មោះថា **ឯកោទិ** ជាធម៌ឯកកើតឡើង រមែងត្រឹមត្រូវ ។

បទថា **អភិញ្ញាយ្យ ញាតដ្ឋោ** សភាពដែលដឹងនៃបញ្ញាបានដល់ សភាពដែលដឹងដល់សភាវធម៌ ដោយញាតប្បរិញ្ញាកំណត់ដឹងដោយបញ្ញា ។

បទថា **បរិញ្ញាយ្យ តរណដ្ឋោ** សភាពដែលកំណត់ពិចា-រណាដោយបរិញ្ញា បានដល់ សភាពដែលកំណត់ពិចារណា ដោយជារបស់មិនទៀងជាដើម ដោយ **តីរណបរិញ្ញា** កំណត់ដឹងដោយការពិចារណា ។

បទថា **បហានស្ស បរិច្ចាគដ្ឋោ** សភាពដែលបហាន បានដល់សភាពដែលលះធម៌ដែលជាបដិបក្ខដល់បហានប្បរិញ្ញា កំណត់ដឹងដោយការលះចេញ ។ សភាពដែលភាវនាប្រព្រឹត្តទៅជានិច្ច មានកិច្ចតែមយ៉ាងដូចគ្នា ឈ្មោះថា **ភាវនាយ ឯករសដ្ឋោ** ។



បទថា **ផស្សនដ្ឋោ** សភាពដែលពាល់ត្រូវ បានដល់ សភាពដែលប្រសព្វ ។ ឈ្មោះថា សភាពដែលជាខន្ធ **ខន្ធដ្ឋោ** ដោយការទទួលភារៈដ៏ធ្ងន់ធ្ងរជាដើមទៅ ។ ឈ្មោះថា សភាពដែលទ្រទ្រង់ទុក **ធាតដ្ឋោ** ព្រោះការសោះសូន្យជាដើម ។ ឈ្មោះថា សភាពជាទី.ត **អាយតនដ្ឋោ** ព្រោះការតដែនខេត្ត ដែលជាចំណែករបស់ខ្លួន ៗ ។ ឈ្មោះថា សភាពដែលបច្ច័យ តាក់តែង **សង្ខតដ្ឋោ** ព្រោះធ្វើរួមជាមួយបច្ច័យទាំងឡាយ ។ ឈ្មោះថា សភាពដែលបច្ច័យមិនតាក់តែង **អសង្ខតដ្ឋោ** ព្រោះផ្ទុយគ្នាជាមួយនឹងបច្ច័យតាក់តែងនោះ ។

ព្រះសារីបុត្តបានបង្ហាញដល់ការវិសជ្ជនា ១៥ ប្រការ មានបទថា **ចិត្តដ្ឋោ** សភាពដែលគិតជាដើម ។ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចិត្តដ្ឋោ** ដូចតទៅនេះ ។ ឈ្មោះថា **ចិត្តំ** ព្រោះគិតដល់អារម្មណ៍ សេចក្តីថា រមែងដឹងច្បាស់ ។ ជវនចិត្តមាននៅក្នុងអារម្មណ៍នេះ រមែងសន្សំសន្តានរបស់ខ្លួនដោយជវនវិថីចិត្ត សូម្បីដូច្នេះ ក៏ឈ្មោះថា **ចិត្តំ** ។ សូម្បីវិបាកដែលកម្មកិលេសសន្សំទុកដូច្នេះ ក៏ឈ្មោះថា **ចិត្តំ** ទាំងអស់ , ឈ្មោះថា **ចិត្តំ** ព្រោះសន្សំ

ទុកតាមសមគួរ , ឈ្មោះថា **ចិត្តំ** ព្រោះធ្វើឲ្យវិចិត្រ , ចិត្តដែលជាបច្ច័យដល់វដ្តៈ រមែងសន្សំសង្សារទុក្ខ សូម្បីដូច្នេះ ក៏ឈ្មោះថា **ចិត្តំ** ។ សភាពដែល គិតដោយមានការសន្សំអារម្មណ៍ជាដើម ដោយប្រការដូច្នេះ ។

ឈ្មោះថា **អនន្តរំ** ព្រោះចិត្តនោះមិនមានចន្លោះ ក្នុងការកើតរបស់ចិត្ត ក្នុងការកើតរបស់ផល ។ ភាពជា **អនន្តរ** ឈ្មោះថា **អនន្តរិយ** ការមិនមានចន្លោះ , សភាពនៃចិត្តមិន មានចន្លោះ ឈ្មោះថា **ចិត្តានន្តរិយ** ។ **ចិត្តានន្តរិយ** នោះ គឺ សភាពនៃចិត្តមិនមានចន្លោះ ។ អធិប្បាយថា សមត្ថភាពក្នុងចិត្តុប្បាទមានបន្ទាប់ពីចិត្តដួងណាមួយដែលរលត់ក្នុងរវាងនោះជានិច្ច វៀរចុតិចិត្តរបស់ព្រះអរហន្ត ។ សមត្ថភាពក្នុងការកើតផល ក៏មានបន្ទាប់អំពីមគ្គចិត្ត ។

បទថា **ចិត្តស្ស វុដ្ឋានដ្ឋោ** សភាពដែលចេញនៃចិត្ត បានដល់សភាពដែលចេញដោយជានិមិត្តនៃគោត្រភូចិត្ត ដោយការប្រព្រឹត្តទៅនៃនិមិត្តរបស់មគ្គចិត្ត ។

បទថា **ចិត្តស្ស វិវដ្តនដ្ឋោ** សភាពដែលចៀសចេញទៅនៃ



ចិត្ត គឺ សភាពដែលចៀសចេញទៅក្នុងនិព្វានរបស់ចិត្តពីរដួងនោះដែលតាំងឡើង ដោយការពោលទុកហើយ ។

បទថា **ចិត្តស្ស ហេតដ្ឋោ** សភាពដែលជាហេតុនៃចិត្ត បានដល់ សភាពដែលជាហេតុរបស់ហេតុ ៩ យ៉ាង ដែលជាបច្ច័យរបស់ចិត្ត ។

បទថា **ចិត្តស្ស បច្ចយដ្ឋោ** សភាពដែលជាបច្ច័យនៃចិត្ត បានដល់ សភាពដែលជាបច្ច័យ នៃបច្ច័យដ៏ច្រើនសន្ធឹកសន្ធាប់របស់ចិត្ត មាន **វត្ថារម្មណ** ជាដើម ។

បទថា **ចិត្តស្ស វត្ថុដ្ឋោ** សភាពដែលជាទីតាំងនៃចិត្ត បានដល់សភាពជាទីតាំងនៃភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ និងចិត្ត ( ហទយ ) ដែលជាទីតាំងរបស់ចិត្ត ។

បទថា **ចិត្តស្ស ភូមដ្ឋោ** សភាពដែលជាភូមិរបស់ចិត្ត បានដល់ សភាពដែលជាភូមិមានកាមាវចរភូមិជាដើម ដែលជាទីកន្លែងកើតរបស់ចិត្ត ។

បទថា **ចិត្តស្ស អារម្មណដ្ឋោ** សភាពជាអារម្មណ៍របស់ចិត្ត បានដល់ អារម្មណ៍ មានរូបជាដើម ។

ឈ្មោះថា **គោចរដ្ឋោ** សភាពជាទីគោចរ ព្រោះអត្ថថា ជាទីសញ្ចរនៃអារម្មណ៍ដែលសន្សំទុក ។

ឈ្មោះថា **ចរិយដ្ឋោ** សភាពដែលត្រាច់ទៅ ព្រោះត្រាច់ទៅក្នុងវិញ្ញាណ ដែលពោលទុកក្នុងខាងដើម ។ម្យ៉ាងទៀត សភាពដែលប្រាកដនៃ **បយោគ** ឈ្មោះថា **ចរិយដ្ឋ** ។

ឈ្មោះថា **គតដ្ឋោ** សភាពដែលទៅដោយការប្រកាន់យកនូវអារម្មណ៍ឆ្ងាយ និងជិត សូម្បីក្នុងការដែលចិត្តមិនទៅ ។

បទថា **អភិនីហារដ្ឋោ** សភាពដែលនាំទៅដ៏ក្រៃលែង បានដល់ សភាពដែលនាំទៅដ៏ក្រៃលែងនៃចិត្ត ដើម្បីមនសិការដល់អារម្មណ៍ដទៃក្រៅពីអារម្មណ៍ដែលប្រកាន់ទុក ។

បទថា **ចិត្តស្ស និយ្យានដ្ឋោ** សភាពដែលនាំចេញនៃចិត្ត បានដល់ សភាពដែលនាំចេញចាកវដ្តៈនៃមគ្គចិត្ត ។

ឈ្មោះថា **ចិត្តស្ស និស្សរណដ្ឋោ** សភាពដែលរលាស់ចេញនៃចិត្ត ព្រោះន័យមានអាទិ៍ថា ចិត្តរបស់អ្នកបាននេក្ខម្មៈ មានការរលាស់ចេញចាកកាមឆន្ទៈ ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញការដល់វិសជ្ជនា ៤២ ប្រការ



មាន **ឯកត្តេ** ជាដើម ។ ដោយភ្ជាប់ឯកត្តសព្ទគ្រប់កន្លែង ។

បទថា **ឯកត្តេ** គឺ ក្នុងការដែលចិត្តមានអារម្មណ៍តែមួយ , អធិប្បាយថា បានដល់ ឯការម្មណ៍ ។

ឈ្មោះថា **បក្ខន្ទនដ្ឋោ** សភាពដែលស្ទុះទៅ ព្រោះដោយអំណាចបឋមជ្ឈាន ។

ឈ្មោះថា **បសីទនដ្ឋោ** សភាពដែលផូរផង់ ព្រោះអំណាចទុតិយជ្ឈាន ។

ឈ្មោះថា **មុច្ចនដ្ឋោ** សភាពដែលរលាស់ផុត ព្រោះអំណាចចតុត្ថជ្ឈាន ។

ឈ្មោះថា **បស្សនដ្ឋោ** សភាពដែលឃើញនេះ ល្អិតល្អន់ដោយការពិចារណា ។

ការវិសជ្ជនា ៥ មាន **យានីកតដ្ឋោ** សភាពដែលធ្វើឲ្យដូចជាយានជាដើម ជាការជំនាញដ៏វិសេសរបស់សមាធិ ។

បទថា **យានីកតដ្ឋោ** បានដល់ សភាពធ្វើឲ្យដូចជាយានដែលទឹមហើយ ។

បទថា **វត្ថុកតដ្ឋោ** សភាពដែលធ្វើឲ្យជាទីតាំង បានដល់

សភាពដែលធ្វើតាំងទុកដូចវត្ថុ ។

បទថា **អនុដ្ឋិតដ្ឋោ** សភាពដែលតាំងឡើងជារឿយ ៗ បានដល់ សភាពដែលចូលទៅតាំងទុកដោយចំពោះ ។

បទថា **បរិចិតដ្ឋោ** សភាពដែលអប់រំ បានដល់ សភាពដែលសន្សំទុកដោយជុំវិញ ។

បទថា **សុសមារទ្ធដ្ឋោ** សភាពដែលប្រារព្ធព្រមដោយល្អ បានដល់ សភាពដែលផ្ដើមដោយល្អ អធិប្បាយថា សភាពដែលធ្វើទុកល្អ ។ ម្យ៉ាងទៀត គួរប្រកបបទ ៥ បទ តាមលំដាប់ដោយភាពជាអ្នកជំនាញក្នុង អាវជ្ជនៈ សមាបជ្ជនៈ អធិដ្ឋានៈ វុដ្ឋានៈ បច្ចវេក្ខណៈ ។

សភាពដែលកំណត់កាន់យក សភាពជាបរិវារ សភាពដែលបរិបូរណ៍នៃចិត្ត ចេតសិក ក្នុងវេលាដែលដល់កំពូលនៃការភាវនាអារម្មណ៍ មានកសិណជាដើម ។

ឈ្មោះថា **សមោធានដ្ឋោ** សភាពដែលប្រជុំ ព្រោះចេតសិកទាំងនោះ តាំងទុកដោយល្អហើយ ដោយការប្រជុំក្នុងអារម្មណ៍តែមួយ ។



ឈ្មោះថា **អធិដ្ឋានដ្ឋោ** សភាពដែលអធិដ្ឋាន ព្រោះចិត្តចេតសិកទាំងនោះ គ្របសង្កត់អារម្មណ៍ ដោយការបង្កើតកម្លាំងហើយតាំងមាំ ។

ឈ្មោះថា **អាសេវនដ្ឋោ** សភាពដែលសេព ព្រោះសេពយ៉ាងយកចិត្តទុកដាក់នៃសមថៈ ឬវិបស្សនា តាំងពីដំបូង ។

ឈ្មោះថា **ភាវនដ្ឋោ** សភាពដែលចម្រើន ព្រោះអាចធ្វើឲ្យចម្រើន ។

ឈ្មោះថា **ពហុលីកម្មដ្ឋោ** សភាពដែលធ្វើឲ្យច្រើន ព្រោះការធ្វើឲ្យរឿយ ៗ ។

ឈ្មោះថា **សុសមុគ្គតដ្ឋោ** សភាពដែលរួបរួមដោយល្អ ព្រោះអាចរួបរួមវត្ថុដែលធ្វើទុកច្រើនហើយដោយល្អ ។

ឈ្មោះថា **សុវិមុត្តដ្ឋោ** សភាពដែលរួចផុតដោយល្អ ព្រោះអាចរួចផុតដោយល្អ ចាកធម៌ជាសត្រូវនៃសភាពដែលរួបរួមទុកល្អហើយ និងក្នុងការបង្អោនទៅដោយល្អក្នុងអារម្មណ៍ ។

ព្រះសារីបុត្តពោលដល់បទ ៤ បទ មានបទថា **ពុជ្ឈនដ្ឋោ** សភាពដែលត្រាស់ដឹងដោយពោជ្ឈង្គៈជាដើម ។

ឈ្មោះថា **ពុជ្ឈនដ្ឋោ** សភាពដែលត្រាស់ដឹងពោជ្ឈង្គៈ ព្រោះអង្គនៃពោជ្ឈង្គៈរបស់សោតាបត្តិមគ្គជាដើម ។

ឈ្មោះថា **អនុពុជ្ឈនដ្ឋោ** សភាពដែលត្រាស់ដឹងតាមពោជ្ឈង្គៈ ព្រោះអង្គនៃពោជ្ឈង្គៈរបស់សកទាគាមិមគ្គ ។

ឈ្មោះថា **បដិពុជ្ឈនដ្ឋោ** សភាពដែលត្រាស់ដឹងចំពោះពោជ្ឈង្គៈ ព្រោះអង្គនៃពោជ្ឈង្គៈរបស់អនាគាមិមគ្គ ។

ឈ្មោះថា **សម្ពុជ្ឈនដ្ឋោ** សភាពដែលត្រាស់ដឹងព្រមពោជ្ឈង្គៈ ព្រោះអង្គនៃពោជ្ឈង្គៈរបស់អរហត្តមគ្គ ។ ម្យ៉ាងទៀត ឈ្មោះថា **ពុជ្ឈនដ្ឋោ** សភាពដែលត្រាស់ដឹងពោជ្ឈង្គៈ ដោយវិបស្សនា ។ ឈ្មោះថា **អនុពុជ្ឈង្គនដ្ឋោ** សភាពដែលត្រាស់ដឹងតាមពោជ្ឈង្គៈ ដោយទស្សនមគ្គ ។ ឈ្មោះថា **បដិពុជ្ឈនដ្ឋោ** សភាពដែលត្រាស់ដឹងចំពោះពោជ្ឈង្គៈដោយភាវនាមគ្គ ។ ឈ្មោះថា **សម្ពុជ្ឈនដ្ឋោ** សភាពដែលត្រាស់ដឹងព្រមដោយពោជ្ឈង្គៈនៃផល ។ គប្បីជ្រាបអត្ថ ៤ យ៉ាង មាន **ពោធនដ្ឋ** សភាពដែលភ្ញាក់ជាដើម នៃពោជ្ឈង្គៈទាំងឡាយ ដោយធ្វើការភ្ញាក់ជាដើម របស់បុគ្គលនោះ ៗ ។

ធម៌ទាំងឡាយ ឈ្មោះថា **ពោធិបក្ខិយ** ព្រោះមានក្នុង



ចំណែករបស់បុគ្គលណា ឈ្មោះថា **ពោធិ** ព្រោះអត្ថថា ត្រាស់ដឹងពោជ្ឈង្គៈតាមដែលពោលហើយនោះឯង ។ គប្បីជ្រាបអត្ថ ៤ យ៉ាង មាន **ពោធិបក្ខិយដ្ឋ** សភាពដែលប្រព្រឹត្តទៅក្នុងចំណែកនៃការត្រាស់ដឹងជាដើម នៃពោជ្ឈង្គៈតាមដែលពោលហើយ ។

ឈ្មោះថា **ជោតនដ្ឋោ** សភាពដែលភ្លឺស្វាង ព្រោះវិបស្សនាបញ្ញា ។

ឈ្មោះថា **ឧជ្ជោតនានុជោតនបដិជោតនសញ្ជោតនដ្ឋោ** សភាពដែលភ្លឺស្វាងឡើង សភាពដែលភ្លឺស្វាងរឿយ ៗ សភាពដែលភ្លឺស្វាងចំពោះ សភាពដែលភ្លឺស្វាងព្រមដោយមគ្គញ្ញាណ ៤ តាមលំដាប់ ។ ម្យ៉ាងទៀត គប្បីជ្រាប **ជោតនដ្ឋោ** សភាពដែលភ្លឺស្វាងជាដើម ដោយមគ្គញ្ញាណ ៤ , **សញ្ជោតនដ្ឋោ** សភាពដែលភ្លឺស្វាងព្រមដោយផលញ្ញាណតាមលំដាប់ ។

ព្រះសារីបុត្តបានចង្អុលបង្ហាញដល់ការវិសជ្ជនា ១៨ ប្រការ មាន **បតាបនដ្ឋ** សភាពដែលអរិយមគ្គធ្វើឲ្យភ្លឺស្វាងជាដើម ដោយអរិយមគ្គ ។ ពិតហើយ អរិយមគ្គ ដែលកើតឡើងដល់ចិត្តណា រមែងញុំាងចិត្តនោះឲ្យភ្លឺស្វាង គឺ ឲ្យរុងរឿង ដូច្នោះទើបឈ្មោះ

ថា **បតាបន** អរិយមគ្គធ្វើឲ្យភ្លឺស្វាង ។ ឈ្មោះថា **បតាបនដ្ឋ** សភាពដែលអរិយមគ្គនោះធ្វើឲ្យភ្លឺស្វាង ។

ឈ្មោះថា **វិរោចនដ្ឋោ** សភាពអរិយមគ្គធ្វើឲ្យរុងរឿង ព្រោះអរិយមគ្គនោះឯង ភ្លឺត្រចះត្រចង់ដ៏ក្រៃលែង ។ ឈ្មោះថា **សន្តាបនដ្ឋោ** សភាពដែលអរិយមគ្គ ធ្វើឲ្យកិលេសក្តៅរោលរាល ដោយធ្វើឲ្យកិលេសទាំងឡាយហួតហែងទៅ ។

ឈ្មោះថា **អមលដ្ឋោ** សភាពដែលអរិយមគ្គមិនមាន មន្ទិល ព្រោះអរិយមគ្គ មិនមានមន្ទិលជាអារម្មណ៍ ។

ឈ្មោះថា **វិមលដ្ឋោ** សភាពដែលអរិយមគ្គប្រាសចាកមន្ទិល ព្រោះមិនមានមន្ទិលក្រេបជញ្ជក់ ។

ឈ្មោះថា **និម្មលដ្ឋោ** សភាពដែលអរិយមគ្គអស់មន្ទិល ព្រោះមិនមានមន្ទិលធ្វើជាអារម្មណ៍ ។ ម្យ៉ាងទៀត **អមលដ្ឋោ** សភាពមិនមានមន្ទិលដោយសោតាបត្តិមគ្គ ។ **វិមលដ្ឋោ** សភាពដែលអរិយមគ្គប្រាសចាកមន្ទិលដោយសកទាគាមិមគ្គ និងអនា-គាមិមគ្គ ។ **និម្មលដ្ឋោ** សភាពដែលអរិយមគ្គអស់មន្ទិល ដោយអរហត្តមគ្គ ។ ម្យ៉ាងទៀត **អមលដ្ឋោ** សភាពដែលអរិយមគ្គ



មិនមានមន្ទិល ដោយមគ្គរបស់ព្រះសាវ័ក ។ **វិមលដ្ឋោ** សភាពដែលអរិយមគ្គប្រាសចាកមន្ទិល ដោយមគ្គរបស់ព្រះបច្ចេកពុទ្ធ ។ **និម្មលដ្ឋោ** សភាពដែលអរិយមគ្គអស់មន្ទិល ដោយមគ្គរបស់ព្រះសម្មាសម្ពុទ្ធ ។

ឈ្មោះថា **សមដ្ឋោ** សភាពដែលអរិយមគ្គស្ងប់ ព្រោះមិនមានការមិនស្ងប់ គឺ កិលេស ។

ឈ្មោះថា **សមយដ្ឋោ** សភាពដែលអរិយមគ្គធ្វើកិលេសឲ្យស្ងប់រំងាប់ ក្នុងសភាពដែលអរិយមគ្គប្រហារកិលេស ដូចក្នុងបាលីមានជាអាទិ៍ថា **សម្មា នានាភិសមយា** ព្រោះអរិយមគ្គ ធ្វើឲ្យកិលេសផ្សេង ៗ ស្ងប់រំងាប់ដោយល្អ ។

ឈ្មោះថា **វិវេកដ្ឋោ** សភាពនៃវិវេក ព្រោះសមុច្ឆេទវិវេកក្នុងវិវេក ៥ គឺ វិក្ខម្ភនវិវេក ១ តទង្គវិវេក ១ សមុច្ឆេទវិវេក ១ បដិបស្សទ្ធិវិវេក ១ និស្សរណវិវេក ១ ។

ឈ្មោះថា **វិនាភាវដ្ឋោ** សភាពនៃការប្រាសទៅ ។

ឈ្មោះថា **វិវេកចរិយដ្ឋោ** សភាពនៃការប្រព្រឹត្តទៅក្នុងវិវេក ព្រោះប្រព្រឹត្តទៅក្នុងនិព្វានដែលជានិស្សរណវិវេក ។

ឈ្មោះថា **វិវេកដ្ឋោ** សភាពដែលប្រាសចាកតម្រេក ព្រោះប្រាសចាកតម្រេកជាសមុច្ឆេទក្នុងវិវេកទាំង ៥ ។

ឈ្មោះថា **វិវេកចរិយដ្ឋោ** សភាពនៃការប្រព្រឹត្តទៅក្នុងការប្រាសចាកតម្រេក ព្រោះត្រាច់ទៅក្នុងនិព្វានដែលជានិស្សរណវិវេក ។

ឈ្មោះថា **និរោធដ្ឋោ** សភាពដែលរំលត់ ព្រោះរំលត់ជាសមុច្ឆេទក្នុងនិរោធ ៥ ។

ឈ្មោះថា **និរោធចរិយដ្ឋោ** សភាពនៃការប្រព្រឹត្តិទៅដើម្បីរំលត់ ព្រោះត្រាច់ទៅក្នុងនិព្វានដែលជាការរំលត់ទុក្ខ ។

ឈ្មោះថា **វោស្សគ្គដ្ឋោ** សភាពដែលបណ្តោយតាម ព្រោះបណ្តោយតាមការបរិច្ចាគ និងការស្ទុះទៅ ។ អរិយមគ្គ ឈ្មោះថា បណ្តោយតាមការបរិច្ចាគ ព្រោះលះកិលេសដោយអំណាចសមុ-ច្ឆេទប្បហាន និងឈ្មោះថា បណ្តោយតាមការស្ទុះទៅ ព្រោះស្ទុះទៅកាន់និព្វាន ដោយធ្វើនិព្វានឲ្យជាអារម្មណ៍ , វិបស្សនាឈ្មោះថា បណ្តោយតាមការបរិច្ចាគ ព្រោះលះកិលេសដោយតទង្គប្បហាន ។ ឈ្មោះថា បណ្តោយតាមការស្ទុះទៅ ព្រោះស្ទុះទៅកាន់និព្វាន ដោយការបង្អោនទៅកាន់និព្វាននោះ ។ ក្នុងនិទ្ទេស



លោកសំដៅដល់អរិយមគ្គនោះ ។

ឈ្មោះថា **វោស្សគ្គចរិយដ្ឋោ** សភាពនៃការប្រព្រឹត្តទៅក្នុងសភាពបណ្តោយតាម ព្រោះលះកិលេសដោយសមុច្ឆេទប្ប-ហាន ។

ឈ្មោះថា **វិមុត្តដ្ឋោ** សភាពដែលផុត ព្រោះផុតដោយសមុច្ឆេទប្បហាន ក្នុងវិមុត្តិទាំង ៥ ។

ឈ្មោះថា **វិមុត្តិចរិយដ្ឋោ** សភាពនៃការប្រព្រឹត្តទៅក្នុងសភាពដែលរួចផុត ព្រោះប្រព្រឹត្តទៅក្នុងនិស្សរណវិមុត្តិ ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ៤០ ប្រការមាន **ឆន្ទដ្ឋោ** សភាពនៃឆន្ទៈជាដើម ដោយអំណាចឥទ្ធិបាទ ៤ មួយយ៉ាង ១០ ដោយឥទ្ធិបាទមួយ ៗ ។ ក្នុងឥទ្ធិបាទ ៤ គឺ ឆន្ទៈ វិរិយៈ ចិត្តៈ វមំសា ។

ឈ្មោះថា **ឆន្ទដ្ឋោ** សភាពនៃឆន្ទៈ គឺ សភាពដែលប្រាថ្នានឹងធ្វើ ។

ឈ្មោះថា **មូលដ្ឋោ** សភាពដែលជាមូលនៃឆន្ទៈក្នុងវេលាផ្តើមភាវនា តាំងឆន្ទៈទុកជាគោល ។

ឈ្មោះថា **បាទដ្ឋោ** សភាពដែលជាបាទនៃឆន្ទៈ ព្រោះភាពជាគោលនៃសហជាតធម៌ ។ បាឋៈថា **បទដ្ឋោ** ក៏មាន ។

ឈ្មោះថា **បធានដ្ឋោ** សភាពដែលជាប្រធាននៃឆន្ទៈ ព្រោះភាពជាធំក្រៃលែង ឲ្យដល់ការសម្រេច ។

ឈ្មោះថា **ឥជ្ឈនដ្ឋោ** សភាពដែលសម្រេចនៃឆន្ទៈ ក្នុងវេលាប្រកបសេចក្តីព្យាយាម ។

ឈ្មោះថា **អធិមោក្ខដ្ឋោ** សភាពដែលបង្អោនទៅនៃឆន្ទៈ ព្រោះប្រកបដោយសទ្ធា ។

ឈ្មោះថា **បគ្គហដ្ឋោ** សភាពដែល ផ្គងទុកនៃឆន្ទៈ ព្រោះប្រកបដោយសេចក្តីព្យាយាម ។

ឈ្មោះថា **ឧបដ្ឋានដ្ឋោ** សភាពដែលតាំងមាំនៃឆន្ទៈ ព្រោះប្រកបដោយសតិ ។

ឈ្មោះថា **អវិក្ខេបដ្ឋោ** សភាពដែលមិនរាយមាយនៃឆន្ទៈ ព្រោះប្រកបដោយសមាធិ ។

ឈ្មោះថា **ទស្សនដ្ឋោ** សភាពដែលឃើញនៃឆន្ទៈ ព្រោះប្រកបដោយបញ្ញា ។



ឈ្មោះថា **វីរិយដ្ឋោ** សភាពនៃវីរិយៈ គឺ សភាពដែលផ្គងទុក ។

ឈ្មោះថា **មូលដ្ឋោ** សភាពដែលជាមូលនៃវីរិយៈ ក្នុងវេលាផ្តើមភាវនា តាំងវីរិយៈទុកជាគោល ។

ឈ្មោះថា **បគ្គហដ្ឋោ** សភាពដែកផ្គងទុកនៃវីរិយៈ ព្រោះមានការផ្គងទុកដោយខ្លួនឯង ។

ឈ្មោះថា **ចិត្តដ្ឋោ** សភាពនៃចិត្ត គឺ ច្រើនដោយការគិត ។

ឈ្មោះថា **មូលដ្ឋោ** សភាពជាមូលនៃចិត្ត ក្នុងវេលាផ្តើមភាវនាចិត្ត ទុកជាគោល ។

ឈ្មោះថា **វីមំសដ្ឋោ** សភាពនៃវីមំសា គឺ សភាពដែលចូលទៅពិចារណា ។

ឈ្មោះថា **មូលដ្ឋោ** សភាពជាមូលនៃវីមំសា ក្នុងវេលាផ្តើមភាវនា តាំងវីមំសាទុកជាគោល ។

ឈ្មោះថា **ទស្សនដ្ឋោ** មានសភាពដែលឃើញនៃវីមំសា ព្រោះពិចារណាដោយខ្លួនឯង ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ១៦ ប្រការ

មានបទថា **ទុក្ខស្ស បីឡនដ្ឋោ** សភាពដែលទុក្ខបៀតបៀន ជាដើម ដោយលក្ខណៈដ៏ពិតនៃសច្ចៈ ។

ឈ្មោះថា **បីឡនដ្ឋោ** សភាពដែលទុក្ខបៀតបៀន ព្រោះការឃើញទុក្ខនោះឯង ។

ឈ្មោះថា **សង្ខតដ្ឋោ** សភាពដែលទុក្ខត្រូវបច្ច័យតាក់ តែង ព្រោះឃើញសមុទ័យប្រមូលមកនូវទុក្ខ ។

ឈ្មោះថា **សន្តាបដ្ឋោ** សភាពដែលទុក្ខធ្វើឲ្យក្តៅក្រហាយ ព្រោះការឃើញមគ្គដែលមានភាពត្រជាក់ ព្រោះនាំសភាពដែលទុក្ខធ្វើឲ្យក្តៅក្រហាយ ចេញទៅ ។

ឈ្មោះថា **វិបរិណាមដ្ឋោ** សភាពដែលទុក្ខប្រែប្រួល ព្រោះឃើញការរលត់វត្ថុដែលមិនប្រែប្រួល ។

ឈ្មោះថា **អាយុហនដ្ឋោ** សភាពដែលសមុទ័យប្រមូលមក ព្រោះឃើញសមុទ័យនោះឯង ។

ឈ្មោះថា **និទានដ្ឋោ** សភាពដែលសមុទ័យជាហេតុ ព្រោះការឃើញទុក្ខដែលប្រមូលមក ដោយសមុទ័យ ។

ឈ្មោះថា **សញ្ញោគដ្ឋោ** សភាពដែលសមុទ័យជាប់ជំពាក់



ព្រោះការឃើញនិរោធដែលជាវិសញ្ញោគៈ សមុទ័យមិនជាប់ជំពាក់ ។

ឈ្មោះថា **បលិពោធដ្ឋោ** សភាពដែលសមុទ័យកង្វល់ ព្រោះការឃើញមគ្គដែលជានិយ្យានិកៈ ការនាំចេញ ។

ឈ្មោះថា **និស្សរណដ្ឋោ** សភាពដែលរលាស់ចេញ ព្រោះឃើញព្រះនិព្វាននោះឯង ។

ឈ្មោះថា **វិវេកដ្ឋោ** សភាពដែលនិរោធជាវិវេក ព្រោះការឃើញសមុទ័យដែលមិនមានវិវេក ។

ឈ្មោះថា **អសង្ខតដ្ឋោ** សភាពដែលនិរោធជាអសង្ខតៈ ព្រោះការឃើញមគ្គដែលជាសង្ខតៈ ។

ឈ្មោះថា **អមតដ្ឋោ** សភាពដែលនិរោធជាអមតៈ ព្រោះការឃើញទុក្ខជាពិស ។

ឈ្មោះថា **និយ្យានដ្ឋោ** សភាពដែលមគ្គនាំចេញ ព្រោះការឃើញមគ្គនោះឯង ។

ឈ្មោះថា **ហេតដ្ឋោ** សភាពដែលមគ្គជាហេតុ ព្រោះការឃើញសមុទ័យដែលមិនមែនហេតុនៃការសម្រេចនិព្វាន ។

ឈ្មោះថា **ទស្សនដ្ឋោ** សភាពដែលមគ្គឃើញ ព្រោះការ

ឃើញនិរោធដែលឃើញបានដ៏សែនលំបាក ។

ឈ្មោះថា **អាធិបតេយ្យដ្ឋោ** សភាពដែលមគ្គជាអធិបតី ដូចគ្នានឹងត្រកូលដែលធំ ព្រោះការឃើញទុក្ខ ដូចគ្នានឹងមនុស្សក្រខ្សត់ ។ អធិប្បាយថា រមែងប្រាកដ ។

ព្រះសារីបុត្ត ពោលដល់សច្ចៈមួយ ៗ មានលក្ខណៈមួយយ៉ាង ៤ ដោយការឃើញសច្ចៈនោះ ៗ និងដោយការឃើញសច្ចៈដទៃក្រៅពីសច្ចៈនោះ ដោយប្រការដូច្នេះ ។

ព្រះសារីបុត្តបានចង្អុលបង្ហាញការវិសជ្ជនា ១២ ប្រការមាន **តថដ្ឋោ** សភាពដ៏ពិតជាដើម ដោយ ១២ បទ ដែលសង្គ្រោះក្នុងធម៌ទាំងអស់ ។

បទថា **តថដ្ឋោ** សភាពដ៏ពិត បានដល់ សភាវៈតាមសេចក្ដីពិត ។

បទថា **អនត្តដ្ឋោ** សភាពជាអនត្តា បានដល់ សភាពដែលវៀរចាកអត្តា ។

បទថា **សច្ចដ្ឋោ** សភាពជាសច្ចៈ បានដល់ សភាពដែលមិននិយាយបោកបញ្ឆោត ។



បទថា **បដិវេធដ្ឋោ** សភាពជាបដិវេធ គឺ ការសម្រេច បានដល់ សភាពដែលគួរសម្រេច ។

បទថា **អភិជាននដ្ឋោ** បានដល់ សភាពដែលគួរដឹងដ៏ក្រៃលែង ។

បទថា **បរិជាននដ្ឋោ** បានដល់ សភាពដែលគួរកំណត់ដឹង ព្រោះកំណត់ដឹងដោយបញ្ញា ។

បទថា **ធម្មដ្ឋោ** សភាពជាធម៌ គឺ មានអត្ថថា ទ្រទ្រង់នូវសភាវៈទុក ជាដើម ។

បទថា **ធាតុដ្ឋោ** សភាពជាធាតុ មានអត្ថថា ជារបស់សូន្យជាដើម ។

បទថា **ញាតដ្ឋោ** បានដល់ សភាពដែលដឹង គឺ អាចដឹងបាន ។

បទថា **សច្ឆិកិរិយដ្ឋោ** គឺ សភាពដែលគួរធ្វើឲ្យជាក់ច្បាស់ ។

បទថា **ផស្សនដ្ឋោ** គឺ សភាពដែលគប្បីសម្ផស្សដោយញាណ ។

បទថា **អភិសមយដ្ឋោ** សភាពដែលគួរត្រាស់ដឹង បានដល់

សភាពដែលគួរដល់ដោយល្អយ៉ាងក្រៃលែង ដោយការពិចារណា ឬគួរបានចំពោះដោយញាណ ។

សូម្បីការបានចំពោះ លោកក៏ពោលថា ការត្រាស់ដឹង ដូចក្នុងបទមានជាអាទិ៍ថា **អត្ថាភិសមយា ធីរោ** បុគ្គលមានបញ្ញា ព្រោះត្រាស់ដឹងដ៏ក្រៃលែងនូវអត្ថ ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ៧ ប្រការ មាន **នេក្ខម្ម** ជាដើម ដោយឧបចារឈាន ។

បទថា **នេក្ខម្មំ** បានដល់ ការមិនលោភ ដែលជាបដិបក្ខដល់កាមច្ឆន្ទៈ ។

បទថា **អាលោកសញ្ញា** បានដល់ សញ្ញាក្នុងអាលោកនិមិត្ត ជាបដិបក្ខដល់ថីនមិទ្ធៈ ។

បទថា **អវិក្ខេបោ** បានដល់ សេចក្តីមិនរាយមាយ ជាបដិបក្ខដល់ឧទ្ធច្ចៈ ។

បទថា **ធម្មវវត្ថានំ** ការកំណត់ធម៌ បានដល់ ញាណដែលជាបដិបក្ខដល់វិចិកិច្ឆា ។

បទថា **ញាណំ** បានដល់ ញាណ ដែលបដិបក្ខដល់អវិជ្ជា ។



បទថា **បាមុជ្ជំ** បានដល់ បីតិដែលបដិបក្ខដល់អរតិ ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ៨ ប្រការ មានបឋមជ្ឈានជាដើម ដោយរូបសមាបត្តិ និងអរូបសមាបត្តិ ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញព្រហ្មវិហារ ៤ ដោយភ្ជាប់រូបឈានទុក ក្នុងលំដាប់រូបសមាបត្តិ ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់បទនេះ មាន **អនិច្ចានុបស្សនា** ការពិចារណាឃើញភាពមិនទៀងជាដើម ដោយមហាវិបស្សនា ១៨ ក្នុងចំណែកខាងដើមរបស់លោកុត្តរមគ្គ ។

ព្រះសារីបុត្ត បានពោលដល់អនុបស្សនា ៧ ចូលទៅប្រកបជាមួយរូបជាដើម ក្នុងចំណែកខាងក្រោយ , តែក្នុងនិទ្ទេសនេះ លោកពោលទុកទាំងអស់ ។ បើសួរថា ព្រោះហេតុអ្វីទើបមិនពោលដល់ឧទយព្វយានុបស្សនា ការពិចារណាឃើញ ការកើត និងការរលត់ ដោយការពិចារណាជាកលាបៈ ( ជាសំណុំ ) ។ ឆ្លើយថា បើលោកពោលដល់អនុបស្សនានេះ ជាការដែលលោកពោលដល់អនុបស្សនា សូម្បីទាំងពីរទាំងនេះផង ព្រោះអនិច្ចានុបស្សនាជាដើម សម្រេចដោយអំណាចវិបស្សនា ២ ទាំងនោះ ,

ឬបើពោលដល់វិបស្សនាទាំងនេះ ជាការពោលដល់វិបស្សនាទាំងនោះផង ព្រោះវិបស្សនា ២ ទាំងនោះ វៀរអនិច្ចានុបស្សនាជាដើមចេញហើយ ប្រព្រឹត្តទៅមិនបាន ។

បទថា **ខយានុបស្សនា** ការពិចារណាឃើញការអស់ទៅ បានដល់ ការឃើញ និងការដឹង សភាពរលត់នៃរូបក្ខន្ធជាដើមដែលជាបច្ចុប្បន្ន និងការឃើញ និងការដឹង សភាពរលត់នៃចិត្ត និងចេតសិក ដែលមានខន្ធជាអារម្មណ៍ក្នុងលំដាប់ការរលត់នៃខន្ធនោះ ៗ ។

បទថា **វយានុបស្សនា** ការឃើញភាពវិនាសទៅ បានដល់ ការឃើញ ការដឹងការរលត់នៃខន្ធក្នុងអតីត អនាគត ដែលបន្តគ្នាទៅជាមួយនឹងខន្ធនោះ លំដាប់នៃការឃើញ និងការដឹង ការរលត់នៃខន្ធក្នុងបច្ចុប្បន្ន ។

បទថា **វិបរិណាមានុបស្សនា** បានដល់ ការពិចារណាឃើញការប្រែប្រួលនៃខន្ធទាំងពួងថា ខន្ធដែលជាអតីត អនាគត បច្ចុប្បន្ន សូម្បីទាំងអស់ មានការប្រែប្រួល ព្រោះបង្អោនទៅក្នុងនិរោធដែលបានដល់ ការរលត់នោះ ។



បទថា **អនិមិត្តានុបស្សនា** ការពិចារណាឃើញការមិនមានគ្រឿងសម្គាល់ បានដល់ អនិច្ចានុបស្សនា ការពិចារណាឃើញភាពមិនទៀង របស់ព្រះយោគាវចរអ្នកឃើញភាពប្រែប្រួលរបស់សង្ខារទាំងពួងយ៉ាងនេះហើយ ពិចារណាឃើញ ដោយភាពជារបស់មិនទៀង ឈ្មោះថា អនិមិត្តានុបស្សនា ព្រោះមិនមានគ្រឿងសម្គាល់ដែលជាសភាពទៀង ដោយការលះបង់គ្រឿងសម្គាល់ដែលជាសភាពទៀងចេញបាន ។

បទថា **អប្បណិហិតានុបស្សនា** ការឃើញធម៌ ដែលមិនមានទីតាំង បានដល់ ការពិចារណាឃើញទុក្ខដែលប្រព្រឹត្តទៅក្នុងលំដាប់នៃអនិច្ចានុបស្សនា ។ ឈ្មោះថា អប្បណិហិតានុបស្សនា ព្រោះមិនមានទីតាំង ដោយការលះសេចក្ដីប្រាថ្នាសុខ ។

បទថា **សុញ្ញតានុបស្សនា** ការពិចារណាឃើញភាពសូន្យទទេ បានដល់ ការពិចារណាឃើញអនត្តា ដែលប្រព្រឹត្តទៅក្នុងលំដាប់ទុក្ខានុបស្សនា ។ ឈ្មោះថា សុញ្ញតានុបស្សនា ព្រោះឃើញសភាពជារបស់សូន្យទទេចាកខ្លួន ដោយលះបង់ការប្រកាន់មាំនូវតួខ្លួន ។

បទថា **អធិប្បញ្ញាធម្មវិបស្សនា** ការពិចារណាឃើញធម៌ដោយបញ្ញាដ៏ក្រៃលែង បានដល់ វិបស្សនាប្រព្រឹត្តទៅ ព្រោះកាន់យកនូវភាពសូន្យទទេ ដោយការរលត់ថា សង្ខាររបស់ព្រះយោគាវចរអ្នកឃើញហើយ ឃើញទៀតនូវការរលត់ របស់សង្ខារយ៉ាងនេះ ហើយពិចារណាឃើញ ដោយភាពជារបស់មិនទៀងជាដើម រមែងរលត់ទៅ , ក្រៅពីការរលត់របស់សង្ខាររមែងមិនមានអ្វីដទៃ ។ វិបស្សនានោះ លោកពោលថា អធិប្បញ្ញាធម្មវិបស្សនា ព្រោះធ្វើជារូបវិគ្រោះថា **អធិប្បញ្ញា ច ធម្មេសុ ច វិបស្សនា អធិប្បបញ្ញា** និងការឃើញច្បាស់ក្នុងធម៌ទាំងឡាយ ។

បទថា **យថាភូតញ្ញាណទស្សនំ** បញ្ញាឃើញតាមសេចក្តីពិត បានដល់ ភយតូបដ្ឋានញ្ញាណ បញ្ញាពិចារណាឃើញសង្ខារប្រាកដជារបស់គួរភ័យ ដែលប្រព្រឹត្តទៅហើយថា **សភយា សង្ខារា** សង្ខារទាំងឡាយគួរភ័យ ព្រោះឃើញការរលត់ហើយ រលត់ទៀត ។

បទថា **អាទីនវានុបស្សនា** ការពិចារណាឃើញទោស ដោយភយតូបដ្ឋានញ្ញាណ ដែលកើតឡើងហើយ ក្នុងភពទាំងពួងជាដើម ។ កាលលោកពោលដល់ អាទីនវានុបស្សនា ការពិចារណាឃើញទោស ដោយភយតូបដ្ឋានញ្ញាណ ជាការដែលលោកពោលដល់និព្វិទានុបស្សនា ការពិចារណាឃើញដោយសេចក្តីនឿយណាយទុកក្នុងនិទ្ទេសនេះ ព្រោះក្នុងបាលីថា ធម៌ទាំងនេះ គឺ ភយតូបដ្ឋានញ្ញាណ និងនិព្វិទាញ្ញាណ មានអត្ថតែមួយ ។ ក្នុងនិទ្ទេសនេះលោកមិនពោលទុក ព្រោះលោកពោលធ្វើបទទី ៤ ទុកខាងដើមហើយ ។



បទថា **បដិសង្ខានុបស្សនា** ការពិចារណារកផ្លូវ បានដល់ អនិច្ចានិបស្សនាញ្ញាណ ទុក្ខានុបស្សនាញ្ញាណ អនត្តានុបស្សនាញ្ញាណ កើតឡើង , មុញ្ចិតុកម្យតាញ្ញាណ បញ្ញាកំណត់ដឹងដល់ការប្រាថ្នានឹងចេញឲ្យផុត ការរកឧបាយដើម្បីចេញផុត កំណត់ដឹងដោយបដិសង្ខានុបស្សនា ។ កាលលោកពោលដល់បដិសង្ខានុបស្សនា ជាការដែលលោកពោលដល់មុញ្ចិតុកម្យតាញ្ញាណ និងសង្ខារុបេក្ខាញ្ញាណ បញ្ញាកំណត់ដឹងដោយភាពព្រងើយ ៗ ក្នុងសង្ខារ ដោយបាលីថា ធម៌ទាំងនេះ គឺ មុញ្ចិតុកម្យតាញ្ញាណ បដិសង្ខានុបស្សនាញ្ញាណ និងសង្ខារុបេក្ខាញ្ញាណ មានអត្ថតែមួយ

ព្យញ្ជនៈ ប៉ុណ្ណោះផ្សេងគ្នា ។

បទថា **វិវដ្ដនានុបស្សនា** ការពិចារណាឃើញឧបាយ ដែលនឹងចៀសចេញទៅ បានដល់ គោត្រភូញាណ ញាណដែលជាលំដាប់នៃអរិយមគ្គកើតឡើងដោយអនុលោមញ្ញាណ ញាណសមគួរដល់ការកំណត់ដឹង កាលលោកពោលដល់គោត្រភូញាណ ជាការដែលលោកពោលដល់អនុលោមញ្ញាណផង ព្រោះគោត្រភូញាណសម្រេចដោយអនុលោមញ្ញាណ , លោកពោលដល់លំដាប់នៃមហាវិបស្សនា ១៨ យ៉ាងនេះ រមែងរួមក្នុងបាលី ដូចដែលលោកពោលទុកក្នុងឥន្ទ្រិយកថា ថា ៖

ឥន្ទ្រីយ៍ ៥ ដោយអំណាចបឋមឈានរលស់ទៅ
ចាកឥន្ទ្រីយ៍ ៥ ក្នុងចំណែកខាងដើម , ឥន្ទ្រីយ
៥ ដោយអំណាចទុតិយឈាន រលាស់ចេញចាក
ឥន្ទ្រីយ៍ ៥ ក្នុងបឋមឈាន ១ ។

លោកពោលដល់ឥន្ទ្រីយ៍តាមលំដាប់បន្ថែមត ៗ ទៅទៀត ដោយន័យដើម រហូតដល់អរហត្តផល ។ ព្រោះដូច្នោះ មហា-វិបស្សនា ១៨ រមែងសមគួរ ក្នុងបាលីដោយលំដាប់ដូចដែលពោល



ហើយ ។

លោកពោលទុកក្នុងវិសុទ្ធិមគ្គថា ៖

បទថា **ខយានុបស្សនា** បានដល់ ញាណរបស់ព្រះយោ-គាវចរ អ្នកចែកឃនសញ្ញាចេញហើយ ឃើញការអស់ទៅ ឈ្មោះថាមិនទៀង ព្រោះអត្ថថា អស់ទៅ ។ បទថា **វិបរិណាមានុបស្សនា** បានដល់ ការឈានកន្លងចំណែកនោះ ៗ ដោយរូបសត្តកៈ និងអរូបសត្តកៈជាដើម និងឃើញការប្រព្រឹត្តទៅដោយប្រការដទៃ ។ មយ៉ាងទៀត ការឃើញការប្រែប្រួល ដោយអាការ ២ គឺ ដោយជរា និងមរណៈ របស់សត្វអ្នកកើតមកហើយ ។ បទថា **យថា-ភូតញ្ញាណទស្សនំ** ការដឹង និងការឃើញតាមសេចក្ដីពិត បានដល់ ការកំណត់នាមរូបព្រមដោយបច្ច័យ ។ បទនោះ ក្នុងបាលីប្រាកដដូចជាបទខុស ។ បទថា **វិវដ្ដនានុបស្សនា** ការពិចារណាឃើញនូវឧបាយ ដែលនឹងចេញទៅ លោកពោលថា បានដល់សង្ខារុបេក្ខាញាណ និងអនុលោមញ្ញាណ ។ បទនោះ ក្នុងបាលីមើលដូចជាខុស ។ ព្រោះលោកពោលទុកក្នុងអរិយកថា ថា ៖

អព្យាកតធម៌ ដែលជាកិរិយារបស់អាវជ្ជនៈ

ដើម្បីប្រយោជន៍ ក្នុងការពិចារណាឃើញ
ឃើញសភាពជារបស់មិនទៀង ឈ្មោះថា
វិញ្ញាណចរិយា ។ ការពិចារណាឃើញ
មិនទៀង ឈ្មោះថា ញាណចរិយា ។ល។
អព្យាកតធម៌ដែលជាកិរិយារបស់អាវជ្ជនៈ
ដើម្បីប្រយោជន៍ ក្នុងការពិចារណារកផ្លូវ
ឈ្មោះថា វិញ្ញាណចរិយា ។ បដិសង្ខា-
នុបស្សនា ជាញាណចរិយា ១ ។

លោកពោលដល់អាវជ្ជនៈដោយឡែកពីគ្នា របស់ញាណដែលបានអាវជ្ជនៈផ្សេង ៗ គ្នា ។ តែលោកមិនពោលដល់អាវជ្ជនៈដើម្បីពិចារណាឃើញឧបាយដែលត្រូវចេញទៅ ហើយពោលថា វិវដ្ដានុបស្សនា ជាញាណចរិយា ។ នឹងគប្បីថា សង្ខារុបេក្ខា-ញាណ និងអនុលោមញ្ញាណ នឹងគប្បីជាវិវដ្ដានុបស្សនាញាណបាន , ក៏គួរពោលដល់អាវជ្ជនៈដើម្បីប្រយោជន៍ដល់ញាណនោះ ព្រោះអាវជ្ជនៈរបស់ញាណនោះមានព្រម , តែលោកមិនពោលដល់អាវជ្ជនៈដើម្បីប្រយោជន៍ដល់ញាណនោះ ។ គោត្រភូញាណ



មិនមានអាវជ្ជនៈផ្សេង ៗ គ្នា ព្រោះកើតឡើងក្នុងអាវជ្ជនវិថីនៃអនុលោមញ្ញាណនោះឯង ។ ព្រោះដូច្នោះ គោត្រភូញាណនោះឯងជាវិវដ្ដនានុបស្សនា ទើបត្រឹមត្រូវ ព្រោះលោកមិនពោលដល់អាវជ្ជនៈ ដើម្បីប្រយោជន៍ដល់វិវដ្ដនានុបស្សនា ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ៨ ប្រការ មានសោតាបត្តិមគ្គជាដើម ដោយអំណាចមគ្គ និងផល ដែលជាលោកុត្តរៈ ។ ការដល់ខ្សែនៃមគ្គ ឈ្មោះថា **សោតាបត្តិមគ្គ** , សោតាបត្តិមគ្គនោះឯងជា **មគ្គ** ឈ្មោះថា សោតាបត្តិមគ្គ ។

ផលនៃការដល់នូវខ្សែ ឈ្មោះថា **សោតាបត្តិផល** , ឈ្មោះថា **សមាបត្តិ** ព្រោះអត្ថថា ចូលដល់ ។ សោតាបត្តិផលនោះឯងជាសមាបត្តិ ឈ្មោះថា សោតាបត្តិផលសមាបត្តិ ។

ឈ្មោះថា **សកទាគាមី** ព្រោះអត្ថថា មកកាន់លោកនេះតែម្ដងប៉ុណ្ណោះ ដោយអំណាចបដិសន្ធិ , មគ្គនៃសកទាគាមីនោះ ឈ្មោះថា សកទាគាមិមគ្គ ។

ឈ្មោះថា **អនាគាមី** ព្រោះអត្ថថា មិនមកកាន់កាមភព ដោយអំណាចបដិសន្ធិនោះឯង , មគ្គនៃអនាគាមីនោះ ឈ្មោះថា

អនាគាមិមគ្គ ។ ផលនៃអនាគាមី ឈ្មោះថា **អនាគាមិផល** ។

ឈ្មោះថា **អរហំ** ព្រោះឆ្ងាយចាកកិលេសទាំងឡាយ , ព្រោះកម្ចាត់សត្រូវ គឺ កិលេស , ព្រោះកាច់បំបាក់កាំរបស់សង្សារចក្របាន , ព្រោះមិនលបធ្វើបាប , ព្រោះគួរដល់បច្ច័យជាដើម ។ ភាពជាអរហន្ត ឈ្មោះថា **អរហត្តំ** នោះគឺអ្វី ? គឺ **អរហត្តផល** ។ មគ្គនៃអរហត្ត ឈ្មោះថា អរហត្តមគ្គ ។ ផលនៃអរហត្តនោះឯង ឈ្មោះថា អរហត្តផល ។

ព្រះសារីបុត្តបានចង្អុលបង្ហាញដល់ការវិសជ្ជនា ៣៣ ប្រការ មានបទថា **អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ** បានដល់ សទ្ធិន្ទ្រីយ៍ ដោយសេចក្តីថា បង្អោនចិត្តជឿជាដើម , បទថា **តថដ្ឋេន សច្ចា** បានដល់ **សច្ច** ដោយសេចក្តីថា ទៀងពិតជាទីបំផុត ព្រះសារីបុត្តបានចង្អុលបង្ហាញដល់ការវិសជ្ជនា ៣៣ ប្រការ មានបទថា **ឥន្ទ្រិយស្ស អធិមោក្ខដ្ឋោ** សភាពដែលបង្អោន ជឿនៃសទ្ធិន្ទ្រីយ៍ជាដើម ក្នុងចំណែកខាងក្រោយ ។ បានបង្ហាញអត្ថដោយធម៌ ទាំងឡាយក្នុងបទនោះដោយអស់ជើង , ក្នុងបទនេះ បានបង្ហាញធម៌ទាំងឡាយដោយអត្ថ នេះជាការផ្សេងគ្នា ។ គប្បីជ្រាបការផ្សេងគ្នានៃការ



វិសជ្ជនា ៤ ប្រការ មានបទថា **អវិក្ខេបដ្ឋេន សមថោ** សមថៈ ដោយសេចក្តីថា មិនរាយមាយជាដើម និងការវិសជ្ជនា ៤ ប្រការ មានបទថា **សមថស្ស អវិក្ខេបដ្ឋោ** សភាពមិនរាយមាយនៃសមថៈជាដើម ដោយន័យដូចពោលហើយ ក្នុងខាងក្រោយនោះឯង ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ៨ ប្រការ មានបទថា **សំវរដ្ឋេន** ដោយអត្ថថា សង្រួមជាដើម ដោយអំណាចធម៌មានសីលជាខាងដើម មានពលៈជាទីបំផុត ។

បទថា **សីលវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃសីល បានដល់ សីល ៤ យ៉ាង មានបាតិមោក្ខសំវរសីល ដែលបរិសុទ្ធិដោយល្អជាដើម , ឈ្មោះថា សីលវិសុទ្ធិ ព្រោះជម្រះមន្ទិល គឺ ភាពជាអ្នកទ្រុស្តសីល ។

បទថា **ចិត្តវិសុទ្ធិ** ការបរិសុទ្ធិនៃចិត្ត បានដល់ សមាបត្តិ ៨ ព្រមដោយឧបចារៈ ។ ក្នុងបទនេះ លោកពោលសមាធិ ដោយមាតិកាថា **ចិត្ត** , សមាធិនោះ ឈ្មោះថា ចិត្តវិសុទ្ធិ ព្រោះជម្រះមន្ទិលរបស់ចិត្ត ។

ឈ្មោះថា **ទិដ្ឋិវិសុទ្ធិ** ការបរិសុទ្ធិនៃទិដ្ឋិ បានដល់ ការ

ឃើញនាមរូបតាមសេចក្តីពិត ឈ្មោះថា ទិដ្ឋិវិសុទ្ធិ ព្រោះជម្រះមន្ទិលរបស់ទិដ្ឋិ ៧ ។

បទថា **មុត្តដ្ឋេន** ដោយអត្ថថា រលាស់ផុត បានដល់ រលាស់ផុតចាកឧបកិលេស ដោយអំណាចតទង្គវិមុត្តិ និងបង្អោនទៅក្នុងអារម្មណ៍ ។

បទថា **វិមោក្ខោ** បានដល់ ការរលាស់ផុតដោយតទង្គ-វិមោក្ខ ។

បទថា **បដិវេធដ្ឋេន វិជ្ជា** វិជ្ជា ដោយអត្ថថា ឃើញច្បាស់ បានដល់ **បុព្វេនិវាសានុស្សតិញ្ញាណ** ឈ្មោះថា ដោយអត្ថថា ឃើញច្បាស់ក្នុងភពមុន ។

បទថា **បដិវេធដ្ឋេន** បានដល់ ដោយអត្ថថា ដឹងច្បាស់ ។

បទថា **បរិច្ចាគដ្ឋោ វិមុត្តិ** ភាពរលាស់ផុតដោយការលះបានដល់ ឈ្មោះថា ផលវិមុត្តិ ព្រោះផុតចាកការលះ ។

បទថា **សមុច្ឆេទដ្ឋេន ខយេ ញាណំ** ញាណក្នុងការអស់ទៅដោយដាច់ខាត បានដល់ ញាណក្នុងអរិយមគ្គធ្វើភាពអស់ទៅនៃកិលេស ដោយលះកិលេសបានដាច់ខាត ។



បទថា **បដិប្បស្សទ្ធដ្ឋេន អនុប្បាទេ ញាណំ** ញាណក្នុងការមិនកើតឡើង ដោយអត្ថថា រម្ងាប់ បានដល់ ញាណក្នុងអរិយផលដែលកើតឡើង ក្នុងទីបំផុតនៃការមិនកើតឡើងនៃកិលេសដែលសម្ងាប់ដោយមគ្គនោះ ៗ ដែលមិនកើតដោយបដិសន្ធិ ព្រោះរម្ងាប់យោគៈ គឺ មគ្គកិច្ចបានហើយ ។

ព្រះសារីបុត្ត បានចង្អុលបង្ហាញដល់ការវិសជ្ជនា ៩ ប្រការមានបទថា **ឆន្ទោមូលដ្ឋេន** ឆន្ទៈ ដោយអត្ថថា ជាមូលដ្ឋានជាដើម ដោយអំណាចអរិយមគ្គ ដែលជាខាងដើម កណ្តាល និងចុងបំផុត ។

បទថា **ឆន្ទោ មូលដ្ឋេន** បានដល់ ឆន្ទៈ គឺ ភាពជាអ្នកប្រាថ្នាដើម្បីនឹងធ្វើកុសលធម៌ទាំងឡាយ ដោយអត្ថថា ជាមូលដ្ឋានព្រោះជាមូលនៃការបដិបត្តិ និងសេចក្តីសម្រេច ។

បទថា **មនសិការោ សមុដ្ឋានដ្ឋេន** មនសិការ ដោយអត្ថថា ជាសមុដ្ឋាន បានដល់ យោនិសោមនសិការ ដោយអត្ថថា ជាសមុ-ដ្ឋាន ព្រោះញុំាងកុសលធម៌ទាំងអស់ឲ្យតាំងឡើង ។

បទថា **ផស្សោ សមោធានដ្ឋេន** ផស្សៈ ដោយអត្ថថា ប្រមូលមក បានដល់ ព្រោះវេទនាជាប្រធានហេតុនៃតណ្ហា ដោយ

ចំពោះ , បើទឹងលះតណ្ហា រមែងលះដោយវេទនាដែលកំណត់ដឹងដោយចំពោះ , និងផស្សៈជាបធានហេតុនៃវេទនានោះ , កាលបើកំណត់ដឹងផស្សៈនោះហើយ ជាការកំណត់ដឹងវេទនាផង ដូច្នោះ លោកទើបពោលផស្សៈក្នុងវត្ថុដែលគួរដឹងច្បាស់ ៧ មុន ។ ក៏ផស្សៈនោះ ឈ្មោះថា គួរដឹងច្បាស់ ដោយអត្ថថា ប្រមូលមក ព្រោះលោកពោលថា **តិកសន្និបាតបច្ចុប្បដ្ឋានោ** មានការប្រមូលមករួមគ្នារវាងវត្ថុ អារម្មណ៍ និងវិញ្ញាណ , ៣ យ៉ាងនេះ ជាអាការប្រាកដ ព្រោះប្រកាសដោយអំណាចហេតុរបស់ខ្លួន ពោលគឺ ការប្រមូលមកនូវធម៌ទាំង ៣ ។ តែអាចារ្យពួកខ្លះពោលថា ផស្សៈ គឺញាណផស្សៈ ។

ក៏ព្រោះវេទនាញុំាងចិត្ត និងចេតសិក ឲ្យប្រព្រឹត្តទៅក្នុងអំណាចរបស់ខ្លួន រមែងប្រជុំ គឺ រមែងរួមចូលទៅក្នុងចិត្ត និងចេតសិកនោះ , ឬចូលទៅកាន់ចិត្តសន្តាននោះឯង , ដូច្នោះ លោកទើបពោលថា **សមោសរណដ្ឋេន អភិញ្ញេយ្យា** វេទនាគួរដឹងច្បាស់ ដោយអត្ថថា **ប្រជុំ** ។ ចំណែកអាចារ្យពួកមួយពោលថា ការកំណត់ដឹងសូម្បីទាំងអស់ រមែងប្រជុំចុះក្នុងវេទនា



ទាំងឡាយ , កាលបើកំណត់ដឹងវេទនាហើយ ជាការកំណត់ដឹងទីតាំងរបស់តណ្ហាទាំងអស់បាន ។ នោះព្រោះហេតុអ្វី ? ព្រោះតណ្ហាទាំងអស់ មានវេទនាជាបច្ច័យ , ដូច្នោះ វេទនាទើបគួរដឹងច្បាស់ ដោយអត្ថថា **ប្រជុំ** ព្រោះសមាធិឈ្មោះថា ជាប្រមុខជាធំ របស់កុសលធម៌ទាំងឡាយ ព្រោះប្រមូលទុកនូវចិត្ត និងចេតសិកទាំងឡាយ ដូចកំពូលកូដាគារ ជាប្រមុខ ព្រោះជាទីភ្ជាប់ទុកដោយឈើផ្ទោង , ដូច្នោះ លោកទើបពោលថា **សមាធិ បមុខដ្ឋេន** សមាធិ ដោយអត្ថថា **ជាប្រធាន** ។ បាឋៈថា **បាមុក្ខដ្ឋេន** ខ្លះ ។

ព្រោះសតិជាធំ ក្នុងការកំណត់អារម្មណ៍ របស់អ្នកចម្រើនសមថវិបស្សនា , បើអារម្មណ៍កំណត់ទុកបាន ដោយកុសលធម៌សូម្បីទាំងអស់ រមែងញុំាងកិច្ចរបស់ខ្លួន ៗ ឲ្យសម្រេច , ដូច្នោះ លោកទើបពោលថា **សតិ អាធិបតេយ្យដ្ឋេន** សតិ ដោយអត្ថថា **ជាធំ** ។

បទថា **បញ្ញា តទុត្តរដ្ឋេន** បញ្ញា ដោយអត្ថថា ប្រសើរជាងកុសលនោះ ៗ បានដល់ **អរិយមគ្គបញ្ញា** ឈ្មោះថា គួរ

ដឹងច្បាស់ ដោយសេចក្តីថា **ក្រៃលែង** គឺ ប្រសើរជាងកុសលនោះ ៗ ។ ម្យ៉ាងទៀត ឈ្មោះថា **តទុត្តរា** ព្រោះអត្ថថា ឈានកន្លងចាកកិលេសទាំងឡាយ ឬចាកសង្សារវដ្ត , អត្ថនៃតទុត្តរានោះ ឈ្មោះថា **តទុត្តរដ្ឋោ** សេចក្តីថា ប្រសើរជាងកុសលធម៌នោះ ៗ ។ ដោយ **តទុត្តរដ្ឋោ** នោះ ។ បាឋៈថា **តតុត្តរដ្ឋេន** ខ្លះ សេចក្តីថា ដោយភាពក្រៃលែងជាងធម៌នោះ ។

បទថា **វិមុត្តិ សារដ្ឋេន** វិមុត្តិដោយអត្ថថា ជាខ្លឹមសារ បានដល់ **ផលវិមុត្តិ** ឈ្មោះថា ជាខ្លឹមសារ ព្រោះសភាព តាំងមាំ ដោយមិនវិនាស , សូម្បីព្រោះឈានកន្លងវត្ថុនោះ ហើយមិនមានវត្ថុដទៃដែលគប្បីស្វែងរក ក៏ឈ្មោះថា ជាខ្លឹមសារ ។ វិមុត្តិនោះ គួរដឹងច្បាស់ ដោយអត្ថថា ជាខ្លឹមសារនោះ ។

បទថា **អមតោគធំ និព្វានំ** និព្វានដែលញ៉ាំងចុះក្នុងអមតៈ ឈ្មោះថា **អមត** ព្រោះនិព្វានមិនមាន **មត** គឺ សេចក្តីស្លាប់ , ឈ្មោះថា **អមត** ព្រោះជាថ្នាំកែរោគពិស គឺ កិលេសខ្លះ , ឈ្មោះថា **ឱគធំ** ព្រោះជាគោលរបស់សត្វទាំងឡាយ ដោយការធ្វើឲ្យជាក់ច្បាស់ ។ ឈ្មោះថា **និព្វានំ** ព្រោះក្នុងនិព្វាននេះ មិន



មានគ្រឿងជោតក្រង គឺ តណ្ហា ។ និព្វាននោះ គួរដឹងច្បាស់ ដោយអត្ថថា **ជាទីបំផុត** ព្រោះជាពាក្យទូន្មានសព្វគ្រប់អស់ហើយ ។ ក្នុងអភិញ្ញេយ្យនិទ្ទេសនេះ រួមការវិសជ្ជនាបាន ៧.៧៤០ បទ ដោយប្រការដូច្នេះ ។

សរុបធម៌ទាំងនោះ ដែលព្រះសារីបុត្តបានចង្អុលបង្ហាញទុកហើយយ៉ាងនេះថា ធម៌ណា ៗ ដែលដឹងច្បាស់ហើយ , ធម៌នោះ ៗ ជាគុណដែលដឹងហើយ , អធិប្បាយថា ជាគុណ ដែលដឹងហើយ ព្រោះធ្វើបទនោះឲ្យជាប្រធាន ។

បទថា **តំញាតដ្ឋេន ញាណំ** ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹងធម៌នោះ សេចក្តីថា ឈ្មោះថា ញាណ ព្រោះអត្ថថា ដឹងធម៌មានប្រការដូចពោលហើយនោះ ។

បទថា **បជាននដ្ឋេន បញ្ញា** ឈ្មោះថា បញ្ញា ព្រោះអត្ថថា ដឹងទូទៅ គឺ ដឹងដោយអាការ ។

ពាក្យសួរដែលលោកសួរទុកតាំងពីដើមថា **តេន វុច្ចតិ** លោកសម្តែងសរុបទុក ។ ដោយហេតុនោះ ទើបមានសេចក្តីថា បញ្ញាជាគ្រឿងទ្រទ្រង់ចាំទុក ដែលបានស្តាប់មក គឺ គ្រឿងដឹង

ច្បាស់នូវធម៌ដែលបានស្ដាប់មកហើយនោះ ថា ធម៌ទាំងនេះគួរដឹងច្បាស់ **ជាសុតមយញ្ញាណ** ដោយប្រការដូច្នេះ ។

( ចប់អដ្ឋកថា ទុតិយភាណវារ )

## អដ្ឋកថា បរិញ្ញេយ្យនិទ្ទេស

### ( តតិយភាណវារ )

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបរិញ្ញេយ្យនិទ្ទេសដូចតទៅនេះ ៖ លោកសង្គ្រោះបរិញ្ញា ៣ គឺ ញាតបរិញ្ញា ១ តីរណបរិញ្ញា ១ បហានបរិញ្ញា ១ ដោយបរិញ្ញាស័ព្ទទុកក៏ពិត តែក្នុងនិទ្ទេសនេះ លោកបំណងយក **តីរណបរិញ្ញា** ប៉ុណ្ណោះ ព្រោះលោកពោលដល់ញាតបរិញ្ញាថា **អភិញ្ញេយ្យា** គួរដឹងច្បាស់ដ៏ក្រៃលែងទុកហើយក្នុងខាងក្រោយ ព្រោះលោកពោលដល់ បហានបរិញ្ញាថា **បហាតព្វា** គួរលះ ទុកក្នុងផ្នែកតទៅទៀត ។

បទថា **ផស្សោ សាសវោ ឧបាទានិយោ** ផស្សៈដែលមានអាសវៈជាទីតាំងនៃឧបាទាន បានដល់ ផស្សៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ជាបច្ច័យ នៃអាសវៈ និងឧបាទាន ។ ពិតហើយ



ផស្សៈនោះឈ្មោះថា **សាសវ** ព្រោះធ្វើខ្លួនឲ្យជាអារម្មណ៍ ព្រមជាមួយអាសវៈដែលប្រព្រឹត្តទៅ ឈ្មោះថា **ឧបាទានិយ** ព្រោះចូលដល់ភាពជាអារម្មណ៍ ហើយបង្អាក់ឧបាទានទុក ដោយការចងទុកជាមួយឧបាទាន ។ ព្រោះកាលបើផស្សៈកំណត់ដឹងបាន ដោយតីរណបរិញ្ញា អរូបធម៌សូម្បីដែលសល់ រមែងកំណត់ដឹងបាន ដោយផស្សៈជាប្រធាន និងរូបធម៌ រមែងកំណត់ដឹងបានដោយប្រព្រឹត្តទៅតាមផស្សៈនោះ , ដូច្នោះ លោកទើបពោលផស្សៈតែម្យ៉ាងប៉ុណ្ណោះ ។ បទថា **នាមំ** បានដល់ ខន្ធ ៤ និងនិព្វានដែលមិនមានរូប ។ បទថា **រូបំ** បានដល់ មហាភូតរូប ៤ និងឧបាទាយរូប ២៤ អាស្រ័យមហាភូតរូប ៤ ។ ខន្ធ ៤ ឈ្មោះថា នាម ព្រោះអត្ថថា បង្អោនទៅ ។ ពិតហើយ ខន្ធទាំងនេះ មានអារម្មណ៍ជាតួនាំ រមែងបង្អោនទៅ ។ នាម សូម្បីទាំងអស់ក៏ឈ្មោះថា នាម ក្នុងអត្ថថា ឲ្យបង្អោនទៅ ។ ពិតហើយ ខន្ធ ៤ ញុំាងគ្នានឹងគ្នាឲ្យបង្អោនទៅក្នុងអារម្មណ៍ , និព្វាន ញុំាងធម៌ដែលមិនមានទោសឲ្យបង្អោនទៅក្នុងខ្លួន ព្រោះជាបច្ច័យនៃសភាពជាធំក្នុងអារម្មណ៍ ។ ឈ្មោះថា **រូបំ** ព្រោះអត្ថថា ប្រែប្រួលទៅដោយ

ភាពត្រជាក់ជាដើម ដោយអំណាច **សន្តតិ** ការបន្ត ។

បទថា **រូបនដ្ឋេន** បានដល់ ការកម្រើក ។ ធម្មជាតិដែលត្រូវភាពត្រជាក់ជាដើម ប៉ះខូចដោយការប្រែប្រួលរបស់សន្តតិ លោកពោលថា **រូបំ** ។ តែក្នុងទីនេះ បទថា **នាមំ** លោកបំណងយកនាម ដែលជាលោកិយៈប៉ុណ្ណោះ , ចំណែករូបជាលោកិយៈដោយចំណែកតែម្យ៉ាង ។

បទថា **តិស្សោ វេទនា** វេទនា ៣ បានដល់ សុខវេទនា ទុក្ខវេទនា អទុក្ខមសុខវេទនា ។ វេទនាទាំងនោះប្រព្រឹត្តទៅក្នុងលោកប៉ុណ្ណោះ ។

បទថា **អាហារា** បានដល់ បច្ច័យ ។ បច្ច័យ ឈ្មោះថា **អាហារា** ព្រោះនាំមកនូវផលរបស់ខ្លួន ។ អាហារ ៤ យ៉ាង គឺ កវឡីង្ការាហារ ( អាហារ គឺ ដុំបាយ ) ១ , ផស្សាហារ ( អាហារ គឺ ផស្សៈ ) ១ , មនោសញ្ចេតនាហារ ( អាហារ គឺ មនោស-ញ្ចេតនា ) ១ , វិញ្ញាណាហារ ( អាហារ គឺ វិញ្ញាណ ) ១ ។ ឈ្មោះថា **កវឡីការ** ព្រោះគួរធ្វើឲ្យជាដុំដោយវត្ថុ ។ ឈ្មោះថា **អាហារ** ព្រោះគួរស៊ីលេប ។ បទនេះជាឈ្មោះ ឱជៈ ដែលជាវត្ថុ



មានបាយ និងនំ ធ្វើដោយសណ្តែកខៀវជាដើម ។ ឱជៈនោះ ឈ្មោះថា អាហារ ព្រោះនាំមកនូវរូបមានឱជៈជាទី ៨ ។ ផស្សៈ ៦ យ៉ាង មានចក្ខុសម្ផ័ស្សជាដើម ឈ្មោះថា អាហារ ព្រោះនាំមកនូវវេទនា ៣ ។ ឈ្មោះថា មនោសញ្ចេតនា ព្រោះមានការតាំងចិត្តរបស់ចិត្ត មិនមែនរបស់សត្វ ដូចការដែលចិត្តមានអារម្មណ៍តែមួយ ។ ម្យ៉ាងទៀត សញ្ចេតនា សម្បយុត្តជាមួយចិត្ត ឈ្មោះថា មនោសញ្ចេតនា ដូចរថទឹមដោយសេះអាជានេយ្យ ។ បានដល់ កុសលចេតនា និងអកុសលចេតនា ប្រព្រឹត្តទៅក្នុងភូមិ ៣ ។ មនោសញ្ចេតនានោះ ឈ្មោះថា អាហារ ព្រោះនាំមកនូវភព ៣ ។

បទថា **វិញ្ញាណំ** បានដល់ បដិសន្ធិវិញ្ញាណ ១៩ យ៉ាង ។ បដិសន្ធិវិញ្ញាណនោះ ឈ្មោះថា អាហារ ព្រោះនាំមកនូវនាមរូបក្នុងកាលបដិសន្ធិ ។

បទថា **ឧបាទានក្ខន្ធា** បានដល់ ខន្ធ ដែលជាគោចររបស់ឧបាទាន គប្បីឃើញការលប់បទកណ្តាល **មជ្ឈបទលោបោ** ។ ម្យ៉ាងទៀត ខន្ធដែលកើតព្រោះឧបាទាន ឈ្មោះថា **ឧបាទានក្ខន្ធ** ដូចភ្លើងឆេះស្មៅ ឆេះអង្កាម ។ ម្យ៉ាងទៀត ខន្ធដែលជឿស្តាប់

ឧបាទាន ឈ្មោះថា ឧបាទានក្ខន្ធ ដូចរាជបុរស ។ ម្យ៉ាងទៀត ខន្ធដែលមានឧបាទានជាដែនកើត ឈ្មោះថា ឧបាទានក្ខន្ធ ដូចដើមឈើមានផ្កា ដើមឈើមានផ្លែ ។ **ឧបាទានមាន ៤** យ៉ាង គឺ កាមុបាទាន គឺ ប្រកាន់កាម ១ , ទិដ្ឋុបាទាន គឺ ប្រកាន់ទិដ្ឋិ ១ , សីលព្វតុបាទាន គឺ ប្រកាន់សីលវត្ត ១ , អត្តវាទុបាទាន គឺ ប្រកាន់វាទៈថាខ្លួន ១ ។ ប៉ុន្តែដោយអត្ថ ឈ្មោះថា ឧបាទាន ព្រោះប្រកាន់ខ្ជាប់ ។

ឧបាទានក្ខន្ធ ៥ គឺ រូបូបាទានក្ខន្ធ ១ , វេទនូបាទានក្ខន្ធ ១ , សញ្ញូបាទានក្ខន្ធ ១ , សង្ខារូបាទានក្ខន្ធ ១ , វិញ្ញាណូបាទានក្ខន្ធ ១ ។

បទថា **ឆ អជ្ឈត្តិកានិ អាយតនានិ** បានដល់ អាយតនៈក្នុង ៦ គឺ ចក្ខ្វាយតនៈ ១ , សោតាយតនៈ ១ , ឃានាយតនៈ ១ , ជិវ្ហាយតនៈ ១ , កាយាយតនៈ ១ , មនាយតនៈ ១ ។

បទថា **សត្ត វិញ្ញាណដ្ឋិតិយោ** បានដល់ វិញ្ញាណឋិតិ ភូមិជាទីតាំងនៃវិញ្ញាណ ៧ ។ វិញ្ញាណឋិតិ មានអ្វីខ្លះ ?

ព្រះមានព្រះភាគទ្រង់ត្រាស់ទុកដូច្នេះថា ម្នាលភិក្ខុទាំង-



ឡាយ សត្វពួកមួយ មានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចជាមនុស្សទាំងឡាយ ទេពពួកខ្លះ វិនិបាតិកៈ ប្រេតពួកខ្លះ នេះជាវិញ្ញាណឋិតិ ទី ១ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចជា ទេពអ្នកនៅក្នុងពួកព្រហ្ម ដែលកើតក្នុងភូមិបឋមឈាន នេះជាវិញ្ញាណឋិតិ ទី ២ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ មានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចជា ពួកទេពអាភស្សរា នេះជាវិញ្ញាណឋិតិ ទី ៣ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ មានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចជា ពួកទេពសុភកិណ្ហា នេះជាវិញ្ញាណឋិតិ ទី ៤ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ ឈានកន្លងរូបសញ្ញាដោយប្រការទាំងពួង រំលត់បដិឃសញ្ញា មិនមនសិការដល់សញ្ញាផ្សេងគ្នា ជាអ្នកចូលដល់អាកាសានញ្ចាយតនៈថា **អនន្តោ អាកាសោ** អាកាសមិនមានទីបំផុត នេះជា វិញ្ញាណឋិតិ ទី ៥ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ ឈានកន្លងអាកាសា-

នញ្ចាយតនៈដោយប្រការទាំងពួង ជាអ្នកចូលដល់វិញ្ញាណញ្ចាយ-តនៈថា **អនន្តំ វិញ្ញាណំ** វិញ្ញាណមិនមានទីបំផុត នេះជាវិញ្ញាណឋិតិ ទី ៦ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ ឈានកន្លងវិញ្ញាណ-ញ្ចាយតនៈដោយប្រការទាំងពួង ជាអ្នកចូលដល់អាកិញ្ចញ្ញាយ-តនៈថា **នត្ថិ កិញ្ចិ** មិនមានអ្វី ៗ នេះជាវិញ្ញាណឋិតិ ទី ៧ ។

ម្នាលភិក្ខុទាំងឡាយ វិញ្ញាណឋិតិ ៧ ដូច្នេះឯង ១ ។

បទថា **វិញ្ញាណដ្ឋិតិយោ** ភូមិជាទីតាំងនៃវិញ្ញាណ បានដល់ខន្ធ ព្រមទាំងវិញ្ញាណដែលជាដ្ឋាននៃបដិសន្ធិវិញ្ញាណ ។

ក្នុងបទទាំងនោះ បទថា **សេយ្យថាបិ** ជានិបាតចុះក្នុងអត្ថថា ការបញ្ជាក់ ។

បទថា **មនុស្សា** គឺ មនុស្ស សូម្បីពីរនាក់នឹងដូចជាមនុស្សតែម្នាក់ ក៏មិនមានដោយវណ្ណៈ និងសណ្ឋានជាដើម របស់មនុស្ស មិនមានប្រមាណក្នុងចក្រវាឡដែលរកប្រមាណមិនបាន ។ សូម្បីមនុស្សនឹងដូចគ្នាដោយវណ្ណៈ ឬសណ្ឋាន ក៏មិនដូចគ្នាដោយការមើល និងការរកជាដើម , ព្រោះដូច្នោះ លោកទើបពោល



ថា **នានត្តកាយា** មានកាយផ្សេងគ្នា ។

បដិសន្ធិសញ្ញា របស់មនុស្សទាំងនោះ ជាតិហេតុកៈខ្លះ ទ្វិហេតុកៈខ្លះ , ព្រោះដូច្នោះ លោកទើបពោលថា **នានត្តកាយា** មានកាយផ្សេងគ្នា ។

បទថា **ឯកច្ចេ ច ទេវា** ទេពពួកខ្លះ បានដល់ កាមាវចរ-ទេព ៦ ជាន់ ។ បណ្ដាទេពទាំងនោះ ទេពពួកខ្លះ មានកាយពណ៌ខៀវ , ពួកខ្លះ មានពណ៌សម្បុរលឿងជាដើម , តែសញ្ញារបស់ទេពទាំងនោះ ប្រព្រឹត្តទៅជាមួយនឹងតិហេតុកៈខ្លះ ទ្វិហេតុកៈខ្លះ , មិនជាអហេតុកៈទេ ។

បទថា **ឯកច្ចេ ច វិនិបាតិកា** វិនិបាតពួកខ្លះ បានដល់វេមានិកប្រេតទាំងឡាយដទៃ មានជាអាទិ៍យ៉ាងនេះ គឺ យក្ខិនីឈ្មោះ បុនព្វសុមាតា បិយំករមាតា ផុស្សមិត្តា ធម្មគុត្តាផុតចាកអបាយ ៤ ។ ប្រេតទាំងនោះមានកាយផ្សេងគ្នា ដោយពណ៌សម្បុរ ស ខ្មៅ លឿង និងពណ៌និលជាដើម និងដោយមានលក្ខណៈស្គម ធាត់ ទាប ខ្ពស់ , សូម្បីសញ្ញាក៏ផ្សេងគ្នាដោយអំណាចតិហេតុកៈ ទ្វិហេតុកៈ និងអហេតុកៈ ដូចសញ្ញា

របស់មនុស្សទាំងឡាយ ។ តែវេមានិកប្រេតទាំងនោះ មិនមានសក្តិធំ ដូចទេពទាំងឡាយ ។ មានសក្តិតូច អាហារ និងសំពត់អាវរកបានដោយលំបាក ត្រូវទុក្ខបៀតបៀនដូចមនុស្សក្រខ្សត់ ។ វិនិបាតិកៈពួកខ្លះ ក្នុងថ្ងៃខាងរនោចបានទទួលទុក្ខ ក្នុងថ្ងៃខាងខ្នើតបានទទួលសេចក្តីសុខ , ព្រោះដូច្នោះ លោកទើបពោលថា **វិនិបាតិកា** ព្រោះធ្លាក់ទៅចាកការសន្សំសេចក្តីសុខ ។

ក្នុងបទនេះ សូម្បីការដឹងធម៌របស់វិនិបាតិកៈ ដែលជាតិហេតុកៈក៏មាន ដូចការដឹងធម៌របស់យក្ខិនី ឈ្មោះថា **បិយំ-ករមាតា** ជាដើម ។

បទថា **ព្រហ្មកាយិកា** ពួកទេពអ្នកនៅក្នុងពពួកព្រហ្មបានដល់ ព្រហ្មបារិសជ្ជៈ ព្រហ្មបរោហិតៈ និងមហាព្រហ្ម ។

បទថា **បឋមាភិនិព្វត្តា** អ្នកកើតក្នុងភូមិបឋមឈាន បានដល់ពួកទេពទាំងអស់នោះ កើតហើយដោយបឋមឈាន ។ ចំណែកពួកព្រហ្មបារិសជ្ជៈ កើតដោយឈានបន្តិចបន្តួច , ព្រហ្មបុរោហិតៈកើតដោយឈានយ៉ាងកណ្តាល , កាយរបស់ពួកទេពទាំងនោះមានពន្លឺផ្សាយចេញយ៉ាងខ្លាំង , មហាព្រហ្ម កើតដោយឈាន



ដ៏ប្រណីត កាយរបស់មហាព្រហ្មទាំងនោះ មានពន្លឺផ្សាយចេញខ្លាំងជាងពួកព្រហ្មបុរោហិតៈ ។ ព្រហ្មកាយិកាទាំងឡាយនេះលោកពោលថា មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ព្រោះកាយផ្សេងគ្នា ព្រោះសញ្ញាដូចគ្នា ដោយអំណាចបឋមជ្ឈាន ។

សត្វដែលកើតក្នុងអបាយ ៤ ក៏ដូចគ្នា ។ ក្នុងនរក ពួកខ្លះមានរាងកាយ ១ គាវុត , ពួកខ្លះកន្លះយោជន៍ , ពួកខ្លះ ៣ គាវុត , ចំណែកទេវទត្ត មានរាងកាយ ១០០ យោជន៍ ។ សូម្បីក្នុងតិរច្ឆានពួកខ្លះក៏តូច ពួកខ្លះក៏ធំ ។ សូម្បីក្នុងបេត្តិវិស័យ ពួកខ្លះក៏ ៦០ហត្ថ ពួកខ្លះក៏ ៨០ ហត្ថ ពួកខ្លះ សម្បុរស្អាត ពួកខ្លះសម្បុរថោកទាប ។ ដូចកាលកញ្ជិកាសូរ ។ បណ្តាប្រេតទាំងនេះពួកទីឃបិដ្ឋិកាប្រេត ក៏មានកាយកម្ពស់ ៦០ យោជន៍ ។ សញ្ញារបស់ប្រេតទាំងអស់នោះ ប្រព្រឹត្តទៅជាមួយនឹងអហេតុកៈ មានអកុសល ជាវិបាក ។ សូម្បីសត្វក្នុងអបាយទាំងឡាយ ក៏ពោលបានថា ជាអ្នកមានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ។

បទថា **អាភស្សរា** ពួកទេពអាភស្សរា រស្មីផ្សាយចេញពីរាងកាយរបស់អាភស្សរាទេពទាំងនោះ រុងរឿងស្វាងស្វៃ រស្មីដាច់ ៗ

ធ្លាក់ចុះមក ដូចគប់ភ្លើងមានជ័ង ទើបឈ្មោះថា អាភស្សរា ។ បណ្ដាទេពទាំងនោះ រស្មីកើតឡើង ព្រោះចម្រើនទុតិយជ្ឈាន និង តតិយជ្ឈានទាំងពីរ ក្នុងបញ្ចកន័យ តិចតួច ទើបឈ្មោះថា **បរិត្តាភា** ។ រស្មីកើតឡើង ព្រោះចម្រើនឈានយ៉ាងកណ្ដាល ទើបឈ្មោះថា **អប្បមាណាភា** ។

រស្មីកើតឡើង ព្រោះចម្រើនឈានដ៏ប្រណីត ទើបឈ្មោះថា **អាភស្សរា** ។ តែក្នុងទីនេះ លោកកំណត់យកទេពទាំងអស់នោះ ដោយកំណត់យកថ្នាក់កំពូល ។ កាយរបស់ទេពទាំងនោះទាំង-អស់ មានរស្មីផ្សាយចេញដូចគ្នា , តែសញ្ញាផ្សេងគ្នា ព្រោះមិនមានវិតក្កៈ មានតែវិចារ និងព្រោះមិនមានទាំងវិតក្កៈ និងវិចារ ។

បទថា **សុភកិណ្ហា** ពួកទេពសុភកិណ្ហៈ បានដល់ ពួកទេពអ្នកពោរពេញដោយសេចក្ដីស្អាតផ្សាយទៅ , អធិប្បាយថា មានរស្មីជាដុំមួយ ៗ ដូចគ្នាដោយពណ៌រស្មីចេញចាករាងកាយ ។ រស្មីរបស់ពួកសុភកិណ្ហទេពទាំងនោះ មិនដាច់ជាដុំ ៗ ដូចរស្មីរបស់ពួកអាភស្សរាទេពទេ ។ ពួកទេព **បរិត្តសុភ អប្បមាណាសុភ សុភកិណ្ហ** កើតឡើងដោយអំណាចតតិយជ្ឈាន ក្នុងចតុក្កន័យ



ចតុត្ថជ្ឈានក្នុងបញ្ចកន័យ ដែលជាឈានថោកទាប កណ្ដាល និង ប្រណីត ។ ពួកទេពទាំងអស់ទាំងនោះ គប្បីជ្រាបថា មានកាយដូចគ្នា មានសញ្ញាដូចគ្នា ដោយសញ្ញាក្នុងចតុត្ថជ្ឈាន ។ **វេហប្ផល** រមែងរួមចូលជាមួយនឹង វិញ្ញាណដ្ឋិតិ ប្រការទី ៤ ។ **អសញ្ញសត្វ** សត្វមិនមានសញ្ញា មិនសង្គ្រោះចូលក្នុងវិញ្ញាណដ្ឋិតិនេះ ព្រោះមិនមានវិញ្ញាណ , សង្គ្រោះចូលក្នុងសត្តាវាស ភពជាទីរស់នៅរបស់សត្វ ។

**សុទ្ធាវាស** ភពជាទីរស់នៅរបស់អ្នកបរិសុទ្ធ តាំងនៅក្នុងចំណែកនៃវិវដ្ដៈ ( និព្វាន ) មិនមែនតាំងនៅរហូតគ្រប់កាលទេ ។ ភពទេពសុទ្ធាវាស រមែងមិនកើតក្នុងលោក ដែលមិនមានព្រះពុទ្ធរហូតមួយសែនកប្បខ្លះ , រហូតមួយអសង្ខេយ្យកប្បខ្លះ ។ កាលបើព្រះពុទ្ធជាម្ចាស់ឧប្បត្តិក្នុងរវាង ១៦.០០០ កប្ប ភពទេពសុទ្ធា-វាសទើបកើត ។ ពួកទេពទាំងនោះ ប្រៀបដូចជាកងទ័ពរបស់ព្រះមានព្រះភាគអ្នកប្រកាសព្រះធម្មចក្រ , ព្រោះដូច្នោះ ទើបមិនមែនជាវិញ្ញាណដ្ឋិតិ , មិនរួមចូលនឹងសត្តាវាស ។

ព្រះមហាសីវត្ថេរ ពោលដោយព្រះសូត្រនេះថា អាវុសោ

សារីបុត្ត សត្តាវាសដែលយើងមិនធ្លាប់អាស្រ័យនៅ ក្រៅពីទេពសុទ្ធាវាស ដោយកាលដ៏យូរនេះ មិនមែនមិនងាយបានសោះឡើយដូច្នេះ ១ , សូម្បីសុទ្ធាវាសក៏រួមចូលជាមួយវិញ្ញាណដ្ឋិតិ ទី ៤ និងសត្តាវាស ទី ៤ , សូត្រនោះ លោកគប្បីពិចារណាផង ព្រោះជាសូត្រដែលមិនបានហាមទុក ។

ឈ្មោះថា **នេវសញ្ញានាសញ្ញាយតន** ព្រោះវិញ្ញាណល្អិតបំផុត នឹងមានវិញ្ញាណក៏មិនមែន មិនមានវិញ្ញាណក៏មិនមែន ដូចជាសញ្ញាយ៉ាងល្អិត , ព្រោះដូច្នោះ លោកទើបមិនពោលទុកក្នុងវិញ្ញាណដ្ឋិតិ ។

បទថា **អដ្ឋ លោកធម្មា** លោកធម៌ ៨ ទាំងនេះ គឺ ៖

លាភ ១ , អត់លាភ ១ , យស ១ , អត់យស ១ , និន្ទា ១ , សរសើរ ១ , សុខ ១ , ទុក្ខ ១ បើការប្រព្រឹត្តទៅរបស់លោកមានហើយ ធម៌របស់លោក ទើបហៅថា លោកធម៌ ព្រោះមានការប្រែប្រួលទៅជាធម្មតា ។ ឈ្មោះថា សត្វនឹងផុតចាកលោកធម៌ទាំងនេះ រមែងមិនមាន ។ នឹងមាន ក៏អាស្រ័យព្រះពុទ្ធជាម្ចាស់ប៉ុណ្ណោះ ។ ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖



ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំងឡាយនេះ រមែងវិលទៅតាមលោក , និងលោក ក៏រមែងវិលទៅតាមលោកធម៌ ៨ ។ លោកធម៌ ៨ គឺអ្វីខ្លះ ។ លោកធម៌ ៨ គឺ លាភ ១ , អត់លាភ ១ , យស ១ , អត់យស ១ , និន្ទា ១ , សរសើរ ១ , សុខ ១ , ទុក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ លោកធម៌ ៨ ទាំងឡាយនេះ រមែងវិលទៅតាមលោក ។ និងលោក រមែងវិលទៅតាមលោកធម៌ ៨ ទាំងឡាយនេះ ១ ។

ក្នុងបទទាំងនោះ បទថា **អនុបរិវត្តន្តិ** រមែងវិលទៅតាម បានដល់ ជាប់ទៅតាម គឺ មិនលះបង់ ។ អធិប្បាយថា មិនចេញចាកពីលោក ។

បទថា **លាភោ** លាភ គឺ លាភរបស់បព្វជិត មានចីវរជាដើម , របស់គ្រហស្ថ មានទ្រព្យ និងស្រូវអង្ករជាដើម ។ កាលបើមិនបានលាភនោះ ឈ្មោះថា អត់លាភ ។ បើពោលថា **ន លាភោ អលាភោ** មិនមែនលាភ ឈ្មោះថា មិនមានលាភ មិនគួរចូលចិត្តដោយការមិនមានប្រយោជន៍ ។

បទថា **យសោ** យស បានដល់ បរិវារយស ។ បើមិន

បានយសនោះ ឈ្មោះថា អត់យស ។

បទថា **និន្ទា** គឺ និយាយពោលទោស ។ បទថា **បសំសា** គឺ និយាយពោលដល់គុណ ។

បទថា **សុខំ** បានដល់ សុខផ្លូវកាយ និងសុខផ្លូវចិត្តរបស់កាមាវចរ ។

បទថា **ទុក្ខំ** បានដល់ ទុក្ខផ្លូវកាយ និងទុក្ខផ្លូវចិត្តរបស់បុថុជ្ជន ។ ព្រះសោតាបន្ន ព្រះសកទាគាមី , ព្រះអនាគាមី និងព្រះអរហន្ត មានតែទុក្ខផ្លូវកាយប៉ុណ្ណោះ ។

បទថា **នវ សត្តាវាស** បានដល់ ទីនៅរបស់សត្វទាំង-ឡាយ , អធិប្បាយថា កន្លែងជាទីរស់នៅ ។ កន្លែងរស់នៅទាំងនោះ បានដល់ ខន្ធដែលមានប្រាកដបានដឹងគ្នាហើយ ។ សត្តាវាស ៩ គឺអ្វីខ្លះ ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ សត្តាវាស ៩ ទាំងឡាយនេះ , សត្តាវាស ៩ គឺអ្វីខ្លះ , ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ មានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ដូចជាពួកមនុស្ស ទេពពួកខ្លះ ពួកវិនិបាតិកៈ ( ប្រេត ) នេះ ជាសត្តាវាស ប្រការទី ១ ។



ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូចជាពួកទេពអ្នកនៅក្នុងជាំពួកព្រហ្ម ដែលកើតនៅក្នុងបឋមឈាន នេះជាសត្តាវាសប្រការទី ២ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ មានកាយដូចគ្នា មានសញ្ញាផ្សេងគ្នា ដូចជាពួកទេពអាភស្សរៈ នេះជាសត្តាវាសប្រការទី ៣ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ មានកាយដូចគ្នា មានសញ្ញាដូចគ្នា ដូចជាពួកទេពសុភកិណ្ហៈ នេះជាសត្តាវាសប្រការទី ៤ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ មិនមានសញ្ញា មិនសោយវេទនា ដូចជាពួកទេពដែលជាអសញ្ញីសត្វ នេះជាសត្តា-វាសប្រការទី ៥ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ ឈានកន្លងរូបសញ្ញាដោយប្រការទាំងពួង រំលត់បដិឃសញ្ញា មិនធ្វើទុកក្នុងចិត្តដល់សញ្ញាផ្សេងគ្នា ចូលដល់អាកាសានញ្ចាយតនៈថា **អនន្តោ អាកា-សោ** អាកាសមិនមានទីបំផុត ។ នេះជាសត្តាវាសប្រការ ទី ៦ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ ឈានកន្លងអាកាសានញ្ចាយតនៈដោយប្រការទាំងពួង ចូលដល់វិញ្ញាណញ្ចាយតនៈថា **អនន្តំ វិញ្ញាណំ** វិញ្ញាណមិនមានទីបំផុត នេះជាសត្តាវាសប្រការទី ៧ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ ឈានកន្លងវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង ចូលដល់អាកិញ្ចញ្ញាយតនៈថា **នត្ថិ កិញ្ចិ** អ្វី ៗ មិនមាន នេះជាសត្តាវាសប្រការទី ៨ ។

ម្នាលភិក្ខុទាំងឡាយ សត្វពួកមួយ ឈានកន្លងអាកិញ្ចញ្ញាយតនៈដោយប្រការទាំងពួង ចូលដល់នេវសញ្ញានាសញ្ញាយតនៈ នេះជាសត្តាវាសប្រការទី ៩ ។ ម្នាលភិក្ខុទាំងឡាយ សត្តាវាស ៩ ទាំងនេះឯង ១ ។

បទថា **ទសាយតនានិ** បានដល់ អាយតនៈ ១០ យ៉ាងនេះ គឺ ចក្ខាយតនៈ ១ , រូបាយតនៈ ១ , សោតាយតនៈ ១ , សទ្ទាយតនៈ ១ , ឃានាយតនៈ ១ , គន្ធាយតនៈ ១ , ជិវ្ហាយតនៈ ១ , រសាយតនៈ ១ , កាយាយតនៈ ១ , ផោដ្ឋព្វាយតនៈ ១ ។ ចំណែកមនាយតនៈ ,ធម្មាយតនៈ លោកមិនចាត់ចូល ព្រោះលាយ



ដោយលោកុត្តរៈ ។ ក្នុងការវិសជ្ជនា ១០ ទាំងនេះ លោកពោលដល់ **តីរណបញ្ញា** ដោយអំណាចវិបស្សនា ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា **សព្វំ ភិក្ខវេ បរិញ្ញេយ្យំ** ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងគួរកំណត់ដឹង ដូចតទៅនេះ ។ លោកពោលដល់ តីរណបរិញ្ញា ដោយការបានចំពោះនូវធម៌ទាំងនេះ គឺ ធម៌ ៣ អនញ្ញាតញ្ញស្សាមីតិន្ទ្រិយ៍ ( ឥន្ទ្រិយ៍ គឺ អធ្យាស្រ័យដែលបំណងធ្វើឲ្យជាក់ច្បាស់មគ្គ.ផល របស់អ្នកបដិបត្តិ ) ជាដើម , ធម៌ ១៥ មាន **អនុប្បាទធម៌** ជាដើម របស់ការចេញចាកទុក្ខជាដើម ដែលជាបដិបទារបស់ការរំលត់ទុក្ខ ជាការចម្រើនដើម្បីធ្វើឲ្យជាក់ច្បាស់ ជាការសម្រេចធម៌ទាំងនោះ , ធម៌ ៣១ មាន **បរិគ្គហដ្ឋោ** សភាពដែលកំណត់ទុក , ធម៌ ៣ មាន **ឧត្តរិបដិវេធដ្ឋ** សភាពដែលជាក់ច្បាស់យ៉ាងក្រៃលែងឡើងទៅជាដើម , ធម៌ ៨ ដែលជា អដ្ឋមគ្គ , ធម៌ ២ មានសភាពស្ងប់នៃបយោគៈជាដើម , ធម៌ ២ មានសភាពចេញចាកសភាវៈ ដែលជាអសង្ខតៈ , ធម៌ ៣ មាន

## អ ដ្ឋ ក ថា

## បហាតព្វនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុង **បហាតព្វនិទ្ទេស** ដូចតទៅនេះ :-

បទថា **អស្មិមានោ** មានះថាជាយើង បានដល់ **មានះ** ព្រោះ សម្គាល់ថាជាយើងក្នុងឧបាទានក្ខន្ធ ៥ មានរូបជាដើម ។ ពិតណាស់ កាលណាលះបង់មានះនោះបាន ជាការបានសម្រេចព្រះអរហត្ត គប្បីជ្រាបថា សូម្បីរូបរាគៈជាដើមនៅមាន ក៏មិនពោលដល់សញ្ញាជនៈដែលសល់ ពោលតែអស្មិមានៈប៉ុណ្ណោះ ព្រោះអស្មិមានៈនោះ គ្រោតគ្រាតប្រៀបបាននឹងទិដ្ឋិ ។

បទថា **អវិជ្ជា** គឺការមិនដឹងក្នុងឋានៈ ៤ យ៉ាង មានទុក្ខជាដើម ដោយសុត្តន្តបរិយាយ , ការមិនដឹងក្នុងឋានៈ ៨ យ៉ាង និងទីបំផុតខាងដើម ដោយអភិធម្មបរិយាយ ។

ដូចព្រះដ៏មានព្រះភាគជាម្ចាស់ត្រាស់ទុកថា ក្នុងធម៌ទាំងនោះ អវិជ្ជាដូចម្តេច ? អវិជ្ជា គឺការមិនដឹងទុក្ខ ១ , មិនដឹងទុក្ខសមុទ័យ ១ , មិនដឹងទុក្ខនិរោធ ១ , មិនដឹងទុក្ខនិរោធគាមិនីបដិបទា ១ , មិនដឹងចំណែកខាងដើម ១ , មិនដឹងចំណែកខាង



ចុង ១ , មិនដឹងចំណែកខាងដើមនិងចំណែកខាងចុង ១ , មិនដឹងបដិច្ចសមុប្បាទធម៌ ដែលជាឥទប្បច្ចយតា វត្ថុនេះជាបច្ច័យនៃវត្ថុនេះ កាលណាវត្ថុនេះមាន វត្ថុនេះរមែងមាន ។

បទថា **ភវតណ្ហា** បានដល់ ការប្រាថ្នាក្នុងភព មានកាមភពជាដើម ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ក្នុងតណ្ហា ៣ នោះ ភវតណ្ហាដូចម្តេច ? ភវតណ្ហា គឺ ការពេញចិត្តក្នុងភព ការត្រេកអរក្នុងភព ការភ្លើតភ្លើនក្នុងភព ការប្រាថ្នាក្នុងភព សេចក្តីជាប់ជំពាក់ក្នុងភព ការក្តៅក្រហាយក្នុងភព ការលិចចុះក្នុងភព ការវិលវល់ក្នុងភព ។

បទថា **តិស្សោ តណ្ហា** តណ្ហា ៣ បានដល់ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ ក្នុងអភិធម្ម លោកពន្យល់តណ្ហាទាំងនោះទុកក្នុងទីនេះថា ក្នុងតណ្ហា ៣ នោះ ភវតណ្ហាដូចម្តេច ? រាគៈសហគតដោយភវទិដ្ឋិ ។ល។ ចិត្តមានរាគៈ នេះហៅថា ភវតណ្ហា ។

វិភវតណ្ហាដូចម្តេច ? រាគៈសហគតដោយឧច្ឆេទទិដ្ឋិ ។ល។ ចិត្តមានរាគៈ នេះហៅថា វិភវតណ្ហា ។ តណ្ហាក្រៅពីនោះ ជា

កាមតណ្ហា ។

កាមតណ្ហាដូចម្តេច ? រាគៈប្រកបដោយកាមធាតុ ។ល។ ចិត្តមានរាគៈ នេះហៅថា កាមតណ្ហា ។

ភវតណ្ហាដូចម្តេច ? រាគៈប្រកបដោយរូបធាតុ និងអរូបធាតុ ។ល។

វិភវតណ្ហាដូចម្តេច ? រាគៈសហគតដោយឧច្ឆេទទិដ្ឋិ ។ល។ តែក្នុងអដ្ឋកថាលោកពោលថា រាគៈប្រព្រឹត្តទៅក្នុងកាមគុណ ៥ ឈ្មោះថា **កាមតណ្ហា** , រាគៈក្នុងរូបភព និងអរូបភព រាគៈសហគតដោយការប្រាថ្នាក្នុងឈាន និងសស្សតទិដ្ឋិ ការប្រាថ្នាដោយអំណាចភព ឈ្មោះថា **ភវតណ្ហា** , រាគៈសហគតដោយឧច្ឆេទទិដ្ឋិ ឈ្មោះថា **វិភវតណ្ហា** ។ នេះអធិប្បាយទុកដោយបរិយាយនៃទសុត្តរសូត្រ ។ សូម្បីតណ្ហា លោកពោលទុកដោយបរិយាយនៃសង្គីតិ និងដោយបរិយាយនៃអភិធម្មថា តណ្ហា ៣ យ៉ាងដទៃទៀត គឺ កាមតណ្ហា រូបតណ្ហា អរូបតណ្ហា ។ យ៉ាងដទៃ ៣ ទៀត គឺ រូបតណ្ហា អរូបតណ្ហា និរោធតណ្ហា ត្រឹមត្រូវក្នុងនិទ្ទេសនេះ ។ ក្នុងតណ្ហាទាំងនោះ តណ្ហា ៥ ប្រកបដោយ



កាមធាតុ រូបធាតុ អរូបធាតុ តណ្ហាចុងក្រោយសហគតៈដោយឧច្ឆេទទិដ្ឋិ ។

បទថា **ចត្តារោ ឱឃា** ឱឃៈ ៤ គឺ កាមោឃៈ ១ ភវោឃៈ ១ ទិដ្ឋោឃៈ ១ អវិជ្ជោឃៈ ១ , ឈ្មោះថា **ឱឃ** ព្រោះអត្ថថារមែងញាំងសត្វនោះឲ្យលិចចុះក្នុងវដ្ដៈ ។ ឱឃៈ ទាំងឡាយពួកនេះ ជាកិលេសមានកម្លាំង ។ ឱឃៈក្នុងកាម បានដល់ កាមគុណឈ្មោះថា **កាមោឃ** ។ ពាក្យថា **កាមោឃ** នេះ ជាឈ្មោះរបស់ **កាមតណ្ហា** ។ ឱឃៈក្នុងភព ២ យ៉ាង គឺ រូបភព និងអរូបភព ឈ្មោះថា **ភវោឃ** ។ ពាក្យថា **ភវោឃ** នេះ ជាឈ្មោះរបស់ **ភវតណ្ហា** ។ ឱឃៈ គឺ ទិដ្ឋិនោះឯង ឈ្មោះថា **ទិដ្ឋោឃ** ។ ពាក្យថា **ទិដ្ឋោឃ** នេះ ជាឈ្មោះរបស់ ទិដ្ឋិ មានជាអាទិ៍ថា **សស្សតោ លោកោ** លោកទៀង ។ ឱឃៈ គឺ អវិជ្ជា នោះឯង ឈ្មោះថា **អវិជ្ជោឃ** ។ ពាក្យថា **អវិជ្ជោឃ** នេះ ជាឈ្មោះនៃការមិនដឹងក្នុងទុក្ខជាដើម ។

បទថា **បញ្ច និវរណានិ** និវរណៈ ៥ គឺ កាមច្ឆន្ទៈ ១ , ព្យាបាទៈ ១ , ថីនមិទ្ធៈ ១ , ឧទ្ធច្ចកុក្កុច្ចៈ ១ , វិចិកិច្ឆា ១ ។

ឈ្មោះថា **និវរណានិ** ព្រោះរារាំង គឺ រួបរឹតចិត្តទុក ។

ឈ្មោះថា **កាមោ** ព្រោះជាហេតុប្រាថ្នា បានដល់ កាមគុណ ៥ ។ ការពេញចិត្តក្នុងកាម ឈ្មោះថា **កាមច្ឆន្ទ** ។ ម្យ៉ាងទៀត ឈ្មោះថា **កាមោ** ព្រោះរមែងប្រាថ្នា ។ ការពេញចិត្ត គឺ **កាម** មិនមែនការពេញចិត្តនឹងប្រាថ្នាធ្វើ មិនមែនសេចក្ដីពេញចិត្តក្នុងធម៌ ព្រោះហេតុនោះ ទើបឈ្មោះថា **កាមច្ឆន្ទ** ។ បទនេះ ជាឈ្មោះនៃ **កាមតណ្ហា** ។

ឈ្មោះថា **ព្យាបាទោ** ព្រោះចិត្តរមែងប្រទូសរ៉ាយ គឺ ញុំាងឲ្យវិនាសដោយការប្រទូសរ៉ាយនោះ , ចិត្តញុំាងវិន័យ-អាចារៈ រូបសម្បត្តិ ប្រយោជន៍ សុខ ឲ្យដល់នូវការវិនាស ។ បទនេះ ជាឈ្មោះរបស់ **ទោស** ។

ឈ្មោះថា **ថីនំ** ព្រោះការរួញរា ឈ្មោះថា **មិទ្ធំ** ព្រោះការងោកងក់ , អធិប្បាយថា ការមិនបង្កើតឡើងនូវភាពឧស្សាហ៍ និងការកម្ចាត់ភាពមិនអង់អាច ។ ចិត្តមិនខ្នះខ្នែង ឈ្មោះថា **ថីន** ចេតសិកដែលមិនគួរដល់ការងារ ឈ្មោះថា **មិទ្ធ** ការរួញរាចិត្ត និងការងោកងក់ ឈ្មោះថា **ថីនមិទ្ធ** ។



ការដែលចិត្តរាយមាយឈ្មោះថា **ឧទ្ធច្ចំ** បានដល់ ការមិនស្ងប់ បទនេះ ជាឈ្មោះនៃការរាយមាយ ។

ចិត្តធ្វើឫកគួរស្អប់ ឈ្មោះថា **កុក្កតំ** , ចិត្តធ្វើឫកគួរស្អប់ ឈ្មោះថា **កុក្កុច្ចំ** អធិប្បាយថា ភាពជាអ្នកមានកិរិយាគួរតិះដៀល ។ បទនេះ ជាឈ្មោះនៃភាពក្ដៅក្រហាយជាខាងក្រោយ ។

ឈ្មោះថា **វិចិកិច្ឆា** ព្រោះប្រាសចាកការគិត , អធិប្បាយថា អត់បញ្ញា ។ ម្យ៉ាងទៀត ឈ្មោះថា **វិចិកិច្ឆា** ព្រោះជាហេតុស្រាវជ្រាវរកការពិតមិនបាន ។ បទនេះ ជាឈ្មោះរបស់ការសង្ស័យ ។ **និវរណ** គឺ កាមច្ឆន្ទៈនោះឯង ឈ្មោះថា **កាមច្ឆន្ទ-និវរណ** ។ សូម្បីក្នុងបទដ៏សេស ក៏យ៉ាងនេះ ។

បទថា **ឆ ធម្មា** បាឋៈថា **ឆទ្ធម្មា** ខ្លះ ។ **ឆ តណ្ហា-កាយា** ពួកតណ្ហា ៦ គឺ រូបតណ្ហា ១ សទ្ទតណ្ហា ១ គន្ធតណ្ហា ១ រសតណ្ហា ១ ផោដ្ឋព្វតណ្ហា ១ ធម្មតណ្ហា ១ តណ្ហាក្នុងរូប ឈ្មោះថា **រូបតណ្ហា** ។ តណ្ហានោះឯង លោកពោលថា ជាពួក ដោយអត្ថថា ជាគំនរ ព្រោះមានច្រើនប្រភេទច្រើនផ្នែក មានកាមតណ្ហាជាដើម សូម្បីក្នុងបទដ៏សេស ក៏យ៉ាង

នេះ ។

បទថា **សត្តានុសយា** អនុស័យ ៧ គឺ កាមរាគានុស័យ ១ បដិឃានុស័យ ១ មានានុស័យ ១ ទិដ្ឋានុស័យ ១ វិចិកិច្ឆានុស័យ ១ ភវរាគានុស័យ ១ អវិជ្ជានុស័យ ១ ឈ្មោះថា **អនុសយ** ព្រោះដេកត្រាំជានិច្ច ដោយអត្ថថា លះបង់មិនទាន់បានសេចក្តីត្រេកអរក្នុងកាម ឈ្មោះថា **កាមរាគ** , មួយ៉ាងទៀត រាគៈ គឺ កាម ឈ្មោះ **កាមរាគ** ។ ឈ្មោះថា **បដិឃ** ព្រោះប៉ះទង្គិចក្នុងអារម្មណ៍ ។ ឈ្មោះថា **ទិដ្ឋិ** ព្រោះអត្ថថា មិនឃើញតាមសេចក្តីពិត ។ ឈ្មោះថា **មានះ** ព្រោះសម្គាល់ថាប្រសើរជាងគេជាដើម ។ ការប្រាថ្នាក្នុងភព ឈ្មោះ **ភវរាគ** ។ កាមរាគៈមានកម្លាំង ឈ្មោះថា **កាមរាគានុសយ** ។ សូម្បីក្នុងបទដ៏សេសក៏យ៉ាងនេះ ។

បទថា **អដ្ឋ មិច្ឆត្តា** សភាពខុស ៨ គឺ មិច្ឆាទិដ្ឋិ ១ មិច្ឆាសង្កប្បៈ ១ មិច្ឆាវាចា ១ មិច្ឆាកម្មន្តៈ ១ មិច្ឆាអាជីវៈ១ មិច្ឆាវាយាមៈ ១ មិច្ឆាសតិ ១ មិច្ឆាសមាធិ ១ ។ ឈ្មោះថា **មិច្ឆត្តា** សភាពដែលខុស ព្រោះមានសភាពខុស សូម្បីសង្ឃឹម



យ៉ាងនេះថា គេនឹងនាំប្រយោជន៍ និងសេចក្តីសុខមកឲ្យដល់យើង ក៏មិនដូច្នោះ និងដែលប្រព្រឹត្តវិបរិតក្នុងវត្ថុមិនល្អ ថាល្អជាដើម ។ ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះឃើញខុស ឬទិដ្ឋិជាហេតុយល់ខុស , មួយ៉ាងទៀត ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះការយល់វិបរិត ឬព្រោះការយល់មិនពិត ឬព្រោះការយល់ផ្តេសផ្តាស ឬព្រោះការយល់ដែលបណ្ឌិតស្អប់ខ្ពើម ព្រោះនាំមកនូវសេចក្តីវិនាស ។ សូម្បីក្នុងពាក្យថា **មិច្ឆាសង្កប្ប** ជាដើម ក៏មានន័យដូចគ្នា ។

បទថា **មិច្ឆាទិដ្ឋិ** យល់ខុស បានដល់ ការប្រកាន់មាំដោយសស្សតទិដ្ឋិ និងឧច្ឆេទទិដ្ឋិ ។

បទថា **មិច្ឆាសង្កប្បោ** ត្រិះរិះខុស បានដល់ វិតក្កៈ ៣ យ៉ាង មានកាមវិតក្កៈជាដើម ។

បទថា **មិច្ឆាវាចា** និយាយខុស បានដល់ ចេតនា ៤ យ៉ាង មានមុសាវាទជាដើម ។

បទថា **មិច្ឆាកម្មន្តោ** ការងារខុស បានដល់ ចេតនា ៣ យ៉ាង មានបាណាតិបាតជាដើម ។

បទថា **មិច្ឆាអាជីវោ** អាជីពខុស បានដល់ ចេតនាតាំង

ឡើងដោយការប្រកបមិច្ឆាអាជីវៈ ។

បទថា **មិច្ឆាវាយាមោ** ព្យាយាមខុស បានដល់ ការព្យាយាមប្រកបដោយអកុសលចិត្ត ។

បទថា **មិច្ឆាសតិ** រលឹកខុស បានដល់ អកុសលចិត្តដែលជាបដិបក្សដល់សតិ ។

បទថា **មិច្ឆាសមាធិ** តាំងចិត្តខុស បានដល់ អកុសលសមាធិ ។

បទថា **នវ តណ្ហាមូលកា** ធម៌មានតណ្ហាជាមូល ៩ ។ បានដល់ ព្រោះអាស្រ័យតណ្ហា ទើបកើតការស្វែងរក ១ , ព្រោះអាស្រ័យការស្វែងរក ទើបកើតលាភ ១ , ព្រោះអាស្រ័យលាភ ទើបកើតការយល់ព្រមក្នុងចិត្ត ១ , ព្រោះអាស្រ័យការយល់ព្រមក្នុងចិត្ត ទើបកើតការស្រលាញ់គាប់ចិត្ត ១ , ព្រោះអាស្រ័យការស្រលាញ់គាប់ចិត្ត ទើបកើតការកន្ទ្វល់ ១ , ព្រោះអាស្រ័យការកន្ទ្វល់ ទើបកើតការប្រកាន់មាំ ១ , ព្រោះអាស្រ័យការប្រកាន់មាំ ទើបកើតសេចក្ដីកំណាញ់ ១ , ព្រោះអាស្រ័យការកំណាញ់ ទើបកើតការហួងហែង ១ , ព្រោះអាស្រ័យការ



ហួងហែង អកុសលធម៌ដ៏លាមកមិនតិច គឺ ការកាន់ដំបងកាន់កាំបិត ជម្លោះ ការប្រឆាំង ការប្រជែង ការវិវាទ ការពោលថា អាម៉ឹង-ឯងហង ការនិយាយ ស៊កសៀត ការនិយាយកុហក រមែងកើតឡើង ១ ។ ធម៌មានតណ្ហាជាមូល ៩ ទាំងនេះ ឈ្មោះថា **តណ្ហាមូលកា** ព្រោះធម៌មានតណ្ហាជាមូល ។ ការស្វែងរកជាដើម ជាអកុសលទាំងអស់ ។

បទថា **តណ្ហំ បដិច្ច** គឺ អាស្រ័យតណ្ហា ។ បទថា **បរិយេសនា** គឺ ការស្វែងរកអារម្មណ៍ មានរូបជាដើម ។ ព្រោះកាលបើតណ្ហាមានហើយ ការស្វែងរកនោះក៏មាន ។

បទថា **លាភោ** បានដល់ ការបានអារម្មណ៍ មានរូបជាដើម ព្រោះបើការស្វែងរកមានហើយ លាភនោះក៏មាន ។ ការព្រមព្រៀងនៃចិត្តមាន ៤ យ៉ាង គឺ ញាណ ១ តណ្ហា ១ ទិដ្ឋិ ១ វិតក្កៈ ១ ។

វិនិច្ឆ័យ គឺ ការព្រមព្រៀងនៃចិត្តទាំងនោះ ឈ្មោះថា **ញាណវិនិច្ឆយោ** ការព្រមព្រៀងនៃចិត្តដោយញាណ ព្រោះគប្បីដឹងសុខវិនិច្ឆ័យ លុះដឹងសុខវិនិច្ឆ័យហើយ គប្បីខ្វល់ខ្វាយស្វែង

រកសេចក្ដីសុខព្វដ៏ខាងក្នុង ។

តណ្ហាវិចរិត ១០៨ ដែលប្រាកដយ៉ាងនេះថា បទថា **វិនិច្ឆយោ** បានដល់ វិនិច្ឆ័យ ២ យ៉ាង គឺ តណ្ហាវិនិច្ឆ័យ ១ ទិដ្ឋិវិនិច្ឆ័យ ១ ។ ឈ្មោះថា **តណ្ហាវិនិច្ឆយោ** ការព្រមព្រៀងចិត្តដោយតណ្ហា ។

ទិដ្ឋិ ៦២ ឈ្មោះថា **ទិដ្ឋិវិនិច្ឆយោ** ការព្រមព្រៀងចិត្តដោយទិដ្ឋិ ។ ក្នុងទីនេះ លោកពោលវិតក្កថា **វិនិច្ឆយ** មកហើយ ក្នុងសូត្រនេះថា **ឆន្ទោ ខោ ទេវានមិន្ទ វិតក្កនិទានោ** បពិត្រសក្កទេវរាជ ឆន្ទៈនេះឯង មានវិតក្កជាហេតុ ។ លុះបានលាភហើយ រមែងសម្រេចចិត្តដល់វត្ថុដែលពេញចិត្ត មិនពេញចិត្ត និងល្អ មិនល្អដោយវិតក្កថា វត្ថុមានប្រមាណប៉ុណ្ណោះ នឹងមានដល់យើង ដើម្បីប្រយោជន៍ដល់រូបារម្មណ៍ , មានប្រមាណប៉ុណ្ណោះនឹងមានដល់យើង ដើម្បីប្រយោជន៍ដល់សទ្ទារម្មណ៍ ជាដើម , មានប្រមាណប៉ុណ្ណោះ នឹងជារបស់យើង មានប្រមាណប៉ុណ្ណោះ នឹងជារបស់អ្នកដទៃ , មានប្រមាណប៉ុណ្ណោះ យើងនឹងប្រើប្រាស់ , មានប្រមាណប៉ុណ្ណោះ យើងនឹងរក្សាទុក ។ ដោយ



ហេតុនោះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបត្រាស់ថា **លាភំ បដិច្ច វិនិច្ឆយោ** អាស្រ័យលាភ ទើបកើតការព្រមព្រៀងចិត្ត ។

បទថា **ឆន្ទរាគោ** ការស្រលាញ់គាប់ចិត្ត បានដល់ កាលបើវិតក្កដល់វត្ថុដោយអកុសលវិតក្កយ៉ាងនេះហើយ រមែងកើតរាគៈយ៉ាងខ្សោយ និងយ៉ាងខ្លាំង ។ បទថា **ឆន្ទោ** ជាឈ្មោះរបស់រាគៈខ្សោយ , បទថា **រាគោ** ជាឈ្មោះរបស់រាគៈយ៉ាងខ្លាំង ។

បទថា **អជ្ឈោសានំ** ការកង្វល់ បានដល់ ការប្រកាន់យ៉ាងមាំថា យើង របស់យើង ។

បទថា **បរិគ្គហោ** ការប្រកាន់ បានដល់ ធ្វើការប្រកាន់ដោយតណ្ហាទិដ្ឋិ ។

បទថា **មច្ឆរិយំ** កំណាញ់ បានដល់ មិនព្រមឲ្យវត្ថុជាសាធារណៈដល់អ្នកដទៃ ដោយហេតុនោះ បុរាណាចារ្យទើបពោលខ្លឹមសាររបស់បទថា **មច្ឆរិយ** ទុកយ៉ាងនេះថា លោកពោលថា **មច្ឆរិយ** ព្រោះប្រព្រឹត្តទៅក្នុងសេចក្ដីថា របស់អស្ចារ្យនេះ ចូលមានដល់យើងប៉ុណ្ណោះ ចូរកុំមានដល់អ្នកដទៃឡើយ ។

បទថា **អារក្ខា** ការរក្សា បានដល់ ការរក្សាដោយល្អ

ដោយបិទទ្វារ ប្រមូលទុកក្នុងហិបជាដើម ។

ឈ្មោះថា **អធិករណំ** ព្រោះធ្វើឲ្យក្រៃលែង ។ បទនេះជាឈ្មោះរបស់ហេតុ ។

បទថា **អារក្ខាធិករណំ** ជាការនៃបំរុងសកលិង្គ បានដល់ហេតុនៃការការពារ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទ មានការកាន់ដំបងជាដើម ដូចតទៅនេះ ការកាន់ដំបងដើម្បីការពារអ្នកដទៃ ឈ្មោះថា **ទណ្ឌាទានំ** ។ ការកាន់សាស្ត្រាមានមុខម្ខាងជាដើម ឈ្មោះថា **សត្ថាទានំ** ។ ការជម្លោះផ្លូវកាយខ្លះ ផ្លូវវាចាខ្លះ ឈ្មោះថា **កលហោ** ។

ទំនងគ្នាមានមកពីគ្រាមុន ៗ ឈ្មោះថា **វិគ្គហោ** ។ ទំនងគ្នាគ្រាក្រោយ ៗ ឈ្មោះថា **វិវាទោ** ។ បទថា **តុវំ តុវំ** បានដល់និយាយអាម៉ឹង ដោយការមិនគោរព ។

បទថា **ទស មិច្ឆត្តា** ការខុស ១០ គឺ មិច្ឆាទិដ្ឋិ ។ល។ មិច្ឆាសមាធិ មិច្ឆាញាណ មិច្ឆាវិមុត្តិ ។

ក្នុងបទទាំងនោះ បទថា **មិច្ឆាញាណំ** ដឹងខុស បានដល់



មោហៈកើតឡើង ដោយគិតដល់ឧបាយក្នុងការធ្វើអាក្រក់ និងដោយអាការពិចារណាថា យើងធ្វើអាក្រក់ក៏ជាការធ្វើរបស់ខ្លួនយើង ។

បទថា **មិច្ឆាវិមុត្តិ** ការរួចផុតខុស បានដល់ កាលបើនៅមិនទាន់រួចផុត ក៏សម្គាល់ថារួចផុត ។

ឥឡូវនេះ ដើម្បីសម្តែងធម៌ដែលគប្បីលះដោយបហានៈមានប្រភេទច្រើនយ៉ាង ព្រះសារីបុត្រទើបផ្តើមបទ មានជាអាទិ៍ថា **ទ្វេ បហានានិ** ការប្រហារ ២ ក៏កាលដឹងច្បាស់បហានៈហើយ គួរដឹងធម៌ដែលគប្បីលះដោយបហានៈនោះ ៗ ។ ក្នុងបហានៈ ៥ លោក ពោលដល់លោកុត្តរបហានៈ ២ ព្រមជាមួយនឹង **បយោគ** មុន រៀរបហានៈ ២ ផ្លូវលោក និង **និស្សរណប្បហាន** ការលះដោយឧបាយជាគ្រឿងរលាស់ចេញ ដែលមិនមែនជា **បយោគ** ។

ឈ្មោះថា **សមុច្ឆេទ** ព្រោះលះបង់ ជាហេតុធ្វើឲ្យកិលេសវិនាសទៅដោយប្រពៃ , ឈ្មោះថា **បហាន** ព្រោះបហានៈជាហេតុលះបង់កិលេស ។

ឈ្មោះថា **សមុច្ឆេទប្បហាន** ព្រោះលះកិលេសបានជា

សមុច្ឆេទ មិនមែនលះបង់កិលេស ហើយមានសល់ទៀតទេ ។

ឈ្មោះថា **បដិប្បស្សទ្ធិ** ព្រោះស្ងប់កិលេស ឈ្មោះថា **បហាន** ព្រោះលះកិលេស , ការលះដែលមានភាពស្ងប់ ឈ្មោះថា **បដិបស្សទ្ធិប្បហាន** ។ ឈ្មោះថា **លោកុត្តរ** ព្រោះឆ្លងលោក ។ ឈ្មោះថា **ខយគាមី** ព្រោះដល់នូវការអស់ទៅ បានដល់ និព្វាន ។ ខយគាមី និងមគ្គ ឈ្មោះថា **ខយគាមិមគ្គ** អធិប្បាយថា មគ្គរបស់អ្នកចម្រើនខយគាមិមគ្គ ឈ្មោះថា **សមុច្ឆេទប្បហាន** ។ លោកុត្តរផល ក្នុងខណៈនៃផល ឈ្មោះថា **បដិប្បស្សទ្ធិបហាន** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទ មានជាអាទិ៍ថា **កាមានមេតំ និស្សរណំ** នេក្ខម្មៈឧបាយជាគ្រឿងរលាស់ចេញចាកកាមជាដើម ឈ្មោះថា **និស្សរណ** ព្រោះនេក្ខម្មៈជាហេតុរលាស់ចេញចាកកាម ចាករូប ចាកសង្ខតៈ ។ មយ៉ាងទៀត ឈ្មោះថា **និស្សរណ** ព្រោះចេញចាកកាមទាំងនោះ ។ **និស្សរណ** គឺ **អសុភឈាន** ។

ឈ្មោះថា **នេក្ខម្ម** ព្រោះចេញចាកកាម ។ ឬបានដល់អនាគាមិមគ្គ ។ ពិតហើយ អសុភឈាន ឈ្មោះថា **និស្សរណ** ព្រោះគ្របសង្កត់កាមទុកបាន ។ ចំណែក **ឧប្បាទិតអនាគាមិមគ្គ**



អនាគាមិមគ្គញុាំងឈានឲ្យកើត ធ្វើឈាននោះឲ្យជាបាទ ឈ្មោះថា **អច្ចន្តនិស្សរណំ** ជាឧបាយរលាស់ចេញដោយចំណែកមួយ ព្រោះលះបង់កាមដោយប្រការទាំងពួង ។ ឈ្មោះថា **រូបំ** ព្រោះអត្ថថា បែកធ្លាយ , អធិប្បាយថា អរូប មិនមែនរូប ជាបដិបក្សដល់រូប ដូចអមិត្តជាបដិបក្សដល់មិត្ត , និងដូចជា អលោភៈជាដើម ជាបដិបក្សដល់លោភៈជាដើម ។ មយ៉ាងទៀត ឈ្មោះថា **អរូបំ** ព្រោះអត្ថថា ក្នុងឈាននោះ មិនមានរូប ដោយអំណាចនៃផល , អរូបនោះឯង ឈ្មោះថា **អារុប្បំ** អរូបជ្ឈាន ។ **អារុប្ប** គឺ **អរូបជ្ឈាន** ។ អរូបជ្ឈានទាំងនោះ ជាឧបាយគ្រឿងរលាស់ចេញនូវរូប ។ **អរហត្តមគ្គ** ឈ្មោះថា ឧបាយជាគ្រឿងរលាស់ចេញនូវរូបដោយប្រការទាំងពួង ព្រោះហាមការកើតថ្មី ដោយអរូបជ្ឈាន ។ បទថា **ភូតំ** គឺ កើតហើយ ។ បទថា **សង្ខតំ** គឺ អាស្រ័យបច្ច័យតាក់តែង ។

បទថា **បដិច្ចសមុប្បន្នំ** ធម៌អាស្រ័យគ្នាកើតឡើង បានដល់បច្ច័យនោះឯង ។ កើតឡើងដោយល្អ និងរួមគ្នា ។ ជាការដែលលោកសម្តែងដោយភាពមិនទៀង សម្តែងដោយការកើត ជាគ្រា

ដំបូង កាលបើមានការមិនទៀង លើកទី ២ លោកក៏សម្ដែងដោយការប្រព្រឹត្តទៅក្នុងខាងមុខ ដោយការសម្ដែងដល់អានុភាពរបស់បច្ច័យ កាលមានការប្រព្រឹត្តទៅក្នុងខាងមុខ លើកទី ៣ , លោកក៏សម្ដែងដល់ភាពជាធម្មតាយ៉ាងនេះ ដោយការសម្ដែងដល់ភាពជាអ្នកខ្វល់ខ្វាយក្នុងបច្ច័យ ។

បទថា **និរោធោ** គឺ និព្វាន ។ លោកពោលថា **និរោធោ** ព្រោះអត្ថថា អាស្រ័យនិព្វានរំលត់ទុក្ខ ។ **និរោធោ** នោះឈ្មោះថា ជាឧបាយរលាស់ចេញចាកសង្ខតៈនោះ ព្រោះរលាស់ចេញពីសង្ខតៈទាំងអស់ ។ ឯក្នុងអដ្ឋកថា លោកពោលទុកថា ៖-

ក្នុងបទនេះថា **និរោធោ តស្ស និស្សរណំ**

**និរោធោ** ជាឧបាយរលាស់ចេញចាកសង្ខតៈនោះ លោកប្រាថ្នាដល់អរហត្តផលថា **និរោធ** ។ ពិតហើយកាលបើឃើញនិព្វានដោយអរហត្តផល សង្ខារទាំងពួង ក៏នឹងមិនមានតទៅទៀត ព្រោះហេតុនោះ លោកទើបពោលថា **និរោធោ** ព្រោះជាបច្ច័យនៃនិរោធ បានដល់ ព្រះអរហត្ត ។



គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា **នេក្ខម្មំ បដិលទ្ធស្ស** កាលបុគ្គលអ្នកបាននេក្ខម្មៈហើយ មានដូចតទៅនេះ ៖-

កាលបុគ្គលអ្នកបាននេក្ខម្មៈ ជាការលះបង់ និងបោះបង់កាមបានហើយដោយ **វិក្ខម្ភនប្បហាន** ព្រោះឧបាយរលាស់ចេញនៃអសុភឈាន , ដោយ **សមុច្ឆេទប្បហាន** ព្រោះឧបាយរលាស់ចេញនៃអនាគាមិមគ្គ ។ គប្បីប្រកបរូបទាំងឡាយយ៉ាងនេះ ក្នុងឧបាយរលាស់ចេញនៃអរូបជ្ឈាន និងព្រោះឧបាយរលាស់ចេញនៃអរហត្តមគ្គ ។ ការលះបង់រូបដោយដាច់ខាត រមែងមានដោយការលះឆន្ទរាគៈក្នុងរូបទាំងឡាយ , ក្នុងបទថា **រូបា** នេះ ជាលិង្គ-វិបល្លាស ។ កាលបុគ្គលអ្នកបាននិរោធ ជាការលះបង់សង្ខារបានហើយដោយ **និស្សរណប្បហាន** ព្រោះព្រះនិព្វានជាគ្រឿងរលាស់ចេញ , ដោយ **បដិប្បស្សទ្ធិប្បហាន** ព្រោះអរហត្តផលជាគ្រឿងរលាស់ចេញ ។ គប្បីជ្រាបថា ការបានចំពោះ ដោយអំណាចធ្វើឲ្យជាអារម្មណ៍ ព្រោះព្រះនិព្វានជាគ្រឿងរលាស់ចេញ ។

**គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទមានជាអាទិ៍ថា**

**ទុក្ខសច្ច ដូចតទៅនេះ**

បទថា **បរិញ្ញាបដិវេធំ** ការចាក់ធ្លុះ ដោយការកំណត់ដឹងជាដើម ជាភាវៈនបុំសកៈ ។ ការចាក់ធ្លុះ ដោយការកំណត់ដឹង ឈ្មោះថា **បរិញ្ញាបដិវេធំ** ។ ទុក្ខសច្ចនោះ ជាការចាក់ធ្លុះដោយការកំណត់ដឹង ។ សូម្បីក្នុងបទដ៏សេសក៏មានន័យនេះ ។

បទថា **បជហាតិ** រមែងលះបង់ គប្បីកាន់យកសេចក្តីថា បុគ្គលអ្នកចាក់ធ្លុះបានយ៉ាងនោះ ៗ រមែងលះកិលេសដែលគួរលះបាន ។ អធិប្បាយថា រមែងលះកិលេសទាំងនោះ ដោយលះធនុរាគៈ សូម្បីលោកិយៈ និងលោកុត្តរៈ ។ បាឋៈថា **បជហតិ** ខ្លះ ។ មគ្គញ្ញាណ រមែងត្រាស់ដឹងអរិយសច្ច ៤ ក្នុងខណៈជាមួយគ្នាមិនមុនមិនក្រោយ , រមែងត្រាស់ដឹងទុក្ខដោយបរិញ្ញាភិសម័យ ការត្រាស់ដឹងដោយការកំណត់ដឹង , រមែងត្រាស់ដឹងសមុទយៈដោយបហានាភិសម័យ ការត្រាស់ដឹងដោយការលះបង់ , រមែងត្រាស់ដឹងមគ្គ ដោយភាវនាភិសម័យ ត្រាស់ដឹងដោយការធ្វើឲ្យកើតឡើង , រមែងត្រាស់ដឹងនិរោធ ដោយសច្ឆិកិរិយាភិសម័យ ការត្រាស់ដឹងដោយការធ្វើឲ្យជាក់ច្បាស់ ។ ដូចទូករមែងធ្វើកិច្ច ៤ យ៉ាង ក្នុងខណៈជាមួយគ្នា មិនមុនមិនក្រោយ , រមែងចេញ



ពីច្រាំងត្រើយអាយ , កាត់ខ្សែទឹក , នាំទំនិញទៅ , រមែងដល់ច្រាំងម្ខាងដូច្នោះ ។ លោកអធិប្បាយទុកយ៉ាងណា ? គប្បីជ្រាបថា លោកពោលដល់ **បហាន** សូម្បីក្នុងខណៈជាមួយគ្នា ក៏ដូចបែកគ្នា ព្រោះលោកពោលថា ព្រះយោគាវចរធ្វើនិរោធឲ្យជាអារម្មណ៍ រមែងសម្រេច រមែងឃើញ រមែងចាក់ធ្លុះអរិយសច្ច ៤ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបហានៈ ៥ ដូចតទៅនេះ ការគ្របសង្កត់ ការធ្វើឲ្យឆ្ងាយពីបច្ចនិកធម៌ មាននីវរណធម៌ជាដើម ដោយលោកិយសមាធិនោះ ៗ ដូចយកឆ្នាំងជ្រមុជចុះទៅក្នុងទឹកមានចក ធ្វើឲ្យចកឃ្លាតទៅឆ្ងាយដូច្នោះ នេះឈ្មោះថា **វិក្ខម្ភនប្បហាន** ។

បទថា **វិក្ខម្ភនប្បហានញ្ច នីវរណានំ បឋមជ្ឈានំ ភាវយតោ** ការលះបង់នីវរណៈដោយការគ្របសង្កត់ទុក រមែងមានដល់អ្នកចម្រើនបឋមជ្ឈាន គប្បីជ្រាបថា លោកពោលដល់ ការលះនីវរណៈ ព្រោះនីវរណៈប្រាកដ ។ ការពិត នីវរណៈមិនគ្របសង្កត់ចិត្តលឿនរហ័ស ទាំងក្នុងចំណែកខាងដើម ទាំងក្នុងចំណែកខាងក្រោយនៃឈាន ។ កាលចិត្តត្រូវនីវរណៈគ្របសង្កត់ ឈាន

រមែងវិនាស , តែវិតក្កៈជាដើម នៅប្រព្រឹត្តទៅបាន មិនជាបដិបក្ស ទាំងមុននិងក្រោយ តាំងពីទុតិយជ្ឈានជាដើម ។ ព្រោះដូច្នោះ ការគ្រប់សង្កត់នីវរណៈទើបប្រាកដ ។

ការលះធម៌ដែលគួរលះនោះ ៗ ដែលជាបដិបក្ខគ្នា ដោយអង្គឈាន ដែលជាចំណែករបស់វិបស្សនានោះ ៗ ដូចដុតប្រទីបទុកក្នុងពេលកណ្ដាលយប់ កម្ចាត់ភាពងងឹតចេញបាន នេះឈ្មោះថា **តទង្គប្បហាន** ។

បទថា **តទង្គប្បហានញ្ច ទិដ្ឋិគតានំ និព្វេធភាគិយំ សមាធឹ ភាវយតោ** ការលះទិដ្ឋិដោយអង្គនោះ ៗ រមែងមានដល់អ្នកចម្រើនសមាធិ ដែលប្រព្រឹត្តទៅក្នុងចំណែកនៃការគ្រប់សង្កត់កិលេស គប្បីជ្រាបថា លោកពោលដល់ការលះបង់ទិដ្ឋិ ព្រោះទិដ្ឋិជារបស់គ្រោតគ្រាត , និច្ចសញ្ញាជាដើម ជារបស់ល្អិត ។

ក្នុងបទទាំងនោះ បទថា **ទិដ្ឋិគតានំ** គឺ ទិដ្ឋិនោះឯងឈ្មោះថា **ទិដ្ឋិគត** ដូចបទមានជាអាទិ៍ថា **គូថគតំ មុត្តគតំ** អាចម៍នោម ។ ទិដ្ឋិគតៈនេះ ត្រាច់ទៅជាមួយទិដ្ឋិ ព្រោះជារបស់ដែលគួរទៅខ្វះ ឈ្មោះថា **ទិដ្ឋិគត** ។ ទៅក្នុងទិដ្ឋិ ព្រោះធ្លាក់ចុះក្នុងទិដ្ឋិ ៦២ ខ្វះ ឈ្មោះថា **ទិដ្ឋិគត** ។ ទិដ្ឋិគតៈទាំងនោះ លោកពោលជាពហុវចនៈ ។



បទថា **និព្វេធភាគិយំ សមាធឹ** សមាធិដែលប្រព្រឹត្តទៅក្នុងចំណែកនៃការលះបង់របស់កិលេស បានដល់ សមាធិសម្បយុត្តដោយវិបស្សនា ។ ការលះបង់ ដោយអាការដែលប្រព្រឹត្តទៅមិនបានតទៅនៃធម៌ដែលជាសំយោជនៈ ដោយអរិយមគ្គញាណ ដូចដើមឈើដែលត្រូវរន្ទះបាញ់ នេះឈ្មោះថា **សមុច្ឆេទប្បហាន** ។

បទថា **និរោធោ និព្វានំ** និរោធ គឺ និព្វាន បានដល់ និព្វាន គឺ និរោធ ។

ដើម្បីសម្ដែងធម៌ដែលគួរលះដោយ **បហាន** យ៉ាងនេះហើយ និងសម្ដែងធម៌ដែលគួរលះទៀត ដោយសរុប ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់មានពាក្យជាអាទិ៍ថា **សព្វំ ភិក្ខវេ បហាតព្វំ** ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងពួងគួរលះបង់ ។

ក្នុងធម៌ទាំងនោះ គួរលះធម៌មានចក្ខុជាដើម ដោយការលះឆន្ទរាគៈ ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទមានជាអាទិ៍ថា **រូបំ បស្សន្តោ**

**បជហាតិ** កាលណាឃើញរូប រមែងលះ បានដល់ កាលណាពិចារណាឃើញរូប ដោយសភាពជារបស់មិនទៀងជាដើម រមែងលះបង់កិលេស ដែលគួរលះបាន ។ កាលពិចារណាឃើញ សង្កេត សំឡឹង ប្រាថ្នា **អនញ្ញតញ្ញស្សាមីតិន្ទ្រិយ** ក្នុងពីរបេយ្យាលថា **ចក្ខុំ** ។បេ។ **ជរា មរណំ** ។បេ។ **អមតោគធំ និព្វានំ** , អនញ្ញតញ្ញស្សាមីតិន្ទ្រិយក្នុងលោកុត្តរធម៌ទាំងនោះ មានជាអាទិ៍ថា **បស្សន្តោ បជហាតិ** កាលណាពិចារណាឃើញ រមែងលះបង់បាន រមែងលះបង់កិលេសដែលគួរលះបង់ ក្នុងខណៈនៃវិបស្សនា ព្រោះហេតុនោះ គួរប្រកបដោយអនុរូបដល់ធម៌នោះ ។

ចប់អដ្ឋកថា បហាតព្វនិទ្ទេស

ចប់អដ្ឋកថា តតិយភាណវារៈ

p [ q



## អដ្ឋកថា ភាវេតព្វនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងភាវេតព្វនិទ្ទេស ដូចតទៅនេះ ៖-

បទថា **កាយគតាសតិ** បានដល់ សតិសម្បយុត្តដោយការមនសិការដល់អានាបានស្សតិ ឥរិយាបថ ៤ , ឥរិយាបថតូច អាការ ៣២ , ធាតុ ៤ , ព្រៃខ្មោច ៩ និងការកំណត់វត្ថុជាបដិកូល លោកពោលទុកហើយក្នុងសូត្រ ដោយកាយគតាសតិ និងសម្បយុត្តដោយរូបជ្ឈានតាមសមគួរ ។ សតិនោះ លោកពោលថា **កាយគតា** ព្រោះទៅ គឺ ប្រព្រឹត្តទៅក្នុងកាយទាំង-នោះ ។

បទថា **សាតសហគតា** សតិសហគតៈដោយភាពសប្បាយ បានដល់ ភាវៈមានការកើតឡើងម្តងមួយគ្រាជាដើម ជាមួយនឹងការសប្បាយ ពោលគឺ ការសោយសុខដ៏ត្រជាក់ ។

**សហគត** ស័ព្ទ ប្រាកដក្នុងជិនវចនៈចុះក្នុងអត្ថ ៥ ប្រការ គឺ **តព្ភាវ** ការស្រឡាញ់ដោយការពេញចិត្ត ១ , ក្នុង **វោកិណ្ណ** ការផ្សំ ១ , ក្នុង **អារម្មណ** អារម្មណ៍ ១ , ក្នុង **និស្សយ** និស្ស័យ ១ , ក្នុង **សំសដ្ឋ** ការទាក់ទង ១ ។

ប្រាកដក្នុងអត្ថថា **តព្ភាវ** ដូចក្នុងពាក្យនេះថា **យាយំ តណ្ហា បោនោព្ភវិកា នន្ទិរាគសហគតា** តណ្ហាធ្វើឲ្យកើតភពថ្មី សហគតដោយនន្ទិរាគៈ , អធិប្បាយថា ជាការស្រឡាញ់ ដោយសេចក្តីពេញចិត្ត ។ ប្រាកដក្នុងអត្ថថា **វោកិណ្ណ** ដូចក្នុងបទនេះថា **យា ភិក្ខវេ វិមំសា កោសជ្ជសហគតា កោសជ្ជ-សម្បយុត្តា** វិមំសាសហគតដោយកោសជ្ជៈ សម្បយុត្តដោយកោសជ្ជៈ , អធិប្បាយថា វិមំសាលាយដោយកោសជ្ជៈ កើតឡើងក្នុងចន្លោះ ៗ ។

ប្រាកដក្នុងបទថា **អារម្មណ** ដូចក្នុង បទនេះថា **លាភី ហោតិ រូបសហគតានំ វា សមាបត្តីនំ អរូបសហគតានំ វា សមាបត្តីនំ** អ្នកបានសមាបត្តិសហគតដោយរូប ឬសហគតដោយអរូប , អធិប្បាយថា សមាបត្តិដែលមានរូបជាអារម្មណ៍ និងមានអរូបជាអារម្មណ៍ ។

ប្រាកដក្នុងអត្ថថា **និស្សយ** ដូចក្នុងបទនេះថា **អដ្ឋិក-សញ្ញាសហគតំ សតិសម្ពោជ្ឈង្គំ ភាវេតិ** ភិក្ខុចម្រើនសតិ-សម្ពោជ្ឈង្គៈ សហគតដោយអដ្ឋិកសញ្ញា , អធិប្បាយថា ចម្រើនអដ្ឋិកសញ្ញា ដែលមានអដ្ឋិកសញ្ញាដេកសម្ងំនៅក្នុងសន្តាន ជាការ



បានចំពោះហើយ ។ ប្រាកដក្នុងអត្ថថា **សំសដ្ឋ** ដូចក្នុងបទនេះថា **ឥទំ សុខំ ឥមាយ បីតិយា សហគតំ ហោតិ សហជាតំ សម្បយុត្តំ** សុខនេះសហគតៈ គឺ កើតរួម គឺ សម្បយុត្តដោយបីតិនេះ អធិប្បាយទាក់ទងគ្នា ។ សូម្បីក្នុងបទនេះ លោកក៏បំណងយកការទាក់ទងគ្នា ។ ព្រោះសតិ ទាក់ទងដោយការរីករាយ លោកពោលថា **សាតសហគតា** សហគតៈដោយការរីករាយ ។ ពិតហើយ សតិទាក់ទងដោយការរីករាយនោះ វៀរចតុត្ថជ្ឈាន ក្នុងឈានដ៏សេស រមែងជា **សាតសហគតា** សហគតៈដោយភាពរីករាយ , សូម្បីកាលណាសតិសហគតៈដោយឧបេក្ខា លោកក៏ពោលថា **សាតសហគតា** , ម្យ៉ាងទៀត ព្រោះចតុត្ថជ្ឈានជាមូលនៃបុរិមជ្ឈាន ជាការដែលលោកពោលដល់សតិសហគតៈដោយឧបេក្ខាខ្លះ ព្រោះសហគតៈដោយភាពរីករាយ កាលបើសេចក្តីសុខមាននៅដោយឧបេក្ខា សតិទើបជា **សាតសហគតា** ព្រោះព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់ទុកហើយ ដោយហេតុនោះ ទើបលោកពោលដល់សតិសម្បយុត្តដោយចតុត្ថជ្ឈានផង ។

បទថា **សមថោ ច វិបស្សនា ច** សមថៈ និង វិបស្សនា ។ ឈ្មោះថា **សមថ** ព្រោះញុំាងធម៌ដែលជាសត្រូវ មានកាមច្ឆន្ទៈជាដើមឲ្យស្ងប់ គឺ ឲ្យអស់ទៅ សមថៈនោះជាឈ្មោះរបស់សមាធិ ។ ឈ្មោះថា **វិបស្សនា** ព្រោះឃើញធម៌ ដោយអាការច្រើនយ៉ាង ដោយជារបស់មិនទៀងជាដើម វិបស្សនានោះ ជាឈ្មោះរបស់បញ្ញា ។ ក្នុងពីរបទនេះ ក្នុងទសុត្តរបរិយាយសូត្រ លោកពោលថា ជាបុព្វភាគ និងក្នុងសង្គីតិបរិយាយសូត្រ លោកពោលថា លាយឡំគ្នាទាំងលោកិយៈ និងលោកុត្តរៈ ។

បទថា **តយោ សមាធិ** សមាធិ ៣ បានដល់ សមាធិមានវិតក្កៈមិនមានវិចារៈ ១ , សមាធិមិនមានវិតក្កៈមានត្រឹមតែវិចារៈ ១ , សមាធិមិនមានទាំងវិតក្កៈមិនមានទាំងវិចារៈ ១ ។

សមាធិព្រមដោយវិតក្កៈ ប្រព្រឹត្តទៅដោយអំណាចសម្បយុត្តធម៌ ឈ្មោះថា **សវិតក្កោ** , សមាធិព្រមដោយវិចារៈ ឈ្មោះថា **សវិចារោ** ។ សមាធិនោះជា **ខណិកសមាធិ** សមាធិជាខណៈ , ជា **វិបស្សនាសមាធិ** សមាធិដឹងច្បាស់ , ជា **ឧបចារសមាធិ** សមាធិជាកណ្តាល ៗ , **បឋមជ្ឈានសមាធិ** សមាធិក្នុងបឋមជ្ឈាន ។ ឈ្មោះថា **អវិតក្កោ** ព្រោះសមាធិមិនមានវិតក្កៈ , ឈ្មោះថា **វិចារមត្តោ** ព្រោះក្នុងវិតក្កវិចារៈ សមាធិមានត្រឹមតែវិចារៈមិនមានប្រមាណក្រៃលែង , អធិប្បាយថា សមាធិមិនប្រកបរួមគ្នាជាមួយនឹងវិតក្កៈ ប្រសើរជាងវិចារៈ ។ ក្នុងបញ្ចកន័យ សមាធិនោះ ជាសមាធិក្នុងទុតិយជ្ឈាន , សមាធិវៀរទាំងពីរយ៉ាងនោះ មិនមានវិតក្កៈ មិនមានវិចារៈ ។ សមាធិនោះក្នុងចតុក្កន័យ ជារូបាវចរសមាធិ មានទុតិយជ្ឈានជាដើម ។ ក្នុងបញ្ចកន័យ ជារូបាវចរសមាធិ មានតតិយជ្ឈានជាដើម ។ សមាធិសូម្បីទាំង ៣ នោះ ក៏ជាលោកិយៈនោះឯង ។ ក្នុងសង្គីតិបរិយាយសូត្រ លោកពោលដល់សមាធិ ៣ យ៉ាង ដទៃទៀត គឺ **សុញ្ញតសមាធិ** សមាធិសូន្យចាករាគៈ ទោសៈ មោហៈ , **អនិមិត្តសមាធិ** សមាធិមិនមានរាគៈ ទោសៈ មោហៈ ជានិមិត្ត , **អប្បណិហិតសមាធិ** សមាធិរករាគៈ ទោសៈ មោហៈ ជាទីតាំងមិនបាន ដោយហេតុនោះ ក្នុងទីនេះលោកមិនបំណងយកសមាធិទាំងនោះ ។

បទថា **ចត្តារោ សតិប្បដ្ឋានា** សតិប្បដ្ឋាន ៤ បានដល់ កាយានុបស្សនាសតិប្បដ្ឋាន ១ , វេទនានុបស្សនាសតិប្បដ្ឋាន ១ , ចិត្តានុបស្សនាសតិប្បដ្ឋាន ១ , ធម្មានុបស្សនាសតិប្បដ្ឋាន ១ ។

ព្រះយោគីអ្នកកំណត់កាយ ដោយវិធី ១៤ យ៉ាង ក្នុងចំណែកខាងដើម គប្បីជ្រាបថាជា **កាយានុបស្សនាសតិប្បដ្ឋាន** ។

ព្រះយោគីអ្នកកំណត់វេទនា ដោយវិធី ៩ យ៉ាង គប្បីជ្រាបថាជា **វេទនានុបស្សនាសតិប្បដ្ឋាន** ។

ព្រះយោគីអ្នកកំណត់ចិត្ត ដោយវិធី ១៦ យ៉ាង គប្បីជ្រាបថាជា **ចិត្តានុបស្សនាសតិប្បដ្ឋាន** ។

ព្រះយោគីអ្នកកំណត់ដឹងធម៌ ដោយវិធី ៥ យ៉ាង គប្បីជ្រាបថាជា **ធម្មានុបស្សនាសតិប្បដ្ឋាន** ។

ក្នុងទីនេះលោកគ្មានបំណងយកលោកុត្តរធម៌ទេ ។

បទថា **បញ្ចង្គិកោ សមាធិ** សមាធិមានអង្គ ៥ បានដល់ សមាធិក្នុងចតុត្ថជ្ឈាន ។ អង្គ ៥ គឺ **បីតិផរណតា** បីតិជ្រួតជ្រាប ១ , **សុខផរណតា** សេចក្តីសុខជ្រួតជ្រាប ១ , **ចេតោ-ផរណតា** ចិត្តជ្រួតជ្រាប ១ , **អាលោកផរណតា** ពន្លឺភ្លឺស្វាង



ផ្សាយជ្រួតជ្រាប ១ , **បច្ចវេក្ខណនិមិត្ត** ការពិចារណានិមិត្ត ១ ។

បញ្ញាក្នុងឈាន ២ ឈ្មោះថា **បីតិផរណតា** ព្រោះបីតិកើតឡើង ។

បញ្ញាក្នុងឈាន ៣ ឈ្មោះថា **សុខផរណតា** ព្រោះផ្សាយសេចក្តីសុខឲ្យកើតឡើង ។

ចេតោបរិយប្បញ្ញា បញ្ញាកំណត់ដឹងចិត្ត ឈ្មោះថា **ចេ-តោផរណតា** ព្រោះផ្សាយចិត្តដល់អ្នកដទៃឲ្យកើតឡើង ។

**ទិព្វចក្ខុបញ្ញា** បញ្ញាកើតពីភ្នែកទិព្វ ឈ្មោះថា **អា-លោកផរណតា** ព្រោះផ្សាយពន្លឺភ្លឺស្វាងឲ្យកើតឡើង ។

បច្ចវេក្ខណញ្ញាណ ឈ្មោះថា **បច្ចវេក្ខណនិមិត្ត** ។ សូម្បីប្រការនេះ លោកក៏ពោលទុកថា បញ្ញាក្នុងឈាន ២ ឈ្មោះថា **បីតិផរណតា** , បញ្ញាក្នុងឈាន ៣ ឈ្មោះថា **សុខផរណតា** , បរចិត្តប្បញ្ញា ឈ្មោះថា **ចេតោផរណតា** , ទិព្វចក្ខុប្បញ្ញា ឈ្មោះ **អាលោកផរណតា** , បច្ចវេក្ខណញ្ញាណរបស់អ្នកចេញពីសមាធិនោះ ឈ្មោះថា **បច្ចវេក្ខណនិមិត្ត** ។

បច្ចវេក្ខណញ្ញាណនោះ លោកពោលថា ជានិមិត្ត ព្រោះ

កាន់យកអាការដែលប្រព្រឹត្តទៅ របស់អ្នកដែលចេញពីសមាធិហើយ ។

ម្យ៉ាងទៀត ក្នុងសមាធិមានអង្គ ៥ នោះ **បីតិផរណតា សុខផរណតា** ដូចជើងទាំងពីរ , **ចេតោផរណតា អាលោកផរណតា** ដូចដៃទាំងពីរ , ចតុត្ថជ្ឈាន មានអភិញ្ញាជាបាទ ដូចមជ្ឈិមកាយ កាយជាកណ្តាល **បច្ចវេក្ខណនិមិត្ត** ដូចក្បាល ។

ព្រះធម្មសេនាបតីសារីបុត្តត្ថេរ សម្តែងសមាធិមានអង្គ ៥ ប្រៀបដូចបុរសមានកម្លាំង ដោយអវយវៈតូចធំ ។

បទថា **ឆ អនុស្សតិដ្ឋានានិ** អនុស្សតិ ៦ ។ សតិនោះឯង ព្រោះកើតឡើងរឿយ ៗ ទើបឈ្មោះថា **អនុស្សតិ** , សតិសមគួរដល់កុលបុត្តអ្នកបួសដោយសទ្ធា ព្រោះប្រព្រឹត្តទៅក្នុងឋានៈដែលគួរប្រព្រឹត្តទៅ ឈ្មោះថា អនុស្សតិក៏មាន , អនុស្សតិនោះឯង ឈ្មោះថា **អនុស្សតិដ្ឋាន** ព្រោះជាឋាននៃបីតិជាដើម ។

អនុស្សតិ ៦ ដូចម្តេច ? អនុស្សតិ ៦ គឺ ពុទ្ធានុស្សតិ ១ ធម្មានុស្សតិ ១ សង្ឃានុស្សតិ ១ សីលានុស្សតិ ១ ចាគានុស្សតិ



១ ទេវតានុស្សតិ ១ ។

បទថា **ពោជ្ឈង្គា** គឺ ដើម្បីការត្រាស់ដឹង ឬអង្គនៃការត្រាស់ដឹង ។ លោកអធិប្បាយទុកថា ព្រះអរិយសាវករមែងត្រាស់ដឹងដោយធម្មសាមគ្គី បានដល់ សតិ ធម្មវិចយៈ វីរិយៈ បីតិ បស្សទ្ធិ សមាធិ និងឧបេក្ខា ដែលជាបដិបក្ខដល់អន្តរាយច្រើនយ៉ាង មានការតក់ស្លុត ចិត្តរាយមាយ ជាប់ស្អិត សន្សំ កាមសុខល្លិកានុយោគ អត្តកិលមថានុយោគ ឧច្ឆេទទិដ្ឋិ សស្សតទិដ្ឋិ ការប្រកាន់មាំជាដើម ដែលកើតឡើងក្នុងខណៈនៃលោកុត្តរមគ្គ ដោយហេតុនោះ លោកទើបពោលថា **ពោធិ** , បទថា **ពុជ្ឈតិ** រមែងភ្ញាក់ បានដល់ ភ្ញាក់ពីការដេកលក់ដែលជាសន្តានកិលេស ឬចាក់ធ្លុះអរិយសច្ច ៤ ឬធ្វើនិព្វានឲ្យជាក់ច្បាស់ , អង្គនៃការត្រាស់ដឹង ពោលគឺ ធម្មសាមគ្គីនោះ ឈ្មោះថា **ពោជ្ឈង្គា** ខ្លះ ដូចអង្គឈាន និងអង្គមគ្គជាដើម ។ អរិយសាវកត្រាស់ដឹងដោយធម្មសាមគ្គី មានប្រការដូចពោលហើយ លោកហៅថា **ពោធិ** , អង្គនៃ **ពោធិ** នោះ ឈ្មោះថា **ពោជ្ឈង្គា** ។ ដូចអង្គនៃសេនា និងអង្គនៃរថជាដើម ។ ដោយ

ហេតុនោះ ព្រះអដ្ឋកថាចារ្យទើបពោលថា អង្គនៃបុគ្គលអ្នកត្រាស់ដឹង ឈ្មោះថា **ពោជ្ឈង្គា** ។ ម្យ៉ាងទៀត គប្បីជ្រាបអត្ថនៃពោជ្ឈង្គៈ ដោយន័យមានជាអាទិ៍ថា បទថា **ពោជ្ឈង្គា** ឈ្មោះថា ពោជ្ឈង្គាដោយអត្ថយ៉ាងណា ? ឈ្មោះថា **ពោជ្ឈង្គា** ព្រោះអត្ថថា រមែងប្រព្រឹត្តទៅដើម្បីការត្រាស់ដឹង ។

បទថា **អរិយោ អដ្ឋង្គិកោ មគ្គោ** អរិយមគ្គមានអង្គ ៨ ឈ្មោះថា **អរិយ** ព្រោះឆ្ងាយពីកិលេសដែលត្រូវសម្លាប់ដោយមគ្គនោះ ៗ ព្រោះធ្វើភាពជាអរិយៈ និងព្រោះធ្វើឲ្យបានអរិយផល ។ មគ្គមានអង្គ ៨ ឈ្មោះថា **អដ្ឋង្គិក** ។ មគ្គមានអង្គ ៨ នោះដូចសេនាមានអង្គ ៤ មានត្រឹមតែអង្គប៉ុណ្ណោះ ដូចតន្ត្រីមានអង្គ ៥ ផុតពីអង្គហើយ រមែងមិនមាន ។ អង្គមគ្គ គឺ ពោជ្ឈង្គៈជាលោកុត្តរៈ , សូម្បីចំណែកខាងដើម ក៏រមែងបានដោយបរិយាយនៃទសុត្តរសូត្រ ។

បទថា **នវ បារិសុទ្ធិបធានិយង្គានិ** អង្គនៃសេចក្តីបរិសុទ្ធិ ៩ យ៉ាង បានដល់ **សីលវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃសីល ជាអង្គជាប្រធាននៃភាពបរិសុទ្ធិ ១ , **ចិត្តវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃចិត្ត



ជាអង្គ ជាប្រធាននៃភាពបរិសុទ្ធិ ១ , **ទិដ្ឋិវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃទិដ្ឋិ ជាអង្គ ជាប្រធាននៃភាពបរិសុទ្ធិ ១ , **កង្ខាវិតរណវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃញាណ ជាគ្រឿងឆ្លងផុតការសង្ស័យ ជាអង្គ ជាប្រធាននៃភាពបរិសុទ្ធិ ១ , **មគ្គាមគ្គញាណទស្សនវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃញាណ ជាគ្រឿងឃើញថាជាផ្លូវ ឬមិនមែនផ្លូវ ជាអង្គ ជាប្រធាននៃភាពបរិសុទ្ធិ ១ , **បដិបទាញាណទស្សនវិសុទ្ធិ** សេចក្តីបរិសុទ្ធិ នៃញាណជាគ្រឿងឃើញផ្លូវបដិបត្តិ ជាអង្គ ជាប្រធាននៃភាពបរិសុទ្ធិ ១ , **ញាណទស្សនវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃញាណទស្សនៈ ជាអង្គជាប្រធាននៃសេចក្តីបរិសុទ្ធិ ១ , **បញ្ញាវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃបញ្ញា ជាអង្គ ជាប្រធាននៃភាពបរិសុទ្ធិ ១ , **វិមុត្តិវិសុទ្ធិ** សេចក្តីបរិសុទ្ធិនៃវិមុត្តិ ជាអង្គ ជាប្រធាននៃភាពបរិសុទ្ធិ ១ ។

បទថា **សីលវិសុទ្ធិ** បានដល់ ចតុប្បារិសុទ្ធិសីល ដែលអាចឲ្យដល់ភាពបរិសុទ្ធិ ។ សីលវិសុទ្ធិនោះ ជម្រះមន្ទិល គឺភាពជាអ្នកទ្រុស្តសីល ។

បទថា **បារិសុទ្ធិបធានិយង្គំ** គឺ ជាអង្គ ជាប្រធានខ្ពស់

បំផុតនៃភាពជាអ្នកបរិសុទ្ធិ ។

បទថា **ចិត្តវិសុទ្ធិ** បានដល់ សមាបត្តិ ៨ ដែលស្ទាត់ជំនាញ ជាបទដ្ឋាននៃវិបស្សនា ។

បទថា **ទិដ្ឋិវិសុទ្ធិ** គឺ ការឃើញនាមរូបព្រមដោយបច្ច័យ ។ ទិដ្ឋិវិសុទ្ធិនោះ ជម្រះមន្ទិល គឺ សត្វទិដ្ឋិ ការឃើញថាជាសត្វ ឲ្យបរិសុទ្ធិ ។

បទថា **កង្ខាវិតរណវិសុទ្ធិ** គឺ ការដឹងបច្ចយាការ ។ ព្រះយោគាវចរ កាលណាឃើញថា ធម៌ទាំងឡាយរមែងប្រព្រឹត្តទៅដោយអំណាចបច្ច័យ ក្នុង **អទ្ធា** កាលដ៏យឺតយូរ ៣ ដោយកង្ខាវិតរណវិសុទ្ធិនោះ ឆ្លងមន្ទិល គឺ ការសង្ស័យ ៧ ក្នុងអទ្ធាសូម្បីទាំង ៣ រមែងបរិសុទ្ធិ ។

បទថា **មគ្គាមគ្គញ្ញាណទស្សនវិសុទ្ធិ** បានដល់ វិបស្សនូ-បកិលេស ១០ គឺ ៖

**ឱភាស** ពន្លឺ ១

**ញាណ** ការដឹង ១

**បីតិ** ការរីករាយនៃចិត្ត ១



**បស្សទ្ធិ** សេចក្ដីស្ងប់ ១

**សុខ** សេចក្ដីសុខ ១

**អធិមោក្ខ** ការបង្អោនចិត្តជឿ ១

**បគ្គហ** សេចក្ដីព្យាយាម ១

**ឧបដ្ឋាន** ការតាំងមាំ ១

**ឧបេក្ខា** ការព្រងើយកន្តើយ ១

**និកន្តិ** សេចក្ដីប្រាថ្នា ១

កើតឡើងក្នុងខណៈ **ឧទយព្វយានុបស្សនា** ពិចារណាឃើញការកើត និងការរលត់ , មិនមែនផ្លូវ , ឧទយព្វយញ្ញាណបដិបិត្តទៅតាមវិថី ជាផ្លូវ ដោយហេតុនោះឈ្មោះថា មគ្គាមគ្គ-ញ្ញាណ ញាណស្គាល់ផ្លូវ និងមិនមែនផ្លូវ ដោយប្រការដូច្នេះ ទើបញុំាងមន្ទិលដែលមិនមែនផ្លូវឲ្យបរិសុទ្ធ ដោយញាណនោះ ។

បទថា **បដិបទាញាណទស្សនវិសុទ្ធិ** បានដល់ វិប-ស្សនាញាណ ៩ ទាំងនេះគឺ :-

**ឧទយព្វយានុបស្សនាញាណ** ញាណដែលឃើញទាំងការកើត ទាំងការរលត់ ។

**ភង្គានុបស្សនាញាណ** ញាណដែលឃើញដល់ការរលត់ ១ ។

**ភយតូបដ្ឋានានុបស្សនាញាណ** ញាណ ដែលឃើញដល់សង្ខារប្រាកដជារបស់គួរខ្លាច ១ ។

**អាទីនវានុបស្សនាញាណ** ញាណ ដែលបានឃើញដល់ទោស ១ ។

**និព្វិទានុបស្សនាញាណ** ញាណ បានឃើញដល់ការនឿយណាយ ១ ។

**មុញ្ចិតុកម្យតាញាណ** ញាណដែលប្រាថ្នានឹងរួចផុត ១ ។

**បដិសង្ខានុបស្សនាញាណ** ញាណ ពិចារណារកផ្លូវ ១ ។

**សង្ខារុបេក្ខាញាណ** ញាណ ក្នុងការព្រងើយកន្តើយក្នុងសង្ខារ ១ ។

**សច្ចានុលោមិកញ្ញាណ** ញាណ ប្រព្រឹត្តទៅដោយសមគួរដល់ការកំណត់ដឹងអរិយសច្ច ១ ។

វិបស្សនាញាណទាំងនោះ រមែងជម្រះមន្ទិល ដែលមានការសម្គាល់ថា ទៀងជាដើម ។

បទថា **ញាណទស្សនវិសុទ្ធិ** បានដល់ បញ្ញាក្នុងអរិយមគ្គ ៤ ។ អរិយមគ្គបញ្ញានោះ រមែងជម្រះមន្ទិល គឺ កិលេសដែលត្រូវសម្លាប់ដោយមគ្គនោះ ៗ ដោយដាច់ខាត ។



បទថា **បញ្ញាវិសុទ្ធិ** បានដល់ បញ្ញាក្នុងអរហត្តផល ។

បទថា **វិមុត្តិវិសុទ្ធិ** បានដល់ វិមុត្តិក្នុងអរហត្តផល ។

បទថា **ទស កសិណាយតនានិ** កសិណ ១០ លោកពោលដល់កសិណ ១០ ទុកយ៉ាងនេះគឺ បុគ្គលពួកមួយ ដឹងព្រមនូវបឋវីកសិណ ខាងលើ ខាងក្រោម ខាងទទឹង មិនមានពីរ មិនមានប្រមាណ , បុគ្គលពួកមួយ ដឹងព្រមអាបោកសិណ ។ល។ បុគ្គលពួកមួយដឹងព្រមតេជោកសិណ , បុគ្គលពួកមួយ ដឹងព្រមវាយោកសិណ , បុគ្គលពួកមួយដឹងព្រមនីលកសិណ , បុគ្គលពួកមួយដឹងព្រមបីតកសិណ , បុគ្គលពួកមួយដឹងព្រម លោហិតកសិណ , បុគ្គលពួកមួយដឹងព្រមឱទាតកសិណ , បុគ្គលពួកមួយដឹងព្រមអាកាសកសិណ , បុគ្គលពួកមួយដឹងព្រមដល់វិញ្ញាណកសិណ ខាងលើ ខាងក្រោម ខាងទទឹង មិនមានពីរ មិនមានប្រមាណ ។ ឈ្មោះថា **កសិណ** ព្រោះអត្ថថា ផ្សាយទូទៅ , មួយាងទៀតឈ្មោះថា **អាយតន** ព្រោះអត្ថថា ជាខេត្ត

ឬជាទីតាំងនៃធម៌ដែលមានកសិណនោះជាអារម្មណ៍ ។

បទថា **ឧទ្ធំ** គឺ សំដៅចំពោះផ្ទៃមេឃខាងលើ ។ បទថា **អធោ** គឺ សំដៅចំពោះផ្ទៃដីខាងក្រោម ។

បទថា **តិរិយំ** គឺ កំណត់ទុកដោយជុំវិញ ដូចបរិវេណរបស់ផ្ទៃដី ។ ព្រោះបុគ្គលពួកខ្លះចម្រើនកសិណខាងលើ , បុគ្គលពួកខ្លះខាងក្រោម , បុគ្គលពួកខ្លះដោយជុំវិញ ។ ឬថា សូម្បីបុគ្គលពួកមួយបំណងនឹងឃើញរូប ដូចបំណងនឹងឃើញពន្លឺ រមែងផ្សាយចេញទៅយ៉ាងនេះ ដោយហេតុនោះ ៗ ។ ដូចលោកពោលទុកថា បុគ្គលពួកមួយដឹងព្រមបឋវីកសិណ ខាងលើ ខាងក្រោម ខាងទទឹង ។

បទថា **អទ្វយំ** នេះ លោកពោលដើម្បីមិនឲ្យកសិណឯណានីមួយមានសភាពជាយ៉ាងដទៃ ។ **បឋវីកសិណ** រមែងជាបឋវីកសិណប៉ុណ្ណោះ បឋវីកសិណនោះ មិនមែនកសិណដទៃ មិនច្រឡូកច្រឡំ ដូចមនុស្សចុះង្ងូតទឹកក្នុងស្ទឹង កំពង់ទឹកនោះ រមែងមានក្នុងទិសទាំងពួង មិនមែនដទៃ ។ ក្នុងបទទាំងពួងមានន័យយ៉ាងនេះ ។



បទថា **អប្បមាណំ** នេះលោកពោលដោយអំណាចការផ្សាយទៅរបស់កសិណនោះ ៗ មិនមានកំណត់ ។ ពិតហើយ កសិណនោះ កាលបើផ្សាយទៅផ្លូវចិត្ត ឈ្មោះថា ពង្រីកទូទៅ មិនបានកំណត់ថា នេះជាខាងដើម នេះជាខាងកណ្តាល របស់កសិណនោះ ។

បទថា **អាកាសកសិណំ** បានដល់ អាកាសដែលបើកកសិណចេញ និងអាកាសកសិណដែលកំណត់ទុក ។

បទថា **វិញ្ញាណកសិណំ** បានដល់ វិញ្ញាណដែលប្រព្រឹត្តទៅក្នុងអាកាសដែលបើកកសិណចេញ ។ ក្នុងវិញ្ញាណកសិណនោះ គប្បីជ្រាបសេចក្តីជាខាងលើ ខាងក្រោម ខាងទទឹង ក្នុងអាកាស ដែលបើកកសិណចេញ ដោយអំណាចនៃកសិណក្នុងវិញ្ញាណ ដែលប្រព្រឹត្តទៅហើយ ក្នុងវិញ្ញាណកសិណនោះដោយអំណាចអាកាសបើកកសិណ ។ គប្បីជ្រាបដោយអំណាចកសិណនោះ ព្រោះសូម្បីអាកាសកសិណដែលកំណត់ទុក ក៏គួរចម្រើនដូច្នេះខ្លះ ។

ឥឡូវនេះ ព្រះសារីបុត្រ កាលសម្តែងប្រភេទរបស់ភាវនា

ទើបពោលបទមានជាអាទិ៍ថា **ទ្វេ ភាវនា** ភាវនា ២ ។ គប្បីវិនិច្ឆ័យក្នុងបទថា **ទ្វេ ភាវនា** ដូចតទៅនេះ ៖-

**វដ្ដ** លោកពោលថា **លោក** ព្រោះអត្ថថា បែកធ្លាយទៅ ឈ្មោះថា **លោកិយា** ព្រោះអត្ថថា ប្រកបហើយក្នុងលោកដោយការទាក់ទងគ្នាក្នុងវដ្ដៈនោះ ការចម្រើនដែលជាលោកិយៈ ឈ្មោះថា **លោកិយា** ។ សូម្បីលោកនឹងពោលថាការចម្រើនធម៌ ដោយវោហារ ការពិត ក៏មិនមានការចម្រើនក្រៅអំពីធម៌ទាំងនោះ ។ ព្រោះលោកចម្រើនធម៌ទាំងនោះឯង ទើបឈ្មោះថា **ភាវនា** ។

បទថា **ឧត្តិណ្ណា** ប្រែថា ឆ្លង ឈ្មោះថា **លោកុត្តរា** ព្រោះអត្ថថា ឆ្លងចាកលោក ដោយការមិនទាក់ទងក្នុងលោក ។

ឈ្មោះថា **រូបាវចរា** ព្រោះអត្ថថា ការប្រព្រឹត្តទៅក្នុងរូប បានដល់ រូបភព ។

**កុសល** សព្ទ ក្នុងបទថា **រូបាវចរកុសលានំ** នេះ រមែងប្រាកដក្នុងការមិនមានរោគ មិនមានទោស ឆ្លាត និងសុខវិបាក ។ ប្រាកដក្នុងការមិនមានរោគ ក្នុងពាក្យមានជាអាទិ៍ថា **កច្ចិ នុ ភោតោ កុសលំ , កច្ចិ ភោតោ អនាមយំ** លោកម្ចាស់



សុខសប្បាយជាទេឬ ? មានអនាម័យល្អឬ ? ។ ប្រាកដក្នុងការមិនមានទោស ក្នុងបទមានជាអាទិ៍យ៉ាងនេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក៏កាយសមាចារជាកុសលដូចម្ដេច ?

មហាបពិត្រ កាយសមាចារមិនមានទោសទេ ជាកុសល និងក្នុងពាក្យមានអាទិ៍ថា បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រការដទៃទៀតមានទៀត ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្ដែងធម៌ក្នុងកុសលធម៌ នោះជា **អនុត្តរិយ** មិនមានធម៌ដទៃប្រសើរជាងនេះ ។

ប្រាកដក្នុងសេចក្ដីឆ្លាត ក្នុងបទមានជាអាទិ៍ថា បពិត្រព្រះរាជកុមារ ព្រះអង្គជាអ្នកឆ្លាត ទ្រង់សម្គាល់ចំណែកតូចធំរបស់រថយ៉ាងណា , និងមានបទជាអាទិ៍ថា ស្ត្រីមានការអង់អាចមានការបងចាំ ជាស្ត្រីឆ្លាតក្នុងការរាំ និងការច្រៀង ។

ប្រាកដក្នុងវិបាក ដូចក្នុងបទមានជាអាទិ៍ថា បុណ្យនេះរមែងចម្រើនយ៉ាងនេះ ព្រោះហេតុសមាទានកុសលធម៌ និងក្នុងបទមានជាអាទិ៍ថា ព្រោះធ្វើ គឺ សន្សំកុសលធម៌ ។

**កុសល** សព្ទ ក្នុងទីនេះ រមែងសមគួរក្នុងការមិនមាន

រោគ សូម្បីក្នុងការមិនមានទោស សូម្បីក្នុងសុខវិបាក ។

ក៏ក្នុងបទនេះមានអធិប្បាយពាក្យដូចតទៅ **កុច្ឆិតេ បាបកេ ធម្មេ សលយន្តិ ចលយន្តិ កម្បេន្តិ វិទ្ធំសេន្តីតិ កុសលា** ធម៌ទាំងនេះឈ្មោះថា **កុសល** ព្រោះអត្ថថា ការពារ រមែងធ្វើឲ្យញាប់ញ័រ រមែងធ្វើឲ្យរញ្ជួយ រមែងកម្ចាត់ធម៌ដ៏លាមកគួរខ្ពើម ។ ម្យ៉ាងទៀត បាបធម៌ ឈ្មោះថា **កុស** ព្រោះអត្ថថា រមែងដេក គឺ រមែងប្រព្រឹត្តទៅដោយអាការដែលគួរខ្ពើម ។ ឈ្មោះថា **កុសល** ព្រោះអត្ថថា កាត់ បំផ្លាញកុសធម៌ដែលគួរខ្ពើម បានដល់ អកុសលទាំងនោះ , ម្យ៉ាងទៀត ឈ្មោះថា **កុសល** ព្រោះធ្វើវត្ថុដែលគួរខ្ពើមឲ្យតិចចុះជាទីបំផុត បានដល់ **ញាណ** ។ ឈ្មោះថា **កុសល** ព្រោះអត្ថថា គប្បីកាត់ គប្បីចាប់ទុក គឺ គប្បីឲ្យប្រព្រឹត្តទៅដោយ **កុស** ញាណនោះ ។

ម្យ៉ាងទៀត ឈ្មោះថា **កុសល** ព្រោះអត្ថថា កុសលសូម្បីទាំងនោះ រមែងកាត់ផ្តាច់ចំណែកដែលជាសង្កិលេស បានដល់ចំណែកទាំងពីរ ទាំងកើត និងមិនទាន់កើត , ដូចស្បូវមុតដៃដែលដល់ចំណែកទាំងពីរ , ព្រោះដូច្នោះ ទើបដូចស្បូវដែល



បុគ្គលកាត់ បានដល់ ការចម្រើនរូបាវចរកុសលទាំងនោះ ។ ដែលឈ្មោះថា **អរូបាវចរ** ព្រោះធ្វើដំណើរទៅក្នុងអរូប បានដល់ អរូបភព ។ ឈ្មោះថា **បរិយាបន្នា** ការបន្ត ព្រោះអត្ថថា បន្ត គឺ ធ្លាក់ចុះខាងក្នុង ក្នុងវដ្តៈដែលប្រព្រឹត្តទៅក្នុងភូមិ ៣ , ដែលឈ្មោះថា **អបរិយាបន្នា** ការមិនបន្ត ព្រោះអត្ថថា មិនបន្តក្នុងវដ្តៈ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ នោះ ទើបជា **លោកុត្តរ** ។

ប្រសិនបើសួរថា ព្រោះហេតុអ្វី ទើបលោកមិនពោលដល់ការចម្រើនធម៌ដែលជាកាមាវចរកុសល ? ឆ្លើយថា ព្រោះការចម្រើននៅមិនទាន់ដល់ថ្នាក់អប្បនា លោកបំណងយកការចម្រើនក្នុងអភិធម៌ ដូចដែលលោកពោលទុកក្នុងអភិធម៌នោះថា ៖-

**ព្រះយោគាវចរមិនបានស្តាប់ពីអ្នកដទៃ រមែងបានចំពោះនូវខន្តិ ទិដ្ឋិ រុចិ មុតិ ការដឹង បេក្ខៈ ការសម្លឹងមើល ធម្មនិជ្ឈានក្ខន្តិ ខន្តិ គឺ ការសម្លឹងធម៌ ដែលជាអនុលោម ឃើញយ៉ាងនេះ គឺ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណ ដែលជាកម្មស្សកតាញាណ ឬសច្ចានុលោមិកញ្ញាណ**

> ក្នុងកាម្មាយតនៈ សិប្បាយតនៈ វិជ្ជាឋានៈ ដែលចាត់ទុកដោយយោគៈ ជារបស់មិនទៀង នេះលោកពោលថា ចិន្តាមយបញ្ញា ។ មយ៉ាង ទៀត ព្រះយោគាវចរ បានស្តាប់ពីអ្នកដទៃ រមែងបាននូវ ខន្តិ ទិដ្ឋិ រុចិ មុតិ បេក្ខៈ ធម្ម-និជ្ឈានក្ខន្តិ ក្នុងកាម្មាយតនៈ ដែលចាត់ទុក ដោយយោគៈ ។ ល ។ នេះលោកពោលថា សុតមយបញ្ញា ។ បញ្ញា របស់អ្នកចូលដល់ ហើយ សមាបត្តិទាំងអស់ ជាភាវនាមយបញ្ញា ។

ចំណែកកាមាវចរភាវនានោះ គប្បីជ្រាបថា លោកមិន ហៅថា **ភាវនា** ព្រោះភាពនៃកាមាវចរភាវនានោះ មានក្នុងវាង អាវជ្ជនៈ និងភវង្គ ។

ឧបចារសមាធិ និងវិបស្សនាសមាធិ ជាបុណ្យសម្រេច ដោយភាវនា ជាការសម្រេចហើយព្រោះបុណ្យទាំងអស់ ដែល ប្រព្រឹត្តទៅក្នុងចំណែកបុញ្ញកិរិយាវត្ថុ ៣ យ៉ាង ។ តែក្នុងទីនេះ លោកសង្គ្រោះភាវនា ចូលក្នុងលោកិយភាវនានោះឯង ។

គប្បីជ្រាបនូវរូបាវចរៈ និងអរូបាវចរៈ មាន ៣ យ៉ាង



ដូចតទៅនេះ បទថា **ហីនា** គឺ លាមក ។ ភាវនាក្នុង ចំណែកកណ្តាលនៃធម៌ថោកទាប និងធម៌ខ្ពស់បំផុត ឈ្មោះថា **មជ្ឈា** បាឋៈថា **មជ្ឈិមា** ខ្ញុំ ។ ឈ្មោះថា **បណីតា** ព្រោះអត្ថថា នាំទៅកាន់ភាពជាប្រធាន បានដល់ ប្រសើរបំផុត ។

គប្បីជ្រាបនូវភាវនា ដែលជាចំណែកថោកទាប ចំណែក កណ្តាល , និងចំណែកប្រណីត ដោយការរួបរួមមក ។ ព្រោះ ក្នុងខណៈរួបរួមមក ភាវនាដែលមានឆន្ទៈ វិរិយៈ ចិត្តៈ វិមំសា ថោកថយ ឈ្មោះថា **ហីនា** ។ ភាវនាដែលជាធម៌កណ្តាល ឈ្មោះថា **មជ្ឈិមា** ។ ភាវនាដែលប្រណីត ឈ្មោះថា **បណីតា** ។ មយ៉ាងទៀត ភាវនាដែលសម្បយុត្តដោយឥន្ទ្រិយនៅទន់ខ្សោយ ឈ្មោះ ថា **ហីនា** ។ ភាវនាដែលសម្បយុត្តដោយឥន្ទ្រិយយ៉ាងកណ្តាល ឈ្មោះថា **មជ្ឈិមា** ភាវនាដែលសម្បយុត្តដោយឥន្ទ្រិយ មាន ប្រមាណមិនបាន ឈ្មោះថា **បណីតា** ។ លោកពោលដល់ ភាពប្រណីតប៉ុណ្ណោះ ព្រោះភាវនាមិនរាប់បន្ត មិនមានចំណែក អាក្រក់ និងចំណែកកណ្តាល ។ ភាវនានោះ ឈ្មោះថា **បណីតា** ព្រោះអត្ថថា ខ្ពស់ និងព្រោះអត្ថថា មិនក្តៅក្រហាយ ។

**ក្នុងបឋមភាវនាចតុក្កៈ មានវិនិច្ឆ័យដូចតទៅ ៖-**

បទថា **ភាវេតិ** បានដល់ ព្រះយោគាវចរសម្រេចយ៉ាង នោះ ៗ ក្នុងមួយខណៈប៉ុណ្ណោះ ឈ្មោះថា រមែងចម្រើនអរិយ-មគ្គ ។

**ក្នុងទុតិយភាវនាចតុក្កៈ មានវិនិច្ឆ័យដូចតទៅនេះ ៈ-**

បទថា **ឯសនាភាវនា** បានដល់ ភាវនាក្នុងចំណែកខាង ដើមរបស់ **អប្បនា** ។ ឯសនាភាវនានោះ លោកពោលថា **ឯសនា** ព្រោះជាហេតុស្វែងរក **អប្បនា** ។

បទថា **បដិលាភភាវនា** បានដល់ **អប្បនាភាវនា** ។ បដិលាភភាវនានោះ លោកពោលថា **បដិលាភ** ព្រោះបានដោយ ការស្វែងរកនោះ ។

បទថា **ឯករសាភាវនា** បានដល់ ភាវនាក្នុងវេលាប្រកប សេចក្តីព្យាយាមរបស់អ្នកប្រាថ្នានឹងសម្រេច ភាពជាអ្នកជំនាញក្នុង ការបានចំពោះ ។ ឯករសាភាវនានោះ មានរសជាមួយគ្នាដោយ វិមុត្តិរស ព្រោះផុតពីកិលេសនោះ ៗ ដោយ **បហាន** នោះ ៗ ព្រោះហេតុនោះ លោកទើបពោលថា **ឯករសា** ។

បទថា **អាសេវនាភាវនា** បានដល់ ភាវនាក្នុងវេលា



បរិភោគតាមសេចក្តីត្រូវការ របស់អ្នកសម្រេចសេចក្តីជំនាញក្នុង ការបានចំពោះ ។ អាសេវនាភាវនានោះ លោកពោលថា **អាសេវនា** ព្រោះអត្ថថា សេពដ៏ធ្ងន់ ។ តែអាចារ្យពួកខ្លះលោក ពោលទុកថា អាសេវនាភាវនា ជា **វសីកម្ម** ។ ឯករសាភាវនា មានប្រយោជន៍ទាំងអស់ ។

គប្បីជ្រាប សេចក្តីក្នុងចតុក្កវិភាគដូចតទៅនេះ បទថា **សមាធឹ សមាបជ្ជន្តានំ** កាលព្រះយោគាវចរ ចូលសមាធិហើយ ជាការពោលដល់ បច្ចុប្បន្នជិតបច្ចុប្បន្ន ។

បទថា **តត្ថ ជាតា** បានដល់ ធម៌ទាំងឡាយដែលកើតក្នុង ធម៌ដែលជាចំណែកខាងដើមនោះ ។ បទថា **ឯករសា ហោន្តិ** ជាធម៌មានកិច្ចស្មើគ្នាក្នុងការចូលដល់អប្បនា ។ បទថា **សមាធឹ សមាបន្នានំ** កាលព្រះយោគាវចរចូលសមាធិហើយ បានដល់ មានអប្បនាប្រាកដហើយ ។

បទថា **តត្ថ ជាតា** បានដល់ ធម៌ទាំងឡាយដែលកើតក្នុង អប្បនានោះ ។ បទថា **អញ្ញមញ្ញំ នាតិវត្តន្តិ** មិនប្រព្រឹត្តទៅ កន្លងគ្នានិងគ្នា បានដល់ មិនកន្លងគ្នានិងគ្នា ដោយប្រព្រឹត្តទៅ ស្មើគ្នា ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងបទមានជាអាទិ៍ថា **អធិមោក្ខដ្ឋេន សទ្ធិន្ទ្រិយំ ភាវយតោ** កាលព្រះយោគាវចរចម្រើនសទ្ធិន្ទ្រិយ ដោយអត្ថថា បង្អោនចិត្តជឿ ដូចតទៅនេះ ឥន្ទ្រិយដ៏សេសមានកិច្ចរបស់ខ្លួន ជាហេតុ ដោយអាស្រ័យឥន្ទ្រិយនោះ ៗ ក្នុងការធ្វើកិច្ចរបស់ខ្លួន នៃឥន្ទ្រិយមួយ ៗ សូម្បីក្នុងខណៈជាមួយគ្នា ទើបមានរសដូចគ្នាដោយវិមុត្តិរស ព្រោះហេតុនោះ ទើបឈ្មោះថា **ភាវនា** ព្រោះអត្ថថា មានរសដូចគ្នាដោយវិមុត្តិរសនោះឯង ។ សូម្បីក្នុងពលៈ ពោជ្ឈង្គៈ និងអង្គមគ្គ ក៏មានន័យនេះដូចគ្នា ។

មួយទៀត បទថា **ឯករសា** ជាលិង្គវិបល្លាស ។

បទថា **ឥធ ភិក្ខុ** គឺ ភិក្ខុក្នុងសាសនានេះ ។ ឈ្មោះថាភិក្ខុ ព្រោះអត្ថថា ឃើញភ័យក្នុងវដ្តសង្សារ ។

ក្នុងបទមានជាអាទិ៍ថា **បុព្វណ្ហសមយំ** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃអច្ចន្តសំយោគ អស់ , រហូត , តែដោយអត្ថជាសត្តមីវិភត្តិ មានសេចក្តីថា មុនពេលថ្ងៃ គឺ វេលាព្រឹក ។

បទថា **អាសេវតិ** បានដល់ សេពយ៉ាងច្រើននូវសមាធិដែលដល់នូវភាពជំនាញ ។

បទថា **មជ្ឈន្តិកសមយំ** បានដល់ ក្នុងវេលាថ្ងៃ គឺ



វេលាថ្ងៃត្រង់ ។

បទថា **សាយណ្ហសមយំ** បានដល់ ក្នុងវេលាល្ងាច ។

បទថា **បុរេភត្តំ** បានដល់ មុនភត្តក្នុងវេលាថ្ងៃត្រង់ ។

បទថា **បច្ឆាភត្តំ** បានដល់ ក្រោយភត្តក្នុងវេលាថ្ងៃត្រង់ ។

បទថា **បុរេមបិ យាមេ** បានដល់ ក្នុងយាមខាងដើមនៃរាត្រី ។

បទថា **កាឡេ** បានដល់ ក្នុងកាឡបក្ស ខាងរនោច ។

បទថា **ជុណ្ហេ** បានដល់ ក្នុងសុក្កបក្ស ខាងខ្នើត ។

បទថា **បុរេមបិ វយោខន្ធេ** បានដល់ ក្នុងចំណែកវ័យដំបូង គឺ បឋមវ័យ ។ មួយទៀតក្នុង ៣ វ័យ មនុស្សមានអាយុ ១០០ ឆ្នាំ ក្នុងវ័យមួយ ៗ មានអាយុ ៣៣ ឆ្នាំ ៤ ខែ ។

**គប្បីជ្រាបវិនិច្ឆ័យក្នុងតតិយភាវនាចតុក្កៈ ដូចតទៅនេះ ៖-**

បទថា **តត្ថ ជាតានំ ធម្មានំ អនតិវត្តនដ្ឋេន** ភាវនា ដោយអត្ថថា មិនកន្លងគ្នានិងគ្នានៃធម៌ទាំងឡាយ ដែលកើតឡើងក្នុងភាវនានោះ គឺ ដោយការមិនកន្លងគ្នានឹងគ្នា នៃធម៌ជាគូគ្នា បានដល់ សមាធិ និងបញ្ញាដែលកើតឡើង ក្នុងភាវនាពិសេសមាននេក្ខម្មៈជាដើមនោះ ។

-

បទថា **ឥន្ទ្រិយានំ ឯករសដ្ឋេន** ការនាដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសដូចគ្នា គឺ ដោយឥន្ទ្រិយទាំងឡាយ មានសទ្ធាជាដើមមានរសដូចគ្នា ដោយវិមុត្តិរស ព្រោះផុតចាកកិលេសផ្សេង ៗ ។

បទថា **តទុបគវីរិយវាហនដ្ឋេន** ការនាដោយអត្ថថា នាំទៅនូវសេចក្តីព្យាយាមដែលចូលដល់ធម៌នោះ ៗ គឺ ដោយការនាំទៅនូវសេចក្តីព្យាយាមដ៏សមគួរដល់ភាពនៃធម៌នោះ មានរសដូចគ្នា មិនកន្លងគ្នា ។

បទថា **អាសេវនដ្ឋេន** ការនាដោយអត្ថថា សេពជាចំណែកច្រើន គឺ ដោយការសេពដ៏ច្រើននៃការសេព ដែលប្រព្រឹត្តទៅក្នុងសម័យនោះ ៗ ។

បទថា **រូបសញ្ញំ** បានដល់ រូបសញ្ញា ពោលគឺ រូបាវចរ-ជ្ឈាន ១៥ យ៉ាង ដោយអំណាចកុសលវិបាក-កិរិយា ។ សូម្បីរូបាវចរជ្ឈាន លោកក៏ពោលថា **រូប** ក្នុងបទមានជាអាទិ៍ថា **រូបី រូបានិ បស្សតិ** អ្នកមានរូប រមែងឃើញរូប , សូម្បីអារម្មណ៍នៃឈាននោះ លោកក៏ពោលថា **រូប** ក្នុងបទមានជាអាទិ៍ថា ឃើញ



រូបខាងក្រៅមានពណ៌សំបុរ ស្អាតនិងមិនស្អាត ។ រូបាវចរជ្ឈានជាសញ្ញាក្នុងរូប ដោយមាតិកាថា **សញ្ញា** ព្រោះហេតុនោះ លោកទើបពោលថា **រូបសញ្ញា** ។

បទថា **បដិឃសញ្ញំ** បានដល់ បដិឃសញ្ញា ១០ យ៉ាង គឺ កុសលវិបាក ៥ អកុសលវិបាក ៥ ។ សញ្ញាសម្បយុត្តដោយទ្វិបញ្ចវិញ្ញាណ លោកហៅថា បដិឃសញ្ញា ព្រោះវត្ថុ មានចក្ខុជាដើម និងអារម្មណ៍ មានរូបជាដើម កើតមានឡើងដោយការប៉ះខ្ទប់ ។ ឈ្មោះរបស់សញ្ញានេះ គឺ រូបសញ្ញា សទ្ទសញ្ញា គន្ធសញ្ញា រសសញ្ញា ផោដ្ឋព្វសញ្ញាខ្លះ ។

បទថា **នានត្តសញ្ញំ** បានដល់ នានត្តសញ្ញា ៤៤ យ៉ាង គឺ កាមាវចរកុសលសញ្ញា ៨ , អកុសលសញ្ញា ១២ , កាមា-វចរកុសលវិបាកសញ្ញា ១១ , អកុសលវិបាកសញ្ញា ២ , កាមា-វចរកិរិយាសញ្ញា ១១ ។ នានត្តសញ្ញានោះ ជាសញ្ញាប្រព្រឹត្តទៅក្នុងគោចរដែលមានប្រភេទ មានរូប និងសំឡេងជាដើម មានការផ្សេងគ្នា គឺ មានសភាពផ្សេងគ្នា ព្រោះហេតុនោះ ទើបជា **នានត្តសញ្ញា** ។ មួយ៉ាងទៀតសញ្ញាមិនដូចគ្នា មានការផ្សេងគ្នា

មានសភាពផ្សេងគ្នាដោយប្រភេទ ៤៤ យ៉ាង លោកពោលថាជា **នានត្តសញ្ញា** ។ សូម្បីសញ្ញាមានច្រើន លោកក៏ធ្វើឲ្យជាឯកវចនៈ ដោយ **ជាតិ** ស័ព្ទ ។

បទថា **និច្ចសញ្ញំ** បានដល់ សញ្ញា ថាជារបស់ទៀង ឈ្មោះ **និច្ចសញ្ញា** ។ **សុខសញ្ញា** **អត្តសញ្ញា** ក៏យ៉ាងនោះ ។ បទថា **នន្ទឹ** សេចក្តីរីករាយ បានដល់ តណ្ហា ដែលមានការរីករាយចិត្ត ។ បទថា **រាគំ** បានដល់ តណ្ហា មិនមានការឆ្អែត ។ បទថា **សមុទយំ** បានដល់ ហេតុនាំឲ្យកើតរាគៈ ។ មយ៉ាងទៀត **ឧទយំ** ការកើតឡើងនៃសង្ខារទាំងឡាយ ព្រោះឃើញការរលត់ដោយភង្គានុបស្សនាញាណ ។

បទថា **អាទានំ** ការប្រកាន់មាំ គឺ ប្រកាន់ខ្ជាប់កិលេសដោយអំណាចការកើត ឬប្រកាន់ខ្ជាប់អារម្មណ៍ ដែលជាសង្ខតៈព្រោះមិនឃើញទោស ។

បទថា **ឃនសញ្ញំ** បានដល់ សញ្ញា ថាជាដុំដោយសន្តតិការបន្ត ។

បទថា **អាយូហនំ** បានដល់ ការធ្វើសេចក្តីព្យាយាម ដើម្បី



ប្រយោជន៍ដល់សង្ខារ ។

បទថា **ធុវសញ្ញំ** បានដល់ សញ្ញាថា មាំមួន ។

បទថា **និមិត្តំ** បានដល់ គ្រឿងសម្គាល់ថាទៀង ។

បទថា **បណិធឹ** បានដល់ ប្រាថ្នាសេចក្តីសុខ ។

បទថា **អភិនិវេសំ** បានដល់ ការប្រកាន់មាំថាមានខ្លួនហើយ ។

បទថា **សារាទានាភិនិវេសំ** សេចក្តីប្រកាន់មាំដោយប្រកាន់ថា មានខ្លឹមសារ បានដល់ ការប្រកាន់មាំ ដោយការប្រកាន់ថាខ្លួនមានខ្លឹមសារជានិច្ច ។

បទថា **សម្មោហាភិនិវេសំ** សេចក្តីប្រកាន់មាំដោយការវង្វេង បានដល់ ការប្រកាន់មាំដោយការវង្វេង មានបទជាអាទិ៍ថា យើងមានក្នុងកាលជាអតីត និងដោយបទមានអាទិ៍ថា សត្វលោកកើតអំពីព្រះ ។

បទថា **អាលយាភិនិវេសំ** ការប្រកាន់មាំដោយសេចក្តីអាល័យ បានដល់ ប្រកាន់ខ្ជាប់ថា នេះគួរប្រកាន់ឲ្យមាំ ព្រោះមិនឃើញទោស ។

បទថា **អប្បដិសង្ខំ** ការមិនពិចារណា បានដល់ ការមិន

កាន់យកនូវឧបាយ ។ បទថា ***សញ្ញោគាភិនិវេសំ*** ការប្រកាន់មាំដោយកិលេស ជាគ្រឿងប្រកបសត្វ បានដល់ ការប្រព្រឹត្តទៅនៃកិលេស មានកាមយោគៈជាដើម ។

បទថា ***ទិដ្ឋេកដ្ឋេ*** កិលេសជាទីតាំងរួមជាមួយនឹងទិដ្ឋិ បានដល់ ឈ្មោះថា ***ទិដ្ឋេកដ្ឋា*** ព្រោះអត្ថថា តាំងក្នុងទីតែមួយជាមួយគ្នានឹងទិដ្ឋិ ។ ដែលកិលេសតាំងរួមគ្នាជាមួយទិដ្ឋិនោះ ។

ឈ្មោះថា ***កិលេសា*** ព្រោះកិលេសធ្វើឲ្យសៅហ្មង ឲ្យក្ដៅក្រហាយ ឲ្យលំបាក ។ កិលេសតាំងនៅរួមគ្នា ២ យ៉ាង គឺ តាំងនៅក្នុងទីជាមួយគ្នាដោយការលះ ១ តាំងនៅក្នុងទីជាមួយគ្នាដោយការកើតរួមគ្នា ១ ។ ឈ្មោះថា តាំងនៅក្នុងទីជាមួយគ្នាដោយការលះ ព្រោះលះទិដ្ឋិ ៦២ មានសក្កាយទិដ្ឋិជាប្រធានដោយសោតាបត្តិមគ្គ , អធិប្បាយថា កិលេសទាំងឡាយតាំងនៅក្នុងបុគ្គលម្នាក់ ។ បទនេះលោកបំណងយកក្នុងទីនេះ ។ កិលេស ១០ យ៉ាង ក្នុងទីនេះ សំដៅដល់កិលេស គឺ ទិដ្ឋិ ប៉ុណ្ណោះ ។ ក៏ក្នុងកិលេសដ៏សេស កិលេស ៩ យ៉ាង គឺ លោភៈ ១ ទោសៈ ១ មោហៈ ១ មានៈ ១ វិចិកិច្ឆា១ ថីនៈ ១ ឧទ្ធច្ចៈ ១ អហិរិកៈ ១



អនោត្តប្បៈ ១ ជាកិលេសធ្វើសត្វឲ្យ ទៅកាន់អបាយ តាំងនៅក្នុងទីជាមួយគ្នានឹងទិដ្ឋិ លះបានដោយសោតបត្តិមគ្គ , កិលេសទាំងអស់ដែលនាំសត្វទៅកាន់អបាយ , មយ៉ាងទៀត បណ្ដាកិលេស ១.៥០០ មានរាគៈ ទោសៈ មោហៈជាប្រធាន , កាលបើលះទិដ្ឋិបាន ដោយសោតាបត្តិមគ្គ កិលេសទាំងអស់ដែលនាំសត្វទៅកាន់អបាយព្រមជាមួយនឹងទិដ្ឋិ រមែងលះបានដោយការតាំងនៅក្នុងទីជាមួយគ្នា ដោយបហានៈ , ក្នុងកិលេសតាំងនៅក្នុងទីជាមួយគ្នា ដោយការកើតរួមគ្នា មានអធិប្បាយថា កិលេសទាំងឡាយតាំងនៅក្នុងចិត្តមួយដួងជាមួយគ្នា ជាមួយនឹងទិដ្ឋិ ។ កាលបើលះចិត្តដែលជាអសង្ខារិកៈ សម្បយុត្តដោយទិដ្ឋិ ២ យ៉ាង ដោយសោតាបត្តិមគ្គបាន កិលេសទាំងនេះ គឺ លោភៈ មោហៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ កើតរួមជាមួយគ្នានឹងចិត្តទាំងនោះ រមែងលះបង់បានដោយអំណាចកិលេស តាំងនៅទីជាមួយគ្នា ដោយការកើតរួមគ្នា ។ កាលបើលះបង់ ចិត្តដែលជាសសង្ខារិកៈ ដែលសម្បយុត្តដោយទិដ្ឋិ ២ យ៉ាង បានកិលេសទាំងនេះ គឺ លោភៈ មោហៈ ថីនៈ ឧទ្ធច្ចៈ អហិរិកៈ អនោត្តប្បៈ កើតរួមគ្នាជាមួយចិត្ត

ទាំងនោះ រមែងលះបានដោយអំណាចកិលេសតាំងនៅក្នុងទីជាមួយគ្នា ដោយការកើតរួមគ្នា ។

បទថា **ឱឡារិកេ កិលេសេ** បានដល់ កិលេសគ្រោតគ្រាត បានដល់ កាមរាគៈ ព្យាបាទៈ ដែលជាកិលេសគ្រោតគ្រាត ។

បទថា **អណុសហគតេ កិលេសេ** កិលេសយ៉ាងល្អិត បានដល់ កាមរាគៈ ព្យាបាទៈ ដែលជាកិលេសដ៏ល្អិត ។

បទថា **សព្វកិលេស** បានដល់ កិលេសដ៏សេស លះបង់បានដោយមគ្គទី ៣ ។

បទថា **វីរិយំ វាហេតិ** រមែងនាំទៅនូវសេចក្ដីព្យាយាម សេចក្ដីថា ព្រះយោគាវចរញ៉ាំងសេចក្ដីព្យាយាមឲ្យប្រព្រឹត្តទៅ ។ លោកពោលដល់ **ឯសនាភាវនា បដិលាភាវនា ឯករសាភាវនា អាសេវនាភាវនា** ក្នុងខាងក្រោយ ដើម្បីសម្ដែងដល់ការផ្សេងគ្នានៃភាវនាទាំងឡាយថា ភាវនាជាយ៉ាងនេះ ។ ដើម្បីសម្ដែងដល់ហេតុនៃភាវនា លោកទើបពោលពាក្យទាំងឡាយថា ឈ្មោះថា ភាវនា ដោយអត្ថថា មិនកន្លងធម៌ដែលកើតក្នុងភាវនានោះ ដោយអត្ថថា ឥន្ទ្រិយទាំងឡាយមានរសតែមួយ ដោយអត្ថថា នាំទៅនូវសេចក្ដី



ព្យាយាមដែលចូលដល់ធម៌នោះ ៗ ដោយអត្ថថា សេពដ៏យ៉ាងច្រើន ។ លោកពោលថា **ភាវនា** ដោយហេតុនេះ និងដោយហេតុនេះ ហើយពោលដោយអំណាចខណៈផ្សេង ៗ គ្នាថា **អាសេវនាភាវនា** ក្នុងខាងក្រោយ , ក្នុងទីនេះ ឈ្មោះថា **ភាវនា** ដោយអត្ថថា សេពដ៏យ៉ាងច្រើន ព្រោះហេតុនោះ ទើបមានសេចក្ដីផ្សេងគ្នា ដោយបទថា **ឯកក្ខណាសេវន** ដោយអំណាចខណៈមួយ ។

ក្នុងបទមានជាអាទិ៍ថា **រូបំ បស្សន្តោ ភាវេតិ** ព្រះយោគាវចរ កាលបើពិចារណាឃើញរូប ឈ្មោះថា ចម្រើនភាវនា មានអធិប្បាយថា ព្រះយោគាវចរ កាលបើពិចារណាឃើញរូបជាដើម ដោយអាការដែលគួរឃើញ ឈ្មោះថា រមែងចម្រើនភាវនា ដែលគួរភាវនា ។

បទថា **ឯករសា ហោន្តិ** ភាវនា មានរសតែមួយដូចគ្នា គឺមានរសតែមួយ ដោយវិមុត្តិរស ឬដោយរសដែលជាកិច្ច ។ បទថា **វិមុត្តិរសោ** បានដល់ សម្បត្តិរស រស គឺ ការដល់ព្រម ឈ្មោះថា

**រស** លោកពោលដោយអត្ថថា ដល់ព្រមដោយកិច្ច ដោយហេតុនោះ លោកក៏បានពោលទុកហើយ ។

ចប់អដ្ឋកថា ភាវេតព្វនិទ្ទេស

ចប់អដ្ឋកថា ចតុត្ថភាណវារៈ

p [ q

## អ ដ្ឋ ក ថា

## សច្ឆិកាតព្វនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុងសច្ឆិកាតព្វនិទ្ទេស ដូចតទៅនេះ ៈ-

ព្រះសារីបុត្តត្ថេរពោលវិសជ្ជនា **ឯកុត្តរ** ធម៌ ១០ ប្រការ ដោយការធ្វើឲ្យជាក់ច្បាស់ដល់ការបានចំពោះ ។

ក្នុងបទទាំងនោះបទថា **អកុប្បា ចេតោវិមុត្តិ** ចេតោវិមុត្តិដែលមិនកម្រើក បានដល់ អរហត្តផលវិមុត្តិ ។ ចេតោវិមុត្តិនោះឈ្មោះថា **អកុប្បា** ព្រោះអត្ថថា មិនកម្រើក មិនញាប់ញ័រ មិនឲ្យវិនាស , លោកពោលថា ចេតោវិមុត្តិ ព្រោះចិត្តផុតពីកិលេស



ទាំងពួង ។

បទថា **វិជ្ជា** បានដល់ វិជ្ជា ៣ ។ បទថា **វិមុត្តិ** លោកពោលដល់អរហត្តផល ដោយបរិយាយក្នុងទសុត្តរសូត្រ , តែលោកពោលដោយបរិយាយក្នុងសង្គីតិសូត្រថា បទថា **វិមុត្តិ** បានដល់ វិមុត្តិ ២ យ៉ាង គឺ ការបង្អោនចិត្តទៅ **ចិត្តស្ស ច អធិមុត្តិ** និងនិព្វាន ។

ម្យ៉ាងទៀត ក្នុងនិទ្ទេសនេះ សមាបត្តិ ៨ ឈ្មោះថា **វិមុត្តិ** ព្រោះផុតដោយល្អពីនីវរណៈធម៌ជាដើម , និព្វាន ឈ្មោះថា **វិមុត្តិ** ព្រោះផុតពីសង្ខតធម៌ទាំងពួង ។

បទថា **តិស្សោ វិជ្ជា** វិជ្ជា ៣ គឺ ញាណរឭកជាតិមុនបាន ១ , ញាណដឹងចុតិ និងឧប្បត្តិរបស់សត្វទាំងឡាយ ១ , ញាណធ្វើអាសវៈឲ្យអស់ ១ ។ ឈ្មោះថា **វិជ្ជា** ដោយអត្ថថា កម្ចាត់សេចក្តីងងឹតបាន , ឈ្មោះថា **វិជ្ជា** ដោយអត្ថថា ធ្វើសេចក្តីដឹងឲ្យជាក់ច្បាស់បាន , **បុព្វេនិវាសានុស្សតិញ្ញាណ** ឈ្មោះថា វិជ្ជា ព្រោះកម្ចាត់សេចក្តីងងឹតដែលបិទបាំងការរឭកជាតិដែលកើតឡើង ចេញបាន , និងធ្វើការដឹងច្បាស់ដល់ការរឭកជាតិបាន ។

**ចុតូបបាតញ្ញាណ** ឈ្មោះថា **វិជ្ជា** ព្រោះកម្ចាត់ សេចក្តីងងឹតដែលបិទបាំងចុតិ និងបដិសន្ធិចេញបាន , និងធ្វើឲ្យដឹងច្បាស់ដល់ចុតិ និងឧប្បត្តិ ។ **អាសវក្ខយញ្ញាណ** ឈ្មោះថា **វិជ្ជា** ព្រោះកម្ចាត់ សេចក្តីងងឹតដែលបិទបាំងអរិយសច្ច ៤ , និងធ្វើឲ្យដឹងច្បាស់ដល់អរិយសច្ចធម៌ ៤ ។

បទថា **ចត្តារិ សាមញ្ញផលានិ** សាមញ្ញផល ៤ គឺ សោតាបត្តិផល ១ សកទាគាមិផល ១ អនាគាមិផល ១ អរហត្តផល ១ ។ ឈ្មោះថា **សមណ** ព្រោះអត្ថថា ញុំាងធម៌លាមកឲ្យស្ងប់ គឺ ឲ្យវិនាស , ភាពជាសមណៈ ឈ្មោះថា **សាមញ្ញ** ។ សាមញ្ញនេះ ជាឈ្មោះរបស់អរិយមគ្គ ៤ ។ ផលនៃសាមញ្ញៈ ឈ្មោះថា **សាមញ្ញផល** ។

បទថា **បញ្ច ធម្មក្ខន្ធា** ធម្មក្ខន្ធ ៥ គឺ សីលក្ខន្ធ ១ សមាធិខន្ធ ១ បញ្ញាខន្ធ ១ វិមុត្តិខន្ធ ១ និងវិមុត្តិញាណ-ទស្សនខន្ធ ១ ។

បទថា **ធម្មក្ខន្ធា** គឺ ការចែកធម៌ ចំណែករបស់ធម៌ សូម្បីក្នុងសីលក្ខន្ធជាដើម ក៏មានន័យនេះដូចគ្នា ។ **សីល សមាធិ**



**បញ្ញា** ទាំងដែលជាលោកិយ និងលោកុត្តរនោះឯង ឈ្មោះថា **សីលសមាធិបញ្ញាខន្ធ** ។ សមុច្ឆេទវិមុត្តិ បដិប្បស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិនោះឯង ឈ្មោះថា **វិមុត្តិខន្ធ** ។ ការពិចារណាវិមុត្តិ ៣ យ៉ាងនោះ ឈ្មោះថា **វិមុត្តិញាណទស្សនខន្ធ** , ខន្ធជាលោកិយៈ ឈ្មោះថា **ញាណ** ព្រោះអត្ថថា ដឹង , ឈ្មោះថា **ទស្សន** ព្រោះអត្ថថា ឃើញ ព្រោះហេតុនោះ ទើបឈ្មោះថា **ញាណទស្សន** ។ ញាណទស្សននៃវិមុត្តិ ទាំងឡាយ លោកពោលថា **វិមុត្តិញាណ-ទស្សន** ។ ចំណែកវិក្ខម្ភនវិមុត្តិ និងតទង្គវិមុត្តិ លោកសង្គ្រោះចូលដោយសមាធិខន្ធ និងបញ្ញាខន្ធ ។ ធម្មខន្ធ ៥ ទាំងនេះ លោកពោលថា ជាសេក្ខធម៌របស់អ្នកនៅសិក្សា ជាអសេក្ខធម៌របស់អ្នកមិនត្រូវសិក្សា ។ ក្នុងធម្មក្ខន្ធទាំងនេះ ធម្មក្ខន្ធដែលជាលោកិយៈ និងជានិស្សរណវិមុត្តិ ជានេវសេក្ខានាសេក្ខធម៌ ធម៌របស់អ្នកសិក្សាក៏មិនមែន មិនត្រូវសិក្សាក៏មិនមែន ។ សូម្បីសេក្ខធម៌មាន លោកក៏ពោលសេក្ខធម៌ថា ទាំងនេះជារបស់អ្នកត្រូវសិក្សា , ពោលអសេក្ខធម៌ថា ទាំងនេះជារបស់អ្នកមិនត្រូវសិក្សា ។ ក្នុងបទនេះថា ព្រះយោគាវចរអ្នកប្រកបដោយវិមុត្តិខន្ធ

ដែលជាសេក្ខធម៌ តែគប្បីជ្រាបថា ព្រះយោគាវចរជាអ្នកប្រកប ដោយការធ្វើនិស្សរណវិមុត្តិឲ្យជាអារម្មណ៍ ។

បទថា **ឆ អភិញ្ញា** ញាណដ៏ក្រៃលែង ៦ ។ ញាណដ៏ក្រៃលែង ៦ ដូចម្ដេច ? , ញាណទាំង ៦ នេះ គឺ ឥទ្ធិវិធញ្ញាណ ១ ទិព្វសោតធាតុញ្ញាណ ១ បុព្វេនិវាសានុស្សតិញ្ញាណ ១ ចេតោបរិយញ្ញាណ ១ ទិព្វចក្ខុញ្ញាណ ១ អាសវក្ខយញ្ញាណ ១ ។

បទថា **សត្ត ខីណាសវពលានិ** កម្លាំងរបស់ព្រះខីណាស្រព ៧ ឈ្មោះថា **ខីណាសវ** ព្រោះមាន អាសវៈអស់ហើយ កម្លាំងរបស់ព្រះខីណាស្រព ឈ្មោះថា **ខីណាសវពល** ខីណាសវៈ ៧ ដូចម្ដេច ? ព្រះដ៏មានព្រះភាគត្រាស់ថា ៖-

> ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាព្រះខីណាស្រព ក្នុងធម្មវិន័យនេះ ឃើញល្អហើយនូវសង្ខារ ទាំងពួង ដោយសេចក្ដីមិនទៀង ដោយ បញ្ញាដ៏ប្រពៃតាមសេចក្ដីពិត ប្រការដែល ភិក្ខុជាព្រះខីណាស្រពឃើញល្អហើយ នូវសង្ខារ



> ទាំងពួងដោយភាពជារបស់មិនទៀង ដោយ បញ្ញាដ៏ប្រពៃតាមសេចក្ដីពិត នេះជាកម្លាំង របស់ព្រះខីណាស្រព , កម្លាំងដែលភិក្ខុជា ព្រះខីណាស្រពអាស្រ័យ រមែងដឹងនូវការអស់ ទៅនៃអាសវៈទាំងឡាយ ថាអាសវៈរបស់ យើងអស់ហើយ នេះជាប្រការទី ១ ។
>
> ម្នាលភិក្ខុទាំងឡាយ ប្រការដទៃទៀត មានទៀត ព្រះខីណាស្រពឃើញល្អហើយ នូវកាមទាំងឡាយ ប្រៀបដូចរណ្ដៅរងើក ភ្លើង ដោយបញ្ញាដ៏ប្រពៃតាមសេចក្ដីពិត ប្រការដែលភិក្ខុជាព្រះខីណាស្រពឃើញល្អហើយ នូវកាមទាំងឡាយ ប្រៀបដូចរណ្ដៅរងើក ភ្លើង ដោយបញ្ញាដ៏ប្រពៃតាមសេចក្ដីពិត នេះជាកម្លាំងរបស់ព្រះខីណាស្រព , កម្លាំង ដែលភិក្ខុជាព្រះខីណាស្រពអាស្រ័យ រមែង ដឹងការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈ

របស់យើងអស់ហើយ នេះជាប្រការទី ២ ។

ម្នាលភិក្ខុទាំងឡាយ ប្រការដទៃទៅមានទៀត ចិត្តរបស់ព្រះខីណាស្រពបង្អោនទៅក្នុងវិវេក ទោរទៅក្នុងវិវេក ឈមទៅក្នុងវិវេក តាំងនៅក្នុងវិវេក ត្រេកអរក្នុងនេក្ខម្មៈ រលាស់ផុតពីធម៌ជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ។ល។ សូម្បីនេះក៏ជាកម្លាំងរបស់ភិក្ខុជាព្រះខីណាស្រព ។ល។ នេះជាប្រការទី៣ ។

ម្នាលភិក្ខុទាំងឡាយ ប្រការដទៃទៅមានទៀតសតិប្បដ្ឋាន ៤ ដែលភិក្ខុជាព្រះខីណាស្រពអប់រំហើយ អប់រំល្អហើយ ។ល។ នេះជាប្រការទី ៤ ។ ឥន្ទ្រិយ ៥ ដែលភិក្ខុជាព្រះខីណាស្រពអប់រំហើយ អប់រំយ៉ាងល្អហើយ ។ល។ នេះជាប្រការទី ៥ ។ ពោជ្ឈង្គៈ ៧ ដែលភិក្ខុជាព្រះខីណាស្រពអប់រំហើយ



អប់រំល្អហើយ ។ល។ នេះជាប្រការទី ៦ ។ អរិយមគ្គមានអង្គ ៨ ដែលភិក្ខុជាព្រះខីណា-ស្រពអប់រំហើយ អប់រំល្អហើយ ។ល។ នេះជាប្រការ ទី ៧ ។

ក្នុងកម្លាំងទាំងនោះ លោកប្រកាសការចាក់ធ្លុះទុក្ខសច្ចៈដោយកម្លាំងទី ១ , ការចាក់ធ្លុះសមុទយសច្ចៈដោយកម្លាំងទី ២ , ការចាក់ធ្លុះនិរោធសច្ចៈដោយកម្លាំងទី ៣ , ការចាក់ធ្លុះមគ្គសច្ចៈដោយកម្លាំងទី ៤ ។

បទថា **អដ្ឋ វិមោក្ខា** វិមោក្ខ ៨ ឈ្មោះថា **វិមោក្ខ** ដោយអត្ថថា បង្អោនទៅក្នុងអារម្មណ៍ និងដោយអត្ថថា រួចផុតដោយល្អពីធម៌ជាសត្រូវ ។ វិមោក្ខ ៨ ដូចម្ដេច ? វិមោក្ខ ៨ គឺ ភិក្ខុមានរូបរមែងឃើញរូប នេះជាវិមោក្ខប្រការទី ១ ។ ភិក្ខុមានការសម្គាល់ក្នុងអរូបខាងក្នុង រមែងឃើញរូបខាងក្រៅ នេះជាវិមោក្ខប្រការ ទី ២ ។ ភិក្ខុបង្អោនចិត្តទៅថា នេះល្អ នេះជាវិមោក្ខប្រការ ទី ៣ ។ ភិក្ខុចូលដល់អាកាសានញ្ចាយតនៈថា **អនន្តោ អាកាសោ** អាកាសមិនមានទីបំផុត ព្រោះកន្លងរូបសញ្ញាដោយ

ប្រការទាំងពួង រំលត់បដិឃសញ្ញា ធ្វើទុកក្នុងចិត្តដល់នានត្តសញ្ញា នេះជាវិមោក្ខប្រការទី ៤ ។ ភិក្ខុចូលដល់វិញ្ញាណញ្ចាយតនៈថា **អនន្តំ វិញ្ញាណំ** វិញ្ញាណមិនមានទីបំផុត ព្រោះកន្លងអាកាសានញ្ចាយតនៈ ដោយប្រការទាំងពួង នេះជាវិមោក្ខប្រការទី ៥ ។ ភិក្ខុចូលអាកិញ្ចញ្ញាយតនៈថា **នត្ថិ កិញ្ចិ** អ្វី ៗ មិនមាន ព្រោះកន្លងវិញ្ញាណញ្ចាយតនៈ ដោយប្រការទាំងពួង នេះជាវិមោក្ខប្រការទី ៦ ។ ភិក្ខុចូលនេវសញ្ញានាសញ្ញាយតនៈ ព្រោះកន្លងអាកិញ្ចញ្ញាយតនៈ ដោយប្រការទាំងពួង នេះជាវិមោក្ខប្រការទី ៧ ។ ភិក្ខុចូលដល់សញ្ញាវេទយិតនិរោធ ព្រោះបានកន្លងនេវសញ្ញានាសញ្ញាយតនៈ ដោយប្រការទាំងពួង នេះជាវិមោក្ខប្រការទី ៨ ។

បទថា **នវ អនុបុព្វនិរោធា** អនុបុព្វនិរោធ ៩ គឺការរំលត់តាមលំដាប់ ៩ យ៉ាង ។ និរោធ ៩ យ៉ាងដូចម្តេច ? កាមសញ្ញារបស់អ្នកចូលបឋមជ្ឈាន រមែងរលត់ទៅ ១ , វិតក្កៈវិចារៈរបស់អ្នកចូលទុតិយជ្ឈាន រមែងរលត់ទៅ ១ , បីតិអ្នកចូលដល់តតិយជ្ឈាន រមែងរលត់ទៅ ១ , ខ្យល់អស្សាស-បស្សាសៈ



របស់អ្នកចូលដល់ចតុត្ថជ្ឈាន រមែងរលត់ទៅ ១ , រូបសញ្ញារបស់អ្នកចូលដល់អាកាសានញ្ចាយតនៈ រមែងរលត់ទៅ ១ , អាកាសានញ្ចាយតសញ្ញារបស់អ្នកចូលវិញ្ញាណញ្ចាយតនៈ រមែងរលត់ទៅ ១ , វិញ្ញាណញ្ចាយតនសញ្ញា របស់អ្នកចូលដល់អាកិញ្ចញ្ញាយតនៈ រមែងរលត់ទៅ ១ , អាកិញ្ចញ្ញាយតនសញ្ញារបស់អ្នកចូលដល់នេវសញ្ញានាសញ្ញាយតនៈ រមែងរលត់ទៅ ១ , សញ្ញា និងវេទនារបស់អ្នកចូលដល់សញ្ញាវេទយិតនិរោធ រមែងរលត់ទៅ ១ ។

បទថា **ទស អសេក្ខា ធម្មា** អសេក្ខធម៌ ១០ ឈ្មោះថា **អសេក្ខា** ព្រោះមិនមានវត្ថុដែលគួរសិក្សាតទៅ ។ ម្យ៉ាងទៀត ឈ្មោះថា **សេក្ខា** ព្រោះត្រូវនៅសិក្សាក្នុងត្រៃសិក្ខា , ឈ្មោះថា **អសេក្ខា** ព្រោះសេក្ខធម៌អស់ហើយ បានដល់ ព្រះអរហត្ត ។ ឈ្មោះថា **អសេក្ខា** ព្រោះធម៌ទាំងនេះជារបស់ព្រះអសេក្ខ ។ អសេក្ខធម៌ ១០ ដូចម្តេច ? អសេក្ខធម៌ ១០ គឺ សម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ សម្មាញាណៈ ១

សម្មាវិមុត្តិ ១ ដែលជារបស់ព្រះអសេក្ខៈ ។

បទថា **អសេក្ខំ សម្មាញាណំ** សម្មាញាណៈ ដែលជារបស់ព្រះអសេក្ខៈ បានដល់ លោកិយបញ្ញាដ៏សេស វៀរអរហត្ត-ផលបញ្ញា ។ បទថា សម្មាវិមុត្តិ បានដល់ អរហត្តផលវិមុត្តិ ។ លោកពោលទុកក្នុងអដ្ឋកថា ថា ៈ-

ធម៌ដែលសម្បយុត្តដោយផលសូម្បីទាំងអស់
មានសម្មាទិដ្ឋិ ជាដើមនោះឯង ជាអសេក្ខធម៌ ។
ម្យ៉ាងទៀត ក្នុងបទនេះ លោកពោលបញ្ញាក្នុង ឋានៈ
២ យ៉ាង គឺ **សម្មាទិដ្ឋិ សម្មាញាណ** សង្គ្រោះធម៌
ដែលជាផលសមាបត្តិ សល់ពីដែលលោកពោលទុក
ដោយបទនេះថា **សម្មាវិមុត្តិ** ។

ក្នុងបទមានជាអាទិ៍ថា **សព្វំ ភិក្ខវេ សច្ឆិកាតព្វំ** ម្នាលភិក្ខុទាំងឡាយ វត្ថុទាំងឡាយគួរធ្វើឲ្យជាក់ច្បាស់ គប្បីជ្រាបថា បានដល់ ការធ្វើឲ្យជាក់ច្បាស់ដោយអារម្មណ៍ ។ ក្នុងបទមានជាអាទិ៍ថា **រូបំ បស្សន្តោ សច្ឆិករោតិ** កាលណាឃើញរូប រមែងធ្វើឲ្យជាក់ច្បាស់ សេចក្តីថា ព្រះយោគាវចរកាលបើឃើញ



រូបជាដើម ដែលជាលោកិយៈដោយអាការដែលគួរឃើញ រមែងធ្វើឲ្យជាក់ច្បាស់នូវរូបជាដើមទាំងនោះ ដោយធ្វើឲ្យជាក់ច្បាស់ដោយអារម្មណ៍ , ឬកាលណាឃើញរូបជាដើម ដោយអាការដែលគួរឃើញ រមែងធ្វើឲ្យជាក់ច្បាស់នូវនិព្វាន ដែលគួរធ្វើឲ្យជាក់ច្បាស់ដោយហេតុនោះ ។ អ្នកគិតអក្ខរៈទាំងឡាយ ត្រូវការបទថា **បស្សន្តោ** ចុះក្នុងអត្ថនៃហេតុ ព្រះយោគាវចរកាលបើឃើញលោកុត្តរធម៌ មានអនញ្ញាតញ្ញស្សាមីតិន្ទ្រិយជាដើម ដោយការពិចារណា រមែងធ្វើឲ្យជាក់ច្បាស់នូវលោកុត្តរធម៌នោះ ដោយអារម្មណ៍ ។ បទនេះថា ព្រះយោគាវចរ រមែងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានដែលឈានចុះកាន់អមតៈ ដោយអត្ថថា ឈានចុះធ្វើឲ្យត្រង់តែម្យ៉ាង ព្រោះធ្វើឲ្យជាក់ច្បាស់ក្នុង **បរិញ្ញេយ្យ** ទុក្ខគួរកំណត់ដឹង , **បហាតព្វ** សមុទ័យគួរលះ **សច្ឆិកាតព្វ** និរោធគួរធ្វើឲ្យជាក់ច្បាស់ , **ភាវេតព្វ** មគ្គគួរចម្រើន ។

បទថា **យេ យេ ធម្មា សច្ឆិកតា ហោន្តិ , តេ តេ ធម្មា ផុសិតា ហោន្តិ** ធម៌ណា ៗ ជាធម៌ដែលធ្វើឲ្យជាក់ច្បាស់ហើយ , ធម៌នោះ ៗ រមែងជាធម៌ដែលត្រឹមត្រូវហើយ បានដល់ ធម៌ដែល

ធ្វើឲ្យជាក់ច្បាស់ហើយ ដោយការធ្វើឲ្យជាក់ច្បាស់ដោយអារម្មណ៍ រមែងជាធម៌ត្រឹមត្រូវហើយ ដោយសភាពត្រឹមត្រូវនៃអារម្មណ៍ , ធម៌ដែលធ្វើឲ្យជាក់ច្បាស់ហើយ ដោយការធ្វើឲ្យជាក់ច្បាស់នូវការបានចំពោះ រមែងជាធម៌ដែលត្រឹមត្រូវហើយ ដោយសេចក្ដីត្រឹមត្រូវក្នុងការបានចំពោះ ដោយប្រការដូច្នេះ ។

**ចប់ អដ្ឋកថាសច្ឆិកាតព្វនិទ្ទេស**

p [ q



# អ ដ្ឋ ក ថា

## ហានភាគិយចតុក្កនិទ្ទេស

ឥឡូវនេះ ព្រោះសភាពនៃធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្ដីវិនាស រមែងមានដោយប្រភេទសូន្យចាកសមាធិមួយ ៗ , ដូច្នោះ ព្រះសារីបុត្ត ទើបបានសម្ដែងហានភាគិយចតុក្កៈ ដោយសភាពតែមួយដូចគ្នា។

ក្នុងបទទាំងនោះ បទថា **បឋមស្ស ឈានស្ស លាភី** គឺរបស់ព្រះយោគាវចរអ្នកបាននូវបឋមជ្ឈាន ។ បទថា **លាភី** ជាទុតិយាវិភត្តិ ចុះក្នុងអត្ថឆដ្ឋីវិភត្តិ ។ **លាភោ** លោកពោលថា **លាភី** ព្រោះអត្ថថា មានការធ្វើឲ្យដឹង ។

ស័ព្ទថា **សហគត** ក្នុងបទថា **កាមសហគត** នេះ លោកបំណងយកសេចក្ដីថា អារម្មណ៍ , អធិប្បាយថា មានវត្ថុកាមនិងកិលេសកាមជាអារម្មណ៍ ។

បទថា **សញ្ញាមនសិការា** សញ្ញា និងមនសិការ បានដល់

ជវនសញ្ញា និងមនសិការ ដោយការនឹកគិតដល់សញ្ញានោះ ។ មនសិការសម្បយុត្តដោយញាណក៏គួរ ។ បទថា **សមុទាចរន្តិ** រមែងប្រាកដ គឺ រមែងប្រព្រឹត្តទៅ ។

បទថា **ធម្មោ** បានដល់ **ធម្ម** គឺ បឋមជ្ឈាន ។ ព្រះយោគាវចរ កាលវិនាសចាកឈាន ឈ្មោះថា វិនាសដោយហេតុ ៣ ប្រការ គឺដោយកិលេសកម្រើក ១ ដោយអសប្បាយកិរិយា ១ ដោយការមិនប្រកបសេចក្តីព្យាយាម ១ ។ កាលវិនាសដោយកិលេសកម្រើក ឈ្មោះថា វិនាសរហ័ស ។ កាលបើវិនាសដោយអសប្បាយកិរិយា ដោយអំណាចការប្រកបសេចក្តីត្រេកអរក្នុងការងារ ភាពជាអ្នកត្រេកអរក្នុងការនិយាយផ្តេស-ផ្តាស ភាពជាអ្នកត្រេកអរក្នុងការដេក ភាពជាអ្នកត្រេកអរក្នុងការស្និទ្ធស្នាល ឈ្មោះថា វិនាសយឺត , កាលបើមិនចូលដល់រឿយ ៗ ដោយ **បលិពោធ** ការកង្វល់ មានជំងឺ និងវិបត្តិដោយបច្ច័យជាដើម សូម្បីកាលវិនាសដោយការមិនប្រកបការព្យាយាម ក៏ឈ្មោះថា វិនាសយឺត ។ តែក្នុងនិទ្ទេសនេះ ព្រះសារីបុត្ត កាលបើនឹងសម្តែងហេតុដ៏មានកម្លាំងប៉ុណ្ណោះ ទើបពោលដល់កិលេស



កម្រើកតែម្យ៉ាង ។

ក៏កាលព្រះយោគាវចរវិនាសចាកទុតិយជ្ឈានជាដើម ឈ្មោះថា **វិនាស** សូម្បីពេញចិត្តក្នុងឈានថ្នាក់ទាប ៗ រមែងកម្រើក ។ សួរថា វិនាសដោយហេតុប្រមាណប៉ុន្មាន ? ឆ្លើយថា វិនាសដោយហេតុយ៉ាងណា ដែលមិនអាចនឹងចូលដល់បាន ។

បទថា **តទនុធម្មតា** ការពេញចិត្តនូវធម៌ដែលសមគួរដល់បឋមជ្ឈាននោះ គឺ ធម៌ដែលប្រព្រឹត្តទៅសមគួរ ឈ្មោះថា **អនុធម្មោ** ។ បទនេះ ជាឈ្មោះរបស់ធម៌ គឺ ការពេញចិត្តដែលប្រព្រឹត្តទៅ ព្រោះធ្វើឈានឲ្យក្រៃលែងឡើង ។ ធម៌ដ៏សមគួរនោះឯង ឈ្មោះថា **អនុធម្មតា** ។ សភាពនៃធម៌ដែលសមគួរដល់ឈាននោះ ឈ្មោះថា **តទនុធម្មតា** ។

បទថា **សតិ** គឺពេញចិត្ត ។ បទថា **សន្តិដ្ឋតិ** គឺ តាំងនៅ ។ លោកអធិប្បាយថា ការពេញចិត្តដែលប្រព្រឹត្តទៅតាមបឋមជ្ឈាននោះ នៅប្រព្រឹត្តទៅ ។

បទថា **អវិតក្កសហគតា** មិនសហគតដោយវិតក្ក បានដល់មានទុតិយជ្ឈានជាអារម្មណ៍ ។ បទនេះ លោកពោលថា **អវិតក្កំ**

ព្រោះទុតិយជ្ឈានមិនមានវិតក្កៈ ។

បទថា **និព្វិទាសហគត** សហគតៈដោយនិព្វិទា បានដល់មានវិបស្សនាជាអារម្មណ៍ ។ វិបស្សនានោះ លោកពោលថា **និព្វិទា** ព្រោះនឿយណាយក្នុងសង្ខារទាំងឡាយ , សមដូចដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា **និព្វិន្ទំ វិរជ្ជតិ** កាលបើនឿយណាយ រមែងប្រាសចាកតម្រេក ។

បទថា **វិរាគូបសញ្ហិតា** ប្រកបដោយ **វិរាគ** បានដល់វិបស្សនាប្រកបដោយអរិយមគ្គ ។ វិបស្សនានោះ ដល់កំពូលហើយ ឲ្យសម្រេចការតាំងឡើងរបស់មគ្គ ។ ព្រោះដូច្នោះ សញ្ញានិងមនសិការ មានវិបស្សនាជាអារម្មណ៍ លោកទើបពោលថា **វិរាគូបសញ្ហិតា** ប្រកបដោយវិរាគៈ , សមដូចដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា **វិរាគា វិមុច្ចតិ** ព្រោះប្រាសចាកតម្រេក ចិត្តរមែងរួចផុត ។

បទថា **វិតក្កសហគតា** សហគតៈដោយវិតក្កៈ បានដល់មានបឋមជ្ឈានជាអារម្មណ៍ ដោយអំណាចវិតក្កៈ ។

បទថា **ឧបេក្ខាសុខសហគតា** សហគតៈដោយឧបេក្ខា



និងសុខ បានដល់ មានតតិយជ្ឈានជាអារម្មណ៍ ដោយអំណាចឧបេក្ខា គឺ ជាកណ្តាលនៃឈាននោះ និងដោយសុខវេទនា ។

បទថា **បីតិសុខសហគតា** សហគតដោយបីតិ និងសុខ បានដល់ មានទុតិយជ្ឈានជាអារម្មណ៍ ដោយអំណាចបីតិ និងសុខវេទនា ។

បទថា **អទុក្ខមសុខសហគតា** សហគតៈដោយអទុក្ខមសុខ បានដល់ មានចតុត្ថជ្ឈានជាអារម្មណ៍ ដោយអំណាចឧបេក្ខាវេទនា ។ វេទនានោះមិនមែនទុក្ខ មិនមែនសុខ ព្រោះហេតុនោះលោកទើបពោលថា **អទុក្ខមសុខវេទនា** ។ **ម** អក្សរ ក្នុងបទនេះ លោកពោលដោយបទសន្ធិ ។

បទថា **រូបសហគតា** សហគតៈដោយរូប បានដល់ សូម្បីកាលណាមានធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្តីវិនាស ធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃការតាំងនៅ និងធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃការលាយដោយកិលេស របស់ព្រះយោគាវចរតាំងនៅក្នុង នេវ-សញ្ញានាសញ្ញាយតនៈ ព្រោះមានរូបជ្ឈានជាអារម្មណ៍ លោកក៏មិនបានចង្អុលបង្ហាញដល់នេវសញ្ញានាសញ្ញាយតនៈ ព្រោះមិនមាន

ធម៌ប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្ដីវិសេស ។ លោកពោលថា សមាធិដែលជាលោកិយៈនេះ សូម្បីទាំងអស់ប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្ដីវិនាស ដល់ព្រះយោគីអ្នកមានឥន្ទ្រិយទន់ខ្សោយ មានប្រក្រតីនៅដោយសេចក្ដីប្រមាទ , ប្រព្រឹត្តទៅក្នុងចំណែកនៃការតាំងនៅមានដល់ព្រះយោគីដែលមានឥន្ទ្រិយទន់ខ្សោយ មានប្រក្រតីនៅដោយសេចក្ដីមិនប្រមាទ , ប្រព្រឹត្តទៅក្នុងចំណែកនៃសេចក្ដីពិសេសដល់ព្រះយោគីអ្នកមានឥន្ទ្រិយចាស់ក្លា ដែលជាតណ្ហាចរិត , ប្រព្រឹត្តទៅក្នុងចំណែកការជ្រៀតចូលនៃកិលេស ដល់ព្រះយោគីអ្នកមានឥន្ទ្រិយចាស់ក្លា ជាទិដ្ឋិចរិត ។

**ចប់អដ្ឋកថាហានភាគិយចតុកនិទ្ទេស**

p [ q



## អ ដ្ឋ ក ថា

## លក្ខណត្តិកនិទ្ទេស

ឥឡូវនេះ ព្រោះលោកិយធម៌សូម្បីមួយ ៗ ត្រូវកម្មាត់ដោយត្រៃលក្ខណ៍ , ដូច្នោះ លោកទើបចង្អុលបង្ហាញដល់ត្រៃ-លក្ខណ៍ដែលមានលក្ខណៈតែមួយដូចគ្នា ។

ក្នុងបទទាំងនោះ បទថា **អនិច្ចំ ខយដ្ឋេន** រូបមិនទៀង ព្រោះអត្ថថា **អស់ទៅ** គឺ រូប ឈ្មោះថា មិនទៀង ព្រោះការអស់ទៅក្នុងលក្ខណៈនោះ ៗ ។ អាចារ្យពួកខ្លះពោលថា ឈ្មោះថា **មិនទៀង** ព្រោះមានសេចក្ដីអស់ទៅ វិនាសទៅ អស់នូវសេចក្ដីត្រេកអរ រលត់ទៅជាធម្មតា ។

បទថា **ទុក្ខំ ភយដ្ឋេន** ជាទុក្ខ ព្រោះអត្ថថា គួរខ្លាច គឺ ឈ្មោះថា **ទុក្ខ** ព្រោះមានភ័យចំពោះមុខ ។ ព្រោះវត្ថុណាជាទុក្ខ វត្ថុនោះមិនទៀង រមែងនាំមកនូវសភាពគួរខ្លាច ដូចសេចក្ដីទុក្ខរបស់ពួកទេពក្នុងសីហោបមសូត្រ ដូច្នោះ ។ អាចារ្យពួកខ្លះពោលថា ឈ្មោះថា **ទុក្ខំ** ដោយអត្ថថា ជាតិ ជរា ព្យាធិ និង

មរណៈ ជាវត្ថុគួរខ្លាច ។

បទថា **អនត្តា អសារកដ្ឋេន** ជាអនត្តា ព្រោះអត្ថថា រកខ្លឹមសារមិនបាន គឺ ឈ្មោះថា **អនត្តា** ព្រោះមិនមានខ្លឹមសារក្នុងខ្លួន ដែលកំណត់ទុកយ៉ាងនេះថា **តួខ្លួន** អ្នកអាស្រ័យនៅ អ្នកធ្វើ អ្នកប្រាជ្ញ អ្នកមានអំណាចដោយខ្លួនឯង ព្រោះថា វត្ថុណាមិនទៀង ជាទុក្ខ , វត្ថុនោះ មិនអាចតាំងនៅភាពមិនទៀងសូម្បីរបស់ខ្លួន ឬការកើត ការវិនាស និងមិនអាចរារាំងទុកបាន , នឹងរកភាពជាអ្នកធ្វើជាដើមរបស់ខ្លួននោះ បានអំពីណា ។ សមដូចព្រះមានព្រះភាគត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ប្រសិនបើរូបនេះជាតួខ្លួនមែននោះ , រូបនេះ នឹងមិនគប្បីប្រព្រឹត្តទៅ ដើម្បីអាពាធឡើយ ។ អាចារ្យពួកខ្លះពោលថា ឈ្មោះថា **អនត្តា** ព្រោះមិនមានខ្លឹមសារក្នុងខ្លួន មិនមានខ្លឹមសារជានិច្ច ។

**ចប់អដ្ឋកថា លក្ខណត្តិកនិទ្ទេស**

p [ q



## អ ដ្ឋ ក ថា

## ទុក្ខសច្ចនិទ្ទេស

ព្រះសារីបុត្ត បានចង្អុលបង្ហាញថា សូម្បីចតុកអរិយសច្ច ដោយការប្រព្រឹត្តទៅជាមួយគ្នា ព្រោះសច្ចៈទាំងឡាយទាក់ទង ជាមួយគ្នាដោយអត្ថថា ជារបស់ពិតប្រាកដ ។

ក្នុងបទទាំងនេះ បទថា **តត្ថ តត្ថ** បានដល់ អរិយសច្ច ៤ ទាំងនោះ ។ បទថា **កតមំ** បានដល់ កថេតុកម្យតាបុច្ឆា សួរបំណងនឹងឆ្លើយខ្លួនឯង ។

បទថា **ទុក្ខំ អរិយសច្ចំ** ទុក្ខអរិយសច្ច បានដល់ ជាការសម្តែងធម៌ដែលសួរហើយ ។

ក្នុងបទមានជាអាទិ៍ថា **ជាតិបិ ទុក្ខា** នោះ លោកប្រកាសអត្ថនៃ **ជាតិ** ស័ព្ទ ទុកយ៉ាងច្រើន ។ ដូចដែលលោកពោលទុកថា ៈ-

ភព ត្រកូល ពួក សីល បញ្ញត្តិ លក្ខណៈ

ប្រសូតិ បដិសន្ធិ លោកប្រកាសអត្ថនៃ **ជាតិ**

ទុកដោយប្រការដូច្នេះ ។



ពិតដូច្នោះ **ជាតិ** ស័ព្ទ ដែលមានអត្ថថា **ភព** ក្នុងបទមានជាអាទិ៍ថា **ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ** ភពសូម្បីមួយ សូម្បីពីរ ។

មានអត្ថថា **ត្រកូល** ក្នុងបទនេះថា **អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន** មិនទម្លាក់កំហុសដាក់អ្នកដទៃ មិនជេរដល់ត្រកូល ។

មានអត្ថថា **ពួក** ក្នុងបទមានជាអាទិ៍ថា **អត្ថិ វិសាខេ និគណ្ឋា នាម សមណជាតិ** ម្នាលវិសាខា ពួកសមណៈនិគ្រន្ថនៅមាន ។

មានអត្ថថា **អរិយសីល** ក្នុងបទមានជាអាទិ៍ថា **យតោហំ ភគិនិ អរិយាយ ជាតិយា ជាតោ នាភិជានាមិ** ម្នាលប្អូនស្រី តាំងតែពីយើងកើតក្នុងអរិយជាតិហើយ នឹងបានដឹងខ្លួនថា បន្ទំសម្លាប់សត្វឲ្យស្លាប់មិនមាន ។

មានអត្ថថា **បញ្ញត្តិ** ក្នុងបទមានជាអាទិ៍ថា **តិរិយា នាម តិណជាតិ នាភិយា ឧគ្គន្ត្វា នភំ អាហច្ច ឋិតា អហោសិ** ស្បូវដុះឡើងចេញពីនាភី ស្ទុះឡើងទៅរហូតដល់ផ្ទៃមេឃ ។

មានអត្ថថា **សន្ធិតលក្ខណ** ក្នុងបទនេះថា **ជាតិ ទ្វីហិ**



**ខន្ធេហិ សង្គហិតា** ជាតិ លោកសង្គ្រោះដោយខន្ធ ២ ។

មានអត្ថថា **បសូតិ** ក្នុងបទនេះថា **សម្បតិជាតោ អានន្ទ ពោធិសត្តោ** ម្នាលអានន្ទ ពោធិសត្វកើតមួយរំពេច ។

មានអត្ថថា **បដិសន្ធិ** ដោយបរិយាយក្នុងបទនេះថា **ភវបច្ចយា ជាតិ** ព្រោះភពជា បច្ច័យ ទើបមានជាតិ ។ បទថា **ជាតិបិ ទុក្ខា** សូម្បីជាតិ ក៏ជាទុក្ខ ។ តែដោយនិប្បរិយាយ ( ដោយត្រង់ ) បានដល់ ការប្រាកដគ្រាដំបូងរបស់ខន្ធទាំងឡាយ ដែលប្រាកដដល់សត្វ អ្នកកើតក្នុងភពនោះ ៗ ។

ប្រសិនបើសួរថា ព្រោះហេតុអ្វី ជាតិនេះទើបជាទុក្ខ ? ឆ្លើយថា ព្រោះជាតិជាទីតាំងរបស់ទុក្ខយ៉ាងច្រើន ។ ទុក្ខមិនតិច គឺ ទុក្ខទុក្ខ វិបរិណាមទុក្ខ សង្ខារទុក្ខ បដិច្ឆន្នទុក្ខ អប្បដិច្ឆន្នទុក្ខ បរិយាយទុក្ខ និប្បរិយាយទុក្ខ ។ ក្នុងទុក្ខទាំងនេះ ទុក្ខផ្លូវកាយ និងទុក្ខផ្លូវចិត្ត លោកពោលថា **ទុក្ខទុក្ខ** ព្រោះជាទុក្ខដោយសភាពវេទនា និងដោយឈ្មោះ ។

***សុខវេទនា*** ឈ្មោះថា ***វិបរិណាមទុក្ខ*** ព្រោះហេតុកើតទុក្ខដោយការប្រែប្រួល ។



***ឧបេក្ខាវេទនា*** និងសង្ខារប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេស ឈ្មោះថា ***សង្ខារទុក្ខ*** ព្រោះត្រូវបៀតបៀន ដោយការកើត និងការរលត់ ។

អាពាធផ្លូវកាយ ផ្លូវចិត្ត មានឈឺត្រចៀក ឈឺធ្មេញ ភាពក្តៅក្រហាយចិត្តកើតព្រោះរាគៈ កើតព្រោះទោសៈជាដើម ឈ្មោះថា ***បដិច្ឆន្នទុក្ខ*** សេចក្តីទុក្ខដែលបិទបាំង ព្រោះសួរទើបដឹង និងព្រោះការឈឺចាប់មិនប្រាកដ ។

អាពាធដែលមានសមុដ្ឋានពីទោស ៣២ ជាដើម ឈ្មោះថា ***អប្បដិច្ឆន្នទុក្ខ*** ទុក្ខមិនបិទបាំង ព្រោះមិនត្រូវសួរ ក៏ដឹងបាន និងព្រោះមានការឈឺចាប់ប្រាកដ ។

សព្វទុក្ខទាំងអស់មានជាតិជាដើម មកក្នុងសច្ចវិភង្គ វៀរ ***ទុក្ខទុក្ខ*** ក្រៅអំពីនោះ ឈ្មោះថា ***បរិយាយទុក្ខ*** ( ទុក្ខដោយអម ) ព្រោះជាទីតាំងនៃទុក្ខទុក្ខនោះ ៗ ។ ចំណែកទុក្ខទុក្ខ លោកពោលថាជានិប្បរិយាយទុក្ខ ( ទុក្ខដោយត្រង់ ) ។

ក្នុងបទនោះ ***ជាតិ*** ជាអបាយិកទុក្ខ សូម្បីព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកាសដោយឧបមាក្នុងពាលបណ្ឌិតសូត្រជាដើម ។



ម្យ៉ាងទៀត ជាតិជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ដែលជាប្រភេទមានទុក្ខជាមូល មកពីការធ្លាក់ចុះកាន់គភ៌ជាដើម ដែលកើតក្នុងមនុស្សលោក សូម្បីក្នុងសុគតិភព ។ ក្នុងបទនេះ ជាតិនេះជាទុក្ខដែលជាប្រភេទ មានទុក្ខជាមូល ពីការចុះកាន់គភ៌ជាដើម ។ ពិតហើយ សត្វដែលកើតក្នុងគភ៌មាតា មិនបានកើតក្នុងផ្កាឧប្បល ផ្កាឈូកធំ និងផ្កាឈូកសជាដើម ។ តាមពិត សត្វដែលកើតក្នុងផ្ទៃគួរខ្ពើមក្រៃលែង ប្រៀបដូចធ្វើដំណើរទៅក្នុងព្រៃធំ ដែលមានក្លិនស្អុយច្រើន ផ្សាយដោយក្លិនសាកសព គ្រប់បែបយ៉ាង ទាំងងងឹតឈឹង ទាំងចង្អៀតចង្អល់ក្រៃលែងក្នុងកណ្តាលផ្ទៃពោះ ឆ្អឹងខ្នងខាងក្រោមក្រពះអាហារខាងលើពោះ ដូចជាដង្កូវកើតក្នុងត្រីស្អុយ ជូរផ្អូម និងច្របល់ដោយគ្រឿងស្អុយជាដើម ។ សត្វនោះកើតក្នុងពោះមាតា ក្តៅធំនៅក្នុងពោះមាតា ១០ ខែ វៀរចាកការពត់ខ្លួន ការសណ្តូកជាដើម ញាត់នៅដូចអាហារច្រកក្នុងថង់ ដូចដុំម្សៅត្រូវនៅស្ងៀម រមែងសោយទុក្ខក្រៃលែង ។ នេះឈ្មោះថា ទុក្ខ

ជាមូល ធ្លាក់ចុះមកកាន់គតិ ។ សត្វនោះ ក្នុងខណៈដែលមាតាក្វាត់ជួល ដើរ អង្គុយ ក្រោក ប្តូរឥរិយាបថជាដើម យ៉ាងប្រញាប់



ប្រញាល់ រមែងសោយទុក្ខធ្ងន់ ព្រោះការឈឺចាប់ មានការកញ្ឆក់អូសទាញទម្លាក់ រំលៀកទៅរំលៀកមកជាដើម ដូចកូនជៀមធ្លាក់ទៅក្នុងដៃពួកអ្នកផឹកស្រា និងដូចកូនពស់ ធ្លាក់នៅក្នុងដៃរបស់អាលម្ពាយ ។ សត្វ រមែងសោយទុក្ខធ្ងន់ ក្នុងវេលាមាតាផឹកទឹកត្រជាក់ប្រាកដ ដូចកើតក្នុងនរកត្រជាក់ ក្នុងវេលាមាតាលេបអាហារ ប្រាកដដូចរងើកភ្លើងធ្លាក់ចុះមក ក្នុងវេលាមាតាលេបរបស់ប្រៃ របស់ជូរជាដើម ប្រាកដដូចបានទទួលទោស ដូចការចាក់ដោយលំពែងដ៏មុតជាដើម , នេះជាទុក្ខមានមូល មកពីការបរិហារគតិ ។

មួយទៀត សត្វ រមែងសោយទុក្ខដោយការវះកាត់ជាដើម របស់មាតាអ្នកមានគតិ ធ្លាក់ទៅក្នុងទីកើតរបស់ទុក្ខដែលមិនគួរសូម្បីមិត្រអាមាត្យ និងមិត្រជិតស្និទ្ធជាដើម មិនគួរមើល , នេះឈ្មោះថា ទុក្ខមានមូល មកពីសេចក្តីវិនាសរបស់គតិ ។

ទុក្ខរមែងកើតដល់សត្វអ្នកត្រូវខ្យល់កម្មជ្ជវាត របស់មាតាដែលមុនប្រសូតិ បក់បង្វិលត្រឡប់រកផ្លូវប្រសូតិ គួរឲ្យខ្លាចក្រៃ-លែង ដូចធ្លាក់ទៅក្នុងជ្រោះជ្រៅ ដូចដំរីត្រូវទាញចេញពីរន្ធដើម



គ្នោត ព្រោះរន្ធតូចចង្អៀតក្រៃលែង និងដូចសត្វនរកត្រូវភ្នំ ក្នុងសង្ឃាតនរកកិនកម្ទេច , នេះទុក្ខមានមូល មកពីការប្រសូតិ ។

ទុក្ខដូចនឹងចាក់ដោយចុងម្ជុល និងច្រៀកដោយកាំបិតកោររមែងកើតដល់សត្វអ្នកដែលកើតហើយ មានរាងកាយតូចខ្ចី ដូចជាដំបៅថ្មី ៗ ក្នុងវេលាចាប់ដៃ ងូតទឹក លាងមុខ ជូតដោយសំពត់តូចជាដើម , នេះទុក្ខមានមូល ដែលប្រសូតចេញពីផ្ទៃម្តាយ ។

ក្នុងការប្រព្រឹត្តទៅក្រៅពីនេះ ទុក្ខរមែងមានដល់អ្នកបំផ្លាញខ្លួនដោយខ្លួនឯង អ្នកប្រកបដោយការព្យាយាម ដោយការធ្វើបាបខ្លួន ធ្វើខ្លួនឲ្យក្តៅក្រហាយដោយអចេលកវត្តជាដើម អ្នកមិនបរិភោគ និងការច្របាច់កដោយការក្រោធ , នេះជាទុក្ខមានមូលពីការព្យាយាមរបស់ខ្លួន , ដែលក្រៅពីនេះទៅ ទុក្ខរមែងកើតមានដល់អ្នកសោយកម្ម មានការសម្លាប់ និងការចាប់ចងជាដើម , នេះទុក្ខ មានការព្យាយាមពីអ្នកដទៃ ។

**ជាតិ** នេះ ជាទីតាំងរបស់ទុក្ខ សូម្បីទាំងអស់ ដោយ
ប្រការដូច្នេះ ។ ដោយហេតុនោះ លោកទើបពោលទុកថា ៖-
ប្រសិនបើសត្វមិនគប្បីកើតក្នុងនរកទាំង



ឡាយដែរ គេក៏នឹងមិនត្រូវបានទទួលកម្ម
មានត្រូវភ្លើងឆេះជាដើម ក្នុងជាតិនោះ ,
សត្វគប្បីបានទុក្ខជាទីពឹងក្នុងទីណា ព្រះ
មុនីក្នុងធម្មវិន័យនេះ ពោល **ជាតិ** ថា
ជាទុក្ខ ដោយប្រការដូច្នេះ ។

ទុក្ខក្នុងជំពូកតិរច្ឆានមានមិនតិច មាន
ការវាយដោយរំពាត់ គ្នោង ដំបងជាដើម ,
វៀរជាតិចេញ , ទុក្ខគប្បីមានក្នុងសត្វនោះ
បានយ៉ាងណា សូម្បីព្រោះហេតុនោះ **ជាតិ**
ទើបឈ្មោះថា ជាទុក្ខក្នុងពួកសត្វនោះ ។

ទុក្ខក្នុងប្រេតទាំងឡាយ កើតព្រោះ
សេចក្តីស្រេកឃ្លាន និងមានទុក្ខ ប្រភេទ
ផ្សេង ៗ មានកើតពីខ្យល់ និងកម្តៅថ្ងៃជា

ដើម , ព្រោះទុក្ខក្នុងទីនោះ រមែងមានដល់
សត្វដែលបានកើតហើយ ដូច្នោះ ព្រះមុនី
ទើបត្រាស់ **ជាតិ** ថាជាទុក្ខ ។



ទុក្ខក្នុងពពួកអសុរក្នុងលោកន្តរនរក
ងងឹតឈឹង ត្រជាក់ក្រៃលែង, ព្រោះការកើត
ក្នុងនរកនោះ មិនមានទុក្ខ ក៏មានមិនបាន
ព្រោះដូច្នោះ ព្រះមុនីទើបត្រាស់ថា ទុក្ខ
ទាំងឡាយមាន ព្រោះ**ជាតិ** ។

សត្វកាលនៅក្នុងគភ៌មាតា ក៏ដូច
នៅក្នុងគូថនរក កាលនៅយូរក្តី ចេញទៅ
ខាងក្រៅក្តី សត្វរមែងដល់ទុក្ខ វៀរជាតិ
ចេញហើយ សូម្បីទុក្ខដ៏ខ្លាំងក្រៃលែង ក៏
មិនមាន ព្រោះ **ជាតិ** នេះមាន ទើបជា
ទុក្ខ ដោយប្រការដូច្នេះ ។

សេចក្តីពិត ទុក្ខនេះមាននៅក្នុង
លោកនេះ សត្វ ៗ កាល ប្រយោជន៍អ្វី

ដែលនឹងត្រូវនិយាយច្រើន ទៅក្នុងកាល
ណាៗ មិនមែនឬ , ទុក្ខវៀរតែជាតិចេញ
ហើយ ក៏មានមិនបាន ព្រោះព្រះដ៏មាន-



ព្រះភាគជាម្ចាស់ អ្នកស្វែងរកគុណដ៏ធំ
ទ្រង់ត្រាស់ដល់ **ជាតិ** នេះ ថាជាទុក្ខមុន
ទុក្ខដទៃទាំងអស់ ដូច្នេះ ។

ក្នុងបទថា **ជរាបិ ទុក្ខា** សូម្បីជរា ក៏ជាទុក្ខ មានអធិប្បាយដូចតទៅនេះ ជរាមាន ២ យ៉ាង គឺ លក្ខណៈរបស់សង្ខតៈ និងសភាពចាស់នៃខន្ធ ដែលទាក់ទងក្នុងភពមួយ ក្នុងសន្តតិដែលបានដឹងថា មានធ្មេញបាក់ជាដើម ។ ក្នុងទីនេះ លោកបំណងយកជរានោះ ។ ជរានោះឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ និងព្រោះជាទីតាំងនៃទុក្ខ ។ ទុក្ខផ្លូវកាយផ្លូវចិត្តកើតឡើង មានបច្ច័យជាច្រើនមានជាអាទិ៍ថា ភាពនៃកំលោះក្រមុំវិនាសទៅ កម្លាំងចុះថយ សតិបញ្ញាទ្រុឌទ្រោម ត្រូវអ្នកដទៃមើលងាយ ព្រោះអវយវៈតូចធំចុះខ្សោយ ឥន្ទ្រិយវិកលវិការ , **ជរា** ទើបជាទីតាំងនៃទុក្ខនោះ , ដូចដែលលោកពោលទុកថា ៖-

ព្រោះអវយវៈចុះខ្សោយ ឥន្ទ្រិយពិការ
ភាពជាកំលោះក្រមុំវិនាស កម្លាំងក៏ចុះថយ ។
សតិជាដើមទ្រុឌទ្រោម, ខ្វះការយកចិត្តទុកដាក់



ពីកូនប្រពន្ធរបស់ខ្លួន ដល់នូវសភាពទន់ជ្រាយ
ច្រើនឡើង ។ សត្វបានទទួលទុក្ខផ្លូវកាយផ្លូវចិត្ត
ទាំងអស់នោះ ព្រោះជរាជាហេតុ ដូច្នោះ លោក
ទើបពោលថា **ជរា** ជាទុក្ខ ។

សូម្បីកាលបើលោកគួរពោល ព្យាធិទុក្ខក្នុងលំដាប់ជរាទុក្ខ គប្បីជ្រាបថា លោកមិនពោល ព្រោះព្យាធិទុក្ខ លោកកាន់យកដោយកាយិកទុក្ខនោះឯង ។

ក្នុងបទថា **មរណម្បិ ទុក្ខំ** សូម្បីសេចក្តីស្លាប់ ក៏ជាទុក្ខ សេចក្តីស្លាប់ មាន ២ យ៉ាង គឺ សេចក្តីស្លាប់ដែលលោកពោលសំដៅដល់លក្ខណៈរបស់សង្ខតៈថា ជរាមរណៈលោកសង្គ្រោះដោយខន្ធ ២ , និងលោកពោលសំដៅដល់ការដាច់ជីវិតិន្ទ្រិយ៍ដែលទាក់ទងគ្នាក្នុងភពមួយថា សេចក្តីភ័យខ្លាចពីការស្លាប់ជានិច្ច ក្នុងទីនេះ លោកបំណងយកសេចក្តីស្លាប់នោះ ។ ឈ្មោះនៃ

សេចក្តីស្លាប់នោះ គឺ **ជាតិប្បច្ចយមរណ** សេចក្តីស្លាប់ ព្រោះជាតិជាបច្ច័យ , **ឧបក្កមមរណ** សេចក្តីស្លាប់ ព្រោះសេចក្តីព្យាយាម , **សរសមរណ** ស្លាប់ព្រោះអស់អាយុ និងកម្ម , **អាយុក្ខយមរណ**



សេចក្តីស្លាប់ព្រោះអស់អាយុ , **បុញ្ញក្ខយមរណ** សេចក្តីស្លាប់ព្រោះអស់បុណ្យ ។ គប្បីជ្រាបប្រភេទរបស់សេចក្តីស្លាប់ ក្នុងទីនេះទៀត គឺ **ខណិកមរណ** សេចក្តីស្លាប់ដោយជួរខណៈ , **សម្មតិមរណ** សេចក្តីស្លាប់ដោយសម្មតិ , **សមុច្ឆេទមរណ** សេចក្តីស្លាប់ពិតប្រាកដ ។ ប្រភេទរបស់រូបធម៌ និងអរូបធម៌ ក្នុងការប្រែប្រួល ឈ្មោះថា **ខណិកមរណ** ។

បទនេះថា **តិស្សោ មតោ , បុស្សោ មតោ** នាយតិស្សៈស្លាប់ហើយ នាយបុស្សៈស្លាប់ហើយ ឈ្មោះថា **សម្មតិមរណ** ព្រោះមិនមានសត្វដោយបរមត្ថ ។

បទនេះថា **សស្សំ មតំ , រុក្ខោ មតោ** សន្ទូងងាប់ហើយ ដើមឈើងាប់ហើយ ឈ្មោះថា **សម្មតិមរណ** ព្រោះមិនមានជីវិតិន្ទ្រិយ៍ ។

កាលកិរិយា ដែលមិនមានបដិសន្ធិ របស់ព្រះខីណាស្រព ឈ្មោះថា **សមុច្ឆេទមរណ** ។ សម្មតិមរណៈ និងសមុច្ឆេទមរណៈ ក្រៅពីនេះ វៀរសម្មតិមរណៈខាងក្រៅ លោកសង្គ្រោះដោយការដាច់ ការដាច់ត តាមដែលពោលហើយ ។ មរណៈ ឈ្មោះថា ទុក្ខ



ព្រោះជាទីតាំងនៃទុក្ខ ។ ដោយហេតុនោះ លោកទើបពោលថា ៈ-

វត្ថុជាទីស្រលាញ់របស់មនុស្សអាក្រក់ ដែល
ឃើញនិមិត្ត មានបាបកម្មជាដើម អ្នកជួបប្រសព្វនឹង
វត្ថុជាទីស្រឡាញ់ត្រូវព្រាត់ប្រាសទៅ , ទុក្ខផ្លូវចិត្ត
របស់អ្នកជិតស្លាប់ដោយមិនខុសប្លែកគ្នា ទុក្ខក្នុងសរីរៈ
មានរោគខ្យល់ដែលកាត់សន្ធាក់ និងផ្តាច់សរសៃជា
ដើម រមែងមានដល់សត្វទាំងពួងអ្នកត្រូវចាក់ទម្លុះ
កន្លែងសំខាន់របស់រាងកាយ រមែងជាទុក្ខកើតអំពី
សរីរៈ ។

សេចក្តីស្លាប់នេះ ជារបស់ដែលអត់ទ្រាំ
មិនបាន មិនមានការប្តូរជំនួស ជាទីតាំងរបស់
ទុក្ខ , ព្រោះហេតុនោះ លោកទើបពោលថា

សេចក្តីស្លាប់នេះ ជាទុក្ខពិតប្រាកដ ។

ចិត្តក្រហល់ក្រហាយ មានការសម្ងឹងខាងក្នុងជាលក្ខណៈរបស់អ្នកដែលត្រូវសេចក្តីវិនាសញាតិជាដើមមកប៉ះខ្ទប់ ឈ្មោះថា សេចក្តីសោក ក្នុងបទថា **សោក** ជាដើម ។ សេចក្តីសោក



ឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ចាកទុក្ខទុក្ខ ។ ដោយហេតុនោះទើបពោលថា :-

សេចក្តីសោក រមែងចាក់ទម្លុះដួងចិត្ត
របស់សត្វទាំងឡាយ ដូចមុតកូនសរដែលលាប
ដោយថ្នាំពិស និងរមែងដុតពេលយ៉ាងខ្លាំង ឬ
ដូចត្រូវប្រហារដោយស្នដែក ដែលដុតភ្លើងដ៏
ក្តៅ ។

សេចក្តីសោក រមែងនាំមកនូវព្យាធិ
ជរាមរណៈ និងការទម្លាយ សូម្បីទុក្ខច្រើនយ៉ាង
ព្រោះដូច្នោះ លោកទើបពោលថា សេចក្តី
សោកជាទុក្ខ ។

ការត្អូញត្អែររបស់អ្នកត្រូវសេចក្តីវិនាស ចាកញាតិជាដើមមកពាល់ត្រូវ ឈ្មោះថា បរិទេវៈ ។ បរិទេវៈ ឈ្មោះថា ជាទុក្ខ ព្រោះភាពជាសង្ខារទុក្ខ និងព្រោះជាទីតាំងនៃទុក្ខ ។ ដោយហេតុនោះ លោកទើបពោលថា :-

សត្វត្រូវកូនសរ គឺ សេចក្តីសោក កំពុង



ស្រែកយំរៀបរាប់ ក បបូរមាត់ ក្រអូមមាត់ ថ្ងាស
ស្ងួត ជាពេគស្គមស្ងួត រមែងបានទទួលទុក្ខយ៉ាង
សែនធ្ងន់ធ្ងរ ដោយហេតុនោះ ព្រះមានព្រះភាគ
ជាម្ចាស់ទើបត្រាស់ **បរិទេវ** ថាជាទុក្ខ ។

**ទុក្ខ** ឈ្មោះថាជាទុក្ខ បានដល់ ទុក្ខផ្លូវកាយ មានលក្ខណៈបៀតបៀនផ្លូវចិត្ត , មួយទៀត ឈ្មោះថា ទុក្ខ ជាទុក្ខ ព្រោះជាទុក្ខក្នុងទុក្ខ និងព្រោះនាំមកនូវទុក្ខមាននៅក្នុងចិត្ត ដោយហេតុនោះ លោកទើបពោលទុកថា :-

ទុក្ខនេះ រមែងបៀតបៀនកាយ និងឲ្យ
ចិត្តកើតទុក្ខខ្លាំងឡើង ព្រោះដូច្នោះ លោក
ទើបពោលដោយវិសេសថា **ទុក្ខំ** ។

**ទោមនស្ស** ជាទុក្ខ បានដល់ ទុក្ខផ្លូវចិត្ត មានលក្ខណៈបៀតបៀនផ្លូវចិត្ត ។ មួយទៀត ទោមនស្ស ឈ្មោះថា ជាទុក្ខ ព្រោះជាទុក្ខទុក្ខ និងព្រោះនាំមកនូវទុក្ខផ្លូវកាយ ។ ពិតហើយ សត្វទាំងឡាយដែលបានទទួលទុក្ខផ្លូវចិត្តច្រើន រមែងសោយទុក្ខដ៏ច្រើន ដូចជារំសាយសក់ទួញយំត្អូញត្អែរ , គក់ទ្រូងយំ ននៀល



ខ្លួនទៅមក ហក់លោត រាវរកសស្ត្រា ផឹកថ្នាំពុល ចងក លោតចូលភ្លើង , ដូចដែលលោកពោលទុកថា ៖-

> ព្រោះចិត្តបានទទួលការបៀតបៀន
> ក៏នាំសេចក្តីបៀតបៀនដល់រាងកាយទៀត
> ផង , ដូច្នោះលោកទើបពោលថា **ទោ-**
> **មនស្ស** ថាជាទុក្ខ ព្រោះការខូចចិត្ត ។

**ឧបាយាស** ជាទុក្ខ បានដល់ ទោសៈធ្វើឲ្យកើតទុក្ខផ្លូវចិត្តក្រៃលែងរបស់អ្នកត្រូវព្រាត់ប្រាសពីញាតិជាដើម មកប៉ះពាល់ ។ អាចារ្យពួកខ្លះពោលថា ធម៌មួយប្រការ ដែលរាប់បញ្ចូលដោយសង្ខារក្ខន្ធ ។ ឧបាយាសៈ ឈ្មោះថា ជាទុក្ខ ព្រោះជាសង្ខារទុក្ខ ព្រោះដុតរោលចិត្ត ព្រោះការលំបាកផ្លូវកាយ ។ ដូចដែលលោកពោលទុកថា ៖-

> ឧបាយាសៈជាទុក្ខ ព្រោះការដុតរោល
> ផ្លូវចិត្ត និងព្រោះការលំបាកផ្លូវកាយដ៏ក្រៃ-
> លែង រមែងញុំាងទុក្ខឲ្យកើត ព្រោះដូច្នោះ
> លោកទើបពោលថា **ឧបាយាស ជាទុក្ខ** ។



មួយទៀត ក្នុងបទថា សោកៈ បរិទេវៈ និងឧបាយាសៈ គប្បីឃើញថា សោកៈ ដូចទឹកបាយដែលភ្លើងខ្សោយ ទឹកបាយក្តៅនៅតែក្នុងភាជនៈ , គប្បីឃើញបរិទេវៈ ដូចទឹកបាយដែលត្រូវភ្លើងខ្លាំង ទឹកបាយក៏ផុលចេញក្រៅភាជនៈ , គប្បីឃើញឧបាយាសៈ ដូចទឹកបាយដែលជាចំណែកសល់ពីការហូរចេញ មិនគ្រប់គ្រាន់ដែលនឹងផុលចេញបាន ទឹកបាយដែលដាំ ក៏នឹងហួតអស់ទៅ មិនមានសេសសល់ក្នុងភាជនៈនោះឯង ។

ការនៅរួមជាមួយសត្វ និងសង្ខារ ដែលមិនជាទីស្រឡាញ់ ឈ្មោះថា **អប្បិយសម្បយោគទុក្ខ** ។ អប្បិយសម្បយោគទុក្ខ

ឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ។ សមដូចដែលលោក
ពោលទុកថា ៈ-

ទុក្ខគ្រាដំបូង រមែងកើតក្នុងចិត្ត
ព្រោះជួបប្រសព្វសត្វ និងសង្ខារមិនជា
ទីស្រឡាញ់ ឬទុក្ខដែលកើតព្រោះត្រូវ
ទទួលទោស រមែងមានក្នុងកាយនេះ ។
សូម្បីទុក្ខទាំងពីរនេះដោយវត្ថុ ក៏ជាការ



នៅរួមគ្នាជាមួយសត្វ និងសង្ខារដែល
មិនជាទីស្រឡាញ់ ជាការដឹងគ្រប់គ្នាថា
ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់ស្វែង
រកនូវគុណដ៏ធំត្រាស់ថា ការនៅរួមគ្នា
ជាមួយសត្វ និងសង្ខារ ថាជាទុក្ខ ។

ការព្រាត់ប្រាសចាកសត្វ និងសង្ខារ ដែលជាទីស្រឡាញ់ ឈ្មោះថា **បិយវិប្បយោគទុក្ខ** ។ បិយវិប្បយោគទុក្ខ ឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ។ សមដូចដែលលោកពោលទុកថា ៈ-

បុគ្គលពាលទាំងឡាយ ប្រកបព្រម
ដោយសរ គឺសេចក្តីសោក ព្រោះការព្រាត់
ប្រាសចាកញាតិ និងសម្បត្តិ រមែងឈឺ
ចាប់បេះដូង **វិប្បយោគទុក្ខ** នេះ បាន
ដឹងហើយថា ជាទុក្ខ ។

ក្នុងការមិនបានសមតាមសេចក្តីប្រាថ្នា គប្បីជ្រាបសេចក្តីដូចតទៅនេះ ការប្រាថ្នាក្នុងវត្ថុដែលមិនគួរបាន លោកពោលថា **យម្បិច្ឆំ ន លភតិ តម្បិ ទុក្ខំ** ការមិនបានសមតាមសេចក្តីប្រាថ្នា



ក៏ជាទុក្ខ ។ អធិប្បាយថា កាលប្រាថ្នាក្នុងវត្ថុដែលមិនគួរបាន ដោយធម៌ ក៏មិនបាន , សេចក្តីប្រាថ្នានោះក៏ជាទុក្ខ ។ ការមិនបានសមតាមសេចក្តីប្រាថ្នា ឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃទុក្ខ ។ សមដូចដែលលោកពោលទុកថា ៈ-

ទុក្ខកើតពីការពិឃាត រមែងកើត
ដល់សត្វទាំងឡាយក្នុងលោកនេះ ដោយ
មិនបានវត្ថុនោះ ៗ តាមប្រាថ្នា ។ ព្រោះ
សេចក្តីប្រាថ្នា ក្នុងវត្ថុដែលមិនគួរបាន
ដែលជាហេតុនៃទុក្ខនោះ , ដូច្នោះព្រះ-

ជិនស្រីជាម្ចាស់ ទើបបានត្រាស់ដល់ការ
មិនបានសមតាមប្រាថ្នា ថាជាទុក្ខ ។

ក្នុងបទថា **សង្ខិត្តេន បញ្ចុបាទានក្ខន្ធា** ដោយសង្ខេប ឧបាទានក្ខន្ធ ៥ ជាទុក្ខ មានអធិប្បាយដូចតទៅនេះ បទថា **សង្ខិត្តេន** លោកពោលដោយន័យទេសនា ។ ព្រោះមិនអាចនឹងសង្ខេបទុក្ខបានថា ទុក្ខមានប្រមាណប៉ុណ្ណេះរយ ទុក្ខមានប្រមាណប៉ុណ្ណេះពាន់ , តែទេសនាអាចសង្ខេបបាន ។ ដូច្នេះ ព្រះដ៏មានព្រះភាគជាម្ចាស់



កាលទ្រង់នឹងត្រាស់យ៉ាងនេះថា **ឈ្មោះថា ទុក្ខមិនមានអ្វីដទៃ , ដោយសង្ខេបឧបាទានក្ខន្ធ ៥ ជាទុក្ខ** ។

បទថា **បញ្ច** ជាការកំណត់ចំនួន ។ បទថា **ឧបាទានក្ខន្ធា** បានដល់ ខន្ធដែលជាអារម្មណ៍របស់ឧបាទាន ។

ព្រះមានព្រះភាគជាម្ចាស់ដែល
ត្រាស់ដល់ទុក្ខ មានជាតិជាដែនកើត
មិនត្រាស់ដល់ទុក្ខទាំងអស់ ទុក្ខក្រៅ
ពីនេះ ក៏នៅមាន ។
ព្រោះដូច្នោះព្រះមានព្រះភាគ
ជាម្ចាស់ជាអ្នកស្វែងរកគុណដ៏ធំ ទ្រង់
សម្តែងទីបំផុតរបស់ទុក្ខថា ដោយ
សង្ខេបឧបាទានក្ខន្ធទាំងនេះជាទុក្ខ ។

ជាការពិតយ៉ាងនោះ ជាតិជាដើម បៀតបៀនឧបាទានក្ខន្ធ ដោយប្រការផ្សេង ៗ ដូចភ្លើងកម្ចាត់ឧស , ដូចគ្រឿងប្រហារកម្ចាត់ទីដៅ , ដូចរបោម និងមូសជាដើម ខាំគោ , ដូចអ្នកកាត់ស្មៅបំផ្លាញដី , ដូចចោរប្លន់អ្នកស្រុក បំផ្លាញអ្នកស្រុកដូច្នោះ



រមែងកើតក្នុងឧបាទានក្ខន្ធនោះឯង ដូចស្មៅ និងវល្លិ៍ កើតលើផែនដី , ដូចផ្កាឈើ ផ្លែឈើ និងស្លឹកឈើខ្ចី កើតនឹងដើមឈើ ។

**ជាតិ** ជាទុក្ខក្នុងខាងដើមរបស់ឧបាទានក្ខន្ធ ។

**ជរា** ជាទុក្ខក្នុងចំណែកកណ្តាល ។

**មរណៈ** ជាទុក្ខក្នុងទីបំផុត ។

**សោកៈ** ជាទុក្ខ ត្រូវដុតបំផ្លាញដោយទុក្ខស្មើរតែនឹងស្លាប់ ព្រោះសោកៈបៀតបៀន ។

**បរិទេវៈ** ជាទុក្ខដោយការរៀបរាប់ ព្រោះអត់ទ្រាំនូវទុក្ខនោះមិនបាន ។

**ទុក្ខ** ជាទុក្ខ ដោយការឈឺចាប់ផ្លូវកាយ ព្រោះប្រសព្វនឹងសម្ផស្សដែលមិនជាទីប្រាថ្នា ពោលគឺ ធាតុកម្រើក ។

**ទោមនស្ស** ជាទុក្ខ ដោយការរុកគួនផ្លូវចិត្ត ព្រោះកើតបដិឃ: សេចក្តីទាស់ចិត្ត ក្នុងទោមនស្សរបស់បុថុជ្ជនអ្នកត្រូវទោមនស្សនោះបៀតបៀន ។

**ឧបាយាស:** ជាទុក្ខ ដោយការក្រៀមក្រំចិត្តរបស់អ្នកមានសេចក្តីចុះខ្សោយ ព្រោះសេចក្តីសោកជាដើមច្រើនក្រៃពេក ។



ការមិនបានតាមសេចក្តីប្រាថ្នាជាទុក្ខ ព្រោះបំផ្លាញសេចក្តីប្រាថ្នារបស់អ្នកដែលអស់សេចក្តីសង្ឃឹម , ឧបាទានក្ខន្ធដែលត្រូវកំណត់ដោយប្រការផ្សេង ៗ ដោយប្រការដូច្នេះ ឈ្មោះថា **ទុក្ខ** ព្រោះដូច្នោះ ដើម្បីសម្តែងទុក្ខនោះមួយបែប ៗ នាំមកពោល តែមិនអាចនឹងពោលឲ្យសព្វគ្រប់បាន ច្រើនកប្ប , ដើម្បីសម្តែងសង្ខេបទុក្ខទាំងអស់ទុកក្នុងឧបាទានក្ខន្ធ ៥ ជាចំណែកខ្វះ ដូចរសទឹកក្នុងមហាសមុទ្រ ក៏បំព្រួញចុះក្នុងតំណក់ទឹកតែមួយ ព្រះថេរៈទើបបានពោលនូវព្រះពុទ្ធវចនៈ ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ទុកថា ដោយសង្ខេបឧបាទានក្ខន្ធ ៥ ជាទុក្ខ ដោយប្រការដូច្នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទភាជនីយ៍ មានជាអាទិ៍ថា **តត្ថ កតមា ជាតិ** ។

បទថា **តត្ថ** គឺ កាលណាជាតិជាដើម ដែលព្រះដ៏មាន-ព្រះភាគជាម្ចាស់ត្រាស់ទុកហើយក្នុងទុក្ខសច្ចនិទ្ទេស ។

បទថា **យា តេសំ តេសំ សត្តានំ** គឺ សម្តែងដល់សត្វដ៏ច្រើនទូទៅដោយសង្ខេប ។ កាលបើពោលយ៉ាងនេះរាល់



ថ្ងៃថា ជាតិរបស់ទេវទត្ត , ជាតិរបស់សោមទត្ត សត្វទាំងឡាយរមែងមិនកំណត់កាន់យក , ការសម្តែងសេចក្តីដទៃទៀតទាំងអស់ក៏រមែងមិនសម្រេច , តែដោយបទពីរបទនេះ សត្វណា ៗ ក៏មិនកំណត់កាន់យក , ការសម្តែងសេចក្តីដទៃទៀតយ៉ាងណា រមែងមិនសម្រេចក៏មិនបាន ។

បទថា **តម្ហិ តម្ហិ** គឺ ការសម្តែងដល់ពពួកសត្វដ៏ច្រើនទូទៅដោយគតិ និងជាតិ ។

បទថា **សត្តនិកាយេ** ក្នុងពួកសត្វទាំងឡាយ គឺ ក្នុងជំនុំសត្វ ក្នុងទីប្រជុំសត្វ ។

បទថា **ជាតិ** គឺ ការកើត ។ បទនេះក្នុងទីនេះ ជាបឋមា-វិភត្តិចុះក្នុងអត្ថសភាវៈ ប្រែថា ការកើត ។

បទថា **សញ្ជាតិ** គឺ ការកើតព្រម ។ បទនេះ បន្ថែមឧបសគ្គចុះទៅ ប្រែថា ការកើតព្រម ។

បទថា **ឱក្កន្តិ** គឺ ការឈានចុះ ។ ម្យ៉ាងទៀត ឈ្មោះថា **ជាតិ** ដោយអត្ថថា ការកើត , លោកពោលថា **ជាតិ** នោះ ដោយអាយតនៈនៅមិនទាន់បរិបូរណ៍ ។ ឈ្មោះថា **សញ្ជាតិ** ដោយអត្ថ



ថា កើតព្រម , លោកពោលថា **សញ្ជាតិ** នោះ ដោយអាយតនៈបរិបូរណ៍ហើយ ។ ឈ្មោះថា **ឱក្កន្តិ** ដោយអត្ថថា ឈានចុះ , លោកពោលថា **ឱក្កន្តិ** នោះ ដោយអំណាចរបស់ **អណ្ឌជ** កើតក្នុងពង និង **ជលាពុជ** កើតក្នុងគភ៌ ។ ព្រោះថា សត្វទាំងនោះឈានចុះកាន់សំបុកពង និងថង់ស្បូន ។ សត្វឈានចុះ រមែងកាន់បដិសន្ធិ ដូចចូលទៅ , ឈ្មោះថា **អភិនិព្វត្តិ** ដោយអត្ថថា ការបង្កើត , លោកពោល **អភិនិព្វត្តិ** នោះ ដោយអំណាចនៃ

**សំសេទជ** កើតពីក្អែល និង **ឱបបាតិក** កើតព្រមឡើង ព្រោះសត្វទាំងនោះជាអ្នកប្រាកដកើតឡើង , នេះជា **សម្មុតិកថា** ពោលដោយសម្មុតិប៉ុណ្ណោះ ។

ឥឡូវនេះនឹងពោលដោយបរមត្ថថា **ខន្ធានំ បាតុភាវោ អាយតនានំ បដិលាភោ** ការប្រាកដនៃខន្ធទាំងឡាយ ការត្រឡប់បានអាយតនៈ ព្រោះដោយបរមត្ថ ខន្ធនោះឯងប្រាកដ មិនមែនសត្វប្រាកដ ។ មួយទៀត ក្នុងបទថា **ខន្ធានំ** នេះ គប្បីជ្រាបការកាន់យកសូម្បីខន្ធ ៥ ក្នុងភពនៃខន្ធ ៥ , ខន្ធ ១ ក្នុងភពនៃខន្ធ ១ , ខន្ធ ៤ ក្នុងភពនៃខន្ធ ៤ ។ បទថា **បាតុភាវោ**



ការប្រាកដ បានដល់ ការកើតឡើង ។ បទថា **អាយតនានំ** គប្បីជ្រាបថា លោកសង្គ្រោះសត្វដោយអំណាចអាយតនៈ ដែលកើតឡើងក្នុងភពនោះ ៗ ។

បទថា **បដិលាភោ** ការបានចំពោះ បានដល់ ការប្រាកដព្រោះសន្តតិនោះឯង ។ ព្រោះថា អាយតនៈទាំងនោះប្រាកដ ដែលឈ្មោះថា បានចំពោះហើយ ។

បទថា **អយំ វុច្ចតិ ជាតិ** នេះ គឺ លោកពោលថា **ជាតិ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងជរានិទ្ទេសដូចតទៅនេះ បទថា **ជរា** ជាបឋមាវិភត្តិចុះក្នុងអត្ថសភាវៈ ប្រែថា ការចាស់ ។ បទថា **ជីរណតា** ជាអាការនិទ្ទេស ប្រែថា ទ្រុឌទ្រោម ។

បីបទ មានបទថា **ខណ្ឌិច្ចំ** ភាពជាអ្នកមានធ្មេញបាក់ ជាដើម , ជាកិច្ចនិទ្ទេស សម្តែងកិច្ចដែលប្រាកដក្នុងខណៈ កន្លងកាល កន្លងវ័យ , ពីរបទក្រោយ ជាបកតិនិទ្ទេស សម្តែងភាពជាប្រក្រតី ។

ពិតហើយ សេចក្តីនេះ លោកសម្តែងដោយសភាវៈដោយបទថា **ជរា** ។ ព្រោះហេតុនោះ បទថា **ខណ្ឌិច្ចំ** នេះ ទើបជា



បឋមាវិភត្តិ ចុះក្នុងអត្ថនៃសភាវៈរបស់ជរានោះ ។

ដោយបទថា **ជីរណតា** ការទ្រុឌទ្រោមនេះ លោកសម្តែងដោយអាការ , ព្រោះហេតុនោះ បទនេះ ទើបជាអាការនិទ្ទេសរបស់ជរានោះ ។

ដោយបទថា **ខណ្ឌិច្ចំ** នេះ លោកសម្តែងដោយកិច្ច គឺការដែលធ្មេញ និងក្រចកបាក់ ក្នុងពេលកន្លងកាលកន្លងវ័យទៅ ។

ដោយបទថា **បាលិច្ចំ** សភាពអ្នកមានសក់ស្កូវ នេះ លោកសម្តែងដោយកិច្ច គឺ សភាពសក់ និងរោមទាំងឡាយស្កូវ ។

ដោយបទថា **វលិត្តចតា** ភាពជាអ្នកមានស្បែកជ្រីវជ្រួញ នេះលោកសម្តែងដោយអាការ គឺ ភាពដែលសាច់ស្ងួត និងស្បែកជ្រីវជ្រួញ , ព្រោះហេតុនោះ ៣ បទ របស់ជរានោះ ទើបជាកិច្ចនិទ្ទេស ក្នុងខណៈកាលកន្លងហួសទៅ ។ ដោយបទទាំង ៣ នោះ លោកសម្តែងដល់ជរាប្រាកដ ឃើញបានច្បាស់ ដោយសម្តែងភាពខុសប្រក្រតីទាំងនេះ ។ ផ្លូវទៅរបស់ជរាប្រាកដ ក្នុងធ្មេញជាដើម ដោយភាពជាអ្នកមានធ្មេញបាក់ជាដើម សូម្បីបិទភ្នែកក៏ដឹងបាន , ម្យ៉ាងទៀត ជរា មានភាពជាអ្នកមានធ្មេញបាក់



ជាដើម ដឹងមិនបាន , ព្រោះជរានឹងគប្បីដឹងដោយភ្នែក មិនបាន ។ ដូចផ្លូវទៅរបស់ទឹក ខ្យល់ ភ្លើង រមែងប្រាកដ ព្រោះស្មៅ និងដើមឈើជាដើម មានគល់បាក់ ឬត្រូវភ្លើងឆេះ ម្យ៉ាងទៀត ផ្លូវទៅនោះមិនប្រាកដ ទឹកជាដើមប៉ុណ្ណោះប្រាកដ ។

ដោយបទទាំងនេះថា **អាយុនោ សំហានិ ឥន្ទ្រិយានំ បរិបាកោ** ការវិនាសអាយុ ការចាស់នៃឥន្ទ្រិយទាំងឡាយ គឺ

លោកសម្ដែងតាមប្រក្រតី ពោលគឺ ការអស់ទៅនៃអាយុ ព្រោះអាយុវិនាសហើយ ៗ ក្នុងកាលកន្លងទៅ និងការចាស់នៃឥន្ទ្រិយមានជាតិជាដើម , ព្រោះហេតុនោះ គប្បីជ្រាបថា បទទាំងពីរនេះជាបកតិនិទ្ទេស ។

ក្នុងបទទាំងពីរនោះ ព្រោះអាយុរបស់អ្នកដល់ជរា រមែងវិនាស ដូច្នោះ លោកទើបពោលនូវជរា ដោយផលូបចារន័យ ដោយន័យបង្ហាញផលថា **អាយុនោ សំហានិ** ការវិនាសនៃអាយុ ដូច្នេះ ។ មួយទៀត ក្នុងវេលាជាក្មេងកំលោះ ឥន្ទ្រិយ មានចក្ខុជាដើម ភ្លឺថ្លាល្អ អាចនឹងទទួលវិស័យរបស់ខ្លួន សូម្បីល្អិតសុខុមបានដោយងាយ លុះដល់ជរា ក៏ទុំដោរ ស្រអាប់ ស្រវាំង



មិនអាចនឹងទទួលវិស័យរបស់ខ្លួនបាន , ដូច្នោះ លោកទើបពោលដោយបង្ហាញផលថា **ឥន្ទ្រិយានំ បរិបាកោ** ការចាស់នៃឥន្ទ្រិយទាំងឡាយ ។ លោកពន្យល់ជរាទុកយ៉ាងនេះ សូម្បីជរា ក៏មាន ២ យ៉ាង គឺ ប្រាកដ ១ បិទបាំង ១ ។

ក្នុងជរាទាំងនោះ ជរាក្នុងរូបធម៌មានធ្មេញជាដើម ជាជរាប្រាកដ ព្រោះសម្ដែងភាពជាអ្នកមានធ្មេញបាក់ជាដើម , ចំណែកជរាក្នុងអរូបធម៌ ឈ្មោះថា ជរាបិទបាំង ព្រោះមិនសម្ដែងការខុសប្រក្រតី ដូច្នោះ ។

ក្នុងជរាប្រាកដនោះ សភាពដែលមានធ្មេញបាក់ជាដើម រមែងប្រាកដជាប្រភេទរបស់ធ្មេញជាដើមដូច្នោះឯង ។ បុគ្គល ឃើញធ្មេញបាក់ជាដើមនោះ ដោយភ្នែកហើយ គិតដោយមនោទ្វារថា ធ្មេញទាំងនេះត្រូវជរាបំផ្លាញហើយ ទើបដឹងថា ជរា ដូចឃើញគោជាដើម ដែលគេចងទុកក្នុងកន្លែងមានទឹក ហើយដឹងថា ខាងក្រោមមានទឹក ។ នៅមានជរាផ្សេង ២ យ៉ាងទៀត គឺ **សវីចិជរា** ជរាដឹងបានងាយ ១ , **អវីចិជរា** ជរាដឹងបានលំបាក ១ ។

ក្នុងជរា ២ យ៉ាងនោះ ជរា ឈ្មោះថា **អវីចិជរា** ព្រោះ



ដឹងការខុសគ្នានៃប្រភេទក្នុងចន្លោះ ៗ មានកែវមណី មាស ប្រាក់ កែវប្រពាឡ ព្រះច័ន្ទ ព្រះអាទិត្យជាដើម បានដោយលំបាក ដូចដឹងសត្វមានជីវិតក្នុងជំពូក **មន្ទទសក** វ័យក្មេង ១០ ខួបជាដើម បានដោយលំបាក , និងដូចដឹងក្នុងវត្ថុដែលមិនមានជីវិត ក្នុងជំពូកផ្កាឈើ ផ្លែឈើ និងស្លឹកឈើជាដើម បានដោយលំបាក ដូច្នោះ ។ អធិប្បាយថា បានដល់ **និរន្តរជរា** ជរាជាប់បន្តគ្នាទៅ ។

កាលបើពោលដោយប្រការដទៃពីនោះ ជរា ឈ្មោះថា **សវីចិជរា** ព្រោះដឹងការខុសគ្នាដោយប្រភេទជាដើម ក្នុងចន្លោះ ៗ បានដោយងាយ ។

ក្នុងជរា ២ យ៉ាងនោះ **សវីចិជរា** គប្បីជ្រាបយ៉ាងនេះ ដោយអំណាចនៃឧបាទិន្នកៈ និងអនុបាទិន្នកៈ ធ្មេញទឹកដោះ រមែងដុះដល់ក្មេងតូចជាគ្រាដំបូង តែធ្មេញទឹកដោះទាំងនោះ មិនមាំទាំ ។ កាលណាធ្មេញទឹកដោះបាក់អស់ទៅ ធ្មេញថ្មីក៏ដុះឡើងទៀត ធ្មេញទាំងនោះ ដំបូងមានពណ៌ស , កាលបើត្រូវខ្យល់ជរាប៉ះពាល់ក៏ប្រែទៅជាពណ៌ខ្មៅ ។ សក់គ្រាដំបូងមានពណ៌ក្រហម , តពីនោះក៏ជាពណ៌ខ្មៅ ក្រោយមកក៏ជាពណ៌ស ។ សម្បុរក៏មានពណ៌



ក្រហមព្រឿង ៗ ។ កាលណាចម្រើនឡើង ៗ ចំណែកនៃពណ៌សក៏ផូរផង់ , ចំណែកពណ៌ខ្មៅ ក៏ប្រាកដជាពណ៌ខ្មៅ , កាលណាត្រូវខ្យល់ជរាប៉ះខ្ចប់ ក៏មានស្នាមជ្រួញ ។ សំណាបក្នុងពេលរាស់ក៏មានពណ៌ស ក្រោយមកមានពណ៌ខៀវ , កាលណាត្រូវខ្យល់ជរាប៉ះខ្ចប់ហើយ ក៏ជាពណ៌លឿង ។ គួរសម្ដែងដល់ដំណាំស្វាយខ្ចះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **មរណនិទ្ទេស** ដូចតទៅនេះ បទថា **ចុតិ** លោកពោលដោយអំណាចការឃ្លាតទៅ ។ បទនេះ ជាពាក្យពោលដល់ភាពស្មើគ្នារបស់ខន្ធ ១ ខន្ធ ៤ និងខន្ធ ៥ ។

បទថា **ចវនតា** ការឃ្លាតទៅ ជាបទបង្ហាញដល់លក្ខណៈដែលពោលដោយភាវៈ ។

បទថា **ភេទោ** ការបែកធ្លាយ ជាបទសម្ដែងដល់ការកើតការរលត់របស់ **ចុតិខន្ធ** ។

បទថា **អន្តរធានំ** ការវិនាសទៅ ជាបទសម្ដែងដល់ការមិនមានឋានៈ ដោយបរិយាយយ៉ាងណា ៗ របស់ចុតិខន្ធដែលបែកធ្លាយហើយ ដូចឆ្នាំងដែលបែក ។

បទថា **មច្ចុ មរណំ** បានដល់ សេចក្ដីស្លាប់ ពោលគឺ



សេចក្ដីស្លាប់ ដែលមិនមែនស្លាប់ក្នុងជួរខណៈ ។ មច្ចុដែលធ្វើនូវទីបំផុត ឈ្មោះថា **កាល** , ការធ្វើកាលនោះ ឈ្មោះថា **កាលកិរិយា** ។ ដោយហេតុត្រឹមនេះ លោកសម្ដែងដល់សេចក្ដីស្លាប់ដោយសម្មតិ ។

ឥឡូវនេះ ដើម្បីសម្តែងដោយបរមត្ថ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់ថា **ខន្ធានំ ភេទោ** ការបែកធ្លាយនៃខន្ធ ៗ ពិតហើយ ដោយបរមត្ថ ខន្ធប៉ុណ្ណោះបែកធ្លាយ សត្វណា ៗ មិនស្លាប់ ។ កាលខន្ធបែកធ្លាយ សត្វក៏ស្លាប់ ទើបមានពាក្យពោលថា កាលណាខន្ធបែកធ្លាយ សត្វស្លាប់ហើយ ។ ក្នុងបទនេះ គប្បីជ្រាបការបែកធ្លាយនៃខន្ធ ដោយអំណាចរបស់ខន្ធ ៤ និងខន្ធ ៥ គប្បីជ្រាបការបោះបង់សាកសព ដោយអំណាចរបស់ខន្ធ ១ , គប្បីជ្រាបការបែកធ្លាយនៃខន្ធ ដោយអំណាចរបស់ ខន្ធ ៤ គប្បីជ្រាបការបោះបង់សាកសព ដោយអំណាចខន្ធ ២ ដែលសល់ ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះសាកសព គឺ រូបកាយនៅមានសូម្បីក្នុងភព ២ ។ ម្យ៉ាងទៀត ព្រោះខន្ធសូម្បីក្នុងជាន់ចាតុម្មហារាជិកា ក៏នឹងបែកធ្លាយបាន , រមែងមិនបន្សល់អ្វី ៗ ទុក ,



ដូច្នោះ ការបែកធ្លាយនៃខន្ធ ដោយអំណាចនៃខន្ធទាំងនោះ ទើបមានការលះបង់សាកសពទុក ក្នុងមនុស្សជាដើម ។ មួយទៀត ក្នុងបទនេះ លោកពោលដល់ មរណៈព្រោះធ្វើការលះបង់សាក-សពថា **កឡេវរស្ស និក្ខេបោ** ការលះបង់សាកសព ។

ដោយបទនេះថា **ជីវិតិន្ទ្រិយស្សុបច្ឆេទោ** ការដាច់នៃជីវិតិន្ទ្រិយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់សម្តែងថា ឈ្មោះថាមរណៈ រមែងមានដល់អ្នកនៅមានឥន្ទ្រិយជាប់តគ្នាប៉ុណ្ណោះ , រមែងមិនមានដល់អ្នកដែលមិនមានឥន្ទ្រិយជាប់តគ្នា ។ ចំណែកបទថា **សស្សំ មតំ , រុក្ខោ មតោ** សំណាបងាប់ ដើមឈើងាប់ត្រឹមតែជាវោហារប៉ុណ្ណោះ ។ តែដោយអត្ថ ពាក្យដូចពោលមកនេះ សម្តែងដល់ការអស់ទៅ និងការវិនាសទៅរបស់សំណាប ជាដើមប៉ុណ្ណោះ ។

ម្យ៉ាងទៀត ជាតិ ជរា មរណៈ ទាំងនេះត្រាច់ស្វែងរកចន្លោះរបស់សត្វទាំងឡាយ ដូចបច្ចាមិត្រអ្នកមានបំណងអាក្រក់ដូច្នោះ ។ ដូចជាបច្ចាមិត្រ ៣ នាក់ ស្វែងរកឱកាសរបស់បុរស ។ បច្ចាមិត្រម្នាក់ពោលថា យើងនឹងពោលពណ៌នា គុណរបស់ព្រៃ



ឯណោះ ហើយក៏នាំបុរសនោះទៅកាន់ព្រៃនោះ , យើងនឹងមិនប្រទូសរ៉ាយក្នុងបុរសនោះឡើយ ។ បច្ចាមិត្រទី ២ ពោលថា ក្នុងវេលាដែលអ្នកនាំបុរសនេះទៅ , យើងនឹងចាប់បោក ធ្វើឲ្យអស់កម្លាំង , យើងមិនធ្វើឲ្យធ្ងន់ធ្ងរក្នុងបុរសនេះឡើយ ។

បច្ចាមិត្រទី ៣ ពោលថា កាលណាអ្នកវាយតប់ ធ្វើបុរសនេះឲ្យទុព្វលហើយ ការយកកាំបិតកាត់ក្បាល ជាការៈរបស់យើង លុះបច្ចាមិត្រទាំងនោះពោលយ៉ាងនេះហើយ ក៏បានធ្វើតាមប្រការនោះ ។

ការនាំចេញពីទីប្រជុំ របស់ញាតិ និងមិត្ត ឲ្យទៅនៅក្នុងទីណាមួយ ដូចបច្ចាមិត្រទីមួយពោលគណនាគុណរបស់ព្រៃ ហើយនាំបុរសនោះទៅក្នុងព្រៃនោះ គប្បីជ្រាបថា **ជាកិច្ចរបស់ជាតិ** , ការដួលចុះក្នុងខន្ធដែលកើតហើយ ត្រូវអាស្រ័យអ្នកដទៃ និងដេកសម្រាកលើគ្រែ ដូចការវាយតប់របស់បច្ចាមិត្រទីពីរ ធ្វើឲ្យអស់កម្លាំង គប្បីជ្រាបថា **ជាកិច្ចរបស់ជរា** ។ ការធ្វើឲ្យអស់ជីវិត ដូចជាបច្ចាមិត្រទីបី យកកាំបិតដ៏មុតកាត់ក្បាល គប្បីជ្រាបថា **ជាកិច្ចរបស់មរណ** ។



ម្យ៉ាងទៀត ក្នុងបទនេះ **ជាតិទុក្ខ** គប្បីឃើញ ដូចការចូលទៅកាន់ទីមហាកន្តារដែលមានទោស , **ជរាទុក្ខ** គប្បីឃើញ ដូចមនុស្សអត់បាយអត់ទឹកក្នុងទីនោះ នឹងមានកម្លាំងថយចុះ , **មរណទុក្ខ** គប្បីជ្រាប ដូចជាការដល់នូវសេចក្តីវិនាសដោយសត្វកាចជាដើម របស់បុគ្គលដែលអស់កម្លាំង អ្នកអស់សេចក្តីព្យាយាមក្នុងការផ្លាស់ប្តូរឥរិយាបថ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សោកនិទ្ទេស** ដូចតទៅនេះ ឈ្មោះថា **ព្យសនំ** ព្រោះអត្ថថា ដល់នូវការវិនាស , អធិប្បាយថា លះបង់ប្រយោជន៍ និងដេកសោកសៅ ។ ការវិនាសរបស់ញាតិទាំងឡាយ ឈ្មោះថា **ញាតិព្យសនំ** ។ ការវិនាសញាតិ ព្រោះភ័យបណ្តាលមកពីចោរ និងរោគជាដើម ឈ្មោះថា **ញាតិវិនាសោ** ។ ដោយការវិនាសនៃញាតិនោះ ។

បទថា **ផុដ្ឋស្ស** ប៉ះខ្ទប់ហើយ គឺ ខ្ទាំងខ្ទប់ គ្របសង្កត់ , បានដល់ ប្រកបព្រម ។ សូម្បីបទដ៏សេសក៏មានន័យដូចគ្នា ។ តែសេចក្តីផ្សេងគ្នាមានយ៉ាងនេះ សេចក្តីវិនាសនៃសម្បត្តិ ឈ្មោះថា **ភោគព្យសនំ** , អធិប្បាយថា សេចក្តីវិនាសសម្បត្តិ សេចក្តី



វិនាសនៃភោគៈ ដោយរាជភ័យ និងចោរភ័យជាដើម ។

សេចក្តីវិនាស គឺ រោគនោះឯង ឈ្មោះថា **រោគព្យសនំ** ។ ពិតណាស់ **រោគ** ឈ្មោះថា **ព្យសន** ព្រោះអត្ថថា ញុំាងការមិនមានរោគឲ្យវិនាសទៅ ។

ការវិនាសនៃសីល ឈ្មោះថា **សីលព្យសនំ** បទនេះ ជាឈ្មោះរបស់អ្នកទ្រុស្តសីល ។

សេចក្តីវិនាស គឺ ទិដ្ឋិនោះឯងកើតឡើងហើយ ធ្វើសម្មាទិដ្ឋិឲ្យវិនាស ឈ្មោះថា **ទិដ្ឋិព្យសនំ** ការវិនាសនៃទិដ្ឋិ ។

មួយទៀត ក្នុងបទនេះ បទពីរខាងដើម នៅមិនសម្បូរ បីបទខាងក្រោយ សម្បូរហើយ ត្រូវកម្ចាត់ដោយត្រៃលក្ខណ៍ ។

មួយទៀត បីបទដំបូង ជាកុសលក៏មិនមែន ជាអកុសលក៏មិនមែន ។ ពីរបទ គឺ **សីលព្យសន** និង **ទិដ្ឋិព្យសន** ជាអកុសល ។

បទថា **អញ្ញតរញ្ញតរេន** ការវិនាសដទៃ ៗ គឺ កាលណាត្រូវសេចក្តីវិនាសឯណាមួយពាល់ត្រូវក្តី កាលត្រូវសេចក្តីវិនាសនៃមិត្រ និងអាមាត្យណាមួយ មិនពាល់ត្រូវក្តី ។



បទថា **សមន្នាគតស្ស** ជួបប្រសព្វហើយ គឺ ជាប់តាមជានិច្ច មិនឃ្លាតទៅ ។

បទថា **អញ្ញតរញ្ញតរេន ទុក្ខធម្មេន** ជាហេតុនៃទុក្ខដទៃ ៗ គឺ ហេតុកើតទុក្ខ ព្រោះសេចក្តីសោកណាមួយ ។

បទថា **សោកោ** បានដល់ សេចក្តីសោក ដោយអំណាចនៃកិរិយាដែលសោក ។ បទនេះជាបឋមាវិភត្តិ ចុះក្នុងអត្ថនៃសភាវៈនៃសេចក្តីសោក ដែលកើតឡើងដោយហេតុទាំងនោះ ។

បទថា **សោចនា** កិរិយាដែលសោក បានដល់ អាការនៃសេចក្តីសោក ។

បទថា **សោចិត្តតំ** បានដល់ ភាពជាអ្នកសោក ។ បទថា **អន្តោសោកោ** បានដល់ សេចក្តីសោកនៅខាងក្នុង ។ បទទីពីរបន្ថែមឧបសគ្គចុះទៅ ។ ពិតណាស់ សេចក្តីសោកនោះ លោកពោលថា **អន្តោសោកោ អន្តោបរិសោកោ** សភាពក្រៀមក្រំរបស់ចិត្តនៅខាងក្នុង ព្រោះសេចក្តីសោកកើតឡើង ភាពស្រពាប់ស្រពោន ក្រៀមក្រំនៃចិត្ត នៅខាងក្នុង ។

បទថា **ចេតសោ បរិជ្ឈាយនា** ការដុតចិត្ត បានដល់ អាការ



ដុតកម្មោចចិត្ត ព្រោះសេចក្តីសោក កាលបើកើតឡើង រមែងដុតចិត្ត ដូចភ្លើងឆេះ ។ ដែលនិយាយបានថា ចិត្តរបស់យើងត្រូវឆេះ , ពន្លឺអ្វី ៗ មិនមានដល់យើងឡើយ ។

ចិត្តមានទុក្ខ ឈ្មោះថា **ទុម្មនោ** ទាស់ចិត្ត ភាពជាអ្នកទាស់ចិត្ត ឈ្មោះថា **ទោមនស្សំ** ។ ឈ្មោះថា **សោកសល្លំ** បានដល់ កូនសរ គឺសេចក្ដីសោក ដោយអត្ថថា ចូលទៅខាងក្នុង គប្បីជ្រាបក្នុងបរិទេវនិទ្ទេសដូចតទៅនេះ ឈ្មោះថា **អាទេវោ** ត្អូញត្អែរ រៀបរាប់ ដោយអត្ថថា ជាហេតុទួញយំរៀបរាប់យ៉ាងនេះថា ធីតារបស់ខ្ញុំ បុត្ររបស់ខ្ញុំ ដូច្នេះ ។

ឈ្មោះថា **បរិទេវោ** សេចក្ដីត្អូញត្អែរ ដោយអត្ថថា ជាហេតុប្រកាសគុណ គឺ សេចក្ដីល្អ ហើយត្អូញត្អែររៀបរាប់ ។ លោកពោលពីរបទ ពីរបទដទៃអំពីបទនោះ ដោយសម្ដែងដល់អាការនៃពីរបទខាងដើមនោះឯង ។

បទថា **វាចា** គឺ ពាក្យនិយាយ ។

បទថា **បលាបោ** ការរអ៊ូរទាំ ពាក្យនិយាយដែលឥតប្រយោជន៍ទៅទទេ ៗ ឈ្មោះថា **វិប្បលាបោ** ការរវើរវាយ ដោយ



អត្ថថា រអ៊ូរទាំគ្មានបំណងច្បាស់លាស់ ដោយនិយាយទៅបានបន្តិច ហើយក៏និយាយពាក្យដទៃទៀតជាដើម ។

បទថា **លាលប្បោ** ការនិយាយប៉ប៉ាច់ប៉ប៉ោច បានដល់ និយាយហើយនិយាយទៀត ។ អាការនិយាយប៉ប៉ាច់ប៉ប៉ោច ឈ្មោះថា **លាលប្បនា** កិរិយាដែលនិយាយប៉ប៉ាច់ប៉ប៉ោច ។ ភាពជាអ្នកនិយាយប៉ប៉ាច់ប៉ប៉ោច ឈ្មោះថា **លាលប្បិតត្តំ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុង ទុក្ខនិទ្ទេសដូចតទៅនេះ ឈ្មោះថា **កាយិកំ** ព្រោះអាស្រ័យកាយ ។

ឈ្មោះថា **អសាតំ** ការមិនសប្បាយ ដោយអត្ថថា មិនមានការរីករាយ ការមិនសប្បាយផ្លូវចិត្ត រមែងប្រើដោយបទថា **កាយិក** , ការសប្បាយផ្លូវកាយ រមែងប្រើដោយបទថា **អសាតំ** ។

ឈ្មោះថា **ទុក្ខំ** ដោយអត្ថថា ដល់សេចក្ដីលំបាក អធិប្បាយថា ទុក្ខនោះកើតដល់អ្នកណា , រមែងធ្វើអ្នកនោះឲ្យលំបាក ។ម្យ៉ាងទៀត ឈ្មោះថា **ទុក្ខំ** ព្រោះអត់ទ្រាំបានដោយលំបាក ។

បទថា **កាយសម្ផស្សជំ** បានដល់ កើតពីកាយសម្ផស្ស ។

បទថា **អសាតំ ទុក្ខំ វេទយិតំ** ការមិនសប្បាយ សេចក្ដី

លំបាកដែលសត្វសោយហើយ បានដល់ ការមិនរីករាយ ដែលសត្វសោយហើយ , ភាពរីករាយដែលសត្វមិនបានសោយ , ទុក្ខដែលសត្វសោយហើយ , សុខដែលសត្វមិនបានសោយ ។

បីបទខាងមុខលោកពោលដោយឥត្ថីលិង្គ ។ ក្នុងបទនេះមានអធិប្បាយយ៉ាងនេះថា សេចក្តីមិនសប្បាយជាវេទនា , សេចក្តីរីករាយមិនមែនជាវេទនា ។ ទុក្ខជាវេទនា សុខមិនមែនវេទនា ។

គប្បីជ្រាបយោជនាលោកដោះស្រាយទុកយ៉ាងនេះថា ការមិនសប្បាយ ការលំបាកដែលមានតាមផ្លូវកាយ ដែលសត្វឯណាសោយហើយ ។ ការមិនសប្បាយ ទុក្ខវេទនាដែលកើតពីកាយ-សម្ផស្សណា នេះលោកពោលថា **ទុក្ខ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងទោមនស្សនិទ្ទេសដូចតទៅនេះ ៈ-

ឈ្មោះថា **ទុម្មនោ** ព្រោះអត្ថថា ខូចចិត្ត , ម្យ៉ាងទៀតឈ្មោះថា **ទុម្មនោ** ព្រោះអត្ថថា ចិត្តគួរស្អប់ ព្រោះបានទទួលពីសេចក្តីអាក្រក់ , ការខូចចិត្ត ឈ្មោះថា **ទោមនស្សំ** ។

ឈ្មោះថា **ចេតសិកំ** ព្រោះអាស្រ័យចិត្ត ។

បទថា **ចេតោសម្ផស្សជំ** កើតពីសម្ផស្សផ្លូវចិត្ត ។



គប្បីជ្រាបវិនិច្ឆ័យក្នុងឧបាយាសនិទ្ទេសដូចតទៅនេះ ៈ-

ឈ្មោះថា **អាយាសោ** ព្រោះអត្ថថា សេចក្តីទុក្ខផ្លូវចិត្ត ។ បទនេះ ជាឈ្មោះរបស់ការលំបាកចិត្ត ដែលប្រព្រឹត្តទៅក្នុងអាការប្រេបូកប្រេបល់ចិត្ត ។ សេចក្តីទុក្ខចិត្តមានកម្លាំង ឈ្មោះថា **ឧបា-យាសោ** ការចង្អៀតចង្អល់ចិត្ត ។ ភាពជាអ្នកចង្អៀតចង្អល់ចិត្ត ឈ្មោះថា **អាយាសិតត្តំ** ។ ភាពជាអ្នកក្តៅចិត្ត ឈ្មោះថា **ឧបាយាសិតត្តំ** ។

គប្បីជ្រាបវិនិច្ឆ័យ ក្នុងអប្បិយសម្បយោគនិទ្ទេសដូចតទៅនេះ ៈ-

បទថា **ឥធ** បានដល់ ក្នុងលោកនេះ ។

បទថា **យស្ស** កាត់បទជា **យេ អស្ស** ។

បទថា **អនិដ្ឋា** មិនគួរប្រាថ្នា គឺ មិនគួរស្វែងរក ។ នឹងគួរស្វែងរកក៏ដោយ មិនគួរស្វែងរកក៏ដោយ លើកទុក , បទនេះជាឈ្មោះរបស់អារម្មណ៍ដែលមិនគួរពេញចិត្ត ។

ឈ្មោះថា **អកន្តា** មិនគួរប្រាថ្នា ព្រោះអត្ថថា មិនឈានចូលទៅក្នុងចិត្ត ។

ឈ្មោះថា **អមនាបា** មិនគួរពេញចិត្ត ព្រោះអត្ថថា មិនគួរស្រឡាញ់ក្នុងចិត្ត ឬមិនចម្រើនចិត្ត ។

បទថា **រូបា** ជាដើម សម្តែងដល់សភាវៈរបស់បទទាំងនោះ ។

ឈ្មោះថា **អនត្ថកាមា** ព្រោះអត្ថថា សង្ឃឹម គឺ ប្រាថ្នារបស់មិនជាប្រយោជន៍ ។

ឈ្មោះថា **អហិតកាមា** ព្រោះអត្ថថា សង្ឃឹម គឺ ប្រាថ្នារបស់មិនមែនជាគ្រឿងឧបត្ថម្ភ ។

ឈ្មោះថា **អផាសុកាមា** ព្រោះអត្ថថា សង្ឃឹម គឺ ប្រាថ្នាសេចក្តីមិនសប្បាយ នៅដោយលំបាក ។

ឈ្មោះថា **អយោគក្ខេមកាមា** ព្រោះអត្ថថា មិនសង្ឃឹមការរំដោះ សភាពផុតពីភយន្តរាយ ការរួចផុតពីយោគៈ ៤ គឺ អន្លង់តណ្ហា ការមានភ័យ ការវិលស្លាប់វិលកើត របស់រូបជាដើមទាំងនោះ ។

ម្យ៉ាងទៀត ឈ្មោះថា **អនត្ថកាមា** ព្រោះមិនសង្ឃឹមវត្ថុជាប្រយោជន៍ គឺ សេចក្តីចម្រើននៃសទ្ធាជាដើម , និងព្រោះសង្ឃឹមវត្ថុមិនជាប្រយោជន៍ គឺ ការវិនាសទៅនៃសទ្ធាជាដើម ទាំងនោះ ។



ឈ្មោះថា **អហិតកាមា** ព្រោះមិនសង្ឃឹមប្រយោជន៍ ជាគ្រឿងឧបត្ថម្ភ ដែលជាឧបាយចូលដល់សទ្ធាជាដើម និងព្រោះសង្ឃឹមវត្ថុដែលមិនជាប្រយោជន៍ជាគ្រឿងឧបត្ថម្ភ ដែលជាឧបាយចូលដល់ការវិនាសនៃសទ្ធាជាដើម ។

ឈ្មោះថា **អផាសុកាមា** ព្រោះមិនសង្ឃឹមការរស់នៅបានសប្បាយ និងព្រោះសង្ឃឹមរស់នៅមិនសប្បាយ ។

ឈ្មោះថា **អយោគក្ខេមកាមា** ព្រោះមិនសង្ឃឹមរួចផុតពីភ័យណា ៗ និងព្រោះសង្ឃឹមឋានទីងមានភ័យ ។ គប្បីឃើញសេចក្តីនៃបទនេះ យ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា **សង្គតិ** បានដល់ ការទៅរួមគ្នា ។

បទថា **សមាគមោ** បានដល់ ការមករួមគ្នា ។

បទថា **សមោធានំ** បានដល់ ការនៅរួមទាំងក្នុងវេលាឈរ វេលាអង្គុយជាដើម ។

បទថា **មិស្សីភាវោ** បានដល់ ការធ្វើកិច្ចទាំងពួងរួមគ្នា ។ បទនេះ យោជនាដោះស្រាយថា ដោយអំណាចសត្វ ។ តែគប្បីកាន់យកកិច្ចដែលបានដោយអំណាចនៃសង្ខារ ។ ការនៅរួមជាមួយ

សត្វ និងសង្ខារ ឬសង្ខារមិនជាទីស្រឡាញ់នោះ ដោយអត្ថថា ធម៌ប្រការមួយមិនមាន , លោកពោលថា **ទុក្ខ** ព្រោះជាទីតាំងនៃទុក្ខ សូម្បី ២ យ៉ាង របស់សត្វដែលនៅរួមគ្នា ជាមួយសត្វ ឬសង្ខារដែលមិនជាទីស្រឡាញ់ ។

**បិយវិប្បយោគនិទ្ទេស** គប្បីជ្រាបដោយន័យផ្ទុយគ្នា ជាមួយនឹងការដែលបានពោលហើយ ។ ក្នុងបទមានជាអាទិ៍ថា **មាតា វា** លោកពោលដើម្បីសម្តែងដល់ការសង្ខេបប្រយោជន៍ ដោយសរុប ។

ក្នុងបទទាំងនោះ ឈ្មោះថា **មាតា** ព្រោះអត្ថថា ថែរក្សាយ៉ាងជាទីពេញចិត្ត ។

ឈ្មោះថា **បិតា** ព្រោះអត្ថថា ប្រព្រឹត្តគួរស្រឡាញ់ ។

ឈ្មោះថា **ភាតា** ព្រោះអត្ថថា រមែងសេពគប់ ។

ឈ្មោះថា **ភគិនី** ក៏ដូចគ្នា ។

ឈ្មោះថា **មិត្រ** ព្រោះអត្ថថា ជាទីស្រឡាញ់ ,ម្យ៉ាងទៀត ឈ្មោះថា **មិត្រ** ព្រោះអត្ថថា រាប់អាន គឺ ទុកចិត្តបានក្នុងការសម្ងាត់ទាំងពួង ។

ឈ្មោះថា **អមច្ចា** ព្រោះអត្ថថា ជាអ្នកនៅរួមគ្នា ដោយការ



រួមគ្នាក្នុងកិច្ចដែលគួរធ្វើ ។

ឈ្មោះថា **ញាតិ** ព្រោះអត្ថថា ដឹង គឺ យល់យ៉ាង នេះថា បុគ្គលនេះជាមនុស្សខាងចំណែកយើង ។

ឈ្មោះថា **សាលោហិតា** ព្រោះអត្ថថា ទាក់ទងគ្នាដោយសាច់ឈាម ។

**ញាតិ** គឺ មនុស្សខាងចំណែកបិតា , **សាលោហិត** គឺ មនុស្សចំណែកខាងមាតា ។ ម្យ៉ាងទៀត **ញាតិ** គឺ មនុស្សចំណែកខាងមាតាបិតា **សាលោហិត** គឺ មនុស្សចំណែកឪពុកក្មេកម្តាយក្មេក ។

ការព្រាត់ប្រាសពីសត្វ និងសង្ខារនេះ ដោយអត្ថថា ឈ្មោះធម៌ប្រការមួយ រមែងមិនមាន , លោកពោលថា **ទុក្ខ** ព្រោះជាទីតាំងនៃទុក្ខ សូម្បី ២ យ៉ាង របស់សត្វអ្នកព្រាត់ប្រាសចាកសត្វ និងសង្ខារដែលជាទីស្រឡាញ់ទាំងអស់ ។ ពាក្យនេះ ក្នុងបទនេះ ជាពាក្យក្នុងអដ្ឋកថាទាំងអស់ ។ គួរនឹងពោលថា វត្ថុដែលមិនជាទីស្រឡាញ់ និងជាទីស្រឡាញ់ ផ្សេងគ្នាពីពាក្យថា **សម្បយោគោ** ការនៅរួមគ្នា និងពាក្យថា **វិប្បយោគោ** ការព្រាត់ប្រាស ព្រោះ

សច្ចធម៌ទាំងឡាយ មាន លក្ខណៈជារបស់ពិតប្រាកដ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **ឥច្ឆិតាលាភនិទ្ទេស** ដូចតទៅនេះ

បទថា **ជាតិ ធម្មានំ** សត្វទាំងឡាយ មានការកើតជាធម្មតា បានដល់ មានការកើតជាសភាវៈ គឺ មានការកើតជាប្រក្រតី ។

បទថា **ឥច្ឆា ឧប្បជ្ជតិ** សេចក្តីប្រាថ្នាកើតឡើង បានដល់ តណ្ហាកើតឡើង ។

បទថា **អហោ វត** គឺ សេចក្តីប្រាថ្នា ។

បទថា **អស្សាម** ប្រែថា គប្បីបាន ។

បទថា **ន ខោ បនេតំ ឥច្ឆាយ បត្តព្វំ** ប្រការនេះ សត្វមិនគប្បីបានតាមសេចក្តីប្រាថ្នា ។ ការដែលសត្វទាំងឡាយ ប្រាថ្នាការមិនមកនៃជាតិ ដែលមាននៅក្នុងសេចក្តីល្អទាំងឡាយ ជាហេតុនៃសេចក្តីលះបង់យ៉ាងនេះថា សូមកុំឲ្យយើងមានជាតិជាធម្មតា និងជាតិកុំមានដល់យើងឡើយ នឹងមានហើយក្នុងការរលត់ការមិនកើតជាធម្មតា នេះជាការដែលសត្វមិនគប្បីបានតាមសេចក្តីប្រាថ្នា ព្រោះសូម្បីអ្នកប្រាថ្នា វៀរមគ្គភាវនា ក៏មិនគប្បីដល់ និងព្រោះសូម្បីអ្នកមិនប្រាថ្នា ក៏គប្បីបានដោយភាវនា ។



បទថា **ឥទម្បិ** គឺ **ឯតម្បិ** សូម្បីមាតិកានោះ ។ **អបិ** ស័ព្ទ សំដៅដល់បទដែលសល់ខាងមុខ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **ឧបាទានក្ខន្ធនិទ្ទេស** ដូចតទៅនេះ

បទថា **សេយ្យថីទំ** ជានិបាត , សេចក្តីនៃបទនោះថា ប្រសិនបើសួរថា ឧបាទានក្ខន្ធទាំងនោះដូចម្តេច ? ឆ្លើយថា ឧបាទានក្ខន្ធ គឺ រូបនោះឯង ព្រោះហេតុនោះ ទើបឈ្មោះថា **រូបូបាទានក្ខន្ធោ** ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យនេះដូចគ្នា ។

**( ចប់អដ្ឋកថាទុក្ខសច្ចនិទ្ទេស )**

# **អ ដ្ឋ ក ថា**

## *សមុទយសច្ចនិទ្ទេស*

គប្បីជ្រាបវិនិច្ឆ័យក្នុង **សមុទយសច្ចនិទ្ទេស** ដូចតទៅនេះ បទថា **យាយំ តណ្ហា** តណ្ហានេះណា ។ បទថា **បោនោព្ភវិកា** តណ្ហាដែលឲ្យកើតក្នុងភពថ្មី ការធ្វើភពថ្មី ឈ្មោះថា **បុនព្ភវោ** ឈ្មោះថា **បោនោព្ភវិកា** ព្រោះអត្ថថា សត្វមានភពថ្មី , ម្យ៉ាងទៀត ឈ្មោះថា **បោនោព្ភវិកា** ព្រោះអត្ថថា តណ្ហា ឲ្យមានភពថ្មី , តណ្ហារមែងប្រព្រឹត្តទៅក្នុងភពថ្មី , តណ្ហាឲ្យកើតភពរឿយ ៗ ។ តណ្ហានោះឲ្យភពថ្មីក៏មាន មិនឲ្យភពថ្មីក៏មាន ។ ឲ្យប្រព្រឹត្តទៅក្នុងភពថ្មីក៏មាន មិនឲ្យប្រព្រឹត្តទៅក្នុងភពថ្មីក៏មាន ។ កាលបើឲ្យបដិសន្ធិហើយ តណ្ហាធ្វើឲ្យខន្ធចាស់ក្លាក៏មាន , តណ្ហានោះសូម្បីធ្វើភាពចាស់ក្លាក៏រមែងបានឈ្មោះថា **បោនោព្ភវិកា** ។ បាឋៈថា **បោនព្ភវិកា** ខ្លះ , មានសេចក្តីដូចគ្នា ។

ឈ្មោះថា **នន្ទិរាគសហគតា** សហគតៈដោយនន្ទិរាគៈ ព្រោះអត្ថថា តណ្ហាសហគតៈដោយនន្ទិរាគៈ ពោលគឺ សេចក្តី



ពេញចិត្តដ៏ក្រៃលែង , លោកអធិប្បាយទុកថា តណ្ហាដោយន័យដូចតែគ្នាជាមួយនឹងនន្ទិរាគៈ ។

បទថា **តត្រ តត្រាភិនន្ទិនី** ដែលភ្លើតភ្លើនក្នុងអារម្មណ៍នោះ ៗ សេចក្តីថា តណ្ហាត្រេកអរក្រៃលែងក្នុងអារម្មណ៍ ដែលអត្តភាពកើត , ឬត្រេកអរក្នុងអារម្មណ៍នោះ ៗ មានរូបជាដើម គឺត្រេកអរក្នុងរូប សំឡេង ក្លិន រស ផោដ្ឋព្វៈ និងធម្មារម្មណ៍ ។ បាឋៈថា **តត្រ តត្រាភិនន្ទី** ខ្លះ សេចក្តីថា ឲ្យត្រេកអរក្នុងអារម្មណ៍នោះ ៗ ។

បទថា **សេយ្យថីទំ** ជានិបាត សេចក្តីនៃបទនេះថា ប្រសិនបើសួរថា តណ្ហានោះ ដូចម្តេច ?

បទថា **កាមតណ្ហា** បានដល់ តណ្ហាក្នុងកាម , បទនេះជាឈ្មោះនៃរាគៈ ដែលប្រព្រឹត្តទៅក្នុងកាមគុណ ៥ ។

បទថា **ភវតណ្ហា** បានដល់ តណ្ហាក្នុងភព ។ បទនេះ ជាឈ្មោះរបស់រាគសហគតៈដោយសស្សតទិដ្ឋិ ដែលកើតឡើងដោយសេចក្តីប្រាថ្នាក្នុងភព និងរាគៈក្នុងរូបភព អរូបភព និងសេចក្តីត្រូវការក្នុងឈាន។

បទថា **វិភវតណ្ហា** បានដល់ តណ្ហាក្នុង **វិភវ** គឺ ប្រាសចាកភព ។ បទនេះ ជាឈ្មោះរបស់ឧច្ឆេទទិដ្ឋិ ។

ឥឡូវនេះ ដើម្បីសម្តែងដល់ទីកើតរបស់តណ្ហានោះ ដោយពិស្តារ ព្រះថេរៈទើបពោលថា **សា ខោ បនេសា** ក៏តណ្ហានោះឯង ជាអាទិ៍ ។

ក្នុងបទទាំងនោះ បទថា **ឧប្បជ្ជតិ** ប្រែថា រមែងកើត ។

បទថា **និវិសតិ** រមែងតាំងនៅ គឺ តាំងនៅដោយការប្រព្រឹត្តទៅរឿយ ៗ គប្បីជ្រាបសេចក្តីថា តណ្ហា កាលកើតរមែងកើតឡើងក្នុងទីណា កាលតាំងនៅ រមែងតាំងនៅក្នុងទីណា ។

បទថា **យំ លោកេ បិយរូបំ សាតរូបំ** វត្ថុណាជាទីស្រឡាញ់ ជាទីត្រេកអរក្នុងលោក គឺ វត្ថុណាមានសភាពគួរស្រឡាញ់ និងមានសភាពផ្អែមល្ហែមក្នុងលោក ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា **ចក្ខុ លោកេ** ដូចតទៅនេះ សត្វទាំងឡាយប្រកាន់មាំថា ជារបស់យើង ក្នុងចក្ខុជាដើមក្នុងលោក តាំងនៅក្នុងវត្ថុដែលដល់ព្រម រមែងសម្គាល់បសាទទាំង ៥ គឺ **ចក្ខុ** របស់ខ្លួនផូរផង់ ដោយការកាន់យកនិមិត្ត



ក្នុងកញ្ចក់ជាដើម ដូចសីហបញ្ជរ ( បង្អួច ) ធ្វើដោយកែវមណីដែលបុគ្គលតាំងឡើងក្នុងវិមានមាស ។ រមែងសម្គាល់ **សោត** ដូចប្រដាប់ឆ្នុះប្រាក់ និងដូចខ្សែស្រង្វារ ។ រមែងសម្គាល់ **ឃានៈ** ដែលគេហៅថា ច្រមុះកោងដូចហរតាល ( ថ្មម្យ៉ាងដែលមានសាច់ទន់ ) ដែលបុគ្គលមូរតាំងទុក ។ រមែងសម្គាល់ **ជីវ្ហា** ឲ្យរសផ្អែមស្អិតរមួត ដូចផ្ទាំងសំពត់កម្ពលពណ៌ក្រហម ។ រមែងសម្គាល់ **កាយ** ដូចដើមសាលៈ និងដូចស៊ុមទ្វារមាស ។ រមែងសម្គាល់ **មន** វិតតែធំ មិនដូច **មន** របស់អ្នកដទៃ ។ រមែងសម្គាល់ **រូប** ដូចពណ៌មានពណ៌មាស និងផ្កាកណិការ៍ជាដើម ។ រមែងសម្គាល់ **សំឡេង** ដូចសំឡេង សត្វករវិក និងដូចតាវៅដែលកំពុងសប្បាយនឹងសំឡេងរំពង របស់ខ្លុយកែវមណីដែលផ្លុំថ្នម ៗ រមែងសម្គាល់អារម្មណ៍មានក្លិនជាដើម ដែលកើតពីសមុដ្ឋាន ៤ ដែលខ្លួនបានហើយថា អ្នកណាហ្ន៎ នឹងបានអារម្មណ៍បែបនេះ ។

កាលណាសត្វទាំងនោះសម្គាល់យ៉ាងនេះហើយ ចក្ខុជាដើមទាំងនោះ រមែងជាបិយរូប និងសាតរូប ។ កាលបើដូច្នោះ តណ្ហាមិនទាន់កើតក្នុងបិយរូប និងសាតរូបនោះ រមែងកើតដល់

សត្វទាំងនោះ , និងដែលកើតឡើងហើយ រមែងតាំងនៅដោយការប្រព្រឹត្តទៅរឿយ ៗ ។ ព្រោះដូច្នោះ ព្រះថេរៈទើបពោលថា ចក្ខុជាបិយរូប សាតរូបក្នុងលោក , តណ្ហានេះ កាលកើតឡើង រមែងកើតឡើងក្នុងវត្ថុនេះ ។

ក្នុងបទទាំងនោះ បទថា **ឧប្បជ្ជមានា** សេចក្តីថា កាលណាបិយរូប សាតរូបកើត , កាលនោះតណ្ហា រមែងកើតឡើងក្នុងវត្ថុនេះ ។

**( ចប់អដ្ឋកថាសមុទយសច្ចនិទ្ទេស )**



## អ ដ្ឋ ក ថា

## និរោធសច្ចនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យក្នុង **និរោធសច្ចនិទ្ទេស** ដូចតទៅនេះ ក្នុងបទនេះថា **យោ តស្សាយេវ តណ្ហាយ** ការរំលត់តណ្ហានោះ ដោយប្រាសចាកតម្រេកមិនមានសេសសល់ គួរពោលថា **យោ តស្សេវ ទុក្ខស្ស** ការរំលត់ទុក្ខនោះ ដោយការប្រាសចាកតម្រេក មិនមានសល់ ព្រោះទុក្ខរលត់ ដោយការរំលត់សមុទ័យ , មិនមែនរំលត់ដោយប្រការដទៃ ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ៖-

**យថាបិ មូលេ អនុបទ្ទវេ ទឡ្ហេ**
**ឆិន្នោបិ រុក្ខោ បុនរេវ រូហតិ ,**
**ឯវម្បិ តណ្ហានុសយេ អនូហតេ**
**និព្វត្តី ទុក្ខមិទំ បុនប្បុនំ ។**

កាលបើដកតណ្ហានុស័យមិនបាន ទុក្ខនេះ រមែងកើតរឿយ ៗ ដូចកាលដែលឫសឈើនៅរឹងមាំ មិនមានអន្តរាយ ដើមឈើសូម្បីកាត់ហើយ ក៏នៅដុះទៀតបាន ។

ព្រោះដូច្នេះ ព្រះដ៏មានព្រះភាគជាម្ចាស់ កាលនឹងទ្រង់សម្ដែងទុក្ខនិរោធនោះ ទើបត្រាស់យ៉ាងនេះ ដើម្បីសម្ដែងសមុទយនិរោធ ។ ពិតហើយ ព្រះតថាគតទាំងឡាយដែលមានការប្រព្រឹត្តស្មើដោយសីហៈ , ព្រះតថាគតទាំងនោះ កាលនឹងទ្រង់រំលត់ទុក្ខ ហើយកាលនឹងទ្រង់សម្ដែងការរំលត់ទុក្ខ ទើបទ្រង់សម្ដែងអំពីហេតុ ទ្រង់មិនសម្ដែងអំពីផល ។ ចំណែកពួកអន្យតិរ្ថិយ៍មានការប្រព្រឹត្តបែបយ៉ាងសុនខ , ពួកនោះ កាលនឹងរំលត់ទុក្ខ និងដើម្បីសម្ដែងដល់ការរំលត់ទុក្ខ ទើបពោលអំពីផលនៃទេសនារបស់ **ទុក្ខនិរោធ** នោះផង **អត្តកិលមថានុយោគ** ការប្រកបសេចក្ដីព្យាយាមដោយធ្វើខ្លួនឲ្យលំបាក មិនពោលក្នុងហេតុ ព្រោះដូច្នេះ ព្រះសាស្ដាកាលនឹងទ្រង់សម្ដែងអំពីហេតុ ទើបត្រាស់ព្រះពុទ្ធវចនៈមានន័យជាអាទិ៍ថា **យោ តស្សាយេវ តណ្ហាយ** ដូច្នេះ ។ សូម្បីព្រះធម្មសេនាបតី ក៏ពោលតាមលំដាប់ដែលព្រះសាស្ដាត្រាស់នោះឯង ។

ក្នុងបទទាំងនោះ បទថា **តស្សាយេវ តណ្ហាយ** សេចក្ដីថា តណ្ហា ដែលព្រះដ៏មានព្រះភាគជាម្ចាស់ ត្រាស់ថា **បោនោព្ភវិកា**



តណ្ហាធ្វើឲ្យកើតភពថ្មី ហើយទ្រង់ចែកជាកាមតណ្ហាជាដើម និងទ្រង់ប្រកាសជាខាងក្រោយដោយការកើតឡើង ការតាំងនៅ ។

បទថា **អសេសវិរាគនិរោធោ** ការរំលត់តណ្ហាដោយ មិនមានសេសសល់ សេចក្ដីថា មគ្គលោកពោលថា **វិរាគ** ការប្រាសចាកតម្រេក ដូចដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា **វិរាគា វិមុច្ចតិ** ព្រោះប្រាសចាកតម្រេក ទើបរួចផុត ។ ការប្រាសចាកតម្រេក ឈ្មោះថា **វិរាគនិរោធ** ។ ការប្រាសចាកតម្រេកដោយមិនសេសសល់ ដោយដកអនុស័យ ឈ្មោះថា **អសេសវិរាគនិរោធ** ។

ម្យ៉ាងទៀត ព្រោះលោកពោលការលះបង់ថា **វិរាគ** ដូច្នោះ គប្បីឃើញការប្រកបក្នុងបទនេះ យ៉ាងនេះថា **វិរាគោ អសេសោ និរោធោ** ការរំលត់មិនមានសេសសល់ ឈ្មោះថា **វិរាគ** ។ តែដោយអត្ថ បទទាំងអស់មានជាអាទិ៍ថា **អសេសវិរាគនិរោធោ** នេះជាវេវចនៈរបស់និព្វាននោះឯង ។ ព្រោះថាដោយបរមត្ថ លោកពោល **និព្វាន** ថា **ទុក្ខនិរោធំ អរិយសច្ចំ** ទុក្ខនិរោធជាអរិយសច្ច ។

ព្រោះតណ្ហាអាស្រ័យនិព្វាននោះ រមែងវិនាស គឺ រមែងរលត់ដោយមិនមានសេសសល់ ។ ដូច្នោះ **និព្វាន** លោកទើបពោលថា **តស្សាយេវ តណ្ហាយ អសេសវិរាគនិរោធោ** ការរំលត់តណ្ហានោះ ព្រោះប្រាសចាកតម្រេកមិនសេសសល់ ។

មួយទៀត តណ្ហាអាស្រ័យនិព្វាន រមែងលះបង់ រមែងកម្ចាត់បង់ រមែងរលាស់ផុត រមែងមិនជាប់ , ក្នុងនិព្វាននេះមិនមានអាល័យ សូម្បីត្រឹមតែបន្តិចក្នុងកាមគុណទាំងឡាយ , ព្រោះដូច្នោះ លោកទើបពោលនិព្វានថា **ចាគោ បដិនិស្សគ្គោ វិមុត្តិ អនាលយោ** ការលះកម្ចាត់បង់ ការរួចផុត សេចក្តីមិនអាល័យ ។

អត្ថរបស់ព្រះនិព្វានមានតែមួយប៉ុណ្ណោះ , តែឈ្មោះរបស់ព្រះនិព្វាននោះ មានជាច្រើនដោយអំណាចបដិបក្ខដល់ឈ្មោះរបស់សង្ខតធម៌ទាំងពួង ។ គឺមានជាអាទិ៍ថា **អសេសវិរាគោ** ប្រាសចាកតម្រេកដោយមិនមានសេសសល់ ។

**អសេសនិរោធោ** រំលត់ដោយមិនមានសេសសល់ ។

**ចាគោ** ការលះបង់ ។



**បដិនិស្សគ្គោ** ការកម្ចាត់បង់ ។

**វិមុត្តិ** ការរួចផុត ។

**អនាលយោ** ការមិនអាល័យ ។

**រាគក្ខយោ** ការអស់រាគៈ ។

**ទោសក្ខយោ** ការអស់ទោសៈ ។

**មោហក្ខយោ** ការអស់មោហៈ ។

**តណ្ហក្ខយោ** ការអស់តណ្ហា ។

**អនុប្បាទោ** ការមិនកើត ។

**អប្បវត្តំ** ការមិនប្រព្រឹត្តទៅ ។

**អនិមិត្តំ** ការមិនមានគ្រឿងសម្គាល់ ។

**អប្បណិហិតំ** ការមិនមានទីតាំង ។

**អយូហណំ** ការមិនមានកម្មជាហេតុឲ្យបដិសន្ធិ ។

**អប្បដិសន្ធិ** ការមិនបន្ត ។

**អនុប្បត្តិ** ការមិនមានឧប្បត្តិ ។

**អគតិ** ការមិនមានគតិ ។

**អជាតំ** ការមិនកើត ។

**អជរំ** ការមិនចាស់ ។

**អព្យាធិ** ការមិនឈឺ ។

**អមតំ** ការមិនស្លាប់ ។

**អសោកំ** ការមិនសោក ។

**អបរិទេវំ** ការមិនយំខ្សឹកខ្សួល ។

**អនុបាយាសំ** ការមិនក្រៀមក្រំចិត្ត ។

**អសង្កិលិដ្ឋំ** ការមិនសៅហ្មង ។

ឥឡូវនេះ លោកសម្តែងដល់ការកើតនៃតណ្ហា សូម្បីដល់ការប្រព្រឹត្តទៅមិនបាន ត្រូវកម្ចាត់ដោយមគ្គ ព្រោះអាស្រ័យនិព្វាន ក្នុងវត្ថុណា ដើម្បីសម្តែងការមិនមានក្នុងវត្ថុនោះ ព្រះសារីបុត្ត ទើបពោលថា **សា បនេសា** ជាអាទិ៍ ។

ក្នុងបទនោះ មានសេចក្តីថា ដូចបុរសឃើញវល្លិ៍ម្រ៉ាង ឬដើមឃ្លោកដែលដុះលើដី ទើបស្វែងរកឫសតាំងតែពីចុងរហូត ហើយក៏កាត់ឫសវាចេញ , វល្លិ៍ម្រ៉ាង និងដើមឃ្លោកនោះ ក៏ស្វិតក្រៀមទៅដោយលំដាប់ ហើយវិនាសអស់ទៅ យ៉ាងណា តណ្ហាក្នុងចក្ខុជាដើម ក៏ដូចវល្លិ៍ និងដើមឃ្លោកដែលដុះលើដីនោះ



ដូច្នោះ ។ តណ្ហានោះ ត្រូវកាត់ផ្តាច់ដោយអរិយមគ្គអស់ហើយ ក៏ដល់នូវសេចក្តីវិនាសទៅ ព្រោះអាស្រ័យព្រះនិព្វាន ។ លុះតណ្ហាដល់នូវការអស់ទៅយ៉ាងនេះហើយ ក៏មិនប្រាកដក្នុងវត្ថុទាំងនោះ ដូចវល្លិ៍ និងដើមឃ្លោកដែលដុះលើដី ដូច្នោះ ។

ម្យ៉ាងទៀត ដូចជារាជបុរសនាំចោរមកពីព្រៃហើយ ក៏សម្លាប់នៅកន្លែងទ្វារទក្សិណនគរ , យ៉ាងនោះគួរពោលបានថា ចោរស្លាប់បាត់ហើយ ឬត្រូវសម្លាប់ឲ្យស្លាប់ហើយនៅក្នុងព្រៃ យ៉ាងណា , តណ្ហាក្នុងចក្ខុជាដើម ដូចចោរក្នុងព្រៃ ដូច្នោះ , តណ្ហានោះ រលត់ទៅហើយក្នុងនិព្វាន ព្រោះអាស្រ័យព្រះនិព្វាន ទើបបានរលត់ទៅ ដូចចោរត្រូវសម្លាប់នៅទ្វារទក្សិណ ។ តណ្ហារលត់ទៅយ៉ាងនេះ មិនប្រាកដក្នុងវត្ថុទាំងនោះ ដូចចោរក្នុងព្រៃ , ដោយហេតុនោះ ព្រះសារីបុត្ត កាលណានឹងសម្តែងដល់ការរលត់តណ្ហានោះ ក្នុងចក្ខុជាដើមនោះ ទើបពោលពាក្យមានជាអាទិ៍ថា **ចក្ខុំ លោកេ បិយរូបំ សាតរូបំ ឯត្ថេសា តណ្ហា បហីយមានា បហីយតិ** ចក្ខុជាទីស្រឡាញ់ ជាទីត្រេកអរក្នុងលោក តណ្ហានេះ កាលលះបង់ រមែងលះបង់បានក្នុងចក្ខុនេះ ។

ម្យ៉ាងទៀត លោកពោលថា ព្រោះកំណត់ដឹងវត្ថុដែលតណ្ហាកើត តណ្ហាទើបរលត់ទៅក្នុងវត្ថុដែលតណ្ហាកើត ដោយមិនឲ្យកើត ព្រោះមិនកើតតទៅទៀតក្នុងវត្ថុដែលកំណត់ដឹង ។ មួយទៀត ក្នុងបទនេះ លោកពោលថា តណ្ហារមែងលះបង់បាន ដោយជាបដិបក្ខដល់ការកើត រមែងរលត់ទៅ ដោយបដិបក្ខដល់ការតាំងនៅ ដូច្នោះ ។

***( ចប់អដ្ឋកថា និរោធសច្ចនិទ្ទេស )***



# អ ដ្ឋ ក ថា

## មគ្គសច្ចនិទ្ទេស

គប្បីវិនិច្ឆ័យក្នុង **មគ្គសច្ចនិទ្ទេស** ដូចតទៅនេះ ៈ-

បទថា **អយមេវ** គឺ កំណត់ធម៌ដែលជាបដិបក្ខដល់មគ្គដទៃ ។ បទថា **អរិយោ** ឈ្មោះថា **អរិយ** ព្រោះឆ្ងាយពីកិលេសដែលមកដោយមគ្គនោះ ៗ , ព្រោះធ្វើភាពជាព្រះអរិយៈ និងព្រោះធ្វើឲ្យសម្រេចនូវអរិយផល ។ ឈ្មោះថា **អដ្ឋង្គិក** ព្រោះអត្ថថា មគ្គនោះមានអង្គ ៨ ។ មគ្គនោះដូចសេនាមានអង្គ ៤ , អង្គមគ្គដូចតន្ត្រីមានអង្គ ៥ , ផុតពីអង្គហើយ មានមិនបាន ។

ឥឡូវនេះ ព្រះសារីបុត្តកាលសម្តែងថា មគ្គមានត្រឹមតែអង្គប៉ុណ្ណោះ ផុតពីអង្គហើយមានមិនបាន ទើបពោលពាក្យមានជាអាទិ៍ថា **សម្មាទិដ្ឋិ ។បេ។ សម្មាសមាធិ** ។

ក្នុងបទទាំងនោះ **សម្មាទិដ្ឋិ** មានការឃើញត្រូវ ជាលក្ខណៈ ។ **សម្មាសង្កប្ប** មានការលើកឡើងជាលក្ខណៈ ។ **សម្មាវាចា** មានការកំណត់ជាលក្ខណៈ ។ **សម្មាកម្មន្ត** មានការ

ឲ្យតាំងឡើងជាលក្ខណៈ ។ **សម្មាអាជីវ** មានការផូរផង់ ជាលក្ខណៈ ។ **សម្មាវាយាម** មានការផ្គងទុកជាលក្ខណៈ ។ **សម្មា-សតិ** មានការចូលទៅតាំងមាំជាលក្ខណៈ **សម្មាសមាធិ** មានការតាំងទុកស្មើ ជាលក្ខណៈ ។

ក្នុងមគ្គទាំងនោះ មគ្គមួយ ៗ រមែងមានកិច្ច ៣ យ៉ាង ។ គឺ **សម្មាទិដ្ឋិ** រមែងលះមិច្ឆាទិដ្ឋិព្រមទាំងកិលេសដែលជាសត្រូវរបស់ខ្លួន មុនអង្គមគ្គដទៃ , ធ្វើនិរោធឲ្យជាអារម្មណ៍ , ហើយឃើញសម្បយុត្តធម៌ ព្រោះមិនវង្វេង ដោយអំណាចកម្ចាត់មោហៈដែលបិទបាំងសម្បយុត្តធម៌ទាំងឡាយបាន ។ សូម្បី **សម្មាសង្កប្ប** ជាដើម ក៏លះមិច្ឆាសង្កប្បៈជាដើម បានដូចគ្នា , ហើយធ្វើនិព្វានឲ្យជាអារម្មណ៍ ។ តែដោយប្លែកគ្នាក្នុងបទនេះ **សម្មាសង្កប្ប** លើកសហជាតធម៌ឡើងដោយប្រពៃ , **សម្មាវាចា** កំណត់យកដោយប្រពៃ , **សម្មាកម្មន្ត** ឲ្យតាំងឡើងដោយប្រពៃ , **សម្មាអាជីវ** ឲ្យផូរផង់ដោយប្រពៃ, **សម្មាវាយាម** ផ្គងទុកដោយប្រពៃ , **សម្មា-សតិ** ឲ្យចូលទៅតាំងទុកដោយប្រពៃ , **សម្មាសមាធិ** តាំងទុកដោយប្រពៃ ។



ម្យ៉ាងទៀត **សម្មាទិដ្ឋិ** នេះ ក្នុងចំណែកលោកិយៈ មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា , ក្នុងកាលនៃមគ្គមានខណៈដូចគ្នា , មានអារម្មណ៍ដូចគ្នា ។ តែដោយកិច្ច រមែងបានឈ្មោះ ៤ យ៉ាង មានជាអាទិ៍ថា **ទុក្ខេញាណំ** ការដឹងក្នុងទុក្ខ ។ សូម្បីសម្មាសង្កប្បៈជាដើម ក្នុងចំណែកលោកិយៈ ក៏មានខណៈផ្សេងគ្នា មានអារម្មណ៍ផ្សេងគ្នា , ក្នុងកាលនៃមគ្គមានខណៈដូចគ្នា មានអារម្មណ៍ដូចគ្នា ។ ក្នុងមគ្គទាំងនោះ សម្មាសង្កប្បៈ ដោយកិច្ច រមែងមានឈ្មោះ ៣ យ៉ាង គឺ **នេក្ខម្មសង្កប្បោ** ជាដើម ។ មគ្គ ៣ មាន **សម្មាវាចា** ជាដើម ក្នុងចំណែកលោកិយៈ ជាវិរតិខ្លះ ជាចេតនាខ្លះ , តែក្នុងខណៈនៃមគ្គ ជាវិរតិតែម្យ៉ាង , ពីរបទនេះ គឺ **សម្មាវាយាមោ សម្មាសតិ** ដោយកិច្ច រមែងបានឈ្មោះ ៤ យ៉ាង ដោយអំណាចសម្មប្បធាន និងសតិប្បដ្ឋាន ។ ចំណែកសម្មាសមាធិ សូម្បីក្នុងចំណែកលោកិយៈ សូម្បីក្នុងខណៈនៃមគ្គ ក៏ជាសមាធិប៉ុណ្ណោះ ។

ក្នុងធម៌ទាំង ៨ យ៉ាងនេះ ព្រះមានព្រះភាគទ្រង់ត្រាស់សម្ដែងសម្មាទិដ្ឋិទុកមុន , ព្រោះជាធម៌មានឧបការៈច្រើនដល់

ព្រះយោគាវចរអ្នកបដិបត្តិដើម្បីដល់ព្រះនិព្វាន ។ ព្រោះសម្មាទិដ្ឋិនេះ លោកពោលថា **បញ្ញា បជ្ជោតោ បញ្ញាសត្ថំ** បញ្ញាជាគ្រឿងបំភ្លឺ ឬដូចជាសស្ត្រា ។ ដូច្នោះ ព្រះយោគាវចរកម្ចាត់កាពងងឹត គឺ អវិជ្ជា ដោយសម្មាទិដ្ឋិ ពោលគឺ វិបស្សនាញាណនោះ ក្នុងចំណែកខាងដើម ហើយសម្លាប់ចោរ គឺ កិលេសបានរមែងដល់និព្វានដោយក្សេមក្សាន្ត ។ ព្រោះដូច្នោះ ព្រះមានព្រះ-ភាគជាម្ចាស់ ទើបទ្រង់សម្តែងសម្មាទិដ្ឋិ ទុកមុន ។

ចំណែកសម្មាសង្កប្បៈ មានឧបការៈច្រើនដល់សម្មាទិដ្ឋិនោះ , ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ទុកក្នុងលំដាប់តទៅ ដូចជាហិរញ្ញិកប្រើដៃត្រឡប់ទៅត្រឡប់មក មើលកហាបណៈដោយភ្នែក ក៏រមែងដឹងថា នេះក្លែងក្លាយ នេះមិនមែនក្លែងក្លាយយ៉ាងណា សូម្បីព្រះយោគាវចរក៏ដូច្នោះ ក្នុងចំណែកខាងដើមគិតហើយគិតទៀតដោយវិតក្កៈ សម្លឹងមើលដោយវិបស្សនាបញ្ញារមែងដឹងថា ធម៌ទាំងនេះជាកាមាវចរ , ទាំងនេះជារូបាវចរជាដើម ។ ឬដូចជាជាងឈើ យកពូថៅចាំងឈើធំដែលបុរសចាប់ត្រង់ខាងចុង ហើយត្រឡប់ទៅត្រឡប់មក ឲ្យនាំយកទៅប្រើប្រាសក្នុងការងារ



យ៉ាងណា ព្រះយោគាវចរក៏ដូច្នោះ កំណត់ធម៌ដែលវិតក្កៈត្រិះរិះទៅមកឲ្យដល់បញ្ញាហើយ ដោយន័យមានជាអាទិ៍ថា ធម៌ទាំងនេះជាកាមាវចរៈ ទាំងនេះជារូបាវចរៈជាដើម ហើយនាំចូលទៅក្នុងការងារ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ត្រាស់សម្មាសង្កប្បៈ ទុកក្នុងលំដាប់សម្មាទិដ្ឋិ ។ សម្មាសង្កប្បៈមានឧបការៈសូម្បីដល់សម្មាវាចា ដូចជាឧបការៈដល់សម្មាទិដ្ឋិ ដូច្នោះ ។ សមដូចដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ម្នាលគហបតីព្រះយោគាវចរត្រិះរិះក្នុងខាងដើមហើយ ទើបបន្លឺវាចាជាខាងក្រោយព្រោះដូច្នោះ ព្រះអង្គទើបត្រាស់សម្មាវាចាក្នុងលំដាប់នោះ ។

មួយទៀត ព្រោះជនទាំងឡាយចាត់ចែងការងាររដោយវាចាមុនថា យើងនឹងធ្វើវត្ថុនេះ ៗ ហើយទើបប្រកបការងារក្នុងលោកដូច្នោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់សម្មាកម្មន្តៈទុក ក្នុងលំដាប់របស់សម្មាវាចា ព្រោះវាចា មានឧបការៈដល់ការធ្វើផ្លូវកាយ ។

ក៏ព្រោះអាជីវមដ្ឋមកសីល សីលមានអាជីវៈជាទី ៨ រមែងបរិបូរណ៍ ដល់អ្នកលះបង់វចីទុច្ចរិត ៤ យ៉ាង កាយទុច្ចរិត ៣

យ៉ាង ហើយបំពេញសុចរិតទាំងពីរ មិនបរិបូរណ៍ដល់អ្នកបំពេញក្រៅអំពីនេះ ដូច្នោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ សម្មា-អាជីវៈទុក ក្នុងលំដាប់តអំពីទាំងពីរនោះ ។

អ្នកមានអាជីវៈបរិសុទ្ធិ មិនគួរធ្វើសេចក្តីត្រេកអរដោយហេតុត្រឹមតែប៉ុណ្ណោះថា អាជីវៈរបស់យើងបរិសុទ្ធិ ហើយនៅដោយសេចក្តីវង្វេង និងសេចក្តីប្រមាទយ៉ាងនេះ , ការពិតគួរប្រារព្ធសេចក្តីព្យាយាមនេះ គ្រប់ឥរិយាបថ , ព្រះមានព្រះភាគជាម្ចាស់ កាលទ្រង់ត្រាស់សម្តែងដោយប្រការដូច្នេះ ទើបត្រាស់សម្មាវាយាមៈទុក ក្នុងលំដាប់តពីនោះ ។

តពីនោះ ព្រះមានព្រះភាគទ្រង់សម្តែងថា អ្នកដែលប្រារព្ធសេចក្តីព្យាយាម គួរធ្វើការតាំងសតិឲ្យមាំទុកក្នុងវត្ថុ ៤ យ៉ាងមានកាយជាដើម ទើបត្រាស់សម្មាសតិទុកក្នុងលំដាប់តពីនោះ ។

ព្រោះកាលសតិតាំងមាំល្អយ៉ាងនេះហើយ ចិត្តក៏ស្វែងរកគតិនៃធម៌ដែលចម្រើន និងមិនចម្រើនដល់សមាធិ រមែងគ្រប់គ្រាន់ដើម្បីតាំងមាំក្នុងអារម្មណ៍ គឺ ភាពតែមួយ ដូច្នោះគប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកសម្មាសមាធិ ក្នុងលំដាប់



តពីសម្មាសតិ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សម្មាទិដ្ឋិនិទ្ទេស** ដូចតទៅ ៈ-

ព្រះសារីបុត្តសម្តែងចតុសច្ចកម្មដ្ឋាន មានជាអាទិ៍ថា **ទុក្ខេ ញាណំ** ដូច្នេះ ។

បណ្តាសច្ចៈទាំង ៤ នោះ សច្ចៈ ២ ខាងដើមជាវដ្តៈ , ២ ខាងក្រោយជាវិវដ្តៈ ។ ក្នុងសច្ចៈទាំងនោះ ការប្រកាន់មាំក្នុងកម្មដ្ឋានជាវដ្តៈ រមែងមានដល់ភិក្ខុ ការប្រកាន់មាំក្នុងវិវដ្តៈ រមែងមិនមាន ។ ព្រោះព្រះយោគាវចររៀនសច្ចៈ ២ ខាងដើម ក្នុងសម្នាក់អាចារ្យដោយសង្ខេបយ៉ាងនេះថា **បញ្ចក្ខន្ធា ទុក្ខំ , តណ្ហា សមុទយោ** ខន្ធ ៥ ជាទុក្ខ តណ្ហាជាហេតុឲ្យកើតទុក្ខ , និងដោយពិស្តារថា **កតមេ បញ្ចក្ខន្ធា , រូបក្ខន្ធោ** ខន្ធ ៥ ដូចម្តេច , គឺរូបក្ខន្ធជាដើម ហើយទន្ទេញត្រឡប់ទៅមករឿយ ៗ ដោយវាចារមែងធ្វើកម្ម ។ ចំណែកសច្ចៈ ២ ក្រៅអំពីនេះ ព្រះយោគាវចរធ្វើកម្ម ដោយការស្តាប់ប៉ុណ្ណោះ យ៉ាងនេះថា **និរោធសច្ចំ ឥដ្ឋំ កន្តំ មនាបំ , មគ្គសច្ចំ ឥដ្ឋំ កន្តំ មនាបំ** និរោធសច្ច គួរត្រូវការ គួរប្រាថ្នា គួរពេញចិត្ត , មគ្គសច្ច គួរត្រូវការ គួរប្រាថ្នា

គួរពេញចិត្ត ។ ព្រះយោគាវចរនោះ កាលបើធ្វើកម្មយ៉ាងនេះ រមែងសម្រេចសច្ចៈ ៤ ដោយការសម្រេចមួយដង រមែងត្រាស់ដឹងដោយការត្រាស់ដឹងមួយដង ដូចគ្នា ។ រមែងចាក់ធ្លុះទុក្ខ ព្រោះការចាក់ធ្លុះដោយបរិញ្ញា រមែងសម្រេចសមុទ័យ ព្រោះការចាក់ធ្លុះដោយបហានៈ រមែងចាក់ធ្លុះនិរោធ ព្រោះការចាក់ធ្លុះដោយសច្ឆិ-កិរិយា , រមែងចាក់ធ្លុះមគ្គ ព្រោះការចាក់ធ្លុះដោយភាវនា ។ រមែងត្រាស់ដឹងទុក្ខ ព្រោះការត្រាស់ដឹង ដោយបរិញ្ញា ។ល។ រមែងត្រាស់ដឹងមគ្គ ព្រោះការត្រាស់ដឹងដោយភាវនា ។

ការចាក់ធ្លុះដោយការរៀន ការសាកសួរ ការស្តាប់ ការចាំទុក និងការពិចារណាក្នុងសច្ចៈ ២ ក្នុងចំណែកខាងដើម រមែងមានដល់ភិក្ខុនោះ , ក្នុងសច្ចៈ ២ រមែងមានការចាក់ធ្លុះ ដោយការស្តាប់តែម្យ៉ាង ។ ចំណែកដទៃ រមែងមានការចាក់ធ្លុះដោយកិច្ចក្នុងសច្ចៈ ៣ រមែងមានការចាក់ធ្លុះដោយអារម្មណ៍ក្នុងនិរោធ ។ ក្នុងសច្ចៈទាំងនោះ ការដឹងដោយការចាក់ធ្លុះ សូម្បីទាំងអស់ជាលោកុត្តរៈ , ការដឹងដោយការស្តាប់ ការចាំទុក និងការពិចារណាជាលោកិយកាមាវចរ ចំណែកការពិចារណា រមែងមានដល់មគ្គ-



សច្ចៈ នេះជាអាទិកម្មិកកម្មខាងដើម ។ ព្រោះដូច្នោះ លោកទើបមិនពោលការពិចារណាទុកក្នុងទីនេះ ។ មួយទៀត ការពិចារណាដោយការផ្តោតចិត្ត ការរួបរួម ការធ្វើទុកក្នុងចិត្តថា **យើងដឹងទុក្ខ យើងលះសមុទ័យ យើងធ្វើឲ្យជាក់ច្បាស់និរោធ យើងចម្រើនភាវនា** យ៉ាងនេះ រមែងមិនមានដល់ភិក្ខុនេះអ្នកកំណត់ទុកមុន ។ រមែងមានបានតាំងពីខណៈកំណត់ ។ ចំណែកជាខាងក្រោយ **ទុក្ខ** ភិក្ខុកំណត់ដឹងហើយ ។ល។ **មគ្គ** ភិក្ខុចម្រើនហើយ ។ ក្នុងសច្ចៈទាំងនោះ សច្ចៈ ២ ជ្រាលជ្រៅ ព្រោះឃើញបានលំបាក , សច្ចៈ ២ ឃើញបានលំបាក ព្រោះមានជម្រៅ ។ ពិតហើយ ទុក្ខសច្ចៈកើតប្រាកដ , ក្នុងខណៈត្រូវជន្លត់ និងបន្ទាចាក់មុតជាដើម ក៏ស្រែកថ្ងូរថា អូយ ! ឈឺចាប់ណាស់ ។ សមុទយសច្ចៈកើតប្រាកដ ដោយប្រាថ្នានឹងទំពាស៊ីជាដើម , សច្ចៈសូម្បីទាំង ២ ឈ្មោះថា ជ្រាលជ្រៅ ព្រោះត្រូវចាក់ធ្លុះ ដោយលក្ខណៈ ។ សច្ចៈទាំងនោះឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានលំបាកដោយប្រការដូច្នេះ ។ ការប្រកបសេចក្តីព្យាយាម ដើម្បីឃើញសច្ចៈ ២ យ៉ាងក្រៅពីនោះ ក៏ដូចឈោងដៃ ដើម្បីចាប់យកភវគ្គព្រហ្ម ឬដូចយក

ដើរលុកឲ្យប៉ះសម្ផស្សអវិចី និងដូចការទល់ចុងរោមទ្រាយ ដែលចែកដោយរយចំណែក ដោយចុងរោមទ្រាយ ។ សច្ចៈទាំងនោះឈ្មោះថា ឃើញបានលំបាក ព្រោះជ្រាលជ្រៅ ដោយប្រការដូច្នេះ ។

ព្រះសារីបុត្ត ពោលបទមានជាអាទិ៍ថា **ទុក្ខេ ញាណំ** នេះមានន័យដល់ការកើតនៃញាណដែលជាចំណែកខាងដើម ដោយការរៀនជាដើម ។ ក្នុងសច្ចៈ ៤ ឈ្មោះថា ជ្រាលជ្រៅ ព្រោះឃើញបានលំបាក និងឈ្មោះថា ឃើញបានលំបាក ព្រោះមានជម្រៅតែក្នុងខណៈចាក់ធ្លុះ ញាណនោះមានតែម្យ៉ាងប៉ុណ្ណោះ ។

ចំណែកអាចារ្យពួកដទៃពោលថា ញាណក្នុងសច្ចៈទាំងឡាយមាន ៤យ៉ាង គឺ **សុតមយញ្ញាណ** ញាណកើតពីការ ស្តាប់ ១ , **វវត្ថានញ្ញាណ** ញាណកើមកពីការកំណត់១ , **សម្មសនញ្ញាណ** ញាណកើតមកអំពីការពិចារណា **អភិសមយញ្ញាណ** ញាណកើតមកអំពីការត្រាស់ដឹង ១ ។

ក្នុងញាណទាំងនោះ **សុតមយញ្ញាណ** ដូចម្តេច ? ព្រះ-យោគីវចរស្តាប់សច្ចៈ ៤ ដោយសង្ខេប ឬដោយពិស្តារ រមែងដឹងថា នេះទុក្ខ , នេះសមុទយ , នេះនិរោធ , នេះមគ្គ , នេះ



ឈ្មោះថា **សុតមយញ្ញាណ** ។

**វវត្ថានញ្ញាណ** ដូចម្តេច ? ព្រះយោគាវចរនោះ រមែងកំណត់ខ្លឹមសាររបស់ការស្តាប់ដោយធម្មតា និងដោយលក្ខណៈ រមែងយល់ឃើញថា ធម៌ទាំងនេះរាប់បញ្ចូលក្នុងសច្ចៈនេះ នេះជាលក្ខណៈរបស់សច្ចៈនេះ នេះឈ្មោះថា **វវត្ថានញ្ញាណ** ។

**សម្មសនញ្ញាណ** ដូចម្តេច ? ព្រះយោគាវចរនោះ កំណត់សច្ចៈ ៤ តាមលំដាប់យ៉ាងនេះហើយ កាន់យកតែទុក្ខប៉ុណ្ណោះ រមែងពិចារណាតទៅដល់គោត្រភូញាណ ដោយភាពមិនទៀង ជាទុក្ខ ជាអនត្តា នេះឈ្មោះថា **សម្មសនញ្ញាណ** ។

**អភិសមយញ្ញាណ** ដូចម្តេច ? ព្រះយោគាវចរនោះត្រាស់ដឹងសច្ចៈ ៤ ដោយញាណមួយ ក្នុងខណៈលោកុត្តរមគ្គមិនមុនមិនក្រោយ គឺ រមែងត្រាស់ដឹងទុក្ខ ដោយការត្រាស់ដឹងជាមួយការកំណត់ដឹង , រមែងត្រាស់ដឹង **សមុទយ** ដោយការត្រាស់ដឹងជាមួយនឹងការលះ , រមែងត្រាស់ដឹង **និរោធ** ដោយការត្រាស់ដឹងជាមួយការធ្វើឲ្យជាក់ច្បាស់ , រមែងត្រាស់ដឹងមគ្គដោយការត្រាស់ដឹងព្រមដោយការចម្រើន នេះឈ្មោះថា **អភិ-**

**សមយញ្ញាណ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សម្មាសង្កប្បនិទ្ទេស** ដូចតទៅនេះ

ឈ្មោះថា **នេក្ខម្មសង្កប្បោ** ព្រោះអត្ថថាចេញចាក **កាម** ។

ឈ្មោះថា **អព្យាបាទសង្កប្បោ** ព្រោះអត្ថថា ចេញចាកអំពី **ព្យាបាទ** ។

ឈ្មោះថា **អវិហិង្សាសង្កប្បោ** ព្រោះអត្ថថា ចេញចាកអំពី **វិហិង្សា** ។

ក្នុងវិតក្កទាំងនោះ **នេក្ខម្មវិតក្ក** ធ្វើការកម្ចាត់ហេតុ កាត់ផ្តាច់ហេតុរបស់ **កាមវិតក្ក** កើតឡើង , **អព្យាបាទវិតក្ក** ធ្វើការកម្ចាត់ហេតុ កាត់ផ្តាច់ហេតុរបស់ **ព្យាបាទវិតក្ក** កើតឡើង , **អវិហិង្សាវិតក្ក** ធ្វើការកម្ចាត់ហេតុ កាត់ផ្តាច់ហេតុ របស់ **វិហិង្សាវិតក្ក** កើតឡើង , មួយទៀត នេក្ខម្មវិតក្កៈ អព្យាបាទ-វិតក្កៈ អវិហិង្សាវិតក្កៈ ជាសត្រូវរបស់កាមវិតក្កៈ ព្យាបាទវិតក្កៈ និងវិហិង្សាវិតក្កៈ កើតឡើង ។

ក្នុងវិតក្កៈទាំងនោះ ព្រះយោគាវចររមែងពិចារណាកាម-វិតក្កៈ ឬសង្ខារឯណានីមួយ ដើម្បីកម្ចាត់ហេតុនៃកាមវិតក្កៈ ។



មយ៉ាងទៀត ការត្រិះរិះសម្បយុត្តដោយវិបស្សនា ក្នុងខណៈនៃវិបស្សនារបស់ព្រះយោគាវចរនោះ ធ្វើការកម្ចាត់ហេតុ កាត់ផ្តាច់ហេតុរបស់កាមវិតក្កៈ ដោយអំណាចតទង្គៈ មួយខណៈនោះកើតឡើង , ព្រះយោគាវចរខ្វល់ខ្វាយក្នុងវិបស្សនាហើយ ទើបសម្រេចមគ្គ ។ មយ៉ាងវិញទៀត កាត្រិះរិះសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គរបស់ព្រះយោគាវចរនោះ ធ្វើការកម្ចាត់ហេតុ , កាត់ផ្តាច់ហេតុរបស់កាមវិតក្កៈដោយសមុច្ឆេទៈ ការកាត់ផ្តាច់ដោយដាច់ខាតរមែងកើតឡើង ។ ព្រះយោគាវចររមែងពិចារណា ព្យាបាទវិតក្កៈ ឬសង្ខារដទៃ ដើម្បីកម្ចាត់បង់ហេតុនៃព្យាបាទវិតក្កៈ , ពិចារណាវិហិង្សាវិតក្កៈ ឬសង្ខារដទៃ ដើម្បីកម្ចាត់បង់ហេតុនៃវិហិង្សាវិតក្កៈ ។ មួយវិញទៀត គប្បីប្រកបបទទាំងពួងថា **អស្ស វិបស្សនាក្ខណេ** ក្នុងខណៈនៃវិបស្សនារបស់ព្រះយោគាវចរនោះ ដូចន័យមុននោះឯង ។

ក៏កាលចែកអារម្មណ៍ ៣៨ ទុកក្នុងបាលី សូម្បីកម្មដ្ឋានណាមួយ ឈ្មោះថា មិនជាសត្រូវដល់វិតក្កៈសូម្បីទាំង ៣ មានកាមវិតក្កៈជាដើម រមែងមិនមាន ។ បឋមជ្ឈានក្នុងអសុភៈនោះឯង

ជាសត្រូវរបស់កាមវិតក្កៈតែម្យ៉ាង ។ ឈានពួក ៣ ពួក ៤ នៃមេត្តា ជាសត្រូវរបស់ព្យាបាទវិតក្កៈ , ឈានពួក ៣ ពួក ៤ នៃករុណា ជាសត្រូវរបស់វិហិង្សាវិតក្កៈ ។ កាលបើព្រះយោគាវចរនោះ ធ្វើការបរិកម្មអសុភៈ ហើយចូលឈាន វិតក្កសម្បយុត្តដោយឈានក្នុងខណៈនៃការចូលសមាបត្តិ ជាសត្រូវរបស់កាមវិតក្កៈដោយអំណាចនៃវិក្ខម្ភនៈ ការគ្របសង្កត់ទុក ក៏កើតឡើង ។ កាលបើព្រះយោគាវចរ ធ្វើឈានឲ្យជាបាទ ហើយផ្ដើមតាំងវិបស្សនា ការត្រិះរិះសម្បយុត្តដោយវិបស្សនា ក្នុងខណៈនៃវិបស្សនា ជាសត្រូវរបស់កាមវិតក្កៈដោយអំណាចតទង្គៈនោះ កើតឡើង ។ កាលបើព្រះយោគាវចរខ្វល់ខ្វាយក្នុងវិបស្សនាហើយញុំាងមគ្គឲ្យសម្រេច ការត្រិះរិះសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គ ជាសត្រូវរបស់កាមវិតក្កៈដោយអំណាចសមុច្ឆេទប្បហាន ក៏រមែងកើតឡើង ។ ការត្រិះរិះដែលកើតឡើងយ៉ាងនេះ គប្បីជ្រាបលោកពោលថា **នេក្ខម្មសង្កប្បោ** ។

គប្បីជ្រាបបទទាំងពួងថា ព្រះយោគាវចរ ធ្វើការបរិកម្មដោយមេត្តា , ធ្វើការបរិកម្មដោយករុណា ហើយចូលឈាន ដូច



ន័យមុននោះឯង ។ សេចក្ដីត្រិះរិះដែលកើតឡើងយ៉ាងនេះ គប្បីជ្រាបថា លោកពោលថា **អព្យាបាទសង្កប្បោ អវិហិង្សាសង្កប្បោ** ។ នេក្ខម្មសង្កប្បោជាដើមទាំងនេះ ផ្សេងគ្នាក្នុងចំណែកខាងដើម ព្រោះការកើតឡើងផ្សេងគ្នាដោយអំណាចវិបស្សនា និងឈាន , តែការត្រិះរិះជាកុសលតែម្យ៉ាងប៉ុណ្ណោះ ញុំាងអង្គមគ្គឲ្យបរិបូណ៌ ដោយអំណាចធ្វើការមិនកើត ឲ្យសម្រេច ព្រោះលះបង់ហេតុនៃសេចក្ដីត្រិះរិះដែលជាអកុសល ដែលកើតឡើងក្នុងឋានៈ ៣ ទាំងនេះ ក្នុងខណៈនៃមគ្គកើតឡើង នេះឈ្មោះថា **សម្មាសង្កប្ប** ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សម្មាវាចានិទ្ទេស** ដូចតទៅនេះ ព្រោះភិក្ខុវៀរចាកមុសាវាទដោយចិត្តដទៃ វៀរចាកបិសុណាវាចាជាដើម ដោយចិត្តដទៃ ៗ ដូច្នោះ ការវៀរ ៤ យ៉ាងទាំងនេះ ទើបផ្សេងគ្នាក្នុងចំណែកខាងដើម , តែក្នុងខណៈនៃមគ្គ ការវៀរដែលជាកុសល ពោលគឺ សម្មាវាចាតែម្យ៉ាងប៉ុណ្ណោះ ញុំាងអង្គមគ្គ ៨ ឲ្យបរិបូណ៌ដោយអំណាចធ្វើភាពមិនកើត ឲ្យសម្រេចបាន ព្រោះលះបង់ចេតនាដែលជាអកុសល និងភាពជាអ្នកទ្រុស្តសីល ៤ យ៉ាង ពោលគឺ មិច្ឆាវាចា រមែងកើតឡើងនេះ ឈ្មោះថា

**សម្មាវាចា** ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សម្មាកម្មន្តនិទ្ទេស** ដូចតទៅនេះ ព្រោះភិក្ខុវៀរចាកបាណាតិបាតដោយចិត្តដទៃ វៀរចាកអទិន្នាទានដោយចិត្តដទៃ វៀរចាកមិច្ឆាចារដោយចិត្តដទៃ ព្រោះដូច្នោះការវៀរ ៣ យ៉ាងទាំងនេះ ទើបផ្សេងគ្នាក្នុងចំណែកខាងដើម តែក្នុងខណៈនៃមគ្គ ការវៀរដែលជាកុសល ពោលគឺ **សម្មាកម្មន្ត** តែម្យ៉ាង ញុំាងអង្គនៃមគ្គឲ្យបរិបូរណ៍ ដោយអំណាចធ្វើការមិនកើតឲ្យសម្រេច ព្រោះលះបង់ចេតនាដែលជាអកុសល និងភាពជាអ្នកទ្រុស្តសីល ៣ យ៉ាង ពោលគឺ **មិច្ឆាកម្មន្ត កើតឡើង** នេះឈ្មោះថា **សម្មាកម្មន្ត** ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សម្មាអាជីវនិទ្ទេស** ដូចតទៅនេះ បទថា **ឥធ** បានដល់ ក្នុងសាសនានេះ ។ បទថា **អរិយសាវកោ** បានដល់ សាវករបស់ព្រះពុទ្ធជាម្ចាស់ដែលជាអរិយៈ ។ បទថា **មិច្ឆាអាជីវំ បហាយ** បានដល់ លះបង់អាជីវៈដែលលាមក ។ បទថា **សម្មាអាជីវេន** បានដល់ អាជីពដែលល្អដែលព្រះពុទ្ធជាម្ចាស់ទ្រង់សរសើរ ។ បទថា **ជីវិតំ កប្បេតិ** សម្រេចការរស់នៅ



បានដល់ ញុំាងការប្រព្រឹត្តទៅរបស់ជីវិតឲ្យប្រព្រឹត្តទៅ ។

ព្រោះភិក្ខុក្នុងសាសនានេះ វៀរចាកការកន្លងផ្លូវកាយទ្វារដោយចិត្តដទៃ វៀរចាកការកន្លងផ្លូវវចីទ្វារដោយចិត្តដទៃ ដូច្នោះ អាជីវៈ រមែងកើតឡើងក្នុងខណៈផ្សេង ៗ គ្នា ក្នុងចំណែកខាងដើម តែក្នុងខណៈនៃមគ្គ ការវៀរដែលជាកុសល ពោលគឺ សម្មាអាជីវៈមានតែម្យ៉ាង ញុំាងអង្គនៃមគ្គឲ្យបរិបូរណ៍ ដោយអំណាចធ្វើការមិនកើត ឲ្យសម្រេច ព្រោះលះបង់ចេតនា ដែលជាមិច្ឆាអាជីវៈ និងភាពជាអ្នកទ្រុស្តសីល ដែលកើតឡើង ដោយអំណាចកម្មបថ ៧ ក្នុងទ្វារ ២ កើតឡើង ឈ្មោះថា **សម្មាអាជីវ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សម្មាវាយាម** និទ្ទេសដូចតទៅនេះ បទថា **ឥធ ភិក្ខុ** បានដល់ ភិក្ខុអ្នកបដិបត្តិក្នុងសាសនានេះ ។

បទថា **អនុប្បន្នានំ** បានដល់ នៅមិនទាន់កើត ។ បទថា **បាបកានំ** បានដល់ លាមក ។ បទថា **អកុសលានំ ធម្មានំ** បានដល់ ធម៌ដែលជាអកុសល ។ បទថា **អនុប្បាទាយ** បានដល់ ដើម្បីមិនឲ្យកើតឡើង ។

បទថា **ឆន្ទំ ជនេតិ** រមែងញុំាងឆន្ទៈឲ្យកើតឡើង បានដល់

ញុំាងឆន្ទៈក្នុងកុសល ពោលគឺ ភាពជាអ្នកត្រូវការធ្វើឲ្យកើត គឺឲ្យកើតឡើង ។ បទថា **វាយមតិ** រមែងព្យាយាម បានដល់ ញុំាងសេចក្ដីព្យាយាមឲ្យកើត គឺ ធ្វើសេចក្ដីព្យាយាម ។ បទថា **វីរិយំ អារភតិ** ប្រារព្ធសេចក្ដីព្យាយាម បានដល់ ធ្វើសេចក្ដីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ។ បទថា **ចិត្តំ បគ្គណ្ហាតិ** ផ្គងចិត្ត បានដល់ លើកចិត្តឡើងដោយសេចក្ដីព្យាយាមដែលរួមគ្នានោះ ៗ ឯង ។ បទថា **បទហតិ** តាំងចិត្តទុក បានដល់ ធ្វើសេចក្ដីព្យាយាមជាទីតាំង ។ គប្បីប្រកបបទ ៤ បទទាំងនេះ ដោយ **អាសេវនា** ការសេព , **ភាវនា** ការចម្រើន , **ពហុលិកម្ម** ការធ្វើឲ្យច្រើន , **សាតច្ចកិរិយា** ការធ្វើជាប់តគ្នា តាមលំដាប់តទៅ ។

បទថា **ឧប្បន្នានំ** ដែលកើតឡើងហើយ បានដល់ ដល់ការមិនគួរនឹងពោលថា **អនុប្បន្នានំ** ដែលនៅមិនកើត ។ បទថា **បហានាយ** បានដល់ ដើម្បីលះបង់ , បទថា **អនុប្បន្នានំ កុសលានំ ធម្មានំ** បានដល់ កុសលធម៌ដែលនៅមិនទាន់កើត ។

បទថា **ឧប្បាទាយ** បានដល់ ដើម្បីឲ្យកើតឡើង ។ បទថា **ឧប្បន្នានំ** បានដល់ ដែលកើតឡើងហើយ ។ បទថា **ឋិតិយា**



បានដល់ ដើម្បីការតាំងមាំ ។ បទថា **អសម្មោសាយ** ដោយការមិនវេសមវសាម បានដល់ ដើម្បីសេចក្ដីមិនវិនាស ។ បទថា **ភិយ្យោភាវាយ** ដើម្បីការចម្រើនដ៏ក្រៃលែង បានដល់ ការចម្រើនរឿយ ៗ ។ បទថា **វេបុល្លាយ** បានដល់ ដើម្បីភាពទូលំទូលាយ ។ បទថា **ភាវនាយ** បានដល់ សេចក្ដីចម្រើន ។ បទថា **បារិបូរិយា** បានដល់ ដើម្បីភាពបរិបូរណ៍ ។

ក៏សម្មប្បធាន ៤ ដែល បានដល់ **សម្មាវាយាម** ទាំងនេះ ជាលោកិយៈក្នុងចំណែកខាងដើម ជាលោកុត្តរៈក្នុងខណៈនៃមគ្គ ។ តែក្នុងខណៈនៃមគ្គ សេចក្ដីព្យាយាមតែម្យ៉ាងប៉ុណ្ណោះ រមែងបានឈ្មោះ ៤ យ៉ាង ដោយអំណាចធ្វើកិច្ច ៤ យ៉ាង ឲ្យសម្រេច ។

ក្នុងសម្មប្បធានទាំងនោះ គប្បីជ្រាបសមម្មប្បធាន ដែលជាលោកិយៈ ដោយន័យដែលលោកពោលទុកក្នុងកស្សបសំយុត្តនោះឯង ។ ក្នុងកស្សបសំយុត្តនោះលោក ពោលទុកថា ៖-

ម្នាលអ្នកមានអាយុ សម្មប្បធាន ៤
ទាំងនេះ ។ សម្មប្បធាន ៤ ដូចម្ដេច ? ម្នាល
អាវុសោ ភិក្ខុក្នុងសាសនានេះធ្វើការព្យាយាម

> ថា អកុសលធម៌ដ៏លាមក នៅមិនទាន់កើតដល់យើង កាលបើកើតគប្បីប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស , ភិក្ខុធ្វើការព្យាយាមថា អកុសលធម៌ដ៏លាមកកើតឡើងហើយដល់យើង កាលបើនៅលះបង់មិនបាន គប្បីប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស , ភិក្ខុធ្វើការព្យាយាមថា កុសលធម៌នៅមិនទាន់កើតឡើងដល់យើង កាលបើមិនកើតឡើង នឹងគប្បីប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស , ភិក្ខុធ្វើសេចក្ដីព្យាយាមថា កុសលធម៌កើតឡើងហើយដល់យើង កាលបើរលត់ទៅ គប្បីប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាស ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អនុប្បន្នា** បានដល់ កិលេសដែលនៅមិនទាន់កើត ដោយការមិនប្រាកដ ឬដោយអារម្មណ៍ដែលនៅមិនទាន់កើត ។ អកុសលធម៌ដ៏លាមក ដែលនៅមិនទាន់កើតក្នុងសង្សារ ដែលមិនដឹងខាងដើម និងទីបំផុតដោយប្រការដទៃ រមែងមិនមាន , អកុសលធម៌ទាំងនេះនោះឯង ដែលនៅមិន



ទាន់កើត សូម្បីកាលបើកើត ក៏រមែងកើត , សូម្បីកាលបើលះបង់ ក៏រមែងលះបង់បាន ។

ក្នុងបទនោះ កិលេសទាំងឡាយរមែងមិនប្រាកដ ដោយអំណាច **វត្ត គន្ថៈ ធុតង្គ សមាធិ វិបស្សនា នវកម្ម និងភព** យ៉ាងណាមួយដល់ភិក្ខុអង្គខ្លះ ។ សួរថា យ៉ាងណា ? ឆ្លើយថា ព្រោះភិក្ខុអង្គខ្លះ ជាអ្នកដល់ព្រមហើយដោយវត្ត , កិលេសទាំងឡាយមិនបានឱកាសដល់ភិក្ខុអ្នកប្រព្រឹត្តខន្ធកវត្ត ៨០ មហាវត្ត ១៤ និងចេតិយង្គណវត្ត ការបូជាលានចេតិយ , ពោធិយង្គណវត្ត ការបូជាលានព្រះពោធិ , បានីយមាឡកវត្ត តាំងទឹកផឹកទុកក្នុងផ្ទះកំពូល , ឧបោសថាគារវត្ត បដិបត្តិក្នុងរោងឧបោសថ , អាគន្តុកវត្ត ទទួលភិក្ខុដែលនិមន្តមក , គមិកវត្ត បដិបត្តិចំពោះភិក្ខុត្រៀមនឹងចេញទៅ តែក្រោយមក បើភិក្ខុនោះលះបង់វត្តទាំងឡាយ ទម្លាយវត្តហើយត្រាច់ទៅ កិលេសទាំងឡាយអាស្រ័យការមិនធ្វើទុកក្នុងចិត្តដោយល្អ និងការមិនមានសតិ រមែងកើតឡើងបាន ។ សូម្បីដោយប្រការដូច្នេះ កិលេសទាំងឡាយដែលនៅមិនទាន់កើត នៅមិនទាន់ប្រាកដ ឈ្មោះថា រមែងកើត ។

ភិក្ខុអង្គខ្លះជាអ្នកប្រកបដោយគន្ថៈ រមែងរៀននិកាយ ១ ខ្លះ ២ និកាយខ្លះ ៣ និកាយខ្លះ ៤ និកាយខ្លះ ៥ និកាយខ្លះ ។ កិលេសទាំងឡាយ រមែងមិនបានឱកាសដល់ភិក្ខុនោះ អ្នករៀនទន្ទេញ ប្រាប់ គិត សម្តែង ពន្យល់ នូវព្រះត្រៃបិដកដែលជាពុទ្ធវចនៈ ដោយបាលី ដោយអនុសន្ធិ ដោយបទដើម បទចុង ។ តែក្រោយមក កាលបើភិក្ខុនោះលះការរៀនគម្ពីរ ខ្ជិលច្រអូសដើរលេង កិលេសទាំងឡាយដែលមិនអាស្រ័យការធ្វើទុកក្នុងចិត្តដោយល្អ ការបណ្តែតបណ្តោយសតិ រមែងកើតឡើងបាន ។ សូម្បីដោយប្រការដូច្នេះ កិលេសទាំងឡាយដែលនៅមិនទាន់កើត នៅមិនទាន់ប្រាកដ ឈ្មោះថា រមែងមិនកើតឡើង ។

ភិក្ខុអង្គខ្លះជាអ្នកទ្រទ្រង់ធុតង្គ បដិបត្តិធុតង្គគុណ ១៣ កិលេស រមែងមិនមានឱកាសដល់ភិក្ខុនោះអ្នកបដិបត្តិធុតង្គគុណ តែក្រោយមក ភិក្ខុនោះលះបង់ធុតង្គចេញ វិលមកប្រាថ្នាច្រើនដើរលេង កិលេសទាំងឡាយ អាស្រ័យការមិនយកចិត្តទុកដាក់ ការបណ្តែតបណ្តោយសតិ រមែងកើតឡើង ។ សូម្បីដោយប្រការដូច្នេះ កិលេសទាំងឡាយដែលមិនទាន់កើត នៅមិនទាន់ប្រាកដ



ឈ្មោះថា រមែងមិនកើតឡើង ។

ភិក្ខុអង្គខ្លះជាអ្នកចម្រើនវិបស្សនា បដិបត្តិក្នុងអនុបស្សនា ៧ ឬមហាវិបស្សនា ១៨ កាលបើភិក្ខុនោះបដិបត្តិយ៉ាងនេះ កិលេសទាំងឡាយ រមែងមិនបានឱកាស ។ តែក្រោយមក កាលបើភិក្ខុឈប់ចម្រើនវិបស្សនា ដោយការប្រកាន់មាំនូវកាមកិលេសទាំងឡាយ អាស្រ័យការមិនយកចិត្តទុកដាក់ ការមិនមានសតិ រមែងកើតឡើង ។ សូម្បីដោយប្រការដូច្នេះ កិលេសទាំងឡាយដែលនៅមិនទាន់កើត នៅមិនទាន់ប្រាកដ ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុអង្គខ្លះជានវកម្មិកៈ ធ្វើការកសាងរោងឧបោសថ និងរោងឆាន់ជាដើម កាលបើភិក្ខុនោះ គិតដល់ឧបករណ៍ការកសាងរោងឧបោសថ និងរោងឆាន់ទាំងនោះ កិលេសទាំងឡាយ ក៏មិនបានឱកាស តែក្រោយមក កាលបើនវកម្មរបស់ភិក្ខុសម្រេចហើយ ឬបោះបង់ចោល កិលេសទាំងឡាយអាស្រ័យ ការមិនយកចិត្តទុកដាក់ ការមិនមានសតិ រមែងកើតឡើង ។ សូម្បីដោយប្រការដូច្នេះ កិលេសទាំងឡាយ ដែលមិនទាន់កើត នៅមិនទាន់ប្រាកដ ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុអង្គខ្លះមកពីព្រហ្មលោក ជាសត្វបរិសុទ្ធ កិលេសទាំងឡាយ រមែងមិនបានឱកាស ដោយការមិនធ្លាប់សេពរបស់ភិក្ខុនោះ , តែក្រោយមក កាលបើភិក្ខុនោះ សេពវត្ថុដែលបានមក កិលេសទាំងឡាយ ដែលអាស្រ័យការមិនធ្វើទុកក្នុងចិត្តដោយល្អ ការមិនមានសតិរបស់ភិក្ខុនោះ រមែងកើតឡើង ។ សូម្បីដោយប្រការដូច្នេះ កិលេសទាំងឡាយដែលនៅមិនទាន់កើត នៅមិនទាន់ប្រាកដ ឈ្មោះថា រមែងកើតឡើង ។ គប្បីជ្រាប កិលេសនៅមិនទាន់កើត នៅមិនទាន់ប្រាកដ យ៉ាងនេះ ។

កិលេសនៅមិនទាន់កើត ដោយអារម្មណ៍ដែលមិនធ្លាប់កើត យ៉ាងណា ? ភិក្ខុអង្គខ្លះក្នុងសាសនានេះ បានអារម្មណ៍ដែលគួរពេញចិត្តជាដើម ដែលមិនធ្លាប់កើតមកអំពីមុន , កិលេសទាំងឡាយមានរាគៈជាដើម អាស្រ័យការមិនធ្វើទុកក្នុងចិត្តដោយល្អ ការមិនមានសតិរបស់ភិក្ខុនោះ រមែងកើតឡើង ។ ដោយប្រការដូច្នេះ កិលេសទាំងឡាយដែលនៅមិនទាន់កើតឡើង ដោយអារម្មណ៍ដែលមិនធ្លាប់កើត ឈ្មោះថា រមែងកើតឡើង កាលបើមានអកុសលធម៌ដែលនៅមិនទាន់កើតឡើងយ៉ាងនេះ ភិក្ខុឃើញ



សេចក្ដីវិនាសរបស់ខ្លួន រមែងចម្រើនសម្មប្បធានប្រការខាងដើម ដោយចម្រើនសតិប្បដ្ឋាន ដើម្បីការមិនកើតឡើងនៃអកុសលធម៌ដែលនៅមិនទាន់កើតទាំងនោះ , កាលបើអកុសលធម៌ទាំងនោះកើត ។ ភិក្ខុឃើញសេចក្ដីវិនាសរបស់ខ្លួន ព្រោះមិនលះបង់អកុសលធម៌ទាំងនោះ ហើយទើបចម្រើនសម្មប្បធានប្រការ ទី ២ ដើម្បីលះបង់អកុសលធម៌ទាំងនោះ ។

បទថា **អនុប្បន្នា កុសលា ធម្មា** កុសលធម៌ដែលនៅមិនទាន់កើត បានដល់ សមថវិបស្សនា និងមគ្គ ។ ភិក្ខុឃើញការវិនាសរបស់ខ្លួន ព្រោះកុសលធម៌ទាំងនោះ ដែលនៅមិនទាន់កើតឡើង ហើយទើបចម្រើនសម្មប្បធានប្រការទី ៣ ដើម្បីឲ្យកុសលធម៌ទាំងនោះកើតឡើង ។

បទថា **ឧប្បន្នា កុសល ធម្មា** កុសលធម៌ដែលកើតឡើងហើយ បានដល់ សមថវិបស្សនានោះឯង ។ ចំណែកមគ្គ កើតតែម្ដងហើយរលត់ទៅ មិនប្រព្រឹត្តទៅដើម្បីសេចក្ដីវិនាសឡើយ ។ ព្រោះមគ្គនោះជាបច្ច័យដល់ផលហើយ ក៏រលត់ទៅ ។ ភិក្ខុកាលបើឃើញសេចក្ដីវិនាសរបស់ខ្លួន ព្រោះសមថៈ និងវិបស្សនាទាំងនោះ

រលត់ទៅ ទើបចម្រើនសម្មប្បធានប្រការទី ៤ ដើម្បីការតាំងមាំនៃសមថៈ និងវិបស្សនាទាំងនោះ ។ ក្នុងខណៈនៃលោកុត្តរមគ្គ រមែងចម្រើនវិរិយៈតែម្យ៉ាងប៉ុណ្ណោះ ។

ភិក្ខុរមែងញុំាងកិច្ច គឺ ការមិនកើតឡើងនៃអកុសលធម៌ទាំងនោះ ដែលនៅមិនទាន់កើតឡើង និងកិច្ច គឺ ការលះបង់អកុសលធម៌ដែលកើតឡើងហើយឲ្យសម្រេច ដូចដែលកុសលធម៌នៅមិនទាន់កើត គប្បីកើតឡើង ។

មួយទៀត ក្នុងបទថា **ឧប្បន្នា** នេះ ឧប្បន្នៈ គឺ ធម៌ដែលកើតឡើង មាន ៤ យ៉ាង គឺ ៖

**វត្តមានុប្បន្នំ** កើតឡើងកំពុងប្រព្រឹត្តទៅ ១

**ភូតាបគតុប្បន្នំ** កើតឡើងសេពអារម្មណ៍ហើយរលត់ទៅ ១

**ឱកាសកតុប្បន្នំ** កើតឡើងធ្វើឱកាស ១

**ភូមិលទ្ធុប្បន្នំ** កើតក្នុងភូមិដែលបាន ១

ក្នុងឧប្បន្នៈទាំងនោះ ធម៌ដែលកើតព្រមជាមួយ **ឧប្បទ ជរា ភង្គ** កើត ចាស់ ស្លាប់ ឈ្មោះថា **វត្តមានុប្បន្នំ** ។

កុសលាកុសល សោយសេអារម្មណ៍ហើយ រលត់ទៅ គឺ



សេពហើយក៏ប្រាស់ទៅ និងសង្ខតធម៌ដែលនៅសល់ ពោលគឺចូលដល់លក្ខណៈ ៣ មានឧប្បាទៈជាដើម ហើយរលត់ទៅ គឺសេពហើយ ប្រព្រឹត្តទូទៅហើយ ឈ្មោះថា **ភូតាបគតុប្បន្នំ** ។

ឈ្មោះថា **ឱកាសកតុប្បន្នំ** ព្រោះហាមកម្មដែលជាវិបាកដទៃដែលមាននៅ សូម្បីក្នុងអតីត ដូចដែលលោកពោលទុកដោយន័យមានជាអាទិ៍យ៉ាងនេះថា **កម្មដែលអ្នកនោះ បានធ្វើទុកហើយក្នុងជាតិមុន** ធ្វើឱកាសនៃបាបរបស់ខ្លួនតាំងនៅ និងព្រោះវិបាកដែលជាឱកាសដែលខ្លួនធ្វើទុកហើយយ៉ាងនោះ សូម្បីនៅមិនទាន់កើត ក៏នឹងកើតឡើងដោយពិតប្រាកដ ក្នុងឱកាសដែលខ្លួនធ្វើទុកយ៉ាងនោះ ។

អកុសលដែលនៅមិនទាន់ដកចេញ ក្នុងភូមិ ៣ នោះ ៗ ឈ្មោះថា **ភូមិលទ្ធុប្បន្នំ** ។

ក្នុងបទនេះគប្បីជ្រាបការខុសគ្នារបស់ **ភូមិ** និង **ភូមិលទ្ធ** ភូមិដែលបានហើយ ពិតហើយខន្ធ ៥ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ជាអារម្មណ៍នៃវិបស្សនា ឈ្មោះថា **ភូមិ** , កិលេសជាតដែលគួរកើតក្នុងខន្ធទាំងនោះ ឈ្មោះថា **ភូមិលទ្ធ** , ព្រោះហេតុដែល

កិលេសនោះបានភូមិ ដូច្នោះលោកទើបពោលថា **ភូមិលទ្ធ** , ភូមិនោះមិនបានដោយអារម្មណ៍ ។ ពិតហើយកិលេសទាំងឡាយប្រារព្ធខន្ធសូម្បីទាំងអស់ ទាំងក្នុងអតីត អនាគត និងសូម្បីដែលព្រះខីណាស្រពកំណត់ដឹងហើយ រមែងកើតឡើងដោយជាអារម្មណ៍ ។ ប្រសិនបើថា អារម្មណ៍នឹងគប្បីឈ្មោះថា **ភូមិលទ្ធ** ហើយ នរណា ៗ ក៏នឹងគប្បីលះបង់ឫសគល់របស់ភពមិនបាន ព្រោះលះបង់ **ភូមិលទ្ធ** នោះ មិនបាន ។ មួយទៀត គប្បីជ្រាប **ភូមិលទ្ធ** ដោយអំណាចវត្ថុ ពិតហើយ ខន្ធដែលកំណត់ដឹងមិនបានដោយវិបស្សនាក្នុង **ភូមិលទ្ធ** ណា ៗ , កិលេសជាតដែលជាឫសគល់នៃវដ្ដៈ ចាប់ផ្ដើមពីក្នុង **ភូមិលទ្ធ** នោះ រមែងដេកត្រាំនៅក្នុងខន្ធនោះ ។ គប្បីជ្រាបថា **កិលេសជាត** នោះ ឈ្មោះថា **ភូមិលទ្ធ** ដោយអត្ថថា នៅលះបង់មិនទាន់បាន ។

ក្នុងបទនោះ មានសេចក្ដីថា ខន្ធទាំងឡាយរបស់អ្នកមានកិលេសដេកសម្ងំហើយ ដោយអត្ថថា នៅលះបង់មិនបាន ជាទីតាំងនៃកិលេសទាំងនោះ ។ ខន្ធទាំងឡាយមិនមែនរបស់អ្នកដទៃ , មួយវិញទៀត ខន្ធក្នុងអតីត ជាទីតាំងរបស់កិលេសដែលនៅលះបង់



មិនបាន នឹងដេកសម្ងំក្នុងខន្ធអតីត ។ ខន្ធក្រៅពីនេះ មិនជាទីតាំង ខន្ធក្នុងអនាគតជាដើម ក៏មានន័យនេះ ។ មួយទៀត កាមាវចរ-ក្ខន្ធនោះឯង ជាទីតាំងរបស់កិលេសដែលនៅលះបង់មិនបាន នឹងដេកសម្ងំនៅក្នុងកាមាវចរក្ខន្ធ , ខន្ធក្រៅពីនេះ មិនជាទីតាំង ។ ក្នុងរូបាវចរក្ខន្ធ និងអរូបាវចរក្ខន្ធ ក៏មានន័យនេះដូចគ្នា ។ មួយវិញទៀត ក្នុងសោតាបន្នជាដើម កិលេសជាតដែលជាមូលនៃវដ្ដៈនោះ ៗ ក្នុងខន្ធរបស់ព្រះអរិយបុគ្គលណា ៗ លះបង់បានដោយមគ្គនោះ ៗ , ខន្ធទាំងនោះ របស់ព្រះអរិយបុគ្គលនោះ ៗ មិនរាប់ថា **ភូមិ** ព្រោះមិនជាទីតាំងនៃកិលេស ដែលជាមូលរបស់វដ្ដៈទាំងនោះ ដែលលះបានហើយ ។ កុសលកម្ម ឬអកុសលកម្មណាមួយ ដែលបុគ្គលធ្វើ រមែងមានដល់បុថុជ្ជន ដោយប្រការទាំងពួង ព្រោះនៅលះបង់កិលេសដែលជាមូលនៃវដ្ដៈ មិនបាន , វដ្ដៈដែលជាបច្ច័យនៃកម្ម-កិលេស រមែងគួរដល់អ្នកនោះ ដោយប្រការដូច្នេះ , កម្មនោះរបស់បុគ្គលនោះ ៗ ជាមូលរបស់វដ្ដៈក្នុងរូបក្ខន្ធនោះឯង , មិនមែនក្នុងវេទនាខន្ធជាដើម , ឬក្នុងវិញ្ញាណក្ខន្ធប៉ុណ្ណោះ , មិនគួរពោលថា មិនមែនក្នុងរូបក្ខន្ធជាដើម ។

ព្រោះហេតុអ្វី ? ព្រោះកិលេសដេកសម្ងំក្នុងខន្ធទាំង ៥ ដោយមិនប្លែកគ្នា ។ យ៉ាងណា ? ដូចរសដី ( **បឋវីរសំ** ) ជាដើម នៅក្នុងដើមឈើ ។ សេចក្ដីថា កាលបើដើមឈើធំ តាំងនៅលើផែនដី អាស្រ័យរសដី និងរសទឹក ( **អាបោរសំ** ) ដុះដាលល្អដោយឫស ដើម មែកតូចធំ ស្លឹកខ្ចី ស្លឹកចាស់ ផ្កា និងផ្លែ ព្រោះរសដី រសទឹកនោះ ពេញមេឃ ដល់អស់កប្ប បន្តខ្សែស្រឡាយរបស់ខ្លួន ដោយបង្កើតជាពូជត ៗ គ្នាមក តាំងនៅហើយ , ពូជឈើនោះ តាំងនៅជាមួយឫស មានរសដីជាដើមប៉ុណ្ណោះ , មិនមែនតាំងនៅដោយដើមជាដើម, ឬក្នុងផ្លែនោះទេ , មិនគួរពោលថា មិនមែននៅនឹងឫសជាដើម ។

ព្រោះហេតុអ្វី ? ព្រោះអាស្រ័យនៅក្នុងឫសជាដើម ទាំង-អស់ ។ ដូចយ៉ាងថា បុរសម្នាក់ មិនពេញចិត្តក្នុងផ្កាឈើ និងផ្លែឈើជាដើម របស់ដើមឈើនោះ ទើបចាក់បន្ទាពិស ឈ្មោះថា មណ្ឌូកកណ្ដកៈ បន្ទាត្រីបបែល ចុះទៅក្នុង ៤ ទិស កាលបើដើមឈើនោះត្រូវបន្ទាពិសនោះ ក៏មិនអាចនឹងបន្តតទៅទៀតបាន ដោយមិនបញ្ចេញផ្កាផ្លែបានតាមធម្មតា ព្រោះរសដី រសទឹក ដែល



ជាអ្នកចិញ្ចឹម វិនាសហើយ យ៉ាងណា , កុលបុត្តអ្នកនឿយណាយក្នុងការប្រព្រឹត្តទៅរបស់ខន្ធក៏ដូច្នោះដូចគ្នា ផ្ដើមចម្រើនមគ្គ ៤ ក្នុងសន្ដានរបស់ខ្លួន ដូចបុរសនោះដែលកាន់យកបន្ទាពិសចាក់ចុះក្នុងដើមឈើ ក្នុង ៤ ទិស ដូច្នោះ ។

កាលបើដូច្នោះ ខន្ធសន្ដានរបស់កុលបុត្តនោះ ត្រូវសម្ផ័ស្សបន្ទាពិស គឺ មគ្គ ៤ នោះ ប៉ះពាល់ហើយ ជាប្រភេទរបស់កម្មទាំងពួង មានកាយកម្មជាដើម ចូលដល់ត្រឹមតែសភាវៈរបស់កិរិយា ព្រោះកិលេសដែលជាឫសគល់របស់វដ្ដៈ ត្រូវកម្ចាត់ដោយប្រការទាំងពួង មិនអាចនឹងបន្តសន្ដានក្នុងភពដទៃបាន អស់សេចក្ដីប្រកាន់ រលត់វិញ្ញាណដួងក្រោយបំផុតមិនមានសល់ ដូចភ្លើង ដែលគ្មានឧសដូច្នោះ ។ គប្បីជ្រាបការផ្សេងគ្នារបស់ **ភូមិ** និង **ភូមិលទ្ធ** យ៉ាងនេះ ។

**ឧប្បន្ន គឺ ធម៌ដែលកើត ៤ យ៉ាង** មយ៉ាងទៀត គឺ ៈ

**សមុទាចារុប្បន្នំ** វត្តដែលកើតឡើង កំពុងប្រព្រឹត្តទៅ ១

**អារម្មណាធិគ្គហិតុប្បន្នំ** កើតដោយការប្រកាន់អារម្មណ៍ ១

**អវិក្ខម្ភិតុប្បន្នំ** កើតដោយការមិនគ្របសង្កត់ ១

**អសម្មូហតុប្បន្នំ** កើតដោយការមិនដកចេញ ១

ក្នុងអនុប្បន្នៈទាំងនោះ វត្ថុដែលកើតឡើង កំពុងប្រព្រឹត្តទៅ ឈ្មោះថា **សមុទាចារុប្បន្នំ** ។ កិលេសជាតសូម្បីមិនទាន់កើតក្នុងចំណែកខាងដើម ក្នុងអារម្មណ៍ដែលទៅកាន់គន្លងនៃចក្ខុជាដើម លោកពោលថា **អារម្មណាធិគ្គហិតុប្បន្នំ** កើតឡើងដោយចំណែកមួយក្នុងកាលដទៃ ព្រោះការកាន់យកអារម្មណ៍ ។ កិលេសជាតមិនគ្របសង្កត់ទុកដោយសមថៈ និងវិបស្សនា ណាមួយ សូម្បីមិនចម្រើនដោយការបន្តរបស់ចិត្ត ក៏ឈ្មោះថា **អវិក្ខម្ភិតុប្បន្នំ** ព្រោះមិនមានហេតុ ដែលនឹងហាមការកើតបាន ។ កិលេសជាត សូម្បីគ្របសង្កត់ទុកដោយសមថៈ និងវិបស្សនា លោកក៏ពោលថា **អសម្មូហតុប្បន្នំ** ព្រោះមិនទាន់ដកចេញដោយអរិយមគ្គ ព្រោះមិនឈានកន្លងជាធម្មតារបស់ការកើត ។

គប្បីជ្រាបថា **អារម្មណាធិគ្គហិតុប្បន្នំ** **អវិក្ខម្ភិតុប្បន្នំ** **អសម្មូហតុប្បន្នំ** ទាំងបីនេះ រមែងសង្គ្រោះចុះដោយ **ភូមិលទ្ធ** នោះឯង ។

កាលបើឧប្បន្នធម៌ មានប្រភេទដូចពោលមកនេះ កើតឡើង



ហើយ ក្នុងកិលេសជាតណា បានដល់ **វត្តមាន ភូតាបគត ឱកាសគត សមុទាចារ** កើតឡើង កិលេសជាតនោះ ដែលមគ្គញ្ញាណណា ៗ មិនគប្បីលះ ព្រោះមិនត្រូវកម្ចាត់ដោយមគ្គ ។ មួយទៀត កិលេសជាតណា ពោលគឺ **ភូមិលទ្ធ** អារម្មណាធិគហិតៈ អវិក្ខម្ភិតៈ អសម្មូហតៈ កើតឡើងហើយ កិលេសជាតនោះ ញុំាងការកើតរបស់ព្រះយោគីនោះ ឲ្យវិនាសទៅ ព្រោះលោកិយញ្ញាណ និងលោកុត្តរញ្ញាណនោះ កើតឡើង , ដូច្នោះកិលេសជាត សូម្បីទាំងអស់នោះ ក៏ត្រូវមគ្គនោះ ៗ គប្បីលះបាន ។ ដោយប្រការដូច្នេះ មគ្គរមែងលះកិលេសទាំងឡាយណា សំដៅយកកិលេសទាំងនោះ ទើបពោលថា **ឧប្បន្នានំ** ។

ហេតុដូច្នេះ ការចម្រើនដើម្បីកើតឡើងនៃកុសល ដែលនៅមិនទាន់កើត រមែងមាន ក្នុងខណៈនៃមគ្គយ៉ាងណា ? និងដើម្បីការតាំងមាំនៃកុសលធម៌ដែលកើតឡើងហើយ យ៉ាងណា ? ដើម្បីចូលដល់មគ្គនោះឯង ។ ព្រោះលោកពោលថា មគ្គដែលប្រព្រឹត្តទៅហើយ ឈ្មោះថា នៅមិនធ្លាប់កើតមកអំពីមុន ។ ពិតហើយ មានអ្នកមកកាន់ឋានៈដែលនៅមិនធ្លាប់មក ឬសោយ

អារម្មណ៍ដែលមិនធ្លាប់សោយ ហើយពោលថា យើងមកកាន់ឋានៈដែលមិនទាន់បានមក យើងសោយអារម្មណ៍ ដែលមិនធ្លាប់សោយ ដូច្នេះ ។ ការប្រព្រឹត្តទៅនៃកុសលធម៌នោះ ឈ្មោះថា **ឋិតិ**, គួរពោលថា **ឋិតិយា ភាវេតិ** ចម្រើនដើម្បីការតាំងមាំ ។ នេះគឺ សេចក្តីព្យាយាមរបស់ភិក្ខុនោះ ក្នុងខណៈនៃលោកុត្តរមគ្គ រមែងបានឈ្មោះ ៤ យ៉ាង មានជាអាទិ៍ថា **អនុប្បន្នានំ បាបកានំ អកុសលានំ ធម្មានំ អនុប្បាទាយ** ដើម្បីញុាំងអកុសលធម៌ដ៏លាមកដែលនៅមិនទាន់កើត មិនឲ្យកើតឡើង ។ កថានេះជាសម្មប្បធានកថា ក្នុងខណៈនៃលោកុត្តរមគ្គ ។ ក្នុងបទនេះលោកចង្អុលបង្ហាញសម្មប្បធាន លាយដោយលោកិយៈ និងលោកុត្តរៈទុកយ៉ាងនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សម្មាសតិនិទ្ទេស** ដូចតទៅនេះ បទថា **កាយេ** បានដល់ **រូបកាយ** ។ រូបកាយក្នុងទីនេះលោកបំណងថា **កាយ** ពួក ដូច **ហត្ថិកាយ** ពួកដំរី **រថកាយ** ពួករថជាដើម ដោយអត្ថថា ជាទីប្រជុំអវយវៈធំតូច និងវត្ថុទាំងឡាយមានសក់ជាដើម ។ មួយទៀត ឈ្មោះថា **កាយ** ដោយអត្ថថា



ជាទីកើតនៃវត្ថុដែលគួរខ្ពើមទាំងឡាយ ដូចដែលឈ្មោះថា **កាយ** ដោយអត្ថថា ជាទីប្រជុំ ដូច្នោះ ។ ឈ្មោះថា **កាយ** ព្រោះជាទីកើតនៃវត្ថុគួរខ្ពើម គឺ គួរខ្ពើមក្រៃលែង ។ បទថា **អាយោ** បានដល់ ទីកើត ។ ក្នុងបទនោះ មានអធិប្បាយពាក្យថា **អាយោ** ព្រោះអត្ថថា វត្ថុទាំងឡាយរមែងកើតពីកាយនោះ ។ អ្វីកើត ? គឺ វត្ថុគួរខ្ពើមមានសក់ជាដើម ។ ឈ្មោះថា **កាយោ** ព្រោះ អត្ថថា ជាទីកើតរបស់វត្ថុគួរខ្ពើម ដោយប្រកាដូច្នេះ ។

បទថា **កាយានុបស្សី** ពិចារណាឃើញកាយ បានដល់ ពិចារណាឃើញកាយជាប្រក្រតី , ឬពិចារណាឃើញនូវកាយ , សូម្បីពោលថា **កាយេ** ហើយនៅកាន់យកកាយជាលើកទី ២ ទៀតថា **កាយានុបស្សី** គប្បីជ្រាបថា លោកពោលដើម្បីសម្តែងការកំណត់ និងចែកចេញជាផ្នែក ដោយមិនឲ្យប្រឡំគ្នា ។ ដោយហេតុនោះ លោកទើបមិនពោលថា **វេទនានុបស្សី** ឬ **ចិត្តា-នុបស្សី ធម្មានុបស្សី** ក្នុងកាយ , តាមពិតក៏ **កាយានុបស្សី** នោះឯង ព្រោះហេតុនោះ ទើបលោកសម្តែងការកំណត់ដោយមិនឲ្យប្រឡំគ្នានៃអាការរបស់ **កាយានុបស្សនា** ក្នុងវត្ថុ គឺ កាយ

នោះឯង ៗ មួយទៀត ភិក្ខុមិនពិចារណាឃើញធម៌ ឯណានីមួយ ផុតពីអវយវៈតូច.ធំក្នុងកាយ , មិនមែនពិចារណាឃើញស្ត្រី និង បុរសក្រៅពីសក់ និងរោមជាដើម ៗ មួយវិញទៀត ក្នុងបទនេះ ភិក្ខុមិនពិចារណាឃើញធម៌ឯណានីមួយ ក្រៅអំពីភូតរូប និង ឧបាទាយរូប សូម្បីក្នុងកាយដែលជាទីប្រជុំភូតរូប និងឧបាទាយ-រូប មានសក់ និងរោមជាដើម , សេចក្តីពិត ពិចារណាឃើញ ការប្រជុំអវយវៈតូច.ធំ ដូចការពិចារណាឃើញគ្រឿងប្រកបរបស់ រថ , ពិចារណាឃើញការប្រជុំសក់ និងរោមជាដើម ដូចពិចារណា ចំណែករបស់នគរ , ពិចារណាឃើញភូតរូប និងឧបាទាយរូប ដូចជាបកស្រទបចេកចេញពីគ្នា និងដូចលាដៃទទេ ព្រោះហេតុ នោះ ទើបលោកសម្តែងការបែកចេញជាដុំ ដោយការឃើញ ដោយ ប្រការខុសគ្នានៃវត្ថុ ពោលគឺ សន្ធារដោយការប្រជុំនោះឯង ៗ ពិតហើយ ក្នុងបទនេះ កាយក្តី ស្រីក្តី ប្រុសក្តី ធម៌ណា ៗ ដទៃក្តី ផុតចាកការប្រជុំគ្នាតាមដែលពោលហើយ រមែងមិនប្រាកដ ៗ តែ ហេតុត្រឹមតែការប្រជុំនៃធម៌ តាមដែលពោលហើយនោះឯង សត្វ ទាំងឡាយ រមែងប្រកាន់ខុសយ៉ាងនោះ ៗ ៗ ដោយហេតុនោះ



បុរាណាចារ្យទាំងឡាយ ទើបពោលថា ៈ-

**យំ បស្សតិ ន តំ ទិដ្ឋំ យំ ទិដ្ឋំ តំ ន បស្សតិ**
**អបស្សំ ពជ្ឈតេ មូឡ្ហោ ពជ្ឈមានោ ន មុច្ចតិ ៗ**

បុគ្គល ឃើញវត្ថុណា វត្ថុនោះឈ្មោះថា
គេឃើញហើយ ក៏មិនមែន វត្ថុណាដែល
ឃើញហើយ ឈ្មោះថា រមែងមិនឃើញ
វត្ថុនោះ បុគ្គលល្ងង់ កាលបើមិនឃើញ
រមែងជាប់ កាលបើជាប់ រមែងមិនរួច
ផុត ដូច្នេះ ៗ

លោកពោលទុកយ៉ាងនេះ ដើម្បីសម្តែងការបែកចេញជាដុំ ជាដើម ៗ ដោយអានិសង្សក្នុងបទនេះ គប្បីជ្រាបសេចក្តីដូច្នេះ , ព្រោះខ្ទឹមសារនេះ បានដល់ ការពិចារណាឃើញកាយក្នុងកាយនេះ នោះឯង ៗ មិនមែនពិចារណាឃើញធម៌ដទៃ ៗ លោកអធិប្បាយ ទុកយ៉ាងណា ? លោកអធិប្បាយទុកថា មិនមែនពិចារណាឃើញ ថា ជារបស់ទៀង ជាសុខ ជាតួខ្លួន និងជារបស់ស្អាតក្នុងកាយនេះ ដែលជារបស់មិនទៀង ជាទុក្ខ មិនមែនជាតួខ្លួន និងជារបស់មិន

ស្អាត ដូចការពិចារណាឃើញទឹកនៃថ្ងៃបណ្ដីរកូន ដែលមិនមានទឹកដូច្នោះ , សេចក្ដីពិត ពិចារណា ឃើញកាយ ក៏គឺពិចារណាឃើញការប្រជុំអាការដែលមិនទៀង , ជាទុក្ខ មិនមែនតួខ្លួន និងជារបស់មិនស្អាតនោះឯង ។

ម្យ៉ាងទៀត លោកពោលដល់កាយ មានខ្យល់អស្សាសៈបស្សាសៈជាខាងដើម និងមានកំទេចឆ្អឹងជាទីបំផុត ដោយន័យមានជាអាទិ៍ថា **ឥធ ភិក្ខវេ ភិក្ខុ អរញ្ញគតោ វា រុក្ខមូលគតោ វា ។បេ។ សោ សតោវ អស្សសតិ** សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ទៅកាន់ព្រៃក្ដី ទៅកាន់គល់ឈើក្ដី ។ល។ ភិក្ខុនោះមានសតិដកដង្ហើមចូល..... ក្នុងសតិប្បដ្ឋានកថាខាងមុខ គប្បីឃើញសេចក្ដីយ៉ាងនេះថា ភិក្ខុពិចារណាឃើញកាយក្នុងកាយ ព្រោះពិចារណាឃើញក្នុងកាយនេះប៉ុណ្ណោះរបស់កាយទាំងអស់ ដែលលោកពោលដល់កាយថា ភិក្ខុអង្គខ្លះក្នុងសាសនា រមែងពិចារណាឃើញគំនរបឋវីធាតុ គំនរអាបោធាតុ គំនរតេជោធាតុ គំនរវាយោធាតុ គំនរសក់ គំនររោម គំនរពណ៌ គំនរស្បែក គំនរសាច់ គំនរឈាម គំនរឆ្អឹង គំនរខួរក្នុងឆ្អឹង ។



ម្យ៉ាងវិញទៀត គប្បីឃើញសេចក្ដីយ៉ាងនេះថា ភិក្ខុពិចារណាឃើញកាយ ពោលគឺ ការប្រជុំធម៌ មានសក់ជាដើម ក្នុងកាយ ព្រោះពិចារណាឃើញការប្រជុំធម៌ផ្សេង ៗ មានសក់ និងរោមជាដើមនោះ ៗ ព្រោះមិនឃើញអ្វី ៗ ដែលគួរប្រកាន់មាំយ៉ាងនេះថា យើង ឬរបស់យើង ក្នុងកាយ ។ ម្យ៉ាងវិញទៀត គប្បីឃើញសូម្បីយ៉ាងនេះថា ភិក្ខុពិចារណាឃើញកាយក្នុងកាយ សូម្បីពិចារណាឃើញកាយ ពោលគឺ ការប្រជុំអាការមានអនិច្ចលក្ខណៈជាដើម ទាំងអស់ដែលមានន័យមកហើយខាងមុខ ដោយលំដាប់មានជាអាទិ៍ថា ភិក្ខុរមែងពិចារណាដោយសេចក្ដីមិនទៀងក្នុងកាយនេះ , មិនមែនពិចារណាឃើញមិនទៀង ជារបស់ទៀងដូច្នេះ ។ នេះជាសេចក្ដីទូទៅក្នុងសតិប្បដ្ឋាន ៤ ។

បទថា **កាយេ កាយានុបស្សី** ភិក្ខុពិចារណាឃើញ កាយក្នុងកាយ សេចក្ដីថា ភិក្ខុពិចារណាឃើញកាយមួយយ៉ាង ៗ ក្នុងកាយដូចដែលបានពោលទុកជាចំណែកច្រើន មានកងអស្សាសៈជាដើម ។

បទថា **វិហរតិ** នេះ សម្ដែងដល់ការបំពេញវិហារធម៌ណា

មួយ ក្នុងវិហារធម៌ គឺ ឥរិយាបថ ៤ ។ អធិប្បាយថា ភិក្ខុផ្លាស់ឥរិយាបថមួយ ដោយឥរិយាបថដទៃហើយ ធ្វើរាងកាយឲ្យរហ័សរហួន។

ពាក្យថា **អាតាបី** មានការព្យាយាមនេះ សម្តែងដល់ការព្យាយាមកំណត់កាយ ។ អធិប្បាយថា ភិក្ខុនោះជាអ្នកប្រកបដោយការព្យាយាម ដែលលោកពោលថា **អាតាបោ** ព្រោះដុតកិលេសក្នុងភព ៣ នាសម័យនោះ , ដូច្នោះទើបលោកពោលថា **អាតាបី** មានការព្យាយាម ។

បទថា **សម្បជានោ** មានសម្បជញ្ញៈ គឺ ជាអ្នកប្រកបដោយញាណ បានដល់ សម្បជញ្ញៈដែលកំណត់កាយ ។

បទថា **សតិមា** មានសតិ គឺ ជាអ្នកប្រកបដោយសតិកំណត់កាយ ។ ក៏ព្រោះភិក្ខុនេះកំណត់អារម្មណ៍ដោយសតិហើយពិចារណាឃើញដោយបញ្ញា ។ ពិតហើយ អ្នកមិនមានសតិនឹងពិចារណាឃើញមិនបានឡើយ ។ ដោយហេតុនោះឯង ព្រះ-មានព្រះភាគជាម្ចាស់ ទើបត្រាស់ថា **សតិញ្ច ខ្វាហំ ភិក្ខវេ សព្វត្ថិកំ វទាមិ** ម្នាលភិក្ខុទាំងឡាយ តថាគតពោលសតិនោះ មាន



ប្រយោជន៍ក្នុងទីទាំងពួង ។ ដូច្នោះក្នុងបទនេះ ទើបលោកពោលដល់កម្មដ្ឋាន គឺ **កាយានុបស្សនាសតិប្បដ្ឋាន** ដោយន័យត្រឹមតែប៉ុណ្ណេះថា **កាយេ កាយានុបស្សី វិហរតិ** ភិក្ខុពិចារណាឃើញកាយក្នុងកាយហើយ ដូច្នេះ ។

ម្យ៉ាងទៀត ព្រោះមិនមានការព្យាយាម ជាអ្នកតក់ស្លុតក្នុងខាងក្នុង ជាអ្នកធ្វើអន្តរាយ , ជាអ្នកមិនមានសម្បជញ្ញៈ រមែងវង្វេងក្នុងការកំណត់ឧបាយ និងក្នុងការវៀរចាកវត្ថុមិនជាឧបាយ ។ អ្នកមិនមានសតិ រមែងមិនអាចក្នុងការលះបង់ឧបាយ ដូច្នោះ , ដោយហេតុនោះ កម្មដ្ឋាននោះទើបមិនសម្រេចដល់ភិក្ខុនោះ , ដូច្នោះកម្មដ្ឋាននោះ រមែងសម្រេចដោយ អានុភាពរបស់ធម៌ពួកណាដើម្បីសម្តែងដល់ធម៌ពួកនោះ គប្បីជ្រាបថា លោកទើបពោលបទនេះថា **អាតាបី សម្បជានោ សតិមា** ភិក្ខុមានសេចក្តីព្យាយាម មានសម្បជញ្ញៈ មានសតិ ដូច្នេះ ។

ព្រះមានព្រះភាគជាម្ចាស់ លុះទ្រង់សម្តែង កាយានុបស្សនាសតិប្បដ្ឋាន និងអង្គប្រកបហើយ ឥឡូវនេះដើម្បីទ្រង់សម្តែងអង្គនៃ **បហាន** ទើបត្រាស់ថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ**

កម្ចាត់អភិជ្ឈា និងទោមនស្សចេញ ។

ក្នុងបទទាំងនោះ បទថា **វិនេយ្យ** កម្ចាត់បង់ បានដល់ កម្ចាត់ដោយ **តទង្គវិន័យ** កម្ចាត់ដោយខណៈ ឬ **វិក្ខម្ភនវិន័យ** កម្ចាត់ដោយការគ្របសង្កត់ទុក ។

បទថា **លោកេ** សេចក្តីថា កាយណាកំណត់ទុកក្នុងកាលមុន កាយនុ៎ះឯង ឈ្មោះថា **លោក** ក្នុងទីនេះ ដោយអត្ថថា បែកធ្លាយទៅ ហើយលះបង់អភិជ្ឈា និងទោមនស្សក្នុងលោកនោះចេញ ។

ម្យ៉ាងទៀត ព្រោះភិក្ខុនោះរមែងលះបង់អភិជ្ឈា និងទោមស្សត្រឹមតែក្នុងកាយប៉ុណ្ណោះ ក៏មិនមែន , រមែងលះបង់សូម្បីវេទនាជាដើមទៀតផង , ដូច្នោះលោកទើបពោលទុកក្នុងវិភង្គថា **បញ្ចបិ ឧបាទានក្ខន្ធា លោកោ** សូម្បីឧបាទានក្ខន្ធ ៥ ក៏ជាលោក ។ គប្បីជ្រាបថា លោកពោលបទនេះ ដោយការដកចេញនូវធម៌ទាំង-នោះ ព្រោះធម៌ទាំងនោះ រាប់បញ្ចូលក្នុងលោក ។

ព្រះសារីបុត្តត្ថេរពោលថា ក្នុងបទថា **លោកេ** នោះ លោកដូចម្តេច ? កាយនុ៎ះឯង ជាលោក ។ នេះជាពាក្យអធិប្បាយក្នុង



បទនេះ ។ លោកពោលសង្ខេបទុកថា **អភិជ្ឈាទោមនស្សំ** ដូច្នេះ ។ ក៏ក្នុងរវាងបាឋៈក្នុងសំយុត្តនិកាយ និងអង្គុត្តរនិកាយ អាចារ្យទាំងឡាយពោលទុកផ្សេងគ្នា ។ ឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា ជាហេតុនៃការសំឡឹងរំពៃ គឺ ប្រាថ្នា ឬការសំឡឹងរំពៃ ឬត្រឹមតែការសំឡឹងរំពៃប៉ុណ្ណោះ ។ ក្នុងបទថា **អភិជ្ឈាទោមនស្សំ** នេះ ព្រោះកាមឆន្ទៈសង្គ្រោះចូល ជាមួយអភិជ្ឈា , ព្យាបាទសង្គ្រោះចូលជាមួយទោមនស្ស ។ ដូច្នេះគប្បីជ្រាបថា លោកពោលដល់ការលះបង់នីវរណៈ ដោយសម្តែងដល់ធម៌ទាំងពីរ ដែលជាធម៌មានកម្លាំងរាប់បញ្ចូលក្នុងនីវរណៈ ។

ក្នុងបទនេះ ដោយសេចក្តីផ្សេងគ្នា លោកពោលដល់ការលះបង់សេចក្តីត្រេកអរ ដែលជាមូលហេតុរបស់សម្បត្តិផ្លូវកាយ ដោយកម្ចាត់អភិជ្ឈា , លះបង់សេចក្តីទាស់ចិត្ត ដែលជាមូលហេតុរបស់វិបត្តិផ្លូវកាយ ដោយកម្ចាត់ទោមនស្ស ។ លះបង់សេចក្តីត្រេកអរក្នុងកាយ ដោយកម្ចាត់អភិជ្ឈា , លះបង់ការមិនត្រេកអរក្នុងកាយភាវនាដោយកម្ចាត់ទោមនស្ស , លះបង់ការសម្គាល់ភាពល្អស្អាត និងសេចក្តីសុខជាដើម ដែលមិនមានពិត

ក្នុងកាយ ដោយកម្ចាត់អភិជ្ឈា , លះបង់ការនាំចេញនូវភាពមិនស្អាត ភាពមិនសុខជាដើម ដែលមានពិតក្នុងកាយ ដោយកម្ចាត់ទោមនស្ស ។ ជាការដែលលោកសម្ដែងដល់អានុភាពរបស់យោគៈ និងសេចក្ដីអង់អាចក្នុងយោគៈរបស់ព្រះយោគាវចរ ដោយបទនោះ ។ អានុភាពរបស់យោគៈ គឺ ព្រះយោគាវចរជាអ្នកផុតចាកពីសេចក្ដីពេញចិត្ត ទាស់ចិត្ត ជាអ្នកអត់ទ្រាំដល់ការទាស់ចិត្ត និងការពេញចិត្ត និងជាអ្នកវៀរចាកពីការបន្ថែមក្នុងរបស់ដែលមិនពិត និងការនាំវត្ថុដែលមានពិតចេញ ។

មួយទៀត ព្រះយោគាវចរនោះ ជាអ្នកផុតចាកពីការសេចក្ដីពេញចិត្ត មិនពេញចិត្ត មិនផ្ដុំបញ្ជ្រួបក្នុងវត្ថុមិនមានពិត និងកម្ចាត់វត្ថុមានពិត ជាអ្នកអង់អាចក្នុងយោគៈដោយប្រការដូច្នេះ ។

ន័យមួយទៀត ក្នុងបទថា **កាយេ កាយានុបស្សី** នេះ លោកពោលដល់កម្មដ្ឋាននៃ **អនុបស្សនា** ។ ក្នុងបទថា **វិហរតិ** នេះ លោកពោលដល់ការគ្រប់គ្រងកាយរបស់ភិក្ខុ អ្នកបំពេញកម្មដ្ឋានដោយវិហារធម៌ដូចពោលមកហើយ ។ គប្បីជ្រាបថា ក្នុងបទមានជាអាទិ៍ថា **អាតាបី** លោកពោលដល់សម្មប្បធាន ដោយ



ការព្យាយាម , ពោលកម្មដ្ឋានដែលមានប្រយោជន៍ទាំងអស់ ឬឧបាយនៃការគ្រប់គ្រងកម្មដ្ឋានដោយសតិសម្បជញ្ញៈ , ពោលសមថៈដែលបានដោយអំណាចកាយានុបស្សនាដោយសតិ , ពោលវិបស្សនាដោយសម្បជញ្ញៈ , ពោលផលរបស់ភាវនាដោយការកម្ចាត់អភិជ្ឈា និងទោមនស្ស ។

ក្នុងបទមានជាអាទិ៍ថា **វេទនាសុ វេទនានុបស្សី** ភិក្ខុពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយ គប្បីប្រកបសេចក្ដីក្នុងពាក្យរបស់វេទនាជាដើមតទៅ គប្បីជ្រាបតាមសមគួរដោយន័យដូចពោលហើយក្នុងកាយានុបស្សនានោះឯង ។ អត្ថដែលមិនទូទៅមានដូចតទៅនេះ ភិក្ខុពិចារណាឃើញវេទនាឯណានីមួយ ដោយសេចក្ដីមិនទៀងជាដើម រឿយ ៗ ក្នុងវេទនាទាំងឡាយ មានច្រើនប្រភេទ មានសុខវេទនាជាដើម , ពិចារណាឃើញចិត្តមួយដួង ៗ ដោយភាពមិនទៀងជាដើម រឿយ ៗ ក្នុងចិត្តមាន ១៦ ប្រភេទ មានចិត្តប្រកបដោយរាគៈជាដើម , ពិចារណាឃើញធម៌រឿយ ៗ ដោយភាពមិនទៀងជាដើម ក្នុងធម៌ប្រព្រឹត្តទៅក្នុងភូមិ ៣ ដ៏សេសវៀរកាយ វេទនា និងចិត្ត , ឬពិចារណាឃើញធម៌ មាននីវរណៈ

ជាដើម ដោយន័យដូចពោល ហើយក្នុងសតិប្បដ្ឋានសូត្រ ។

ក្នុងបទទាំងនេះ គប្បីជ្រាបថា បទថា **កាយេ** ជាឯកវចនៈ ព្រោះសរីរៈមានមួយ , បទថា **ចិត្តេ** ជាឯកវចនៈ លោកពោលដោយកាន់យកជាតិ ព្រោះមិនមានការផ្សេងនៃសភាវៈរបស់ចិត្ត ។ ភិក្ខុពិចារណាឃើញ ដោយប្រការដែលគប្បីឃើញវេទនាជាដើម គប្បីជ្រាបថា ជាអ្នកពិចារណាឃើញវេទនាក្នុងវេទនាទាំងឡាយ , ជាអ្នកពិចារណាឃើញចិត្តក្នុងចិត្ត , ជាអ្នកពិចារណាឃើញធម៌ក្នុងធម៌ទាំងឡាយ ។ គប្បីពិចារណាឃើញវេទនាយ៉ាងណា ? គប្បីពិចារណាឃើញសុខវេទនាថា ជាទុក្ខ , គប្បីពិចារណាឃើញទុក្ខវេទនា ដូចជាសរ , គប្បីពិចារណាឃើញអទុក្ខមសុខវេទនាថា ជារបស់មិនទៀង ដូចលោកពោលទុកថា ៖-

**យោ សុខំ ទុក្ខតោ អទ្ទ ទុក្ខមទ្ទក្ខិ សល្លតោ**
**អទុក្ខមសុខំ សន្តំ អទ្ទក្ខិ នំ អនិច្ចតោ ។**
**ស វេ សម្មទ្ទសោ ភិក្ខុ បរិជានាតិ វេទនា ។**

ភិក្ខុណាបានពិចារណាឃើញសុខថា ជាទុក្ខ
បានឃើញទុក្ខថា ដូចជាសរ បានឃើញ



អទុក្ខមសុខវេទនា ដែលស្ងប់រំងាប់ហើយ
នោះថា ជារបស់មិនទៀង ។ ភិក្ខុនោះឯង
ជាអ្នកឃើញប្រពៃ រមែងដឹងជុំវិញនូវវេទនា
ទាំងឡាយ ។

មួយទៀត គប្បីពិចារណាឃើញវេទនាទាំងអស់ថា ជាទុក្ខ ដូចព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា តថាគតពោលថា ***វត្ថុណាមួយដែលបានសោយហើយ វត្ថុទាំងអស់នោះប្រព្រឹត្តទៅក្នុងទុក្ខ*** ។

គប្បីពិចារណាឃើញដោយភាពជាសុខខ្លះ ទុក្ខខ្លះ ។ ដូចដែលលោកពោលទុកថា សុខវេទនាជាសុខ ព្រោះតាំងនៅជាទុក្ខ ព្រោះប្រែប្រួល ។ ទុក្ខវេទនាជាទុក្ខ ព្រោះតាំងនៅជាសុខ ព្រោះប្រែប្រួល , អទុក្ខមសុខវេទនាជាសុខ ព្រោះបានដឹងជាទុក្ខ ព្រោះមិនដឹង ។ តែក៏គួរពិចារណា ដោយអំណាចការពិចារណាឃើញសត្វ មានភាពមិនទៀងជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងចិត្ត និងធម៌ដូចតទៅនេះ ៖-

គប្បីពិចារណាឃើញចិត្តជាមុន ដោយអំណាចនៃការពិចា-

រណាឃើញសត្វ មានសភាពមិនទៀងជាដើម ដែលមានប្រភេទចិត្តផ្សេង ៗ គ្នា ដោយមាន **អារម្មណ អធិបតិ សហជាត ភូមិ កម្ម វិបាក និងកិរិយា** ជាដើម និងប្រភេទ នៃចិត្ត ១៦ យ៉ាង មាន **សរាគចិត្ត** ជាដើម ។ គប្បីពិចារណាឃើញធម៌ទាំងឡាយ ដោយអំណាចនៃការពិចារណាឃើញសត្វ មានការមិនទៀងជាដើម នៃសុញ្ញតាធម៌ ដែលមានលក្ខណៈរបស់ខ្លួន និងសាមញ្ញលក្ខណៈ ទាំងមានការស្ងប់ និងមិនស្ងប់ជាដើម ។

ក្នុងបទនេះ អភិជ្ឈាទោមនស្សនោះ ដែលភិក្ខុលះបង់បាន ក្នុងលោក ដែលបានដល់កាយ ទើបជាការលះបង់បាន សូម្បីក្នុងលោក មានវេទនាជាដើមផង ដោយពិត , ដូច្នោះហើយ លោកក៏ពោលទុកក្នុងទីទាំងពួង ដោយអំណាចបុគ្គលផ្សេងគ្នា និងដោយអំណាចការចម្រើនសតិប្បដ្ឋាន ដែលមានក្នុងខណៈផ្សេងគ្នា ។ ម្យ៉ាងទៀត កាលបើលះបង់បាន ក្នុងចំណែកណាមួយ ហើយ សូម្បីក្នុងចំណែកដ៏សេស ក៏ជាការលះបង់បានដែរ ដោយហេតុនោះ គប្បីជ្រាបថា លោកពោលយ៉ាងនេះ ដើម្បីសំដែងការលះបង់អភិជ្ឈារបស់ភិក្ខុនោះ ។



សតិប្បដ្ឋាន ៤ ទាំងនេះ រមែងបានក្នុងចិត្តផ្សេង ៗ គ្នា ក្នុងចំណែកខាងដើមដោយប្រការដូច្នេះ ។ ភិក្ខុរមែងកំណត់កាយដោយចិត្តដទៃ កំណត់វេទនាដោយចិត្តដទៃ កំណត់ចិត្តដោយចិត្តដទៃ កំណត់ធម៌ទាំងឡាយដោយចិត្តដទៃ ។ តែក្នុងខណៈលោកុត្តរមគ្គ សតិប្បដ្ឋាន រមែងបានក្នុងចិត្តតែមួយដួង ប៉ុណ្ណោះ ។

សតិសម្បយុត្តដោយវិបស្សនា របស់បុគ្គលដែលកំណត់កាយតាំងពីដើម ឈ្មោះថា **កាយានុបស្សនា** ។ បុគ្គលអ្នកប្រកបដោយសតិនោះ ឈ្មោះថា **កាយានុបស្សី** ។ សតិសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គរបស់បុគ្គលអ្នកខ្វល់ខ្វាយក្នុងវិបស្សនាហើយសម្រេចអរិយមគ្គ ឈ្មោះថា **កាយានុបស្សនា** ។ សតិសម្បយុត្តដោយវិបស្សនា របស់បុគ្គលដែលកំណត់វេទនា កំណត់ចិត្ត កំណត់ធម៌ទាំងឡាយ ឈ្មោះថា **ធម្មានុបស្សនា** , បុគ្គលអ្នកប្រកបដោយសតិនោះ ឈ្មោះថា **ធម្មានុបស្សី** ។ សតិសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គរបស់បុគ្គលអ្នកខ្វល់ខ្វាយក្នុងវិបស្សនា ហើយសម្រេចអរិយមគ្គ ឈ្មោះថា **ធម្មានុបស្សនា** , បុគ្គលអ្នកប្រកបដោយសតិនោះ ឈ្មោះថា **ធម្មានុបស្សី** ។

ការសម្តែងយ៉ាងនេះ រមែងតាំងនៅក្នុងបុគ្គល ។ តែសតិកំណត់កាយ លះបង់ការយល់ខុសក្នុងកាយថា ស្អាត រមែងសម្រេចដោយមគ្គ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **កាយានុបស្សនា** ។ សតិកំណត់វេទនា លះបង់ការយល់ខុសក្នុងវេទនាថា ជាសុខ រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបឈ្មោះថា **វេទនានុបស្សនា** ។ សតិកំណត់ចិត្ត លះបង់ការយល់ខុស ក្នុងចិត្តថា ជារបស់ទៀង រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបឈ្មោះថា **ចិត្តានុបស្សនា** សតិកំណត់ធម៌ លះបង់ការយល់ខុសក្នុងធម៌ទាំងឡាយថា ជាតួខ្លួន រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបឈ្មោះថា **ធម្មានុបស្សនា** ។ សតិសម្បយុត្តដោយមគ្គតែម្យ៉ាង រមែងបានឈ្មោះ ៤ យ៉ាង ដោយការញ៉ាំងកិច្ច ៤ យ៉ាង ឲ្យសម្រេចដោយប្រការដូច្នេះ ។ ដោយហេតុនោះ លោកទើបពោលថា សតិប្បដ្ឋាន ៤ រមែងបានក្នុងចិត្តតែមួយដូងប៉ុណ្ណោះ ក្នុងខណៈនៃលោកុត្តរមគ្គ ។

គប្បីជ្រាបវិនិច្ឆ័យក្នុង **សម្មាសមាធិនិទ្ទេស** ដូចតទៅនេះ ៖-

បទថា **វិវិច្ចេវ កាមេហិ** ស្ងាត់ចាកកាម បានដល់ **ស្ងាត់**



**វៀរ គេចចេញ** ពីកាមទាំងឡាយ ។ គប្បីជ្រាប **ឯវ** ស័ព្ទក្នុងបទនេះ មានសេចក្តីថា ពិតប្រាកដ ។ ព្រោះ **ឯវ** ស័ព្ទមានសេចក្តីថា ពិតប្រាកដ ដូច្នោះ ព្រះសារីបុត្តត្រេរសម្តែងដល់កាម សូម្បីមិនមាននៅក្នុងខណៈចូលដល់បឋមជ្ឈាន ជាបដិបក្ខនឹងបឋមជ្ឈាននោះ និងការសម្រេចបឋមជ្ឈាននោះ ដោយការលះបង់កាមនោះឯង ។ យ៉ាងណា ? ព្រោះកាលធ្វើសេចក្តីពិតប្រាកដយ៉ាងនេះថា **វិវិច្ចេវ កាមេហិ** បឋមជ្ឈាននេះ រមែងប្រាកដ , កាមទាំងឡាយជាបដិបក្ខដល់ឈាននេះពិតប្រាកដ , កាលបើនៅមានកាម ឈាននេះរមែងប្រព្រឹត្តទៅមិនបាន ។ ដូចសភាពងងឹតនៅមាន ពន្លឺប្រទីបក៏បំភ្លឺមិនបាន ។ ការសម្រេចឈាននោះ ដោយការលះបង់កាមនោះឯង ដូចការដល់ត្រើយនាយដោយការលះបង់ត្រើយអាយ , ដូច្នោះទើបធ្វើសេចក្តីពិតប្រាកដ ។

ក្នុងបទនោះមានពាក្យសួរថា ព្រោះហេតុអ្វីលោកទើបពោលការសម្រេចនេះទុកក្នុងបទមុន , មិនពោលទុកក្នុងបទក្រោយ , ភិក្ខុសូម្បីមិនស្ងាត់ចាកអកុសលធម៌ ក៏នឹងចូលឈានបានឬ ? ប្រការនោះមិនគួរយល់យ៉ាងនោះ ។ ព្រោះលោកពោលទុកការ

សម្រេចនោះ ទុកហើយក្នុងបទមុន ព្រោះរលាស់ចេញចាកកាមនោះ ។ មួយវិញទៀត ឈាននេះ ជាការរលាស់ចេញចាកកាមទាំងឡាយ ព្រោះឈានកន្លងកាមធាតុ និងព្រោះជាបដិបក្ខនឹងកាមរាគ ។ ដូចព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា **កាមានមេតំ និស្សរណំ យទិទំ នេក្ខម្មំ** នេក្ខម្ម ជាការរលាស់ចេញចាកកាមទាំងឡាយ ។ សូម្បីក្នុងបទក្រោយក៏គប្បីពោលដូចគ្នាដែលលោកនាំ **ឯវ** អក្សរ មកពោលទុកក្នុងបទនេះថា **ឥធេវ ភិក្ខវេ សមណោ , ឥធ ទុតិយោ សមណោ** ម្នាលភិក្ខុទាំងឡាយ សមណៈមានក្នុងសាសនានេះប៉ុណ្ណោះ , សមណៈទីពីរក៏មានក្នុងសាសនានេះ ។

ព្រោះមិនស្ងាត់ចាកអកុសលធម៌ដែលបានដល់ នីវរណៈ សូម្បីដទៃពីនេះ ក៏មិនអាចចូលឈានបាន , ដូច្នោះគប្បីឃើញសូម្បីក្នុងពីរបទយ៉ាងនេះថា **វិវិច្ចេវ កាមេហិ វិវិច្ចេវ អកុសលេហិ** ស្ងាត់ចាកកាមនោះឯង ស្ងាត់ពីអកុសលនោះឯងដូច្នេះ ។ តទង្គវិវេក វិក្ខម្ភនវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក និស្សរណវិវេក និងចិត្តវិវេក កាយវិវេក



ឧបធិវិវេក រមែងសង្គ្រោះដោយពាក្យទូទៅនេះថា **វិវិច្ច** ក៏ពិតតែក៏គប្បីឃើញកាយវិវេក ចិត្តវិវេក វិក្ខម្ភនវិវេក ក្នុងចំណែកខាងដើមផង , គប្បីឃើញកាយវិវេក ចិត្តវិវេក សមុច្ឆេទវិវេក បដិបស្សទ្ធិវិវេក និងនិស្សរណវិវេក ក្នុងខណៈនៃលោកុត្តរមគ្គផង ។

ដោយបទថា **កាមេហិ** នេះ លោកពោលដល់វត្ថុកាមទុកក្នុងមហានិទ្ទេស ដោយន័យមានជាអាទិ៍ថា **កតមេ វត្ថុកាមា មនាបិកា រូបា** វត្ថុកាម មានរូបជាទីពេញចិត្តដូចម្តេច និងលោកពោលដល់កិលេសកាមទុកក្នុងវិភង្គនោះ យ៉ាងនេះថា **ឆន្ទោ កាមោ រាគោ កាមោ ឆន្ទរាគោ កាមោ , សង្កប្បោ កាមោ រាគោ កាមោ , សង្កប្បរាគោ កាមោ** ឆន្ទៈជាកាម រាគៈជាកាម ឆន្ទរាគៈជាកាម សង្កប្បៈជាកាម រាគៈជាកាម សង្កប្បរាគៈជាកាម គប្បីឃើញថា លោកសង្គ្រោះកាមទាំងនោះទុកទាំងអស់ ។ កាលបើយ៉ាងនេះ បទថា **វិវិច្ចេវ កាមេហិ** សេចក្តីថា ស្ងាត់ចាកវត្ថុកាមនោះឯង ក៏គួរ ។ ដោយបទនោះ គឺ លោកពោលដល់កាយវិវេក ។

បទថា **វិវិច្ច អកុសលេហិ ធម្មេហិ** ស្ងាត់ចាកអកុសលធម៌ សេចក្ដីថា ស្ងាត់ចាកអំពីកិលេសកាម ឬអកុសលទាំងអស់ ដូច្នេះ ក៏គួរ ។ ដោយបទនោះ គឺ លោកពោលដល់ចិត្តវិវេក ។ មួយវិញទៀត ក្នុងពីរបទនេះ ដោយបទដើមជាការចម្រើនការលះបង់កាមសុខ ព្រោះពាក្យថា ស្ងាត់ចាកវត្ថុកាម , ដោយបទទីពីរ ជាការចម្រើនការកំណត់នេក្ខម្មសុខ ព្រោះពាក្យថា ស្ងាត់ចាកកិលេសកាម ។ ព្រោះពាក្យថា ស្ងាត់ចាកវត្ថុកាម និងកិលេសកាម គប្បីជ្រាបថា ដោយបទដើមជាការចម្រើនការលះបង់វត្ថុដែលសៅហ្មង ។ ដោយបទទីមួយជាការចម្រើនការលះបង់ហេតុនៃសេចក្ដីរាយមាយ , ដោយបទទាំងពីរ គឺ ចម្រើនការលះបង់ហេតុនៃសភាពជាពាល , និងដោយបទទីមួយ គឺ ចម្រើនភាពបរិសុទ្ធិដោយការព្យាយាម , ដោយបទទីពីរ ជាការចម្រើនអប់រំអជ្ឈាស្រ័យ ។ ក្នុងបណ្ដាកាមទាំងឡាយ ដែលលោកពោលទុកក្នុងបទថា **កាមេហិ** នេះ មានន័យដូចគ្នាផ្នែកវត្ថុកាម ។

គប្បីជ្រាបវិនិច្ឆ័យផ្នែកកិលេសកាមដូចតទៅនេះ កាមច្ឆន្ទៈ



មានច្រើនប្រភេទ ដោយបទមានជាអាទិ៍យ៉ាងនេះថា **ឆន្ទ** និង **រាគ** លោកបំណងថា **កាម** ។ កាមនោះ សូម្បីរាប់បញ្ចូលក្នុងអកុសលធម៌ លោកក៏ពោលទុកដោយឡែកក្នុងវិភង្គ ដោយន័យមានជាអាទិ៍ថា **កាមដូចម្ដេច** ? **ឆន្ទៈជាកាម** ព្រោះជាបដិបក្ខដល់អង្គឈានខាងដើម ឬលោកពោលទុកក្នុងបទមុន ព្រោះជាកិលេសកាម ។ លោកពោលទុកក្នុងបទទីពីរ ព្រោះរាប់បញ្ចូលក្នុងអកុសល ។

មួយវិញទៀត លោកមិនពោលថា **កាមតោ** ចាកកាម ព្រោះកាមនោះមានច្រើនប្រភេទ ទើបពោលថា **កាមេហិ** ចាកកាមទាំងឡាយ ។ កាលបើធម៌សូម្បីពួកដទៃជាអកុសលនៅមាន លោកពោលនីវរណៈទាំងឡាយទុកក្នុងវិភង្គ ដោយន័យមានជាអាទិ៍ថា **អកុសលធម៌ដូចម្ដេច** ? **កាមច្ឆន្ទៈជាអកុសលធម៌** ព្រោះជាសត្រូវ និងជាបដិបក្ខដល់អង្គឈានខាងដើម ។ ពិតហើយ នីវរណៈជាសត្រូវដល់អង្គឈាន , អង្គឈានជាបដិបក្ខដល់នីវរណៈទាំងនោះ លោកអធិប្បាយថា កម្ចាត់ ធ្វើឲ្យវិនាស ។ លោកពោលទុកក្នុងបិដកថា **សមាធិជាបដិបក្ខដល់កាមច្ឆន្ទៈ** ,

**បីតិជាបដិបក្ខដល់ព្យាបាទ , វិតក្កៈជាបដិបក្ខ ដល់ថីនមិទ្ធ , សុខជាបដិបក្ខដល់ឧទ្ធច្ចកុក្កុច្ចៈ , វិចារៈ ជាបដិបក្ខដល់វិចិកិច្ឆា** ដូច្នេះ ។

ក្នុងបទនេះ ដោយបទថា **វិវិច្ចេវ កាមេហិ** ការដែលលោកពោលដល់សេចក្តីស្ងាត់ ដោយការគ្រប់សង្កត់កាមច្ឆន្ទៈ ដោយបទថា **វិវិច្ច អកុសលេហិ ធម្មេហិ** នេះ ជាការដែលលោកពោល ដល់ការគ្រប់សង្កត់នីវរណៈទាំង ៥ ។ ក៏ដោយការកាន់យកហើយ មិនកាន់យកទៀត លោកពោលដល់សេចក្តីស្ងាត់ ដោយការគ្រប់សង្កត់កាមច្ឆន្ទៈ ដោយឈានទី ១ , លោកពោលសេចក្តីស្ងាត់ ដោយការគ្រប់សង្កត់នីវរណៈដ៏សេស ដោយឈាន ទី ២ ។

មួយវិញទៀត លោកពោលដល់សេចក្តីស្ងាត់ ដោយការគ្រប់សង្កត់លោភៈ ដែលជាទីតាំងរបស់កាមគុណ ៥ ក្នុងអកុ-សលមូល ៣ ដោយឈានទី ១ , លោកពោលដល់សេចក្តីស្ងាត់ ដោយការគ្រប់សង្កត់ទោសៈ មោហៈដែលជាទីតាំងនៃអាឃាតវត្ថុជាដើម ដោយឈានទី ២ ។ ឬក្នុងធម៌ទាំងឡាយ មានឱឃៈ



ជាដើម លោកពោលដល់សេចក្តីស្ងាត់ ដោយការគ្រប់សង្កត់កាមោឃៈ កាមយោគៈ កាមាសវៈ កាមុបាទាន អភិជ្ឈា-កាយគន្ថៈ និងកាមរាគសំយោជនៈ ដោយឈានទី ១ , លោកពោលដល់សេចក្តីស្ងាត់ ដោយការលះបង់ឱឃៈ យោគៈ អាសវៈ ឧបាទាន គន្ថៈ និងសំយោជនៈដ៏សេសដោយឈានទី ២ ។ លោកពោលដល់សេចក្តីស្ងាត់ ដោយការគ្រប់សង្កត់កិលេសដែលសម្បយុត្តដោយតណ្ហា ដោយឈានទី ១ , លោកពោលដល់សេចក្តីស្ងាត់ដោយការគ្រប់សង្កត់កិលេស ដែលសម្បយុត្តដោយអវិជ្ជា ដោយឈានទី ២ ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា លោកពោលដល់សេចក្តីស្ងាត់ ដោយការគ្រប់សង្កត់ចិត្តុប្បាទ ៨ ដួង ដែលសម្បយុត្តដោយលោភៈ ដោយឈានទី ១ , លោកពោលដល់សេចក្តីស្ងាត់ ដោយការគ្រប់សង្កត់ចិត្តុប្បាទដែលជាអកុសល ៤ ដួង ដ៏សេស ដោយឈានទី ២ ។

ដោយហេតុត្រឹមតែប៉ុណ្ណោះ ព្រះសារីបុត្តត្ថេរ លុះសម្តែងអត្ថនៃការលះបង់ឈានទី ១ ហើយ ឥឡូវនេះ ដើម្បីសម្តែងអត្ថនៃការប្រកបរួមគ្នា ទើបពោលបទមានជាអាទិ៍ថា **សវិតក្កំ**

***សវិចារំ*** មានវិតក្កវិចារៈ ដូច្នេះ ។

ក្នុងបទទាំងនោះ **វិតក្ក** មានលក្ខណៈលើកចិត្តទុកក្នុងអារម្មណ៍ ។ **វិចារ** មានលក្ខណៈពិចារណាអារម្មណ៍ ។ កាលបើអារម្មណ៍ទាំងនោះនៅមិនទាន់ចេញទៅក្នុងទីណា ៗ វិតក្កៈ គឺ អារម្មណ៍ដែលគោងនៃចិត្តគ្រាដំបូង ដោយអត្ថថា ជាអារម្មណ៍គ្រោតគ្រាត និងដោយអត្ថថា ទៅដល់មុនដូចការគោះរគាំង , វិចារៈ គឺ អារម្មណ៍ជាប់នឹងចិត្ត ដោយអត្ថថា ជាអារម្មណ៍ល្អិត និងមានសភាពឡាយឡំដោយចិត្ត ដូចសំឡេងរគាំងបន្ទឺឡើង ។

មួយវិញទៀត វិតក្កមានការផ្សាយទៅក្នុងអារម្មណ៍ ក្នុងខណៈកើតជាគ្រាដំបូង ធ្វើឲ្យចិត្តញ័ររន្ធត់ ដូចបក្សីទទះស្លាបបំណងនឹងហើរទៅឰដ៏អាកាស , និងដូចជាឃ្មុំតាមក្លិនក្រអូបហើរឆ្ពោះទៅទំនៅលើផ្កាឈូកដូច្នោះ ។ វិចារៈមានការប្រព្រឹត្តិទៅយ៉ាងស្ងប់ មិនធ្វើចិត្តឲ្យញ័ររន្ធត់ ដូចបក្សីដែលទទះស្លាបហើរទៅកាន់ឰដ៏អាកាស និងឃ្មុំទុំលើផ្កាឈូក ហើររេរានៅលើផ្កាឈូកដូច្នោះ ។

ក៏ក្នុងអដ្ឋកថាទុកនិបាតលោកពោលទុកថា វិតក្កៈប្រព្រឹត្ត



ទៅ ដោយការលើកចិត្តទុកក្នុងអារម្មណ៍ ដូចសត្វបក្សីធំទៅកាន់ឰដ៏អាកាស យកស្លាបទាំងពីរទប់ខ្យល់ រួចធ្វើស្លាបទាំងពីរឲ្យស្ងៀមហើរទៅ , វិចារប្រព្រឹត្តទៅដោយច្របូកច្របល់អារម្មណ៍ ដូចបក្សីត្រដាងស្លាបដើម្បីទប់ខ្យល់ ហើយទើបហើរទៅដូច្នោះ ។ វិចារៈ រមែងសមគួរក្នុងការប្រព្រឹត្តទៅ ដោយការជាប់ជាមួយនឹងអារម្មណ៍នោះ ។ ចំណែកសេចក្ដីផ្សេងគ្នានៃវិតក្កវិចារនោះប្រាកដក្នុងឈានទី ១ និងឈានទី ២ ។ ម្យ៉ាងវិញទៀត វិតក្កៈ ដូចបុគ្គលដែលចាប់កាន់ភាជនៈសំរិតដែលមានស្នឹម ដោយដៃម្ខាងយ៉ាងណែន ហើយដុះដោយប្រាស់ធ្វើដោយកន្ទុយសត្វ ជ្រលូកប្រេងផង្សំដោយម្សៅម៉ត់ ដោយដៃម្ខាងទៀត វិចារៈដូចដៃដែលដុះខាត់ ។

មួយវិញទៀត វិតក្កៈ ដូចដៃម្ខាងរបស់នាយស្មូនឆ្នាំងដែលបង្វិលកង់ឈើធ្វើភាជនៈ , វិចារៈ ដូចដៃម្ខាងដែលសិតភាជនៈ ម្ដងខាងនោះ ម្ដងខាងនេះ ។ មួយវិញទៀត វិតក្កៈ លើកទឹកចិត្តទុកក្នុងអារម្មណ៍ដូច **កណ្ឌកោ** បន្លាដែលដោតទុកនៅចំកណ្ដាលរបស់អ្នកធ្វើរង្វង់មូល , វិចារៈការស្ទាបអង្អែល

អារម្មណ៍ ដូចបន្ទាដែលវិលទៅខាងក្រៅ ។ បឋមជ្ឈាន រមែងប្រព្រឹត្តទៅជាមួយវិតក្កៈ និងវិចារៈ ដូចដើមឈើ រមែងប្រព្រឹត្តទៅជាមួយផ្កាឈើ និងផ្លែ ព្រោះហេតុនោះ លោកទើបពោលឈាននេះថា **សវិតក្កំ សវិចារំ** ដូច្នេះ ។

ក្នុងបទថា **វិវេកជំ** នេះ សេចក្តីស្ងាត់ គឺ **វិវេក** សេចក្តីថា ប្រាសចាកនីវរណៈ ។ ម្យ៉ាងវិញទៀត ឈ្មោះថា **វិវេក** ព្រោះអត្ថថា ស្ងាត់ , បានដល់ ពួកធម៌ដែលសម្បយុត្តដោយឈាន ស្ងាត់ចាកវិវេក ។ ព្រោះដូច្នោះ ឈ្មោះថា **វិវេកជំ** ព្រោះអត្ថថា កើតពីវិវេក ឬកើតក្នុងវិវេកនោះ ។

ក្នុងបទថា **បីតិសុខំ** នេះ ឈ្មោះថា **បីតិ** ព្រោះអត្ថថា ឆ្អែតចិត្ត , បីតិនោះមានលក្ខណៈរីករាយ ។ បីតិនោះមាន ៥ យ៉ាងគឺ ៈ-

**ខុទ្ទកាបីតិ** បីតិតិចតួច ១ ។

**ខណិកាបីតិ** បីតិដោយខណៈ ១ ។

**ឱក្កន្តិកាបីតិ** បីតិជារយៈ ៗ ១ ។

**ឧព្វេង្គាបីតិ** បីតិធ្វើឲ្យអណ្តែតឡើង ១ ។



**ផរណាបីតិ** បីតិផ្សាយជ្រួតជ្រាប ១ ។

ក្នុងបីតិទាំងនោះ បទថា **ខុទ្ទកាបីតិ** កាលកើតឡើង អាចធ្វើឲ្យត្រឹមតែព្រឺរោមក្នុងរាងកាយប៉ុណ្ណោះ ។ បទថា **ខណិកាបីតិ** បានដល់ ការកើតឡើងដូចជាផ្លេកបន្ទោរ ជារយៈ ៗ ។ បទថា **ឱក្កន្តិកាបីតិ** បានដល់ កាលកើតឡើងធ្វើរាងកាយឲ្យឆ្អែត ហើយបាត់ទៅ ដូចរលកខ្ទប់ច្រាំង ។ បទថា **ឧព្វេង្គាបីតិ** បានដល់ បីតិមានកម្លាំងធ្វើឲ្យកាយអណ្តែតឡើង ដូចជាលោតទៅកាន់ពួដ៏អាកាសមួយរយៈ ។ បទថា **ផរណាបីតិ** បានដល់ បីតិមានកម្លាំងដ៏ខ្លាំង ។ ពិតហើយ កាលបើបីតិនោះកើតឡើង សរីរៈទាំងអស់ញាប់ញ័រដូចបស្សាវៈពេញក្រពះ និងដូចប្រានភ្នំទៅក្នុងអន្លង់ទឹកធំ ។ បីតិ ៥ យ៉ាងនោះ កាន់យកនូវ **គព្ភំ** ផ្លែដល់នូវការចាស់ដោយជុំវិញហើយ រមែងញ៉ាំងបស្សទ្ធិ ២ យ៉ាង គឺ កាយបស្សទ្ធិ ចិត្តបស្សទ្ធិ ឲ្យបរិបូរណ៍ ។ បីតិនោះ កាន់យកនូវផ្លែនៃបស្សទ្ធិដែលដល់ការចាស់ដោយជុំវិញ ហើយ រមែងញ៉ាំងសុខសូម្បី ២ យ៉ាង កាយិកសុខ និងចេតសិកសុខឲ្យបរិបូរណ៍ ។ សុខនោះកាន់យកផ្លែ គឺ គភ៌ ដល់ការចាស់

ដោយជុំវិញហើយ រមែងញុាំងសមាធិ ៣ យ៉ាង គឺ ខណិកសមាធិ ឧបចារសមាធិ និងអប្បនាសមាធិ ឲ្យបរិបូរណ៍ ។ ក្នុងបីតិទាំងនោះ បីតិដែលលោកបំណងយក ក្នុងអត្ថនេះ បានដល់ **ផរណាបីតិ** ដែលជាហេតុរបស់អប្បនាសមាធិចម្រើនលូតលាស់ហើយ ដល់ការប្រកបព្រមនៃសមាធិ ។

បទតទៅ ឈ្មោះថា **សុខំ** ព្រោះអត្ថថា ឲ្យដល់នូវសុខ , អធិប្បាយថា បីតិកើតដល់អ្នកណា , រមែងធ្វើអ្នកនោះឲ្យដល់នូវសុខ ។ មង្យ៉ាងវិញទៀត សេចក្តីសប្បាយ ឈ្មោះថា **សុខំ** , ធម្មជាតិណា រមែងទំពារស៊ីល្អ និងកម្ចាត់ការបៀតបៀនផ្លូវកាយ និងចិត្ត ឈ្មោះថា **សុខំ** , បទនេះ ជាឈ្មោះរបស់**សោមនស្សវេទនា** ។ សេចក្តីសុខនោះ មានលក្ខណៈសប្បាយរីករាយ ។ សូម្បីកាលបើបីតិ និងសុខនៅមិនទាន់ប្រាសទៅក្នុងទីណា ៗ សេចក្តីរីករាយក្នុងការបានអារម្មណ៍ដែលគួរប្រាថ្នាជា **បីតិ** , ការសោយរសដែលបានហើយជា **សុខ** ។

បីតិមាននៅក្នុងទីណា សេចក្តីសុខរមែងមានក្នុងទីនោះ ។ សេចក្តីសុខមានក្នុងទីណា បីតិរមែងមិនប្រាកដថាមានក្នុងទីនោះ



ទេ បីតិសង្គ្រោះចូលក្នុងសង្ខារក្ខន្ធ , សុខសង្គ្រោះចូលក្នុងវេទនាខន្ធ ។ បីតិដូចជាការបានឃើញ បានស្តាប់ថា មានទឹកនៅជាយព្រៃរបស់អ្នកដំណើរដែលនឿយហត់ក្នុងផ្លូវលំបាក , សុខដូចការចូលទៅអាស្រ័យក្នុងម្លប់ព្រៃ និងការផឹកទឹក ។ គប្បីជ្រាបថា លោកពោលដល់បទនេះ ព្រោះជាការប្រាកដក្នុងសម័យនោះ ៗ ។ បីតិ និងសុខនេះ មានប្រាកដដល់ឈាននោះ ឬមាននៅក្នុងឈាននោះ ព្រោះហេតុនោះ លោកទើបពោលឈាននោះថា **បីតិសុខំ** យ៉ាងនេះ ។

មង្យ៉ាងវិញទៀត បីតិ និងសុខ ឈ្មោះថា **បីតិសុខំ** ដូចធម៌ និងវិន័យ ជាដើម , បីតិសុខកើតពីវិវេក រមែងដល់ឈាននោះ ឬមានក្នុងឈាននោះ ព្រោះហេតុនោះ បីតិសុខ ទើបកើតពីវិវេកដោយការប្រការដូច្នេះ ។ សូម្បីបីតិសុខក្នុងញាណនេះ ក៏កើតពីវិវេកប៉ុណ្ណោះ ដូចគ្នានឹងឈាន ។ មួយវិញទៀត បីតិសុខមានដល់ឈាននោះ ព្រោះដូច្នោះ ការធ្វើជាអលោបសមាស សមាសដែលមិនលុបវិភត្តិ ហើយពោលថា **វិវេកជំបីតិសុខំ** បីតិសុខកើតពីវិវេក ដូច្នេះ ដោយបទតែមួយប៉ុណ្ណោះ

ក៏គួរ ។

បទថា **បឋមំ** ឈ្មោះថា **បឋម** ព្រោះតាមលំដាប់នៃការរាប់ , ឈ្មោះថា **បឋម** ព្រោះអត្ថថា កើតមុនខ្វះ ។

បទថា **ឈានំ** ឈានមាន ២ យ៉ាង គឺ **អារម្មណូបនិជ្ឈាន** សម្ងឹងអារម្មណ៍ និង **លក្ខណូបនិជ្ឈាន** សម្ងឹងលក្ខណៈ ក្នុងឈាន ២ យ៉ាងនោះ សមាបត្តិ ៨ ចូលទៅសម្ងឹងអារម្មណ៍ មានបឋវីកសិណជាដើម ឈ្មោះថា **អារម្មណូបនិជ្ឈាន** ។ វិបស្សនា មគ្គ និងផល ឈ្មោះថា **លក្ខណូបនិជ្ឈាន** ។

ក្នុងវិបស្សនា មគ្គ និងផលទាំងនោះ **វិបស្សនា** ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះចូលទៅសម្ងឹងលក្ខណៈ មានអនិច្ចលក្ខណៈជាដើម , **មគ្គ** ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះកិច្ចធ្វើដោយវិបស្សនា សម្រេចដោយមគ្គ , ចំណែកផល ឈ្មោះថា លក្ខណូបនិជ្ឈាន ព្រោះអត្ថថា ចូលទៅសម្ងឹងនិរោធសច្ចៈដែលជាលក្ខណៈដ៏ពិត ។ ក្នុងឈានទាំងពីរនោះ ក្នុងចំណែកខាងដើមនេះ លោកប្រាថ្នាយក **អារម្មណូបនិជ្ឈាន** ,



ក្នុងខណៈនៃលោកុត្តរមគ្គ លោកប្រាថ្នាយក **លក្ខណូបនិជ្ឈាន** , ព្រោះដូច្នោះ គប្បីជ្រាបថា ឈ្មោះថា **ឈាន** ព្រោះចូលទៅសម្ងឹង **អារម្មណ៍** , ចូលទៅសម្ងឹង **លក្ខណៈ** និងចូលទៅសម្ងឹង **ធម៌ដែលជាសត្រូវ** ។

បទថា **ឧបសម្បជ្ជ** គឺ ចូលដល់ , អធិប្បាយសម្រេចហើយ ។ ម្យ៉ាងវិញទៀត អធិប្បាយថា ចូលទៅដល់ហើយ គឺឲ្យសម្រេចហើយ ។

បទថា **វិហរតិ** បានដល់ ជាអ្នកមានការព្រមព្រៀងដោយឈាន មានប្រការដូចពោលហើយ ដោយធម៌ជាគ្រឿងនៅដោយឥរិយាបថដ៏សមគួរ គប្បីដល់ឈាននោះ ញុំាងកាប្រព្រឹត្តទៅនៃអត្តភាពឲ្យសម្រេច ។

ក្នុងបទថា **វិតក្កវិចារានំ វូបសមា** ព្រោះវិតក្កវិចារៈស្ងប់ទៅ គឺ ព្រោះអង្គឈានពីរយ៉ាងនេះ គឺ វិតក្កវិចារៈស្ងប់ គឺ ឈានកន្លង , អធិប្បាយថា ព្រោះមិនប្រាកដក្នុងខណៈទុតិយជ្ឈាន ។ ក្នុងបទនោះ **ធម៌** គឺ បឋមជ្ឈាន សូម្បីទាំងអស់មិនមានក្នុងទុតិយជ្ឈានក៏ពិត , តែផស្សៈជាដើម ក្នុងបឋម-

ជ្ឈានទៅមាន ។ ក្នុងទុតិយជ្ឈាននេះមិនមាន ។ គប្បីជ្រាបថា លោកពោលទុក យ៉ាងនេះថា **វិតក្កវិចារានំ វូបសមា** ដើម្បីសម្តែងថា ការសម្រេចទុតិយជ្ឈានជាដើម ពួកដទៃពីបឋមជ្ឈានរមែងមានបានព្រោះកន្លងអង្គ គ្រោតគ្រាត ។

ក្នុងបទថា **អជ្ឈត្តំ** ក្នុងខាងក្នុងនេះ លោកប្រាថ្នាយកចំណែកខាងក្នុងរបស់ខ្លួន , ព្រោះដូច្នោះ ទើបកើតក្នុងខ្លួន , អធិប្បាយថា កើតក្នុងសន្តានរបស់ខ្លួន ។

បទថា **សម្បសាទនំ** សេចក្តីផូរផង់ សទ្ធាលោកពោលថា ផូរផង់ ។ សូម្បីឈានក៏ផូរផង់ ព្រោះប្រកបដោយការជឿ ដូចសម្ពត់ពណ៌ខៀវ ព្រោះជ្រលក់ដោយពណ៌ខៀវ ។

ម្យ៉ាងវិញទៀត ព្រោះឈាននោះជាការផូរផង់នៃចិត្ត ព្រោះប្រកបដោយការជឿ និងព្រោះស្ងប់ការកម្រើករបស់វិតក្ក-វិចារៈ , ដូច្នោះ លោកទើបពោលថា **សម្បសាទនំ** ។ ក្នុងអត្ថវិកប្បនេះ គប្បីជ្រាបការភ្ជាប់បទយ៉ាងនេះថា **សម្បសាទនំ ចេតសោ** សេចក្តីផូរផង់នៃចិត្ត , ចំណែកក្នុងអត្ថវិកប្បមុន គប្បីប្រកបបទថា **ចេតសោ** នេះ ព្រមដោយស័ព្ទ **ឯកោទិភាវំ**



ភាពជាធម៌ឯកផុសឡើង ។

គប្បីជ្រាបការកែអត្ថក្នុងបទថា **ឯកោទិភាវំ** នោះ ដូចតទៅនេះ ឈ្មោះថា **ឯកោទិ** ព្រោះអត្ថថា ជាធម៌ឯកកើតឡើង អធិប្បាយថា ទុតិយជ្ឈានជាធម៌ដ៏ប្រសើរផុសឡើង ព្រោះមិនមានវិតក្កវិចារៈកើតឡើងខាងក្នុង ។ ពិតហើយ សូម្បីបុគ្គលដ៏ប្រសើរ លោកក៏ហៅថាជា **ឯក** ក្នុងលោក ។ ឬគប្បីនឹងពោលថា ទុតិយជ្ឈានជាធម៌ឯក មិនមានពីរ ព្រោះវៀរចាកវិតក្កវិចារៈយ៉ាងនេះខ្លះ ។

ម្យ៉ាងវិញទៀត ឈ្មោះថា **ឧទិ** ព្រោះកើតឡើងក្នុងសម្បយុត្តធម៌ ។ គឺ ញុំាងសម្បយុត្តធម៌ឲ្យកើតឡើង ។ ឈ្មោះថា **ឯកោទិ** ព្រោះអត្ថថា ជាធម៌ឯកកើតឡើងដោយអត្ថថាប្រសើរបំផុត ។ បទនេះ ជាឈ្មោះរបស់សមាធិ ។ ទុតិយ-ជ្ឈាននេះ ជាធម៌ឯកផុសឡើង ព្រោះញុំាងទុតិយជ្ឈាន ជាធម៌ឯកផុសឡើង ឲ្យចម្រើនលូតលាស់ល្អ ។ ព្រោះ **ឯកោទិ** នេះ ជាធម៌ឯកកើតឡើងដល់ចិត្ត មិនមែនដល់សត្វ មិនមែនដល់ជីវៈ, ដូច្នោះ លោកទើបពោលថា **ចេតសោ ឯកោទិភាវំ** សភាពជា

ធម៌ឯកកើតឡើងដល់ចិត្ត ។

សទ្ធានេះ សូម្បីក្នុងបឋមជ្ឈានក៏មាន , សមាធិនេះ មានឈ្មោះថា **ឯកោទិ** មិនមែនឬ ? បើដូច្នោះ ព្រោះហេតុអ្វីលោកទើបពោលថា **សម្បសាទនំ ចេតសោ ឯកោទិភាវំ** ទុតិយជ្ឈានដែលជាការផ្សូរផង់នៃចិត្ត , ជាធម៌ឯកផុសឡើង ។ ដោះស្រាយថា ព្រោះបឋមជ្ឈាននោះ មិនទាន់ផូរផង់ល្អ ដោយវិតក្កវិចារៈនៅកម្រើក ដូចទឹកកម្រើកដោយរលក , ដូច្នោះសូម្បីកាលបើមានសទ្ធា លោកក៏មិនពោលថា **សម្បសាទនំ** មានការផូរផង់ ។ មួយវិញទៀត សូម្បីសមាធិក្នុងបឋមជ្ឈាននេះ ក៏មិនប្រាកដដោយល្អ ព្រោះមិនទាន់ផូរផង់ , ព្រោះដូច្នោះ លោកទើបមិនពោលថា **ឯកោទិភាវំ** ។

ក្នុងឈាននេះ សទ្ធាមានកម្លាំងបានឱកាស ព្រោះមិនមានការពាក់ព័ន្ធដោយវិតក្កៈ និងវិចារៈ , សទ្ធាមានកម្លាំងសមាធិក៏ប្រាកដ ព្រោះបានមិត្តនោះឯង ។ ព្រោះដូច្នោះ គប្បីជ្រាបថាបទនេះ លោកទើបពោលទុកយ៉ាងនេះ ។

បទថា **អវិតក្កំ អវិចារំ** មិនមានវិតក្កៈ មិនមានវិចារ ។



ឈ្មោះថា **អវិតក្កំ** ព្រោះអត្ថថា វិតក្កមិនមានក្នុងឈាននេះ ឬដល់ឈាននេះ ព្រោះលះបង់បានដោយភាវនា ។ ឈ្មោះថា **អវិចារំ** ក៏ដោយន័យនេះដូចគ្នា ។

ក្នុងបទនេះ ព្រះសារីបុត្តត្ថេរពោលថា សូម្បីដោយបទនេះថា **វិតក្កវិចារានំ វូបសមា** ព្រោះវិតក្កវិចារស្ងប់រម្ងាប់ក៏ស្រេចហើយ មិនមែនឬ , បើដូច្នោះ ព្រោះហេតុអ្វី ទើបលោកពោលថា **អវិតក្កំ អវិចារំ** បន្តទៀត ។ ឆ្លើយថា ពិតយ៉ាងដូច្នោះហើយ ។ សម្រេចសេចក្តីនេះហើយ , តែបទនេះមិនសម្តែងន័យនោះ , យើងបានពោលទុកហើយមិនមែនឬថា លោកពោលទុកយ៉ាងនេះថា **អវិតក្កវិចារានំ វូបសមា** ដើម្បីសម្តែងថា ការសម្រេចទុតិយជ្ឈានជាដើម ដទៃពីបឋមជ្ឈាន ព្រោះឈានកន្លងអង្គគ្រោតគ្រាត ។

ម្យ៉ាងវិញទៀត ព្រោះវិតក្កវិចារៈស្ងប់ ឈាននេះទើបមានភាពផូរផង់ , មិនមែនផូរផង់ ព្រោះការសៅហ្មងកិលេស , មិនមែនព្រោះការប្រាកដនៃអង្គដូចបឋមជ្ឈាន ព្រោះដូច្នោះ ពាក្យពោលនេះ ទើបសម្តែងហេតុនៃការមិនមានវិតក្កវិចារយ៉ាងនេះ ។

មិនមែនសម្តែងត្រឹមតែការមិនមានវិតក្កវិចារ , តែពាក្យពោលនេះថា **អវិតក្កំ អវិចារំ** សម្តែងត្រឹមតែការមិនមានវិតក្កវិចារៈប៉ុណ្ណោះ ។ ព្រោះដូច្នោះ សូម្បីពោលទុកមុនហើយ ក៏គួរពោលបានទៀត ។

បទថា **សមាធិជំ** កើតពីសមាធិ អធិប្បាយថា ទុតិយជ្ឈាន កើតពីសមាធិក្នុងបឋមជ្ឈាន ឬសមាធិដែលដល់ព្រមហើយ ។ ក្នុងបទនោះ សូម្បីបឋមជ្ឈានកើតពីសមាធិ ដែលដល់ព្រមហើយក៏ពិត តែសមាធិនេះឯងគួរនឹងពោលថា **សមាធិ** បាន ព្រោះមិនញាប់ញ័រ និងព្រោះមិនទាន់ផូរផង់ ដោយល្អដែលវិតក្កវិចារៈនៅមានការកម្រើក ។ ព្រោះដូច្នោះ ដើម្បីពណ៌នាដល់គុណរបស់ឈាននេះ លោកទើបពោលថា **សមាធិជំ** ។ បទថា **បីតិសុខំ** នេះ មានន័យដូចពោលហើយ ។ បទថា **ទុតិយំ** គឺ ឈានទីពីរតាមលំដាប់របស់ការរាប់ , ឈ្មោះថា **ទុតិយំ** ព្រោះកើតជាលើកទីពីរខ្លះ ។

បទថា **បីតិយា ច វិរាគា** ម្យ៉ាងវិញទៀត ព្រោះបីតិអស់ទៅ សេចក្តីថា ការឃ្លាត ឬការឈានកន្លងបីតិ មានប្រការ



ដូចពោលហើយ ឈ្មោះថា **វិរាគ** , **ច** ស័ព្ទក្នុងរវាងពីរបទនោះជា **សម្បិណ្ឌនត្ថ** ចុះក្នុងអត្ថថា រួម ។ **ច** ស័ព្ទនោះ រមែងរួមសេចក្តីស្ងប់ ឬវិតក្កវិចារៈស្ងប់ ចូលជាមួយគ្នា ។ ព្រោះបីតិអស់ទៅ ក្នុងខណៈដែលរួមសេចក្តីស្ងប់ទុកបាននោះឯង , យ៉ាងណាក្តី ដោយចំពោះយ៉ាងក្រៃលែង គប្បីជ្រាបការប្រកបយ៉ាង នេះថា **វូបសមា ច** ដូច្នេះ ។

ការអស់ទៅនៃបីតិដែលប្រកបទុកនេះ មានសេចក្តីថា គួរស្អប់ , ព្រោះដូច្នោះ គប្បីឃើញសេចក្តីនេះថា ព្រោះគួរស្អប់ និងឈានកន្លងបីតិ , ព្រោះបីតិអស់ទៅក្នុងខណៈរួមសេចក្តីស្ងប់នៃវិតក្កវិចារៈទុក , យ៉ាងណាក្តី ដោយចំពោះក្រៃលែង គប្បីជ្រាបការប្រកបយ៉ាងនេះថា ព្រោះវិតក្កវិចារៈស្ងប់ដូច្នេះ ។ ការអស់បីតិដែលប្រកបទុកនេះ មានសេចក្តីថា ឈានកន្លង , ព្រោះដូច្នោះ គប្បីឃើញយ៉ាងនេះថា ព្រោះបីតិឈានកន្លងទៅ និងព្រោះវិតក្កវិចារៈស្ងប់ ។

វិតក្កវិចារៈទាំងនេះ ស្ងប់ហើយក្នុងទុតិយជ្ឈានក៏ពិត , ប៉ុន្តែ ដើម្បីសម្តែងមគ្គ និងដើម្បីពណ៌នាគុណរបស់ឈាននេះ

លោកទើបពោលបទនេះទុក ។ ពិតហើយ កាលលោកពោលថា **វិតក្កវិចារានំ វូបសមា** ឈាននេះរមែងប្រាកដថា មគ្គរបស់ឈាននេះ មានវិតក្កវិចារៈស្ងប់ដោយពិតប្រាកដ ។ មួយវិញទៀត ដូចដែលលោកពោលដល់ការលះបង់ ទុកយ៉ាងនេះថា **បញ្ចន្នំ ឱរម្ភាគិយានំ សំយោជនានំ បហានា** ព្រោះលះបង់សំយោជនៈខាងក្រោម ៥ ដូច្នេះ ជាការពណ៌នាគុណរបស់កិលេស មានសក្កាយទិដ្ឋិជាដើម សូម្បីមិនបានលះបង់ក្នុងអរិយមគ្គទី ៣ , ដើម្បីសម្រេចដល់ឈាននោះ ការពណ៌នាគុណរបស់ឈាននោះ រមែងញ៉ាំងឧស្សាហៈដើម្បីសេចក្ដីខ្វល់ខ្វាយ តទៅទៀតយ៉ាងណា , លោកពោលដល់សេចក្ដីស្ងប់របស់វិតក្កវិចារៈ សូម្បីនៅមិនទាន់ស្ងប់ក្នុងបទនេះ ក៏ជាការពណ៌នាគុណទាំងនោះដូចគ្នា ។ ដោយហេតុនោះ លោកទើបពោលសេចក្ដីនេះទុកថា **បីតិយា ច សមតិក្កមា វិតក្កវិចារានញ្ច វូបសមា** ឈានកន្លងបីតិ និងស្ងប់វិតក្កវិចារៈ ដូច្នេះ ។

ក្នុងបទថា **ឧបេក្ខា ច វិហារតិ** ភិក្ខុជាអ្នកមានឧបេក្ខានេះ មានសេចក្ដីដូចតទៅនេះ ឈ្មោះថា **ឧបេក្ខា** ព្រោះអត្ថថា



ឃើញដោយកើតឡើង , អធិប្បាយថា ឃើញរឿយ ៗ គឺជាអ្នកធ្លាក់ទៅក្នុងបក្ខពួក ឃើញហើយ ។ ជាអ្នកមានការព្រមព្រៀងក្នុងតតិយជ្ឈាន ព្រោះប្រកបដោយឧបេក្ខានោះ ដ៏បរិសុទ្ធិ ទូលំទូលាយ មានកម្លាំង លោកទើបពោលថា **ឧបេក្ខកោ** ជាអ្នកមានឧបេក្ខា ។

ឧបេក្ខា មាន ១០ យ៉ាង គឺ **ឆឡង្គុបេក្ខា ១ ព្រហ្មវិហារុបេក្ខា ១ ពោជ្ឈង្គុបេក្ខា ១ វីរិយុបេក្ខា ១ សង្ខារុបេក្ខា ១ វេទនុបេក្ខា ១ វិបស្សនុបេក្ខា ១ តត្រមជ្ឈត្តុបេក្ខា ១ ឈានុបេក្ខា ១ បារិសុទ្ធុបេក្ខា ១** ។

ក្នុងឧបេក្ខាទាំងនោះ **ឆឡង្គុបេក្ខា** គឺ ឧបេក្ខា ដែលជាអាការនៃការមិនលះបង់ភាពប្រក្រតីដ៏បរិសុទ្ធ ក្នុងគន្លងអារម្មណ៍ ៦ ទាំងដែលគួរប្រាថ្នា និងមិនគួរប្រាថ្នាក្នុងទ្វារ ៦ របស់ព្រះខីណាស្រពដែលមានមកយ៉ាងនេះថា **ឥធ ភិក្ខវេ ខីណាសវោ ភិក្ខុ រូបំ ទិស្វា នេវ សុមនោ ហោតិ ន ទុម្មនោ , ឧបេក្ខកោ ច វិហរតិ សតោ សម្បជានោ** ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាខីណាស្រពក្នុងសាសនានេះ

ឃើញរូបហើយ មិនត្រេកអរ មិនអាក់អន់ចិត្ត , ជាអ្នកមានឧបេក្ខា មានសតិសម្បជញ្ញៈ ។

**ព្រហ្មវិហារុបេក្ខា** គឺ ឧបេក្ខា ដែលមានអាការជាកណ្តាលក្នុងសត្វទាំងឡាយ ដែលមកហើយយ៉ាងនេះថា **ឧបេក្ខាសហគតេន ចេតសា ឯកំ ទិសំ ផរិត្វា វិហរតិ** ភិក្ខុមានចិត្តសហគតៈដោយឧបេក្ខាផ្សាយទៅកាន់ទិសមួយ ។

**ពោជ្ឈង្គុបេក្ខា** គឺ ឧបេក្ខា ដែលមានអាការជាកណ្តាលក្នុងធម៌ដែលកើតរួមគ្នា ដែលមកហើយយ៉ាងនេះថា **ឧបេក្ខាសម្ពោជ្ឈង្គំ ភាវេតិ វិវេកនិស្សិតំ** ភិក្ខុចម្រើនឧបេក្ខាសម្ពោជ្ឈង្គៈអាស្រ័យវិវេក ។

**វិរិយុបេក្ខា** គឺ ឧបេក្ខា បានដល់ ការព្យាយាមមិនធូរថយ ដោយការប្រារព្ធដល់ភាពមិនទៀង ដែលមកហើយយ៉ាងនេះថា **កាលេន កាលំ ឧបេក្ខានិមិត្តំ មនសិករោតិ** ភិក្ខុធ្វើទុកក្នុងចិត្តដល់ឧបេក្ខានិមិត្តគ្រប់កាល ។

**សង្ខារុបេក្ខា** គឺ ឧបេក្ខា ដែលមានភាពជាកណ្តាល ក្នុងការមិនប្រកាន់មាំ នៃការតាំងនៅ ក្នុងការពិចារណានីវរណៈជា



ដើម ដែលមកហើយយ៉ាងនេះថា **កតិ សង្ខារុបេក្ខា សមថវសេន ឧប្បជ្ជន្តិ , កតិ សង្ខារុបេក្ខា វិបស្សនាវសេន ឧប្បជ្ជន្តិ , អដ្ឋ សង្ខារុបេក្ខា សមថវសេន ឧប្បជ្ជន្តិ , ទស សង្ខារុបេក្ខា វិបស្សនាវសេន ឧប្បជ្ជន្តិ** សង្ខារុបេក្ខា រមែងកើតឡើងដោយអំណាចសមថប៉ុន្មាន , សង្ខារុបេក្ខា រមែងកើតឡើងដោយអំណាចវិបស្សនាប៉ុន្មាន , សង្ខារុបេក្ខា ៨ រមែងកើតឡើងដោយសមថៈ , សង្ខារុបេក្ខា ១០ រមែងកើតឡើងដោយអំណាចវិបស្សនា ។

**វេទនុបេក្ខា** គឺ ឧបេក្ខា ដែលមិនមែនទុក្ខ មិនមែនសុខ ដែលមកហើយយ៉ាងនេះថា **យស្មឹ សមយេ កាមាវចរំ កុសលំ ចិត្តំ ឧប្បន្នំ ហោតិ ឧបេក្ខាសហគតំ** សម័យណា ចិត្តជាកាមាវចរកុសល សហគតៈដោយឧបេក្ខាកើតឡើង ។

**វិបស្សនុបេក្ខា** គឺ ឧបេក្ខាជាកណ្តាល ក្នុងការស្រាវជ្រាវ ដែលមកហើយយ៉ាងនេះថា **យទត្ថិ យំ ភូតំ , តំ បជហតិ , ឧបេក្ខំ បដិលភតិ** ភិក្ខុរមែងលះបង់វត្ថុដែលមាន តែងតែបានឧបេក្ខា ។

**តត្រមជ្ឈត្តុបេក្ខា** គឺ ឧបេក្ខាដែលនាំសហជាតធម៌ ទៅរឿយ ៗ ដែលមកក្នុងយេវាបនកធម៌ មានឆន្ទៈជាដើម ។

**ឈានុបេក្ខា** គឺ ឧបេក្ខា ដែលញុំាងធម៌ដែលមិនឲ្យធ្លាក់ទៅក្នុងចំណែក ឲ្យកើតក្នុងឈាននោះ សូម្បីជាសុខដ៏ក្រៃលែង ដែលមកហើយយ៉ាងនេះថា **ឧបេក្ខកោ ច វិហរតិ** ភិក្ខុអ្នកមានឧបេក្ខាហើយ ។

**បារិសុទ្ធុបេក្ខា** គឺ ឧបេក្ខាដែលមិនខ្វល់ខ្វាយ សូម្បីក្នុងការស្ងប់រម្ងាប់ចាកធម៌ជាសត្រូវ បរិសុទ្ធចាកធម៌ជាសត្រូវទាំងអស់ ដែលមកហើយយ៉ាងនេះថា **ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ** ភិក្ខុចូលចតុត្ថជ្ឈានមានឧបេក្ខាជាហេតុ ឲ្យសតិបរិសុទ្ធិ ។

ក្នុងឧបេក្ខាទាំងនោះ ឆឡង្គុបេក្ខា ព្រហ្មវិហារុបេក្ខា ពោជ្ឈង្គុបេក្ខា តត្រមជ្ឈត្តុបេក្ខា ឈានុបេក្ខា និងបរិសុទ្ធុបេក្ខា ដោយអត្ថដូចគ្នា , គឺជា **តត្រមជ្ឈត្តុបេក្ខា** ។ តែឧបេក្ខាទាំងនោះផ្សេងគ្នា ដោយការផ្សេងគ្នានៃភាពប្រែប្រួល ដូចការផ្សេងរបស់មនុស្ស សូម្បីមនុស្សម្នាក់ក៏ជាកុមារ ជាកំលោះ



ជាថេរៈ ជាសេនាបតី ជាព្រះរាជាជាដើម , ព្រោះដូច្នេះគប្បីជ្រាបថា ក្នុងឧបេក្ខាទាំងនោះ ឆឡង្គុបេក្ខាមានក្នុងឈានណា , ក្នុងឈាននោះមិនមានពោជ្ឈង្គុបេក្ខាជាដើម , ឬថាក្នុងឈានណា មានពោជ្ឈង្គុបេក្ខា , ក្នុងឈាននោះ មិនមានឆឡង្គុបេក្ខាជាដើម ។

ភាពដូចគ្នា ដោយអត្ថរបស់ឧបេក្ខាទាំងនោះយ៉ាងណា , សូម្បីរបស់សង្ខារុបេក្ខា និងវិបស្សនុបេក្ខាក៏ដូច្នោះ ។ ពិតហើយឧបេក្ខានោះ គឺ បញ្ញានោះឯង , ដោយកិច្ចចែកចេញជាពីរយ៉ាង ។ ដូចជា បុរសកាលនឹងចាប់ពស់ដែលលូនចូលទៅដល់ផ្ទះ ក្នុងវេលាល្ងាច ក៏ស្វែងរកឈើជើងពពែ ឃើញពស់នោះដេកក្នុងបន្ទប់តូច ទើបសំឡឹងមើលថា ពស់ឬ មិនមែនពស់ , លុះឃើញគ្រឿងសម្គាល់ ៣ ផ្នត់ ក៏អស់សេចក្តីសង្ស័យ ភាពជាកណ្តាលក្នុងការពិនិត្យមើលថា ពស់ , មិនមែនពស់ , រមែងកើតឡើងយ៉ាងណា , កាលភិក្ខុចម្រើនវិបស្សនា ឃើញត្រៃលក្ខណ៍ធម៌ដោយវិបស្សនាញាណ ភាពជាកណ្តាលក្នុងការរាវរកត្រៃលក្ខណ៍ធម៌ មានការមិនទៀងជាដើមរបស់សង្ខារធម៌ រមែង

កើតឡើង ដូច្នោះ នេះគឺ **វិបស្សនុបេក្ខា** ។ មួយវិញទៀត កាលបើបុរសនោះយកឈើដើងពពៃចាប់ពស់ ហើយគិតថា ធ្វើយ៉ាងណា យើងនឹងមិនបៀតបៀនពស់នេះ និងមិនឲ្យពស់នេះចឹកខ្លួន គប្បីលែងទៅ ហើយរកវិធីលែងពស់នោះទៅ ក្នុងខណៈចាប់នោះ រមែងមានភាពជាកណ្តាលយ៉ាងណា , ភាពជាកណ្តាលក្នុងការប្រកាន់មាំក្នុងសង្ខារ របស់ភិក្ខុអ្នកឃើញភព ៣ ដូចឃើញភ្លើងឆេះទូទៅហើយ ព្រោះឃើញត្រៃលក្ខណ៍ ក៏ដូច្នោះ នេះគឺ **សង្ខារុបេក្ខា** ។ កាលបើវិបស្សនុបេក្ខាសម្រេចហើយ សូម្បីសង្ខារុបេក្ខា ក៏ជាការសម្រេចហើយ ដោយប្រការដូច្នេះ ។

មួយវិញទៀត ដោយបទនេះ ឧបេក្ខានេះចែកជាពីរចំណែក ដោយកិច្ច ពោលគឺ ភាពជាកណ្តាលក្នុងការពិចារណា និងការចាប់ ។ ចំណែក វីរិយុបេក្ខា និងវេទនុបេក្ខា ដោយអត្ថនៅផ្សេងគ្នា គឺ ជារបស់ផ្សេងគ្នាអំពីឧបេក្ខាដ៏សេស ។

ក្នុងអធិការនេះព្រះសារីបុត្តត្ថេរពោលថា ៖-

**ឧបេក្ខា ១០** ដោយពិស្តារ គឺ មជ្ឈត្តុបេក្ខា
ព្រហ្មវិហារុបេក្ខា ពោជ្ឈង្គុបេក្ខា ឆឡង្គុបេក្ខា



ឈានុបេក្ខា បារិសុទ្ធុបេក្ខា វិបស្សនុបេក្ខា
សង្ខារុបេក្ខា វេទនុបេក្ខា និងវិរិយុបេក្ខា ,
អំពីនោះ មានមជ្ឈត្តុបេក្ខាជាដើម ៦ ចាកអំពី
បញ្ញុបេក្ខាតែម្យ៉ាង ២ រួមគ្នាជា ៤ ។

ក្នុងបទទាំងនោះ ក្នុងទីនេះ លោកប្រាថ្នាយកឈានុ-បេក្ខា ។ ឈានុបេក្ខានោះ មានលក្ខណៈជាកណ្តាល ។ ក្នុងអធិការនេះ ព្រះសារីបុត្តត្ថេរពោលថា ឧបេក្ខានេះ ដោយអត្ថ គឺជា តត្រមជ្ឈត្តុបេក្ខា មិនមែនឬ ។ មួយវិញទៀត ឧបេក្ខានោះ សូម្បីមានក្នុងបឋមជ្ឈាន និងទុតិយជ្ឈាន , ព្រោះហេតុនោះ សូម្បីក្នុងឈាននោះ ក៏គួរពោលដល់ឧបេក្ខាយ៉ាងនេះថា **ឧបេក្ខកោ ច វិហរតិ** , ព្រោះហេតុអ្វី លោកទើបមិនពោលដល់ឧបេក្ខានោះទៅ ? ព្រោះភាពមិនមុតស្រួចជាកិច្ច ។ កិច្ចក្នុងឈាននោះ របស់ភិក្ខុនោះ ឈ្មោះថា ការមិនមុតស្រួច ព្រោះត្រូវវិតក្កៈជាដើម គ្របសង្កត់ , តែក្នុងអធិការនេះ ឧបេក្ខានេះ មានភាពវាងវៃជាកិច្ច ព្រោះមិនត្រូវវិតក្កៈ វិចារៈ បីតិគ្របសង្កត់ ដូចងើបក្បាលឡើង ព្រោះដូច្នោះ លោក

ទើបពោលទុក ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះថា **សតោ ច សម្បជានោ** ដូចតទៅនេះ ឈ្មោះថា **សតោ** ព្រោះរឭកបាន ឈ្មោះថា **សម្បជានោ** ព្រោះដឹងព្រម ។ សតិ និងសម្បជញ្ញៈ លោកពោលដោយបុគ្គល ។ ក្នុងបទនោះ សតិមានការរឭកបាន ជាលក្ខណៈ ។ សម្បជញ្ញៈមានការមិនវង្វេង ជាលក្ខណៈ ។ សតិសម្បជញ្ញៈនេះមាន សូម្បីក្នុងបុរិមឈានក៏ពិត ប៉ុន្តែអ្នកមានសតិវង្វេង មិនមានសម្បជញ្ញៈ សតិសម្បជញ្ញៈសូម្បីត្រឹមតែឧបចារៈក៏នៅមិនសម្បូរណ៍ នឹងចាំបាច់និយាយថ្វីដល់ **អប្បនា** ។ ព្រោះសតិសម្បជញ្ញៈគ្រោតគ្រាត គតិរបស់បុគ្គលនោះ រមែងជាសុខ ដូចនៅក្នុងភូមិនៃឈានទាំងនោះ , ភាពមិនវាងវៃមានសតិសម្បជញ្ញៈក្នុងគតិនោះជាកិច្ច ។

ក៏ព្រោះឈាននេះល្អិត ដោយអង្គមួយយ៉ាងគ្រោតគ្រាត គប្បីប្រាថ្នាគតិនៃចិត្តយ៉ាងនេះ កំណត់សតិសម្បជញ្ញៈជាកិច្ច ដូចបុរសប្រាថ្នាគតិក្នុងមុខកាំបិតដូច្នោះ ព្រោះហេតុនោះទើបលោកពោលទុកក្នុងទីនេះ អ្វីទៅក្រៃលែងជាងនោះ ដូចកូនគោ



ចូលទៅរកមេគោ ត្រូវបំបែកចេញពីមេគោ មិនបានទទួលការបៅឡើយ ទើបចូលទៅរកមេគោម្តងទៀត យ៉ាងណា សុខក្នុងតតិយជ្ឈានក៏ដូច្នោះ ត្រូវនាំចេញចាកបីតិ ដែលសតិសម្បជញ្ញៈមិនរក្សា គប្បីចូលទៅរកបីតិទៀត , សុខក្នុងតតិយជ្ឈានគប្បីសម្បយុត្តដោយបីតិនោះឯង ។ សត្វទាំងឡាយ រមែងត្រេកអរ សូម្បីក្នុងសេចក្តីសុខ , សេចក្តីសុខនេះមានរសផ្អែមត្រជាក់ណាស់ ព្រោះមិនមានសុខក្រៃលែងជាងនោះ ។ កាលសម្តែងសេចក្តីពិសេសរបស់អត្ថនេះថា ដោយអានុភាពរបស់សតិសម្បជញ្ញៈ សេចក្តីមិនត្រេកអរ រមែងមានក្នុងសេចក្តីសុខនេះ មិនមែនមានដោយប្រការដទៃ គប្បីជ្រាបថា លោកទើបពោលបទថា **សតោ ច សម្បជានោ** នេះទុកក្នុងទីនេះ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះថា **សុខញ្ច កាយេន បដិសំវេទេតិ** ភិក្ខុសោយសុខដោយនាមកាយដូចតទៅនេះ ភិក្ខុអ្នកមានការព្រមព្រៀងដោយតតិយជ្ឈាន រមែងមិនមានការផ្ចាប់ផ្ចំពាក់ចិត្តក្នុងការសោយសុខដោយពិត , សូម្បីដូច្នោះ ព្រោះសុខសម្បយុត្តដោយនាមកាយរបស់ភិក្ខុនោះ ,

សុខសម្បយុត្តដោយនាមកាយជារបស់ធម្មតា , ព្រោះរូបកាយរបស់ភិក្ខុនោះ ត្រូវរូបដែលប្រណីតក្រៃលែង ដែលមានសេចក្តីសុខនោះជា សមុដ្ឋានពាល់ត្រូវហើយ , ភិក្ខុសូម្បីចេញពីឈានព្រោះរូបប្រណីតពាល់ត្រូវហើយ ក៏គប្បីសោយសេចក្តីសុខបាន , ដូច្នោះ ព្រះសារីបុត្ត កាលបើសម្តែងសេចក្តីនេះ ទើបពោលថា **សុខញ្ច កាយេន បដិសំវេទេតិ** ដូច្នេះ ។

ឥឡូវនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបទនេះថា **យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារី** ដូចតទៅនេះ ភិក្ខុចូលតតិយជ្ឈាន ដែលព្រះអរិយជាម្ចាស់ទាំងឡាយសរសើរថា អ្នកបានឈាននេះ ជាអ្នកមានឧបេក្ខា មានសតិនៅជាសុខ ដូចតទៅនេះ ព្រះអរិយជាម្ចាស់ទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ជាដើម រមែងប្រាប់ រមែងសម្តែង រមែងបញ្ញត្តិ រមែងតែងតាំង រមែងបើកបង្ហាញ រមែងធ្វើឲ្យច្បាស់ រមែងធ្វើឲ្យងាយ រមែងប្រកាស , អធិប្បាយថា រមែងសរសើរបុគ្គលអ្នកព្រមដោយតតិយជ្ឈាននោះ ព្រោះឈានជាហេតុជាបច្ច័យ ។ សរសើរយ៉ាងណា ? សរសើរថា អ្នកបានឈាននេះ ជាអ្នកមានឧបេក្ខា



មានសតិនៅជាសុខ ។ ក្នុងបទនេះ គប្បីជ្រាបការប្រកបយ៉ាងនេះថា ភិក្ខុចូលតតិយជ្ឈាននោះនៅជាសុខ ដូច្នេះ ។

ក៏ព្រោះហេតុអ្វី ព្រះអរិយជាម្ចាស់ទាំងនោះ ទើបសរសើរបុគ្គលនោះ យ៉ាងនេះ ? ព្រោះជាអ្នកគួរដល់ការសរសើរ ។ ព្រោះថា បុគ្គលនេះកាលបើសេចក្តីសុខមានរសស្រស់ល្អ សម្រេចបារមីដែលជាសេចក្តីសុខហើយ ក៏ជាអ្នកនៅមានឧបេក្ខាក្នុងតតិយជ្ឈាន , មិនមានអ្វីរាំងដល់សេចក្តីសុខក្នុងឈាននោះ ចាប់ទុកឡើយ ។ ភិក្ខុឈ្មោះថា មានសតិ ព្រោះសតិតាំងមាំដោយបីតិនៅមិនទាន់កើត ។

មួយវិញទៀត ព្រោះភិក្ខុសោយសុខមិនសៅហ្មង ដែលអរិយជនត្រូវការ និងអរិយជនសេពដោយនាមកាយ ដូច្នោះ ទើបជាអ្នកគួរដល់ការសរសើរ ។ ព្រោះភិក្ខុជាអ្នកគួរដល់ការសរសើរ ព្រះអរិយជាម្ចាស់ទាំងនោះ ទើបប្រកាសបុគ្គលនោះក្នុងគុណដែលជាហេតុគួរដល់ការសរសើរ យ៉ាងនេះ គប្បីជ្រាបថា លោកសរសើរទុកយ៉ាងនេះថា **ឧបេក្ខកោ សតិមា សុខវិហារី** ជាអ្នកមានឧបេក្ខា មានសតិនៅជាសុខ ដូច្នេះ ។ បទថា

**តតិយំ** ឈ្មោះថា **តតិយ** ព្រោះតាមលំដាប់នៃការរាប់ ។ ឈ្មោះថា **តតិយ** ព្រោះកើតជាលើកទី ៣ ខ្វះ ។

បទថា **សុខស្ស ច បហានា ទុក្ខស្ស ច បហានា** ព្រោះលះបង់សុខ និងទុក្ខ បានដល់ ព្រោះលះបង់សុខផ្លូវកាយ និងលះបង់ទុក្ខផ្លូវកាយ ។

បទថា **បុព្វេវ** គឺ ព្រោះលះបង់សុខ និងទុក្ខនោះអំពីមុន ៗ បាន មិនមែនលះបង់បានក្នុងខណៈចតុត្ថជ្ឈាន ។ បទថា **សោមនស្សទោមនស្សានំ អត្ថង្គមា** ព្រោះរំលត់សោមនស្ស និងទោមនស្សបាន គឺ ព្រោះរំលត់សោមនស្ស និងទោមនស្ស ទាំងពីរនេះ គឺ សុខផ្លូវចិត្តនិងទុក្ខផ្លូវចិត្តអំពីមុន ៗ បាន ដែលលោកពោលថា **បហានា** ព្រោះលះបង់យ៉ាងនេះ ដោយប្រការដូច្នេះ ។

ទាំងពីរនោះ នឹងលះបង់បានពេលណា ? លះបង់បានក្នុងខណៈឧបចារនៃឈាន ៤ ពិតហើយ សោមនស្សលះបង់បានក្នុងខណៈឧបចារនៃឈានទី ៤ ប៉ុណ្ណោះ , ទុក្ខ ទោមនស្ស សុខ លះបង់បានក្នុងខណៈឧបចារនៃឈានទី ១ ទី ២ និងទី ៣ ។



កាលបើលោកមិនពោលឈានទាំងនេះ តាមលំដាប់នៃការលះបង់យ៉ាងនេះ តែក្នុងឥន្ទ្រិយវិភង្គ គប្បីជ្រាបការលះបង់សុខ ទុក្ខ សោមនស្ស និងទោមនស្សទុកក្នុងទីនេះ តាមលំដាប់នៃឧទ្ទេសរបស់ឥន្ទ្រិយទាំងឡាយ ។

ប្រសិនបើថា សុខ ទុក្ខ សោមនស្ស និងទោមនស្ស ទាំងនេះ លះបង់បានក្នុងខណៈឧបចារនៃឈាននោះ ៗ ដែរ , ដូច្នោះហេតុអ្វី ព្រះសម្ពុទ្ធទើបសម្តែង **និរោធ** នោះ ទុកក្នុងឈានយ៉ាងនេះថា **ក៏ទុក្ខិន្ទ្រិយកើតហើយ រមែងរលត់មិនមាន**
**សល់ក្នុងទីណា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម៌វិន័យនេះ**
**ស្ងាត់ចាកកាម ។ ល ។ ចូលដល់បឋមជ្ឈានហើយ ។ ទុក្ខិ-**
**ន្ទ្រិយកើតឡើងហើយ រមែងរលត់ទៅមិនមានសល់ក្នុងទីនេះ ។**
**ទោមនស្សិន្ទ្រិយ សុខិន្ទ្រិយ សោមនស្សិន្ទ្រិយ កើតឡើងហើយ**
**រមែងរលត់ទៅមិន មានសល់ក្នុងទីណា ។ ម្នាលភិក្ខុទាំងឡាយ**
**ភិក្ខុក្នុងធម៌ វិន័យនេះ ព្រោះលះបង់សុខ និងទុក្ខបាន ។ល។**
**ចូលដល់ចតុត្ថជ្ឈាន ។ សោមនស្សិន្ទ្រិយកើតឡើងហើយ រមែង**
**រលត់ទៅមិនមានសេសសល់ក្នុងទីនេះ ព្រោះរំលត់ដ៏វិសេស ។**

ពិតហើយ ការរំលត់យ៉ាងវិសេស និងដ៏ក្រៃលែងរបស់ទុក្ខិន្ទ្រីយ៍ជាដើម ទាំងនោះមានក្នុងបឋមជ្ឈានជាដើម , មិនមែននិរោធក្នុងឧបចារប៉ុណ្ណោះរលត់ ។ និរោធរលត់ក្នុងខណៈនៃឧបចារៈ មិនមែនរលត់យ៉ាងល្អ ។ ជាការពិតណាស់ ទុក្ខិន្ទ្រិយ សូម្បីរលត់ក្នុងឧបចារៈនៃបឋមជ្ឈាន ក្នុងការពិចារណាផ្សេង ៗ ក៏គប្បីកើតឡើងដោយត្រូវរបោម និងមូសខាំជាដើម ឬដោយការលំបាកដែលមានអាសនៈមិនរៀបស្មើ មិនមែនខាងក្នុងអប្បនាប៉ុណ្ណោះ ។

ម្យ៉ាងទៀត ទុក្ខិន្ទ្រិយជាដើមនេះ សូម្បីរលត់ហើយក្នុងឧបចារៈ , ក៏ជាការពោលថា នៅរលត់មិនទាន់បានល្អនោះទេ ព្រោះនៅកម្ចាត់បដិបក្ខមិនបាន , តែកាយទាំងអស់ ក៏ឈានចុះកាន់សេចក្តីសុខដោយការផ្សាយទៅនៃបីតិក្នុងខាងក្នុងអប្បនា , មួយវិញទៀត ទុក្ខិន្ទ្រិយក៏រលត់ទៅដោយល្អ ព្រោះកាយឈានចុះកាន់សេចក្តីសុខ កម្ចាត់បដិបក្ខចេញបាន ។

ទុក្ខិន្ទ្រិយនេះ កាលនៅមានសេចក្តីលំបាកកាយ និងចិត្តរាយមាយ សូម្បីមានវិតក្កវិចារៈជាបច្ច័យ រមែងកើតឡើងដល់



ទោមនស្សិន្ទ្រិយ សូម្បីលះបង់បានហើយក្នុងឧបចារៈនៃទុតិយ-ជ្ឈាន ក្នុងការពិចារណាផ្សេង ៗ , ទុតិយជ្ឈាន រមែងកើតឡើងព្រោះមិនមានវិតក្កៈ និងវិចារៈនុ៎ះឯង ។ ទុក្ខិន្ទ្រិយ គប្បីកើតឡើងក្នុងការមានវិតក្កវិចារៈក្នុងឈានដែលទុក្ខិន្ទ្រិយកើតឡើង ។ ទុក្ខិន្ទ្រិយគប្បីកើតឡើងក្នុងឈាននោះ ព្រោះវិតក្កវិចារៈនៅលះបង់មិនទាន់បានក្នុងឧបចារៈនៃទុតិយជ្ឈាន , ក្នុងទុតិយជ្ឈានមិនត្រូវពោលដល់ការលះបង់ដូចគ្នា ព្រោះមានបច្ច័យដែលលះបង់បានហើយ ។

មួយវិញទៀត សូម្បីសុខិន្ទ្រិយលះបង់បានហើយ ក្នុងឧបចារៈនៃតតិយជ្ឈាន កាយដែលត្រូវរូបប្រណីត មានបីតិជាសមុដ្ឋាន ក៏គប្បីកើតឡើងបាន , ក្នុងតតិយជ្ឈានមិនគប្បីពោលដល់ការលះបង់ដូចគ្នា ។ ព្រោះក្នុងតតិយជ្ឈាន បីតិជាបច្ច័យនៃសេចក្តីសុខបានរលត់ទៅដោយប្រការទាំងពួង ។ ព្រោះសោ-មនស្សិន្ទ្រិយ សូម្បីលះបង់បានក្នុងឧបចារនៃចតុជ្ឈាន ក៏ជិតចូលទៅដល់ហើយដូចគ្នា ព្រោះមិនមានឧបេក្ខា ដែលជាថ្នាក់អប្បនា និងព្រោះមិនឈានកន្លងទៅដោយល្អ បីតិក៏គប្បីកើតឡើងបាន ។

ក្នុងចតុត្ថជ្ឈានមិនចាំបាច់ពោលដូចគ្នា ។ ព្រោះដូច្នោះ ទើបកាន់យកដោយមិនមានសល់ក្នុងបទនោះ ៗ ថា **ឯត្ថុប្បន្នំ ទុក្ខិន្ទ្រិយំ អបរិសេសំ និរុជ្ឈតិ** ទុក្ខិន្ទ្រិយកើតឡើងហើយ រមែងរលត់ទៅដោយមិនមានសល់ក្នុងទីនេះ ដូច្នេះ ដោយប្រការយ៉ាងនេះ ។

ក្នុងបទនេះ ព្រះថេរៈពោលថា បើដូច្នោះវេទនាសូម្បីលះបង់បានហើយក្នុងឧបចារនៃឈាននោះ ៗ យ៉ាងនេះ ហេតុអ្វីទើបនាំមករួមទុកក្នុងទីនេះទៀត ? ដើម្បីកាន់យកសុខវេទនា ។ ពិតយ៉ាងនោះ អទុក្ខមសុខវេទនា ដែលលោកពោលទុកក្នុងបទនេះថា អទុក្ខមសុខំ ជាវេទនាដ៏ល្អិតដឹងដោយលំបាក គឺ មិនអាចកាន់យកបានងាយ , ព្រោះដូច្នោះ ទើបនាំវេទនាទាំងអស់មករួមគ្នាដើម្បីកាន់យកសេចក្ដីសុខ ដូចអ្នកចិញ្ចឹមគោ នាំគោទាំងអស់មករួមគ្នាក្នុងក្រោលតែមួយ ដើម្បីនឹងចាប់គោកាច ដែលមិនមានអ្នកណាអាចចូលទៅចាប់ជិត ៗ បានព្រោះជាគោ កាចលុះចូលក្រោលហើយ ទើបនាំចេញមកម្ដងមួយក្បាល បង្គាប់ឲ្យចាប់តាមលំដាប់ថា ចាប់គោមួយក្បាលនោះ ដូច្នេះ ។ លុះ



សំដែងវេទនាទាំងនេះ ដែលនាំមករួមទុកយ៉ាងនេះហើយថា វត្ថុណាមិនមែនសុខ , មិនមែនទុក្ខ , មិនមែនសោមនស្ស , មិនមែនទោមនស្ស , វត្ថុនេះជាអទុក្ខមសុខវេទនា យ៉ាងនេះហើយ ទើបអាចកំណត់កាន់យកវេទនានេះបាន ។

ម្យ៉ាងវិញទៀត គប្បីជ្រាបថា លោកពោលដល់វេទនាទាំងនេះ ក៏ដើម្បីសំដែងហេតុរបស់ចេតោវិមុត្តិ ដោយអទុក្ខមសុខវេទនា ។ ព្រោះថា ការលះបង់សុខវេទនា និងទុក្ខជាដើម ជាបច្ច័យនៃអទុក្ខមសុខវេទនានោះ ។ ដូចលោកពោលទុកថា ម្នាលអាវុសោ បច្ច័យ ៤ នេះឯង ដើម្បីការដល់ព្រមចេតោវិមុត្តិ ដែលជាអទុក្ខមសុខវេទនា , ម្នាលអាវុសោ ភិក្ខុក្នុងធម៌វិន័យនេះ ព្រោះលះបង់សុខ និងទុក្ខ ។ល។ ចូលដល់ចតុត្ថជ្ឈានហើយ , ម្នាលអាវុសោ បច្ច័យ ៤ ទាំងនេះឯង ដើម្បីសេចក្ដីដល់ព្រមនៃចេតោវិមុត្តិដែលជា អទុក្ខមសុខវេទនា ។

ម្យ៉ាងវិញទៀត លោកពោលដល់សក្កាយទិដ្ឋិជាដើម សូម្បីលះបង់បានហើយក្នុងទីដទៃ ក៏ជាការលះបង់បានក្នុងទីនោះ ដើម្បីពណ៌នាគុណរបស់អនាគាមិមគ្គ យ៉ាងណា , គប្បីជ្រាបថា លោក

ពោលដល់វេទនាទាំងនោះទុកទីនេះ ក៏ដើម្បីពណ៌នាគុណ របស់ឈាននេះ ដូច្នោះ ។ ម្យ៉ាងវិញទៀត គប្បីជ្រាបថា ក្នុងទីនេះ លោកពោលដល់វេទនាទាំងនោះ ដើម្បីសម្តែងដល់ រាគៈ ទោសៈ នៅឆ្ងាយ ដោយការកម្ចាត់ហេតុ ។ ពិតហើយ ក្នុងវេទនាទាំងនោះ សុខវេទនាជាបច្ច័យនៃសោមនស្ស , សោមនស្សជាបច្ច័យនៃរាគៈ , ទុក្ខវេទនាជាបច្ច័យនៃទោមនស្ស , ទោមនស្សជាបច្ច័យនៃទោសៈ ។ ម្យ៉ាងទៀត រាគៈ ទោសៈ ព្រមទាំងហេតុត្រូវកម្ចាត់បង់ហើយ ដោយការកម្ចាត់សុខវេទនា ជាដើម ព្រោះហេតុនោះ វេទនាទាំងនោះ ទើបនៅក្នុងទីឆ្ងាយ ។

បទថា **អទុក្ខមសុខំ** ឈ្មោះថា **អទុក្ខំ** ព្រោះមិនមានទុក្ខ , ឈ្មោះថា **អសុខំ** ព្រោះមិនមានសុខ ។ ដោយបទនេះ លោកសំដែងវេទនាទី ៣ , ដែលជាបដិបក្ខចំពោះទុក្ខ និងសុខទុកក្នុងទីនេះ ។ មិនសំដែងត្រឹមតែការមិនមានទុក្ខ និងសុខ ។ អទុក្ខមសុខវេទនា ឈ្មោះថា វេទនាទី ៣ , លោកពោលថា ឧបេក្ខាខ្លះ ។ ឧបេក្ខាវេទនានោះ មានលក្ខណៈសោយអារម្មណ៍ផ្ទុយគ្នាជាមួយនឹងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ ។



បទថា **ឧបេក្ខាសតិបារិសុទ្ធិំ** គឺ សេចក្តីបរិសុទ្ធិរបស់សតិកើតជាមួយឧបេក្ខា ។ ព្រោះសតិបរិសុទ្ធិដោយល្អក្នុងឈាននេះ , សេចក្តីបរិសុទ្ធិនៃសតិនោះ បំពេញដោយឧបេក្ខា , មិនមែនដោយហេតុដទៃ ។ ព្រោះដូច្នោះ ទើបលោកពោលបទនេះថា **ឧបេក្ខាសតិបារិសុទ្ធិំ** ។ គប្បីជ្រាបថា សេចក្តីបរិសុទ្ធិនៃសតិដោយឧបេក្ខាក្នុងទីនេះ ដោយអត្ថ បានដល់ តត្រមជ្ឈត្តតា ។ មួយវិញទៀត ក្នុងទីនេះ មិនមែនសតិបរិសុទ្ធិដោយឧបេក្ខាតែម្យ៉ាងប៉ុណ្ណោះទេ , សម្បយុត្តធម៌សូម្បីទាំងអស់ក៏បរិសុទ្ធិដែរ តែលោកពោលទេសនាដោយមាតិការបស់សតិ ។ ក្នុងវេទនាទាំងនោះ ឧបេក្ខាវេទនានេះមាននៅក្នុងឈាន ៣ ខាងក្រោមក៏ពិត ក៏ដូចដូងច័ន្ទ្រ គឺតត្រមជ្ឈត្តុបេក្ខានេះ គ្របសង្កត់ដោយតេជៈនៃធម៌ដែលជាសត្រូវមានវិតក្កជាដើម មិនបានរាត្រី គឺ ឧបេក្ខាវេទនា ដែលជាសភាគគ្នាសូម្បីមាននៅ ក៏ជាការមិនបរិសុទ្ធិ ក្នុងប្រភេទមានបឋមជ្ឈានជាដើម ដូចពន្លឺព្រះចន្ទដែលរះក្នុងពេលថ្ងៃ មិនបានរាត្រីដែលជាសភាគៈនឹងគ្នា ដោយសភាពជាដួងច័ន្ទ ឬដោយសភាពជាឧបការៈនៃខ្លួន សូម្បីមាន

ហើយក្នុងពេលថ្ងៃ ក៏មិនបរិសុទ្ធិ មិនផូរផង់ ដូច្នោះ ។

មួយវិញទៀត កាលបើដួងច័ន្ទ គឺ តត្រមជ្ឈត្តុបេក្ខានោះ មិនបរិសុទ្ធិ សតិជាដើម សូម្បីជាសហជាតប្បច្ច័យ ក៏មិនបរិសុទ្ធិដែរ ដូចរស្មីរបស់ដួងច័ន្ទ ដែលមិនបរិសុទ្ធិក្នុងពេលថ្ងៃ ដូច្នោះ ។ ព្រោះដូច្នោះ ក្នុងវេទនាទាំងនោះ លោកមិនពោលដល់វេទនា សូម្បីតែមួយថា ឧបេក្ខាសតិបារិសុទ្ធិ ។ តែក្នុងទីនេះ ដួងច័ន្ទ គឺ តត្រមជ្ឈត្តុបេក្ខានេះ មិនមានការគ្របសង្កត់ដោយធម្មតេជៈ ដែលជាសត្រូវរបស់វិតក្កជាដើម និងបានរាត្រី គឺ ឧបេក្ខាវេទនាដែលសភាគៈគ្នា ទើបជាការបរិសុទ្ធិយ៉ាងក្រៃលែង ព្រោះដួងច័ន្ទ គឺ តត្រមជ្ឈត្តុបេក្ខានោះបរិសុទ្ធិ សតិជាដើម សូម្បីជាសហជាតធម៌ ក៏បរិសុទ្ធិផូរផង់ ដូចជារស្មីរបស់ដួងច័ន្ទបរិសុទ្ធិដូច្នោះ ។ ព្រោះដូច្នោះ គប្បីជ្រាបថា លោកពោលបទនេះទុកយ៉ាងនេះថា ឧបេក្ខាសតិបារិសុទ្ធឹ ដូច្នេះ ។ បទថា **ចតុត្ថំ** ឈ្មោះថា **ចតុត្ថ** ព្រោះតាមលំដាប់នៃការរាប់ , ឈ្មោះថា **ចតុត្ថ** ព្រោះកើតជាលើកទី ៤ ខ្លះ ។

ឈាន ៤ ទាំងនេះ ផ្សេងគ្នាក្នុងចំណែកខាងដើមខ្លះ ,



ក្នុងខណៈនៃមគ្គខ្លះ ។ ក្នុងចំណែកខាងដើម ផ្សេងគ្នាដោយសមាបត្តិ , ក្នុងខណៈនៃមគ្គ ផ្សេងគ្នាដោយមគ្គ ។ ពិតហើយ បឋមមគ្គនៃឈានមួយ មានហើយក្នុងបឋមជ្ឈាន , សូម្បីទុតិយមគ្គជាដើម ក៏មាននៅក្នុងបឋមជ្ឈាន ឬមាននៅក្នុងឈានឯណានីមួយ មាននៅក្នុងទុតិយជ្ឈានជាដើម ។ បឋមមគ្គនៃឈានមួយ មានក្នុងឈានណាមួយ ក្នុងទុតិយជ្ឈានជាដើម , សូម្បីទុតិយមគ្គជាដើម ក៏មាននៅក្នុងឈានណាមួយ ក្នុងទុតិយជ្ឈានជាដើម ឬមាននៅក្នុងបឋមជ្ឈាន ។

មគ្គសូម្បី ៤ យ៉ាង ដូចគ្នាខ្លះ មិនដូចគ្នាខ្លះ , ដូចគ្នាក្នុងចំណែកខ្លះដោយអំណាចឈាន ដោយប្រការដូច្នេះ ។ សេចក្តីវិសេសនៃមគ្គនោះ រមែងមាន ដោយកំណត់ឈានជាបាទ ។ ពិតហើយ កាលអ្នកបានបឋមជ្ឈានចេញចាកបឋមជ្ឈាន ហើយឃើញច្បាស់នូវមគ្គដែលកើតឡើងហើយ រមែងមានក្នុងបឋមជ្ឈាន , មួយវិញទៀត ពោជ្ឈង្គៈដែលជាអង្គនៃមគ្គ ក៏បរិបូរណ៍ហើយក្នុងបឋមជ្ឈាននេះ ។ កាលបើអ្នកបានទុតិយជ្ឈាន ចេញពីទុតិយជ្ឈានហើយ ឃើញច្បាស់នូវមគ្គដែលកើតឡើងហើយ រមែង

មានក្នុងទុតិយជ្ឈាន , អង្គនៃមគ្គក្នុងទុតិយជ្ឈាននេះ មាន ៧ យ៉ាង ។ អ្នកបានតតិយជ្ឈាន ចេញចាកតតិយជ្ឈានហើយឃើញច្បាស់នូវមគ្គដែលកើតឡើងហើយ រមែងមានក្នុងតតិយជ្ឈាន , អង្គនៃមគ្គក្នុងតតិយជ្ឈាននេះ មាន ៧ យ៉ាង , ពោជ្ឈង្គៈមាន ៦ យ៉ាង ។ ន័យនេះ រមែងបានតាំងពីចតុត្ថជ្ឈាន រហូតដល់នេវ-សញ្ញានាសញ្ញាយតនឈាន ។ ចតុកឈាន បញ្ចកឈាន រមែងកើតក្នុងការមិនមានរូប ។ មួយវិញទៀត ចតុកឈាន និងបញ្ចកឈាននោះឯងជា លោកុត្តរៈ លោកពោលថា មិនមែនជាលោកិយៈ ។ ក្នុងឈាននេះ លោកពោលទុកយ៉ាងណា ?

ភិក្ខុបានចេញអំពីឈាន មានបឋមជ្ឈានជាដើម ក្នុងឈាននេះហើយ បានសោតាបត្តិមគ្គ ហើយចម្រើនអរូបសមា-បត្តិកើតឡើងក្នុងការមិនមានរូប , មគ្គ ៣ ក្នុងឈាននោះ រមែងកើតដល់ភិក្ខុអ្នកបានឈាននោះ ។ លោករមែងកំណត់ឈានជាបាទប៉ុណ្ណោះ ដោយប្រការដូច្នេះ ។

ចំណែកព្រះថេរៈអង្គខ្លះពោលថា ខន្ធដែលជាអារម្មណ៍របស់វិបស្សនា រមែងកំណត់ ។ អង្គខ្លះពោលថា អធ្យាស្រ័យ



របស់បុគ្គល រមែងកំណត់ , អង្គខ្លះពោលថា វិបស្សនាដែលជាវុដ្ឋានគាមិនី រមែងកំណត់ ។

ក្នុងបទនោះ មានកថាតាមលំដាប់យ៉ាងនេះ មគ្គដែលកើតឡើងដល់ព្រះសុក្ខវិបស្សកៈ ដោយកំណត់វិបស្សនាខ្លះ , មគ្គដែលភិក្ខុធ្វើបឋមជ្ឈានឲ្យជាបាទ ហើយពិចារណាសង្ខារតិចតួច ៗ ឲ្យកើតឡើងខ្លះ , រមែងមាននៅក្នុងបឋមជ្ឈានទាំងនោះ ។ ក្នុងមគ្គទាំងអស់ បានដល់ ពោជ្ឈង្គៈ ៧ អង្គមគ្គ ៨ អង្គឈាន ៥ ។ វិបស្សនាដែលជាចំណែកខាងដើមរបស់មគ្គទាំងនោះ សហគតៈដោយសោមនស្សខ្លះ សហគតៈដោយឧបេក្ខាខ្លះ ដល់សភាពជាសង្ខារុបេក្ខាក្នុងវេលាចេញ ក៏ជាការសហគតៈដោយសោមនស្សទាំងនោះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបញ្ចកន័យដូចតទៅនេះ ឈានមានអង្គ ៤ មានអង្គ ៣ និងមានអង្គ ២ រមែងមានតាមលំដាប់ ក្នុងមគ្គ ដែលភិក្ខុធ្វើទុតិយជ្ឈាន តតិយជ្ឈាន និងចតុត្ថជ្ឈានឲ្យជាបាទកើតឡើង ។ ក្នុងឈានទាំងអស់ អង្គមគ្គមាន ៧ ក្នុងឈានទី ៤ ពោជ្ឈង្គៈមាន ៦ ។ ភាពវិសេសនេះ រមែងមាន

ដោយការកំណត់ឈានជាបាទ និងដោយការកំណត់វិបស្សនា ។

ពិតហើយ វិបស្សនាក្នុងចំណែកខាងដើម របស់ឈានទាំងនោះ សហគតៈដោយសោមនស្សខ្លះ សហគតៈដោយឧបេក្ខាខ្លះ , វុដ្ឋានគាមិនី សហគតៈដោយសោមនស្សប៉ុណ្ណោះ ។ អង្គឈាន ២ ដោយអំណាចនៃឧបេក្ខា និងសភាពចិត្តមានអារម្មណ៍តែមួយ ក្នុងមគ្គដែលបឋមជ្ឈានធ្វើជាបាទ ហើយកើតឡើង , អង្គនៃពោជ្ឈង្គៈ ៦ និង ៧ , ភាពវិសេសនេះ រមែងមានដោយអំណាចការនិយមទាំងពីរ ។

ពិតហើយ ក្នុងន័យនេះ វិបស្សនាក្នុងចំណែកខាងដើម សហគតៈដោយសោមនស្ស ឬសហគតៈដោយឧបេក្ខា , វុដ្ឋានគាមិនី សហគតៈដោយឧបេក្ខាប៉ុណ្ណោះ ។ សូម្បីក្នុងមគ្គដែលភិក្ខុធ្វើអរូបឈានឲ្យជាបាទឲ្យកើតឡើងហើយ ក៏គប្បីជ្រាបន័យនេះដូចគ្នា ។ ចំណែកក្នុងចតុក្កន័យនេះ គប្បីនាំវិតក្កវិចារៈចេញទៅ ហើយប្រកបចំណែកដ៏សេស ព្រោះទុតិយជ្ឈានមិនមានវិតក្កវិចារៈ ។ សមាបត្តិដែលភិក្ខុនៅក្នុងទីដែលជិតមគ្គដែលភិក្ខុចេញចាកឈានជាបាទយ៉ាងនេះហើយ ពិចារណាសង្ខារ



ណាមួយ ហើយធ្វើឲ្យកើតឡើង រមែងធ្វើសមាបត្តិឲ្យដូចនឹងខ្លួន ដូចសត្វទន្សងសំដែងពណ៌ខ្លួន ឲ្យដូចពណ៌ដី ដូច្នោះ ។

ក្នុងវាទៈរបស់ព្រះថេរៈអង្គទី ២ ពោលថា មគ្គ រមែងដូចនឹងសមាបត្តិ ដែលភិក្ខុចេញហើយ ពិចារណាដល់ធម៌ក្នុងសមាបត្តិកើតឡើង ។ សូម្បីក្នុងវាទៈរបស់ព្រះថេរនោះ គប្បីជ្រាបវិបស្សនានិយម ដោយន័យដូចពោលហើយនោះឯង ។

ក្នុងវាទៈរបស់ព្រះថេរអង្គទី ៣ ពោលថា មគ្គដូចនឹងឈានដែលធ្វើឲ្យជាបាទ តាមសមគួរដល់អជ្ឈាស្រ័យរបស់ខ្លួន ហើយ ពិចារណាធម៌ក្នុងឈានកើតឡើង ។ ឈាននោះ វៀរឈានជាបាទ ឬឈានដែលពិចារណាហើយ រមែងមិនសម្រេចដោយត្រឹមតែអជ្ឈាស្រ័យប៉ុណ្ណោះ ។ មួយវិញទៀត សូម្បីក្នុងវាទៈរបស់ព្រះថេរនេះ ក៏គប្បីជ្រាបថាជា វិបស្សនានិយម ដោយន័យដូចពោលហើយនោះឯង ។

បទថា **អយំ វុច្ចតិ សម្មាសមាធិ** នេះ លោកពោលថា សម្មាសមាធិ សេចក្តីថា សភាពដែលចិត្តមានអារម្មណ៍តែមួយ ក្នុងឈាន ៤ ទាំងនេះ ក្នុងចំណែកខាងដើមជាលោកិយៈ , ក្នុង

ចំណែកខាងចុង ជាលោកុត្តរៈ លោកពោលថា ឈ្មោះថា សម្មាសមាធិ ។ ព្រះធម្មសេនាបតីសារីបុត្រ សំដែងមគ្គសច្ចៈ ដោយលោកិយៈ និងលោកុត្តរៈ ដោយប្រការដូច្នេះ ។

អដ្ឋមគ្គទាំងអស់ក្នុងលោកិយមគ្គនោះ ជាអារម្មណ៍ណាមួយក្នុងអារម្មណ៍ ៦ តាមសមគួរ ។ ចំណែកក្នុងលោកុត្តរមគ្គ សម្មាទិដ្ឋិ ដែលជាបញ្ញាចក្ខុកម្ចាត់អវិជ្ជានុស័យ មាននិព្វានជាអារម្មណ៍នៃភាពជាអរិយៈ ប្រព្រឹត្តទៅហើយដោយការចាក់ធ្លុះអរិយសច្ច ៤ ។

**សម្មាសង្កប្ប** គឺ ការលើកឡើងកាន់បទនៃនិព្វាន ផ្លូវចិត្ត កម្ចាត់មិច្ឆាសង្កប្បៈ ៣ យ៉ាង សម្បយុត្តដោយសម្មាទិដ្ឋិនោះ របស់អ្នកមានទិដ្ឋិដល់ព្រមហើយ ។

**សម្មាវាចា** វៀរមិច្ឆាវាចា កម្ចាត់វចីទុច្ចរិត ៤ យ៉ាង សម្បយុត្តដោយសម្មាសង្កប្បៈនោះ របស់អ្នកឃើញ និងត្រិះរិះយ៉ាងនោះ ។

**សម្មាកម្មន្ត** វៀរមិច្ឆាកម្មន្តៈ កម្ចាត់មិច្ឆាកម្មន្តៈ ៣ យ៉ាង សម្បយុត្តដោយសម្មាវាចានោះ របស់អ្នកវៀរនោះឯង ។



**សម្មាអាជីវ** គឺ វៀរចាកមិច្ឆាអាជីវៈ កម្ចាត់ការបោកបញ្ឆោតជាដើម សម្បយុត្តដោយសម្មាកម្មន្តៈនោះ ជាភាពផូរផង់របស់វាចាកម្មន្តៈទាំងនោះ របស់បុគ្គលនោះ ,

**សម្មាវាយាម** ប្រារព្ធសេចក្ដីព្យាយាម កម្ចាត់សេចក្ដីខ្ជិលច្រអូស សម្បយុត្តដោយសម្មាកម្មន្តៈនោះ សមគួរដល់សម្មាកម្មន្តៈនោះ របស់បុគ្គលអ្នកតាំងនៅក្នុងសីលភូមិ ពោលគឺសម្មាវាចា សម្មាកម្មន្តៈ និងសម្មាអាជីវៈ និងឲ្យសម្រេចដោយមិនឲ្យអកុសលកើតឡើង លះបង់អកុសលដែលកើតឡើង ធ្វើកុសលដែលមិនទាន់កើតឲ្យកើតឡើង តាំងមាំនៅក្នុងកុសលដែលកើតឡើងហើយ ។

**សម្មាសតិ** សភាពមានចិត្តមិនវង្វេង កម្ចាត់មិច្ឆាសតិ សម្បយុត្តដោយសម្មាវាយាមៈនោះ របស់អ្នកព្យាយាមហើយនោះឯង និងឲ្យសម្រេចការពិចារណាកាយក្នុងកាយជាដើម ។

**សម្មាសមាធិ** សភាពចិត្តមានអារម្មណ៍តែមួយ កម្ចាត់មិច្ឆាសមាធិ សម្បយុត្តដោយសម្មាសតិនោះ របស់អ្នកដែលឃុំគ្រងចិត្ត តាំងចិត្តទុកដោយសតិដ៏ល្អក្រៃលែង ។ នេះគឺ

អដ្ឋង្គិកមគ្គដ៏ប្រសើរ ជាលោកុត្តរៈ ។

មគ្គដែលជា ទុក្ខនិរោធគាមិនីបដិបទានោះ ព្រមដោយលោកិយមគ្គ បានដល់ វិជ្ជា និង ចរណៈ ព្រោះសង្គ្រោះសម្មាទិដ្ឋិ និងសម្មាសង្កប្បៈដោយវិជ្ជា , សង្គ្រោះធម៌ដ៏សេសដោយចរណៈ ។ មួយវិញទៀត បានដល់ សមថៈ និងវិបស្សនា ព្រោះសង្គ្រោះធម៌ទាំងពីរយ៉ាងនោះដោយវិបស្សនាយានសង្គ្រោះធម៌ក្រៅពីនេះដោយសមថយាន ។ បានដល់ខន្ធ ៣ និងសិក្ខា ៣ ព្រោះសង្គ្រោះធម៌ទាំងពីរនោះ ដោយបញ្ញាខន្ធ សង្គ្រោះធម៌ ៣ យ៉ាង ក្នុងលំដាប់ធម៌នោះ ដោយសីលក្ខន្ធ សង្គ្រោះធម៌ ៣ យ៉ាងដ៏សេស ដោយសមាធិក្ខន្ធ និងសង្គ្រោះដោយអធិប្បញ្ញាសិក្ខា អធិសីលសិក្ខា អធិចិត្តសិក្ខា ។

ព្រះអរិយសាវកប្រកបដោយមគ្គ ជាអ្នកដល់ព្រមដោយវិជ្ជា និងចរណៈ ដូចបុគ្គលដើរផ្លូវឆ្ងាយ ប្រកបដោយភ្នែកអាចឃើញបាន និងដោយជើងអាចដើរបាន វៀរទីបំផុត ២ យ៉ាង គឺ វៀរកាមសុខល្លិកានុយោគ ដោយវិបស្សនាយាន វៀរអត្តកិលមថានុយោគ ដោយសមថយាន បដិបត្តិមជ្ឈិមាបដិបទា កម្ចាត់



បង់កងមោហៈ ដោយបញ្ញាខន្ធ... កងទោសៈ ដោយសីលខន្ធ... កងលោភៈ ដោយសមាធិខន្ធ ដល់សម្បត្តិ ៣ គឺ បញ្ញាសម្បទាដោយអធិប្បញ្ញាសិក្ខា , សីលសម្បទា ដោយអធិសីលសិក្ខា , សមាធិសម្បទា ដោយចិត្តសិក្ខា ហើយសម្រេចនិព្វានដែលជាអមតៈ ។ ភិក្ខុឈានចុះកាន់អរិយភូមិ ពោលគឺ សម្មត្តនិយាមដែលវិចិត្រដោយធម្មរតនៈ គឺ ពោធិបក្ខិយធម៌ ៣៧ មានលំអរក្នុងខាងដើម បទកណ្តាល និងបទចុង ដោយប្រការដូច្នេះ ។

**( ចប់ អដ្ឋកថាមគ្គសច្ចនិទ្ទេស )**

## អដ្ឋកថា សច្ចបកិណ្ណក

ក៏ក្នុងសច្ចៈ ៤ ទាំងនោះ ទុក្ខសច្ចមានលក្ខណៈបៀតបៀន , សមុទយសច្ច មានលក្ខណៈជាដែនកើត , និរោធសច្ច មានលក្ខណៈស្ងប់ , មគ្គសច្ចមគ្គសច្ច មានលក្ខណៈនាំចេញ , មយ៉ាងវិញទៀត អរិយសច្ចៈ មានបវត្តិ ( ការប្រព្រឹត្តទៅ ) មានបវត្តកៈ ( អ្នកឲ្យប្រព្រឹត្តទៅ ) មាននិវត្តិ ( ការមិនប្រព្រឹត្តទៅ ) និងមាននិវត្តកៈ ( ហេតុមិនប្រព្រឹត្តទៅ ) ជាលក្ខណៈដោយលំដាប់ និងមានសង្ខតៈ គឺ ទុក្ខ មានតណ្ហា គឺ ហេតុឲ្យកើតទុក្ខ មានអសង្ខតៈ គឺ និព្វាន និងមានទស្សនៈ គឺ មគ្គជាលក្ខណៈ ដូចគ្នា ។

ប្រសិនបើមានពាក្យសួរថា ហេតុអ្វីទើបលោកពោលអរិយសច្ច ៤ មិនតិចមិនច្រើន ? ព្រោះមិនមានដទៃផ្សេងទៀត និងព្រោះមិនគួរធ្វើយ៉ាងណាបន្ថែមទៀត ។

ព្រោះវត្ថុដទៃដែលក្រៃលែងជាងនេះ ឬអរិយសច្ចទាំងនោះនឹងគប្បីនាំចេញសូម្បីតែមួយ ក៏មិនមាន ។

**ដូចព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកថា ៖**



ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍គប្បីមកក្នុងទីនេះ ពោលថា ប្រការដែលព្រះសមណៈគោតមសម្ដែង មិនមែនទុក្ខ-អរិយសច្ច ទុក្ខអរិយសច្ចដទៃអំពីនោះទេ , យើងនឹងបញ្ញត្តទុក្ខអរិយសច្ចដទៃ អំពីនេះវៀរទុក្ខអរិយសច្ច ៤ ដូច្នេះប្រការនោះមិនមែនជាឋានៈឡើយ ជាដើម ។

**ត្រាស់ទុកទៀតថា ៖**

ម្នាលភិក្ខុទាំងឡាយ សមណៈ ឬព្រាហ្មណ៍ទាំងឡាយឯណានីមួយ គប្បីពោលយ៉ាងនេះថាប្រការដែលព្រះសមណគោតមសម្ដែងថានេះមិនមែនជាទុក្ខដែលជាអរិយសច្ចប្រការទី ១ , យើងនឹងបញ្ញត្តទុក្ខដទៃដែលជាអរិ-យសច្ចប្រការទី ១ ដោយប្រានចោលទុក្ខនេះ ដែលជាអរិយសច្ចប្រការទី ១ ចេញដូច្នេះ ប្រការនោះ មិនមែនជាឋានៈឡើយ ។

ម្យ៉ាងវិញទៀត ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងបវត្តិ ( ការប្រព្រឹត្តទៅ ) ទើបទ្រង់សម្តែងព្រមដោយហេតុ , និងសម្តែងនិវត្តិ គឺ ព្រះនិព្វាន ព្រមដោយឧបាយ គឺ មគ្គ , ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់អរិយសច្ច ៤ ជាធម៌យ៉ាងក្រៃលែងជាងនោះ នៃហេតុទាំង ២ ប្រការ គឺ របស់បវត្តិ ( ការប្រព្រឹត្តទៅ ) និងនិវត្តិ ( ការមិនប្រព្រឹត្តទៅ ) ។

ម្យ៉ាងទៀតលោកពោលដល់អរិយសច្ច ៤ ដោយអំណាចនៃតណ្ហា វត្ថុតណ្ហា តណ្ហានិរោធ និងឧបាយរំលត់តណ្ហា , និងសេចក្តីអាល័យ ត្រេកអរក្នុងសេចក្តីអាល័យ ដកនូវសេចក្តីអាល័យ និងឧបាយក្នុងការដកនូវសេចក្តីអាល័យ , ដែលគួរកំណត់ដឹងគួរលះបង់គួរធ្វើឲ្យជាក់ច្បាស់ និងគួរធ្វើឲ្យចម្រើន ។

ម្យ៉ាងទៀតក្នុងអរិយសច្ចនេះ លោកពោលទុក្ខសច្ច ជាប្រការទី១ ព្រោះទុក្ខសច្ចដឹងបានងាយ ព្រោះជារបស់គ្រោតគ្រាត និងព្រោះជារបស់ទូទៅដល់សត្វទាំងពួង ។ ដើម្បីសម្តែងដល់ហេតុនៃទុក្ខសច្ចនោះ លោកទើបពោល សមុទយសច្ចក្នុងលំដាប់តទៅ , ដើម្បីឲ្យដឹងអំពីការរំលត់ផលបាន ព្រោះរំលត់ហេតុ



ទើបពោលនិរោធសច្ចតអំពីនោះ , ដើម្បីសម្តែងឧបាយឲ្យសម្រេចនិរោធសច្ចនោះ ទើបពោល មគ្គសច្ចក្នុងទីបំផុត ។ មួយវិញទៀត លោកពោលដល់ទុក្ខសច្ច ដល់សត្វទាំងឡាយដែលត្រូវចងដោយសេចក្តីពេញចិត្ត នឹងសេចក្តីសុខក្នុងភព ទុក្ខនោះបុគ្គលមិនធ្វើ ក៏រមែងមិនមកដល់ , រមែងមិនមាន ដោយមិនប្រកាន់ខ្លួនថាជាធំ ជាដើម , តែរមែងមានបានដោយហេតុនេះ ដើម្បីឲ្យដឹង ដូច្នេះលោកទើបពោលសមុទយសច្ចក្នុងលំដាប់អំពីទុក្ខសច្ចនោះ ដើម្បីឲ្យកើតសេចក្តីជ្រះស្រឡះចិត្ត ។ ដោយការឃើញឧបាយរលាស់ចេញរបស់អ្នកស្វែងរកឧបាយ ដើម្បីរលាស់ចេញចាកទុក្ខ មានការភ័យខ្លាច ព្រោះត្រូវទុក្ខ ព្រមទាំងហេតុគ្របសង្កត់ លោកទើបពោលនិរោធសច្ចតអំពីនោះ , បន្ទាប់ពីនោះដើម្បីឃើញនិរោធ លោកទើបពោលមគ្គ ដែលធ្វើឲ្យដល់និរោធ នេះជាលំដាប់របស់អរិយសច្ចទាំងនោះ ដោយប្រការដូច្នោះ ។

ម្យ៉ាងទៀត ក្នុងអរិយសច្ចទាំងនេះ គប្បីឃើញទុក្ខសច្ចដូចជាភារៈ , គប្បីឃើញសមុទយសច្ច ដូចបន្ថែមភារៈ , គប្បី

ឃើញនិរោធសច្ច ដូចជាការដាក់ចុះនូវភារៈ , គប្បីឃើញមគ្គ-សច្ច ដូចជាឧបាយក្នុងការដាក់ចុះនូវភារៈ ។

ម្យ៉ាងវិញទៀត គួរឃើញទុក្ខសច្ច ដូចជារោគ , គួរឃើញសមុទយសច្ច ដូចជាហេតុរបស់រោគ , គួរឃើញ និរោធសច្ច ដូចការស្ងប់រោគ , គួរឃើញមគ្គសច្ច ដូចថ្នាំកែរោគ ។

ម្យ៉ាងវិញទៀត គួរឃើញទុក្ខសច្ច ដូចស្រុកកើតទុរ្ភិក្ស , គួរឃើញសមុទយសច្ច ដូចជាការមិនមានភ្លៀង , គួរឃើញនិរោធសច្ច ដូចការបាននូវម្ហូបអាហារដោយងាយ , គួរឃើញមគ្គសច្ច ដូចជាភ្លៀងធ្លាក់ត្រូវតាមរដូវកាល ។

ម្យ៉ាងវិញទៀត គប្បីប្រកបអរិយសច្ចៈទាំងនេះ ហើយគប្បីជ្រាប ដោយការប្រៀបធៀបជាមួយនឹងបុគ្គលអ្នកមានពៀរ ហេតុរបស់ពៀរ ការកម្ចាត់នូវពៀរ ឧបាយកម្ចាត់នូវពៀរ , ប្រៀបធៀបជាមួយនឹងដើមឈើមានពិស ឫសដើមឈើ ការបំផ្លាញឫស និងឧបាយកម្ចាត់ឫសនៃដើមឈើនោះ , ប្រៀបជាមួយនឹងភ័យ ហេតុរបស់ភ័យ ការមិនមានភ័យ និងឧបាយដើម្បីសម្រេចដល់ការមិនមានភ័យនោះ ។



ប្រៀបដូចជាត្រើយអាយនៃអន្លង់ទឹកធំ ត្រើយនាយ និងសេចក្តីព្យាយាមឲ្យដល់ត្រើយនាយនោះ ដោយប្រការដូច្នេះ ។

គប្បីជ្រាបសច្ចៈទាំងនេះទាំងអស់ ដោយបរមត្ថថា សូន្យ ព្រោះមិនមានអ្នកសោយ អ្នកធ្វើ អ្នករំលត់ និងអ្នកប្រព្រឹត្តទៅ ។

ដោយហេតុនោះ ទើបលោកពោលថា ៖

**ទុក្ខមេវ ហិ ន កោចិ ទុក្ខិតោ**
**ការកោ ន កិរិយាវ វិជ្ជតិ ,**
**អត្ថិ និព្វុតិ ន និព្វុតោ បុមា**
**មគ្គមត្ថិ គមកោ ន វិជ្ជតិ ។**

សេចក្តីពិត ទុក្ខប៉ុណ្ណោះមានហើយ មិនមាននរណា ៗ ទទួលទុក្ខ កិរិយា គឺ ការធ្វើមានហើយ តែអ្នកធ្វើមិនមាន , ការរំលត់មានហើយ តែបុគ្គលអ្នករំលត់មិនមាន ផ្លូវមានហើយ តែអ្នកដើរមិនមាន ។

មួយវិញទៀត លោកពោលថា ៖

**ធុវសុភសុខត្តសុញ្ញំ បុរិមទ្វយមត្តសុញ្ញមត្តំ បទំ**
**ធុវសុខត្តវិរហិតោ មគ្គោ ឥតិ សុញ្ញតា តេសុ**

សេចក្តីសូន្យក្នុងសច្ចៈ ៤ ទាំងនោះ គប្បីជ្រាបយ៉ាងនេះថា សច្ចៈ ២ បទដំបូង គឺ ទុក្ខ សមុទ័យ សូន្យចាកសេចក្តីទៀង សេចក្តីស្អាត សេចក្តីសុខ និងអត្តា អមតបទ គឺ ព្រះនិព្វាន សូន្យចាកអត្តា មគ្គសូន្យចាកការប្រកាន់មាំ សេចក្តីសុខ និងអត្តា ដូច្នេះ ។

ម្យ៉ាងទៀត សច្ចៈ ៣ យ៉ាង សូន្យចាកនិរោធ , និងនិរោធក៏សូន្យចាកសច្ចៈ ៣ យ៉ាងដ៏សេស ។ ម្យ៉ាងវិញទៀត ក្នុងសច្ចៈ ៤ ទាំងនេះ ហេតុ សូន្យចាកផល ព្រោះទុក្ខមិនមានក្នុងសមុទ័យ , និងនិរោធមិនមានក្នុងមគ្គ , ហេតុ មិនរួមគភ៌ជាមួយផល ដូចប្រក្រតីរបស់លទ្ធិទាំងឡាយ មានប្រក្រតីវាទីជាដើម ម្យ៉ាងទៀត ផល ក៏សូន្យចាកហេតុ ព្រោះទុក្ខ សមុទ័យ និងនិរោធ មគ្គ មិនស្មើគ្នា , ផលនោះ មិនដូចគ្នានឹងហេតុ តែជាហេតុជាផល ដូចពីរអណូរបស់លទ្ធិទាំងឡាយ មានសមវាយវាទីជាដើម ។ ដោយហេតុនោះ លោកទើបពោលថា ៖

**តយមិធ និរោធសុញ្ញំ តយេន តេនាបិ និព្វុតី សញ្ញា**
**សុញ្ញា ផលេន ហេតុ ផលម្បិ តំហេតុនា សុញ្ញំ**



ក្នុងទីនេះសច្ចៈ ៣ យ៉ាង សូន្យចាកនិរោធ និរោធក៏សូន្យចាកសច្ចៈ ៣ យ៉ាងនោះ សច្ចៈដែលជាហេតុ សូន្យចាកសច្ចៈដែលជាផល សូម្បីសច្ចៈដែលជាផល ក៏សូន្យចាកសច្ចៈដែលជាហេតុនោះ ដូច្នេះ ។

សច្ចៈទាំងអស់ ជាសភាគៈដល់គ្នានឹងគ្នា ដោយសេចក្តីពិត ដោយសូន្យចាកតួខ្លួន និងដោយចាក់ធ្លុះវត្ថុ ដែលធ្វើបានលំបាក ដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលអានន្ទ អ្នកសម្គាល់សេចក្តីនោះដូចម្តេច , ណាមួយនឹងធ្វើបានលំបាកជាងគ្នា ឬនឹងធ្វើឲ្យកើតឡើងបានលំបាកជាងគ្នា គឺ ការបាញ់កូនសរឲ្យប្រព្រឹត្តទៅជាប់ត ៗ គ្នា ក្នុងរន្ធដើមត្នោតដ៏តូចអំពីទីជិតដោយមិនខុស ជាមួយនឹងបុគ្គលដែលបានចាក់ចុងរោមទ្រាយដោយចុងរោមទ្រាយ ដែលបានបំបែកជា ៧ ចំណែក ហើយ ។

ព្រះអានន្ទក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើនការចាក់ចុងរោមទ្រាយ ដោយចុងរោមទ្រាយដែលបែងចេញជា ៧ ចំណែក ធ្វើបានលំបាកជាង និងឲ្យកើតឡើងបានលំបាកជាង ព្រះអង្គ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ ជនទាំងឡាយណា រមែងចាក់ធ្លុះតាមសេចក្តីពិតថា នេះទុក្ខ ។ល។ នេះទុក្ខនិរោធគាមិនីបដិបទា ជនទាំងឡាយនោះ រមែងចាក់ធ្លុះបានដ៏យ៉ាងលំបាកក្រៃលែង ដូច្នេះ ។

សច្ចៈទាំងឡាយ ជាវិសភាគៈនឹងគ្នា ព្រោះកំណត់ដោយលក្ខណៈរបស់ខ្លួន ។ សច្ចៈពីរខាងដើម ជាសភាគៈគ្នា ដោយអត្ថថា យល់ដឹងបានលំបាក ព្រោះជ្រាលជ្រៅ ព្រោះជាលោកិយៈ និងព្រោះមានអាសវៈ , ជាវិសភាគៈនឹងគ្នា ព្រោះផ្សេងគ្នាជាហេតុ និងផល និងព្រោះគួរកំណត់ដឹង និងគួរលះបង់ ។ សូម្បីពីរប្រការក្រោយ ក៏ជាសភាគៈនឹងគ្នា ព្រោះជាធម៌ដ៏ជ្រាលជ្រៅ ព្រោះយល់ដឹងបានលំបាក ព្រោះជាលោកុត្តរៈ និងព្រោះមិនមានអាសវៈ , ជាវិសភាគៈនឹងគ្នា ព្រោះភាពជាធំក្នុងវិស័យ និងព្រោះគួរធ្វើឲ្យជាក់ច្បាស់ គួរធ្វើឲ្យកើតឡើង ។

សូម្បីប្រការទី ១ និងប្រការទី ៣ ក៏ជាសភាគៈគ្នា ដោយអាងថាជាផល , ជាវិសភាគៈគ្នា ព្រោះជាសង្ខតៈ និងអសង្ខតៈ ។

សូម្បីប្រការទី ២ និងប្រការទី ៤ ក៏ជាសភាគៈនឹងគ្នា



ដោយអាងដល់ហេតុ ជាវិសភាគៈនឹងគ្នា ព្រោះជាកុសល និងអកុសលតែម្យ៉ាង , សច្ចៈទី ១ និងទី ៤ ជាសភាគៈនឹងគ្នា ព្រោះជាសង្ខតធម៌ដូចគ្នា , ជាវិសភាគៈនឹងគ្នា ព្រោះជាលោកិយៈ និងលោកុត្តរៈ , ធម៌ប្រការទី ២ និងទី ៣ ក៏ជាសភាគៈនឹងគ្នា ព្រោះជាសេក្ខៈក៏មិនមែន អសេក្ខៈក៏មិនមែន , ជាវិសភាគៈនឹងគ្នា ដោយការដឹងអារម្មណ៍ និងការមិនដឹងអារម្មណ៍ ។ លោកពោលទុកថា ៖

**ឥតិ ឯវំ បការេហិ នយេហិ ច វិចក្ខណោ**
**វិជញ្ញា អរិយសច្ចានំ សភាគវិសភាគតំ**

បណ្ឌិតអ្នកឃើញច្បាស់ដោយប្រការ និងដោយន័យយ៉ាងនេះ គប្បីដឹងច្បាស់អត្ថនៃអរិយសច្ចៈទាំងឡាយជាសភាគៈ គឺមានចំណែកស្មើគ្នា និងវិសភាគៈ គឺមានចំណែកមិនស្មើគ្នា ដោយប្រការដូច្នេះ ។

ម្យ៉ាងវិញទៀត ក្នុងអរិយសច្ចៈនេះ ទុក្ខទាំងអស់ មានតែម្យ៉ាង ដោយការប្រព្រឹត្តទៅ , មាន ២ យ៉ាង ដោយនាម និងរូប , មាន ៣ យ៉ាង ដោយប្រភេទនៃភពដែលកើត គឺ កាមភព

រូបគត និងអរូបគត , មាន ៤ យ៉ាង ដោយប្រភេទនៃអាហារ ៤ , មាន ៥ យ៉ាង ដោយប្រភេទរបស់ឧបាទានក្ខន្ធ ៥ ។

សូម្បីសមុទ័យ មានតែមយ៉ាង ដោយឲ្យវដ្ដៈប្រព្រឹត្តទៅ , មាន ២ យ៉ាង ដោយសម្បយុត្ត និងមិនសម្បយុត្តដោយទិដ្ឋិ , មាន ៣ យ៉ាង ដោយប្រភេទនៃកាមតណ្ហា ភវតណ្ហា និងវិភវតណ្ហា , មាន ៤ យ៉ាង ព្រោះជាធម៌ដែលមគ្គ ៤ គប្បីលះបង់ , មាន ៥ យ៉ាង ដោយប្រភេទនៃការត្រេកអរក្នុងរូបជាដើម , មាន ៦ យ៉ាង ដោយប្រភេទនៃពពួកតណ្ហា ៦ ។

សូម្បីនិរោធ មានតែមយ៉ាង ព្រោះជាអសង្ខតធាតុ , តែដោយបរិយាយមាន ២ យ៉ាង គឺជាសឧបាទិសេសៈ និងអនុបាទិសេសៈ , មាន ៣ យ៉ាង ដោយចូលទៅស្ងប់ភពទាំង ៣ , មាន ៤ យ៉ាង ព្រោះគប្បីចាក់ធ្លុះដោយមគ្គ ៤ , មាន ៥ យ៉ាង ដោយចូលទៅស្ងប់សេចក្ដីត្រេកអរ ៥ , មាន ៦ យ៉ាង ដោយប្រភេទនៃការអស់ទៅពពួកតណ្ហា ៦ ។

សូម្បីមគ្គ មានតែមយ៉ាង ព្រោះគប្បីធ្វើឲ្យកើត , មាន ២ យ៉ាង ដោយប្រភេទនៃសមថៈ និងវិបស្សនា , ឬដោយប្រភេទ



នៃទស្សនៈ និងភាវនា , មាន ៣ យ៉ាង ដោយប្រភេទនៃខន្ធ ៣ , ពិតហើយ មគ្គនេះ ព្រោះជាសប្បទេសធម៌ ទើបសង្គ្រោះដោយខន្ធ ៣ (សីលក្ខន្ធ សមាធិខន្ធ បញ្ញាខន្ធ) ដែលជានិប្បទេសធម៌ ដូចជាក្រុង សង្គ្រោះរួមចូលដោយរាជាណាចក្រដូច្នោះ ដូចដែលលោកពោលទុកថា ៖

ម្នាលអាវុសោវិសាខៈ ខន្ធ ៣ មិនសង្គ្រោះចូលក្នុងមគ្គមានអង្គ ៨ ដែលជាអរិយៈ ។ ម្នាលអាវុសោវិសាខៈ មគ្គមានអង្គ ៨ ដែលជាអរិយៈ សង្គ្រោះចូលក្នុងខន្ធ ៣ ។ ម្នាលអាវុសោវិសាខៈ ធម៌ទាំងនេះ គឺ សម្មាវាចា សម្មាកម្មន្តោ និងសម្មាអាជីវោ សង្គ្រោះចូលក្នុងសីលក្ខន្ធ ។ ធម៌ទាំងនេះ គឺ សម្មាវាយាមោ សម្មាសតិ និងសម្មាសមាធិ សង្គ្រោះចូលក្នុងសមាធិខន្ធ ។ ធម៌ទាំងនេះ គឺ សម្មាទិដ្ឋិ សម្មាសង្កប្បៈ សង្គ្រោះចូលក្នុងបញ្ញាខន្ធ ។ មគ្គ ៤ យ៉ាង សង្គ្រោះដោយសោតាបត្តិមគ្គជាដើម ។

មយ៉ាងវិញទៀត សច្ចៈទាំងអស់មានតែមយ៉ាង ព្រោះជាវត្ថុពិត , ឬព្រោះជាវត្ថុគប្បីដឹងដ៏ក្រៃលែង , មាន ២ យ៉ាង ព្រោះ

ជាលោកិយៈ និងលោកុត្តរៈ ឬព្រោះជាសង្ខតៈ និងអសង្ខតៈ , មាន ៣ យ៉ាង ព្រោះជាវត្ថុគប្បីលះបង់ និងជាវត្ថុមិនគប្បីលះបង់ និងជាវត្ថុគប្បីលះបង់ក៏មិនមែន ជាវត្ថុមិនគប្បីលះបង់ក៏មិនមែន ចាកទស្សនៈ និងភាវនា , មាន ៤ យ៉ាង ព្រោះជាវត្ថុគួរកំណត់ដឹង គួរលះបង់ គួរធ្វើឲ្យជាក់ច្បាស់ និងគួរធ្វើឲ្យកើតឡើង ។ លោកពោលថា ៖

**ឯវំ អរិយសច្ចានំ ទុព្ពោធានំ ពុធោ វិធឹ**

**អនេកភេទតោ ជញ្ញា ហិតាយ ច សុខាយ ច ។**

ព្រះសម្ពុទ្ធជាម្ចាស់ ទ្រង់ដឹងច្បាស់វិធីរបស់អរិយសច្ចៈយ៉ាងនេះ ដែលដឹងបានដោយលំបាក ដោយប្រភេទដ៏អនេក ដើម្បីប្រយោជន៍ និងដើម្បីសេចក្តីសុខ ដូច្នេះ ។

( ចប់អដ្ឋកថា សច្ចបកិណ្ណកៈ )



ឥឡូវនេះ ព្រះធម្មសេនាបតីចង្អុលបង្ហាញ សច្ចចតុក្កន័យក្នុងទីបំផុតតាមលំដាប់ ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់សម្តែងហើយនោះឯង ហើយសម្តែងសរុប **សុតមយញ្ញាណ** ជាមួយសច្ចចតុក្កន័យ មានជាអាទិ៍ថា **តំ ញាតដ្ឋេន ញាណំ** ឈ្មោះថា **ញាណ** ដោយអត្ថថា ដឹងធម៌នោះ , លុះព្រះធម្មសេនាបតីសម្តែងសរុបអរិយសច្ចៈទាំងអស់ ដែលលោកពោលទុកក្នុងគ្រាមុនថា **សោតាវធានេ បញ្ញា សុតមយេញាណំ** បញ្ញាក្នុងការចាំធម៌ដែលបានស្តាប់មកហើយ ឈ្មោះថា **សុតមយញ្ញាណ** ដោយប្រការដូច្នេះ ។

( ចប់អដ្ឋកថា សុតមយញ្ញាណនិទ្ទេស )

# អដ្ឋកថា សីលមយញ្ញាណនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ ក្នុងសីលមយញ្ញាណនិទ្ទេស ដូចតទៅនេះ ៖-

បទថា **បញ្ច** គឺ ការកំណត់ចំនួន ។ បទថា **សីលានិ** ជាការសម្តែងធម៌ដែលកំណត់ទុក ។ បទមានជាអាទិ៍ថា **បរិយន្តបារិសុទ្ធិសីលំ** សីល គឺ សេចក្តីបរិសុទ្ធិដែលមានទីបំផុត បានដល់ សម្តែងសីល ៥ ដោយសរុប ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា **បរិសុទ្ធបារិសុទ្ធិ** ដូចតទៅនេះ សេចក្តីបរិសុទ្ធិ ឈ្មោះថា **បរិយន្ត** ព្រោះភាពបរិសុទ្ធិមានទីបំផុត គឺ មានកំណត់ដោយការរាប់ ដូចសំពត់ ព្រោះជ្រលក់ដោយពណ៌ខៀវ ទើបហៅថា **នីលំ** ព្រោះមានពណ៌ខៀវ ។

ម្យ៉ាងវិញទៀត កាលសីលសំបូរហើយ សេចក្តីបរិសុទ្ធិ ឈ្មោះថា **បរិយន្ត** ព្រោះមានទីបំផុត គឺ អវសាន ព្រោះអ្នកមានសីលមិនទាន់សំបូរ ប្រាកដអវសានហើយ ។



ម្យ៉ាងវិញទៀត គប្បីពោលថា **សបរិយន្តា** គប្បីជ្រាបថា លោកលុប **ស** អក្សរចេញ ដូចលុប **ឧ** អក្សរ ក្នុងបទនេះថា **ទកំ ទកាសយា បវិសន្តិ** ក្រសែទឹករមែងហូរទៅកាន់សមុទ្រ ។ សេចក្តីបរិសុទ្ធិ ឈ្មោះថា **បារិសុទ្ធិ** ទើបឈ្មោះថា **បរិយន្តបារិសុទ្ធិ** , សីល គឺ បរិយន្តបារិសុទ្ធិ ឈ្មោះ **បរិយន្តបារិសុទ្ធិសីល** ។

ដោយផ្ទុយគ្នាជាមួយនឹងការពោលហើយ សេចក្តីបរិសុទ្ធិមិនមានទីបំផុត ឈ្មោះថា **អបរិយន្ត** , ឈ្មោះថា **អបរិយន្ត** ព្រោះទីបំផុតនៃសេចក្តីបរិសុទ្ធិនោះ មិនមានខ្វះ , ទីបំផុតនៃសេចក្តីបរិសុទ្ធិនោះ ចម្រើនហើយខ្វះ ។

ឈ្មោះថា **បរិបុណ្ណា** ពេញដោយល្អ ដោយអត្ថថា មិនខ្វះជាបទដ្ឋាននៃអរិយមគ្គ ព្រោះមិនដាច់ ចាប់ផ្តើមអំពីសមាទានព្រោះសូម្បីដាច់ ក៏ធ្វើឲ្យជាប់វិញបាន និងព្រោះវៀរចាកមន្ទិលសូម្បីត្រឹមតែចិត្តុប្បាទ និងព្រោះបរិសុទ្ធដូចកែវមណីដែលបរិសុទ្ធនិងដូចមាសដែលដុសខាត់យ៉ាងល្អ ដូច្នោះ ។

ឈ្មោះថា **អបរាមដ្ឋ** ព្រោះបានដោយទិដ្ឋិ ព្រោះទិដ្ឋិមិន

ចាប់យក , ម្យ៉ាងវិញទៀត ឈ្មោះថា **អបរាមដ្ឋ** ព្រោះចោទក៍មិនអាចនឹងពោលបានថា នេះជាទោស ព្រោះសីលរបស់លោក ។ ឈ្មោះថា **បដិប្បស្សទ្ធិ** ព្រោះស្ងប់សេចក្តីក្រវល់ក្រវាយទាំងពួងក្នុងខណៈអរហត្តផល ។

បទថា **អនុបសម្បន្នានំ** ឈ្មោះ **ឧបសម្បន្នា** ព្រោះដល់ព្រមហើយដោយសីលសម្បទា ដោយការសមាទានមិនមានចំណែកសល់ ។ មិនមែនឧបសម្បន្ន ទើបឈ្មោះថា **អនុបសម្បន្ន** ក្នុងបទថា **បរិយន្តសិក្ខាបទានំ** អធិប្បាយដូចតទៅនេះ ឈ្មោះថា **សិក្ខា** ដោយអត្ថថា គួរសិក្សា , ឈ្មោះថា **បទានិ** អធិប្បាយថា ចំណែកដែលគួរសិក្សា . ម្យ៉ាងវិញទៀត កុសលធម៌ទាំងអស់ ឈ្មោះថា **សិក្ខា** ព្រោះគួរបដិបត្តិឲ្យក្រៃលែងដោយការតាំងនៅក្នុងសីល , សីលទាំងឡាយ ឈ្មោះថា **បទានិ** ដោយអត្ថថាជាទីតាំងនៃសិក្ខាទាំងនោះ ព្រោះហេតុនោះទើបឈ្មោះថា **សិក្ខាបទ** ព្រោះជាចំណែកនៃសិក្ខាទាំងឡាយ , ឈ្មោះថា បរិយន្តសិក្ខាបទ ព្រោះសិក្ខាមានទីបំផុត ។ នៃអនុបសម្បន្នអ្នកមានសិក្ខាបទមានទីបំផុតទាំងនោះ ។



ម្យ៉ាងទៀត ក្នុងបទនេះ ទីបំផុតមាន ២ យ៉ាង គឺ សិក្ខាបទមានទីបំផុត ១ , កាលមានទីបំផុត ១ ។

សិក្ខាបទមានទីបំផុត ដូចម្តេច ? ឧបាសក-ឧបាសិកា មានសិក្ខាបទ ១ , ២ , ៣ , ៤ , ៥ , ៨ ឬ ១០ តាមដែលសមាទាន , សិក្ខមានា សាមណេរ សាមណេរី មានសិក្ខាបទ ១០ នេះ ឈ្មោះថា **សិក្ខាបទបរិយន្តា** មានសិក្ខាបទជាទីបំផុត ។

កាលមានទីបំផុត ដូចម្តេច ? ឧបាសក.ឧបាសិកាទាំងឡាយ ឲ្យទាន រមែងសមាទានសីល មានការចាត់ចែងអាហារចិញ្ចឹមគ្នាជាទីបំផុត , ទៅកាន់វត្ត រមែងសមាទានសីល មានវត្តជាទីបំផុត , កំណត់សីល ១ ថ្ងៃ ២ ថ្ងៃ ឬ ៣ ថ្ងៃ ឬក្រៃលែងជាងនោះ ហើយសមាទានសីល នេះឈ្មោះថា មានកាលជាទីបំផុត ។

ក្នុងទីបំផុត ២ យ៉ាងនេះ សីលដែលសមាទានហើយ ធ្វើសិក្ខាបទឲ្យមានទីបំផុត ដោយការឈោនកន្លងកាល ឬដោយការស្លាប់ រមែងស្ងប់ , សីលដែលសមាទានហើយធ្វើកាលឲ្យមានទីបំផុត ដោយការឈោនកន្លងកាលនោះ រមែងស្ងប់ ។

បទថា **អប្បរិយន្តសិក្ខាបទានំ** សិក្ខាបទមិនមានទីបំផុត

លោកពោលថា ៖

**នវ កោដិសហស្សានិ អសីតិ សតកោដិយោ**
**បញ្ញាស សតសហស្សានិ ឆត្តឹស ច បុនាបរេ ,**
**ឯតេ សំវរវិនយេ សម្ពុទ្ធេន បកាសិតា**
**បេយ្យាលមុខេន និទ្ទិដ្ឋា សិក្ខា វិនយសំវរេ ។**

ព្រះសម្មាសម្ពុទ្ធជាម្ចាស់ ទ្រង់ប្រកាសសំវរវិន័យទាំងនេះទុក **ប្រាំបួនពាន់ប្រាំបីរយកោដិ និងប្រាំលានសាមសិបប្រាំមួយ-កោដិ** និងដទៃ ៗ ទៀត ទ្រង់បញ្ញត្តសិក្ខាក្នុង **សំវរវិន័យ** ដោយមាតិកាបេយ្យាល ។

ឈ្មោះថា **អបរិយន្តានិ** មិនមានទីបំផុត ព្រោះសិក្ខាបទទាំងនោះ មិនមានទីបំផុត ដោយការសមាទានសិក្ខាបទ សូម្បីមានទីបំផុត មិនមានសល់ ដោយការគណនាយ៉ាងនេះ ព្រោះមានទីបំផុតដែលមិនបានឃើញ ព្រោះហេតុ គឺ លាភ យស ញាតិ អវយវៈ និងជីវិត និងដោយការមិនកំណត់សីលដែលគួររក្សាតទៅខាងមុខ , ឈ្មោះថា **អបរិយន្តសិក្ខាបទា** សិក្ខាបទមិនមានទីបំផុត ព្រោះអនុបសម្បន្ន មានសិក្ខាបទមិនមានទីបំផុត , នៃ



អនុបសម្បន្ន អ្នកដែលមានសិក្ខាបទ មិនមានទីបំផុតទាំងនោះម្យ៉ាងវិញទៀត អធិប្បាយថា **វុទ្ធបរិយន្តសិក្ខាបទានំ** អនុបសម្បន្នអ្នកមានសិក្ខាបទមានទីបំផុត ចម្រើនហើយ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទមានជាអាទិ៍ថា **បុថុជ្ជនកល្យា-ណកានំ** ដូចតទៅនេះ លោកពោលថា ៖

**បុថូនំ ជននាទីហិ ការណេហិ បុថុជ្ជនោ**
**បុថុជ្ជនន្តោគធត្តា បុថុវាយំ ជនោឥតិ ។**

ឈ្មោះថា **បុថុជ្ជន** ដោយហេតុមានកិលេសក្រាស់ កើតឡើងជាដើម , ព្រោះកិលេសក្រាស់នៅខាងក្នុងនៃបុថុជ្ជននោះដូច្នោះ ជននេះ ទើបជាអ្នកមានកិលេសក្រាស់ ។

សូម្បីក្នុងការឈានចុះកាន់ឈាន ដែលជាលក្ខណៈរបស់បុថុជ្ជនដូចពោលហើយ លោកក៏ពោលថា ៖

**ទុវេ បុថុជ្ជនា វុត្តា ពុទ្ធេនាទិច្ចពន្ធុនា**
**អន្ធោ បុថុជ្ជនោ ឯកោ កល្យាណោកោ បុថុជ្ជនោ ។**

ព្រះសម្ពុទ្ធជាម្ចាស់អ្នកមានផៅពង្សដូចព្រះអាទិត្យ ត្រាស់ដល់បុថុជ្ជនទុក ២ ប្រភេទ គឺ អន្ធបុថុជ្ជន ដែលល្ងង់ខ្លៅ និង

កល្យាណបុថុជ្ជន បុថុជ្ជនល្អ ។

ក្នុងបុថុជ្ជនពីរប្រភេទដូចពោលមកនោះ លោកអធិប្បាយទុកថា សីលរបស់កល្យាណបុថុជ្ជន ជាបុថុជ្ជនមានកល្យាណធម៌តាំងនៅក្នុងភាពជាកល្យាណបុថុជ្ជន ចួងផុតភាពជាអន្ធបុថុជ្ជន ដោយការប្រព្រឹត្តកល្យាណធម៌ ។ម្យ៉ាងទៀត អ្នកមានកល្យាណធម៌ក្នុងពពួកបុថុជ្ជន ឈ្មោះថា **បុថុជ្ជនកល្យាណកានំ** ។

**កុសល** ស័ព្ទ ក្នុងបទនេះថា **កុសលធម្មយុត្តានំ** រមែងប្រាកដក្នុងអត្ថមិនមានរោគ អត្ថមិនមានទោស អត្ថថាឆ្លាត និងផលនៃសេចក្តីសុខ ។

**កុសល** ស័ព្ទ ប្រាកដក្នុងអត្ថមិនមានរោគ ក្នុងបទមានជាអាទិ៍ថា **កច្ចិ នុ ភោ តោកុសលំ , កច្ចិ ភោតោ អនាមយំ** សប្បាយចិត្តឬ , មានអនាម័យល្អឬ ។

ប្រាកដក្នុងសេចក្តី មិនមានទោស ក្នុងបទមានជាអាទិ៍យ៉ាងនេះថា **កតមោ បន ភន្តេ កាយសមាចារោ កុសលោ , យោ ខោ មហារាជ កាយសមាចារោ អនវជ្ជោ** បពិត្រលោកដ៏ចម្រើន កាយសមាចារ ជាកុសល ដូចម្តេច ? មហារាជ កាយសមាចារដែលមិនមានទោស គឺ កាយសមាចារជាកុសល និងក្នុងបទមានជាអាទិ៍ថា **បុន ចបរំ ភន្តេ ឯទានុត្តរិយំ យថា ភគវា ធម្មំ ទេសេតិ កុសលេសុ ធម្មេសុ** បពិត្រលោកដ៏ចម្រើន នៅមានប្រការដទៃទៀត ប្រការដែលព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ ក្នុងកុសលធម៌ទាំងឡាយនោះ ជាធម៌មិនមានធម៌ដទៃក្រៃលែងជាង , **ប្រាកដក្នុងសេចក្តីឆ្លាត** ក្នុងបទមានជាអាទិ៍ថា **កុសលោ ត្វំ រថស្ស អង្គបច្ចង្គានំ** លោកជអ្នកឆ្លាតក្នុងចំណែកធំតូចរបស់រថ , និងស្រ្តីដែលឆ្លាត មានកុសល គឺ សេចក្តីឆ្លាតក្នុងការរាំច្រៀងដែលបានសិក្សាហើយ ។ **ប្រាកដក្នុងវិបាកជាសេចក្តីសុខ** ក្នុងប្រយោគមានជាអាទិ៍ថា **កុសលានំ ភិក្ខវេ ធម្មានំ សមាទាន ហេតុ , កុសលស្ស កម្មស្ស កតត្តា ឧបចិតត្តា** ម្នាលភិក្ខុទាំងឡាយ ព្រោះកុសលធម៌ដែលអ្នកធ្វើហើយ សន្សំហើយ ព្រោះហេតុសមាទានកុសលកម្ម ។ **កុសល** ស័ព្ទ ក្នុងទីនេះ សមគួរក្នុងការមិនមានរោគខ្លះ ក្នុងការមិនមានទោសខ្លះ ក្នុងវិបាកជាសុខខ្លះ ។

ចំណែកអធិប្បាយក្នុងពាក្យ **កុសល** ស័ព្ទ មានដូចតទៅនេះ

**កុច្ឆិតេ បាបកេ ធម្មេ សលយន្តិ ចលយន្តិ ធម្មេ កម្បេន្តិ វិទ្ធំសេន្តីតិ កុសលា** , ឈ្មោះថា **កុសល** ព្រោះអត្ថថា កម្ចាត់ ធ្វើឲ្យញាប់ញ័រ ធ្វើឲ្យកម្រើក កម្ចាត់ធម៌ដ៏លាមកគួរឲ្យខ្ពើម ។

ម្យ៉ាងវិញទៀត ឈ្មោះថា **កុសា** ព្រោះអត្ថថា រមែងនៅ គឺ រមែងប្រព្រឹត្តទៅដោយអាការគួរខ្ពើម , ឈ្មោះថា **កុសល** ព្រោះអត្ថថា កម្ចាត់ គឺ កាត់ផ្ដាច់អាការដែលគួរខ្ពើមទាំងនោះ , ម្យ៉ាងវិញទៀត ឈ្មោះថា **កុស** ព្រោះធ្វើឲ្យស្រោលស្តើង គឺ ធ្វើឲ្យអស់ដល់ទីបំផុតនូវអាការគួរខ្ពើមទាំងឡាយ បានដល់ **ញាណ** ។ ឈ្មោះថា **កុសល** ព្រោះអត្ថថា គួរកម្ចាត់ គួរកាន់យក គួរឲ្យប្រព្រឹត្តទៅដោយ កុស ញាណនោះ , ម្យ៉ាងវិញទៀត ដូចជាស្បូវក្លាំង រមែងមុតដៃសូម្បីទាំងពីរខាង យ៉ាងណា , សូម្បីកុសលធម៌ទាំងនេះ ក៏រមែងកាត់ចំណែកសៅហ្មង ដែលមានក្នុងចំណែកទាំងពីរ គឺ ដោយការកើតហើយ និងនៅមិនទាន់កើត ដូច្នោះ , ព្រោះដូច្នោះ ទើបឈ្មោះថា **កុសល** ព្រោះអត្ថថា រមែងកាត់ដូចស្បូវក្លាំង ដូច្នោះ ។

ម្យ៉ាងវិញទៀត ឈ្មោះថា **កុសល** ដោយអត្ថថា មិនមាន



រោគ ដោយអត្ថថា មិនមានទោស ឬដោយអត្ថថា កើត ព្រោះភាពជាអ្នកឆ្លាត ។ តែក្នុងទីនេះ ព្រោះលោកបំណងយកវិបស្សនាកុសលប៉ុណ្ណោះ , ដូច្នោះ ដើម្បីលះបង់ធម៌ដ៏សេស ហើយសម្ដែងវិបស្សនាកុសលប៉ុណ្ណោះ គប្បីជ្រាបថា លោកទើបធ្វើជាឯកវចនៈក្នុងបទថា **កុសលធម្មេ** ក្នុងកុសលធម៌ ។ អធិប្បាយថា ប្រកបហើយក្នុងកុសលធម៌ គឺ វិបស្សនា ព្រោះធ្វើឲ្យជាប់តគ្នា និងព្រោះធ្វើដោយសេចក្ដីគោរព ។

ក្នុងបទថា **សេក្ខបរិយន្តេ បរិបូរការីនំ** អ្នកធ្វើឲ្យបរិបូរណ៍ក្នុងធម៌ដែលជាទីបំផុតរបស់ព្រះសេក្ខៈ មានសេចក្ដីដូចតទៅនេះ , ឈ្មោះថា **សេក្ខា** ព្រោះកើតក្នុងសិក្ខា ៣ ខ្វះ , ព្រោះធម៌ទាំងនេះ របស់សេក្ខៈ ៧ ពួកខ្វះ , ព្រោះព្រះសេក្ខៈទាំងឡាយ រមែងសិក្សាដោយខ្លួនឯងខ្វះ ។ បានដល់ ធម៌ គឺ សោតាបត្តិមគ្គ សោតាបត្តិផល សកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផល និងអរហត្តមគ្គ ។ ឈ្មោះថា **សេក្ខបរិយន្តោ** ព្រោះអត្ថថា មានសេក្ខធម៌ក្នុងទីបំផុត គឺ ក្នុងអវសាន , ឬមានសេក្ខធម៌ដែលជាទីបំផុត គឺ មានកំណត់ ។ គប្បីភ្ជាប់

សេចក្ដីថា ក្នុងធម៌ដែលជាទីបំផុតរបស់ព្រះសេក្ខៈនោះ ។

ឈ្មោះថា **បរិបូរការិនោ** ព្រោះអត្ថថា កល្យាណបុថុជ្ជនរមែងធ្វើកុសលធម៌ឲ្យពេញដោយល្អ គឺ ឲ្យបរិបូរណ៌ , ឬ កល្យាណបុថុជ្ជន មានការធ្វើឲ្យពេញដោយជុំវិញ គឺ ធ្វើឲ្យបរិ-បូរណ៌ , កល្យាណបុថុជ្ជនទាំងនោះ អ្នកធ្វើឲ្យបរិបូរណ៌ក្នុងបដិបទាធម៌ ដែលជាទីបំផុតរបស់ព្រះសេក្ខៈ ដែលជាចំណែកខាងដើមនៃសោតាបត្តិមគ្គ ដោយភាពបរិបូរណ៌នៃវិបស្សនា ។

ក្នុងបទនេះ **កាយេ ច ជីវិតេ ច អនបេក្ខានំ** អ្នកមិនអាល័យក្នុងរាងកាយ និងជីវិត មានសេចក្ដីដូចតទៅនេះ បទថា **កាយេ** គឺ សរីរៈ ពិតហើយ សរីរៈ លោកពោលថា **កាយ** ព្រោះជាទីប្រជុំនៃភាពមិនស្អាតរបស់រាងកាយ មានសក់ជាដើមដែលគួរខ្ពើម និងព្រោះជាទីមកនៃរោគច្រើនរយ មានចក្ខុរោគជាដើម ។

បទថា **ជីវិតេ** បានដល់ ជីវិតិន្ទ្រិយ៍ ។ ព្រោះថា ជីវិតិ-ន្ទ្រិយ៍នោះ លោកពោលថា **ជីវិត** ព្រោះអត្ថាថា ជាហេតុឲ្យរស់នៅបាន ។ ឈ្មោះថា **អនបេក្ខា** ព្រោះអត្ថថា មិនមានអាល័យ



ក្នុងជីវិត , អធិប្បាយថា អស់ការជាប់ជំពាក់ ។ កល្យាណបុថុ-ជ្ជនទាំងនោះ អ្នកមិនអាល័យក្នុងរាងកាយ និងក្នុងជីវិតនោះ ។

ឥឡូវនេះព្រះសារីបុត្រកាលនឹងសម្ដែងហេតុរបស់អ្នកមិនអាល័យក្នុងរាងកាយ និងជីវិតនៃកល្យាណបុថុជ្ជនទាំងនោះ ទើបពោលថា **បរិច្ចត្តជីវិតានំ** អ្នកលះបង់ជីវិតហើយ ។ ពិតហើយ កល្យាណបុថុជ្ជនទាំងនោះ ជាអ្នកមិនអាល័យក្នុងរាងកាយ សូម្បីលំបាកក្នុងជីវិត សូម្បីទាល់គំនិត ដោយការលះបង់ជីវិតរបស់ខ្លួនដល់ព្រះមានព្រះភាគ ឬដល់អាចារ្យ ។

បទថា **សត្តន្នំ សេក្ខានំ** ព្រះសេក្ខៈ ៧ ពួក បានដល់ ព្រះអរិយបុគ្គល ៧ ពួក មានលោកដែលតាំងនៅក្នុងសោតា-បត្តិមគ្គជាដើម បានឈ្មោះថា **សេក្ខ** ត្រូវសិក្សាបន្ត ។

បទថា **តថាគតសាវកានំ** បានដល់ សាវករបស់ព្រះត-ថាគត ។ ពិតហើយ ព្រះអរិយបុគ្គល ៨ ពួក ឈ្មោះថា **សាវក** ព្រោះអត្ថថា ស្ដាប់ទេសនា ពាក្យទូន្មានរបស់ព្រះមានព្រះភាគដោយគោរព ដោយតាំងបសាទៈមិនញាប់ញ័រ ព្រោះកើតក្នុងជាតិដែលជាអរិយៈក្នុងទីបំផុតក្នុងការស្ដាប់ ។ សូម្បីក្នុងព្រះ-

អរិយបុគ្គលទាំងនោះ ព្រះសារីបុត្រ កាលនឹងសម្ដែងឲ្យវិសេសដល់អ្នកតាំងនៅក្នុងអរហត្តផលប៉ុណ្ណោះ ទើបលោកសម្ដែងថា **ខីណាសវានំ** ដូច្នេះ , អធិប្បាយថា ព្រះខីណាស្រពអ្នកអស់អាសវៈទាំងពួង ដោយអរហត្តមគ្គញ្ញាណ ។

បទថា **បច្ចេកពុទ្ធានំ** ឈ្មោះថា **បច្ចេកពុទ្ធ** អត្ថថា តែម្នាក់ឯងប៉ុណ្ណោះមិនមានអាចារ្យ អាស្រ័យហេតុនោះ ៗ ត្រាស់ដឹងអរិយសច្ច ៤ របស់ព្រះបច្ចេកពុទ្ធជាម្ចាស់ទាំងឡាយនោះ ។

ក្នុងបទនេះថា **តថាគតានំ** ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ៨ ប្រការ , ព្រះនាមថា **តថាគតោ** ព្រោះអត្ថថា ស្ដេចមកយ៉ាងនោះ , ស្ដេចទៅហើយយ៉ាងនោះ , ត្រាស់ដឹងនូវលក្ខណៈដែលជារបស់ពិត , ត្រាស់ដឹងធម៌ពិត តាមសេចក្ដីពិត , ទ្រង់សម្ដែងវត្ថុដែលពិត , ព្រោះទ្រង់ពោលតែពីសេចក្ដីពិត , ព្រោះជាអ្នកធ្វើយ៉ាងនោះ , ព្រោះអត្ថថា គ្របសង្កត់ ។

ព្រះមានព្រះភាគ ព្រះនាមថា **តថាគត** ស្ដេចមកហើយយ៉ាងនោះ ដូចម្ដេច ? ដូចព្រះសម្មាសម្ពុទ្ធជាម្ចាស់ទាំងឡាយអំពីមុន ទ្រង់ដល់នូវសេចក្ដីខ្វល់ខ្វាយ ស្ដេចមកហើយដើម្បី



ប្រយោជន៍ដ៏ធំទូលាយ ដល់លោកទាំងមូល ។ លោកអធិប្បាយទុកយ៉ាងណា ? អធិប្បាយទុកថា ព្រះមានព្រះភាគទាំងឡាយអំពីមុន ស្ដេចមកហើយដោយអភិនិហារឯណា , សូម្បីព្រះមានព្រះភាគរបស់យើងទាំងឡាយ ក៏ស្ដេចមកហើយ ដោយអភិនិហារនោះដូចគ្នា ។

ម្យ៉ាងវិញទៀត ព្រះមានព្រះភាគអំពីមុនទ្រង់បំពេញបារមី ៣០ គឺ បារមី ១០ ឧបបារមី ១០ បរមត្ថបារមី១០ បានដល់ ទាន សីល នេក្ខម្មៈ បញ្ញា វីរិយៈ ខន្តិ សច្ចៈ អធិដ្ឋានៈ មេត្តា ឧបេក្ខា , ទ្រង់បរិច្ចាគមហាបរិច្ចាគ ៥ ទាំងនេះ គឺ បរិច្ចាគអវយវៈ ១ ន័យន៍តា ១ ទ្រព្យ ១ រាជសម្បត្តិ ១ បុត្រភរិយា ១ , ទ្រង់បំពេញញាតត្ថចរិយា ដោយទ្រង់ប្រាប់ធម៌ ដែលគួរប្រកបក្នុងខាងដើម និងគួរប្រព្រឹត្តក្នុងខាងដើម ហើយដល់ទីបំផុតនៃពុទ្ធចរិយា ស្ដេចមកហើយ , សូម្បីព្រះមានព្រះភាគជាម្ចាស់របស់យើងទាំងឡាយ ក៏ស្ដេចទ្រង់បំពេញមកហើយ យ៉ាងនោះ ។

ម្យ៉ាងវិញទៀត ព្រះមានព្រះភាគអំពីមុន ទ្រង់ចម្រើន

ទ្រង់បរិបូរដោយសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រីយ៍ ៥ ពលៈ ៥ ពោជ្ឈង្គៈ ៧ អរិយមគ្គមានអង្គ ៨ យ៉ាងណា , សូម្បីព្រះមានព្រះភាគជាម្ចាស់របស់យើងទាំងឡាយ ក៏ស្តេចមកហើយ ដូច្នោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **តថាគតោ** បណ្ឌិតពោលថា ៖

**យថេវ ទីបង្ករពុទ្ធអាទយោ**
**សព្វញ្ញុភាវំ មុនយោ ឥធាគតា ។**
**តថា អយំ សក្យមុនីបិ អាគតោ**
**តថាគតោ វុច្ចតិ តេន ចក្ខុមា ។**

ព្រះមុនីទាំងឡាយ មានព្រះទីបង្ករសម្ពុទ្ធជាម្ចាស់ ជាដើម ដល់ភាពជាព្រះសព្វញ្ញូ ស្តេចមកហើយក្នុងលោកនេះ យ៉ាងណា , សូម្បីព្រះសក្យមុនីអ្នកមានចក្ខុនេះ ក៏ស្តេចមកហើយយ៉ាងនោះ ដោយហេតុនោះ បណ្ឌិតទើបថ្វាយព្រះនាមថា **តថាគត** ។

ព្រះមានព្រះភាគ ព្រះនាមថា **តថាគត** ព្រោះអត្ថថា ស្តេចទៅហើយដូច យ៉ាងនោះ យ៉ាងដូចម្តេច ? ព្រះមានព្រះភាគអំពីមុនដែលប្រសូតិហើយក្នុងពេលនេះ ឈ្មោះថា ស្តេចទៅហើយ ។



ព្រះមានព្រះភាគទាំងឡាយនោះ ឈ្មោះថា ស្តេចទៅហើយ យ៉ាងណា ? ព្រោះថា ព្រះមានព្រះភាគទាំងឡាយនោះ ប្រសូតិហើយក្នុងពេលនេះ ប្រតិស្ឋានព្រះបាទទាំងពីរស្មើគ្នាលើផែនដី បែរព្រះភ័ក្ត្រទៅទិសឧត្តរ ស្តេចយាងទៅដោយព្រះបាទ ៧ ជំហាន ។

សមដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលអានន្ទ ព្រះពោធិសត្វដែលប្រសូតិ
ក្នុងពេលនេះ ប្រតិស្ឋានព្រះបាទទាំងគូ
ស្មើគ្នាលើផែនដី បែរព្រះភក្ត្រទៅកាន់
ទិសឧត្តរ ស្តេចយាងទៅដោយព្រះបាទ ៧
ជំហាន មហាព្រហ្មយកស្វេត្រឆ័ត្របាំងថ្វាយ
ព្រះពោធិសត្វបានក្រឡេកមើលទិសទាំងពួង
ទ្រង់បន្លឺព្រះអសភិវាចាដ៏អង់អាចថា ៖
**អគ្គោហមស្មិ លោកស្ស , ជេដ្ឋោហមស្មិ**
**លោកស្ស សេដ្ឋោហមស្មិ លោកស្ស ,**
**អយមន្តិមា ជាតិ នត្ថិ ទានិ បុនព្ភវោតិ** ។
ប្រែថា អាត្មាអញជាកំពូកនៃលោក អាត្មា

អញជាបុគ្គលប្រសើជាងគេ ក្នុងលោក
អាត្មាអញជាចម្បងជាងគេទាំងអស់ក្នុង
លោក ជាតិនេះ ជាកំណើតចុងក្រោយ
បំផុតរបស់អាត្មាអញ អំណេះតទៅមុខ
អាត្មាអញលែងកើតទៀតហើយ ។

ក្នុងតំណើររបស់ព្រះពោធិសត្វនោះ បានឈ្មោះថាជាសេចក្តីដ៏ពិតប្រាកដ ដែលជាបុព្វនិមិត្តនៃការត្រាស់ដឹងធម៌ដ៏វិសេស ជាអនេក ។ ប្រការដែលព្រះពោធិសត្វនោះ ប្រសូតិក្នុងពេលនេះប្រតិស្ឋានព្រះបាទស្មើគ្នា នេះជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ របស់ព្រះពោធិសត្វនោះ , ការបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ជាបុព្វនិមិត្តនៃការបាននូវលោកុត្តរៈទាំងឡាយ របស់ព្រះពោធិសត្វនោះ , ការដែលស្តេចយាង ៧ ជំហាន ជាបុព្វនិមិត្តនៃការបានពោជ្ឈង្គរតនៈ ៧ ការលើកចាមរឡើង ដូចពោលទុកក្នុងបទនេះថា **សុវណ្ណទណ្ឌា វីតិបតន្តិ ចាមរា** ចាមរទាំងឡាយមានដងជាវិការនៃមាសសំយុងចុះ ដូច្នេះ ជាបុព្វនិមិត្តនៃការញាំញីតិរ្ថិយ៍ទាំងអស់ ។ ការបាំងស្វេត្រឆត្រ ជាបុព្វនិមិត្តនៃការបានស្វេត្រ-



ឆត្រដ៏ប្រសើរប្រាសចាកមន្ទិល ព្រោះការលោស់ផុតដោយអរ-ហត្តមគ្គ ការក្រឡេកមើលទៅកាន់ទិសទាំងពួង ជាបុព្វនិមិត្តនៃការបានអនាវរណញ្ញាណ គឺ ព្រះសព្វញ្ញុតញ្ញាណ , ការបន្លឺនូវវាចាដ៏អង់អាច ជាបុព្វនិមិត្តនៃការប្រព្រឹត្តទៅនៃធម្មចក្រដ៏ប្រសើរដែលមិនធ្លាប់ប្រព្រឹត្តទៅ ។ សូម្បីព្រះមានព្រះភាគជាម្ចាស់ព្រះអង្គនេះ ក៏ស្តេចទៅយ៉ាងនោះ ។ ដំណើររបស់ព្រះពោធិសត្វនោះ ជាសេចក្តីពិតប្រាកដដោយភាពនៃបុព្វនិមិត្ត នៃការបានសម្រេចធម៌ទាំងនោះ នោះឯង ។ ដោយហេតុនោះ ព្រះបុរា-ណាចារ្យ ទើបពោលថា ៖

មុហុត្តជាតោវ គវម្បតី យថា

**សមេហិ បាទេហិ ផុសីវ សុន្ធរំ ,**
**សោ វិក្កមិ សត្ត បាទានិ គោតមោ**
**សេតញ្ច ឆត្តំ អនុធារយុំ មរូ ។**
**តមោ ទិសា វិលោកេសិ សមា**
**សមន្តតោ , អដ្ឋង្គុបេតំ គិរមព្ភុទីរយិ**
**សីហោ យថា បព្វតមុទ្ធនិដ្ឋិតោ ។**

ព្រះគវម្បតិ ប្រសូតិបានមួយរយៈប៉ុណ្ណោះ
ទ្រង់សម្ផស្សផែនដីដោយព្រះបាទស្មើគ្នា , ព្រះ
ពោធិសត្វទាំងឡាយអំពីមុនព្រះគោតមនោះ ក៏
ស្តេចទ្រង់ឈានព្រះបាទ ៧ ជំហាន និងទាំងពពួក
ស្តេចទេវតានាំគ្នាបាំងស្វេត្រឆត្រ ។

ព្រះគោតមនោះស្តេចយាងទៅ ៧ ជំហាន
ទ្រង់ក្រឡេកមើលទៅកាន់ទិស ដោយជុំវិញ ,
ទ្រង់បន្លឺនូវព្រះវាចាប្រកបដោយអង្គ ៨ ដូចសីហៈ
ឈរនៅលើកំពូលភ្នំ បន្លឺសីហនាទ ដូច្នោះ ។

ទ្រង់ព្រះនាមថា **តថាគត** ព្រោះស្តេចទៅហើយយ៉ាងនោះ ដោយប្រការដូច្នេះ ។

មយ៉ាងវិញទៀត ព្រះមានព្រះភាគអំពីមុនយ៉ាងណា , សូម្បីព្រះមានព្រះភាគជាម្ចាស់អង្គនេះ ក៏ដូច្នោះដូចគ្នា ស្តេចទៅហើយដើម្បីលះបង់កាមច្ឆន្ទៈ ដោយនេក្ខម្មៈ ។ល។ លះបង់នីវរណៈដោយបឋមជ្ឈាន ។ល។ លះបង់និច្ចសញ្ញា ដោយអនិច្ចានុបស្សនា ។ល។ លះបង់កិលេសទាំងអស់ ដោយអរហត្តមគ្គ , ព្រះនាមថា **តថាគត**



ព្រោះស្តេចទៅហើយយ៉ាងនោះ ដោយប្រការដូច្នេះ ។

ព្រះនាមថា **តថាគតោ** ព្រោះត្រាស់ដឹងលក្ខណៈតាមសេចក្តីពិត យ៉ាងណា ? លក្ខណៈដែលពិត គឺ **សភាពរឹង** ជាលក្ខណៈនៃបឋវីធាតុ , **ការហូរទៅ** ជាលក្ខណៈនៃអាបោធាតុ , **សភាពក្តៅ** ជាលក្ខណៈនៃតេជោធាតុ , **ការបក់ទៅមក** ជាលក្ខណៈនៃវាយោធាតុ , **ការប៉ះពាល់មិនបាន** ជាលក្ខណៈនៃអកាសធាតុ , **ការដឹងច្បាស់** ជាលក្ខណៈនៃវិញ្ញាណធាតុ ។

**ការបែកធ្លាយ** ជាលក្ខណៈរបស់រូប , **ការសោយអារម្មណ៍** ជាលក្ខណៈនៃវេទនា , **ការចាំបាន** ជាលក្ខណៈនៃសញ្ញា , **ការតាក់តែង** ជាលក្ខណៈនៃសង្ខារ , **ការដឹងច្បាស់** ជាលក្ខណៈនៃវិញ្ញាណ ។

**ការលើកឡើង** ជាលក្ខណៈនៃវិតក្កៈ , **ការពិចារណា** ជាលក្ខណៈរបស់វិចារៈ , **ការផ្សាយទៅ** ជាលក្ខណៈរបស់បីតិ , **ការរីករាយ** ជាលក្ខណៈនៃសេចក្តីសុខ , **ការមិនរាយមាយ** ជាលក្ខណៈនៃចិត្តដែលមានអារម្មណ៍តែមួយ , **ការពាល់ត្រូវ** ជាលក្ខណៈរបស់ផស្សៈ ។

**ការបង្អោនចិត្តជឿ** ជាលក្ខណៈនៃសទ្ធិន្ទ្រីយ៍ , **ការផ្គងទុក** ជាលក្ខណៈនៃវីរិយិន្ទ្រីយ៍ , **ការតាំងមាំ** ជាលក្ខណៈនៃសតិន្ទ្រីយ៍ , **ការមិនរាយមាយ** ជាលក្ខណៈនៃសមាធិន្ទ្រីយ៍ , **ការដឹងទូទៅ** ជាលក្ខណៈនៃបញ្ញិន្ទ្រីយ៍ ។

**ភាពមិនញាប់ញ័រក្នុងការមិនជឿ** ជាលក្ខណៈនៃសទ្ធាពលៈ , **ភាពមិនញាប់ញ័រក្នុងការខ្ជិលច្រអូស** ជាលក្ខណៈនៃវីរិយពលៈ , **ភាពមិនញាប់ញ័រក្នុងការវង្វេង** ជាលក្ខណៈនៃសតិពលៈ , **ភាពមិនញាប់ញ័រក្នុងការរាយមាយ** ជាលក្ខណៈនៃសមាធិពលៈ , **ភាពមិនញាប់ញ័រក្នុងអវិជ្ជា** ជាលក្ខណៈនៃបញ្ញាពលៈ ។

**ការតាំងមាំ** ជាលក្ខណៈនៃសតិសម្ពោជ្ឈង្គៈ , **ការឈ្លាសវៃ** ជាលក្ខណៈនៃធម្មវិចយសម្ពោជ្ឈង្គៈ , **ការផ្គងទុក** ជាលក្ខណៈនៃវីរិយសម្ពោជ្ឈង្គៈ , **ការផ្សាយទៅ** ជាលក្ខណៈនៃបីតិសម្ពោជ្ឈង្គៈ , **សេចក្តីស្ងប់** ជាលក្ខណៈនៃបស្សទ្ធិសម្ពោជ្ឈង្គៈ , **ការមិនរាយមាយ** ជាលក្ខណៈនៃសមាធិសម្ពោជ្ឈង្គៈ , **ការពិចារណា** ជាលក្ខណៈនៃឧបេក្ខាសម្ពោជ្ឈង្គៈ ។



**ការឃើញ** ជាលក្ខណៈរបស់សម្មាទិដ្ឋិ , **ការលើកឡើង** ជាលក្ខណៈរបស់សម្មាសង្កប្បៈ , **ការកំណត់** ជាលក្ខណៈរបស់សម្មាវាចា , **ការតាំងឡើង** ជាលក្ខណៈរបស់សម្មាកម្មន្តៈ , **សេចក្តីបរិសុទ្ធិ** ជាលក្ខណៈរបស់សម្មាអាជីវៈ , **ការផ្គងទុក** ជាលក្ខណៈរបស់សម្មាវាយាមៈ , **ការចូលទៅតាំងទុក** ជាលក្ខណៈរបស់សម្មាសតិ , **ការមិនរាយមាយ** ជាលក្ខណៈរបស់សម្មាសមាធិ ។

**ការមិនដឹង** ជាលក្ខណៈរបស់អវិជ្ជា , **ការគិត** ( ចេតនា ) ជាលក្ខណៈរបស់សង្ខារ , **ការដឹងច្បាស់** ជាលក្ខណៈរបស់វិញ្ញាណ , **ការបង្អោនទៅ** ជាលក្ខណៈរបស់នាម , **ការបែកធ្លាយទៅ** ជាលក្ខណៈរបស់រូប , **ការជាប់តគ្នា** ជាលក្ខណៈនៃសឡាយតនៈ , **ការពាល់ត្រូវ** ជាលក្ខណៈនៃផស្សៈ , **ការសោយអារម្មណ៍** ជាលក្ខណៈរបស់វេទនា , **ហេតុ** ជាលក្ខណៈនៃតណ្ហា , **ការប្រកាន់មាំ** ជាលក្ខណៈនៃឧបាទាន , **ការប្រមូល** ( អាយូហនៈ ) ជាលក្ខណៈនៃភព , **ការកើត** ជាលក្ខណៈនៃជាតិ , **ការទ្រុឌទ្រោម** ជាលក្ខណៈនៃជរា , **ចុតិ** ការឃ្លាតទៅ ជាលក្ខណៈនៃ

សេចក្តីស្លាប់ ។

**ភាពជារបស់សូន្យ** ជាលក្ខណៈនៃធាតុ , ការជាប់តគ្នា ជាលក្ខណៈនៃអាយតនៈ , **ការចូលទៅតាំងទុក** ជាលក្ខណៈនៃសតិប្បដ្ឋាន , **ការផ្តើមឡើង** (ការសេចក្តីព្យាយាម) ជាលក្ខណៈនៃសម្មប្បធាន , **ការសម្រេច** ជាលក្ខណៈនៃឥទ្ធិបាទ , **ភាពជាធំ** ជាលក្ខណៈនៃឥន្ទ្រិយ៍, **ភាពមិនញាប់ញ័រ** ជាលក្ខណៈនៃពលៈ , **ការនាំចេញ** ជាលក្ខណៈនៃពោជ្ឈង្គៈ , **ហេតុ** ជាលក្ខណៈនៃមគ្គ ។

**សេចក្តីពិត** ជាលក្ខណៈនៃសច្ចៈ , **ភាពមិនរាយមាយ** ជាលក្ខណៈនៃសមថៈ , **ការពិចារណាឃើញតាម** ជាលក្ខណៈនៃវិបស្សនា , **ឯករស** ( ធម្មរសដ៏វិសេស ) ជាលក្ខណៈនៃសមថៈនិងវិបស្សនា , **សភាពមិនប្រែប្រួល** ជាលក្ខណៈនៃធម៌ជាគូគ្នា ។

**សំវរ** ជាលក្ខណៈនៃសីលវិសុទ្ធិ ។

**ការមិនរាយមាយ** ជាលក្ខណៈនៃចិត្តវិសុទ្ធិ ។

**ការឃើញ** ជាលក្ខណៈនៃទិដ្ឋិវិសុទ្ធិ ។

**ការកាត់ផ្តាច់** ជាលក្ខណៈនៃញាណក្នុងការអស់ទៅ ។

**សេចក្តីស្ងប់** ជាលក្ខណៈនៃញាណក្នុងការអស់ទៅ ។



**មូល** ជាលក្ខណៈនៃឆន្ទៈ , **សមុដ្ឋាន** ជាលក្ខណៈនៃមនសិកា , **សមោធាន** ជាលក្ខណៈនៃផស្សៈ , **សមោសរណ** ជាលក្ខណៈនៃវេទនា , **បមុខ** ជាលក្ខណៈនៃសមាធិ , **អាធិបតេយ្យ** ជាលក្ខណៈនៃសតិ , **តទុត្តរិ** ( សេចក្តីដឹងដ៏ក្រៃលែង ) ជាលក្ខណៈនៃបញ្ញា , **សារ** ជាលក្ខណៈនៃវិមុត្តិ , **បរិយោសាន** ជាលក្ខណៈនៃនិព្វានដែលញុំាងចុះកាន់អមតៈ , នេះគឺសេចក្តីពិត ព្រះនាមថា **តថាគតោ** ព្រោះត្រាស់ដឹងលក្ខណៈដែលពិតនោះផងញាណគតិ គឺ សម្រេច សម្រេចដល់ដោយមិនខុស , ត្រាស់ដឹងលក្ខណៈដែលពិត ដោយប្រការដូច្នេះ ។ ទើបទ្រង់ព្រះនាមថា **តថាគត** ។

ព្រះនាមថា **តថាគតោ** ព្រោះត្រាស់ដឹងធម៌ដែលពិត តាមសេចក្តីពិតនោះ យ៉ាងណា ? **អរិយសច្ច ៤** ឈ្មោះថា ធម៌ដែលពិត ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

> ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ យ៉ាង
> ទាំងនេះជាធម៌ពិតប្រាកដ មិនជាយ៉ាងដទៃ ។
> អរិយសច្ច ៤ ដូចម្តេច ? ម្នាលភិក្ខុទាំងឡាយ

អរិយសច្ចថា នេះទុក្ខ នេះហេតុឲ្យកើតទុក្ខ នេះទីរំលត់ទុក្ខ នេះផ្លូវឲ្យដល់ទីរំលត់ទុក្ខ ជារបស់ពិតប្រាកដមិនជាយ៉ាងដទៃ ដូច្នេះ គប្បីធ្វើឲ្យពិស្តារ ។

ម្យ៉ាងវិញទៀត ព្រោះព្រះមានព្រះភាគត្រាស់ដឹង អរិយ-សច្ចទាំងនោះ បណ្ឌិតទើបថ្វាយព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងវត្ថុពិត ។ **គត** ក្នុងទីនេះមានន័យថា ត្រាស់ដឹង ។

ម្យ៉ាងវិញទៀត សេចក្ដីពិតប្រាកដមិនជាយ៉ាងដទៃ មានការចង្អុលបង្ហាញដល់សេចក្ដីពិតថា ជាតិ ជាបច្ច័យដល់ជរា និងមរណៈ ។លៗ មានការចង្អុលបង្ហាញដល់សេចក្ដីពិតថា អវិជ្ជា ជាបច្ច័យនៃសង្ខារ ។លៗ

សេចក្ដីពិតមិនជាយ៉ាងដទៃរបស់អវិជ្ជា អត្ថថាជាបច្ច័យនៃសង្ខារ ។លៗ សេចក្ដីពិតមិនជា យ៉ាងដទៃរបស់ជាតិ ជរាមរណ ។ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ដឹងធម៌ទាំងពួងនោះ ព្រោះដូច្នោះ ទើបទ្រង់ព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងនូវសេចក្ដីពិត ។

ព្រះនាមថា **តថាគត** ព្រោះទ្រង់ឃើញសេចក្ដីពិតនោះ



ដូចម្ដេច ? ប្រការដែលព្រះមានព្រះភាគ ទ្រង់ឃើញរូបារម្មណ៍ដែលមកកាន់គន្លងចក្ខុ ក្នុងចក្ខុទ្វាររបស់សត្វទាំងឡាយ រកប្រមាណមិនបាន ក្នុងលោកធាតុដែលរកប្រមាណមិនបាន ក្នុងលោកព្រមទាំងទេវលោក ។លៗ ប្រព្រឹត្តទៅជាមួយនឹងទេវតា និងមនុស្សមានហើយ ដោយប្រការទាំងពួង ។ ម្យ៉ាងវិញទៀត រូបារម្មណ៍នោះ ព្រះមានព្រះភាគទ្រង់ដឹង ទ្រង់ឃើញ ទ្រង់ចែកទុកដោយន័យ ៥២ , ដោយវារៈ ១៣ , ដោយឈ្មោះច្រើនយ៉ាង ដោយន័យមានជាអាទិ៍ថា រូបដែលហៅថា រូបាយតនៈ ដូចម្ដេច ? រូបណាមានពន្លឺ អាស្រ័យមហាភូតរូប ៤ ប្រព្រឹត្តទៅជាមួយនឹងការឃើញបាន និងមានការប៉ះខ្ទប់បាន មានពណ៌ខៀវ ( ម៉ែច ) ពណ៌លឿងជាដើម ជាសេចក្ដីពិត មិនប្រែទៅជាសភាពដទៃ ។

ក្នុងសំឡេងជាដើម ដែលមកកាន់គន្លងក្នុងសោតទ្វារ ជាដើម ក៏មានន័យនេះ ។ សូម្បីព្រះមានព្រះភាគក៏ត្រាស់ទុកថា ៖

ម្នាលភិក្ខុទាំងឡាយ រូបារម្មណ៍ដែលឃើញ
ដោយចក្ខុ សទ្ទារម្មណ៍ដែលឮ ដោយត្រចៀក
គន្ធារម្មណ៍ រសារម្មណ៍ និងផោដ្ឋព្វារម្មណ៍ដែល

ដឹងបានដោយទ្វារនោះ ៗ ធម្មារម្មណ៍ដែលដឹង
ច្បាស់ដោយចិត្តរបស់លោក ព្រមទាំងទេវលោក
មារលោក ព្រហ្មលោករបស់ពពួកសត្វ ព្រមទាំង
សមណព្រាហ្មណ៍ ទេវតា និងមនុស្ស តថាគត
បានត្រាស់ដឹងហើយ តថាគតស្វែងរកហើយ
ពិចារណាហើយដោយចិត្ត តថាគត រមែងដឹង
រូបារម្មណ៍ ដែលឃើញបានដោយចក្ខុជាដើមនោះ
ត្រាស់ដឹងហើយដោយបញ្ញាដ៏ក្រៃលែង តថា-
គតត្រាស់ដឹងរូបារម្មណ៍ជាដើមនោះ ដ៏ជាក់
ច្បាស់ រូបារម្មណ៍ជាដើមនោះ មិនប្រាកដ
ក្នុងតថាគត ។

ព្រះនាមថា **តថាគត** ព្រោះទ្រង់ឃើញតាមសេចក្ដីពិត ដោយប្រការដូច្នេះ ។ គប្បីជ្រាបការផ្ដើមបទថា **តថាគតោ** ចុះក្នុងអត្ថថា ឃើញតាមសេចក្ដីពិតនោះ ។

ព្រះនាមថា **តថាគតោ** ព្រោះទ្រង់ត្រាស់តែសេចក្ដីពិតយ៉ាងណា ? ប្រការដែលព្រះដ៏មានព្រះភាគ ប្រថាប់គង់នៅលើ



អបរាជិតបល្ល័ង្កក្រោមពោធិមណ្ឌល ក្នុងវេលាកណ្ដាលយប់ ទ្រង់បានញាំញីមារទាំង ៤ ហើយត្រាស់ដឹងព្រះសម្មាសម្ពោធិញ្ញាណដ៏កំពូល , និងប្រការដែលព្រះមានព្រះភាគស្ដេចបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងចន្លោះដើមសាលៈទាំងគូ ក្នុងវេលាអារុណរះឡើង , និងប្រការដែលព្រះមានព្រះភាគត្រាស់សុត: គេយ្យ: ។ល។ វេទល្ល:ក្នុងបឋមពោធិកាលខ្លះ ក្នុងមជ្ឈិមពោធិ-កាលខ្លះ ក្នុងបច្ឆិមពោធិកាលខ្លះ ក្នុងវេលាប្រមាណ ៤៥ ឆ្នាំក្នុងរវាងនេះ , ទាំងអស់នោះ ទាំងដោយអត្ថ ទាំងដោយព្យញ្ជន: មិនមានទោស មិនគប្បីតិះដៀល មិនខ្វះចន្លោះ បរិបូរណ៍ដោយអាការទាំងពួង កម្ចាត់បង់សេចក្ដីស្រវឹង រាគ: ទោស: មោហ: , មិនមានការខុសក្លាត់ សូម្បីត្រឹមតែប៉ុនចុងរោមសត្វ ក្នុងពាក្យទូន្មានទាំងនោះ , ទាំងអស់នោះជាសេក្ដីពិត ដូចការប្រថាប់ត្រាដោយត្រាតែមួយ , ដូចវាល់របស់ដោយមាត្រដ្ឋានតែមួយ និងដូចថ្លឹងវត្ថុ ដោយជញ្ជីងតែមួយ ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

ម្នាលចុន្ទ: ប្រការដែលតថាគតត្រាស់ដឹង

សម្មាសម្ពោធិញ្ញាណដ៏កំពូល ក្នុងវេលាជិតភ្លឺ , និងប្រការដែលតថាគតបរិនិព្វានដោយអនុបាទិសេសនិព្វាន ក្នុងវេលាជិតភ្លឺ , ប្រការដែលតថាគតចង្អុលបង្ហាញសម្ដែង ក្នុងរវាងនេះ ទាំងអស់នោះ ជាសេចក្ដីពិតតែម្យ៉ាង , មិនជាយ៉ាងដទៃ ព្រោះដូច្នោះ បណ្ឌិតទើបថ្វាយព្រះនាមថា **តថាគត** [1] ។

**គត** ស័ព្ទ ក្នុងទីនេះមានអត្ថថា ពាក្យនិយាយព្រះនាមថា **តថាគត** ព្រោះត្រាស់ដឹងយ៉ាងនោះ ដោយប្រការដូច្នេះ ។

ម្យ៉ាងវិញទៀត ពាក្យនិយាយ ឈ្មោះថា **អាគទ** អធិប្បាយថា ការពោល , ពាក្យពោលរបស់ព្រះតថាគត ជាសេចក្ដីពិតមិនប្រែប្រួល ព្រោះផ្លាស់ **ទ** ជា **ត** ទើបជា **តថាគតោ** ដូច្នោះ គប្បីជ្រាបបទសម្រេចដោយអត្ថនេះ ដោយប្រការដូច្នេះ ។

ប្រការដូច្នេះ ។

---

**១** ទីឃនិកាយ បាដិកវគ្គ ។



ព្រះនាមថា **តថាគតោ** ព្រោះធ្វើដូចយ៉ាងនោះ តើដូចម្ដេច ? ពិតណាស់ កាយរបស់ព្រះមានព្រះភាគ រមែងព្រមតាមវាចា , វាចារមែងព្រមតាមកាយ , ព្រោះដូច្នោះទើបមានសេចក្ដីថា និយាយយ៉ាងណា ធ្វើយ៉ាងនោះ , និងធ្វើយ៉ាងណា និយាយយ៉ាងនោះ ។ អធិប្បាយថា វាចារបស់ព្រះមានព្រះភាគនោះ គឺយ៉ាងនោះ យ៉ាងណា , សូម្បីកាយក៏ប្រព្រឹត្តទៅដូច្នោះ ។ ម្យ៉ាងទៀត ព្រះនាមថា **តថាគតោ** ទៅយ៉ាងនោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ៖

ម្នាលភិក្ខុទាំងឡាយ តថាគតនិយាយយ៉ាងណា ធ្វើយ៉ាងនោះ , ធ្វើយ៉ាងណានិយាយយ៉ាងនោះ ។ ដោយហេតុដែលតថាគតនិយាយយ៉ាងណាធ្វើយ៉ាងនោះ , ធ្វើយ៉ាងណា និយាយយ៉ាងនោះ បណ្ឌិតទើបថ្វាយព្រះនាមថា **តថាគត** ។

ព្រះនាមថា **តថាគត** ព្រោះធ្វើយ៉ាងនោះ ដោយប្រការដូច្នេះ ។

ព្រះនាមថា **តថាគតោ** ដោយអត្ថថា គ្របសង្កត់នោះយ៉ាង

ណា ? ព្រះតថាគតទ្រង់ធ្វើទីបំផុត ខាងលើដល់ភវគ្គព្រហ្ម ខាងក្រោមដល់អវេចី ហើយទ្រង់គ្របសង្កត់សព្វសត្វក្នុងលោកធាតុដែលប្រមាណមិនបាន ក្នុងខាងទទឹង ដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ ។ ព្រះតថាគតនោះ មិនមានការថ្លឹង ឬការប៉ាន់ស្មាន , តថាគតមិនមានអ្នកប្រៀប មិនមានគួរផ្ទឹមបាន ទ្រង់ជាអគ្គបុគ្គល ជារាជាក្រៃលែងជាងរាជា ជាទេវតាក្រៃលែងជាងទេវតា ជាសក្កៈក្រៃលែងជាងសក្កៈ ជាព្រហ្មក្រៃលែងជាងព្រហ្ម ។ ដោយហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា ៖

> ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកធំក្រៃលែង ។ល។
> អ្នកគ្របសង្កត់ ជាអ្នកឃើញយ៉ាងច្បាស់ ជាអ្នកញុំាង
> សត្វឲ្យនៅក្នុងអំណាច ព្រោះដូច្នោះ បណ្ឌិតទើបថ្វាយ
> ព្រះនាមថា **តថាគត** ។

ក្នុងបទនោះ គប្បីជ្រាបបទដែលសម្រេចដូចតទៅនេះ , ព្រះតថាគត ព្រះនាមថា **អគទោ** គឺ ដូចជាគ្រូពេទ្យដ៏វិសេស ។ ក្នុងបាលីថា ទុំះជានរណា ? មានសភាពល្អស្អាតដោយទេសនា



និងជាអ្នកដែលសម្រេចហើយដោយបុណ្យ ។ ដោយហេតុនោះ ព្រះតថាគត ទើបមានអានុភាពច្រើន រមែងគ្របសង្កត់លទ្ធិរបស់អ្នកដទៃទាំងអស់ និងលោក ព្រមទាំងទេវលោក ដូចគ្រូចាប់ពស់ រមែងបង្ក្រាបពស់បាន ដោយថ្នាំវិសេសដូច្នោះ ។ ដោយហេតុនេះ ព្រះតថាគត ជា **អគទោ** និងសម្រេចដោយបុណ្យ ជាការពិត មិនប្រែប្រួលក្នុងការគ្របសង្កត់លោកទាំងពួង ព្រោះដូច្នោះ គប្បីជ្រាបថា ព្រះនាមថា **តថាគតោ** ព្រោះផ្លាស់ **ទ** ជា **ត** , ព្រះនាមថា **តថាគត** ដោយអត្ថថា គ្របសង្កត់ ដោយប្រការដូច្នេះ ។

ម្យ៉ាងវិញទៀត ព្រះនាមថា **តថាគត** ព្រោះអត្ថថា ស្តេចយាងទៅហើយដោយសេចក្តីពិតខ្លះ ។ ព្រះនាមថា **តថាគត** ព្រោះអត្ថថា ស្តេចយាងទៅកាន់សេចក្តីពិតខ្លះ ។ បទថា **គតោ** មានសេចក្តីថា ឈានចុះហើយ កន្លងទៅហើយ សម្រេចហើយ ស្តេចយាងទៅហើយ ។

ក្នុងបទទាំងឡាយនោះ ព្រះតថាគត ព្រះនាមថា **តថាគតោ** ព្រោះអត្ថថា ឈានចុះកាន់លោកទាំងអស់ដោយសេចក្តីពិត គឺ

តីរណបរិញ្ញា , ព្រះនាមថា **តថាគតោ** ព្រោះអត្ថថា កន្លងទៅហើយនូវហេតុឲ្យកើតលោក ដោយសេចក្តីពិត គឺ បហានបរិញ្ញា , ព្រះនាមថា **តថាគតោ** ព្រោះអត្ថថា បានជាក់ច្បាស់នូវការរំលត់លោកដោយសេចក្តីពិត គឺ សច្ឆិកិរិយា , ព្រះនាមថា **តថាគតោ** ព្រោះអត្ថថា ស្តេចយាងទៅហើយកាន់សេចក្តីពិត គឺ លោក-និរោធគាមិនីបដិបទា បដិបទាដែលឲ្យដល់ការរំលត់លោក ។

ដោយហេតុនោះ ពាក្យណាដែលព្រះមានព្រះភាគ ត្រាស់ហើយថា ៖

> ម្នាលភិក្ខុទាំងឡាយ លោកដែលតថាគត
> ត្រាស់ដឹងហើយ , តថាគតប្រាសចាកលោក
> ហើយ , ហេតុឲ្យកើតលោក តថាគតត្រាស់
> ដឹងហើយ តថាគតបានលះបង់ហេតុឲ្យកើត
> លោកហើយ , ការរំលត់លោក តថាគតបាន
> ត្រាស់ដឹងហើយ , តថាគតធ្វើឲ្យជាក់ច្បាស់
> នូវការរំលត់លោកហើយ , បដិបទាធ្វើឲ្យ
> ដល់ការរំលត់លោក តថាគតបានត្រាស់ដឹង



> ហើយ , តថាគតធ្វើឲ្យកើតបដិបទាដែលធ្វើ
> ឲ្យដល់ការរំលត់លោកហើយ ។
> ម្នាលភិក្ខុទាំងឡាយ រូបដែលឃើញដោយ
> ចក្ខុ ។ល។ ធម៌ដែលដឹងដោយចិត្ត របស់លោក
> ព្រមទាំងទេវលោកទាំងអស់នោះ តថាគតត្រាស់
> ដឹងហើយ , ព្រោះដូច្នោះ បណ្ឌិតទើបថ្វាយ
> ព្រះនាមថា **តថាគត** ។

គប្បីជ្រាបសេចក្តីរបស់ពាក្យនោះ សូម្បីយ៉ាងនេះ ។

មួយ៉ាងវិញទៀត បទនេះក៏មានត្រឹមតែមុខ ក្នុងការសំដែងភាពជា **តថាគត** របស់ព្រះតថាគតនោះឯង ។ ព្រះតថាគតប៉ុណ្ណោះ គប្បីពណ៌នាភាពជា **តថាគត** របស់ព្រះតថាគតបានដោយអាការទាំងពួង ។ ក៏ព្រោះព្រះពុទ្ធជាម្ចាស់ទាំងពួង ជាអ្នកសមគួរ សូម្បីដោយគុណរបស់ព្រះតថាគត , ដូច្នោះ ព្រះសារី-បុត្រ ទើបពោលថា **តថាគតានំ** ដោយអំណាចនៃព្រះពុទ្ធជាម្ចាស់ទាំងអស់ ។

បទថា **អរហន្តានំ** សេចក្តីថា ព្រះតថាគត ជាព្រះអរហន្ត

ព្រោះទ្រង់ឆ្ងាយចាកកិលេសទាំងឡាយ , ព្រោះកម្ចាត់សឹកសត្រូវនិងកាច់បំបាក់នូវកាំនៃចក្រទាំងឡាយ , ព្រោះជាអ្នកគួរដល់នូវបច្ច័យជាដើម , ព្រោះមិនមានការធ្វើបាបក្នុងទីកំបាំង ។

ពិតណាស់ ព្រះតថាគតនោះ ជាអ្នកឆ្ងាយ គឺ តាំងនៅឆ្ងាយសែនឆ្ងាយអំពីកិលេសទាំងពួង ព្រះនាមថា **អរហំ** ព្រោះទ្រង់លះបង់កិលេស ព្រមទាំងវាសនាដោយមគ្គ បណ្ឌិតពោលពាក្យថា **អរហំ** ទុក ៥ ន័យ , ន័យទី ១ ថា ៖

**សោ តតោ អារកា នាម យស្ស យេនាសមង្គិតា**
**អសមង្គី ច ទោសេហិ នាថោ តេនារហំ មតោ**

ព្រះតថាគត ទ្រង់ជានាថៈ មិនត្រូវកិលេសរួបរឹត និងមិនប្រកបដោយទោស គឺ វាសនាទាំងឡាយ ឈ្មោះថា ទ្រង់ឆ្ងាយចាកកិលេស និងទោសទាំងនោះ ព្រោះហេតុនោះបណ្ឌិតទើបពោលថា **អរហំ** ជាព្រះអរហន្ត ។

ម្យ៉ាងវិញទៀត ព្រះតថាគតជាម្ចាស់ ទ្រង់កម្ចាត់សឹកសត្រូវ គឺ កិលេសទាំងនោះដោយមគ្គ ព្រោះហេតុនោះ បណ្ឌិតទើបថ្វាយព្រះនាមថា **អរហំ** ព្រោះទ្រង់កម្ចាត់សឹកសត្រូវ គឺ កិលេស



ទាំងឡាយ ។

**យស្មា រាគាទិសង្ខាតា សព្វេបិ អរយោ ហតា**
**បញ្ញាសត្ថេន នាថេន តស្មាបិ អរហំ មតោ ។**

ព្រះនាម **នាថៈ** ទ្រង់កម្ចាត់សឹកសត្រូវ គឺ កិលេស មានរាគៈជាដើម សូម្បីទាំងអស់ ដោយសស្ត្រា គឺ បញ្ញា ព្រោះដូច្នោះបណ្ឌិតទើបជ្រាបថា **អរហំ** ជាព្រះអរហន្ត ។

ម្យ៉ាងវិញទៀត សង្សារចក្រ កង់ គឺ សង្សារ មានដុំសម្រេចដោយអវិជ្ជា និងភវតណ្ហា មានគ្រឿងតាក់តែង គឺ បុណ្យជាដើម មានខ្នងកង់ គឺ ជរា និងមរណៈ សឹកភ្ជាប់កង់នោះដោយភ្ងៅ គឺ ហេតុកើតអាសវៈ ប្រកបជាមួយនឹងរថ គឺ ភព ៣ ប្រព្រឹត្តទៅដោយកាល ដែលកំណត់អំពីខាងដើមមិនបាន , ព្រះតថាគតប្រតិស្ឋានលើផែនដី គឺ សីល ដោយព្រះបាទ គឺ វីរិយៈ ត្រង់ពោធិមណ្ឌល ទ្រង់ចាប់កាន់កាំបិត គឺ បញ្ញា ធ្វើកម្មឲ្យអស់ទៅដោយព្រះហត្ថ គឺ សទ្ធា ហើយទ្រង់កម្ចាត់គ្រប់ផ្នែករបស់កង់ទាំងអស់នៃសង្សារចក្រនោះ ព្រោះហេតុនោះ ទើបទ្រង់ព្រះនាមថា **អរហំ** ជាព្រះអរហន្ត ព្រោះកម្ចាត់កង់ទាំងឡាយ នេះជា

ន័យទី ២ ។ បណ្ឌិតពោលន័យទី ៣ ថា៖

**អរា សង្សារចក្កស្ស ហតា ញាណាសិនា យតោ**
**លោកនាថេន តេនេស អរហន្តិ បវុច្ចតិ ។**

ព្រោះព្រះលោកនាថ ទ្រង់កម្ចាត់នូវកង់នៃសង្សារចក្រ ដោយកាំបិត គឺ បញ្ញា , ព្រោះហេតុនោះ ព្រះលោកនាថនោះ បណ្ឌិតទើបថ្វាយព្រះនាមថា **អរហំ** ជាព្រះអរហន្ត ។

ម្យ៉ាងវិញទៀត ព្រះតថាគត ព្រោះព្រះអង្គជាស្រែបុណ្យដ៏ប្រសើរ ទើបគួរទទួលបច្ច័យ មានចីវរជាដើម និងការបូជាដ៏ពិសេស ។ ក៏ដោយហេតុនោះឯង កាលបើព្រះតថាគតឧប្បត្តិហើយ ទេវតា និងមនុស្សដែលមានសក្តិធំពួកណាមួយ នឹងមិនធ្វើការបូជាក្នុងទីដទៃឡើយ ។

ជាការពិតណាស់ សហម្បតីព្រហ្ម រមែងបូជាព្រះតថាគត ដោយ ( កួង ) កម្រងកែវប្រមាណប៉ុនភ្នំសិនេរុ , ទេវតាពួកដទៃ និងមនុស្សទាំងឡាយ មានព្រះបាទពិម្ពិសារ និងព្រះបាទកោសល ជាដើម រមែងបូជាតាមកម្លាំង ។

ម្យ៉ាងវិញទៀត ព្រះបាទអសោកមហារាជលះបង់រាជទ្រព្យ



៩៦ កោដិ ឧទ្ទិសចំពោះព្រះមានព្រះភាគ សូម្បីស្តេចបរិនិព្វានហើយ នឹងបានសាងវិហារ ៨៤.០០០ ខ្នង ទុកក្នុងជម្ពូទ្វីបទាំងអស់ , នឹងចាំបាច់ពោលថ្វីដល់ការបូជាវិសេសយ៉ាងដទៃ ព្រោះហេតុនោះ ព្រះតថាគត ទើបទ្រង់ព្រះនាមថា **អរហំ** ជាព្រះអរហន្ត ព្រោះសមគួរដល់បច្ច័យជាដើម ។ បណ្ឌិតពោលន័យទី ៤ ថា ៖

**បូជាវិសេសំ សហ បច្ចយេហិ**
**យស្មា អយំ អរហតិ លោកនាថោ ,**
**អត្ថានុរូបំ អរហន្តិ លោកេ**
**តស្មា ជិនោ អរហតិ នាមមេតំ ។**

ព្រះលោកនាថនេះ សមគួរទទួលការបូជាដ៏វិសេស ព្រមដោយបច្ច័យទាំងឡាយ , ដូច្នោះ ព្រះជិនៈទើបសមគួរទទួលព្រះនាមថា **អរហំ** ជាព្រះអរហន្តដ៏សមគួរដល់អត្ថៈ ។

ព្រះតថាគតនោះ មិនថាក្នុងកាលណា ៗ ទ្រង់មិនធ្វើទំនៀមដូចបុគ្គលពាលទាំងឡាយពួកណាមួយ ដែលសំគាល់ថាជាបណ្ឌិត ធ្វើបាបក្នុងទីស្ងាត់ ដោយគិតថា មិនបានទទួលការសរសើរ ព្រោះហេតុនោះ ព្រះតថាគត ទើបជាព្រះអរហន្ត ព្រោះ

មិនមានការលេបធ្វើបាបក្នុងទីកំបាំង ។ បណ្ឌិតពោលន័យទី ៥ ថា ៖

**យស្មា នត្ថិ រហោ នាមបាបកម្មេសុ តាទិនោ**

**រហាភាវេន តេនេស អរហំ ឥតិ វិស្សុតោ ។**

ដែលឈ្មោះថា ការលេបធ្វើបាបកម្មក្នុងទីកំបាំង មិនមានដល់ព្រះតថាគតយ៉ាងពិតប្រាកដ ព្រោះហេតុនោះ ព្រះតថាគតនោះ ទើបប្រាកដព្រះនាមថា **អរហំ** ជាព្រះអរហន្ត ព្រោះមិនមានការលេបធ្វើបាបក្នុងទីកំបាំង ។

លោកពោលសរុបសេចក្តីទាំងអស់ទុកយ៉ាងនេះថា ៖

**អារកត្តា ហតត្តា ច កិលេសារីន សោ មុនិ**

**ហតសំសារចក្ការោ បច្ចយាទីន ចារហោ**

**ន រហោ ករោតិ បាបានិ អរហំ តេន វុច្ចតិ ។**

ព្រះមុនីនោះ ព្រោះទ្រង់ជាអ្នកឆ្ងាយចាកកិលេស ១ , ព្រោះទ្រង់កម្ចាត់សឹកសត្រូវ គឺ កិលេស ១ , ព្រោះកាច់បំបាក់កង់ គឺ សង្សារចក្រ ១ , ទ្រង់សមគួរដល់បច្ច័យជាដើម ១ , ព្រោះទ្រង់មិនធ្វើបាបក្នុងទីកំបាំង ១ ព្រោះហេតុនោះ បណ្ឌិតទើបថ្វាយព្រះនាមថា **អរហំ** ព្រះអរហន្ត ។



ក៏ព្រោះព្រះពុទ្ធជាម្ចាស់ទាំងពួងជាអ្នកសមគួរ សូម្បីដោយគុណរបស់ព្រះអរហន្ត ដូច្នោះព្រះសារីបុត្តទើបពោលថា **អរហ-ន្តានំ** ដោយអំណាចនៃព្រះពុទ្ធជាម្ចាស់ទាំងពួង ។

បទថា **សម្មាសម្ពុទ្ធានំ** សេចក្តីថា ឈ្មោះថា **សម្មាសម្ពុ-ទ្ធា** ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ ដោយព្រះអង្គឯង ។ ជាការពិតណាស់ ព្រះសម្មាសម្ពុទ្ធជាម្ចាស់ត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ ដោយព្រះអង្គឯង គឺ ដែលទ្រង់ព្រះនាមថា **ពុទ្ធ** ព្រោះទ្រង់ត្រាស់ដឹងធម៌ដែលគួរត្រាស់ដឹង , ព្រោះទ្រង់កំណត់ដឹងធម៌ ដែលគួរកំណត់ដឹង , ព្រោះទ្រង់លះបង់ធម៌ ដែលគួរលះបង់ , ព្រោះទ្រង់ធ្វើឲ្យជាក់ច្បាស់នូវធម៌ ដែលគួរធ្វើឲ្យជាក់-ច្បាស់ , ព្រោះចម្រើនធម៌ ដែលគួរចម្រើន ។ ដូចព្រះមានព្រះភាគត្រាស់ទុកថា ៖

**អភិញ្ញេយ្យំ អភិញ្ញាតំ ភាវេតព្វញ្ច ភាវិតំ**

**បហាតព្វំ បហីនំ មេ តស្មា ពុទ្ធោស្មិ ព្រាហ្មណ ។**

ម្នាលព្រាហ្មណ៍ វត្ថុដែលគួរដឹង តថាគតបានដឹងហើយ វត្ថុដែលគួរចម្រើន តថាគតបានចម្រើនហើយ និងវត្ថុដែលគួរលះបង់

តថាគតបានលះបង់ហើយ , ព្រោះដូច្នោះ តថាគតទើបជា **ពុទ្ធ** ។

ម្យ៉ាងវិញទៀត គប្បីជ្រាបថា ព្រះសម្មាសម្ពុទ្ធត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង សូម្បីដោយការលើកបទមួយ ៗ ឡើងយ៉ាងនេះថា ចក្ខុ ជាទុក្ខសច្ច , បុរិមតណ្ហាដែលធ្វើចក្ខុនោះឲ្យកើតឡើងជាហេតុ ជាសមុទយសច្ច , សភាពដែលទុក្ខសច្ចៈ និងសមុទយសច្ចៈ ទាំង ២ ប្រព្រឹត្តទៅមិនបាន ជានិរោធសច្ច , បដិបទាដែលដឹងទូទៅដល់ការរលត់ ជាមគ្គសច្ច , ក្នុងសោតៈ ឃានៈ ជិវ្ហា និងកាយ ក៏មានន័យនេះ ។

ដោយន័យនេះឯង គប្បីប្រកបអាយតនៈ ៦ មានរូប ជាដើម , កងវិញ្ញាណ ៦ មានចក្ខុវិញ្ញាណជាដើម , ផស្សៈ ៦ មានចក្ខុសម្ផស្សជាដើម , វេទនា ៦ មានចក្ខុសម្ផស្សជាវេទនាជាដើម , សញ្ញា ៦ មានរូបសញ្ញាជាដើម , ចេតនា ៦ មានរូបសញ្ចេតនាជាដើម , កងតណ្ហា ៦ មានរូបតណ្ហាជាដើម , វិតក្កៈ ៦ មានរូបវិតក្កៈជាដើម , វិចារៈ ៦ មានរូបវិចារៈជាដើម , ខន្ធ ៥ មានរូបក្ខន្ធជាដើម , កសិណ ១០ , អនុស្សតិ ១០ , សញ្ញា ១០ , ដោយអំណាចឧទ្ធុមាតកសញ្ញា ការសំគាល់



សាកសពដែលហើមប៉ោងជាដើម , ឈាន ៤ មានបឋមជ្ឈានជាដើម , អប្បមញ្ញា ៤ មានមេត្តាភាវនាជាដើម , អរូបសមាបត្តិ ៤ , និងអង្គបដិច្ចសមុប្បាទ មានជរាមរណៈជាដើម ដោយបដិលោម , មានអវិជ្ជាជាដើម ដោយអនុលោមចូលជាមួយផង ។

គប្បីជ្រាបការប្រកបបទមួយ ៗ ដូចតទៅនេះ ព្រះសម្មាសម្ពុទ្ធត្រាស់ដឹង ត្រាស់ដឹងដ៏ក្រៃលែង ចាក់ធ្លុះធម៌ទាំងពួងដោយប្រពៃដោយព្រះអង្គឯង ដោយការលើកបទមួយ ៗ ឡើងយ៉ាងនេះថា ជរាមរណៈ ជាទុក្ខសច្ច , ជាតិ ជាសមុទយសច្ច , ការចេញចាកទាំងពីរយ៉ាងនោះ ជានិរោធសច្ច , បដិបទាដែលដឹងទូទៅដល់ការរំលត់ ជាមគ្គសច្ច ។

នៅមានវត្ថុដែលគួរណែនាំម្យ៉ាងទៀត , ព្រះសម្មាសម្ពុទ្ធជាម្ចាស់ព្រះនាមថា **សម្មាសម្ពុទ្ធោ** ព្រោះត្រាស់ដឹងវត្ថុទាំងពួងដោយប្រពៃ ដោយព្រះអង្គឯងដោយ **វិមោក្ខន្តិកញ្ញាណ** ញាណដែលជាទីបំផុតនៃការរួចផុត , **វិភាគញ្ញាណ** របស់ព្រះសម្មាសម្ពុទ្ធនោះ នឹងមានច្បាស់នៅខាងមុខ ។ ក៏ព្រោះព្រះពុទ្ធជាម្ចាស់ទាំងពួងសមគួរ សូម្បីដោយគុណរបស់ព្រះសម្មាសម្ពុទ្ធ ដូច្នោះ

ព្រះសារីបុត្រទើបពោលថា **សម្មាសម្ពុទ្ធានំ** ដោយអំណាចនៃព្រះពុទ្ធជាម្ចាស់ទាំងឡាយ ។

ឥឡូវនេះ ដើម្បីលើកឡើងសម្តែងសីលមួយ ៗ ចែកចេញជា ៥ ចំណែក ក្នុងសីល ២ ពួក គឺ បរិយន្តប្បារិសុទ្ធសីល សីលបរិសុទ្ធិមានទីបំផុត ១ , អបរិយន្តប្បារិសុទ្ធិសីល សីលបរិសុទ្ធមិនមានទីបំផុត ១ ព្រះសារីបុត្រទើបពោល បទមានជាអាទិ៍ថា **អត្ថិ សីលំ បរិយន្តំ , អត្ថិ សីលំ អបរិយន្តំ** សីលមានទីបំផុតក៏មាន , សីលមិនមានទីបំផុតក៏មាន ។ ក៏ក្នុងសីល ២ យ៉ាងនោះ មិនមានសេចក្តីផ្សេងគ្នា សូម្បីក្នុងក្នុងសីល ៣ យ៉ាង ។

ក្នុងបទទាំងនោះ បទថា **លាភបរិយន្តំ** ទីបំផុតព្រោះលាភ គឺ ឈ្មោះថា **លាភបរិយន្តំ** សីលមានទីបំផុត គឺ ដាច់ព្រោះលាភ ។ សូម្បីបទដ៏សេសក៏យ៉ាងនេះ ។

ក្នុងបទថា **យសោ** នេះ បានដល់ បរិវារ ។ បទថា **ឥធ** គឺ ក្នុងលោកនេះ ។ បទថា **ឯកច្ចោ** គឺ បុគ្គលម្នាក់ ។

បទថា **លាភហេតុ** ព្រោះហេតុនៃលាភ គឺ លាភនុ៎ះឯងជាហេតុ , ព្រោះដូច្នោះ លោកទើបពោល **លាភហេតុតោ** ព្រោះហេតុនៃលាភ ។ បទនេះ ជាបញ្ចមីវិភត្តិចុះក្នុងអត្ថថា **ហេតុ** ។ បទថា **លាភបច្ចយា លាភការណា** ជាវេវច្ចនៈរបស់បទថា **លាភហេតុ** នោះឯង ។ ការពិត ផលនោះរមែងមកដល់ព្រោះអាស្រ័យហេតុនោះឯង ព្រោះហេតុនោះ លោកទើបពោលថា **បច្ចយោ** , និងហេតុធ្វើឲ្យកើតផល ព្រោះហេតុនោះ លោកទើបពោលថា ការណំ ។ បទថា **យថាសមាទិន្នំ** សមាទាន បានដល់ កន្លង គឺ ប្រព្រឹត្តកន្លងសិក្ខាបទ ដែលខ្លួនសមាទាន គឺ កាន់ទុកហើយ ។



បទថា **ឯវរូបានិ** មានសភាពយ៉ាងនេះ , អធិប្បាយថា មានប្រការដូចពោលហើយ ។

បទថា **សីលានិ** គឺ ជាសីលរបស់គ្រហស្ថក៏ដោយ សីលរបស់បព្វជិតក៏ដោយ , សីលណាមួយក្នុងខាងដើម ឬខាងចុង ដាច់ ឈ្មោះថា **ខណ្ឌានិ** ដូចសំពត់សាដកដែលដាច់ជាយ ។

សីលណាមួយដាច់ ក្នុងចំណែកកណ្តាល ឈ្មោះថា **ឆិទ្ទានិ** កណ្តាល ។

សីលប្រការទីពីរ ឬប្រការទីបី ដាច់តាមលំដាប់ ឈ្មោះថា **សព្វលានិ** សីលពពាល ដូចមេគោណាមួយដែលមានសម្បុរ

ខ្នួនខ្មៅផង និងក្រហមផងជាដើម ដោយមានពណ៌មិនដូចគ្នា មានសណ្ឋានវែង និងមូលជាដើម តាំងនៅលើខ្នង ឬពោះ ។

សីលប្រការណាមួយ ដាច់ជាចន្លោះ ៗ ឈ្មោះថា **កម្មាសានិ** សីលពព្រុះ ដូចមេគោមានពណ៌អុច ៗ មិនដូចគ្នាក្នុងចន្លោះ ៗ ។

**សីល** សូម្បីទាំងអស់ ឈ្មោះថា ដាច់ ធ្លុះ ពពាល ពព្រុះ ព្រោះមេថុនសំយោគ ការប្រកបព្រមដោយមេថុន ៧ យ៉ាង និង ព្រោះត្រូវធម៌ដ៏លាមក មានសេចក្ដីក្រោធ និងការចងសេចក្ដីក្រោធទុកជាដើម ធ្វើឲ្យវិនាស ។

សីលទាំងនោះ ឈ្មោះថា **ន កុជិស្សានិ** មិនជាឥស្សរៈ ដោយមិនប្រព្រឹត្តទៅជាឥស្សរៈ ព្រោះជាទាសៈនៃតណ្ហា ។

សីលទាំងឡាយ ឈ្មោះថា **ន វិញ្ញូប្បសដ្ឋានិ** វិញ្ញូជនមិនសរសើរ ព្រោះវិញ្ញូជន មានព្រះពុទ្ធជាម្ចាស់ជាដើម មិនសរសើរ ។

ឈ្មោះថា **បរាមដ្ឋានិ** ព្រោះត្រូវតណ្ហា និងទិដ្ឋិ ចាប់យកហើយ , ឬព្រោះនរណា ៗ អាចនឹងតិះដៀលបានថា នេះជាទោសក្នុងសីលរបស់លោក ។



មួយ៉ាងវិញទៀត ឈ្មោះថា **អសមាធិសំវត្តនិកានិ** មិនប្រព្រឹត្តទៅដើម្បីសមាធិ ព្រោះមិនគប្បីធ្វើឲ្យមគ្គសមាធិ ឬផលសមាធិប្រព្រឹត្តទៅបាន , បាឋៈថា **ន សមាធិសំវត្តនិកានិ** ដូច្នេះខ្លះ តែសេចក្ដីដូចគ្នា ។

ចំណែកអាចារ្យពួកខ្លះ ពណ៌នាសេចក្ដីទុកយ៉ាងនេះថា ឈ្មោះថា **ខណ្ឌានិ** ព្រោះមិនជាទីតាំងនៃកុសលធម៌ទាំងឡាយ , សូម្បីឈ្មោះថា **ឆិទ្ទានិ** នោះ ក៏មានសេចក្ដីយ៉ាងនោះ , ឈ្មោះថា **សពលានិ** ព្រោះមានពណ៌ផ្សេង ៗ គ្នា , សូម្បីឈ្មោះថា **កម្មាសានិ** ក៏យ៉ាងនោះ ។ ឈ្មោះថា ន កុជិស្សានិ ព្រោះដល់ភាពជាទាសៈរបស់តណ្ហា ។ ឈ្មោះថា **ន វិញ្ញូប្បសដ្ឋានិ** ព្រោះត្រូវអ្នកប្រាជ្ញតិះដៀល ។ ឈ្មោះថា **បរាមដ្ឋានិ** ព្រោះត្រូវតណ្ហាចាប់យក ។ ឈ្មោះថា **អសមាធិសំវត្តនិកានិ** ព្រោះជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ។

បទថា **ន អវិប្បដិសារវត្ថុកានិ** ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ សេចក្ដីថា ជាទីតាំងនៃសេចក្ដីមិនក្ដៅក្រហាយមិនមាន ព្រោះនាំមកនូវសេចក្ដីក្ដៅក្រហាយ ។

បទថា **ន បាមុជ្ជវត្ថុកានិ** មិនជាទីតាំងនៃបាមោជ្ជៈ សេចក្តីថា មិនជាទីតាំងនៃបីតិយ៉ាងទន់ ដែលមិនឲ្យកើតសេចក្តីក្តៅក្រហាយ ព្រោះមិននាំបីតិយ៉ាងទន់នោះមក ។ សូម្បីក្នុងបទដ៏សេស ក៏គប្បីប្រកបយ៉ាងនេះ ។

បទថា **ន បីតិវត្ថុកានិ** មិនជាទីតាំងនៃបីតិ សេចក្តីថា មិនជាទីតាំងនៃបីតិយ៉ាងខ្លាំង ដែលកើតពីបីតិយ៉ាងទន់ ។

បទថា **ន បស្សទ្ធិវត្ថុកានិ** មិនជាទីតាំងនៃស្ងប់ស្ងប់ សេចក្តីថា មិនជាទីតាំងនៃសេចក្តីស្ងប់កាយ និងចិត្តដែលកើតពីបីតិដ៏ខ្លាំងនោះ ។

បទថា **ន សុខវត្ថុកានិ** មិនជាទីតាំងនៃសេចក្តីសុខ សេចក្តីថា មិនជាទីតាំងនៃសេចក្តីសុខផ្លូវកាយ និងផ្លូវចិត្ត ដែលកើតអំពីសេចក្តីស្ងប់ ។

បទថា **ន សមាធិវត្ថុកានិ** សេចក្តីថា មិនជាទីតាំងនៃសមាធិ សេចក្តីថា មិនជាទីតាំងនៃសមាធិដែលកើតពីសេចក្តីសុខ ។

បទថា **ន យថាភូតញ្ញាណទស្សនវត្ថុកានិ** មិនជាទីតាំងនៃ



យថាភូតញ្ញាណទស្សនៈ សេចក្តីថា មិនជាទីតាំងនៃយថាភូត-ញ្ញាណទស្សនៈ ដែលជាបទដ្ឋាននៃសមាធិ ។

ក្នុងបទមានជាអាទិ៍ថា **ន ឯកន្តនិព្វិទាយ** មិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយតែម្យ៉ាង គប្បីនាំ **ន** អក្សរ មកប្រកបសូម្បីក្នុងបទដ៏សេស ដោយន័យមានជាអាទិ៍ថា **ន វិរាគាយ** មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក ។

ម្យ៉ាងវិញទៀត បាឋៈមាន **ន** អក្សរ ក្នុងបទមានជាអាទិ៍ថា **ន វិរាគាយ** ។ ក្នុងបទទាំងនោះ បទថា **ឯកន្តនិព្វិទាយ** គប្បីជ្រាបន័យដែលជាប់គ្នាថា សីលទាំងឡាយ រមែងមិនប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយ ក្នុងវដ្តៈតែម្យ៉ាង ។ សូម្បីបទដ៏សេសក៏គប្បីប្រកបយ៉ាងនេះ ។

បទថា **វិរាគាយ** គឺ ដើម្បីសេចក្តីប្រាសចាកតម្រេកក្នុងវដ្តៈ ។

បទថា **និរោធាយ** គឺ ដើម្បីសេចក្តីរលត់នៃវដ្តៈ ។ បទថា **ឧបសមាយ** គឺ ដើម្បីសេចក្តីស្ងប់នៃវដ្តៈ ដោយការមិនកើតទៀតនៃវដ្តៈដែលរលត់ហើយ ។

បទថា **អភិញ្ញាយ** គឺ ដើម្បីសេចក្តីដឹងដ៏ក្រៃលែងនៃវដ្តៈ ។

បទថា **សម្ពោធាយ** គឺ ដើម្បីការត្រាស់ដឹង គឺ ដើម្បីសេចក្តីភ្ញាក់អំពីវដ្តៈដោយប្រាសចាកការដេកលក់ គឺ កិលេស ។

បទថា **និព្វានាយ** គឺ ដើម្បីនិព្វានដែលជាអមតៈ ។

បទថា **យថាសមាទិន្នំ សិក្ខាបទំ វីតិក្កមាយ** ដើម្បីកន្លងសិក្ខាបទតាមដែលខ្លួនសមាទានទុកហើយ ក្នុងបទនេះ លោកប្រកបជាទុតិយាវិភត្តិ ដោយវិភត្តិវិបល្លាស ។

បទថា **ចិត្តម្បិ ន ឧប្បាទេតិ** សូម្បីការគិត ក៏មិនឲ្យកើតឡើង លោកពោលដើម្បីសម្តែងសភាពរបស់សីល ដែលបរិសុទ្ធិដ៏ក្រៃលែង ដោយសេចក្តីបរិសុទ្ធិនៃចិត្តុប្បាទ ។ សីលមិនមែនដាច់ដោយត្រឹមតែចិត្តុប្បាទ ។

បទថា **កឹ សោ វីតិក្កមិស្សតិ** គេនឹងកន្លងសិក្ខាបទបានយ៉ាងណាទៅ គឺ គេនឹងធ្វើការកន្លងដើម្បីអ្វី អធិប្បាយថា គេនឹងមិនធ្វើការកន្លងនោះឯង ។

បទមានជាអាទិ៍ថា **អខណ្ឌានិ** គប្បីជ្រាបដោយន័យផ្ទុយគ្នា ដូចពោលហើយក្នុងខាងដើមនោះឯង ។ បាឋៈថា **ន ខណ្ឌានិ**



ខ្លះ ។ ក្នុងបទមានជាអាទិ៍ថា **ឯកន្តនិព្វិទាយ** គប្បីប្រកបដោយន័យមានជាអាទិ៍ថា **ឯកន្តេន វដ្តេ និព្វិន្ទនត្ថាយ** ដើម្បីសេចក្តីនឿយណាយក្នុងវដ្តៈតែម្យ៉ាង ។

ម្យ៉ាងទៀត ក្នុងបទទាំងនេះ បទថា **និព្វិទាយ** បានដល់វិបស្សនា ។

បទថា **វិរាគាយ** បានដល់ មគ្គ ។

បទថា **និរោធាយ ឧសមាយ** បានដល់ និព្វាន ។

បទថា **អភិញ្ញាយ សម្ពោធាយ** បានដល់ មគ្គ ។

បទថា **និព្វានាយ** បានដល់ និព្វានប៉ុណ្ណោះ ។

គប្បីជ្រាបកថាដែលនៅមិនទាន់ច្បាស់យ៉ាងនេះថា លោកពោលថា វិបស្សនាក្នុងឋានៈ ១ , មគ្គក្នុងឋានៈ ២ , និព្វានក្នុងឋានៈ ៣ ។ តែដោយបរិយាយ បទទាំងអស់នេះជាវេវចនៈរបស់មគ្គខ្លះ ជាវេវចនៈរបស់និព្វានខ្លះ ។

ឥឡូវនេះ ព្រះសារីបុត្ត កាលសម្តែងប្រភេទរបស់សីលដែលមានទីបំផុត និងមិនមានទីបំផុតហើយ ដើម្បីសម្តែងប្រភេទរបស់សីលដែលសម្បយុត្តដោយធម៌ ដោយជាតិ ដោយបច្ច័យ

តទៅ ទើបពោលបទមានជាអាទិ៍ថា ***កឹ សីលំ*** អ្វីជាសីល ដូច្នេះ ។

ក្នុងបទទាំងឡាយនោះ ឈ្មោះថា ***សមុដ្ឋានំ*** មានវិគ្រោះថា សីលជាហេតុតាំងឡើង ។ បទនេះជាឈ្មោះរបស់បច្ច័យ ។ ឈ្មោះថា ***កឹ សមុដ្ឋានំ*** វិគ្រោះថា សីលមានអ្វីជាសមុដ្ឋាន ។ ឈ្មោះថា ***កតិធម្មសមោធានំ*** ព្រោះមានវិគ្រោះថា សីលជាទីប្រជុំ ជាទីប្រមូលមកនូវធម៌អ្វី ។

បទថា ***ចេតនា សីលំ*** សេចក្ដីថា ចេតនារបស់អ្នកវៀរចាកបាណាតិបាតជាដើម ឬរបស់អ្នកបំពេញវត្តបដិបត្តិ ។

បទថា ***ចេតសិកំ សីលំ*** ចេតសិកក៏ជាសីល សេចក្ដីថា ការវៀររបស់អ្នកវៀរចាកបាណាតិបាតជាដើម ។ ម្យ៉ាងទៀត ***ចេតនា*** ឈ្មោះថា ជាសីល បានដល់ ចេតនាក្នុងកម្មបថ ៧ របស់អ្នកវៀរចាកបាណាតិបាតជាដើម ។ ***ចេតសិក*** ឈ្មោះថា សីល បានដល់ ធម៌ គឺ អនភិជ្ឈា អព្យាបាទ និងសម្មាទិដ្ឋិ ដែលលោកពោលទុក ដោយន័យមានជាអាទិ៍ថា ***អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ*** ភិក្ខុលះបង់អភិជ្ឈាក្នុងលោក មានចិត្តប្រាសចាកអភិជ្ឈាហើយ ។



ក្នុងបទថា ***សំវរោ សីលំ*** សេចក្ដីសង្រួមជាសីល គប្បីជ្រាបសេចក្ដីសង្រួមមាន ៥ យ៉ាង គឺ ***បាតិមោក្ខសំវរ*** សេចក្ដីសង្រួមក្នុងបាតិមោក្ខ ១ , ***សតិសំវរ*** សេចក្ដីសង្រួមក្នុងសតិ ១ , ***ញាណសំវរ*** សេចក្ដីសង្រួមក្នុងញាណ ១ , ***ខន្តិសំវរ*** សេចក្ដីសង្រួមក្នុងខន្តិ ១ , ***វីរិយសំវរ*** សេចក្ដីសង្រួមក្នុងការព្យាយាម ១ ។

ក្នុងការសង្រួម ៥ យ៉ាងនោះ ភិក្ខុចូលដល់ ចូលដល់រឿយ ៗ ដោយការសង្រួមក្នុងបាតិមោក្ខនេះ នេះឈ្មោះថា បាតិមោក្ខសំវរៈ ។ ភិក្ខុរក្សាចក្ខុន្ទ្រិយ៍ , បានដល់ ការសង្រួមក្នុងចក្ខុន្ទ្រិយ៍នេះ ឈ្មោះថា សតិសំវរៈ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ត្រាស់ថា ៖

***យានិ សោតានិ លោកស្មឹ សតិ តេសំ និវារណំ***
***សោតនំ សំវរំ ព្រូមិ បញ្ញាយេតេ បិធិយ្យរេ ។***

ម្នាលអជិតៈ សតិជាគ្រឿងហាមក្រសែតណ្ហា ក្នុងលោកតថាគតពោលការសង្រួម ជាការបិទក្រសែតណ្ហាទាំងនោះ បណ្ឌិតគប្បីបិទក្រសែទាំងនេះ ដោយបញ្ញា ។

នេះឈ្មោះថា **ញាណសំវរ** ។ សូម្បីការសេពចំពោះបច្ច័យ ក៏រមែងសង្គ្រោះចូលក្នុងបទនេះដូចគ្នា ។ ការសង្រួមមកហើយ ដោយន័យមានជាអាទិ៍ថា **ខមោ ហោតិ សីតស្ស ឧណ្ហស្ស** កិក្ខុ ជាអ្នកអត់ទ្រាំចំពោះភាពត្រជាក់ក្តៅ នេះឈ្មោះថា **ខន្តិសំវរ** ។ សេចក្តីសង្រួម ដោយន័យមានជាអាទិ៍ថា **ឧប្បន្នំ កាមវិតក្កំ នាធិវាសតិ** ចំពោះកាមវិតក្កៈដែលកើតឡើង នេះឈ្មោះថា **វីរិយសំវរ** ។ សូម្បីអាជីវបរិសុទ្ធ ក៏រួមចូលក្នុងបទនេះដូចគ្នា ។ សេចក្តីសង្រួម ៥ យ៉ាងនេះ ដោយប្រការដូច្នេះ , ម្យ៉ាងទៀត ចេតនាវៀរចាកវត្ថុដែលមកដល់ របស់កុលបុត្តអ្នកខ្លាចបាប , គប្បីជ្រាបថា ទាំងអស់នោះជា **សំវរសីល** ។

បទថា អវីតិក្កមោ សីលំ ការមិនឈានកន្លងជា សីល បានដល់ ការមិនឈានកន្លងផ្លូវកាយ និងផ្លូវវាចារបស់អ្នកសមាទានសីល ។ នេះជាការដោះស្រាយបញ្ហាថា **កឹ សីលំ** អ្វីជាសីល ទុកត្រឹមនេះសិន ។

ក្នុងការដោះស្រាយបញ្ហាថា **កតិ សីលានិ** សីលមានប៉ុន្មានយ៉ាង ព្រោះប្រក្រតីរបស់សត្វទាំងឡាយក្នុងលោក លោក



ពោលថា **សីលំ** ទុកក្នុងបទនេះថា **កុសលសីលំ** កុសលជាសីល , **អកុសលសីលំ** អកុសលជាសីល , **អព្យាកតសីលំ** អព្យាក្រិតជាសីល , អាចារ្យទាំងឡាយពោលសំដៅដល់សីលថា នេះជា **សុខសីល** សេចក្តីសុខជាសីល , នេះជា **ទុក្ខសីល** សេចក្តីទុក្ខជាសីល , នេះជា **កលហសីល** ការឈ្លោះទាស់ទែងគ្នា ជាសីល , នេះជា **មណ្ឌនសីល** ការតុបតែងខ្លួនជាសីល ។ ដូច្នោះដោយបរិយាយនោះ សូម្បី **អកុសលសីល** លោកពោលថា ជាសីល ដោយការលើកយកការកើតឡើង តែសីលដែលលោកបំណងយកក្នុងទីនេះមិនមាន ព្រោះបាលីថា **សុត្វាន សំវរេ បញ្ញា** បញ្ញាក្នុងការស្តាប់ ហើយសង្រួមដូច្នេះ ។

ម្យ៉ាងទៀត ព្រោះចិត្តដែលសម្បយុត្ត ជាសមុដ្ឋានរបស់សីល ដែលជាប្រភេទ មានចេតនាជាដើម , ដូច្នោះព្រះសារីបុត្តទើបពោលបទមានជាអាទិ៍ថា **កុសលចិត្តសមុដ្ឋានំ** កុសលសីល កុសលសីល មានកុសលចិត្តជាសមុដ្ឋាន ។

បទថា **សំវរសមោធានំ សីលំ** សីល ជាទីប្រជុំនៃសំវរៈ បានដល់ ខន្ធដែលសម្បយុត្តដោយការសង្រួម ។ ពិតណាស់ ខន្ធ

ទាំងនោះ មកព្រមគ្នាជាមួយសេចក្តីសង្រួម ទើបលោកពោលថា **មិស្សីភូតា** ជាវត្ថុលាយគ្នា , **សំវរសមោធានំ** ប្រជុំនៃការមិនឈានកន្លង ក៏គប្បីជ្រាបយ៉ាងនេះ ។

បទថា **តថាភាវេ ជាតចេតនា សមោធានំ សីលំ** សីលជាទីប្រជុំនៃចេតនាដែលកើតក្នុងសភាពយ៉ាងនោះ បានដល់ ខន្ធដែលសម្បយុត្តដោយចេតនា ដែលកើតព្រោះការសង្រួម ក្នុងការមិនឈានកន្លង ។ លោកបំណងយកធម៌ ដែលសម្បយុត្តជាមួយចេតនានោះ ក្នុងចេតនាសូម្បីទាំងបី , ដូច្នោះគប្បីជ្រាបថា លោកមិនចង្អុលបង្ហាញសីល ដែលជាទីប្រជុំនៃចេតសិកទុកផ្សេងអំពីគ្នា ព្រោះសូម្បីចេតសិក លោកក៏សង្គ្រោះដោយការប្រជុំនៃចេតនា ។ ធម៌ទាំងឡាយ មានចេតនាជាដើម លោកពោលថា **សីលំ** ទុកក្នុងខាងក្រោយហើយ ។ គប្បីជ្រាបថា លោកពោលតិកៈនេះ ដើម្បីសម្តែងថា ធម៌ទាំងឡាយនោះមិនមែនជាសីលតែម្យ៉ាង ។ សូម្បីធម៌សម្បយុត្តជាមួយសីលនោះ ក៏ជាសីលដូចគ្នា ។

ឥឡូវនេះ ព្រោះចេតនា និងចេតសិក មិនឈានកន្លងសំវរៈដូចគ្នា , ដូច្នោះ ព្រះសារីបុត្តកាលនឹងប្រកបការមិនឈាន



កន្លងសំវរៈដោយលំដាប់ទូទៅរហូតដល់អរហត្តមគ្គ ទើបពោលបទមានជាអាទិ៍ថា **បាណាតិបាតំ សំវរដ្ឋេន សីលំ , អវីតិក្កមដ្ឋេន សីលំ** ឈ្មោះថា សីល ព្រោះអត្ថថា សង្រួម និងមិនឈានកន្លងបាណាតិបាត ដូច្នេះ ។ ព្រោះការវៀរចាកបាណាតិបាតជាដើម រមែងសង្រួមចំពោះវត្ថុដែលជាសត្រូវរបស់ខ្លួន , និងរមែងមិនឈានកន្លងវត្ថុដែលជាសត្រូវនោះ , ដូច្នោះ ឈ្មោះថា **សីល** ព្រោះអត្ថថា សង្រួម ព្រោះអត្ថថា មិនឈានកន្លង ព្រោះសង្រួម និងព្រោះមិនឈានកន្លង ។

ក្នុងបទទាំងនោះ បទថា **បាណាតិបាតំ សំវរដ្ឋេន** បានដល់ ឈ្មោះថា **សីល** ព្រោះអត្ថថា បិទបាណាតិបាត ។ សីលប្រការនោះ គឺអ្វី ? គឺ **បាណាតិបាតា វេរមណី** ។ ម្យ៉ាងទៀត **បាណាតិបាត វេរមណី** នោះ សង្រួមសីលប្រការនោះ មិនឈានកន្លងសីលនោះ ព្រោះហេតុ មិនឈានកន្លងសីលនោះ ព្រោះហេតុនោះ ឈ្មោះថា **សីលំ** ព្រោះអត្ថថា មិនឈានកន្លង ។ សីលប្រការ **អទិន្នាទាន វេរមណី** ជាដើម គប្បីប្រកបអនភិជ្ឈា អព្យាបាទ និងសម្មាទិដ្ឋិ ចូលជាមួយផង ។

ក្នុងបទមានជាអាទិ៍ថា **បាណាតិបាតំ** គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ការញុំាងសត្វឲ្យធ្លាក់ទៅក្នុងអកុសលកម្មបថ ១០ ឈ្មោះថា បាណាតិបាត , លោកអធិប្បាយថា ការប្រហារសត្វ ការសម្លាប់សត្វ ។

មយ៉ាងទៀត ក្នុងបទថា **បាណោ** នេះ ដោយវោហារ បានដល់ សត្វ , ដោយបរមត្ថ បានដល់ជីវិតិន្ទ្រីយ៍ ។ សត្វមានជីវិត ក៏ដឹងថាសត្វមានជីវិត ចេតនាដែលនឹងសម្លាប់ ប្រព្រឹត្តទៅក្នុងទ្វារណាមួយ នៃកាយទ្វារ និងវចីទ្វារ តាំងសេចក្តីព្យាយាមក្នុងការផ្តាច់បង់ជីវិតិន្ទ្រីយ៍ ឈ្មោះថា **បាណាតិបាត** តិរច្ឆានជាដើម មិនមានគុណ បាណាតិបាតនោះ ក៏មានទោសតិចក្នុងសត្វតូច ៗ , មានទោសច្រើន ក្នុងសត្វធំ ៗ ។ ព្រោះហេតុអ្វី ? ព្រោះប្រើសេចក្តីព្យាយាមច្រើន ។ ព្រោះសូម្បីក្នុងការព្យាយាមក៏ត្រូវប្រើសំភារៈធំ ៗ , ក្នុងមនុស្សជាដើម អ្នកមានគុណ គប្បីជ្រាបថា បាណាតិបាត មានទោសតិចក្នុងមនុស្សមានគុណតិច , មានទោសច្រើន ក្នុងមនុស្សមានគុណច្រើន ។ កាលបើរាងកាយនិងគុណស្មើគ្នា បាណាតិបាតមានទោសតិច ព្រោះកិលេស និង



សេចក្តីព្យាយាមតិច , មានទោសច្រើន ព្រោះកិលេស និងសេចក្តីព្យាយាមខ្លាំងក្លា ។

**បាណាតិបាតនោះ មានអង្គ ៥ គឺ :**

**១.បាណោ** សត្វមានជីវិត ។

**២.បាណសញ្ញិតា** ដឹងថាសត្វមានជីវិត ។

**៣.វធកចិត្តំ** ចិត្តគិតនឹងសម្លាប ់។

**៤.ឧបក្កមោ** ព្យាយាមនឹងសម្លាប់ ។

**៥.តេនមរណំ** សត្វស្លាប់ដោយសេចក្តីព្យាយាមនោះ ។

ការកាន់យករបស់ដែលគេមិនបានឲ្យជា **អទិន្នាទាន** , លោកអធិប្បាយការនាំ របស់បុគ្គលដទៃទៅ មានចិត្តគិតនឹងលួចយកនូវរបស់នោះ ។

ក្នុងបទទាំងនោះ បទថា **អទិន្នំ** របស់ដែលគេមិនបានឲ្យ គឺ របស់ដែលបុគ្គលដទៃហួងហែង ។ បុគ្គលដទៃ បានទទួលរបស់ដែលខ្លួនធ្វើតាមបំណង ជាអ្នកមិនគួរបានទទួលអាជ្ញា និងមិនគួរតិះដៀលក្នុងវត្ថុណា , កាលបើវត្ថុនោះ អ្នកដទៃហួងហែងខ្លួនក៏ដឹងថា អ្នកដទៃហួងហែង ចេតនាប្រព្រឹត្តទៅដើម្បីលួចក្នុង

ទ្វារណាមួយ តាមផ្លូវកាយទ្វារ និងវចីទ្វារ ដែលតាំងឡើងដោយសេចក្ដីព្យាយាមកាន់យករបស់នោះ ឈ្មោះថា **អទិន្នាទាន** មានទោសតិច ក្នុងរបស់របរអ្នកដទៃដែលអន់ថយ , មានទោសច្រើនក្នុងរបស់ដែលប្រណីត ។ ព្រោះហេតុអ្វី ? ព្រោះវត្ថុប្រណីត ។ បើវត្ថុស្មើគ្នា មានទោសច្រើនក្នុងវត្ថុដែលជារបស់អ្នកក្រៃលែងដោយគុណ , មានទោសតិច ក្នុងវត្ថុដែលជារបស់អ្នកមានគុណតិចជាងអ្នកក្រៃលែងដោយគុណនោះ ៗ សំដៅយកវត្ថុនោះ ៗ មានគុណច្រើន ។

**អទិន្នាទាន** មានអង្គ ៥ គឺ :

**១.បរបរិគ្គហិតំ** វត្ថុដែលបុគ្គលដទៃហួងហែង

**២.បរបរិគ្គហិតសញ្ញិតា** ដឹងថាបុគ្គលដទៃហួងហែង

**៣.ថេយ្យចិត្តំ** ចិត្តគិតនឹងលួច

**៤.ឧបក្កមោ** ព្យាយាមនឹងលួច

**៥.តេន ហរណំ** នាំទៅដោយសេចក្ដីព្យាយាមនោះ

បទថា **កាមេសុ** បានដល់ ការប្រព្រឹត្តក្នុងមេថុន ។ បទថា **មិច្ឆាចារោ** ប្រព្រឹត្តលាមកដែលត្រូវបានតិះដៀលតែម្យ៉ាង ។ តែ



តែដោយលក្ខណៈ ចេតនាដែលឈានកន្លងឋានៈស្ត្រីដែលមិនគួរ គឺ ប្រព្រឹត្តក្នុងកាយទ្វារ ដោយបំណងនឹងប្រព្រឹត្តអាក្រក់ ( អសទ្ធម្ម ) ឈ្មោះថា **កាមេសុ មិច្ឆាចារ** ។

ក្នុងបទនោះ ស្ត្រី ២០ ជំពូក គឺ ស្ត្រីដែលមាតាឃុំគ្រងជាដើម , ១០ ជំពូក គឺ មាតាឃុំគ្រង ១ , បិតាឃុំគ្រង ១ , មាតាបិតាឃុំគ្រង ១ , បងប្រុសឃុំគ្រង ១ , បងស្រីឃុំគ្រង ១ , ញាតិឃុំគ្រង ១ , គោត្រឃុំគ្រង ១ , ធម៌ឃុំគ្រង ១ , មានអ្នកអារក្ខា ១ , មានទោសទណ្ឌ ១ ។ ស្ត្រី ១០ ជំពូក គឺ ស្ត្រីដែលបានមកដោយទ្រព្យជាដើម ១០ ជំពូក គឺ ស្ត្រីដែលបានមកដោយទ្រព្យ ១ , នៅដោយសេចក្ដីពេញចិត្ត ១ , នៅដោយភោគៈ ១ , នៅដោយឲ្យសំពត់ ១ , យួរធុងទឹក ១ , ដាក់កាជនៈពីលើសិរសៈ ១ , ករិយាដែលជាទាសី ១ , ករិយាដែលជាកម្មករ ១ , នាំមកដោយទង់ ១ , នៅមួយដងមួយគ្រា ១ ឈ្មោះថា **អគមនីយដ្ឋាន** គឺ ឋានៈស្ត្រី ដែលបុរសមិនគួរដល់របស់បុរសទាំងឡាយ ។ ក៏ក្នុងបណ្ដាស្ត្រីទាំងឡាយ បុរសដទៃឈ្មោះថាជា **អគមនីយដ្ឋាន** របស់ស្ត្រី ១២ ជំពូក គឺ ស្ត្រីដែល

មានអ្នកឃុំគ្រង និងស្ត្រីត្រូវទោសទណ្ឌ ២ និងស្ត្រីដែលលោះមកដោយទ្រព្យជាដើម ១០ ជំពូកនេះ ។

មួយ៉ាងទៀត មិច្ឆាចារនោះ មានទោសតិច ក្នុងស្ត្រីដែលជាអគមនីយដ្ឋានដែលមិនមានគុណធម៌ មានសីលជាដើម , មានទោសច្រើន ក្នុងស្ត្រីដែលសម្បូរដោយគុណធម៌ មានសីលជាដើម ។

**មិច្ឆាចារ** មានអង្គ ៤ គឺ :

**១.អគមនីយវត្ថុ** វត្ថុដែលមិនគួរដល់ ។

**២.តស្មឹ សេវនចិត្តំ** ចិត្តគិតនឹងសេពក្នុងវត្ថុដែលមិនគួរនឹងសេពនោះ ។

**៣.សេវនប្បយោគោ** ព្យាយាមនឹងសេព ។

**៤.មគ្គេន មគ្គប្បដិបត្តិអធិវាសនំ** មគ្គ និងមគ្គដល់គ្នា ។

បទថា **មុសា** បានដល់ វចីបយោគៈ ឬកាយបយោគៈ ដែលកាត់នូវប្រយោជន៍របស់អ្នកបំណងនឹងនិយាយឲ្យខុស ។

ចេតនាតាំងឡើងដោយកាយបយោគៈ និងវចីបយោគៈរបស់អ្នកនិយាយឲ្យអ្នកដទៃយល់ខុស ដោយបំណងឲ្យគេយល់ខុស ឈ្មោះថា **មុសាវាទ** ។ ន័យម្យ៉ាងទៀត បទថា **មុសា** បានដល់



រឿងមិនពិត ។ បទថា **វាទោ** បានដល់ និយាយឲ្យគេដឹងដោយសេចក្តីពិត ។ តែដោយលក្ខណៈ ចេតនាតាំងឡើងដោយការប្រាប់សេចក្តីនោះ របស់អ្នកមានបំណងនឹងឲ្យអ្នកដទៃដឹងរឿងមិនពិត ថាជារឿងពិត ឈ្មោះថា **មុសាវាទ** ។ មុសាវាទនោះមានទោសតិច ព្រោះកាត់ប្រយោជន៍តិច , មានទោសច្រើនព្រោះកាត់ប្រយោជន៍ច្រើន ។ ម្យ៉ាងវិញទៀត មានទោសតិចប្រព្រឹត្តទៅដោយន័យមានជាអាទិ៍ថា របស់របរខ្លួនមិនមាន ព្រោះបំណងនឹងមិនឲ្យដល់គ្រហស្ថ , មានទោសច្រើន ព្រោះព្យាយាមនិយាយបោកប្រាសដើម្បីប្រយោជន៍ ។ មានទោសតិច ប្រព្រឹត្តទៅដោយន័យដែលបព្វជិតបានប្រេង ឬទឹកដោះថ្លា ហើយនិយាយបញ្ឆោតដោយបំណងនឹងសើចលេងថា ថ្ងៃនេះក្នុងផ្ទះគង់នឹងមានប្រេងហូរមកដូចទន្លេជិនៈ , មានទោសច្រើនដល់អ្នកនិយាយដោយន័យមានជាអាទិ៍ថា មិនឃើញហើយ ក៏និយាយថាឃើញដូច្នេះ ។

**មុសាវាទ** មានអង្គ ៤ គឺ ៖

**១.អតថំ វត្ថុំ** រឿងមិនពិត ។

**២.វិសំវាទនចិត្តំ** ចិត្តគិតនឹងនិយាយឲ្យខុស ។

**៣.តជ្ជោ វាយាមោ** ព្យាយាមកើតពីចិត្តគិតនិយាយឲ្យខុសនោះ ។

**៤.បរស្ស តទត្ថវិជាននំ** អ្នកដទៃដឹងសេចក្តីបំណងរបស់ពាក្យនិយាយនោះ ។

វាចាដែលនិយាយ ធ្វើសេចក្តីគួរស្រឡាញ់របស់ខ្លួន តែក្នុងចិត្តរបស់អ្នកនោះ ធ្វើអ្នកដទៃឲ្យវិនាស ឈ្មោះថា **បិសុណាវាចា** វាចាស៊កសៀត ។

វាចាដែលធ្វើខ្លួនឯងខ្លះ អ្នកដទៃខ្លះ ឲ្យលំបាក សូម្បីវាចានោះឯងក៏គ្រោតគ្រាត មិនសប្បាយត្រចៀក ឬមិនសប្បាយចិត្ត ឈ្មោះថា **ផរុសវាចា** វាចាគ្រោតគ្រាត ។

វាចាដែលនិយាយរោយរាយឥតប្រយោជន៍ ឈ្មោះថា **សម្ផប្បលាបោ** សូម្បីចេតនាដែលជាមូលហេតុរបស់មុសាវាទទាំងនោះ ក៏បានឈ្មោះថា មានបិសុណាវាចាជាដើម ។ **បិសុណាវាចា** នោះឯង លោកបំណងយកក្នុងទីនេះ ។

ក្នុងបទថា **បិសុណា វាចា** នោះ ចេតនារបស់អ្នកមានចិត្ត



សៅហ្មង តាំងឡើងដោយកាយបយោគៈ និងវចីបយោគៈ ដើម្បីទម្លាយអ្នកដទៃ ឬដើម្បីបំណងឲ្យអ្នកដទៃស្រឡាញ់ខ្លួន ឈ្មោះថា **បិសុណា វាចា** ។ បិសុណា វាចា នោះ ឈ្មោះថា មានទោសតិច ព្រោះធ្វើសេចក្តីទម្លាយដល់អ្នកដទៃដែលមានគុណធម៌តិច , ឈ្មោះថា មានទោសច្រើន ព្រោះធ្វើសេចក្តីទម្លាយដល់អ្នកមានគុណធម៌ច្រើន ។

**បិសុណាវាចា** មានអង្គ ៤ គឺ ៖

១. អ្នកដទៃដែលខ្លួនគួរទម្លាយ ។

២. បំណងទម្លាយថា អ្នកទាំងនេះនឹងប្រព្រឹត្តទៅផ្សេង ៗ បំណងឲ្យជាទីស្រឡាញ់ថា យើងនឹងជាទីស្រឡាញ់ នឹងជាទីរាប់អាន ។

៣. សេចក្តីព្យាយាមកើតពីបំណងនោះ ។

៤. ឲ្យអ្នកនោះដឹងសេចក្តីបំណងរបស់ការព្យាយាមនោះ ។

កាលបើអ្នកដទៃនៅមិនទាន់បែកគ្នា កម្មបថក៏មិនដាច់ , កាលបើគេបែកគ្នាហើយ កម្មបថទើបដាច់ ។

ចេតនាព្យាយាមតែម្យ៉ាង តាំងឡើងដោយកាយយោគៈ

និងវចីបយោគៈ កាត់នូវសេចក្តីស្រឡាញ់របស់អ្នកដទៃ ជា **ផរុសា វាចា** ។ **បយោគ** សូម្បីកាត់សេចក្តីស្រឡាញ់ ក៏មិនមែនជាផរុសវាចា ព្រោះចិត្តទន់ភ្លន់ ។ ពិតណាស់ មាតាបិតាខ្លះកាលនិយាយជាមួយនឹងបុត្តតូច យ៉ាងនេះថា សូមឲ្យចោរចាប់ពួកឯងយកទៅចុះ ដូច្នេះ ។ តែសេចក្តីពិត មាតាបិតាមិនប្រាថ្នាសូម្បីឲ្យស្លឹកឈូកធ្លាក់លើសីសៈរបស់បុត្តតូច ៗ ទាំងនោះឡើយ ។ រីឯអាចារ្យ និងឧបជ្ឈាយ៍ខ្លះ កាលពោលនឹងពួកនិស្សិតយ៉ាងនេះថា ពួកអ្នកទាំងនេះ មិនមានហិរិឱត្តប្បៈដល់គ្នាសោះឡើយ , បណ្តេញចេញឲ្យអស់ទៅ ។ ប៉ុន្តែតាមការពិត អាចារ្យ និងឧបជ្ឈាយ៍ប្រាថ្នាឲ្យនិស្សិតទាំងនោះ ដល់ព្រមដោយការសិក្សារៀនសូត្រនិងចេះដឹងដូចគ្នាប៉ុណ្ណោះ ។

វាចាគ្រោតគ្រាតមានមិនបាន ព្រោះចិត្តទន់ភ្លន់យ៉ាងណា , សូម្បីវាចាមិនគ្រោតគ្រាត ក៏មានមិនបានព្រោះពាក្យនិយាយទន់ភ្លន់ ដូច្នោះ ។ អ្នកបំណងនឹងសំម្លាប់មនុស្សនិយាយថា ពួកលោកចូរឲ្យអ្នកនេះដេកឲ្យសប្បាយចុះ ដូច្នេះ ជាវាចាគ្រោតគ្រាត , វាចានេះជាវាចាគ្រោតគ្រាត ព្រោះចិត្តគ្រោតគ្រាត , វាចា



គ្រោតគ្រាតនោះ មានទោសតិច ព្រោះអ្នកដែលពោលសំដៅដល់នោះ ជាអ្នកមានគុណតិច , ឈ្មោះថា មានទោសច្រើន ព្រោះអ្នកពោលនោះសំដៅដល់អ្នកមានគុណច្រើន ។

**ផរុសវាចា** មានអង្គ ៣ គឺ ៖

**១.អក្កោសិតព្វោ បរោ** អ្នកដទៃដែលគួរជេរ ។

**២.កុបិតចិត្តំ** មានចិត្តក្រោធខឹង ,

**៣.អក្កោសនា** ការជេរ ។

ចេតនាជាអកុសល តាំងឡើងដោយកាយបយោគៈ និងវចីបយោគៈ ដើម្បីឲ្យដឹងដល់សេចក្តីវិនាស ឈ្មោះថា **សម្ផប្ប-លាប** ។ សម្ផប្បលាបៈនោះ មានទោសតិច ព្រោះអាសេវនៈតិច , មានទោសច្រើន ព្រោះអាសេវនៈច្រើន ។

**សម្ផប្បលាប** មានអង្គ ២ គឺ ៖

១. បំណងនិយាយរឿងដែលមិនមែនជារឿង មានរឿងការ-តយុទ្ធ និងរឿងដណ្តើមនាងសីតាជាដើម ។

២. ការនិយាយរឿងនោះ ។

ក៏កាលបើអ្នកដទៃមិនទាន់ជឿរឿងនោះ កម្មបថក៏នៅមិន

ទាន់ដាច់ , កាលបើអ្នកដទៃជឿពាក្យនិយាយកេយកាយនោះ កម្មបថទើបដាច់ ។

ឈ្មោះថា **អភិជ្ឈា** ព្រោះអត្ថថា **សំឡឹង** អធិប្បាយថា ជាអ្នកសំឡឹងកណ្ឌៈរបស់អ្នកដទៃ រមែងប្រព្រឹត្តទៅ ព្រោះចិត្តបង្អោនទៅក្នុងកណ្ឌៈនោះ ។ អភិជ្ឈានោះ មានលក្ខណៈសំឡឹងកណ្ឌៈរបស់អ្នកដទៃយ៉ាងនេះថា ធ្វើយ៉ាងណាហ្ន៎ កណ្ឌៈនេះទើបនឹងជារបស់យើងបាន , អភិជ្ឈានោះ មានទោសតិច និងមានទោសច្រើន ដូចអទិន្នាទាន ។

**អភិជ្ឈា** មានអង្គ ២ គឺ

**១. បរភណ្ឌំ** កណ្ឌៈរបស់អ្នកដទៃ ។

**២. អត្តនោ បរិណាមនំ** បង្អោនទៅដើម្បីខ្លួន ។

កាលបើសេចក្តីលោភក្នុងវត្ថុ ដែលជារបស់អ្នកដទៃ សូម្បីកើតឡើងហើយ កម្មបថក៏នៅមិនទាន់ដាច់ រហូតដល់មិនទាន់ញ៉ាំងចិត្តបង្អោនទៅថា ធ្វើយ៉ាងណាហ្ន៎ កណ្ឌៈនេះទើបនឹងជារបស់យើងបាន ដូច្នេះ , អភិជ្ឈានោះ មានទោសតិច-ច្រើន ដូចអទិន្នាទាន ។



ឈ្មោះថា **ព្យាបាទ** ព្រោះអត្ថថា ញ៉ាំងប្រយោជន៍ និងសេចក្តីសុខឲ្យដល់សេចក្តីវិនាស ។ **ព្យាបាទ** មានចិត្តបំណងញ៉ាំងសេចក្តីវិនាសឲ្យដល់អ្នកដទៃ មានលក្ខណៈប្រទូសរ៉ាយ , មានទោសតិច និងមានទោសច្រើន ដូចផរុសវាចា ។

**ព្យាបាទ** មានអង្គ ២ គឺ ៖

**១. បរសត្តោ** សត្វដទៃ ។

**២. តស្ស វិនាសចិន្តា** គិតញ៉ាំងសេចក្តីវិនាសឲ្យដល់សត្វដទៃនោះ ។

កាលបើសេចក្តីក្រោធក្នុងសត្វដទៃ សូម្បីកើតឡើងហើយ កម្មបថក៏មិនទាន់ដាច់ រហូតពេលនៅមិនទាន់គិតដល់ការញ៉ាំងសេចក្តីវិនាសដល់សត្វនោះថា ធ្វើយ៉ាងណាហ្ន៎ អ្នកនេះនឹងដល់នូវសេចក្តីវិនាសទៅ ដូច្នេះ ។

ឈ្មោះថា **មិច្ឆាទិដ្ឋិ** ព្រោះអត្ថថា ឃើញខុស ដោយមិនមានការប្រកាន់តាមសេចក្តីពិត ។ មិច្ឆាទិដ្ឋិនោះ មានលក្ខណៈឃើញវិបរិត ដោយន័យមានជាអាទិ៍ថា **នត្ថិ ទិន្នំ** ទានដែលឲ្យហើយមិនមានផល , មិច្ឆាទិដ្ឋិ មានទោសតិច និងទោសច្រើន

ដូចសម្ផប្បលាបៈ , ម្យ៉ាងវិញទៀត មានទោសតិចមិនពិតប្រាកដ , មានទោសច្រើនពិតប្រាកដ ។

**មិច្ឆាទិដ្ឋិ** មានអង្គ ២ គឺ ៖

១. មានការឃើញវិបរិត ខុសពីការពិត ។

២. មានការឃើញខុស ក្នុងការប្រាកដនៃវត្ថុនោះ ហើយប្រកាន់ទុក ។

ក្នុងមិច្ឆាទិដ្ឋិនោះ កម្មបថដាច់ រមែងមានបានដោយ **នត្ថិកទិដ្ឋិ** ការឃើញថាមិនមាន , **អហេតុកទិដ្ឋិ** ការឃើញថាមិនមានហេតុ , **អកិរិយទិដ្ឋិ** មិនមានការធ្វើ , មិនមែនដាច់ដោយទិដ្ឋិដទៃ ។

អកុសលកម្មបថ ១០ ទាំងនេះ គប្បីជ្រាបវិនិច្ឆ័យដោយអាការ ៥ គឺ ដោយធម៌ ១ , ដោយកោដ្ឋាសៈ គឺ ចំណែក ១ , ដោយអារម្មណ៍១ , ដោយវេទនា ១ , ដោយមូលហេតុ ១ ។

ក្នុងបទទាំងនោះ បទថា **ធម្មតោ** ដោយធម៌ បានដល់ចេតនាធម៌ ៧ យ៉ាង , អកុសលកម្មបថ ៣ យ៉ាង មានអភិជ្ឈាជាដើម សម្បយុត្តដោយចេតនា រមែងមានតាមលំដាប់ក្នុងអកុស-



លកម្មបថទាំងនោះ ។

បទថា **កោដ្ឋាសតោ** បានដល់ ធម៌ ៨ ទាំងនេះ គឺ ចេតនាធម៌ ៧ តាមលំដាប់ និងមិច្ឆាទិដ្ឋិ ជាកម្មបថតែម្យ៉ាង , មិនមែនជាមូល ។ អភិជ្ឈា និងព្យាបាទ មានទាំងកម្មបថ មានទាំងមូល ។ ពិតណាស់ **អភិជ្ឈា** លោភៈ ជាអកុសលមូល ព្រោះដល់ហើយនូវមូល , **ព្យាបាទ** ទោសៈ ជាអកុសលមូល ។

បទថា **អារម្មណតោ** ដោយអារម្មណ៍ បានដល់ **បាណាតិបាត** មានសង្ខារជាអារម្មណ៍ ដោយជាអារម្មណ៍ គឺ ជីវិតិន្ទ្រិយ ។

**អទិន្នាទានា** មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ ។

**មិច្ឆាចារ** មានសង្ខារជាអារម្មណ៍ ដោយអំណាចផោដ្ឋព្វៈ , អាចារ្យពួកខ្លះ ពោលថា មានសត្វជាអារម្មណ៍ ដូច្នេះខ្លះ ។

**មុសាវាទ** មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍ ។

**បិសុណាវាចា** ក៏យ៉ាងនោះ ។

**ផរុសវាចា** មានសត្វជាអារម្មណ៍តែម្យ៉ាង ។

**សម្ផប្បលាប** មានសត្វជាអារម្មណ៍ ឬមានសង្ខារជាអារម្មណ៍

ដោយអំណាចរូបដែលបានឃើញ សំលេងដែលបានឮ ក្លិន រស សម្ផ័ស្សដែលបានដឹង និងធម៌ដែលបានជ្រាប ។

**អភិជ្ឈា** ក៏ដូច្នោះ ។

**ព្យាបាទ** មានសត្វជាអារម្មណ៍តែម្យ៉ាង ។

**មិច្ឆាទិដ្ឋិ** មានសង្ខារជាអារម្មណ៍តែម្យ៉ាង ដោយអំណាចធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។

បទថា **វេទនាតោ** ដោយវេទនា បានដល់ **បាណាតិបាត** ជាទុក្ខវេទនា ។ សេចក្ដីពិត ព្រះរាជាទ្រង់ឃើញចោរ សូម្បីទ្រង់សើចសប្បាយ ក៏នៅត្រាស់ថា ម្នាលនាយពួកអ្នកចូរសម្លាប់ចោរនោះចុះ ដូច្នេះ , ក្នុងកាលនោះ ចេតនាដែលកើតឡើងក្នុងចិត្តព្រះរាជាទាំងឡាយ ក៏សម្បយុត្តដោយទុក្ខ ។

**អទិន្នាទាន** មានវេទនា ៣ ។ ព្រោះអទិន្នាទាន នោះជាសុខវេទនា ដល់អ្នកឃើញកណ្ឌៈរបស់អ្នកដទៃហើយត្រេកអររីករាយក្នុងការកាន់យកទៅ , ជាទុក្ខវេទនា ដល់អ្នកដែលលួចយកទៅ ព្រោះមានការភ័យខ្លាច , កាលបើពិចារណាវិបាក និងផលជាខាងក្រោយ ៗ មក ក៏ជាអទុក្ខមសុខវេទនាដល់អ្នកដែល



កាន់យក តាំងនៅក្នុងភាពជាកណ្ដាល ក្នុងពេលលួចយកទៅ ។

**មិច្ឆាចារ** មានវេទនា ២ ដោយអំណាចសុខវេទនា និងភាពជាកណ្ដាល , វេទនាក្នុងភាពជាកណ្ដាល រមែងមិនមានក្នុងចិត្តដែលកំពុងប្រព្រឹត្ត ។

**មុសាវាទ** មានវេទនា ៣ ដោយន័យដូចពោលហើយ ក្នុងអទិន្នាទាននោះឯង ។

**បិសុណាវាចា** ក៏យ៉ាងនោះ ។

**ផរុសវាចា** ជាទុក្ខវេទនា ។

**សម្ផប្បលាប** មានវេទនា ៣ ។ ពេលអ្នកដទៃឲ្យសាធុការលើកសំពត់ជាដើមបក់គ្រវី អ្នកនោះមានសុខវេទនា ក្នុងវេលាពោល មានរឿងដណ្ដើមនាងសីតា និងការតយុទ្ធជាដើម របស់អ្នកផ្ដើមរឿងរីករាយ , កាលបើ អ្នកណាម្នាក់ឲ្យប្រាក់ឈ្នួលទុកមុន តែក្រោយមកបានពោលថា ចូរលោកលេងតាំងពីដើមមកគេរមែងមានទុក្ខវេទនា ក្នុងពេលពោលរបស់អ្នកដែលកើតទោ-មនស្សថា យើងនឹងពោលរឿងផ្សេង ៗ ជាប់តគ្នាមិនឲ្យមានសល់ឬមិនចាំបាច់និយាយហ្ន៎ ។ រមែងជាអទុក្ខមសុខវេទនា ដល់អ្នក

ពោលជាកណ្តាល ៗ ។

**អភិជ្ឈា** មានវេទនា ២ ដោយអំណាចនៃសុខវេទនា និង អទុក្ខមសុខវេទនា ។

**មិច្ឆាទិដ្ឋិ** ក៏យ៉ាងនោះ ។

**ព្យាបាទ** ជាទុក្ខវេទនា ។

បទថា **មូលតោ** , **បាណាតិបាត** មានមូល ២ ដោយ អំណាចនៃទោសៈ និងមោហៈ ។

**អទិន្នាទាន** មានមូល ២ ដោយអំណាចទោស និងមោហ ឬដោយអំណាចនៃលោភៈ និងមោហៈ ។

**មិច្ឆាចារ** មានមូល ២ ដោយអំណាចនៃលោភៈ និងមោហៈ ។

**មុសាវាទ** មានមូល ២ ដោយទោសៈ និងមោហៈ ឬ ដោយអំណាច នៃលោភៈ និងមោហៈ ។

**បិសុណាវាចា សម្ផប្បលាប** ក៏យ៉ាងនោះ ។

**ផរុសវាចា** ដោយអំណាចទោសៈ និងមោហៈ ។

**អភិជ្ឈា** មានមូល ១ ដោយអំណាចមោហៈ , **ព្យាបាទ** ក៏យ៉ាងនោះ ។



**មិច្ឆាទិដ្ឋិ** មានមូល ២ ដោយអំណាចនៃលោភៈ មិងមោហៈ ដោយប្រការដូច្នេះ ។

**( ចប់អកុសលកម្មបថកថា )**

ឈ្មោះថា **កុសលកម្មបថ** មាន ១០ យ៉ាងទាំងនេះ គឺ ការវៀរចាកបាណាតិបាតជាដើម និងអនភិជ្ឈា អព្យាបាទ សម្មា-ទិដ្ឋិ ។ ឈ្មោះថា **វិរតិ** ព្រោះអត្ថថា ជាហេតុវៀរចាកបាណា-តិបាតជាដើម , ឬការវៀរនោះឯង , ឬត្រឹមតែវៀរប៉ុណ្ណោះ ។ ការវៀរ សម្បយុត្តដោយកុសលចិត្តរបស់អ្នកវៀរចាកបាណាតិ-បាតជាដើម មាន ៣ យ៉ាង គឺ **សម្បត្តវិរតិ ១** , **សមាទានវិរតិ ១** , **សមុច្ឆេទវិរតិ ១** ។

ក្នុងវិរតិ ៣ យ៉ាងនោះ វិរតិកើតដល់អ្នកមិនបានសមា-ទានសិក្ខាបទ អ្នកពិចារណាដល់ជាតិ វ័យ ពាហុសច្ចៈជាដើម របស់ខ្លួនហើយ មិនឈានកន្លងក្នុងសម្បត្តវត្ថុ ដោយគិតថា ការធ្វើបាបបែបនេះ មិនសមគួរដល់យើងឡើយ ឈ្មោះថា **សម្បត្ត-វិរតិ** ។ វិរតិ កើតដល់អ្នកបានសមាទានសិក្ខាបទ ហ៊ានលះបង់សូម្បីជីវិតរបស់ខ្លួន ក្នុងការសមាទានសិក្ខាបទ និងក្រៃលែងជាងនោះ ហើយមិនឈានកន្លងវត្ថុ ឈ្មោះថា **សមាទានវិរតិ** ។ វិរតិ សម្បយុត្តដោយអរិយមគ្គ ឈ្មោះថា **សមុច្ឆេទវិរតិ** ។ សូម្បីចិត្ត មានជាអាទិ៍ថា យើងនឹងសម្លាប់សត្វជាដើម ក៏មិន



បានកើតដល់ព្រះអរិយបុគ្គល តាំងពីការកើតសមុច្ឆេទវិរតិ ។

ពេលនេះគប្បីជ្រាបវិនិច្ឆ័យកុសលកម្មបថទាំងនេះ ដោយអាការ ៥ យ៉ាង គឺ ដោយធម៌ ១ , ដោយកោដ្ឋាសៈ , ដោយអារម្មណ៍ ១ , ដោយវេទនា ១ , ដោយមូលហេតុ ។

ក្នុងបទទាំងនោះបទថា **ធម្មតោ** បានដល់ ចេតនា ៧ យ៉ាង សូម្បីវិរតិកម្មបថ ៣ ក្នុងទីបំផុត សម្បយុត្តដោយចេតនារមែងសមគួរតាមលំដាប់ក្នុងកុសលកម្មបថទាំងនោះ ។

បទថា **កោដ្ឋាសតោ** បានដល់ កម្មបថ ៧ យ៉ាងនោះឯងតាមលំដាប់ , មិនមែនជាមូលហេតុ ។

កុសលកម្មបថ ៣ ក្នុងទីបំផុត មានទាំងកម្មបថ និងទាំងមូលហេតុ ។ **អនភិជ្ឈា** អលោភៈ ជាកុសលមូល ព្រោះដល់ព្រមដោយមូល ។ **អព្យាបាទ** អទោសៈ ជាកុសលមូល , **សម្មាទិដ្ឋិ** គឺ អមោហៈ ជាកុសលមូល ។

បទថា **អារម្មណតោ** បានដល់ អារម្មណ៍របស់បាណា-តិបាតជាដើមនោះឯង ជាអារម្មណ៍របស់កម្មបថទាំងនោះ ។

ឈ្មោះថា **វេរមណី** ព្រោះគួរឈានកន្លងនោះឯង ។

**អរិយមគ្គ** មាននិព្វានជាអារម្មណ៍រមែងលះកិលេសទាំងឡាយ យ៉ាងណា , កម្មបថទាំងនោះ មានជីវិតិន្ទ្រិយជាដើម ជាអារម្មណ៍ ក៏ដូច្នោះ រមែងលះភាពជាអ្នកទ្រុស្តសីល មានបាណាតិបាតជាដើម ។

បទថា **វេទនាតោ** បានដល់ កុសលកម្មបថទាំងអស់ ជាសុខវេទនា ឬមជ្ឈត្តវេទនា ។ ពិតណាស់ កុសលកម្មបថ មិនមានទុក្ខវេទនា ព្រោះភាពជាកុសល ។

បទថា **មូលតោ** បានដល់ **កុសលកម្មបថ ៧** តាមលំដាប់ មានមូល ៣ ដោយអំណាចនៃអលោភៈ អទោសៈ អមោហៈ របស់អ្នកវៀរដោយចិត្តសម្បយុត្តដោយញាណ , មានមូល ២ ដោយអំណាចអលោភៈ អទោសៈ របស់អ្នកវៀរដោយចិត្តមិនប្រកបដោយញាណ , **អនភិជ្ឈា** មានមូល ២ ដោយអំណាចអទោសៈ និងអមោហៈ របស់អ្នកវៀរ ដោយចិត្តសម្បយុត្តដោយញាណ , មានមូល ១ ដោយអំណាចអទោសៈ របស់អ្នកវៀរ ដោយចិត្តមិនប្រកបដោយញាណ ។ ចំណែកអលោភៈ មិនជាមូលរបស់ខ្លួន ដោយខ្លួនឯង ។ សូម្បីក្នុង អព្យាបាទៈ ក៏មាន



ន័យដូចគ្នា ។ **សម្មាទិដ្ឋិ** មានមូល ២ ដោយអំណាចអលោភៈ អទោសៈនោះឯង ។

**( ចប់កុសលកម្មបថកថា )**

ព្រះសារីបុត្តកាលបានសម្តែងសីល ដោយអំណាចនៃកុសលកម្មបថ ១០ យ៉ាងនេះហើយ ពេលនេះដើម្បីសម្តែងធម៌ ៣៧ មាននេក្ខម្មៈជាដើម មានអរហត្តមគ្គជាបរិយោសាន ទើបពោលបទមានជាអាទិ៍ថា **នេក្ខម្មេន កាមច្ឆន្ទំ សំវរដ្ឋេន សីលំ , អវីតិក្កមដ្ឋេន សីលំ** ឈ្មោះថា សីល ដោយអត្ថថា សង្រួម និងមិនឈានកន្លងកាមច្ឆន្ទៈ ដោយនេក្ខម្មៈ ។ ក្នុងបទនោះ មានអធិប្បាយថា ព្រោះភិក្ខុសង្រួម មិនឈានកន្លងកាមច្ឆន្ទៈ ដោយនេក្ខម្មៈ , ដូច្នោះ **នេក្ខម្ម** ទើបជាសីល ។ មួយវិញទៀត អធិប្បាយថា **នេក្ខម្ម** ជាតតិយាវិភត្តិចុះក្នុងអត្ថបឋមាវិភត្តិ ។ ក្នុងបទដ៏សេសក៏មានន័យនេះ ។ តែក្នុងបាលី លោកសម្តែងនេក្ខម្មៈ និងអព្យាបាទៈ ហើយសង្ខេបបទដ៏សេស ព្រោះមានន័យដូចដែលបានពោលហើយ ទើបសម្តែងអរហត្តមគ្គប៉ុណ្ណោះ ទុកក្នុងទីបំផុត ។

ព្រះសារីបុត្ត លុះសម្តែងសីល ដោយអំណាចការសង្រួម និងការមិនឈានកន្លងយ៉ាងនេះហើយ ពេលនេះដើម្បីសម្តែងទាំងពីរយ៉ាងនោះ ទើបពោលបទមានជាអាទិ៍ថា **បញ្ច សីលានិ**



**បាណាតិបាតស្ស បហានំ សីលំ** សីល ៥ គឺ ការលះបាណាតិបាត ជាសីល ។ មួយវិញទៀត ក្នុងបទនេះ គប្បីប្រកបថា ការលះបាណាតិបាត ជាសីល , ការវៀរចាកបាណាតិបាត ជាសីល , ចេតនាជាបដិបក្ខដល់បាណាតិបាត ជាសីល , ការសង្រួមក្នុងបាណាតិបាតជាសីល ការមិនឈានកន្លងបាណាតិបាតជាសីល ។

បទថា **បហានំ** ការប្រហារ សេចក្តីថា ឈ្មោះថា ធម៌អ្វី ៗ វៀរចាកត្រឹមតែមិនឲ្យកើតបាណាតិបាតជាដើម ដូចពោលហើយរមែងមិនមាន , ព្រោះការប្រហារនោះ ៗ ឈ្មោះថា ជាការរ៉ាប់រង ដោយអត្ថថា ជាទីតាំងរបស់កុសលធម៌នោះ ៗ , និងឈ្មោះថា ជាទីរួបរួម ព្រោះមិនធ្វើឲ្យមានសភាពខ្វាត់ខ្វាយ , ដូច្នោះលោកទើបពោល **សីលំ** ព្រោះអត្ថថា ជាការបដិបត្តិ ពោលគឺ ជាទីរ៉ាប់រង និងជាទីរួបរួម ដូចពោលទុកហើយក្នុងខាងដើមនោះឯង ។ ធម៌ ៤ យ៉ាង ក្រៅពីនេះ លោកពោលសំដៅដល់សភាពដែលប្រព្រឹត្តទៅរបស់ចិត្ត ដោយអំណាចការវៀរចាកបាណាតិបាតនោះ ដោយការសង្រួមក្នុងបាណាតិបាតនោះ ដោយចេតនាសម្បយុត្ត ដោយការវៀរចាក និងការសង្រួមទាំងពីរនោះ និងដោយការមិន

ឈានកន្លងរបស់អ្នកមិនឈានកន្លងបាណាតិបាតនោះ ៗ ។

ម្យ៉ាងវិញទៀត សូម្បីការលះ ក៏នឹងមាននៅដោយធម្មតា នោះឯង ។ យ៉ាងដូចម្ដេច ? ឈ្មោះថា **បហានំ** ព្រោះរមែងលះបង់វត្ថុដែលជាបដិបក្ខដល់បាណាតិបាតជាដើម ដោយការវៀរ និងការសង្រួមនោះ , ឬរមែងលះបង់វត្ថុដែលជាបដិបក្ខនោះ ។

វត្ថុដែលជាបដិបក្ខនោះ គឺអ្វី ? កុសលធម៌ សូម្បីទាំងអស់ ។ តែអាចារ្យពួកដទៃពោលថា សូម្បីក្នុងនេក្ខម្មៈជាដើម ឈ្មោះថា **វិរតិ** ដូចគ្នា សេចក្ដីពិតក្នុងកុសលទាំងអស់ ព្រោះកាន់យកត្រឹមតែពាក្យថា **វេរមណី សីលំ** ការវៀរចាកជាសីល , ក្នុងទីនេះមិនមែនយ៉ាងនោះ ។ លោកពោលអបរិយន្តសីល ប៉ុណ្ណោះ ក្នុងសីលពីរយ៉ាង គឺ **បរិយន្តសីល** និង **អបរិយន្តសីល** ធ្វើឲ្យពិសេសដោយបទ ៥ បទ មានបហានៈជាដើម ។ ព្រោះដូច្នោះ ព្រះសារីបុត្តទើបពោលថា **ឯវរូបានិ សីលានិ ចិត្តស្ស អវិប្បដិសារាយ សំវត្តន្តិ ។បេ។ សច្ឆិកាតព្វំ សច្ឆិករោន្តោ សិក្ខតិ** សីលទាំងឡាយនេះ រមែងប្រព្រឹត្តទៅដើម្បីសេចក្ដីមិនក្ដៅក្រហាយនៃចិត្ត ។ល។ កាលបើធ្វើឲ្យជាក់ច្បាស់នូវធម៌ដែល



គួរធ្វើឲ្យជាក់ច្បាស់ ឈ្មោះថា រមែងសិក្សា ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា **អវិប្បដិសារាយ សំវត្តន្តិ** សេចក្ដីថា រមែងប្រព្រឹត្តទៅដោយល្អ ដើម្បីការមិនក្ដៅក្រហាយ ព្រោះព្រះបាលីថា ការសង្រួមដើម្បីសេចក្ដីមិនក្ដៅក្រហាយ និងថា ម្នាលអានន្ទ **សីល** មានការមិនក្ដៅក្រហាយជាប្រយោជន៍ មានការមិនក្ដៅប្រហាយជាអានិសង្ស ។

រមែងប្រព្រឹត្តទៅដើម្បីបាមោជ្ជៈ ព្រោះបាលីថា ការមិនក្ដៅក្រហាយ រមែងប្រព្រឹត្តទៅដើម្បីបាមោជ្ជៈ និងថាភាពបាមោជ្ជៈ រមែងកើតដល់អ្នកធ្វើទុកក្នុងចិត្តដោយប្រពៃ ។

រមែងប្រព្រឹត្តទៅដើម្បីបីតិ ព្រោះបាលីថា ភាពបាមោជ្ជៈ រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់បីតិ និងថាបីតិរមែងកើតដល់អ្នកមានបាមោជ្ជៈ ។

រមែងប្រព្រឹត្តទៅដើម្បីបស្សទ្ធិ ព្រោះបាលីថា បីតិរមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់បស្សទ្ធិ និងថាកាយរមែងស្ងប់ដល់អ្នកមានបីតិ ។

រមែងប្រព្រឹត្តទៅដើម្បីសោមនស្ស ព្រោះបាលីថា បស្សទ្ធិ

រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ដល់សេចក្តីសុខ និងថា កាយដែលស្ងប់រមែងសោយសេចក្តីសុខ ។ ព្រោះសេចក្តីសុខផ្សំចិត្ត លោកពោលថាជាសោមនស្ស ។

បទថា **អាសេវនាយ** ដើម្បីការសេពជាគ្រឿងឧបការៈ បានដល់ ការសេពដែលជាគ្រឿងឧបការៈយ៉ាងធ្ងន់ ។

សេពអ្វី ? សេចក្តីសុខពិត ព្រោះសេចក្តីសុខ លោកពោលដោយពាក្យថា សោមនស្សជាលំដាប់ ។

សមាធិ ជាសុខពិត ព្រោះបាលីថា ចិត្តរបស់អ្នកមានសេចក្តីសុខ រមែងតាំងមាំ ។ ការសេពសមាធិដែលពិត ដោយប្រការដូច្នេះ ។

សីលដែលពោលមកនេះ រមែងប្រព្រឹត្តទៅដើម្បីការសេពដោយឧបការៈដល់សមាធិនោះ , អធិប្បាយថា សីលទាំងឡាយរមែងប្រព្រឹត្តទៅដើម្បីភាពមានកម្លាំងខ្លាំងក្លា ។

បទថា **ភាវនាយ** ដើម្បីសេចក្តីចម្រើន បានដល់ ដើម្បីសេចក្តីចម្រើនរបស់សមាធិនោះ ៗ ឯង ។

បទថា **ពហុលីកម្មាយ** ដើម្បីធ្វើឲ្យច្រើន បានដល់ ដើម្បីធ្វើសមាធិនោះឲ្យកើតឡើងរឿយ ៗ ។



រមែងប្រព្រឹត្តទៅ ដើម្បីជាគ្រឿងប្រដាប់ ដោយឲ្យសម្រេចជាគ្រឿងប្រដាប់ មានសទ្ធិន្ទ្រិយ៍ជាដើម របស់សមាធិដែលជាមូលហេតុនៃសេចក្តីប្រព្រឹត្តទៅ មានការមិនក្តៅក្រហាយជាដើម ។

រមែងប្រព្រឹត្តទៅ ដើម្បីជាបរិក្ខារ ដោយឲ្យសម្រេចជាសម្ភារៈរបស់សមាធិ មានការមិនក្តៅក្រហាយជាដើម ។ បរិក្ខារស័ព្ទក្នុងបទនេះ មានសេចក្តីថា របស់ប្រើប្រាស ដូចក្នុងប្រយោគមានជាអាទិ៍ថា **យេ ច ខោ ឥមេ បព្វជិតេន ជីវិតបរិក្ខារា សមុទានេតព្វា** របស់ប្រើប្រាសសម្រាប់ជីវិតទាំងនេះ ដែលបព្វជិតគួរស្វែងរកទុក ។ មានសេចក្តីថា **គ្រឿងប្រដាប់** ដូចក្នុងប្រយោគមានជាអាទិ៍ថា **រថោ សីលបរិក្ខារោ , ឈានក្ខោ ចក្កវីរិយោ** រថ គឺ កាយ មានសីលជាគ្រឿងប្រដាប់ , ក្ងៅ គឺ ឈានមានសេចក្តីព្យាយាមជាចក្កៈ ។ មានអត្ថថា **បរិវារ** ដូចក្នុងបទមានជាអាទិ៍ថា **សត្តហិ នគរបរិក្ខារេហិ សុបរិក្ខតំ ហោតិ** នគរ ៧ រមែងជាបរិវារដល់នគរដែលបានរក្សាដោយល្អ ។ តែក្នុងទីនេះ លោកពោល **សម្ភារត្ថោ** នេះ សេចក្តីថា សម្ភារៈ ព្រោះ

អលង្ការ និងបរិវារផ្សេងគ្នា ។ ម្យ៉ាងទៀត អត្ថនៃសម្ភារៈ មាន សេចក្ដីថា បច្ច័យ ។ **សីល** រមែងប្រព្រឹត្តទៅដើម្បីជាបរិវារ ដោយឲ្យសម្រេចធម្មសម្បត្តិ មានផស្សៈ សម្បយុត្តដោយសមាធិ ជាដើម ដោយភាពជាមូលហេតុនោះឯង , រមែងប្រព្រឹត្តទៅដើម្បី ភាពបរិបូរណ៍ ព្រោះឲ្យសម្រេចភាពបរិបូរណ៍ ដោយធ្វើឲ្យដល់ ភាពជាបទដ្ឋាននៃសមាធិ និងវិបស្សនា និងធ្វើឲ្យដល់ភាពជាអ្នក ជំនាញ ។

ព្រះសារីបុត្ត លុះសម្ដែងសមាធិបរិបូរណ៍ ដោយអាការ ទាំងពួងដោយឧបនិស្ស័យនៃសីលយ៉ាងនោះហើយ ពេលនេះ កាលនឹងសម្ដែងយថា ភូតញ្ញាណទស្សនៈជាដើម ដែលជាបទ-ដ្ឋានរបស់សមាធិ មានសីលជាមូល ព្រោះបាលីថា **សមាហិតេ ចិត្តេ យថាភូតំ បជានាតិ , យថាភូតំ ជានំ បស្សំ និព្វិន្ទតិ , និព្វិន្ទំ វិរជ្ជតិ , វិរាគា វិមុច្ចតិ** ។ កាលបើចិត្តតាំងមាំ រមែងដឹងច្បាស់តាមសេចក្ដីពិត , កាលដឹងច្បាស់តាមសេចក្ដីពិត រមែងនឿយណាយ , កាលបើនឿយណាយ ក៏ប្រាសចាកតម្រេក , ព្រោះប្រាសចាកតម្រេក ចិត្តរមែងរួចផុត ដូច្នេះ ។ ទើបពោល



បទមានជាអាទិ៍ថា **ឯកន្តនិព្វិទាយ** ដើម្បីសេចក្ដីនឿយណាយ តែម្យ៉ាង ។ កាលបើសម្ដែងសេចក្ដីនឿយណាយហើយ ក៏ជាការ សម្ដែងយថាភូតញ្ញាណទស្សនៈ ដែលជាបទដ្ឋាននៃសេចក្ដីនឿយ-ណាយនោះឯង ។ កាលយថាភូតញ្ញាណទស្សនៈនោះ នៅមិន ទាន់សម្រេច ការនឿយណាយក៏នៅមិនទាន់សម្រេច ។ ក៏បទ ទាំងនោះ មានអត្ថដូចបានពោលទុកហើយនោះឯង ។ តែក្នុង ទីនេះ យថាភូតញ្ញាណទស្សនៈ កំណត់យកនាមរូបព្រមទាំងបច្ច័យ ។

ព្រះសារីបុត្តលុះសម្ដែងដល់ប្រយោជន៍របស់សីល ដែល មានអមតមហានិព្វានជាទីបំផុតយ៉ាងនេះហើយ ពេលនេះបំណង នឹងសម្ដែងសីលនោះ ជាអធិសីលសិក្ខា និងអធិចិត្តសិក្ខា អធិ-ប្បញ្ញាសិក្ខា ដែលមានអធិសីលសិក្ខាជាមូល ទើបពោលបទ មានជាអាទិ៍ថា **ឯវរូបានំ សីលានំ សំវរបរិសុទ្ធិ អធិសីលំ** សេចក្ដីបរិសុទ្ធិនៃការសង្រួមសីលយ៉ាងនេះឯង ជាអធិសីល ។

ក្នុងបទទាំងនោះ សេចក្ដីបរិសុទ្ធិ គឺ ការសង្រួមនោះឯង ឈ្មោះថា សំវរបារិសុទ្ធិ ការសង្រួមសីលអាស្រ័យវិវដ្ដៈ ដែល ជាសីលមិនមានទីបំផុតយ៉ាងនេះ លោកពោលថាជា **អធិសីល**

ព្រោះជាសីលដ៏ក្រៃលែងជាងសីលដ៏សេស ព្រោះអាស្រ័យវិវដ្ដៈ ។

បទថា **សំវរបារិសុទ្ធិយា ឋិតំ ចិត្តំ** ចិត្តតាំងនៅក្នុងសេចក្ដីបរិសុទ្ធិដោយការសង្រួម សេចក្ដីថា ចិត្តតាំងនៅដោយសេចក្ដីបរិសុទ្ធិ ដោយការសង្រួមក្នុងសីលដូច្នេះ រមែងមិនដល់នូវភាពរាយមាយ ព្រោះនាំការមិនក្ដៅក្រហាយជាដើមមកដោយល្អ , គឺ តាំងនៅក្នុងសមាធិ ។

សេចក្ដីបរិសុទ្ធិ គឺ ការមិនរាយមាយ ឈ្មោះថា **អវិក្ខេបបារិសុទ្ធិ** ។ សមាធិដែលជាចំណែកនៃការចាក់ធ្លុះ វៀរចាកមន្ទិលទាំងពួង លោកពោលថា **អធិចិត្តំ** ព្រោះជាសមាធិដ៏ក្រៃលែង ជាងសមាធិដ៏សេស ។ ក្នុងបទនេះ លោកចង្អុលបង្ហាញដល់ សមាធិដោយមាតិកាថា **ចិត្តំ** ។

បទថា **សំវរបារិសុទ្ធិំ សម្មា បស្សតិ** ព្រះយោគាវចររមែងឃើញសេចក្ដីបរិសុទ្ធិ ដោយការសង្រួមដោយប្រពៃ សេចក្ដីថា រមែងឃើញសេចក្ដីបរិសុទ្ធិ គឺ ការសង្រួមក្នុងសីលដោយប្រពៃ ដោយអំណាចនៃញាតបរិញ្ញា តីរណបរិញ្ញា , រមែងឃើញសមាធិដ៏បរិសុទ្ធិ ពោលគឺ សេចក្ដីបរិសុទ្ធិ គឺ សភាពដែល



ចិត្តមិនរាយមាយយ៉ាងនោះឯង ដោយល្អ ។ កាលបើព្រះយោគាវចរឃើញយ៉ាងនោះ សេចក្ដីបរិសុទ្ធិ ពោលគឺ ការឃើញ ឈ្មោះថា **ទស្សនបារិសុទ្ធិ** សេចក្ដីបរិសុទ្ធិនៃទស្សនៈ ។

**ទស្សនបារិសុទ្ធិ** នោះឯង លោកពោលថាជា អធិប្បញ្ញា ព្រោះក្រៃលែងជាងបញ្ញាដ៏សេស ។

បទថា **យោ តត្ថ** គឺ ក្នុងការសង្រួម ការមិនរាយមាយ និងទស្សនៈនោះ ។ បទថា **សំវរដ្ឋោ** គឺ សេចក្ដីសង្រួម ។

គប្បីជ្រាប ការមិនរាយមាយ និងការឃើញ ក៏យ៉ាងនោះដូចគ្នា ។ **សិក្ខា** គឺ អធិសីលនោះឯង ឈ្មោះថា **អធិសីលសិក្ខា** ។ សូម្បីក្រៅពីនោះ ក៏គប្បីជ្រាបយ៉ាងនេះ ។

ព្រះសារីបុត្ត លុះសម្ដែងសិក្ខា ៣ យ៉ាងនេះហើយ ពេលនេះ ដើម្បីនឹងសម្ដែងដល់លំដាប់របស់សិក្ខាទាំងនោះឲ្យបរិបូរណ៍ ទើបពោលបទមានជាអាទិ៍ថា **ឥមា តិស្សោ សិក្ខាយោ អាវជ្ជេន្តោ សិក្ខតិ** ព្រះយោគាវចរកាលនឹកដល់សិក្ខា ៣ ទាំងនេះ ឈ្មោះថា រមែងសិក្សា ។ បទនោះ មានអធិប្បាយដូចតទៅនេះ ព្រះយោគាវចរ សូម្បីកាលនឹកដល់ដើម្បីញុំាងសិក្ខាមួយ ៗ ឲ្យ

បរិបូរណ៍ ក៏ឈ្មោះថា រមែងសិក្សា , លុះនឹកដល់ហើយ សូម្បីដឹងថាសិក្ខាឈ្មោះយ៉ាងនេះ ក៏ឈ្មោះថា រមែងសិក្សា , លុះដឹងហើយ សូម្បីឃើញញយ ៗ ក៏ឈ្មោះថា រមែងសិក្សា , លុះឃើញហើយ សូម្បីពិចារណាតាមដែលបានឃើញ ក៏ឈ្មោះថា រមែងសិក្សា , គ្រាពិចារណាហើយ ធ្វើទុកឲ្យតាំងមាំ ធ្វើចិត្តមិនឲ្យញាប់ញ័រក្នុងសិក្ខានោះ ក៏ឈ្មោះថា រមែងសិក្សា , សូម្បីធ្វើកិច្ចរបស់ខ្លួនដោយសទ្ធា វីរិយៈ សតិ សមាធិ និងបញ្ញា ដែលសម្បយុត្តដោយសិក្ខានោះ ៗ ក៏ឈ្មោះថា រមែងសិក្សា , កាលធ្វើកិច្ចនោះ ៗ សូម្បីក្នុងកាលមានសេចក្ដីដឹងដ៏ក្រៃលែងក្នុងវត្ថុដែលគួរដឹងដ៏ក្រៃលែងជាដើម ក៏ឈ្មោះថា រមែងសិក្សាសិក្ខាសូម្បី ៣ យ៉ាង ។

បទថា **បញ្ច សីលានិ** ជាដើម ម្ដងទៀតមានសេចក្ដីដូចបានពោលហើយនោះឯង ។ម្យ៉ាងវិញទៀត គប្បីជ្រាបសេចក្ដីក្នុងបទមានជាអាទិ៍ថា **អរហត្តមគ្គេន សព្វកិលេសានំ** ដូចតទៅនេះ បទទាំងនោះត្រឹមត្រូវហើយ ព្រោះមិនមានការក្ដៅក្រហាយជាដើម និងព្រោះមានការសេពដែលជាឧបការៈជាដើមដោយល្អ របស់



ព្រះអរហន្តទាំងឡាយ ។

គប្បីប្រកបបទមានជាអាទិ៍ថា **ឯកត្តនិព្វិទានាយ** ដើម្បីសេចក្ដីនឿយណាយតែម្យ៉ាង ក្នុងខណៈនៃមគ្គ ដូចសតិប្បដ្ឋាន និងសម្មប្បធាន ។

គប្បីប្រកបបទទាំងពីរនេះថា **សំវរបារិសុទ្ធី សម្មា បស្សតិ** , **អវិក្ខេបបារិសុទ្ធី សម្មា បស្សតិ** ព្រះយោគាវចររមែងឃើញភាពបរិសុទ្ធិដោយសំវរៈដោយល្អ ជាសីល , រមែងឃើញភាពបរិសុទ្ធិដោយចិត្តមិនរាយមាយដោយល្អ ជាសីល ដោយអំណាចវិបស្សនា ដើម្បីប្រយោជន៍ដល់ផលសមាបត្តិ ។ ពាក្យទីពីររមែងត្រឹមត្រូវ សូម្បីដោយអំណាចនៃវិបស្សនាដើម្បីប្រយោជន៍ដល់និរោធសមាបត្តិ ។ ក្នុងពាក្យទាំង ៥ មានជាអាទិ៍ថា **អាវជ្ជន្តោ សិក្ខតិ** គប្បីជ្រាបថា លោកពោលថា **សិក្ខតិ** ព្រោះមានព្រះអសេក្ខៈជាដើម សូម្បីក្នុងការមិនមានវត្ថុដែលត្រូវសិក្សារបស់ព្រះអរហន្ត ។

បទមានជាអាទិ៍ថា **សទ្ធាយ អធិមុច្ចន្តោ សិក្ខតិ** ព្រះយោគាវចរបង្អោនទៅដោយសទ្ធា ក៏ឈ្មោះថា រមែងសិក្សា លោកពោល

សំដៅដល់ខណៈនៃមគ្គនោះឯង ។ គប្បីប្រកបពាក្យសូម្បីដទៃ ដែលលោកពោលដោយអំណាចនៃឧបចារៈ អប្បនា វិបស្សនា និងមគ្គ តាមសមគួរ ។

( ចប់អដ្ឋកថា សីលមយញ្ញាណនិទ្ទេស )



# ប្រជុំកងធម៌
## ក្នុងគម្ពីរអដ្ឋកថាបដិសម្ភិទាមគ្គ


| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| ឋានៈ ( នៃភូមិ ) | ២ | ២២ |
| ញាណកថា | ២ | ៣៦ |
| ពលៈ ( កម្លាំង ) | ២ | ១៣១ |
| ការធ្វើឱ្យច្បាស់ | ២ | ២០៨ |
| ធាតុ | ២ | ២២៦ |
| ចក្ខុ | ២ | ២៥៨ |
| មំសចក្ខុ | ២ | ២៥៩ |
| វិមុត្តិ | ២ | ៤៤៨ |
| ជរា | ២ | ៤៩៥ |
| ឈាន | ២ | ៥៩០ |
| សម្ផប្បលាបៈ | ២ | ៧០៧ |
| អភិជ្ឈា | ២ | ៧០៨ |
| ព្យាបាទៈ | ២ | ៧០៩ |
| មិច្ឆាទិដ្ឋិ | ២ | ៧១០ |
| បិដក | ៣ | ២៩ |
| បដិសម្ភិទា មានវគ្គ | ៣ | ៣០ |
| បរិញ្ញា | ៣ | ១០៨ |
| សង្ខារ | ៣ | ១៣២ |
| បុគ្គល មានហើយ | ៣ | ១៣៨ |

| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| វិជ្ជា | ៣ | ១៦៧ , ៤៤៨ |
| ឥន្ទ្រិយ ( លោកុត្តរ ) | ៣ | ១៨១ |
| ធាតុ | ៣ | ២២៧ |
| កុសលធាតុ | ៣ | ២២៨ |
| ធាតុ ( ដទៃទៀត ) | ៣ | ២២៨ |
| ធាតុ ( ដទៃទៀត ) | ៣ | ២២៨ |
| អរូបាវចរ មាន | ៣ | ៤៤៣ |
| ឈានវិនាសដោយហេតុ | ៣ | ៤៦១ |
| ផរុសវាចា មានអង្គ | ៣ | ៧០៧ |
| វិរតិ | ៣ | ៧១៦ |
| បដិសម្ភិទា | ៤ | ១១ |
| ប្រភេទនៃញាណ | ៤ | ១៣ |
| អង្គសម្រេចសោតាបន្ន | ៤ | ៣៥ |
| សំវរៈ | ៤ | ៤៧ |
| ធម៌ | ៤ | ៥៥ |
| សព្វអជ្ឈត្តៈ មានអត្ថ | ៤ | ១០៣ |
| ការសង្គ្រោះ មាន | ៤ | ១៥១ |
| អាហារ | ៤ | ២១៩ |
| ទេសនា | ៤ | ២២៤ |
| អរិយសច្ចៈ | ៤ | ២៣០ |
| ឧបាទាន | ៤ | ៣៧៥ |
| ឱឃៈ | ៤ | ៣៩២ |





| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| ការសម្រេចចិត្ត | ៤ | ៣៩៨ |
| សាមញ្ញផល | ៤ | ៤៤៩ |
| ញាណក្នុងសច្ចៈ មាន | ៤ | ៥៣៦ |
| សម្មប្បធាន | ៤ | ៥៤៥ |
| ឧប្បន្នៈ គឺ ធម៌ដែលកើត | ៤ | ៥៥២ |
| សតិប្បដ្ឋាន | ៤ | ៥៧៥ |
| សច្ចៈ ( សច្ចបកិណ្ណកៈ ) | ៤ | ៦២៨ |
| មិច្ឆាចារ មានអង្គ | ៤ | ៧០២ |
| មុសាវាទ មានអង្គ | ៤ | ៧០៣ |
| បិសុណាវាចា មានអង្គ | ៤ | ៧០៥ |
| ធម៌ ( ដែលកើតពីបច្ច័យ ) | ៥ | ១៤ |
| ធម៌ ( ជាហេតុឱ្យកើតផល ) | ៥ | ១៥ |
| បដិសម្ភិទា ដែលផ្ទូរផង់ដោយហេតុ | ៥ | ២២ |
| ញេយ្យៈ | ៥ | ១៩៨ |
| សព្វញ្ញូ មាន | ៥ | ១៩៩ |
| ពាក្យសួរ មាន | ៥ | ២០៤ |
| វិមុត្តាយតនៈ | ៥ | ២៣១ |
| បញ្ចចក្ខុ | ៥ | ២៥៨ |
| ខន្ធ | ៥ | ២៦៦ |
| វិវេក | ៥ | ៣៤៤ |
| នីវរណៈ | ៥ | ៣៩២ |
| សមាធិ មានអង្គ | ៥ | ៤១៧ |

| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| ធម្មក្ខន្ធ | ៥ | ៤៤៩ |
| បីតិ | ៥ | ៥៨៦ |
| មហាបរិច្ចាគ | ៥ | ៦៥៥ |
| ពាក្យថា អរហំ | ៥ | ៦៧៦ |
| ការសង្រួម មាន | ៥ | ៦៩៣ |
| បាណាតិបាត មានអង្គ | ៥ | ៦៩៩ |
| អទិន្នាទាន មានអង្គ | ៥ | ៧០០ |
| អនុត្តរិយៈ | ៦ | ២៣៦ |
| ធាតុ | ៦ | ២៦៨ |
| អាយតនៈ | ៦ | ៣៧៥ |
| ពួកតណ្ហា | ៦ | ៣៩៤ |
| អភិញ្ញា | ៦ | ៤៥១ |
| និទ្ទសវត្ថុ | ៧ | ២៤៥ |
| វិញ្ញាណដ្ឋិតិ | ៧ | ៣៧៥ |
| អនុស័យ | ៧ | ៣៩៥ |
| កម្លាំងរបស់ព្រះខីណាស្រព | ៧ | ៤៥១ |
| ធមិជាបច្ច័យដល់បដិសម្ភិទា | ៨ | ២៥ |
| អង្គ ( មគ្គ ) | ៨ | ៣២ |
| អភិភាយតនៈ | ៨ | ២៤៧ |
| លោកធមិ | ៨ | ៣៨៣ |
| សេចក្តីខុស | ៨ | ៣៩៥ |
| វិមោក្ខ | ៨ | ៤៥៤ |





| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| អង្គនៃសត្ថុសាសន៍ | ៩ | ៣០ |
| សមាធិចរិយា | ៩ | ១៣២ |
| អនុបុព្វវិហារធមិ | ៩ | ២៥១ |
| សត្តាវាស | ៩ | ៣៨៤ |
| តណ្ហា មានមូល | ៩ | ៣៩៧ |
| បរិសុទ្ធិ | ៩ | ៤២១ |
| វិបស្សនាញាណ | ៩ | ៤២៤ |
| អនុបុព្វនិរោធ | ៩ | ៤៥៥ |
| និជ្ជរវត្ថុ | ១០ | ២៥៣ |
| កសិណ | ១០ | ២៦៩ |
| វិបស្សនូបកិលេស | ១០ | ៤២៣ |
| បដិឃសញ្ញា | ១០ | ៤៤០ |
| កិលេស | ១០ | ៤៤៣ |
| អសេក្ខធមិ | ១០ | ៤៥៦ |
| ឧបេក្ខា | ១០ | ៦០៤ |
| កុសលកម្មបថ | ១០ | ៧១១ |
| ធម្មារម្មណ៍ មាន | ១២ | ២៦៥ |
| សីរសៈ មាន | ១៣ | ១៣៩ |
| បច្ចវេក្ខណញ្ញាណ | ១៩ | ១៤០ |
| ស្ត្រី ( អគមនីយដ្ឋាន ) | ២០ | ៧០១ |
| ឥន្ទ្រិយ | ២២ | ២៨៥ |
| និព្វាន មានឈ្មោះ | ២៦ | ៥២២ |

| ឈ្មោះធម៌ | ពួក | ទំព័រ |
|---|---|---|
| បារមី | ៣០ | ៦៥៥ |
| អាការ | ៣២ | ២៧០ |
| ធម៌ ( មាននេក្ខម្មៈជាដើម ) | ៣៧ | ១៣៦ |
| មាតិកា ពោលដោយបញ្ញាញាណ | ៧៣ | ១ |




## នាមសប្បុរស បូជាធម្មទាន


| | |
|---|---|
| ឧបាសិកា ពូ ហ៊ាង ........................................... | 80 $ U.S.A |
| ឧបាសក ជា ស៊ីបាន ........................................ | 50 $ U.S.A |
| ឧបាសក ហម សារ៉េន ប្រធានអាស្រមទួលត្នោតជុំ .. | 50 $ U.S.A |
| ឧបាសិកា ម៉ម សុខហេង .................................. | 30 $ U.S.A |
| ឧបាសិកា ថាប់ លឿម .................................. | 20 $ U.S.A |
| ឧបាសក ថន វ៉ាសនា ប្រធានកម្មវិធីកល្យាណមិត្ត .... | ៣០០.០០០ ៛ |
| ឧបាសក សោម រតនៈ និងភរិយា ព្រមទាំងបុត្ត ....... | ១០០.០០០ ៛ |
| លោក ហម ស៊ុនទៀង និងភរិយា ព្រមទាំងបុត្ត ....... | ៥០.០០០ ៛ |
| ឧបាសិកា ប៊ុត សុម៉ាលី និងបុត្រី.......................... | ១០ ដុល្លា |
| ឧបាសិកា ថាប់ ឡឹង ....................................... | ៥ ដុល្លា |
| ឧបាសិកា យស់ សម្បត្តិ .................................. | ៥ ដុល្លា |
| ឧបាសក គុយ សុធន់ ឧបាសិកា ខាត់ កាន និងបុត្រ . | ៣០.០០០ ៛ |
| ឧបាសិកា ម៉ែន ថាប់ ...................................... | ២០.០០០ ៛ |
| ឧបាសិកា ប៊ុត សេដាដួង ................................. | ១៥.០០០ ៛ |
| ឧបាសិកា យិន យឹម ...................................... | ១៥.០០០ ៛ |
| ឧបាសិកា ........................................ | ១០.០០០ ៛ |
| ឧបាសិកា គង់ សាន់........................................ | ១០.០០០ ៛ |
| ឧបាសិកា គុយ សេងណា .............................. | ១០.០០០ ៛ |
| កញ្ញា ហ៊ិច ហៀក ....................................... | ១០.០០០ ៛ |
| ឧបាសក តាំង ផល ភរិយានិងបុត្រ .................. | ១០.០០០ ៛ |
| លោកយាយ ឈួម .......................... | ៦.០០០ ៛ |
| ឧបាសិកា គួច សាវុន .......................... | ៥.០០០ ៛ |
| ឧបាសិកា រុន សោភ័ណ .......................... | ៥.០០០ ៛ |
| ឧបាសិកា យិន យឹន .......................... | ៥.០០០ ៛ |

ឧបាសិកា គី ពេញ .................. ៥.000 ៛
ឧបាសិកា ភួង លីណា .................. ៥.000 ៛
លោកយាយ យុន .................. ៥.000 ៛
លោកយាយ វ៉ាន .................. ៥.000 ៛
លោកយាយ ស៊ុំ ហេង .................. ៥.000 ៛
ភិក្ខុ សូ ឈិន ................................ ៥.000 ៛
ឧបាសិកា ខុន ................................ ៥.000 ៛
ឧបាសិកា ឡៃ ................................ ៥.000 ៛
ឧបាសិកា សត់ ................................ ៥.000 ៛
ឧបាសិកា សោម យ៉ាន ........................ ៥.000 ៛
លោកយាយ យូន ............................... ៣.000 ៛
លោកយាយ ទុំ ................................ ២.000 ៛

**ភិក្ខុចិត្តរក្ខិត្តោ សំ សម្បត្តិ និងពុទ្ធបរិស័ទនៅប្រទេសអូស្ត្រាលី**

លោក រស់ ធារុន កូនស្រី ជេស មិន .................... 100 $ AUS
ឧបាសិកា ស សាន .......................................... 100 $ AUS
ឧបាសិកា តាំង ពូជី ឧបាសិកា សៀក លី .............. 100 $ AUS
ឧបាសក បុត ឡៅគឹមងួន , ឧបាសិកា ដួង លី ........ 100 $ AUS
ឧបាសក ឪ មុយ ឧបាសិកា តៃ ចាន់ណារ៉ា ហៅ ឌឹង.. 100 $ AUS
ឧបាសិកា ទៀន ស៊ីហ៊ុន .................................... 100 $ AUS
ឧបាសក ទា អៃតិច ឧបាសិកា ឡៅសៃងម .......... 100 $ AUS
ឧបាសក ភិន ហាច ឧបាសិកា ពេជ្រ សឿម .......... 100 $ AUS
ឧបាសិកា គិមស៊ីន ឧបាសិកា សំ ថានី ................ 100 $ AUS
ឧបាសិកា ស៊ឹម គឹមហេង .................................... 0 $ AUS
ឧបាសិកា ស៊ូ ឃីម ស៊ូ សៀងតិច .......................... 50 $ AUS



ឧបាសក ថាំ ហ៊ូ ............................................... 50 $ AUS
ឧបាសក យ៉ង សិន ឧបាសិកា នន់ ហេង ............... 50 $ AUS
ឧបាសិកា សេង សៀងឈុន និងបុត្ត ..................... 50 $ AUS
ឧបាសិកា វ៉ាន់ យ៉ាណូរី និងបុត្ត ........................... 50 $ AUS
ឧបាសិកាប៉ាង សុម .......................................... 50 $ AUS
ឧបាសក ស៊ុន សាន ឧបាសិកា សម្បត្តិ គង់ .......... 50 $ AUS
ឧបាសិកា ស៊ឹម គឹមហេង និងកូនចៅ ................. 50 $ AUS
យុង គិមសាន យុង ម៉ាលី ............................... 50 $ AUS
ឧបាសិកា ចំរើន រ៉ាក់ជិត ................................. 50 $ AUS
ឧបាសិកា ផន ដារ៉ា លោកស្រី គ្រី ប្រសើរ លោកស្រី លី ធីមដៃ និងកូនស្រី .
..................................................................... 50 $ AUS
ឧបាសក គង់ ហ៊ាល ឧបាសិកា គង់ ជា ................. 50 $ AUS
លោក ស្រ៊ុន ហេង លោក តឹក ចាន់ដារ៉ា លោកស្រី រូថា សេង 40 $ AUS
ឧបាសិកា ផៅក វណ្ណា .................................... 40 $ AUS
ឧបាសក ហៀក ម៉េងហួរ ឧបាសិកា ផ្លោក ម៉ុង .... 40 $ AUS
ឧបាសក ណាំង លាងហុង ឧបាសិកា អង្គជុំ សុវណ្ណារ៉េត 30 $ AUS
ឧបាសក សុខ យូ ឧបាសិកា សុខ ណារី ............... 30 $ AUS
ឧបាសិកា លីវ ទូច ......................................... 30 $ AUS
លោកយាយ ញឹប .......................................... 30 $ AUS
ចឿក ផន .................................................... 30 $ AUS
តៃ យក់ហ៊ុន ............................................... 30 $ AUS
ឧបាសិកា ជួន រ៉េន .......................................... 30 $ AUS
ឧបាសក តូ សារ៉ឿន ឧបាសក មាន សុវត្ថិ ............. 30 $ AUS
ឧបាសក រស់ សារ៉េន ឧបាសិកា គង់ សារឿន ....... 30 $ AUS
ឧបាសក ឡុង ហួន និងគ្រួសារ .......................... 30 $ AUS

| | |
|---|---|
| ឧបាសិកា វ៉ាន់ យ៉ាណ្ណូរ៉េត និងបុត្ត ...................... | 30 $ AUS |
| ឧបាសក ធម្មសារី សេក ឈុន ........................... | 20 $ AUS |
| ឧបាសក ពុធ ប៉េងណេង ឧបាសិកា ហ៊ុន ស៊ីវអៀង និងកូនចៅ | 20 $ AUS |
| ឧបាសិកា លឹម យ៉ាណ្ណូវ៉ាន់ និងបុត្ត ...................... | 20 $ AUS |
| ឧបាសក នួន សុឆេង ........................................ | 20 $ AUS |
| ឧបាសក ហួត វ៉ា ហែម ឃឿន ........................... | 20 $ AUS |
| ឧបាសក សំហៃឡេង ឧបាសិកា ស៊ុត ផល្លីន ........... | 20 $ AUS |
| ឧបាសិកា នួន គុង ............................................ | 20 $ AUS |
| ឧបាសិកា ដា្វ ចេង ............................................ | 20 $ AUS |
| ឧបាសិកាយ៉ា យ៉ុម និងស្វាមី ............................. | 20 $ AUS |
| ឧបាសិកា សាត់ ឡាយ ...................................... | 20 $ AUS |
| ឧបាសិកា ម៉េង សំបូរ ....................................... | 20 $ AUS |
| ឧបាសិកា សៅ សុឃឿន .................................... | 20 $ AUS |
| ឧបាសិកា ស៊ឹង គិមព្រូ , ទូច ស៊ីថា និងបុត្ត ............ | 20 $ AUS |
| ឧបាសិកា កាំង ជូ .......................................... | 20 $ AUS |
| ឧបាសិកា ហឿ  សិទ្ធ , គិត យ៉ុំ ........................ | 20 $ AUS |
| ឧបាសិកា ជីវ អេង ........................................ | 20 $ AUS |
| ឧបាសិកា មុយ ហួរម៉ា ..................................... | 20 $ AUS |
| ឧបាសិកា មាឃ សូផាន ................................... | 20 $ AUS |
| ឧបាសិកា លឹម យូឃាង និងគ្រួសារ .................... | 20 $ AUS |
| ឧបាសក សុខ ជួន ឧបាសិកា មាស ឃឿន ............ | 20 $ AUS |
| ឧបាសិកា ឡាយ លាង ..................................... | 20 $ AUS |
| ឧបាសិកា អៀ ភិចណៃ .................................... | 20 $ AUS |
| ឧបាសក RAKHA LEAS ................................ | 10 $ AUS |
| ប៉ាន់ យ៉ា , វិលាម ភិត , វី ជាឡេង .................... | 10 $ AUS |



| | |
|---|---|
| គុយ ថ ........................................................ | 10 $ AUS |
| សៅ លីម ..................................................... | 10 $ AUS |
| ឧបាសិកា អឹប គឹមឡាយ ................................. | 10 $ AUS |
| ឧបាសក ទូត ភាង ឧបាសិកា ចៅ ចន្ថា ............... | 5 $ AUS |
| ចៅ សារិ ..................................................... | 5 $ AUS |

### ពុទ្ធបរិស័ទអូស្ត្រាលី តាមរយៈ ព្រះអគ្គទិន្ននោ ភិក្ខុ នៅ បូរ៉ា

| | |
|---|---|
| លោក ជុង ឡេង និងអ្នកស្រី .......................... | 100 $ AUS |
| ឧបាសក សេង លី ឧបាសិកា ចាន់ ផល្លា ............ | 100 $ AUS |
| ឧបាសក នូ សុវ៉ារុធ និងភរិយា ......................... | 50 $ AUS |
| ឧបាសក រិន គ្រេត និងភរិយា ......................... | 50 $ AUS |
| ឧបាសក លឹម ហុងលី ឧបាសិកា តេង គី ........... | 50 $ AUS |
| ឧបាសក ង៉ូវ ឈីវ ឧបាសិកា ហេង ពាស៊ីម និងបុត្ត ៤ នាក់ | 50 $ AUS |
| ឧបាសក ទូត សឿប ឧបាសិកា សល់ កែវ........... | 50 $ AUS |
| ឧបាសក សឹម តាជួន .................................... | 20 $ AUS |
| ឧបាសក ជួន យ៉ារ៉ែន ឧបាសិកា អ៊ិន ផល្លី ............ | 20 $ AUS |
| ឧបាសក ភុន ញ៉ាន ....................................... | 20 $ AUS |
| លោក SO KON និងអ្នកស្រី HUn ................ | 20 $ AUS |
| ឧបាសក ហ៊ាង ម៉ុន ...................................... | 20 $ AUS |
| លោក RRUN SRANN និងអ្នកស្រី RANY KAO | 20 $ AUS |
| លោក PHEAP KAO ............................... | 10 $ AUS |
| លោក SOU SOPHON ............................ | 10 $ AUS |
| លោក THEAR ROS ............................... | 10 $ AUS |
| ឧបាសក ប៉ុន ដេត ឧបាសិកា ម៉ាច និងបុត្ត ........ | 10 $ AUS |
| លោក SOKEN និងអ្នកស្រី SEYLA ........... | 10 $ AUS |

| | |
|---|---|
| ឧបាសក ផៃ មន្ទីកៅ .................................. | 10 $ AUS |
| ឧបាសក ពៅ វ៉ាន់ទីន .................................. | 10 $ AUS |
| លោក Chouy Sannykao .......................... | 10 $ AUS |
| ឧបាសក ស៊ុន គិមឆេង .................................. | 10 $ AUS |
| លោក KIM YEE ...................................... | 5 $ AUS |
| ឧបាសក ឆាយ ឈួយលិម ហៅ មិត ឆិម .......... | 5 $ AUS |

**ពុទ្ធបរិស័ទវត្តត្រៃរតនារាម សហរដ្ឋអាមេរិក**

**តាមរយៈ ព្រះភិក្ខុ ធម្មត្ថេរោ សៅ ឃួន**

**ព្រះភិក្ខុធម្មប្បញ្ញោ វ៉ាន វឿន**

| | |
|---|---|
| ព្រះភិក្ខុ ធម្មត្ថេរោ សៅ ឃួន .............................. | 300 $ U.S.A |
| ព្រះភិក្ខុ កិត្តិកធម្មោ ប៊ូ សាំយ៉ុន ............................ | 50 $ U.S.A |
| ឧបាសិកា ទូន សឿយ ........................................ | 50 $ U.S.A |
| ឧបាសិកា ឈួន ផៃ ........................................... | 30 $ U.S.A |
| ឧបាសិកា ប្រាក់ យឿត ...................................... | 30 $ U.S.A |
| ឧបាសិកា អុក ណៃ ........................................... | 30 $ U.S.A |
| ឧបាសក អួន មិត្ត ឧបាសិកា នាក់ ប្រិម .................. | 25 $ U.S.A |
| ឧបាសិកា ចាប ឡាន ......................................... | 25 $ U.S.A |
| ឧបាសក សាន សុទ្ធ ឧបាសិកា យស់ សារី ................ | 20 $ U.S.A |
| លោកអាចារ្យ កង កាក់ ឧបាសិកា ទឹម សារី ............ | 20 $ U.S.A |
| ឧបាសិកា សរ គឹម ............................................ | 20 $ U.S.A |
| ឧបាសក លឹម សេងហ៊ួ ........................................ | 20 $ U.S.A |
| ឧបាសិកា កែវ ស៊ីណាត ...................................... | 20 $ U.S.A |
| ឧបាសក គាំ សាមុត ........................................... | 20 $ U.S.A |
| វ៉ា ស៊ីម៉ន ........................................................ | 20 $ U.S.A |



| | |
|---|---|
| អេម អែម និង អ៊ែល អ៊ុន .................................. | 20 $ U.S.A |
| ឧបាសក ឃុន ខេន .......................................... | 20 $ U.S.A |
| ឧបាសក ម៉ៅ សារី ឧបាសិកា ឯក ផេន និងបុត្ត ...... | 20 $ U.S.A |
| ឧបាសិកា អ៊ុំ សឿន ឧបាសិកា សែម អ៊ុំ ................ | 20 $ U.S.A |
| ផូ លាង និង សុខ ខេន ...................................... | 20 $ U.S.A |
| នាង ឡាយ សុវណ្ណ .......................................... | 20 $ U.S.A |
| ឃុត នីកង ...................................................... | 20 $ U.S.A |
| ទឹម សុជាតិ .................................................... | 20 $ U.S.A |
| ឧបាសិកា ជួប ប៉ាក់ .......................................... | 15 $ U.S.A |
| ជាស់ ស្ទីន ..................................................... | 10 $ U.S.A |
| អ៊ិស ស្ទីន ...................................................... | 10 $ U.S.A |
| សារុន ម៉ន ..................................................... | 10 $ U.S.A |
| មឿង ម៉ៅ ....................................................... | 10 $ U.S.A |
| មាន ណាត ..................................................... | 10 $ U.S.A |
| គិម លាងជា ................................................... | 10 $ U.S.A |
| វី យ៉ាត ......................................................... | 10 $ U.S.A |
| ឧបាសិកា ចិន ឈួន ......................................... | 10 $ U.S.A |
| គង់ថៃ ប៊ុនរឿង ............................................. | 10 $ U.S.A |
| ឧបាសិកា ឡឹក រេត ......................................... | 10 $ U.S.A |
| ព្រហ្ម សារិន .................................................. | 10 $ U.S.A |
| ព្រហ្ម វ៉ារុធ ................................................... | 10 $ U.S.A |
| វ៉ារិត អួន ...................................................... | 10 $ U.S.A |
| ឪកូឡូ ជីវ៉ូខាយ .............................................. | 10 $ U.S.A |
| អាន ណាង ............................................ | 10 $ U.S.A |
| សយស ាម៉ុន និងបុត្ត ....................................... | 10 $ U.S.A |

| | |
|---|---|
| ចិន្តា អឿវ និង ចក់ ណាហួត .............................. | 10 $ U.S.A |
| សែង ឈីម និង ហួត ចាន់នួន ............................ | 10 $ U.S.A |
| ហួត ចាន់ណាត និង ឈឿង សុភាព .................... | 10 $ U.S.A |
| វ៉ន ឡៃ ........................................................ | 10 $ U.S.A |
| ទឹម ស៊ីនួន ...................................................... | 10 $ U.S.A |
| ឈី ជិម ...................................................... | 10 $ U.S.A |
| ឡេង ដា ...................................................... | 10 $ U.S.A |
| ឌី ណាញឹប ...................................................... | 10 $ U.S.A |
| ញឹប ហុង ...................................................... | 10 $ U.S.A |
| នី សាញឹប ...................................................... | 10 $ U.S.A |
| ឧបាសិកា ញឹប ទាង .......................................... | 10 $ U.S.A |
| ឧបាសិកា អឹម លឹម .......................................... | 10 $ U.S.A |
| ឧបាសិកា ខាត់ សំអឿន .................................... | 10 $ U.S.A |
| ម៉ៅ ចំបើង .................................................... | 10 $ U.S.A |
| ម៉ៅ វ៉ាត .................................................... | 10 $ U.S.A |
| ម៉ៅ កំសត់ .................................................... | 10 $ U.S.A |
| ម៉ៅ កំសាន្ត .................................................... | 10 $ U.S.A |
| ម៉ៅ សុខា .................................................... | 10 $ U.S.A |
| ម៉ៅ គឹមសុង .................................................. | 10 $ U.S.A |
| លោកយាយ ភួង សឿន .................................... | 5 $ U.S.A |
| សែម មុីញឹប .............................................. | 5 $ U.S.A |
| ឧបាសិកា មឿង ញ៉ិល ........................................ | 5 $ U.S.A |
| គឹម ស៊ា .............................................. | 5 $ U.S.A |

**ពុទ្ធបរិស័ទវត្តពន្លឺពុទ្ធចក្រ រដ្ឋមាសាជូសេត សហរដ្ឋអាមេរិក**

**តាមរយះ  ព្រះភិក្ខុធម្មប្បញ្ញោ ឆ្នំ សាវឿន**



| | |
|---|---|
| ព្រះភិក្ខុធម្មប្បញ្ញោ ឆ្នំ សាវឿន .............................. | 120 $ U.S.A |
| ឧបាសិកា ពិន សាត .......................................... | 100 $ U.S.A |
| ឧបាសក ចាន់ ម៉ុល ឧបាសិកា ជា សុផា .................. | 100 $ U.S.A |
| ឧបាសក កែម សាគុណ ឧបាសិកា ជា សុភាព ............ | 100 $ U.S.A |
| កែម សុធា និង មាស ចំណាន .............................. | 100 $ U.S.A |
| ឧបាសិកា ម៉ៅ លន់ ព្រមទាំងបុត្ត ............................ | 100 $ U.S.A |
| ឧបាសិកា គីម កក់ និងម្តាយ ស្រេន ង៉ោ ..................... | 100 $ U.S.A |
| ព្រះភិក្ខុ ឈួម បូ និងឧបាសិកា ជី ............................ | 50 $ U.S.A |
| ជា សុផល និង សុំ ឆៃយ៉ាន .................................. | 50 $ U.S.A |
| កែម សុធា និង មាស ចំណាន ................................ | 50 $ U.S.A |
| ឧបាសក ឡាង ឆរី ឧបាសិកា កុក សា វ៉ាង ............... | 50 $ U.S.A |
| ឧបាសក កាន គង់ ឧបាសិកា ជី វ៉ួម ........................ | 50 $ U.S.A |
| ឧបាសិកា ដុះ ឡឿម ............................................ | 50 $ U.S.A |
| ឧបាសិកា កែវ សារិន ឧបាសិកា សុំ អែម និងបុត្ត ........ | 50 $ U.S.A |
| កៅ ចាន់ស៊ូសាណា ............................................ | 50 $ U.S.A |
| ជា សុភ័ណ និង ម៉ាប់ ........................................... | 40 $ U.S.A |
| ជា សុភី និង សារិន ណៃ ..................................... | 30 $ U.S.A |
| នាង លីន ពិសី ................................................ | 30 $ U.S.A |
| ឧបាសក យុន ឈួរ ឧបាសិកា ម៉ូវ ឈាវក្លួយ ............. | 30 $ U.S.A |
| ឧបាសក ចាន់ សួន ឧបាសិកា តែង អន .................. | 30 $ U.S.A |
| ឧបាសិកា ហៀ ណន ............................................. | 20 $ U.S.A |
| ឧបាសិកា ចាំង យុនថេង និងបុត្ត ............................ | 20 $ U.S.A |
| ឡាច ម៉ាឡៃ .................................................... | 20 $ U.S.A |
| ព្រំ ហោ ........................................................ | 20 $ U.S.A |
| ឧបាសិកា នួន សូនី ............................................. | 20 $ U.S.A |

ឧបាសិកា កាង លាង ............................................ 20 $ U.S.A

ឧបាសិកា សាយ ហេង .......................................... 20 $ U.S.A

តាំង ហួយ និង ស្រីមុំ ............................................ 20 $ U.S.A

ឧបាសិកា ប៉ៃ លិន .................................................. 20 $ U.S.A

មុត សំអុល ព្រមទាំងកូនចៅ ................................. 15 $ U.S.A

ឧបាសិកា ប៊ុន សារុំ ............................................... 15 $ U.S.A

ឧបាសក គង លេង ភរិយា និងបុត្ត .......................... 10 $ U.S.A

ឧបាសក កែវ ណេន និងភរិយា ព្រមទាំងបុត្ត .............. 10 $ U.S.A

ឧបាសិកា ណាំ ..................................................... 10 $ U.S.A

អ៊ុំ បូរិន ......................................................... 10 $ U.S.A

អ៊ុំ បូនី ............................................................. 10 $ U.S.A

ជឹម ណយ ......................................................... 10 $ U.S.A

ឧបាសិកា តាន់ សៀវ ...... .................................... 10 $ U.S.A

និត ភាព និងស្វាមី ព្រមទាងបុត្ត ............................ 10 $ U.S.A

សា ឆៃហេង និងភរិយា ម៉ុង ដណេ និងកូនស្រី .......... 10 $ U.S.A

ចូត គង់ ព្រមទាំងគ្រួសារ និងបុត្ត .......................... 10 $ U.S.A

ច្រឹម ......................................................... 10 $ U.S.A

មីង លាភ ........................................................ 5 $ U.S.A

ប៊ុន ណ្ណារី .......................................................... 5 $ U.S.A

លីន នី ............................................................... 5 $ U.S.A

បេ រ៉ូចម៉េង ......................................................... 5 $ U.S.A

ម៉ន លីណា ......................................................... 5 $ U.S.A

សុគីន ................................................................ 5 $ U.S.A

រ៉ុន ឆា .............................................................. 5 $ U.S.A

កាន់ ណាល ......................................................... 5 $ U.S.A



ជុំ ម៉ាឡា .......................................................... 5 $ U.S.A

សារឿត សរិត .................................................... 5 $ U.S.A

ឧបាសិកា អាង ណារី ........................................... 5 $ U.S.A

ឧបាសិកា ជា ហុង ............................................... 5 $ U.S.A

ឧបាសិកា ទូត ចាន់វណ្ណី ...................................... 5 $ U.S.A

ឧបាសិកា ជំនិត .................................................. 5 $ U.S.A

ជុំ ចានថា ................................................... 5 $ U.S.A

លីនដា ...................................................... 5 $ U.S.A

មីង ឃីម ........................................................ 2 $ U.S.A

គីម ហួ ............................................................ 2 $ U.S.A

សថា ............................................................... 2 $ U.S.A

វណ្ណា .............................................................. 2 $ U.S.A

ហ៊ុន ថា ............................................................ 2 $ U.S.A

ស៊ីមឿង ........................................................... 2 $ U.S.A

